# របត់នយោបាយ

## សីហនុ ~ លន់ នល់ ~ ប៉ុល ពត ~ ជា ស៊ីម ~ ហេង សំរិន ~ ហ៊ុន សែន




ភាគ ៤

(ពីឆ្នាំ ១៩៦៣ ដល់ឆ្នាំ ១៩៦៨)

ឈឹម សេរីតួន

# របត់នយោបាយ

សីហនុ ~ លន់ នល់ ~ ប៉ុល ពត ~ ជា ស៊ីម ~ ហេង សំរិន ~ ហ៊ុន សែន

ភាគ ៤

ហាមថតចម្លង

ស្នាដៃនេះត្រូវបានចុះបញ្ជីលេខ Ⓡ ៦៨៣/២១ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ នៅនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ។

***-សហការីពិនិត្យអក្ខរាវិរុទ្ធ៖***

វេជ្ជបណ្ឌិត អ៊ុន សុវណ្ណា

***-ការីកុំព្យូទ័រ***

ហែម សុធា

ឈឹម មករា

ប៉ោ កុសល

ចាន់ ពិសុទ្ធ

ឈឹម ពុទ្ធី

រក្សាសិទ្ធិ© ឈឹម សេរីភ្ជួន គ.ស.២០២៣

ISBN-13 : 978-9924-969-808

# ឧទ្ទិសកថា

ក្នុងរយៈពេលតែ៩ឆ្នាំប៉ុណ្ណោះ គឺពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩ ដោយសារមនោគមវិជ្ជានយោបាយ និងការជ្រៀតជ្រែកពីសំណាក់ពួកបរទេសផងដែរ ប្រទេសជាតិយើងបានឆ្លងកាត់របត់នយោបាយ ក្លាយជារដ្ឋប្រហារផ្លាស់ប្តូរពីរបបរាជានិយម ទៅជារបបសាធារណរដ្ឋនិយម បង្កឱកាសឱ្យពួកកុម្មុយនិស្តខ្មែរក្រហមបំផុសគំនុំវណ្ណៈធ្វើសង្គ្រាមបដិវត្តន៍ទទួលបានជ័យជម្នះ និងបានបង្កើតរបបថ្មីមួយឡើង គឺកម្ពុជាប្រជាធិបតេយ្យ ដែលគ្មានអ្វី ក្រៅពីអំពើប្រល័យពូជសាសន៍ដ៏មហាឃោរឃៅព្រៃផ្សៃបំផុតនោះឡើយ។

ក្រោយថ្ងៃទី៧ ខែមករា ១៩៧៩ ប្រជាជាតិយើងបានរួចផុតពីរបបប្រល័យពូជសាសន៍ក៏ពិតមែន តែសង្គ្រាមបង្ហូរឈាមខ្មែរគ្នាឯង នៅតែបន្តឆាបឆេះ រហូតដល់ឆ្នាំ១៩៩៨ ទើបទទួលបានសុខសន្តិភាពពេញលេញ។

ប្រាកដណាស់ ប្រជាជាតិយើងប្រាកដជាមិនចង់ដើរជាន់ដានប្រវត្តិសាស្ត្រគួរឲ្យឈឺចាប់វេទនាខ្លោចផ្សារនេះជាថ្មីម្តងទៀតឡើយ ពោលគឺប្រជាជាតិយើងគ្មានប្រាថ្នាអ្វី ក្រៅពីសុខសន្តិភាពនោះទេ។

ដូច្នេះ សូមអ្នកនយោបាយខ្មែរគ្រប់និន្នាការទាំងអស់ ទាំងជំនាន់នេះ និងជំនាន់ក្រោយៗទៀត មេត្តាបោះបង់ចោលនូវមហិច្ឆតាដណ្តើមអំណាចគ្នា បង្កជាជម្លោះបែកបាក់ធ្វើឱ្យសង្គមជាតិយើងធ្លាក់ចូលទៅក្នុងភ្លើងសង្គ្រាមបង្ហូរឈាមខ្មែរគ្នាឯង ដូចសម័យមុនៗទៀតទៅ។

សង្គមជាតិមួយ ដែលមានតែជម្លោះបែកបាក់មិនឈប់ឈរនោះ លទ្ធផល គឺគ្មានអ្វីក្រៅពីការបង្កើតឱ្យមានចលាចល វឹកវរ បង្កអសន្តិសុខ និងការបង្ហូរឈាមខ្មែរគ្នាឯងនោះឡើយ។

សូមឧទ្ទិសបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ជួយតាមថែរក្សាប្រជាជាតិមាតុភូមិខ្មែរ ឱ្យមានសុខសន្តិភាពជារៀងរហូត ដើម្បីប្រជាពលរដ្ឋរស់នៅដោយសុខសាន្តត្រាណមានសុភមង្គល និងមានឱកាសកសាងអភិវឌ្ឍប្រទេសឲ្យបានរីកចម្រើនថ្កុំថ្កើងរុងរឿង ដូចបច្ចុប្បន្ននេះ ជារៀងរហូត...។

ថ្ងៃចន្ទ ១៤រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣

**ឈឹម សេរីឥន្ទ្រ**

# អារម្ភកថា

ឯកសារប្រវត្តិសាស្ត្រ ដែលមានចំណងជើងថា **របត់នយោបាយ** (**សីហនុ-លន់ នល់-ប៉ុល ពត-ហ៊ុន សែន**) នេះ បានបោះពុម្ពជាសៀវភៅ តាំងពីភាគ១, ភាគ២ និងភាគ៣ រួចមកហើយ ដោយបានរំលេចនាមឥស្សរជនជាអ្នកនយោបាយខ្មែរតែ៤រូបប៉ុណ្ណោះ គឺៈ **សីហនុ - លន់ នល់ - ប៉ុល ពត - ហ៊ុន សែន។** ប៉ុន្តែ នៅពេលបោះពុម្ពជាសៀវភៅភាគ៤ នេះ ខ្ញុំបាទជាអ្នកសិក្សាស្រាវជ្រាវ បានរំលេចនាមសម្តេច ជា ស៊ីម និងសម្តេច ហេង សំរិន នៅលើចំណងជើងតូចបន្ថែមទៀត គឺៈ **សីហនុ - លន់ នល់ - ប៉ុល ពត - ជា ស៊ីម - ហេង សំរិន - ហ៊ុន សែន។**

គោលបំណង និងមូលហេតុ ដែលខ្ញុំបាទរំលេចនាម **សម្តេច ជា ស៊ីម** និង **សម្តេច ហេង សំរិន** បន្ថែមទៀត នៅលើចំណងជើងតូចនេះ គឺដោយសារឥស្សរជនជាអ្នកនយោបាយខ្មែរ២រូបនេះ មានតួនាទីសំខាន់បំផុតក្នុងការរួមចំណែកដឹកនាំចលនាតស៊ូប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យប្រល័យពូជសាសន៍ បង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នាថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ រហូតបានទទួលជ័យជម្នះថ្ងៃទី៧ ខែមករា ដឹកនាំប្រទេស តាំងពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (របបកុម្មុយនិស្ត) ពីឆ្នាំ១៩៧៩-១៩៨៩ និងរបបរដ្ឋកម្ពុជា (របបកុម្មុយនិស្តពាក់កណ្តាល និងសេរីពាក់កណ្តាល) ពីឆ្នាំ១៩៨៩-១៩៩៣ រហូតដល់របបប្រជាធិបតេយ្យសេរីពហុបក្ស ជាព្រះរាជាណាចក្រកម្ពុជាទី២ ពីឆ្នាំ១៩៩៣ មកដល់ពេលបច្ចុប្បន្ននេះ។

ដូច្នេះសួរថា ហេតុអ្វីបានជា **សម្តេចជា ស៊ីម**, **សម្តេចហេង សំរិន** និង **សម្តេចហ៊ុន សែន** ព្រមទាំង **សម្តេច ស ខេង** ផងដែរ សុទ្ធតែប្រសូតចេញពីវណ្ណៈកសិករក្រីក្រ ចេះរួបរួមសាមគ្គីគ្នាទទួលបានជោគជ័យក្នុងការកាន់អំណាច តាំងពីឆ្នាំ១៩៧៩ និងនៅតែរឹងមាំរហូតដល់សព្វថ្ងៃ ខណៈសម្តេចសីហនុ ដឹកនាំរបបសង្គមរាស្ត្រនិយម កាន់អំណាចបានត្រឹម១៥ឆ្នាំ, លន់ នល់ ដឹកនាំរបបសាធារណរដ្ឋខ្មែរកាន់អំណាចបានត្រឹមតែ

ជាង៥ឆ្នាំ និងប៉ុល ពត ដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យកាន់អំណាច បានត្រឹមតែជិត៤ឆ្នាំប៉ុណ្ណោះ ?

ខ្ញុំបាទនឹងធ្វើការសិក្សាស្រាវជ្រាវពីបញ្ហានេះជូនប្រិយមិត្តអ្នកអានជ្រាប ស្របតាមកាលៈទេសៈព្រឹត្តិការណ៍ ដែលកើតមានឡើងជាក់ស្តែង។

ក្នុងឱកាសនេះដែរ ខ្ញុំបាទសូមលំអោនកាយគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដែលបានជួយឧបត្ថម្ភគាំទ្រទាំងស្រុងក្នុងការបោះពុម្ពសៀវភៅ**ចេតនយោបាយ** នេះតាំងពីភាគ១ រហូតដល់ភាគ៤ ដើម្បីទុកជាឯកសារប្រវត្តិសាស្ត្រសំខាន់មួយសម្រាប់កូនខ្មែរ ជំនាន់ក្រោយៗទៀត។

បើគ្មានការជួយឧបត្ថម្ភគាំទ្រពី **សម្តេចក្រឡាហោម** ទេនោះ ក៏គ្មានវត្តមានសៀវភៅប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់នេះដែរ។

ប្រសិនបើមានការខ្វះខាតខុសឆ្គងលើសលោះត្រង់ចំណុចណាមួយ សូមសម្តេចទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់មេត្តាខន្តីអភ័យទោស ដោយក្តីអនុគ្រោះ។

ថ្ងៃចន្ទ ១៤រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣

**ឈឹម សេរីភ្នួន**

# មាតិកា

●១៥១ ង៉ូ ឌិញយៀម បញ្ជាឱ្យកងទ័ពពិសេស ចេញបង្ក្រាបពុទ្ធសាសនិក១៥.០០០នាក់ ..1
●១៥២ រដ្ឋប្រហារទម្លាក់ប្រធានាធិបតី ង៉ូ ឌិញ យៀម ......................................9
●១៥៣ ង៉ូ ឌិញយៀម និងង៉ូ ឌិញញូ ត្រូវបានគេចាក់នឹងកាំបិត រួចបាញ់សម្លាប់ .......15
●១៥៤ អ្វីទៅដែលហៅថា សង្គ្រាមត្រជាក់? ......................................................21
●១៥៥ អាមេរិក បង្កើតអង្គការណាតូ សូវៀត បង្កើតអង្គការវ៉ាសូវី....................... 25
●១៥៦ សង្គ្រាមនៅឧបទ្វីបកូរ៉េ ...........................................................................31
●១៥៧ គុយបា នៅក្បែរក្បៀកអាមេរិក ក្លាយជាប្រទេសកុម្មុយនិស្ត ....................... 34
●១៥៨ សម្ព័ន្ធភាព និងការបែកបាក់គ្នារវាងសូវៀត និងចិន ..................................39
●១៥៩ អ្វីទៅដែលហៅថា វៀតមិញ? ............................................................ 43
●១៦០ សង្គ្រាមឥណ្ឌូចិនលើកទី១ ......................................................................49
●១៦១ អ្វីទៅដែលហៅថា វៀតកុង? ............................................................ 60
●១៦២ ការកាត់ទោសប្រហារជីវិតខ្មែរសេរី ឈ្មោះ ព្រាប អ៊ិន ..................................72
●១៦៣ អាមេរិក យួនខាងត្បូង និងថៃ ជួយបង្កើតចលនាខ្មែរសេរី ម្តងទៀត ............79
●១៦៤ កងទ័ពខ្មែរសេរី ស្ទាក់វាយទាហានរាជរដ្ឋាភិបាល ......................................87
●១៦៥ សម្តេចសីហនុ ទាត់ចោលជំនួយអាមេរិក ទទួលជំនួយចិន និងសូវៀត.........92
●១៦៦ ប្រធានាធិបតី ចន អែហ្វ. កេណ្ណឌី ត្រូវឃាតករបាញ់សម្លាប់ ......................98
●១៦៧ សិស្សនិស្សិតមន្ត្រីរាជការ ធ្វើបាតុកម្មបណ្តេញទូតអាមេរិក ......................104
●១៦៨ កងទ័ពវៀតណាមខាងត្បូង ចូលមកបាញ់សម្លាប់ប្រជារាស្ត្រខ្មែរ នៅភូមិចន្ទ្រា .. 111
●១៦៩ ទំនាក់ទំនងការទូតកម្ពុជា-អាមេរិក កាន់តែធ្លាក់ដុនដាប ........................120
●១៧០ ចិន ជួយវៀតណាមខាងជើង អាមេរិក ជួយវៀតណាមខាងត្បូង...............126
●១៧១ ចិនប្រកាសផ្តល់ជំនួយយោធា និងជួយការពារកម្ពុជា ..........................134
●១៧២ សម្តេចសីហនុ ចរចាបញ្ហាព្រំដែន ជាមួយវៀតណាមខាងជើង ................ 141
●១៧៣ សម្តេចសីហនុ ធ្វើជាតូបនីយកម្ម ដើម្បីកែទម្រង់សេដ្ឋកិច្ច.......................148

●១៧៤ សម្តេចសីហនុ អញ្ជើញតំណាងវៀតកុង
មកចូលរួមសន្និសីទប្រជាជនឥណ្ឌូចិន នៅភ្នំពេញ .............................. 151
●១៧៥ សម្តេចសីហនុ សុំឲ្យមានសន្និសីទអន្តរជាតិមួយ
ដើម្បីរកដំណោះស្រាយបញ្ហាកម្ពុជា ................................................ 156
●១៧៦ បាតុកម្មវាយស្ថានទូតអាមេរិកលើកទី២ ........................................ 162
●១៧៧ សាឡុត ស និងអៀង សារី រត់ចូលព្រៃតស៊ូ ........................................ 167
●១៧៨ សាឡុត ស ធ្វើដំណើរទៅក្រុងហាណូយ ........................................ 173
●១៧៩ សាឡុត ស ទៅបំពេញទស្សនកិច្ច នៅសាធារណរដ្ឋប្រជាមានិតចិន ......... 180
●១៨០ សម្តេចសីហនុ សរសើរចិន រិះគន់សហភាពសូវៀត ................................ 185
●១៨១ ចិនថា បើអាមេរិក ចូលឈ្លានពាន កងទ័ពលន់ នល់
មិនអាចទប់ទល់បានទេ ........................................................ 192
●១៨២ សាឡុត ស ប្តូរឈ្មោះបក្សពលករកម្ពុជា ទៅជាបក្សកុម្មុយនិស្តកម្ពុជា........ 196
●១៨៣ បដិវត្តន៍វប្បធម៌ នៅប្រទេសចិនកុម្មុយនិស្ត ........................................ 202
●១៨៤ ប្រពន្ធកូន សម សារី ត្រូវបង្ខំឲ្យចាកចេញពីមាតុប្រទេស ........................ 218
●១៨៥ កូនៗ និងប្រពន្ធ សម សារី សង្ឃឹមបានជួបឪពុក និងប្តី
ហេតុអ្វី ជួបតែ សឹង ង៉ុកថាញ់? ................................................ 226
●១៨៦ មហាសេដ្ឋី សុង សាក់ ជានរណា? ................................................ 234
●១៨៧ សម រង្ស៊ី ដូរត្រកូល សម ទៅជាត្រកូល ង្វៀន ........................................ 239
●១៨៨ សម្តេចសីហនុ ថា៖ (ហ៊ូ យន់) ឈ្មោះ យន់ ស្រដៀងយួន........................ 245
●១៨៩ ឧត្តមសេនីយ៍ លន់ នល់ ចុះហត្ថលេខាជាមួយចិន
ជួយដឹកជញ្ជូនអាវុធឱ្យពួកវៀតកុង ................................................ 251
●១៩០ កងទ័ពថៃ បានចូលមកឈ្លានពាន ប្រាសាទព្រះវិហារ ជាថ្មីម្តងទៀត........ 257
●១៩១ នរណាជាអ្នកឲ្យឈ្មោះខ្មែរកុម្មុយនិស្តថា ខ្មែរក្រហម?............................ 267
●១៩២ ការប្រហារជីវិតខ្មែរសេរី ឈ្មោះ សៅ ង៉ុយ ........................................ 274
●១៩៣ កសិករនៅស្រុកសំឡូត នាំគ្នាបះបោរប្រឆាំងនឹង លន់ នល់........................ 279
●១៩៤ មេដឹកនាំចិន និងវៀតណាម ពិភាក្សាគ្នាពីបញ្ហាប្រទេសកម្ពុជា ................ 288

# ១៥១
# ង៉ូ ឌិញយៀម បញ្ជាឱ្យកងទ័ពពិសេស ចេញបង្ក្រាបពុទ្ធសាសនិក១៥.០០០នាក់



**កងទ័ពពិសេសចេញបង្ក្រាបព្រះសង្ឃ និងពុទ្ធសាសនិក**

នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៦៣ សម្តេចសីហនុ ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា បានផ្ញើព្រះរាជសារមួយជូនប្រធានាធិបតីសហរដ្ឋអាមេរិក ចន អែហ្វ. កេណ្ណឺឌី (John F. Kennedy) ស្នើសុំមេដឹកនាំប្រទេសមហាអំណាចមួយនេះជួយធ្វើអន្តរាគមន៍ទៅមេដឹកនាំកាន់អំណាចផ្តាច់ការនៅវៀតណាមខាងត្បូង ង៉ូ ឌិញយៀម ឱ្យបញ្ឈប់ធ្វើសកម្មភាពបង្ក្រាបសាហាវព្រៃផ្សៃមកលើព្រះសង្ឃពុទ្ធសាសនានៅកម្ពុជាក្រោម តទៅទៀត ព្រោះព្រះសង្ឃទាំងអស់នោះ គ្រាន់តែប្រើសិទ្ធិសេរីភាពធ្វើបាតុកម្មអហិង្សា ដើម្បីការពារថែរក្សាសាសនារបស់ខ្លួនតែប៉ុណ្ណោះ។

៤ថ្ងៃក្រោយមក ប្រធានាធិបតី ចន អែហ្វ. កេណ្ណឺឌី (John F. Kennedy) ក៏បាន

ធ្វើសារឆ្លើយតបព្រះអង្គវិញដែរ តែមិនបានបញ្ជាក់ពីវិធានការណាមួយក្នុងការដោះស្រាយបញ្ហានេះទេ។ ជាមួយគ្នានេះ ប្រធានាធិបតី ចន អែហ្វ. កេណ្ណឺឌី បានចាត់ឱ្យមន្ត្រីក្រសួងការបរទេសម្នាក់ឈ្មោះ ហង់រី កាបូត ឡូដ ( Henry Cabot Lodge ) ឱ្យមកធ្វើឯកអគ្គរដ្ឋទូតអាមេរិកថ្មី នៅទីក្រុងព្រៃនគរ( សៃហ្គន )ដើម្បីពិនិត្យមើលបញ្ហានេះ និងមកជួយដាស់តឿនកែលម្អប្រធានាធិបតី ង៉ូ ឌិញ យៀម ដែលល្បីថា ជាមេដឹកនាំផ្តាច់ការ ពុករលួយ និងគ្រួសារនិយមនោះ ឱ្យកែខ្លួនបានល្អត្រឹមត្រូវឡើងវិញ។

ពេលទៅដល់ប្រទេសវៀតណាមខាងត្បូង ឯកអគ្គរដ្ឋទូតថ្មី របស់សហរដ្ឋអាមេរិក ហង់រី កាបូត ឡូដ ( Henry Cabot Lodge ) បានស្នើសុំឱ្យ ង៉ូ ឌិញញូ ជាប្អូនរបស់ប្រធានា-ធិបតី ង៉ូ ឌិញ យៀម ដែលជាមនុស្សមានពិសពុលបំផុតនោះ ដកខ្លួនចេញពីតំណែងជាទីប្រឹក្សាប្រធានាធិបតី។ តែត្រកូល ង៉ូ នេះ មិនព្រមធ្វើតាមបំណងរបស់អ្នកការទូតអាមេរិករូបនេះទេ។

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៦៣ ដោយបានទទួលជំនួយពីសហរដ្ឋអាមេរិក និងប្រទេសវៀតណាមខាងត្បូង ព្រមទាំងប្រទេសថៃ ផងនោះ ចលនាតស៊ូខ្មែរសេរី របស់ សឺង ង៉ុកថាញ់ ចាប់ផ្តើមផ្សព្វផ្សាយ គោលនយោបាយរបស់ខ្លួន និងធ្វើការវាយប្រហារមកលើសម្តេចសីហនុ តាមរលកវិទ្យុផ្សាយសំឡេងរបស់ខ្លួន ដែលមានទីតាំងនៅលើទឹកដីនៃប្រទេសជិត- ខាងទាំងពីរនេះ។

នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៦៣ ដោយសារមេដឹកនាំវៀតណាមខាងត្បូង នៅតែបន្តការធ្វើទុកបុកម្នេញទៅលើព្រះ សង្ឃពុទ្ធសាសនានៅកម្ពុជាក្រោម ព្រមទាំងចេះតែបន្តការរំលោភឈ្លានពានមក លើបូរណភាពទឹកដីខ្មែរទៀតនោះ ពិសេសគាំទ្រចលនាតស៊ូខ្មែរសេរីរបស់ សឺង ង៉ុកថាញ់ ផងដែរ សម្តេចសីហនុ ក៏សម្រេចប្រកាសផ្តាច់ទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាម ខាងត្បូង និងប្រទេសថៃ តែម្តងទៅ។

នៅចុងខែសីហា ឆ្នាំ១៩៦៣ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ហ្វ្រឺដឺរិក ណូលទីង ( Frederick Nolting ) ដែលជាមិត្តជិតស្និទ្ធបំផុតជាមួយប្រធានាធិបតី ង៉ូ ឌិញយៀម ត្រូវ



**អ្នកកាសែតអាមេរិកទាំង២នាក់ត្រូវឃាត់ខ្លួន**(រូបថត New York Times)

បានផ្លាស់ចេញ ហើយឯកអគ្គរដ្ឋទូតថ្មី ហង់រី កាបូត ឡដ(Henry Cabot Lodge) ត្រូវមកជំនួសវិញ។

នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៦៣ ជាខួបទី៩ឆ្នាំនៃការឡើងកាន់អំណាចរបស់ប្រធា - នាធិបតី ង៉ូ ឌិញយៀម នោះ ប៉ូលិសសម្ងាត់របស់គាត់បានវាយតប់ទៅលើក្រុមអ្នកកាសែតមកពីសហរដ្ឋអាមេរិក ដែលកំពុងចុះយកព័ត៌មាន អំពីសកម្មភាពតវ៉ារបស់ក្រុមបាតុករជាពុទ្ធសាសនិក ។

ភីទ័រ អានេត្ត (Peter Arnett) អ្នកឆ្លើយឆ្លងព័ត៌មានមកពីកាសែតអេភី(AP= Associated Press) ត្រូវបានប៉ូលិសសម្ងាត់របស់ ង៉ូ ឌិញយៀម ដាល់គាត់ត្រូវចំច្រមុះ ។ ភ្លាមនោះមានអ្នកកាសែតអាមេរិកម្នាក់ទៀតឈ្មោះ ដាវីដ ហាលបឺស្តាំ(David Halberstam)អ្នកឆ្លើយឆ្លងព័ត៌មានមកពីកាសែតញូវយ៉កថាមស៍(New York Times )ដែលមានកម្ពស់ខ្ពស់ ជួយអន្តរាគមន៍វាយតបតទៅប៉ូលិសសម្ងាត់នោះឱ្យដកថយវិញ។



**ឯកអគ្គរដ្ឋទូតហង់រី កាបូត ឡូដ និងប្រធានាធិបតី ង៉ូ ឌិញយៀម**(រូបថត LIFE)

ក្រោយមក អ្នកកាសែតអាមេរិក ទាំង២នាក់នេះ ត្រូវបានកម្លាំងសមត្ថកិច្ចប៉ូលិសចោទថា បានវាយដំទៅលើមន្ត្រីប៉ូលិស ហើយបាននាំយកទៅឃុំខ្លួននៅការិយាល័យ ដើម្បីសាកសួរ។ តែបន្ទាប់ពីមានការអន្តរាគមន៍ពីស្ថានទូតសហរដ្ឋអាមេរិក អ្នកកាសែតទាំង ២ នាក់នេះ ត្រូវបានដោះលែងវិញ។

នៅព្រឹកថ្ងៃអាទិត្យ ទី១៨ ខែសីហា ពុទ្ធសាសនិកចាប់ផ្ដើមនាំគ្នាធ្វើបាតុកម្មទ្រង់ទ្រាយធំនៅវត្តសាឡឺយ (Xá Lợi) ជាវត្តដ៏ធំបំផុតរបស់ទីក្រុង សៃហ្គន ដោយមានមនុស្សចូលរួមប្រហែល១៥.០០០នាក់ គឺច្រើនជាងបីដង នៃការជួបជុំពុទ្ធសាសនិកធ្វើបាតុកម្មប្រឆាំងនឹងប្រធានាធិបតី ង៉ូ ឌិញយៀម កាលពីអាទិត្យមុន។ នេះជាធ្វើបាតុកម្មមានរយៈពេលយូរ និងមានទ្រង់ទ្រាយធំបំផុតនៅវៀតណាម ខាងត្បូង ចាប់តាំងពីការឡើងកាន់អំណាចរបស់ ង៉ូ ឌិញយៀម ជិតមួយទសវត្សរ៍មកនេះ។ ក្រុមបាតុករ ក៏មានបំណងដង្ហែក្បួនឆ្ពោះទៅកាន់វិមានយ៉ាឡុង (Gia Long) ដែលជានិវេសនដ្ឋានរបស់ប្រធានាធិបតី ង៉ូ ឌិញយៀម ផង

ដែរ។ ចំណែកនៅតាមវត្តផ្សេងៗទៀតទូទាំងប្រទេស ក៏មានព្រះសង្ឃ និងពុទ្ធសាសនិកនាំគ្នាមក ជួបជុំធ្វើបាតុកម្មដែរ គ្រាន់តែមិនមាន ទ្រង់ទ្រាយធំដូចនៅវត្តសាឡើយ (Xá Lợi) នៅទីក្រុងសៃហ្គន នោះទេ។

រយៈពេលតែ២ថ្ងៃប៉ុណ្ណោះ បាតុកម្មកាន់តែឡើងកម្តៅពុះកញ្ជ្រោល។ នៅថ្ងៃទី២០ ខែសីហា ង៉ូ ឌិញញូ ជាទីប្រឹក្សា និងជាប្អូនប្រធានាធិបតី ង៉ូ ឌិញយៀម បានកោះហៅឧត្តមសេនីយ៍ ជាមេទ័ពកំពូលៗចំនួន៧នាក់ ឲ្យទៅកាន់វិមានយ៉ាឡុង ដើម្បីពិគ្រោះយោបល់គ្នាពីបញ្ហាប្រើច្បាប់អាជ្ញាសឹក និងការបំបែកហ្វូងបាតុករ។ បន្ទាប់មក ង៉ូ ឌិញញូ បានឱ្យឧត្តមសេនីយ៍ជាមេទ័ពកំពូលៗ ទាំង៧នាក់ ដឹកនាំដោយឧត្តមសេនីយ៍ ចឹន វ៉ាន់ដុង (Trần Văn Đôn) ទៅជួបរាយការណ៍ឱ្យប្រធានាធិបតី ង៉ូ ឌិញយៀម ជាបន្តទៀត ។



**ឧត្តមសេនីយ៍ឯក ចឹន វ៉ាន់ដុង**
(រូបថត LIFE)

ឧត្តមសេនីយ៍ ចឹន វ៉ាន់ដុង(Trần Văn Đôn) បានរាយការណ៍ប្រាប់ ង៉ូ ឌិញយៀម ថា ពួកកុម្មុយនិស្តវៀតកុង ជាច្រើនបានជ្រៀតចូលធ្វើសកម្មភាពជាមួយព្រះសង្ឃនៅក្នុងវត្តសាឡើយ(Xá Lợi) ដូច្នេះមិនត្រូវឱ្យពួកគេដង្ហែក្បួនមកកាន់វិមានយ៉ាឡុង(Gia Long) នេះជាដាច់ខាត។ យើងត្រូវតែប្រើច្បាប់អាជ្ញាសឹក ទើបអាចទប់ទល់ជាមួយពួកគេបាន។

ព្ធដូច្នេះ ង៉ូ ឌិញយៀម បានយល់ព្រមប្រកាសឱ្យប្រើច្បាប់អាជ្ញាសឹក ហើយនៅថ្ងៃបន្ទាប់ កងទ័ពជាច្រើនអង្គភាព ត្រូវបានបញ្ជាឱ្យចូលក្នុងទីក្រុងសៃហ្គន ដើម្បីកាន់កាប់ចំណុចយុទ្ធសាស្ត្រមួយចំនួន។ ឧត្តមសេនីយ៍ ចឹន វ៉ាន់ដុង(Trần Văn Đôn) ត្រូវបានតែងតាំងជា

## របត់នយោបាយ



**ឧត្តមសេនីយ៍ឯក ឡេ វ៉ាន់ទី**
(រូបថត flickr)



**វរសេនីយ៍ឯកឡេ ក្វាងទុង**
(រូបថត flickr)

អគ្គមេបញ្ជាការស្តីទី នៃកងទ័ពវៀតណាមខាងត្បូង ជំនួសលោកឧត្តម សេនីយ៍ ឡេ វ៉ាន់ទី (Lê Văn Tỵ) ដែល បានចាកចេញទៅក្រៅប្រទេស ដើម្បីព្យាបាលជំងឺ។

វេលាជិតពាក់ កណ្តាលអធ្រាត្រថ្ងៃទី២១ ខែសីហា ង៉ូ ឌិញញូ បានបញ្ជាឱ្យកងទ័ពពិសេស ក្រោមការដឹកនាំរបស់វរសេនីយ៍ឯក ឡេ ក្វាងទុង (Lê Quang Tung) បើកយុទ្ធនាការបង្ក្រាបបាតុករ នៅវត្តពុទ្ធសាសនានោះជាបន្តបន្ទាប់ ពិសេសគឺបង្ក្រាបបាតុករនៅវត្តសាឡឿយ (Xá Lợi) ជាកន្លែងប្រមូលផ្តុំធ្វើបាតុកម្មធំជាងគេនោះ មានសភាពសាហាវឃោរឃៅបំផុត។

កងទ័ពរដ្ឋការ ង៉ូ ឌិញយៀម បានវាយបំផ្លិចបំផ្លាញអាសនៈធំមួយមានតាំងរូបថតព្រះសង្ឃព្រះនាម ធិច ក្វាងឌឹក (Thích Quảng Đức) ពេលបូជាព្រះកាយក្នុងអណ្តាតភ្លើង កំពុងឆាបឆេះយ៉ាងសន្ធោសន្ធៅ ដើម្បីតវ៉ាប្រឆាំងនឹងគោលនយោបាយរើសអើងពុទ្ធសាសនា របស់ប្រធានាធិបតី ង៉ូ ឌិញយៀម នេះទៀតផង។

ដោយមិនអាចទប់ទល់ជាមួយនឹងកងទ័ពពិសេសដ៏កំណាចឃោរឃៅនោះបាន ព្រះ-សង្ឃនិងពុទ្ធសាសនិក បានបង្ខំចិត្តនាំគ្នាគេចខ្លួនចេញពីវត្ត។ ព្រះសង្ឃ២អង្គ បានលោតតាមរបងខាងក្រោយវត្ត ចូលទៅក្នុងបរិវេណការិយាល័យបេសកកម្មជំនួយសហរដ្ឋអាមេរិក ដែលនៅជាប់គ្នារបងវត្តនោះ ដើម្បីគេចពីការចាប់ខ្លួន។ ព្រះសង្ឃ និងពុទ្ធសាសនិកជាង ១៤០០អង្គ/នាក់ ត្រូវបានចាប់ខ្លួន ក្នុងនោះ ព្រះតេជគុណ ធិច ទីញខៀត (Thích Tịnh Khiết) ប្រមុខសង្ឃពុទ្ធសាសនានិកាយមហាយានមានព្រះជន្ម៧៤វស្សា ត្រូវបញ្ជូនទៅបន្ទាយយោធាមួយនៅជាយក្រុងសៃហ្គន ខណៈព្រះសង្ឃនិងពុទ្ធសាសនិករាប់រយអង្គ/នាក់ទៀត ត្រូវស្លាប់ និងបាត់ខ្លួន។



**ឧត្តមសេនីយ៍ត្រី តូន ថឹតឌីញ**
(រូបថត LIFE)

ឧត្តមសេនីយ៍ តូន ថឹតឌីញ (Tôn Thất Đính) មេបញ្ជាការនៃកងអង្គរក្សរបស់ប្រធា-នាធិបតី ង៉ូ ឌិញយៀម បានប្រកាសថា ពេលនេះក្រុងសៃហ្គន ត្រូវគ្រប់គ្រងដោយកងទ័ព ហើយលុបចោលជើងហោះហើរពាណិជ្ជកម្មទាំងអស់ និងបង្កើតការត្រួតពិនិត្យសារព័ត៌មានផងដែរ។

ក្រោយពីមានការបង្ក្រាបយ៉ាងសាហាវព្រៃផ្សៃនោះមក រដ្ឋាភិបាលសហរដ្ឋអាមេរិក បានសម្តែងការមិនពេញចិត្តចំពោះប្រធានាធិបតី ង៉ូ ឌិញយៀម ដែលបានប្រើកងកម្លាំងពិសេសដែលពួកសេអ៊ីអា (CIA) សហរដ្ឋអាមេរិក ជាអ្នកជួយផ្តល់មូលនិធិ និងបណ្តុះបណ្តាលនោះ ឱ្យទៅបង្ក្រាបបាតុករក្នុងវិបត្តិសាសនានោះ ហើយនេះក៏ជាការបង្ហាញពីបរាជ័យ នៃបេសកកម្មរបស់ ហង់រី កាបូត ឡូជ (Henry Cabot Lodge ) ដែលទើបមកទទួលតំណែង

ជាឯកអគ្គរដ្ឋទូតថ្មីរបស់សហរដ្ឋអាមេរិក នៅប្រទេសវៀតណាមខាងត្បូង នោះផងដែរ។

នៅថ្ងៃទី២៤ ខែសីហា រដ្ឋបាលប្រធានាធិបតី ចន អែហ្វ. កេណ្ណឺឌី ( John F. Kennedy ) បានបញ្ជូនសារទូរលេខសម្ងាត់មួយទៅឯកអគ្គរដ្ឋទូត ហង់រី កាបូត ឡជ នៅទីក្រុងសៃហ្គន ឱ្យដាក់សម្ពាធ ធ្វើយ៉ាងណាឱ្យ ង៉ូ ឌិញយៀម ចុះចេញពីអំណាច រកមើលដឹកនាំថ្មីមកដាក់ជំនួស។ តែ ង៉ូ ឌិញយៀម មិនព្រមជាដាច់ខាត។

ជាមួយគ្នានោះ វិទ្យុផ្សាយសំឡេងអាមេរិក ក៏បានចាក់ផ្សាយនូវសេចក្តីថ្លែងការណ៍ស្តីបន្ទោស ង៉ូ ឌិញយៀម ចំពោះការប្រើកងកម្លាំងពិសេសឱ្យទៅវាយបង្ក្រាបបាតុករ និងស្តីបន្ទោសពីការបញ្ជាកងទ័ពខុសពីតួនាទីភារកិច្ចដែលពួកគេត្រូវបំពេញផងដែរ។

# ១៥២
# រដ្ឋប្រហារទម្លាក់ប្រធានាធិបតី ង៉ូ ឌិញ យៀម



**កងទ័ពរដ្ឋប្រហារចូលកាន់កាប់វិមានជុកឡាប់** (រូបថត wikimedia)

នៅដើមឆ្នាំ១៩៦០ សកម្មភាពប្រឆាំងនឹងការដឹកនាំបែបផ្តាច់ការ និងគ្រួសារនិយម របស់ប្រធានាធិបតី ង៉ូ ឌិញយៀម និងទីប្រឹក្សាឈ្មោះ ង៉ូ ឌិញញូ ជាប្អូនប្រុសគាត់ បានចាប់ផ្តើមកើតមានឡើង។ ពួកមន្ត្រីយោធាជាន់ខ្ពស់មួយចំនួនមិនពេញចិត្តចំពោះប្រធានាធិបតី ង៉ូ ឌិញយៀម និងទីប្រឹក្សា ង៉ូ ឌិញញូ ដែលចេះតែលាក់បាំងក្នុងការតម្លើងបុណ្យស័ក្តិដល់មន្ត្រីដែលមិនមែនជាសមាជិកនៃគណបក្សគឹនឡាវ( Cần Lao )របស់ពួកគេ ខណៈពួកមន្ត្រីដែលស្មោះត្រង់នឹងគណបក្សពិតប្រាកដ គ្រួសារត្រកូលង៉ូ នេះ មើលមិនឃើញ ឡើយ។

វរសេនីយ៍ឯក ង្វៀន ចាញ់ធិ ( Nguyễn Chánh Thi ) បានបញ្ចុះបញ្ចូលវរសេនីយ៍ទោ យឿង វ៉ាន់ដុង (Vương Văn Đông) ឱ្យចូលរួមក្នុងផែនការធ្វើរដ្ឋប្រហារផ្តួលរម្លំប្រធានា-ធិបតី ង៉ូ ឌិញយៀម។ ដោយសារវរសេនីយ៍ទោ យឿង វ៉ាន់ដុង គាំទ្រគំនិតរបស់វរសេនីយ៍ឯក ង្វៀន ចៀវ ហុង ( Nguyen Trieu Hong )ជាប្អូនថ្លៃរបស់គាត់ ដែលមានពូម្នាក់ជាមន្ត្រីនៅក្នុងគណបក្សប្រឆាំង មានបំណងចង់ផ្តួលរម្លំប្រធានាធិបតី ង៉ូ ឌិញយៀម ដែរនោះ គាត់ក៏



**វរសេនីយ៍ទោ យឿង វ៉ាន់ដុង**
( រូបថតAlchetron )



**វរសេនីយ៍ឯក ង្វៀន ចាញ់ ធិ**
( រូបថតAlchetron )

យល់ព្រមចូលរួមក្នុងផែនការធ្វើរដ្ឋប្រហារនោះភ្លាម។

កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៦០ នៅក្នុងឱកាសហ្វឹកហាត់ដង្ហែក្បួនព្យុហយាត្រា ដើម្បីប្រារព្ធពិធីរម្លឹកខួបថ្ងៃបង្កើតរបបសាធារណរដ្ឋវៀតណាមខាងត្បូងនោះ វរសេនីយ៍ទោ យឿង វ៉ាន់ដុង ( Vương Văn Đông ) និងវរសេនីយ៍ឯក ង្វៀន ចាញ់ធិ ( Nguyễn Chánh Thi ) ជាមនុស្សជំនិតរបស់ប្រធានាធិបតី ង៉ូ ឌិញយៀម និងជាអ្នករៀបចំពិធីព្យុហយាត្រានោះ បានដឹកនាំធ្វើរដ្ឋប្រហារមួយ ដើម្បីផ្តួលរម្លំប្រធានាធិបតី ង៉ូ ឌិញយៀម។

ពេលកងទ័ពរដ្ឋប្រហារ កំពុងវាយប្រយុទ្ធគ្នាជាមួយកងទ័ពដែលស្មោះត្រង់នឹងប្រធា-នាធិបតី ង៉ូ ឌិញយៀម នៅក្នុងវិមានដុកឡាប់ ង៉ូ ឌិញយៀម បានសុំឱ្យបញ្ឈប់ការវាយប្រយុទ្ធគ្នាសិន ដើម្បីចរចាគ្នា ហើយថែមទាំងបានសន្យាជាមួយកងទ័ពរដ្ឋប្រហារធ្វើកំណែទម្រង់មួយចំនួន ដូចជាការដាក់បញ្ចូលមន្ត្រីយោធានៅក្នុងរដ្ឋបាលខេត្តស្រុកទៀតផង។ ពេលនោះ មានជនស៊ីវិលជាច្រើនកុះករដែលមានកំហឹងឈឺចាប់ជាមួយ ង៉ូ ឌិញយៀម ក៏នាំគ្នាព្យាយាមឡើងជញ្ជាំងរបងចូលទៅក្នុងបរិវេណវិមានដុកឡាប់ នោះផងដែរ។ ការពិត ពេលស្នើសុំឱ្យ

បញ្ឈប់ការវាយប្រយុទ្ធគ្នាសិននោះ គឺគ្រាន់ជាល្បិចពន្យារពេលរបស់ប្រធានាធិបតី ង៉ូ ឌិញ យៀម ដើម្បីរង់ចាំកម្លាំងកងពលដែលស្មោះត្រង់នឹងគាត់ មកជួយសង្គ្រោះគាត់តែប៉ុណ្ណោះ។

បន្តិចក្រោយមកកងពលដែលស្មោះត្រង់នឹងគាត់ចំនួន២កងពល គឺកងពលលេខ៥ និងកងពលលេខ៧ ដែលកំពុងវាយប្រយុទ្ធជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើងនៅតំបន់ជនបទ បានបកក្រោយសម្រុកចូលក្នុងទីក្រុងសៃហ្គន មកវាយកម្ទាត់កងទ័ពរដ្ឋប្រហារ និងបង្ក្រាបជនស៊ីវិលជាអ្នកបះបោរ បណ្តាលឱ្យមនុស្សជាង ៤០០នាក់ ភាគច្រើនជាជនស៊ីវិល ត្រូវបានសម្លាប់។ ចំណែកវរសេនីយ៍ទោ យឿង វ៉ាន់ដុង និងវរសេនីយ៍ឯក ង្វៀន ចាញ់ធិ ក៏បានបើកយន្តហោះរត់គេចខ្លួនចូលមកក្នុងប្រទេសកម្ពុជា ដើម្បីសុំសម្តេចសីហនុ ជ្រកកោនខាងនយោបាយ ។

វរសេនីយ៍ទោ យឿង វ៉ាន់ដុង និងវរសេនីយ៍ឯក ង្វៀន ចាញ់ធិ បានមករស់នៅក្នុងប្រទេសកម្ពុជា ពីពេលនោះ រហូតដល់ក្រោយរដ្ឋប្រហារដឹកនាំដោយឧត្តមសេនីយ៍ យឿង វ៉ាន់មិញ ទទួលជោគជ័យ និងសម្លាប់ប្រធានាធិបតី ង៉ូ ឌិញយៀម និងង៉ូ ឌិញញូ ឆ្នាំ១៩៦៣ ទើបពួកគាត់វិលត្រលប់ទៅប្រទេសវៀតណាមខាងត្បូង វិញ។

ប្រធានាធិបតី ង៉ូ ឌិញយៀម បានស្តីបន្ទោសពួកទីប្រឹក្សាសហរដ្ឋអាមេរិក ថាមិនបានជួយធ្វើអន្តរាគមន៍ណាមួយ ដើម្បីជួយសង្គ្រោះគាត់ក្នុងអំឡុងពេលធ្វើរដ្ឋប្រហារនោះទេ ហើយគាត់បានបញ្ជាឱ្យចាប់ខ្លួនមន្ត្រីយោធាជាន់ខ្ពស់១៤នាក់ និងជនស៊ីវិល៣៤នាក់ យកទៅដាក់ពន្ធនាគារ។ មន្ត្រីយោធាជាន់ខ្ពស់ចំនួន៧នាក់ និងជនស៊ីវិល ២នាក់ទៀត ត្រូវបានកាត់ទោសប្រហារជីវិត ដោយកំបាំងមុខ។ ចំណែកមន្ត្រីយោធា និងមន្ត្រី ស៊ីវិលដែលស្មោះត្រង់នឹងគាត់ ត្រូវបានដំឡើងបុណ្យស័ក្តិ។

ទោះបីមានការប៉ុនប៉ងធ្វើរដ្ឋប្រហារយ៉ាងនេះក៏ដោយ ក៏ ង៉ូ ឌិញយៀម នៅតែបន្តសកម្មភាពផ្តាច់ការ និងពុករលួយបន្តទៅទៀត។ មិនត្រឹមតែពុករលួយ កេងប្រវ័ញ្ចប្រាក់ដុល្លារជាជំនួយរបស់សហរដ្ឋអាមេរិក ប៉ុណ្ណោះទេ សូម្បីតែសម្ភារសឹក និងអាវុធយុទ្ធភណ្ឌផ្សេងៗទៀត ក៏ពួកគាត់លួចយកទៅលក់ឱ្យពួកវៀតកុង ដែលជាគូសត្រូវរបស់ពួកគាត់ផងដែរ។



យន្តហោះរបស់អនុសេនីយ៍ទោ ផាម ភូគួក ត្រូវកងការពារអាកាសបាញ់ធ្លាក់




អនុសេនីយត្រី ង្វៀន វ៉ាន់គី បើកយន្តហោះមកសុំចុះចូលជ្រកកោននៅប្រទេសកម្ពុជា

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៦២ អាកាសយានិកកងទ័ពអាកាសសាធារណរដ្ឋវៀតណាម ២រូប គឺអនុសេនីយ៍ត្រី ង្វៀន វ៉ាន់គី (Nguyễn Văn Cử) និងអនុសេនីយ៍ទោ ផាម ភូគួក (Pham Phú Quốc) បានរួមដៃគ្នាបើកយន្តហោះម្នាក់មួយគ្រឿង ទៅទម្លាក់គ្រាប់បែកលើវិមានដុកឡាប់ (Doc Lap) ជានិវេសនដ្ឋានរបស់ប្រធានាធិបតី បំណងកម្ទេច ង៉ូ ឌិញយៀម មេដឹកនាំផ្តាច់ការ និងក្រុមគ្រួសារឱ្យស្លាប់ទាំងពូជតែម្តង។

គ្រាប់បែកមួយគ្រាប់បាន ទម្លុះបន្ទប់មួយនៅខាងលិចជាប់ បន្ទប់ដែល ង៉ូ ឌិញយៀម កំពុងអានសៀវភៅ ប៉ុន្តែ គ្រាប់បែកមួយគ្រាប់នោះមិនផ្ទុះទេ។

ចំណែកគ្រាប់បែកផ្សេងទៀត ផ្ទុះលាន់កក្រើកទីក្រុងសៃហ្គន បណ្តាលឱ្យអ្នកនៅក្នុងវិមានដុកឡាប់ ចំនួន៦នាក់ ត្រូវស្លាប់ និង៣០នាក់ទៀត រងរបួស។ តែគ្រួសារត្រកូល ង៉ូ គ្មាននរណាម្នាក់ រងរបួសធ្ងន់ទេ លើកលែងតែម៉ាដាមញូ (ប្រពន្ធ ង៉ូ ឌិញញូ) ម្នាក់ប៉ុណ្ណោះ រងរបួសស្រាល ។

ដោយសារគ្រាប់បែកមួយគ្រាប់ដែលធ្លាក់នៅក្បែរបន្ទប់គាត់កំពុងអានសៀវភៅនោះមិនផ្ទុះ ប្រធានាធិបតី ង៉ូ ឌិញយៀម បានអួតអាងថា៖ " មកពីព្រះជាម្ចាស់(ព្រះយេស៊ូ)ជួយ



ឧត្តមសេនីយ៍
ង្វៀន វ៉ាន់ធីវ



ឧត្តមសេនីយ៍
យឿង វ៉ាន់មិញ



ឧត្តមសេនីយ៍
ង្វៀន ភាន់គី

ការពារគាត់ ទើបបានជាគ្រាប់បែកមួយគ្រាប់នោះ មិនផ្ទុះ " ។

ពេលនោះ យន្តហោះទម្លាក់គ្រាប់បែករបស់អនុសេនីយ៍ទោ ផាម ភូគួក ត្រូវកងការពារអាកាសរបស់ ង៉ូ ឌិញយៀម បាញ់ធ្លាក់ និងចាប់អនុសេនីយ៍ទោរូបនោះបាន ហើយយកទៅដាក់ពន្ធនាគារ។ ចំណែកអនុសេនីយ៍ត្រី ង្វៀន វ៉ាន់គី បានបើកយន្តហោះគេចខ្លួនចូលមកក្នុងទឹកដីកម្ពុជា ដើម្បីសុំសម្តេចសីហនុ ជ្រកកោនខាងនយោបាយ។

ដោយសារមានការទម្លាក់គ្រាប់បែកនៅថ្ងៃទី២៧ ខែកុម្ភៈនោះ វិមានដុកឡាប់ ត្រូវរងការខូចខាតយ៉ាងដំណំ ដូច្នេះ វិមាននេះត្រូវបានគេជួសជុល និងកែលម្អឡើងវិញ ដើម្បីការពារសុវត្ថិភាពឱ្យបានរឹងមាំជាងពេលមុន។

ក្នុងឱកាសធ្វើការជួសជុលវិមានដុកឡាប់ ឡើងវិញនោះ ង៉ូ ឌិញយៀម និងក្រុមគ្រួសារបានចាកចេញទៅស្នាក់បណ្តោះអាសន្ននៅវិមានយ៉ាឡុង មួយរយៈសិន រង់ចាំទាល់តែវិមានដុកឡាប់ ជួសជុលរួចរាល់ ទើបពួកគេត្រលប់មកស្នាក់នៅវិញ។

នាព្រឹកថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៦៣ នៅកណ្តាលទីក្រុងព្រៃនគរ (សៃហ្គន) ស្នូរកាំភ្លើងគ្រប់ធុនបានផ្ទុះឡើង លាន់សូរកក្រើក ធ្វើឱ្យប្រជាពលរដ្ឋនៅទីក្រុងមួយនេះ មានការភ្ញាក់ផ្អើល និងជ្រួលច្របល់យ៉ាងខ្លាំង។

លុះដល់វេលារសៀលថ្ងៃដដែលនោះ កងទ័ពជើងទឹកនៃរបបក្រុងព្រៃនគរ(សៃហ្គន)

បានចាប់ផ្តើមវាយដណ្តើមកាន់កាប់បញ្ជាការដ្ឋានសម្ងាត់របស់ ង៉ូ ឌិញយៀម។

ឧត្តមសេនីយ៍ ចឹន វ៉ាន់ដុង( Trần Văn Đôn ) ដែលធ្លាប់ជាមនុស្សជំនិតរបស់ប្រធា-នាធិបតី ង៉ូ ឌិញយៀម បានបញ្ជាឱ្យកងទ័ពរបស់គាត់ចាប់ខ្លួនពួកឧត្តមសេនីយ៍ និងវរសេនីយ៍ទាំងឡាយដែលជាបក្ខពួករបស់ ង៉ូ ឌិញយៀម នៅក្នុងបញ្ជាការដ្ឋានសម្ងាត់នោះជាច្រើននាក់។

បន្ទាប់មក កងទ័ពរដ្ឋប្រហារ ក៏បានចូលកាន់កាប់ស្ថានីយវិទ្យុផ្សាយសំឡេង ហើយបានប្រកាសពីសមាសភាពក្រុមប្រឹក្សាបដិវត្តន៍មួយ ដោយមានឧត្តមសេនីយ៍ យឿង វ៉ាន់មិញជាប្រធាន និងមានឧត្តមសេនីយ៍ចំនួន១៤នាក់ ទៀត រួមមាន៖ ឧត្តមសេនីយ៍ ង្វៀន ខាន់, ឧត្តមសេនីយ៍ តូច ចឹតឌីញ, ឧត្តមសេនីយ៍ ចឹន វ៉ាន់ដុង( Trần Văn Đôn ), ឧត្តមសេនីយ៍ឡេ វ៉ាន់គីម, ឧត្តមសេនីយ៍ ង្វៀន វ៉ាន់ធីវ( Nguyễn Văn Thiệu ), ឧត្តមសេនីយ៍ ង្វៀន កាវគី( Nguyễn Cao Kỳ ) និងឧត្តមសេនីយ៍ ឌិញ ជាដើម ព្រមទាំងវរសេនីយ៍ឯកចំនួន១០នាក់ទៀត ជាសមាជិក ដើម្បីធ្វើបដិវត្តន៍ផ្តួលរម្លំមេដឹកនាំផ្តាច់ការ ពុករលួយ ង៉ូ ឌិញយៀម នេះ។

ដំបូង កងទ័ពដែលស្ថិតនៅក្រោមបញ្ជារបស់ឧត្តមសេនីយ៍ ង្វៀន វ៉ាន់ធីវ( Nguyễn Văn Thiệu ) ក៏បានត្រៀមធ្វើការវាយលុកចូលវិមានយ៉ាឡុង ដែលជាកន្លែង ង៉ូ ឌិញយៀម និងក្រុមគ្រួសារទៅស្នាក់នៅបណ្តោះអាសន្ននោះ រួចជាស្រេច។

ពេលនោះ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ហង់រី កាបូត ឡដ ក៏បានប្រាប់ទៅ ង៉ូ ឌិញយៀម ឱ្យបញ្ជាកងទ័ពដែលស្មោះត្រង់នឹងខ្លួនទម្លាក់អាវុធចុះចាញ់ កុំឱ្យតបតជាមួយកងទ័ពរដ្ឋប្រហារ ហើយគាត់បានផ្តល់លទ្ធភាពឱ្យ ង៉ូ ឌិញយៀម និងគ្រួសារខ្លួនគេចខ្លួនទៅក្រៅប្រទេសដែរ តែ ង៉ូ ឌិញយៀម មិនព្រម។

ក្រោយការប្រយុទ្ធគ្នាតាំងពីវេលារសៀលដល់ពាក់កណ្តាលអធ្រាត្រមក កងទ័ពដែលស្មោះត្រង់នឹង ង៉ូ ឌិញយៀម ចេះតែទន់ដៃទៅៗ វរសេនីយ៍ឯក ឌយ ជាមេបញ្ជាការកងអង្គរក្សប្រធានាធិបតី ង៉ូ ឌិញយៀម ក៏ត្រូវគ្រាប់ស្លាប់នៅលើទីលានប្រយុទ្ធ។

# ១៥៣
# ង៉ូ ឌិញយៀម និងង៉ូ ឌិញញូ ត្រូវបានគេចាក់នឹងកាំបិត រួចបាញ់សម្លាប់



**ប្រធានាធិបតី ង៉ូ ឌិញយៀម និងប្អូនប្រុស ង៉ូ ឌិញញូ**

ពេលនោះ ង៉ូ ឌិញយៀម និងង៉ូ ឌិញញូ ទាំងពីរនាក់បងប្អូន ក៏បានគេចខ្លួនពីវិមានយ៉ាឡុង តាមរថយន្ត ដើម្បីទៅកាន់ទីក្រុងចឹឡឹង ហើយបានទៅពួនសំងំក្នុងផ្ទះមិត្តភក្តិ ជាជនជាតិចិនម្នាក់ ដែលជាមន្ត្រីនៅក្នុងគណបក្សគឹនឡាវ (Cần Lao Party) ជាមួយគ្នា។ តែពួកគាត់សំងំមិនសុខ ក៏នាំគ្នារត់ចូលទៅក្នុងព្រះវិហារសាំងហ្វ្រង់ស័រ សាវិយេរ ឬវិហារចាតាំ (Cha Tam Church) ដើម្បីបួងសួងសុំឱ្យព្រះយេស៊ូ ដែលពួកគាត់ជឿជាក់បំផុតនោះ ជួយស្រោចស្រង់អាយុជីវិតពួកគាត់ផង។

ព្រលឹមស្រាងៗថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៦៣ កងទ័ពរដ្ឋប្រហារ និងពលរដ្ឋយ៉ាងច្រើនកុះករដែល មានកំហឹងឈឺចាប់ជាមួយ ង៉ូ ឌិញយៀម និងង៉ូ ឌិញញូ បាននាំគ្នាធ្វើការឡោមព័ទ្ធ

## របត់នយោបាយ


ព្រះវិហារសាំងហ្វ្រង់ស័រ សាវិយេរ

ជុំជិតព្រះវិហារសាសនាកាតូលិក ដែលពួកគាត់ទាំងពីរនាក់បងប្អូន ចូលទៅបួងសួងនោះ។

នៅក្នុងភាពតក់ស្លុតរកទីបំផុតគ្មាន ង៉ូ ឌិញយៀម ក៏បានទូរស័ព្ទទៅឧត្តមសេនីយ៍ ចឹន វ៉ាន់ដុង(Trần Văn Đôn) នៅសេនាធិការដ្ឋានក្រុមប្រឹក្សាបដិវត្តន៍ ឱ្យជួយធ្វើអន្តរាគមន៍ការពារជីវិតរបស់គាត់ និងប្អូនប្រុសគាត់ផង។

ឧត្តមសេនីយ៍ ចឹន វ៉ាន់ដុង ក៏បានប្រាប់មកវិញថា ឱ្យរង់ចាំបន្តិច!។ ប៉ុន្តែរហូតដល់ម៉ោង៩ព្រឹក ថ្ងៃទី០២ ខែវិច្ឆិកា ក៏នៅតែមិនឮឧត្តមសេនីយ៍ ចឹន វ៉ាន់ដុង ឆ្លើយតបមកវិញ ថាយ៉ាងណា?។

លុះដល់ម៉ោង៩ និង២៩នាទី គេឃើញឧត្តមសេនីយ៍ ម៉ាយ ហ៊ឺវស៊ួន, ឧត្តមសេនីយ៍ យឿងង៉ុកឡាំ និងឧត្តមសេនីយ៍ឡេវ៉ាន់គីមធ្វើដំណើរតាមក្បួនរថក្រោះអឹម១១៣(M113) ជាច្រើនគ្រឿង មកដល់វិហារកាតូលិកនោះ ហើយចាប់ ង៉ូ ឌិញយៀម និងង៉ូ ឌិញញូ បញ្ចូលទៅក្នុងរថក្រោះអឹម១១៣ (M113) មួយគ្រឿង ដឹកចេញពីក្រុងចឹឡឹង ឆ្ពោះទៅកាន់សេនាធិការដ្ឋានក្រុមប្រឹក្សាបដិវត្តន៍ នៅទីក្រុងព្រៃនគរ(សៃហ្គន)។

ប៉ុន្តែ ពេលមកដល់ពាក់កណ្តាលផ្លូវ ត្រង់ចំណុចចម្ការចាស់មួយឈ្មោះភូគូ ក្បែរវាលប្រណាំងសេះ ក្បួនរថក្រោះបានឈប់នៅទីនោះ ហើយ ង៉ូ ឌិញយៀម និងង៉ូ ឌិញញូ ត្រូវបានគេប្រាបឱ្យចេញពីរថក្រោះ រួចចងស្លាបសេកភ្លាមៗ។

ពេលនោះ ដោយមានបញ្ជាមកពីឧត្តមសេនីយ៍ យឿង វ៉ាន់មិញ ជាប្រធានក្រុមប្រឹក្សា



**សាកសពប្រធានាធិបតី ង៉ូ ឌិញយៀម**



**សាកសព ង៉ូ ឌិញញូ**

បដិវត្តន៍ អនុសេនីយ៍ឯក ង្វៀន វ៉ាន់ញ៉ុង ជាកូនចៅជំនិតរបស់គាត់ ក៏បានយកកាំបិតខ្លីមកចាក់ ង៉ូ ឌិញយៀម និងង៉ូ ឌិញញូ ជាច្រើនកាំបិត រួចហើយទាញកាំភ្លើងខ្លីមកបាញ់បន្ថែមទៀត ផ្តាច់ជីវិតបងប្អូនទាំង២នាក់ នៅចំពោះមុខឧត្តមសេនីយ៍ ម៉ាយ ហ៊ីវស៊្វន, ឧត្តមសេនីយ៍ យឿង ង៉ុកឡាំ និងឧត្តមសេនីយ៍ ឡេ វ៉ាន់គីម នៅពេលនោះតែម្តងទៅ។

អនុសេនីយ៍ឯក ង្វៀន វ៉ាន់ញ៉ុង ជាអ្នកសម្លាប់ ង៉ូ ឌិញយៀម និងង៉ូ ឌិញញូ ផ្ទាល់ដៃនោះ ត្រូវដំឡើងឋានន្តរស័ក្តិ ជាវរសេនីយ៍ត្រីភ្លាមៗ តែមិនយូរប៉ុន្មាន គាត់ក៏ត្រូវបានគេសម្លាប់ចោលដែរ។

សាកសពប្រធានាធិបតី យៀម និងប្អូនប្រុស ញូ ត្រូវបានគេយកទៅទុកនៅក្នុងបន្ទប់តម្កល់សាកសពរបស់មន្ទីរពេទ្យសាំង ម៉ូល មួយយប់។

ស្អែកឡើង ព្រឹកថ្ងៃទី០៣ ខែវិច្ឆិកា ត្រូវបានគេយកទៅកប់ចោលនៅទីធ្លាមួយដែលនៅខាងក្រោយអគ្គសេនាធិការដ្ឋានកងទ័ពវៀតណាមខាងត្បូង។

ចំណែកអ្នកស្រីញូ មានឈ្មោះដើម ចឺន ឡេស៊្វន( Tran Le Xuân ) បានរួចជីវិតក្នុងព្រឹត្តិការណ៍ធ្វើរដ្ឋប្រហារនោះ ហើយបានចាកចេញទៅរស់នៅប្រទេសអ៊ីតាលី ជាមួយ នឹងប្រាក់ដុល្លារ បានមកពីអំពើពុករលួយកេងប្រវ័ញ្ចយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលផ្ញើនៅធនាគារក្រៅប្រទេសតាំងពីឆ្នាំ១៩៥៥នោះ ផងដែរ។

ង៉ូ ឌិញយៀម ជាអ្នកកាន់សាសនារ៉ូម៉ាំងកាតូលិកយ៉ាងខ្ជាប់ខ្ជួន តាំងពីក្មេងមកនោះ

## របត់នយោបាយ

កើតនៅថ្ងៃទី០៣ ខែមករា ឆ្នាំ១៩០១ នៅក្នុងស្រុកមួយ មានចម្ងាយ១១០គីឡូម៉ែត្រ ពីភាគខាងជើងទីក្រុងព្រៃនគរ(សៃហ្គន) ឪពុកគាត់ឈ្មោះង៉ូ ឌិញខា (Ngô Đình Khả) ជាអ្នកកាន់សាសនារ៉ូម៉ាំងកាតូលិកដ៏លេចធ្លោមួយ និងជាមន្ត្រីរាជការជាន់ខ្ពស់ម្នាក់។ កាលពីក្មេង គាត់បានទទួលការអប់រំនៅសាលាបារាំង។ លុះធំពេញវ័យ គាត់មានបំណងក្លាយជាបព្វជិតក្នុងសាសនារ៉ូម៉ាំងកាតូលិកតាមគន្លងបងប្រុសរបស់គាត់ឈ្មោះ ង៉ូ ឌិញធុក (Ngô Đình Thục)ដែរ។

ប៉ុន្តែនៅទីបំផុត គាត់បានជ្រើសរើសអាជីពជាមន្ត្រីរាជការ នៅក្នុងស្ថាប័នតុលាការរបស់ព្រះចៅ បាវដាយ (Bảo Đại) វិញ និងបានឡើងឋានៈជាបន្តបន្ទាប់ និងឆាប់រហ័សបំផុត។ គាត់បានឡើងឋានៈជាចៅហ្វាយខេត្តប៊ីញធួន(Bình Thuận) ក្នុងឆ្នាំ១៩២៩ និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅឆ្នាំ១៩៣៣។ តែក្រោយកាន់តំណែងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានរយៈពេលតែបីខែ គាត់ក៏លាលែងវិញ ហើយងាកទៅគាំទ្រចលនាជាតិនិយមវៀតណាមដែលជាចលនាប្រឆាំងលទ្ធិកុម្មុយនិស្តផង និងប្រឆាំងអាណានិគមនិយមបារាំងផងដែរ។ គាត់បានប្រកាសថ្កោល ទោសចំពោះព្រះចៅ បាវដាយ(Bảo Đại) ជាសាធារណៈថា ព្រះចៅគ្រាន់តែជាឧបករណ៍នយោបាយរបស់ប្រទេសបារាំងប៉ុណ្ណោះ។

ក្រោយមក គាត់បានបង្កើតគណបក្សមួយឈ្មោះគឺនឡាវ។ តែគាត់មិនបានទទួលផលអ្វីពីការបង្កើតគណបក្សនេះទេ គឺបានត្រឹមតែនិរទេសខ្លួនទៅរស់នៅក្រៅប្រទេសអស់រយៈពេលជា ច្រើនឆ្នាំប៉ុណ្ណោះ។

នៅក្នុងខែកក្កដា ឆ្នាំ១៩៥៤ គាត់បានត្រលប់មកមាតុប្រទេសវិញ ហើយព្រះចៅបាវដាយ(Bảo Đại) ដែលបារាំង លើកបន្តុបឱ្យធ្វើជាប្រមុខរដ្ឋនៅវៀតណាមភាគខាងត្បូងនោះ បានតែងតាំងគាត់ឱ្យធ្វើជានាយករដ្ឋមន្ត្រី។

បន្ទាប់ពីការបោះឆ្នោតប្រជាមតិឱ្យប្រជាពលរដ្ឋសម្រេចចិត្តថា តើត្រូវជ្រើសរើសរបបរាជានិយមបន្តទៀត ឬត្រូវជ្រើសរើសរបបសាធារណរដ្ឋនិយម ក្នុងឆ្នាំ១៩៥៥ មក គាត់បានប្រកាសបង្កើតរបបសាធារណរដ្ឋវៀតណាមខាងត្បូង ហើយគាត់ក៏បានឡើងតំណែង



**អនុសេនីយ៍ទោ ផាម ភូគួក និងប្រធានាធិបតី ផាន ខាក់ស៊ូ** (Phan Khac Suu) **ឆ្នាំ១៩៦៤**

ជាប្រធានាធិបតី ចាប់ពីពេលនោះមក ដោយមានបណ្តាប្រទេសប្រឆាំងនឹងលទ្ធិកុម្មុយនិស្ត ផ្សេងៗទៀត ជាពិសេសសហរដ្ឋអាមេរិក ជាអ្នកគាំទ្រគាត់ពេញទំហឹង។

បន្ទាប់ពីរដ្ឋប្រហារផ្តួលរម្លំប្រធានាធិតី ង៉ូ ឌិញយៀម បានសម្រេចដោយជោគជ័យ នាដើមខែវិច្ឆិកា ឆ្នាំ១៩៦៣មក ឧត្តមសេនីយ៍ យឿង វ៉ាន់មិញ ប្រធានក្រុមប្រឹក្សាបដិវត្តន៍ ត្រូវបានជ្រើសតាំងជាប្រធានាធិបតី និងឧត្តមសេនីយ៍ ង្វៀន ខាន់ ត្រូវបានជ្រើសតាំងជានាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋវៀតណាម។ ចំណែកមន្ត្រីយោធា និងស៊ីវិល ជាអ្នកទោសទាំងអស់ដែលពាក់ព័ន្ធរឿងធ្វើរដ្ឋប្រហារមិនបានសម្រេច កាលពីឆ្នាំ១៩៦០ និងឆ្នាំ១៩៦២ ត្រូវបានដោះលែងឱ្យមានសេរីភាព និងប្រគល់តំណែងឱ្យដូចដើមវិញ ក្នុងនោះអនុសេនីយ៍ ទោ ផាម ភូគួក ដែលត្រូវកងការពារអាកាសរបស់ ង៉ូ ឌិញយៀម បាញ់ធ្លាក់កាលពីឆ្នាំ១៩៦២ និង យកទៅដាក់ពន្ធនាគារ ក៏ត្រូវបានដោះលែង និងប្រគល់តំណែងឱ្យដូចដើមវិញដែរ។

## របត់នយោបាយ

នៅដើមឆ្នាំ១៩៦៤ ដោយមានការស៊ុមគ្រលុំគ្នាជាមួយពួកឧត្តមសេនីយ៍នៅក្នុងក្រុមប្រឹក្សាបដិវត្តន៍ធ្វើរដ្ឋប្រហារទម្លាក់ប្រធានាធិបតី ង៉ូ ឌិញយៀម នោះ ឧត្តមសេនីយ៍ ង្វៀន ខាន់ ជានាយករដ្ឋមន្ត្រី ក៏បានធ្វើរដ្ឋប្រហារទម្លាក់ឧត្តមសេនីយ៍ យឿង វ៉ាន់មិញ ចេញពីតំណែងប្រធានាធិបតី ហើយខ្លួនគាត់បានឡើងជំនួសវិញ។ តែក្រោយពីទម្លាក់ឧត្តមសេនីយ៍ យឿង វ៉ាន់មិញ ចេញពីតំណែងប្រធានាធិបតីនោះមក ធ្វើឱ្យប្រជាពលរដ្ឋសិស្សនិស្សិតនាំគ្នាងើបឡើងបះបោរធ្វើបាតុកម្មយ៉ាងគគ្រឹកគគ្រេងប្រឆាំងនឹងឧត្តមសេនីយ៍ ង្វៀន ខាន់ ជាប្រធានាធិបតីថ្មីនោះ បង្កជាចលាចលពេញទីក្រុងសៃហ្គន។

ដើម្បីឱ្យមានស្ថេរភាពឡើងវិញ ឧត្តមសេនីយ៍ ង្វៀន វ៉ាន់ជីវ និងឧត្តមសេនីយ៍ ង្វៀន ការគី ក៏បានដកឧត្តមសេនីយ៍ ង្វៀន ខាន់ ចេញពីតំណែងប្រធានាធិបតីវិញ ហើយឧត្តមសេនីយ៍ ង្វៀន វ៉ាន់ជីវ ក៏បានឡើងជាប្រធានាធិបតី និងឧត្តមសេនីយ៍ ង្វៀន ការគី បានឡើងជាអនុប្រធានាធិបតី ដឹកនាំសាធារណរដ្ឋវៀតណាម (វៀតណាមខាងត្បូង) បន្តទៀត។

# ១៥៤
# អ្វីទៅដែលហៅថា សង្គ្រាមត្រជាក់ ?



**ស្តាលីន** (**សូវៀត**), **ហ្វ្រង់គ្លីន រ៉ូស្វែល** (**សហរដ្ឋអាមេរិក**) **និង វីនស្តុន ឆឺឈីល** (**អង់គ្លេស**)

ពាក្យថា "សង្គ្រាមត្រជាក់" ត្រូវបានអ្នកនិពន្ធអង់គ្លេសម្នាក់ ឈ្មោះហ្សក អូវែល (George Orwell) ប្រើជាដំបូង នៅឆ្នាំ១៩៤៥ ក្នុងន័យសំដៅទៅលើស្ថានភាពនៃការប្រឈមមុខដាក់គ្នាជាប្រចាំ រវាងរដ្ឋមួយជាមួយរដ្ឋមួយទៀត ក៏ប៉ុន្តែមិនឈានដល់ការផ្ទុះសង្គ្រាមជាមួយគ្នាដោយផ្ទាល់នោះទេ។

អ្នកប្រវត្តិសាស្ត្រខ្លះយល់ថា ក្រោយសង្គ្រាមលោកលើកទី២ ពាក្យថា "សង្គ្រាមត្រជាក់" នេះ ត្រូវបានគេយកមកប្រើជាទូទៅ ដើម្បីសំដៅលើការប្រឈមមុខដាក់គ្នារវាងមហាអំណាចធំៗ២ គឺសហរដ្ឋអាមេរិក និងសហភាពសូវៀត។ តែអ្នកប្រវត្តិសាស្ត្រខ្លះទៀតយល់ថា ដើមហេតុនៃការប្រឈមមុខដាក់គ្នារវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត បានចាប់ផ្តើមឡើងតាំងពីមុនសង្គ្រាមលោកលើកទី២ មកម្ល៉េះ គឺនៅពេលពួកកុម្មុយនិស្តរុស្ស៊ី ធ្វើបដិវត្តន៍ខែតុលា ឆ្នាំ១៩១៧ ដើម្បីផ្តួលរម្លំស្តេចត្សារ៍ (Tsar Nicholas II)។

## របត់នយោបាយ

ដោយសារជិវត្តន៍ខែតុលា ឆ្នាំ១៩១៧នេះ ធ្វើឱ្យរុស្ស៊ី និងប្រទេសលោកខាងលិច ដែលធ្លាប់តែជាសម្ព័ន្ធមិត្តនឹងគ្នា បានដកខ្លួនចេញពីសង្គ្រាមលោកលើកទី១ ទៅចរចាសន្ធិសញ្ញាសន្តិភាពជាមួយអាល្លឺម៉ង់ ហើយទុកឲ្យសម្ព័ន្ធមិត្តលោកខាងលិច ច្បាំងតទល់នឹងអាល្លឺម៉ង់តែម្នាក់ឯង ជាហេតុធ្វើឲ្យប្រទេសលោកខាងលិច ជាពិសេសសហរដ្ឋអាមេរិក ចាប់ផ្តើមមិនទុកចិត្តនឹងរុស្ស៊ី។

ការមិនទុកចិត្តនេះ បានកើតមានកាន់តែខ្លាំងឡើង ក្រោយពីដឹងថា វ្លាឌីមៀរ អ៊ីលីច លេនីន មេដឹកនាំពួកកុម្មុយនិស្តរុស្ស៊ី ពីមុនធ្លាប់តែរស់នៅនិរទេសខ្លួននៅក្នុងប្រទេសស្វ៊ីស ហើយអាចវិលត្រលប់ចូលទៅក្នុងប្រទេសរុស្ស៊ីវិញ រៀបចំធ្វើបដិវត្តន៍ផ្តួលរម្លំស្តេចត្សារ៍នោះ គឺដោយសារតែមានការជួយជ្រោមជ្រែងពីសំណាក់មេដឹកនាំអាល្លឺម៉ង់។ សំខាន់ជាងនេះទៅទៀត សហភាពសូវៀត និងប្រទេសលោកខាងលិច មានការមិនចុះសម្រុងគ្នាពីបញ្ហាមនោគមន៍វិជ្ជានយោបាយ ដោយសារប្រទេសលោកខាងលិច ប្រកាន់យកនូវរបបដឹកនាំតាមបែបប្រជាធិបតេយ្យ និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ដែលផ្ទុយគ្នាទាំងស្រុងពីសហភាពសូវៀតប្រកាន់យករបបនយោបាយកុម្មុយនិស្តផ្តាច់ការ និងប្រព័ន្ធសេដ្ឋកិច្ចផែនការ ។

លើសពីនេះទៅទៀត នៅក្នុងឆ្នាំ១៩១៩ បក្សកុម្មុយនិស្តសូវៀត បានបង្កើតអង្គការមួយ ឈ្មោះអង្គការកុម្មុយនិស្តអន្តរជាតិ ហៅកាត់ថា កូមីនទែន ( Comintern = Communist International ) ដើម្បីផ្សព្វផ្សាយ និងពង្រីកលទ្ធិកុម្មុយនិស្តនៅទូទាំងពិភពលោក ព្រមទាំងប្រឆាំងនឹងលទ្ធិមូលធននិយមប្រទេសលោកខាងលិចផងដែរ។ ប៉ុន្តែ នៅក្នុងសង្គ្រាមលោកលើកទី២ សហភាពសូវៀត និងសហរដ្ឋអាមេរិក បានបង្ខំចិត្តយល់ព្រមសហការគ្នាក្នុងការធ្វើសង្គ្រាមជាមួយពួកណាហ្ស៊ីអាល្លឺម៉ង់ ដោយសារតែកាលៈទេសៈតម្រូវតែប៉ុណ្ណោះ ពោលគឺនៅពេលនោះ ប្រទេសទាំងពីរមានសត្រូវរួមគ្នា គឺមិនមែនធ្វើឡើងក្នុងលក្ខណៈជាសម្ព័ន្ធមិត្តស្មោះស្ម័គ្រនឹងគ្នានោះទេ។

មហាអំណាចទាំងពីរនេះ មានភាពតានតឹង និងមិនទុកចិត្តគ្នា តាមរយៈសន្និសីទធំៗចំនួន ៣ ដែលបានធ្វើឡើងនៅក្នុងអំឡុងសង្គ្រាមលោកលើកទី២នោះ គឺសន្និសីទទី១

ធ្វើឡើងពីថ្ងៃទី២៨ វិច្ឆិកា ដល់ថ្ងៃទី១ធ្នូ ឆ្នាំ១៩៤៣ នៅក្នុងស្ថានទូតសូវៀត ប្រចាំទីក្រុងតេហេរ៉ង់ (អ៊ីរ៉ង់) ដែលគេហៅថា "សន្និសីទក្រុងតេហេរ៉ង់"។ នៅក្នុងសន្និសីទនេះ ប្រធានាធិបតីអាមេរិក ហ្វ្រង់គ្លីន រូស្វែល (Franklin Roosevelt) និងនាយករដ្ឋមន្ត្រីអង់គ្លេស វីនស្តុន ឆឺឈីល (Winston Churchill) ព្រមទាំងអគ្គលេខាបក្សកុម្មុយនិស្តសហភាពសូវៀត ស្តាលីន បានពិភាក្សាគ្នា អំពីយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការបែងចែកកម្លាំងវាយបកទៅលើពួកអ៊ីត្លែរ ដោយកងទ័ពសូវៀត វាយលុកពីទិសខាងកើត ចំណែកកងកម្លាំងសម្ព័ន្ធមិត្តលោកខាងលិច វាយលុកពីទិសខាងលិច។

ពេលនោះ ប្រធានាធិបតីអាមេរិក និងនាយករដ្ឋមន្ត្រីអង់គ្លេស បានយល់ព្រមតាមអគ្គលេខាបក្សកុម្មុយនិស្តសហភាពសូវៀត ស្តាលីន ដែលបានទាមទារថា ក្រោយពេលទទួលជ័យជម្នះលើពួកអ៊ីត្លែរ ត្រូវឱ្យសូវៀតកាន់កាប់តំបន់អឺរ៉ុបខាងកើតមួយចំណែក។ ដោយឡែកសម្ព័ន្ធមិត្តលោកខាងលិច ក៏បានព្រមព្រៀងឲ្យសូវៀត កាត់យកទឹកដីមួយផ្នែករបស់ប៉ូឡូញ ហើយកាត់យកទឹកដីអាល្លឺម៉ង់មួយផ្នែកទៅឲ្យប៉ូឡូញ វិញ។

ពីថ្ងៃទី៤ ដល់ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៤៥ ពេលកងកម្លាំងសម្ព័ន្ធមិត្តកំពុងតែមានប្រៀបលើកងទ័ពអាល្លឺម៉ង់ នៅសមរភូមិខាងលិច ហើយកងទ័ពសូវៀត បានចូលកាន់កាប់តំបន់អឺរ៉ុបខាងកើត បានមួយផ្នែកធំហើយនោះ ប្រធានាធិបតីអាមេរិក ហ្វ្រង់គ្លីន រូស្វែល (Franklin Roosevelt) នាយករដ្ឋមន្ត្រីអង់គ្លេស វីនស្តុន ឆឺឈីល (Winston Churchill) និងអគ្គលេខាបក្សកុម្មុយនិស្តសហភាពសូវៀត ស្តាលីន បានជួបគ្នាជាលើកទី២ នៅក្នុងសន្និសីទក្រុងយ៉ាល់តា (តំបន់គ្រីមៀរ) ពិភាក្សាគ្នាស្តីពីការបែងចែកគ្នាគ្រប់គ្រងប្រទេសអាល្លឺម៉ង់ថាក្រោយពេលឈ្នះសង្គ្រាម ប្រទេសអាល្លឺម៉ង់ ត្រូវបែងចែកជា៤ចំណែក ក្នុងនោះអាមេរិកកាន់កាប់មួយចំណែក, អង់គ្លេស កាន់កាប់មួយចំណែក, សូវៀត កាន់កាប់មួយចំណែក និងបារាំង កាន់កាប់មួយចំណែក។ ចំណែកទីក្រុងប៊ែរឡាំង ជារដ្ឋធានីរបស់អាល្លឺម៉ង់ ដែលជាទឹកដីស្ថិតនៅក្រោមការគ្រប់គ្រងរបស់សូវៀត ក៏ត្រូវបែង ចែកជា៤ចំណែកផងដែរ។

នាថ្ងៃ១២ ខែមេសា ឆ្នាំ១៩៤៥ ប្រធានាធិបតីអាមេរិក ហ្វ្រង់គ្លីន រូស្វែល (Franklin

Roosevelt) បានទទួលមរណភាពដោយជំងឺ ដូច្នេះ ហារី អេស. ទ្រូម៉ាន់ (Harry S. Truman) ជាអនុប្រធានាធិបតី ត្រូវទទួលតំណែងជាប្រធានាធិបតីអាមេរិក បន្ត។

ប្រធានាធិបតីអាមេរិក ហារី អេស. ទ្រូម៉ាន់ (Harry S. Truman) ជាមេដឹកនាំមានគំនិតស្អប់ខ្ពើមលទ្ធិកុម្មុយនិស្តបំផុត។ ចំណែក អគ្គលេខាបក្សកុម្មុយនិស្តសហភាពសូវៀត ស្តាលីន ក៏ស្អប់ខ្ពើមលទ្ធិមូលធននិយមខ្លាំងណាស់ដែរ។ លើសពីនេះទៅទៀត មេដឹកនាំអាមេរិក និងសូវៀត មានគោលដៅផ្ទុយគ្នាទាំងស្រុងចំពោះបញ្ហាប្រទេសអាល្លឺម៉ង់។

អាមេរិក ចង់ឃើញអាល្លឺម៉ង់ ក្លាយជាប្រទេសមួយមានការអភិវឌ្ឍឡើងវិញ ដើម្បីអាចជាដៃគូពាណិជ្ជកម្មជាមួយខ្លួនបាន។ ចំណែក សូវៀត ចង់ឱ្យប្រទេសអាល្លឺម៉ង់ ក្លាយជាប្រទេសកុម្មុយនិស្ត ដើម្បីងាយស្រួលគ្រប់គ្រងផង និងចង់យកប្រទេសអាល្លឺម៉ង់ ធ្វើជាតំបន់ទ្រនាប់ ដើម្បីទប់ទល់នឹងមហាអំណាចលោកខាងលិចផង។

# ១៥៥
# អាមេរិក បង្កើតអង្គការណាតូ  សូវៀត បង្កើតអង្គការវ៉ាសូវី



កិច្ចប្រជុំអង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង ហៅកាត់ថា អង្គការណាតូ

ក្រោយពេលសង្គ្រាមលោកលើកទី២ ត្រូវបានបញ្ចប់ក្នុងខខែកញ្ញា ឆ្នាំ១៩៤៥ ដំណាក់កាលដំបូង ការប្រឈមមុខដាក់គ្នា រវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត គឺការពុះចែកតំបន់អឺរ៉ុបជាពីរ គឺអឺរ៉ុបខាងកើត ស្ថិតក្រោមឥទ្ធិពលសូវៀត និងអឺរ៉ុបខាងលិចស្ថិតក្រោមឥទ្ធិពលអាមេរិក។ ប្រទេសអាល្លឺម៉ង់ ត្រូវបានពុះចែកជាពីរប្រទេសផងដែរ គឺសាធារណរដ្ឋប្រជាធិតេយ្យអាល្លឺម៉ង់ (អាល្លឺម៉ង់ខាងកើត) គ្រប់គ្រងដោយពួកកុម្មុយនិស្ត និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (អាល្លឺម៉ង់ខាងលិច) ជាសម្ព័ន្ធមិត្តរបស់អាមេរិក។

ចាប់ពីពេលនោះមក សហភាពសូវៀត និងសហរដ្ឋអាមេរិក ក៏ចាប់ផ្តើមប្រកួតប្រជែងគ្នាព្យាយាមបង្កើនឥទ្ធិពលរៀងៗខ្លួន។

ពីថ្ងៃទី១៧ខែកក្កដា ដល់ថ្ងៃទី២ខែសីហា ឆ្នាំ១៩៤៥ មេដឹកនាំអាមេរិក អង់គ្លេស

និងសូវៀត បានជួបពិភាក្សាគ្នានៅក្នុងសន្និសីទលើកទី៣ នាទីក្រុងប៉ូស្តាំ (Potsdam) ក្បែររដ្ឋធានីប៊ែរឡាំង ស្តីពីការបែងចែកគ្នាគ្រប់គ្រងប្រទេសអាល្លឺម៉ង់នេះ ម្តងទៀត។

នៅដើមឆ្នាំ១៩៤៦ មន្ត្រីទូតអាមេរិកម្នាក់ប្រចាំទីក្រុងមូស្គូ ឈ្មោះថា ហ្សក កេណ្ណាន់ (George Kennan) បានផ្ញើសារទូរលេខមួយ ទៅក្រុងវ៉ាស៊ីនតោន ដោយបានសរសេរលម្អិតអំពីយុទ្ធសាស្ត្រមួយដែលអាមេរិក គួរដាក់ចេញចំពោះសហភាពសូវៀត។ នៅក្នុងសារទូរលេខនោះ ហ្សក កេណ្ណាន់(George Kennan) បានលើកឡើងថា បច្ចុប្បន្នសហភាពសូវៀត កំពុងអនុវត្តនយោបាយមួយ ដែលមិនអាចឈរនៅជាមួយសហរដ្ឋអាមេរិក បានជាដាច់ខាត។ ដូច្នេះ សហរដ្ឋអាមេរិក គ្មានជម្រើសអ្វីក្រៅតែពីការដាក់ចេញនូវយុទ្ធសាស្ត្ររយៈពេលវែងមួយ ដោយប្រើគ្រប់មធ្យោបាយ ដើម្បីរាំងខ្ទប់ការរីកសាយភាយនៃឥទ្ធិពលកុម្មុយនិស្តសូវៀត។

យុទ្ធសាស្ត្រដែលមន្ត្រីទូតអាមេរិក ឈ្មោះហ្សក កេណ្ណាន់ បានសរសេរឡើងនោះ ជាទូទៅ គេហៅតាមភាសាអង់គ្លេសថា « Containment » ត្រូវបានប្រធានាធិបតីអាមេរិក ហារី អេស. ទ្រូម៉ាន់ (Harry S. Truman) ឯកភាពតាម ។

នៅឆ្នាំ១៩៤៧ ប្រធានាធិបតីអាមេរិក ហារី អេស. ទ្រូម៉ាន់ (Harry S. Truman) បានថ្លែងសុន្ទរកថានៅក្នុងសភាពេញអង្គថា អាមេរិកត្រូវតែប្រកាន់ខ្ជាប់នូវនយោបាយមួយ គឺត្រូវតែចេញមុខជួយប្រជាជាតិនៅគ្រប់ទីកន្លែងទាំងអស់ ដែលត្រូវប្រឈមមុខនឹងការគាបសង្កត់ពីប្រទេសក្រៅ(កុម្មុយនិស្ត)។

ជាមួយគ្នានោះ ហារី អេស. ទ្រូម៉ាន់ បានស្នើសុំឲ្យសភាផ្តល់ប្រាក់ចំនួន ៤០០លានដុល្លារ ដើម្បីយកទៅជួយដល់ប្រទេសតួកគី និងប្រទេសក្រិក ក្នុងការប្រយុទ្ធប្រឆាំងនឹងក្រុមឧទ្ទាមកុម្មុយនិស្ត ដែលមានការគាំទ្រពីសំណាក់ប្លុកសូវៀត ផងដែរ។

សុន្ទរកថារបស់ប្រធានាធិបតីអាមេរិក ហារី អេស. ទ្រូម៉ាន់ នៅចំពោះសភាអាមេរិក នាពេលនោះ ត្រូវបានគេដាក់ឈ្មោះថា «លទ្ធិទ្រូម៉ាន់ (Truman Doctrine)» ហើយត្រូវបានអ្នកប្រវត្តិសាស្ត្រទូទៅកំណត់យកជាចំណុចចាប់ផ្តើមនៃសង្គ្រាមត្រជាក់ ចាប់ពីពេលនោះ

មក។

នាថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៤៧ នៅរដ្ឋការ៉ូលីណាខាងត្បូង (South Carolina) ក្នុងឱកាសឡើងមានបញ្ចេញទស្សនៈការពីភាពតានតឹងនៃជម្លោះមនោគមវិជ្ជានយោបាយ រវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត រដ្ឋបុរសអាមេរិកឈ្មោះ ប៊ែរណាដ៍ បារុច (Bernard Baruch) បានថ្លែង ថា៖ "យើងមិនអនុញ្ញាតឲ្យគេបំភាន់យើងបានទេ។ សព្វថ្ងៃនេះ យើងកំពុងតែស្ថិតនៅចំកណ្ដាលនៃសង្គ្រាមត្រជាក់" ។

ចំណែកជនកុម្មុយនិស្ត វ៉លធ័រ លីបម៉ាន់ (Walter Lippmann) វិញ នៅពេលបោះពុម្ពផ្សាយសៀវភៅរបស់គាត់នៅក្នុងឆ្នាំ១៩៤៧នោះដែរ គាត់ក៏បានដាក់ចំណងជើងសៀវភៅរបស់គាត់ថា "សង្គ្រាមត្រជាក់" ដែរ។

នៅឆ្នាំ១៩៤៩ ក្រោយពេលដែលសហភាពសូវៀត បានធ្វើការសាកល្បងអាវុធនុយក្លេអ៊ែរប្រកបដោយជោគជ័យ ហើយបញ្ចប់ភាពជាមហាអំណាចនុយក្លេអ៊ែរផ្ដាច់មុខតែឯងរបស់សហរដ្ឋអាមេរិកមក មហាអំណាចទាំង២ បានចាប់ផ្ដើមប្រឈមមុខដាក់គ្នាកាន់តែខ្លាំងឡើងៗ។

បន្ទាប់មកទៀត សង្គ្រាមត្រជាក់បានចាប់ផ្ដើមរីករាលចេញពីតំបន់អឺរ៉ុប ក្លាយទៅជាសង្គ្រាមត្រជាក់ពិភពលោក។ សហរដ្ឋអាមេរិក បានដឹកនាំសម្ព័ន្ធមិត្តរបស់ខ្លួនជាច្រើនប្រទេស ជាពិសេសប្រទេសនៅអឺរ៉ុបខាងលិច និងនៅមជ្ឈិមបូព៌ា ដើម្បីទប់ស្កាត់ការរីករាលដាល និងកាត់បន្ថយឥទ្ធិពលនៃលទ្ធិកុម្មុយនិស្ត ខណៈដែលសហភាពសូវៀត បានផ្ដត់ផ្គង់ និងគាំទ្រដល់ចលនាបដិវត្តន៍កុម្មុយនិស្តនៅទូទាំងពិភពលោក ជាពិសេសនៅអឺរ៉ុបខាងកើត នៅអាមេរិកឡាទីន និងនៅអាស៊ីអាគ្នេយ៍ ។

នៅថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៤៩ នៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ផ្ដួចផ្ដើមគំនិត និងចុះហត្ថលេខាជាមួយប្រទេសកាណាដា អ៊ីស្លង់ ចក្រភពអង់គ្លេស បារាំង បែលហ្ស៊ិក ហូឡង់ លុចសំបួ ន័រវេស ដាណឺម៉ាក អ៊ីតាលី និងព័រទុយហ្គាល់ បង្កើតបក្សសម្ព័ន្ធយោធាមួយហៅថា អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង ហៅកាត់ថា អង្គការណាតូ (NATO = The

North Atlantic Treaty Organization ) ដែលភាសាបារាំង ហៅថា "អង្គការអូតង់" ( OTAN )។ អង្គការបក្សសម្ព័ន្ធយោធានេះ មានទីបញ្ជាការនៅទីក្រុងព្រុចសែល ប្រទេសបែលហ្សិក។

អង្គការណាតូ បានធ្វើបតិដ្ឋាប័នលើប្រព័ន្ធការពាររួមគ្នា មានន័យថា រដ្ឋជាសមាជិកទាំងអស់ត្រូវធ្វើអន្តរាគមន៍ជួយការពារគ្នាទៅវិញទៅមកតាមលទ្ធភាពដែលអាចធ្វើបាននៅពេលមានការវាយប្រហារណាមួយពីសំណាក់ភាគីខាងក្រៅ។

ចាប់ផ្តើមដំបូង អង្គការណាតូ ពុំមានអ្វីគួរឱ្យចាប់អារម្មណ៍ ក្រៅតែពីសមាគមនិន្នាការនយោបាយមួយប៉ុណ្ណោះ។ តែនៅពេលសង្គ្រាមនៅកូរ៉េ ចាប់ផ្តើមផ្ទុះឡើងនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥០មក បានដាស់ស្មារតីរដ្ឋជាសមាជិកទាំងអស់ឱ្យបង្កើតរចនាសម្ព័ន្ធយោធារួមគ្នាមួយ ស្ថិតក្រោមការដឹកនាំផ្ទាល់របស់មេបញ្ជាការសហរដ្ឋអាមេរិក ២រូប។

ពេលនោះដែរ ឡូត អ៊ីស្មាយ អគ្គលេខាធិការទី១ របស់អង្គការណាតូ បានប្រកាសយ៉ាងម៉ឺងម៉ាត់ថា គោលដៅរបស់អង្គការណាតូ គឺ "រក្សាទុករុស្ស៊ី ឲ្យនៅខាងក្រៅ, សហរដ្ឋអាមេរិក នៅខាងក្នុង ហើយអាល្លឺម៉ង់ ត្រូវធ្លាក់ចុះ" ( "to keep the Russians out, the Americans in, and the Germans down" ) ។

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៥៥ ដោយមានសហរដ្ឋអាមេរិក ជាអ្នកនាំមុខផងដែរ អង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ ហៅកាត់ថា អង្គការសេអាតូ ( SEATO= the Southeast Asia Treaty Organization ) ត្រូវបានបង្កើតឡើង ដោយមានប្រទេសចំនួន៨ ជាសមាជិករួមមាន៖ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស បារាំង ណូវែលសេឡង់ អូស្ត្រាលី ប៉ាគីស្ថាន ថៃ និងហ្វីលីពីន។ គោលបំណងនៃការបង្កើតអង្គការនេះគឺសាមញ្ញបំផុត ពោលគឺដើម្បីទប់ស្កាត់លទ្ធិកុម្មុយនិស្តដែលកាន់រីករាលដាលខ្លាំងឡើងៗនៅតំបន់អាស៊ីទាំងមូល។

ក្រោយពីសហរដ្ឋអាមេរិក បង្កើតអង្គការសេអាតូ បានប្រមាណ៣ខែប៉ុណ្ណោះ សហភាពសូវៀត ក៏បានផ្តួចផ្តើមគំនិតជាមួយប្រទេសកុម្មុយនិស្តនៅអឺរ៉ុបខាងកើត ចំនួន៧ទៀត គឺប្រទេសអាល់បានី ប៊ុលហ្គារី ឆេកូស្លូវ៉ាគី សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ (អាល្លឺម៉ង់ខាងកើត ) ហុងគ្រី ប៉ូឡូញ និងរ៉ូម៉ានី បង្កើតអង្គការសន្ធិសញ្ញាមិត្តភាពកិច្ចសហប្រតិបត្តិការ



**កិច្ចប្រជុំអង្គការសន្ធិសញ្ញាមិត្តភាពកិច្ចសហប្រតិបត្តិការ និងជនុបត្ថម្ភ (អង្គការវ៉ាសូវី)**

និងជនុបត្ថម្ភ (the Warsaw Pact) ដែលគេស្គាល់ជាទូទៅថា អង្គការកតិកាសញ្ញាវ៉ាសូវី ព្រោះអង្គការនេះត្រូវបានចុះហត្ថលេខាបង្កើតឡើងនៅទីក្រុងវ៉ាសូវី ប្រទេសប៉ូឡូញ នៅខែ ១៤ ខែឧសភា ឆ្នាំ១៩៥៥ ។

អង្គការកតិកាសញ្ញាវ៉ាសូវី ដែលមានសហភាពសូវៀត ជាបងធំនៃពួកកុម្មុយនិស្ត នាំមុខ ត្រូវបានបង្កើតឡើង ដើម្បីរក្សាតុល្យភាពកម្លាំង ដើម្បីប្រឆាំងនឹងអង្គការណាតូ ដែលមានសហរដ្ឋអាមេរិក ជាអ្នកនាំមុខ។ អង្គការកតិកាសញ្ញាវ៉ាសូវី បានចែងច្បាស់ថា រដ្ឋសង្គមនិយមនៅអឺរ៉ុបកណ្ដាល និងខាងកើត ជាសមាជិកទាំងអស់ត្រូវជួយធ្វើអន្តរាគមន៍ជួយការពារគ្នាទៅវិញទៅមកលើផ្នែកយោធា និងសេដ្ឋកិច្ច។

ដោយសារសង្គ្រាមត្រជាក់រវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៤៩ ប្រទេសអាល្លឺម៉ង់ បានបំបែកជារដ្ឋពីរ គឺមួយជាសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (អាល្លឺម៉ង់ខាងលិច) ជារដ្ឋប្រកាន់លទ្ធិប្រជាធិបតេយ្យសេរី និងជាសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក និងមួយទៀតជាសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ (អាល្លឺម៉ង់ខាងកើត)



**សកម្មភាពសាងសង់កំពែងជញ្ជាំងខណ្ឌចែកទីក្រុងប៊ែរឡាំង**

ជារដ្ឋប្រកាន់លទ្ធិកុម្មុយនិស្ត និងជាសម្ព័ន្ធមិត្តរបស់សហភាពសូវៀត។

នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៦១ ទីក្រុងប៊ែរឡាំង ត្រូវបានសាងសង់កំពែងជញ្ជាំង ដែលមានកម្ពស់៣,៦ម៉ែត្រ ដើម្បីខណ្ឌចែកជាទីក្រុងប៊ែរឡាំងខាងលិច និងទីក្រុងប៊ែរឡាំងខាងកើត។

# ១៥៦
# សង្គ្រាមនៅឧបទ្វីបកូរ៉េ



នៅចុងបញ្ចប់សង្គ្រាមលោកលើកទី២ ក្នុងឆ្នាំ១៩៤៥ កងទ័ពជប៉ុន បានប្រកាសចុះចាញ់កងទ័ពសាធារណរដ្ឋចិន ហើយ ជៀង កៃជៀក មេដឹកនាំបក្សគួមីនតាង បានឡើងកាន់អំណាចដឹកនាំសាធារណរដ្ឋចិន (ចិនសេរី)បន្តទៀត។ ប៉ុន្តែសង្គ្រាមផ្ទៃក្នុង ឬសង្គ្រាមស៊ីវិលនៅប្រទេសចិន រវាងគណបក្សគួមីនតាង និងបក្សកុម្មុយនិស្ត ដឹកនាំដោយ ម៉ៅ សេទុង ដែលបានបង្កើតឡើងតាំងពីថ្ងៃទី២៣ កក្កដា ឆ្នាំ១៩២១ នៅទីក្រុងស៊ាងហៃ ហើយបានបង្រួបបង្រួមគ្នាជាជាតិសាសន៍តែមួយ ដើម្បីប្រយុទ្ធប្រឆាំងតទល់នឹងការឈ្លានពានរបស់ចក្រភពជប៉ុន ពីឆ្នាំ១៩៣៧ រហូតដល់កងទ័ពជប៉ុន បានប្រកាសចុះចាញ់នៅឆ្នាំ ១៩៤៥នោះ

ក៏បានចាប់ផ្ដើមបង្ហូរឈាមពូជសាសន៍ឯងជាថ្មីម្ដងទៀត។

នៅឆ្នាំ១៩៤៩ កងទ័ពរំដោះប្រជាជនរបស់ចិន របស់ ម៉ៅ សេទុង ទទួលជ័យជម្នះឡើងគ្រប់គ្រងត្រួតត្រាចិនដីគោក និងបង្កើតរបបកុម្មុយនិស្ដមួយឱ្យឈ្មោះថា សាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៩ ។

នៅក្នុងខែធ្នូ ឆ្នាំ១៩៤៩ ជៀង កៃជៀក ដែលចាញ់សង្គ្រាមបាននាំកងទ័ពរត់ភៀសខ្លួនទៅនៅកោះតៃវ៉ាន់ ហើយបានប្រកាសយកទីក្រុងតៃប៉ិ ជារដ្ឋធានីបណ្ដោះអាសន្ន នៃសាធារណរដ្ឋចិន និងនៅតែអះអាងថា រដ្ឋាភិបាលរបស់គាត់ គឺជារដ្ឋាភិបាលស្របច្បាប់តែមួយគត់របស់ប្រទេសចិន។

នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៥០ ប្រធានាធិបតី ហារី អេស. ទ្រូម៉ាន់ (Harry S. Truman) បានប្រកាសថា សហរដ្ឋអាមេរិក នឹងមិនលូកដៃចូលក្នុងជម្លោះនៅច្រកសមុទ្រតៃវ៉ាន់ឡើយ ហើយសហរដ្ឋអាមេរិក នឹងមិនចូលធ្វើអន្តរាគមន៍ឡើយ ប្រសិនបើកោះតៃវ៉ាន់ ត្រូវទទួលរងនូវការវាយដណ្ដើមយកពីសាធារណរដ្ឋប្រជាមានិតចិន។

នៅដើមឆ្នាំ១៩៥០នោះដែរ កងទ័ពរំដោះប្រជាជនចិន(ចិនកុម្មុយនិស្ដ) បានបើកប្រតិបត្តិការវាយយកកោះសំខាន់ៗចំនួន៣ទៀតរបស់សាធារណរដ្ឋចិន (ចិនសេរី) ដែលមានទីតាំងនៅជិតចិនដីគោក ក្នុងនោះ កោះហៃណាំ កងទ័ពរំដោះប្រជាជនចិន ដណ្ដើមកាន់កាប់នៅក្នុងខែមេសា ឆ្នាំ១៩៥០, បន្ទាប់មក គឺកោះចូសាន ដណ្ដើមកាន់កាប់ក្នុងខែឧសភា ឆ្នាំ១៩៥០ និងទីប្រជុំកោះវ៉ានសាន ដណ្ដើមកាន់កាប់ក្នុងខែឧសភា–ខែសីហា ឆ្នាំ១៩៥០ ។

ក្រោយកងទ័ពចិនកុម្មុយនិស្ដបើកប្រតិបត្តិការវាយយកកោះសំខាន់ៗទាំង៣នេះមក អ្នកសង្កេតការណ៍ភាគច្រើន យល់ឃើញថា មិនយូរប៉ុន្មាន កងទ័ពចិនកុម្មុយនិស្ដ នឹងវាយដណ្ដើមយកកោះតៃវ៉ាន់ របស់ ជៀង កៃជៀក បន្តទៀតជាមិនខាន។ តែបន្ទាប់ពីសង្គ្រាមកូរ៉េផ្ទុះឡើងនៅក្នុងអំឡុងខែមិថុនា ឆ្នាំ១៩៥០ ប្រធានាធិបតី ហារី អេស. ទ្រូម៉ាន់ ក៏សម្រេចចិត្តបញ្ជូនកងនាវាចរណ៍ទី៧ ទៅច្រកសមុទ្រតៃវ៉ាន់ ដើម្បីប្រឆាំងទប់ទល់នឹងការ

រីកពាលដាលនៃលទ្ធិកុម្មុយនិស្តនៅអាស៊ី ដោយចូលធ្វើអន្តរាគមន៍ដោយផ្ទាល់ក្នុងការការពារកោះតៃវ៉ាន់ មិនឱ្យកងទ័ពចិនកុម្មុយនិស្តវាយដណ្តើមយករហូតដល់សព្វថ្ងៃនេះ។

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥០ សង្គ្រាមនៅឧបទ្វីបកូរ៉េ បានចាប់ផ្តើមឡើង ដោយមានសហភាពសូវៀត នៅពីក្រោយខ្នង កងទ័ពសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ (កូរ៉េខាងជើង) ប្រមាណ៧៥,០០០នាក់ បានឆ្លងខ្សែបន្ទាត់ស្របទី៣៨ ជាចំណុចខ័ណ្ឌចែកព្រំដែន សម្រុកចូលទៅក្នុងទឹកដីសាធារណរដ្ឋកូរ៉េ (កូរ៉េខាងត្បូង) ដែលមានសហរដ្ឋអាមេរិក ជាខ្នងបង្អែក។

មិនបាន២សប្តាហ៍ផង គឺនៅក្នុងខែកក្កដា សហរដ្ឋអាមេរិក បានបញ្ជូនកងទ័ពរបស់ខ្លួន និងកងទ័ពសម្ព័ន្ធមិត្តយ៉ាងច្រើនសន្ធឹកសន្ធាប់ មកជួយកូរ៉េខាងត្បូងផង និងធ្វើសង្គ្រាមប្រឆាំងនឹងរបបកុម្មុយនិស្តដោយផ្ទាល់ផង។ ពេលនោះ កងទ័ពរំដោះប្រជាជនចិន (ចិនកុម្មុយនិស្ត) ក៏បានចូលមកជួយសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ (កូរ៉េកុម្មុយនិស្ត)ដែរ។

បន្ទាប់ពីឆ្លងព្រំដែនវាយប្រយុទ្ធស៊ីសាច់ហុតឈាមគ្នាទៅវិញទៅមក ជាច្រើនលើក ហើយកងទ័ពទាំងសងខាង ត្រូវស្លាប់ពាយតែរៀងៗខ្លួនមក ភាគីទាំង២ ហាក់ដូចជា ខ្លាចរអាគ្នាទៅវិញទៅមក ការប្រយុទ្ធក៏បាននៅទ្រឹង។

ពេលនោះ សហរដ្ឋអាមេរិក បានប្រឹងប្រែងស្វែងរកបទឈប់បាញ់ក្នុងទម្រង់ណាមួយ ដើម្បីកុំឱ្យផ្ទុះសង្គ្រាមជាមួយសហភាពសូវៀតនិងចិន បន្តទៀត សង្គ្រាមលោកលើកទី៣ ប្រាកដជាកើតឡើងមិនខាន។ ទីបំផុត នៅខែ កក្កដា ឆ្នាំ១៩៥៣ សង្គ្រាមកូរ៉េ ក៏បានឈានដល់ទីបញ្ចប់ តាមរយៈបទឈប់បាញ់ ដោយមិនមានសន្ធិសញ្ញាបញ្ចប់សង្គ្រាមជាផ្លូវការណាមួយនោះឡើយ ហើយឧបទ្វីបកូរ៉េ នៅតែបែងចែកជាពីរ គឺសាធារណរដ្ឋប្រជាមានិតប្រជា-ធិបតេយ្យកូរ៉េ (កូរ៉េខាងជើង) និងសាធារណរដ្ឋកូរ៉េ (កូរ៉េខាងត្បូង) រហូតមកទល់សព្វថ្ងៃដដែល។

# ១៥៧
# គុយបា នៅក្បែរភៀកអាមេរិក ក្លាយជាប្រទេសកុម្មុយនិស្ត



**ហ្វីដែល កាស្ត្រូ ត្រូវចាប់ខ្លួននៅក្នុងឆ្នាំ១៩៥៣**

ហ្វីដែល កាស្ត្រូ (Fidel Castro) មានដើមកំណើតក្នុងត្រកូលគ្រួសារកសិករមួយ ជាជនជាតិអេស្ប៉ាញ មានជីវភាពធូរធារ។ គាត់បានទទួលយកគំនិតឆ្វេងនិយម និងប្រឆាំងចក្រពត្តិនិយមតាំងពីពេលគាត់កំពុងសិក្សាច្បាប់នៅសាកលវិទ្យាល័យហាវ៉ាន (Havana)។

នៅដើមទសវត្សរ៍ឆ្នាំ១៩៥០ នៅប្រទេសគុយបា អង្គការផ្សេងៗ រួមទាំងចលនាតស៊ូបះបោរប្រដាប់អាវុធមួយចំនួនត្រូវបានប្រជែងគ្នាបង្កើតឡើង ដើម្បីផ្លាស់ប្តូររបបនយោបាយដឹកនាំប្រទេស។

បន្ទាប់ពីបានចូលរួមក្នុងការបះបោរប្រឆាំងនឹងរដ្ឋាភិបាលស្តាំនិយមនៅសាធារណរដ្ឋដូមីនីកែន និងកូឡុំប៊ី មក នៅក្នុងឆ្នាំ១៩៥៣ ហ្វីដែល កាស្ត្រូ បានចូលរួមក្នុងការវាយប្រហារទៅលើបន្ទាយរដ្ឋាភិបាលមួយឈ្មោះម៉ុងកាដា (Moncada) ក្នុងបំណងផ្តួលរម្លំឧត្តមសេ-

នីយ៍ ហ្វូលហេ្សនស្យូ បាទីស្តា (Fulgencio Batista)ជាប្រធានាធិបតីគុយបា។

តែត្រូវបរាជ័យ ហើយគាត់ក៏ត្រូវកងទ័ពឧត្តមសេនីយ៍ ហ្វូលហេ្សនស្យូ បាទីស្តា ចាប់ខ្លួនបានផងដែរ។ បន្ទាប់ពីជាប់ពន្ធនាគារមួយឆ្នាំ នៅក្នុងឆ្នាំ១៩៥៤ គាត់បានធ្វើដំណើរទៅកាន់ប្រទេសម៉ិកស៊ិក ជាកន្លែងដែលគាត់បានបង្កើតចលនាតស៊ូមួយឈ្មោះថា ចលនាបដិវត្តន៍ថ្ងៃទី២៦ ខែកក្កដា។

នៅក្នុងឆ្នាំ១៩៥៦ ជាមួយនឹងកម្លាំងចំនួនតែ៨០នាក់ប៉ុណ្ណោះ ហ្វីដែល កាស្ត្រូ បានធ្វើដំណើរតាមនាវាមកដល់គុយបា ក្នុងគោលបំណងដឹកនាំការតស៊ូបន្តទៀត ដើម្បីផ្តួលរម្លំរបបផ្តាច់ការដឹកនាំដោយឧត្តមសេនីយ៍ ហ្វូលហេ្សនស្យូ បាទីស្តា (Fulgencio Batista) ដែលគាំទ្រដោយសហរដ្ឋអាមេរិក។ ត្រឹមតែរយៈពេល២ឆ្នាំប៉ុណ្ណោះ គឺនៅឆ្នាំ១៩៥៨ ចលនាបដិវត្តន៍២៦កក្កដា របស់ ហ្វីដែល កាស្ត្រូ បានក្លាយជាចលនាតស៊ូនាំមុខគេនៅគុយបា។

នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៩ កងទ័ពរបស់ហ្វីដែល កាស្ត្រូ បានចូលវាយដណ្តើមកាន់កាប់ក្រុងសានតាក្លារ៉ា ឧត្តមសេនីយ៍ ហ្វូលហេ្សនស្យូ បាទីស្តា (Fulgencio Batista) ជាប្រធានាធិបតីគុយបា និងគ្រួសារ ក៏នាំគ្នារត់គៀសខ្លួនទៅជ្រកកោននៅសាធារណរដ្ឋដូមីនីគែន។

ក្រោយពេលប្រទេសគុយបា ដែលនៅនឹងមាត់របងរបស់អាមេរិក ត្រូវបានពួកឧទ្ទាមកុម្មុយនិស្តឡើងកាន់អំណាច សហរដ្ឋអាមេរិក ដែលជាមហាអំណាចនាំមុខក្នុងការប្រឆាំងនឹងការរីករាលដាលលទ្ធិកុម្មុយនិស្តនៅទូទាំងពិភពលោក មានការអាម៉ាស់បំផុត។

ដើម្បីស្តារមុខមាត់ឡើងវិញ សហរដ្ឋអាមេរិក ព្យាយាមស្វែងរកគ្រប់វិធី ដើម្បីដណ្តើមយកអំណាចពីមេដឹកនាំកុម្មុយនិស្ត ហ្វីដែល កាស្ត្រូ វិញ។ ពួកភ្នាក់ងារចារកិច្ចសេអ៊ីអា (CIA) ក៏បានចាប់ផ្តើមប្រមែប្រមូលក្រុមប្រឆាំងពួកកុម្មុយនិស្តគុយបា ដែលកំពុងនិរទេសខ្លួនទៅរស់នៅលើទឹកដីអាមេរិក ឲ្យបង្កើតជារដ្ឋាភិបាលនិរទេសមួយ ព្រមទាំងបានជួយហ្វឹកហ្វឺននិងបំពាក់គ្រឿងសព្វាវុធដល់កងទ័ពរដ្ឋាភិបាលនិរទេសនោះ ដើម្បីត្រៀមវាយផ្តួលរម្លំរបបកុម្មុយនិស្តគុយបា នោះទៀតផង។ ពេលនោះ ពីមួយថ្ងៃទៅមួយថ្ងៃ ទំនាក់ទំនងរវាងអាមេរិក

និងគុយបា កាន់តែមានសភាពតានតឹងឡើងៗ រហូតដល់ ហ្វីដែល កាស្ត្រូ ភ្ជាប់ទំនាក់ទំនងការទូតជិតស្និទ្ធជាមួយសហភាពសូវៀត ហើយថែមទាំងបានបើកយុទ្ធនាការធ្វើជាតូបនីយកម្មក្រុមហ៊ុនបរទេសទាំងអស់ឲ្យទៅជារបស់រដ្ឋ ហើយបណ្តេញក្រុមហ៊ុនរកស៊ីធំៗរបស់អាមេរិកឲ្យឈប់រកស៊ីនៅក្នុងប្រទេសគុយបា ទៀតផង។

នៅខែមករា ឆ្នាំ១៩៦១ ស្ថិតក្រោមការដឹកនាំរបស់លោកប្រធានាធិបតី ចន អែហ្វ. កេណ្ណឌី (John F. Kennedy) សហរដ្ឋអាមេរិក មិនត្រឹមតែកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយគុយបា ប៉ុណ្ណោះទេ គឺថែមទាំងបានឱ្យពួកភ្នាក់ងារចារកិច្ចអាមេរិក សេអ៊ីអា (CIA) រៀបចំផែនការសម្ងាត់បំផុតមួយហៅថា "ការឈ្លានពាននៅឆកសមុទ្រជ្រូក " Bay of Pigs" ដោយសហការជាមួយកងទ័ពរដ្ឋាភិបាលនិរទេសរបស់គុយបា ដែលខ្លួនជួយបង្កើតឡើងនោះ ឱ្យបើកប្រតិបត្តិការចូលវាយផ្តួលរម្លំរបបកុម្មុយនិស្ត ហ្វីដែល កាស្ត្រូ ឆៅៗតែម្តង។

នៅយប់ថ្ងៃទី១៤ ឈានចូលថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៦១ យន្តហោះចម្បាំងអាមេរិកចំនួន ៨គ្រឿង ដែលត្រូវបានគេលាបពណ៌ទង់ជាតិរបស់រដ្ឋាភិបាលនិរទេសគុយបា បានបើកការវាយប្រហារទៅលើមូលដ្ឋានទ័ពអាកាសរបស់របបកុម្មុយនិស្ត ហ្វីដែល កាស្ត្រូ ដើម្បីជាការបើកផ្លូវឱ្យកងទ័ពជើងគោកវាយលុកចូលមកក្នុងប្រទេសគុយបា។

តែដោយសារផែនការសម្ងាត់នេះ ត្រូវភ្នាក់ងារចារកម្មរបស់របបកុម្មុយនិស្ត ហ្វីដែល កាស្ត្រូ និងភ្នាក់ងារចារកម្មកាហ្សេបេ (KGB) របស់សូវៀត ស៊ើបការណ៍ដឹងជាមុន ហ្វីដែល កាស្ត្រូ បានជម្លៀសយន្តហោះចម្បាំងទាំងអស់ ចេញពីមូលដ្ឋានទ័ពអាកាសនោះ ទើបមិនមានរងការខូចខាតអ្វីធំដុំឡើយ។

នៅយប់ថ្ងៃទី១៦ ឈានចូលថ្ងៃទី១៧ មេសា កងទ័ពរដ្ឋាភិបាលនិរទេសគុយបា មានគ្នាប្រមាណជា ១៥០០នាក់ បានបើកការវាយលុកចូលតាមឆកសមុទ្រជ្រូក "Bay of Pigs"។ តែប្រតិបត្តិការវាយលុកនេះ ក៏ត្រូវទទួលបរាជ័យដែរ ដោយត្រូវកងទ័ពរបស់ហ្វីដែល កាស្ត្រូ ឡោមព័ទ្ធជាប់នៅនឹងមាត់ឆ្នេរសមុទ្រនោះ ហើយត្រូវបង្ខំចិត្តទម្លាក់អាវុធចុះចាញ់។

បន្ទាប់មក ដោយសារការហ៊ុមព័ទ្ធសេដ្ឋកិច្ច និងការរំលោភឈ្លានពាន ព្រមទាំងផែនការ



**ហ្វីដែល កាស្ត្រូ ចុះព្រមព្រៀងជាមួយ នីគីតា គ្រូស្ចេវ ប្រឆាំងនឹងអាមេរិក**

ធ្វើឃាតមកលើរូបគាត់ពីសំណាក់សហរដ្ឋអាមេរិក ផងដែរ ហ្វីដែល កាស្ត្រូ ក៏បានរឹតចំណង មិត្តភាព និងសហប្រតិបត្តិការជាមួយសហភាពសូវៀត កាន់តែខ្លាំងឡើងៗថែមទៀត ដើម្បី ជាខ្នងបង្អែករបស់ខ្លួន។

នៅខែឧសភា ឆ្នាំ១៩៦២ ហ្វីដែល កាស្ត្រូ បានព្រមព្រៀងជាមួយ នីគីតា គ្រូស្ចេវ ប្រធានាធិបតីសហភាពសូវៀត ឱ្យដំឡើងមីស៊ីលបំពាក់ក្បាលគ្រាប់នុយក្លេអ៊ែរ នៅលើទឹក ដីគុយបា។

ការដំឡើងមីស៊ីលនុយក្លេអ៊ែរនៅគុយបានេះ គឺជាការឆ្លើយតបរបស់មេដឹកនាំសហភាព សូវៀត ទៅនឹងយុទ្ធសាស្ត្រនុយក្លេអ៊ែររបស់អាមេរិក ដែលកំពុងមានប្រៀបលើខ្លួន តាមរយៈ ការដាក់ពង្រាយមីស៊ីលនុយក្លេអ៊ែរនៅតាមបណ្ដាប្រទេសក្នុងតំបន់អឺរ៉ុបខាងលិច ផងដែរ។ គិតត្រឹមឆ្នាំ១៩៦១ មីស៊ីលជាង ១០០ដើម ត្រូវបានអាមេរិក ដំឡើងនៅក្នុងប្រទេសអ៊ីតាលី និងតួកគី ដោយមីស៊ីលនីមួយៗសុទ្ធតែអាចបំពាក់ក្បាលគ្រាប់នុយក្លេអ៊ែរ បាញ់ទៅដល់ទីក្រុង មូស្គូ។

ចំណែកសហភាពសូវៀតវិញ មានមីស៊ីលតែ ២០ដើមប៉ុណ្ណោះ ដែលអាចបំពាក់




**មីស៊ីលនុយក្លេអ៊ែរសូវៀត នៅគុយបា តម្រង់ទិសដៅទៅរកទីក្រុង៩ របស់អាមេរិក**

ក្បាលគ្រាប់នុយក្លេអ៊ែរ បាញ់ទៅលើទឹកដីសហរដ្ឋអាមេរិកបាន គឺជាមីស៊ីលអន្តរទ្វីប តែមិនសូវជាមានប្រសិទ្ធភាព ក្នុងការបាញ់ឲ្យចំគោលដៅ ដោយសារនៅពេលនោះ បច្ចេកវិទ្យាមីស៊ីលអន្តរទ្វីបរបស់សូវៀត មិនទាន់ជឿនលឿនគួរ ឲ្យទុកចិត្តបាន១០០% នៅឡើយ។ ដូច្នេះការដំឡើងមីស៊ីលនុយក្លេអ៊ែររយៈចម្ងាយមធ្យម នៅលើទឹកដីគុយបា ដែលនៅក្បែរសហរដ្ឋអាមេរិក គឺជាឱកាសល្អមួយដើម្បីសហភាពសូវៀត ស្វែងរកតុល្យភាពអាវុធនុយក្លេអ៊ែរជាមួយសហរដ្ឋអាមេរិក។

ហ្វីដែល កាស្ត្រូ យល់ថា ការដំឡើងមីស៊ីលនុយក្លេអ៊ែរ នៅលើទឹកដីគុយបា គឺជាមធ្យោបាយដ៏ល្អមួយ ដើម្បីកំញើញអាមេរិក កុំឲ្យឈ្លានពានមកលើគុយបាសាជាថ្មីម្តងទៀត។ ក៏ប៉ុន្តែ សម្រាប់សហរដ្ឋអាមេរិក វត្តមានមីស៊ីលនុយក្លេអ៊ែរសូវៀតនៅគុយបា ដែលមានចម្ងាយប្រមាណតែជាង១០០គីឡូម៉ែត្រ ពីរដ្ឋហ្វ្លរីដា (Florida) របស់ខ្លួននោះ គឺជាការគំរាមកំហែងដ៏ធំបំផុត សម្រាប់សន្តិសុខជាតិរបស់អាមេរិក ដូច្នេះ អាមេរិកត្រូវតែប្រើគ្រប់មធ្យោបាយទាំងអស់ ដើម្បីកម្ចាត់ចោល។

ទីបំផុត វិបត្តិមីស៊ីលនៅគុយបាក៏បានផ្ទុះឡើង បង្កឲ្យមានការប្រឈមមុខដាក់គ្នាខាងផ្នែកយោធាយ៉ាងខ្លាំងបំផុត រហូតស្ទើរតែនឹងផ្ទុះទៅជាសង្គ្រាមនុយក្លេអ៊ែរ នៅខែតុលា ឆ្នាំ១៩៦២។

# ១៥៨
# សម្ព័ន្ធភាព និងការបែកបាក់គ្នារវាងសូវៀត និងចិន



**មេដឹកនាំកុម្មុយនិស្តចិន ម៉ៅ សេទុង និងមេដឹកនាំសូវៀត ចូសេហ្វ ស្តាលីន**

នៅថ្ងៃទី២ ខែមីនា ឆ្នាំ១៩១៩ សហភាពសូវៀត បានបង្កើតអង្គការមួយឱ្យឈ្មោះថា កុម្មុយនិស្តអន្តរជាតិ ហៅកាត់ថា"កូមីនទែន" (Comintern= Communist international)ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយ និងគាំទ្រដល់ចលនាតស៊ូរបស់បដិវត្តសង្គមនិយម នៅតាមបណ្តាប្រទេសនានាជុំវិញពិភពលោក ឱ្យទទួលបានជោគជ័យដូចបដិវត្តន៍រុស្ស៊ី ខែតុលា ឆ្នាំ១៩១៧ ដែរ។

ដោយសារមានការជួយជ្រោមជ្រែងគ្រប់បែបយ៉ាងពីអង្គការកុម្មុយនិស្តអន្តរជាតិ ហៅកាត់ថា "កូមីនទែន"នេះហើយ ទើបចលនាតស៊ូរបស់បក្សកុម្មុយនិស្តចិន (Chinese Communist Party) បានជោគជ័យ ហើយ ម៉ៅ សេទុង បានប្រកាសបង្កើតសាធារណរដ្ឋ

របត់នយោបាយ

ប្រជាមានិតចិន ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៩ នៅឯទីលានធានអានមេន។

នៅក្នុងឆ្នាំ១៩៤៩នោះដែរ អគ្គលេខាបក្សកុម្មុយនិស្តចិន ម៉ៅ សេទុង និងអគ្គលេខាបក្សកុម្មុយនិស្តសហភាពសូវៀត ចូសេហ្វ ស្តាលីន បានចុះហត្ថលេខាលើសន្ធិសញ្ញាទ្វេភាគីមួយ ហៅថាសន្ធិសញ្ញាមិត្តភាព រួមបញ្ចូលទាំងសម្ព័ន្ធភាពយោធាដែលតម្រូវ ឱ្យភាគីសងខាងអាចសុំជំនួយពីគ្នាទៅវិញទៅមក ប្រសិនបើប្រទេសទាំង២ ត្រូវរងការវាយប្រហារណាមួយពីខាងក្រៅ ព្រមទាំងសម្ព័ន្ធភាពជាជំនួយផ្នែកសេដ្ឋកិច្ច និងធនធានមនុស្សផងដែរ។

ក្រោយពេលអគ្គលេខាបក្សកុម្មុយនិស្ត ចូសេហ្វ ស្តាលីន (Joseph Stalin) ទទួលមរណភាពថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៥៣ នៅក្នុងវ័យ៧៣ឆ្នាំ ដោយជំងឺបែកសរសៃឈាម និងហូរឈាមក្នុងខួរក្បាលខាងឆ្វេងមក ការប្រជែងដណ្តើមអំណាចគ្នានៅក្នុងជួរគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តសូវៀត បានកើតមានឡើងយ៉ាងជូរចត់បំផុត។

នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៥៦ នៅក្នុងសមាជគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តសូវៀត លើកទី២០ នីគីតា គ្រូស្ចូវ (Nikita Khrushchev) លេខាបក្សទីក្រុងមូស្គូ ដែលមិនពេញចិត្តការដឹកនាំរបស់ ចូសេហ្វ ស្តាលីន (Joseph Stalin)ពីមុនមកនោះ បានឡើងថ្លែងសុន្ទរកថាបរិហារពីការគាបសង្កត់ និងការបោសសម្អាតរបស់ស្តាលីន ពេលនៅកាន់អំណាច ហើយសមាជិកសមាជបក្សភាគច្រើនបានសម្តែងការគាំទ្រចំពោះគាត់។

នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៥៣ នីគីតា គ្រូស្ចូវ (Nikita Khrushchev) ត្រូវបានជ្រើសតាំងជាអគ្គលេខាគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តសូវៀត ។ ក្រោយពេលបានឡើងកាន់តំណែងកំពូលនេះមក នីគីតា គ្រូស្ចូវ ដែលចាត់ទុកខ្លួនឯងថា ជាជនកុម្មុយនិស្តស្មោះត្រង់ចំពោះមេដឹកនាំលេនីន បានចោទប្រកាន់ ស្តាលីន ថា ដឹកនាំប្រទេសខុសទ្រឹស្តីកុម្មុយនិស្ត ដែលលេនីន ជាអ្នកបង្កើតឡើង ហើយគាត់មានតួនាទីជាអ្នកធ្វើកំណែទម្រង់នយោបាយ សេដ្ឋកិច្ច និងយោធា ដែលបន្សល់ទុកពីរបបស្តាលីន កន្លងមកនោះ។

ជាមួយគ្នានោះ ពួកកម្មាភិបាលជាន់ខ្ពស់មួយចំនួនដែលធ្លាប់ជិតស្និទ្ធជាមួយស្តាលីន ដូចជា បេរីយ៉ា ជាដើម ក៏គ្រូស្ចូវ ឱ្យគេកាត់ទោសប្រហារជីវិត ហើយបើមានកម្មាភិបាល



**នីគីតា គ្រូស្ឆេវ ជួបពិភាក្សាជាមួយប្រធានាធិបតី ចន អែហ្វ. កេណ្ណឺឌី ឆ្នាំ១៩៦១**

ជាន់ខ្ពស់ ណាហ៊ានរិះគន់គាត់ ក៏ត្រូវបណ្តេញចេញពីតំណែងដែរ។

មិនតែប៉ុណ្ណោះ សូម្បីតែសពស្តាលីន ដែលតម្កល់ទុកនៅទីលានក្រហម ក៏គាត់ឱ្យគេយកចេញដែរ ហើយអ្វីៗជាសម្បត្តិរបស់រដ្ឋដែលដាក់ឈ្មោះស្តាលីន ក៏គាត់ឱ្យគេប្តូរឈ្មោះថ្មី ឬដាក់ឈ្មោះដូចដើមវិញទាំងអស់។ អ្នកទោសនៅសម័យសង្គ្រាម ជាពិសេសជនជាតិភាគតិចដែលនិរទេសមកពីតំបន់អាស៊ី ត្រូវដោះលែងឱ្យមានសេរីភាព វិលមកកាន់ប្រទេសកំណើតវិញ។

ពេលនោះ ម៉ៅ សេទុង យល់ថា ការលុបបំបាត់ទ្រឹស្តីស្តាលីន ជាការគំរាមកំហែងប្រជាប្រិយភាពរបស់គាត់ជាមេដឹកនាំបក្សកុម្មុយនិស្តចិន ដែលតែងតែប្រកាសពីជំហរគាំទ្រទ្រឹស្តីស្តាលីន នេះ តាំងពីដើមមក។

## របត់នយោបាយ

នៅពេល នីគីតា គ្រូស្ចេវ (Nikita Khrushchev)ចេះតែបន្តប្រឆាំង និងរិះគន់ទ្រឹស្តីស្តាលីន មិនឈប់ឈរ ពេលនោះ ម៉ៅ សេទុង យល់ឃើញថា នីគីតា គ្រូស្ចេវ ធ្វើឱ្យបាត់បង់ស្នាដៃដ៏ត្រចះត្រចង់ និងកិត្យានុភាពរបស់ទ្រឹស្តីលទ្ធិកុម្មុយនិស្ត ដែលបង្កើតឡើងដោយ ចូសេហ្វ ស្តាលីន (Joseph Stalin)។

ម្យ៉ាងវិញទៀត នីគីតា គ្រូស្ចេវ បានដាក់ចេញគោលនយោបាយថ្មីដែលហៅថា"ការរួមរស់ដោយសន្តិភាព(Peaceful coexistence)" គឺត្រូវសហប្រតិបត្តិការជាមួយបស្ចិមប្រទេសទៀតនោះ ធ្វើឱ្យ ម៉ៅ សេទុង កាន់តែក្តៅក្រហាយខ្លាំងឡើងៗ។ ម៉ៅ សេទុង យល់ឃើញថា សហភាពសូវៀត ជាខ្នងបង្អែករបស់លទ្ធិកុម្មុយនិស្ត ប៉ុន្តែបែរជាបន្ទន់ជង្គង់ជាមួយលោកខាងលិចទៅវិញ។ ឯសាធារណរដ្ឋប្រជាមានិតចិន មានគោលនយោបាយប្រយុទ្ធប្រឆាំងពួកមូលធននិយម និងជួយឧបត្ថម្ភគាំទ្រដល់ចលនាបដិវត្តកុម្មុយនិស្តនិយម ទូទាំងពិភពលោក មិនមែនត្រូវរួមរស់ដោយសន្តិភាពជាមួយពួកលោកខាងលិច ឡើយ។

ម្យ៉ាងទៀត បញ្ហាជម្លោះព្រំដែនរវាងចិន និងឥណ្ឌា កាន់តែធ្វើឱ្យចិន មានការព្រួយបារម្ភ ដោយហេតុថា សហភាពសូវៀត មិនត្រឹមតែមិនបានជួយខ្លួននោះទេ ប៉ុន្តែសហភាពសូវៀត បែរជាមានទំនាក់ទំនងល្អ ហើយចាំជួយប្រទេសឥណ្ឌា ពីក្រោយខ្នងទៅវិញ។

អ្វីដែលធ្វើឱ្យចិននិងសហភាពសូវៀត បែកបាក់គ្នាខ្លាំងថែមទៀតនោះ គឺនៅឆ្នាំ១៩៦៤ ម៉ៅ សេទុង បានប្រកាសថា សហភាពសូវៀត នៅតែកាន់កាប់ទឹកដីចិន ដែលខ្លួនបានលួចយកមុនបដិវត្តន៍ ខែតុលា ឆ្នាំ១៩១៧នោះ បន្តទៀតដដែល។ គាត់បានដកឯកអគ្គរដ្ឋទូតចិនពីទីក្រុងមូស្គូ ហើយកាត់ផ្តាច់ទំនាក់ទំនងការទូត ព្រមទាំងបានឃោសនាប្រឆាំងសូវៀត យ៉ាងពេញទំហឹងតែម្តង។

ម៉ៅ សេទុង បានចាត់ទុកមេដឹកនាំសហភាពសូវៀត នីគីតា គ្រូស្ចេវ (Nikita Khrushchev)ជាពួកសេរីនិយម តាំងពីពេលនោះមក។

# ១៥៩
# អ្វីទៅដែលហៅថា វៀតមិញ ?



**កងទ័ពវៀតមិញ**

ក្រោយពេលប្រទេសវៀតណាម ត្រូវបានដាក់បញ្ចូលជាប្រទេសអាណានិគមបារាំង នៅក្នុងឆ្នាំ១៨៨៧ អ្នកដឹកនាំចលនាតស៊ូដើម្បីឯករាជ្យវៀតណាមដំបូង គឺជាបញ្ញវន្តម្នាក់ ឈ្មោះ ផាន បូយចូវ ( Phan Bội Châu )។ ក្នុងអំឡុងពេលទៅសិក្សានៅប្រទេសជប៉ុន គាត់ឃើញប្រទេសជប៉ុន មានការរីកចម្រើន ហើយអាចទប់ទល់នឹងមហាអំណាចអាណានិគមអឺរ៉ុប ទៀតផង គាត់ក៏បានបង្កើតអង្គការរំដោះជាតិ នៅឯប្រទេសជប៉ុន នោះ។

តែដោយសារបារាំង ដាក់សម្ពាធ ជប៉ុនក៏តម្រូវឱ្យ ផាន បូយចូវ ទៅរស់នៅប្រទេសចិន។ ក្រោយពេលមករស់នៅប្រទេសចិន ផាន បូយចូវ ទទួលបានបទពិសោធពីបដិវត្តន៍ជាតិនិយមរបស់ ស៊ុន យ៉ាតសេន គាត់ក៏រៀបចំបង្កើតចលនាបដិវត្តន៍មួយនៅទីក្រុង ក្វាងចូវ។

តែគាត់ត្រូវបានរដ្ឋាភិបាលចិន ដែលជាអ្នកបង្ក្រាបបដិវត្តន៍ជាតិនិយមរបស់ ស៊ុន យ៉ាតសេន ចាប់ដាក់គុកពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៧។ នៅឆ្នាំ១៩២៥ គាត់ត្រូវភ្នាក់ងារបារាំង



ផាន បូយចូវ

នៅទីក្រុងស៊ាងហៃ បញ្ជូនឱ្យត្រលប់មកវៀត-ណាមវិញ ដើម្បីកាត់ទោស។

ដោយសារគាត់មានប្រជាប្រិយភាពខ្លាំងពេក តុលាការបារាំងមិនហ៊ានកាត់ទោសប្រហារជីវិតគាត់ឡើយ តែបានឃុំខ្លួនគាត់ឱ្យនៅតែក្នុងគេហដ្ឋានអស់មួយជីវិត រហូតដល់គាត់ទទួលមរណភាពនៅក្នុងឆ្នាំ១៩៤០។

ក្រោយពីប្រទេសអាល្លឺម៉ង់ ជាសម្ព័ន្ធមិត្តវាយដណ្តើមកាន់កាប់ប្រទេសបារាំង នៅខែកញ្ញា ឆ្នាំ១៩៤០ កងទ័ពជប៉ុន ក៏បានវាតទីចូលមកឈ្លានពានតំបន់ឥណ្ឌូចិន ដែលបារាំង កំពុងត្រួតត្រា ។ តែជប៉ុន មិនដណ្តើមអំណាចពីរដ្ឋបាលអាណានិគមបារាំង ដើម្បីត្រួតត្រាទេ គឺគ្រាន់តែយកតំបន់ឥណ្ឌូចិន បោះទីតាំងកងទ័ព និងជាកន្លែងសម្រាប់ផ្គត់ផ្គង់ស្បៀងតែប៉ុណ្ណោះ។

ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៤១ ជាខួបឆ្នាំទី៥១ នៃថ្ងៃកំណើតរបស់ ហូ ជីមិញ ដោយមានជំនួយពីកងទ័ពសហរដ្ឋអាមេរិក និងកងទ័ពសាធារណរដ្ឋចិន (ចិនជាតិនិយម)ផងដែរ ង្វៀន អាយគួក មេដឹកនាំបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលទើបតែដូរឈ្មោះមកជា ហូ ជីមិញ បានរួបរួមជាមួយចលនាជាតិនិយមវៀតណាម និងចលនាតស៊ូវៀតណាមមួយចំនួនទៀត ដោយមិនគិតពីនិន្នាការនយោបាយអ្វីទាំងអស់ បង្កើតចលនាតស៊ូមួយឈ្មោះ វៀតមិញ (Việt Minh) មានឈ្មោះពេញថា វៀតណាម ដុក ឡឹប ដុង មិញ (Việt Nam độc lập đồng minh)ប្រែជាភាសាខ្មែរថា៖ "សម្ព័ន្ធដើម្បីឯករាជ្យវៀតណាម" ក្នុងគោលបំណងដើម្បីរើបម្រះបះបោរប្រឆាំងនឹងកងទ័ពជប៉ុន ចូលមកកាន់កាប់តំបន់ឥណ្ឌូចិន។



**ហូ ជីមិញ និងវ៉ូ ង្វៀនយ៉ាប់ ជាមួយកងទ័ពអាមេរិក និងកងទ័ពចិនជាតិនិយម**

ចលនាតស៊ូវៀតមិញនេះ បានបង្កើតឡើងនៅភូមិប៉ាក់ប (Pac Bó) ជាភូមិតូចមួយនៅក្នុងខេត្ត កាវ បាង (Cao Bằng) ភាគខាងជើងប្រទេសវៀតណាម មានចម្ងាយតែ៣គីឡូម៉ែត្រប៉ុណ្ណោះពីព្រំដែនចិន។ នៅក្បែរភូមិនេះ មានរូងភ្នំមួយឈ្មោះ ហាង កុក.ប (Hang Cốc Bó) ជារូងភ្នំដែល ហូ ជីមិញ រស់នៅរយៈពេល៧សប្តាហ៍ ក្នុងអំឡុងពីខែកុម្ភៈ ដល់ខែមីនា ឆ្នាំ១៩៤១ បន្ទាប់ពីត្រលប់ពីការនិរទេសខ្លួនរយៈពេល៣០ឆ្នាំរបស់គាត់។

នៅក្នុងខែមីនា ឆ្នាំ១៩៤៥ កងទ័ពជប៉ុន ដែលចូលមកឈរជើងនៅឧបទ្វីបឥណ្ឌូចិន បានបើកយុទ្ធការចាប់ខ្លួនមន្ត្រីបារាំង ទាំងយោធា និងស៊ីវិលទាំងអស់ ដើម្បីដណ្តើមអំណាចពីបារាំង យកមកគ្រប់គ្រងដោយខ្លួនឯងវិញ។

កាលនោះ ប្រធានាធិបតីអាមេរិក ហ្វ្រង់គ្លីន រូស្វែល (Franklin Roosevelt) បានបញ្ជាក់ប្រាប់មេដឹកនាំចិន ជៀង កៃជៀក យ៉ាងច្បាស់ថា នៅពេលចប់សង្គ្រាម (សង្គ្រាមលោកលើកទី២) បារាំង នឹងមិនអាចគ្រប់គ្រងឧបទ្វីបឥណ្ឌូចិន បន្តទៅទៀតបានទេ ដូច្នេះ សាធារណរដ្ឋចិន គួរតែដាក់ឧបទ្វីបឥណ្ឌូចិនឱ្យនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ពេលនោះ ជៀង កៃជៀក បានតបមកវិញថាៈ " ឧបទ្វីបឥណ្ឌូចិន អាចនឹងក្លាយមកជារបស់ចិន មែនឬមិនមែន គឺអាស្រ័យលើកាលៈទេសៈប៉ុណ្ណោះ" ។ ប៉ុន្តែ បន្ទាប់ពីមរណភាពរបស់ប្រធានាធិបតី



**ជៀង កៃជៀក, ហ្វ្រង់គ្លីន រូស្វែល និងនាយករដ្ឋមន្ត្រីអង់គ្លេស វីនស្តុន ឆឺឈីល**

ហ្វ្រង់គ្លីន រូស្វែល (Franklin Roosevelt) នៅខែមេសា ឆ្នាំ១៩៤៥មក ការប្រឆាំងរបស់សហរដ្ឋអាមេរិក ពីបញ្ហាបារាំង គ្រប់គ្រងនៅឧបទ្វីបឥណ្ឌូចិន ក៏បានចុះខ្សោយ វិញ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៤៥ មេដឹកនាំចលនាជាតិនិយមវៀតណាម ម្នាក់ឈ្មោះ ចឹន ចុងគីម (Trần Trọng Kim) ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី របស់វៀតមិញ ឬសម្ព័ន្ធដើម្បីឯករាជ្យវៀតណាម។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៤៥ ហូ ជីមិញ មេដឹកនាំចលនាវៀតមិញ បានរៀបចំកិច្ចប្រជុំមួយដើម្បីធ្វើការតស៊ូបះបោរជាទូទៅ ហៅថាបដិវត្តន៍ខែតុលា ព្រមទាំងបង្កើតទង់ជាតិ បទភ្លេងជាតិរបស់ខ្លួន និងជ្រើសរើសសមាសភាពគណៈកម្មាធិការជាតិមួយ ដើម្បីរំដោះប្រទេសវៀតណាម។ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៤៥ ហូ ជីមិញ ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី ជំនួស ចឹន ចុងគីម នោះវិញ។

ក្រោយពីជប៉ុន បានទទួលចុះចាញ់ ហើយសង្គ្រាមលោកលើកទី២ត្រូវបានបញ្ចប់ នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ កងទ័ពវៀតមិញ បានចូលកាន់កាប់ទីក្រុងហាណូយ និង

ប្រកាសបង្កើតរបបសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ នោះដែរ ដោយមាន ហូ ជីមិញ ជានាយករដ្ឋមន្ត្រី ។

រយៈពេលពីរបីថ្ងៃក្រោយ ជៀង កៃជៀក មេដឹកនាំសាធារណរដ្ឋចិន បានបញ្ជាឱ្យឧត្តមសេនីយ៍ លូ ហាន នាំកងទ័ព ចំនួន២០០,០០០នាក់ ចូលទៅភាគខាងជើងវៀតណាម ដើម្បីត្រួតពិនិត្យ និងទទួលយកការសុំចុះចាញ់របស់កងទ័ពជប៉ុន។

នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៤៥ កងទ័ពអង់គ្លេសមួយក្រុមដំបូង បានមកដល់ទីក្រុងសៃហ្គន (វៀតណាមភាគខាងត្បូង) ដើម្បីបើកផ្លូវឱ្យបារាំង ចូលមកគ្រប់គ្រងដែនដីឥណ្ឌូចិន ជាថ្មីម្តងទៀត។

រយៈពេល២ថ្ងៃ គឺនៅថ្ងៃទី១៨ និងថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៥ មេដឹកនាំវៀតមិញ បានបើកកិច្ចចរចាសម្ងាត់ ជាមួយមេដឹកនាំចលនាតស៊ូជាតិនិយមវៀតណាម ហៅកាត់ថា វៀតកាច់ (Việt Cách) និងចលនាតស៊ូវៀតណាម មួយទៀតឈ្មោះ វៀតគួក (Việt Quốc) ។

ក្នុងកិច្ចប្រជុំនេះ ហូ ជីមិញ បានឯកភាពយល់ព្រមបង្រួបបង្រួមបង្កើតរដ្ឋាភិបាល ដឹកនាំដោយពួកវៀតមិញ ដែលទទួលបានការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងនយោបាយពីសាធារណរដ្ឋចិន តាមសំណើរបស់ចលនាតស៊ូវៀតកាច់ (Việt Cách) និងវៀតគួក (Việt Quốc)។

តែ វ៉ ង្វៀនយ៉ាប់ បានលើកហេតុផលថា សំណើនេះមិនមានសុពលភាពគួរឱ្យទុកចិត្តបាននោះទេ ព្រោះវាប្រៀបបានដូចជាយើងរត់គេចផុតពីបារាំង បានហើយ បែរជាមកនៅជ្រកកោនជាមួយចិន ទៅវិញ។ ប៉ុន្តែ កម្មាភិបាលជាន់ខ្ពស់វៀតមិញ ឈ្មោះ ហ័ង មិញជាម មានគំនិតផ្ទុយពី វ៉ ង្វៀនយ៉ាប់ ដោយបានលើកហេតុផលថា ការបង្រួបបង្រួមវៀតមិញ ជាមួយចលនាជាតិនិយមវៀតណាម ទាំង២នេះ អាចកាត់បន្ថយគូប្រជែង និងអ្នកប្រឆាំង ហើយម្យ៉ាង ទៀតវានឹងជួយឱ្យវៀតមិញ មានអំណាចកាន់តែខ្លាំងជាងមុនទៅទៀត។

តែក្រោយពីការចរចាសម្ងាត់នោះ ពួកមេដឹកនាំវៀតមិញ បានឯកភាពគ្នាសម្រេចថា មិនបង្រួបបង្រួមជាមួយចលនាតស៊ូជាតិនិយមវៀតណាម ទាំង២នោះទេ។

## របត់នយោបាយ

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៤៥ ដោយមានការគាំទ្រពីមេបញ្ជាការអង់គ្លេស នៅសៃហ្គន (ព្រៃនគរ) អាជ្ញាធរបារាំង បានប្រកាសត្រួតត្រាឧបទ្វីបឥណ្ឌូចិន ឡើងវិញ ហើយមានបំណងផ្តួលរម្លំរបបសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង)ផងដែរ។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៤៦ ហូ ជីមិញ បានរៀបចំការបោះឆ្នោតសភាជាលើកដំបូង និងអនុម័តរដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ផងដែរ។

ពេលនោះ ចលនាតស៊ូវៀតកាច់ (Việt Cách)និងវៀតគួក (Việt Quốc) ដែលក្លាយទៅជាគណបក្សប្រឆាំងទៅហើយ បានធ្វើពហិការមិនចូលរួមក្នុងការបោះឆ្នោតសភានោះទេ។

ទីបំផុត បេក្ខជនភាគច្រើនមកពីគ្រប់វណ្ណៈ សាសនា និងក្រុមជនជាតិ មិនមែនជាសមាជិកវៀតមិញ ត្រូវជាប់ឆ្នោតនៅក្នុងរដ្ឋសភាជាតិដំបូងនោះ។ តែទោះបីយ៉ាងណា ក្រោយការបោះឆ្នោតនោះ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៤៦ រដ្ឋាភិបាលចម្រុះមួយ មានហូ ជីមិញជានាយករដ្ឋមន្ត្រីត្រូវបានបង្កើតឡើង ហើយបេក្ខជនម្នាក់ ដែលឈរឈ្មោះជាឯកក្កនាម (គ្មានគណបក្ស) ឈ្មោះហ៊្វីញ ធូកខាង (Huỳnh Thúc Kháng) ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ពីថ្ងៃទី៣១ ខែឧសភា ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៤៦ នាយករដ្ឋមន្ត្រី ហូ ជីមិញចាកចេញពីប្រទេស ទៅចរចានៅប្រទេសបារាំង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហ៊្វីញ ធូកខាង (Huỳnh Thúc Kháng) ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីស្តីទី។ ប៉ុន្តែទោះបី ហូ ជីមិញចំណាយពេលប្រមាណ៥ខែ ដើម្បីស្វះស្វែងរកដំណោះស្រាយបញ្ហាអនាគតរបស់វៀតណាមជាមួយមេដឹកនាំបារាំង យ៉ាងណា ក៏មិនបានទទួលលទ្ធផលអ្វីដែរ ព្រោះ បារាំង បានឱ្យឥណ្ឌូចិនទាំងមូល ក្លាយជាសហព័ន្ធមួយ ស្ថិតនៅក្រោមការត្រួតត្រារបស់ខ្លួនដដែល។

ក្រោយពីកងទ័ពសាធារណរដ្ឋចិន ត្រូវបានដកចេញពីទឹកដីវៀតណាមភាគខាងជើងនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៤៦ វ៉ ង្វៀនយ៉ាប់ មានផែនការថ្មីមួយ គឺឱ្យពួកវៀតមិញ របស់គាត់ឡើងទៅដឹកនាំរបបសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ផ្តាច់មុខតែឯង។

# ១៦០
# សង្គ្រាមឥណ្ឌូចិនលើកទី១



វ៉ ង្វៀនយ៉ាប់ មេបញ្ជាការកងទ័ពវៀតមិញ

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៤៦ សង្គ្រាមរវាងកងទ័ពបារាំង និងវៀតមិញ ក៏បានផ្ទុះឡើងជាទ្រង់ទ្រាយធំ។ ក្រុមប្រវត្តិវិទូបានកំណត់ថា ជាថ្ងៃចាប់ផ្តើមសង្គ្រាមឥណ្ឌូចិនលើកទី១។

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៤៦ កងនាវាបារាំង បានបើកការបាញ់ប្រហារមកលើផ្នែកមួយនៃទីក្រុងហៃហ្វុង ក្នុងរយៈវេលាតែមួយរសៀលប៉ុណ្ណោះ បណ្តាលឱ្យជនស៊ីវិលប្រមាណ ៦,០០០ នាក់បានស្លាប់ ។ កងទ័ពវៀតមិញ ក៏បានយល់ព្រមឈប់បាញ់ភ្លាមៗ ហើយក៏បាននាំគ្នាចាកចេញពីទីក្រុង។

មិនយូរប៉ុន្មាន ឧត្តមសេនីយ៍ វ៉ ង្វៀនយ៉ាប់ ក៏បានលើកទ័ពចំនួន ៣០,០០០ នាក់

មកវាយប្រហារដើម្បីដណ្ដើមយកទីក្រុងហៃហ្វុង វិញ។ ទោះបីជាបារាំង មានចំនួនទ័ពតិចជាងក៏ដោយ តែបារាំង មានអាវុធទំនើបៗ និងកងទ័ពជើងទឹកដ៏ខ្លាំងពូកែ ក៏បានធ្វើឱ្យការវាយតបតរបស់កងទ័ពវៀតមិញ ទទួលបរាជ័យ។

នៅអំឡុងខែធ្នូ ឆ្នាំ១៩៤៦ ហូ ជីមិញ និងមេដឹកនាំវៀតមិញផ្សេងៗទៀត ព្រមទាំងកងទ័ព ត្រូវបង្ខំចិត្តភៀសខ្លួនចេញទីក្រុងហាណូយ ចូលទៅក្នុងតំបន់ព្រៃភ្នំ ដើម្បីបន្តការតស៊ូប្រឆាំងនឹងបារាំង បន្តទៀត។

នៅក្នុងឆ្នាំ១៩៤៧ បារាំងបានបញ្ជូនកងទ័ពទៅវាយប្រហារមូលដ្ឋានទ័ពរបស់ឧត្ដមសេនីយ៍ វ៉ ង្វៀនយ៉ាប់ នៅតំបន់ព្រៃភ្នំក្នុងខេត្តទ្វៀនក្វាង (Tuyen Quang) តែគាត់មិនឱ្យកងទ័ពគាត់ប្រយុទ្ធតទល់នឹងបារាំងឡើយ គឺគ្រប់ទីតាំងដែលកងទ័ពបារាំង បានចូល ទៅដល់កងទ័ពវៀតមិញ តែងតែដកថយពីទីតាំងរបស់ខ្លួន។

នៅចុងឆ្នាំ១៩៤៧ បារាំងបានបើកប្រតិបត្តិការវាយប្រហារទៅលើទីតាំងលាក់ខ្លួនរបស់មេដឹកនាំវៀតមិញ តែពួកគេមិនអាចចាប់ខ្លួន ហូ ជីមិញ និងមេដឹកនាំសំខាន់ៗ របស់ពួកវៀតមិញ បានឡើយ។ តែយ៉ាងណា បារាំងក៏បានអះអាងថា កងទ័ពវៀតមិញប្រមាណ ៩០០០ នាក់ត្រូវបានសម្លាប់នៅក្នុងការបើកប្រតិបត្តិការសឹកនេះ។

នៅក្នុងឆ្នាំ១៩៤៨ បារាំង បានរកមធ្យោបាយបង្កើតរដ្ឋាភិបាលផ្សេងមួយទៀត នៅសៃហ្គន(ព្រៃនគរ) ដើម្បីប្រឆាំងនឹងវៀតមិញ ដោយបានចរចាជាមួយអតីតព្រះចៅអធិរាជបាវដាយ ដើម្បីឱ្យទ្រង់ចូលដឹកនាំរដ្ឋវៀតណាម(វៀតណាម ភាគខាងត្បូង)។

នៅក្នុងឆ្នាំ១៩៤៩ បារាំង បានទទួលស្គាល់រដ្ឋវៀតណាម ក្រោមការដឹកនាំរបស់របស់ស្ដេច បាវដាយ ថា ជារដ្ឋឯករាជ្យមួយ នៅក្នុងសហភាពបារាំង ដូចប្រទេសកម្ពុជា និងឡាវ ដែរ។

ពេលនោះ ពួកវៀតមិញ ប្រកាសមិនទទួលស្គាល់ឯករាជ្យនោះឡើយ ព្រោះបារាំងនៅតែគ្រប់គ្រងលើកិច្ចការបរទេស និងយោធាដដែល។ តែយ៉ាងណា បារាំងបានជួយបង្កើតអង្គភាពកងទ័ពវៀតណាម ដែលមានមេបញ្ជាការជាជនជាតិវៀតណាម ជាច្រើនអង្គភាព

ដើម្បីត្រៀមប្រយុទ្ធជាមួយវៀតមិញ ផងដែរ។

បន្ទាប់ពីបង្កើតរបបសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៩ មក ពួកវៀតមិញ កាន់តែមានទំនាក់ទំនងជិតស្និទ្ធខ្លាំងឡើងៗ ជាមួយពួកកុម្មុយនិស្តចិន។

ពួកកុម្មុយនិស្តចិន ក៏បានគាំទ្រពួកវៀតមិញ ក្នុងការធ្វើសង្គ្រាមប្រឆាំងនឹងបារាំង ព្រមទាំងផ្តល់ជំនួយគ្រឿងសព្វាវុធ និងគ្រឿងផ្គត់ផ្គង់ផ្សេងៗទៀតជាច្រើន។

ដោយសារជំនួយនេះ ឧត្តមសេនីយ៍ វ៉ូ ង្វៀនយ៉ាប់ បានរៀបចំកងទ័ពវៀតមិញ ចំនួន ៥កងពល គឺ កងពលលេខ៣០៤ កងពលលេខ៣០៨ កងពលលេខ៣១២ កងពលលេខ ៣១៦ និងកងពលលេខ៣២០។

ក្រោយពីឧត្តមសេនីយ៍ វ៉ូ ង្វៀនយ៉ាប់ លើកទ័ពវាយប្រហារទៅលើមូលដ្ឋានទ័ពបារាំង នៅតាមបណ្តោយព្រំដែនចិន សហរដ្ឋអាមេរិក ក៏ចាប់ផ្តើមលូកដៃចូលក្នុងសង្គ្រាមនេះដែរ តាមរយៈការផ្តល់ជំនួយជាគ្រឿងសព្វាវុធ និងអ្នកសង្កេតការណ៍ដល់បារាំង។

នៅក្នុងខែមករា ឆ្នាំ១៩៥០ សាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋសង្គមនិយម សហភាពសូវៀត ប្រកាសទទួលស្គាល់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យ របស់ហូ ជីមិញ នៅវៀតណាមភាគខាងជើង។ ចំណែកសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស ក៏ ប្រកាសទទួលស្គាល់រដ្ឋាភិបាលនៃរដ្ឋវៀតណាម របស់ស្តេច បាវដាយ នៅវៀតណាម ភាគ ខាងត្បូង ដែរ។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៥០ កងទ័ពវៀតមិញ បានបើកការវាយប្រហារទៅលើបន្ទាយ ទាហានបារាំង នៅឡៃខេ ជាប់ព្រំដែនចិន ចាប់បានទាហានបារាំង ចំនួន ១៥០នាក់។

នៅក្នុងខែមិថុនា ឆ្នាំ១៩៥០ សង្គ្រាមនៅឧបទ្វីបកូរ៉េ ក៏បានផ្ទុះឡើងរវាងពួកកុម្មុយនិស្ត កូរ៉េខាងជើង គាំទ្រដោយសាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋសង្គមនិយមសហ-ភាពសូវៀត ជាមួយកូរ៉េខាងត្បូង គាំទ្រដោយសហរដ្ឋអាមេរិក និងប្រទេសសមាជិកមួយចំនួន នៃអង្គការសហប្រជាជាតិ។

សង្គ្រាមត្រជាក់ក៏ចាប់ក្តៅខ្លាំងឡើងៗ សហរដ្ឋអាមេរិក មានការព្រួយបារម្ភខ្លាចពួក

# របត់នយោបាយ

កុម្មុយនិស្តចូលគ្រួតត្រាតំបន់នៅអាស៊ីបូព៌ាទាំងមូល ដែលធ្វើឲ្យមានផលប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍របស់ខ្លួន សហរដ្ឋអាមេរិក ក៏កាន់តែលូកដៃជ្រៅទៅៗក្នុងការប្រឆាំងនឹងពួកវៀតមិញ ដែលជាពួកកុម្មុយនិស្ត។

នៅថ្ងៃទី១៨ ខែកញ្ញា កងទ័ពវៀតមិញ ដឹកនាំដោយឧត្តមសេនីយ៍ទោ ថាយ (Thái) វាយដណ្ដើមបានទីតាំងទាហានបារាំង នៅតំបន់ដុងខេ (Đông Khê) ហើយបានវាយស្ទាក់កងកម្លាំងជំនួយបារាំង មកពីកាវបាង(Cao Bằng) និងមកពី ថាត់ខេ(That Khe) ធ្វើឱ្យកងកម្លាំងជំនួយទាំង២អង្គភាពនេះ បាក់ទ័ពរត់គេចទៅភាគខាងត្បូង វិញអស់។ សមរភូមិនេះ ត្រូវបានគេស្គាល់ជាទូទៅថា សមរភូមិផ្លូវអាណានិគមលេខ៤។

ពេលនោះ កងទ័ពអាកាសបារាំង បានទម្លាក់កងវរសេនាធំឆត្រយោង នៅភាគខាងត្បូងកាវបាង(Cao Bằng) ដើម្បីជួយអន្តរាគមន៍ដែរ ប៉ុន្តែកងទ័ពឆត្រយោងទាំងអស់នោះក៏បាននាំគ្នារត់គេចខ្លួនពីការវាយប្រហាររបស់កងទ័ពវៀតមិញ ទៀតដែរ។ បន្ទាប់មក កងកម្លាំងបារាំង នៅឡាងសឺន (Lạng Sơn) ក៏បានដកថយទៀត ព្រោះខ្លាចកងទ័ពវៀតមិញ ចូលមកសម្លាប់ពួកគេ។

នៅពេលពួកទាហានបារាំង បាក់ទ័ពបានមកដល់ទីសុវត្ថិភាពនៅតំបន់ដីសណ្ដទន្លេក្រហម ពួកគេក៏បានធ្វើការប៉ាន់ប្រមាណថា កងទ័ពបារាំង ដែលត្រូវវៀតមិញចាប់បាន ត្រូវបាត់ខ្លួន និងត្រូវស្លាប់ មានចំនួន៤,៨០០នាក់ ហើយក្នុងចំណោមទាហានសរុបជាង ១០,០០០នាក់ ត្រូវរងរបួសចំនួន២,០០០នាក់ទៀត។ ជាមួយគ្នានោះ ទាហានបារាំង ត្រូវបាត់បង់អាវុធនិងគ្រឿងសម្ភារសឹកជាច្រើនទៀត ដូចជា៖ កាំភ្លើងធំចំនួន ១៣ដើម, កាំភ្លើងត្បាល់ចំនួន ១២៥ដើម, រថយន្តធំសម្រាប់ដឹកជញ្ជូនចំនួន ៤៥០គ្រឿង, កាំភ្លើងយន្តចំនួន ៩៤០ដើម, កាំភ្លើងយន្តធុនស្រាលចំនួន១,២០០ដើម និងកាំភ្លើងវែងធម្មតាចំនួន៨,០០០ដើម ។

នៅក្នុងឆ្នាំ១៩៥០ ត្រូវបានគេកត់សម្គាល់ថា ជាឆ្នាំដំបូងបង្អស់ដែលគ្រាប់បែកណាប៉ាល់ ត្រូវបានសហរដ្ឋអាមេរិក ផ្ដល់ឱ្យកងជើងអាកាសបារាំង ប្រើប្រាស់នៅក្នុងប្រទេសវៀតណាម ។




**គំនូសព័ណ៌ប្រផេះ ជាខ្សែក្រវាត់ដឺ ឡាត្រ** (De Lattre Line) **របស់បារាំង**

ក្រោយពីបរាជ័យយ៉ាងអាម៉ាស់នេះមក មេបញ្ជាការថ្មីរបស់បារាំង ប្រចាំឥណ្ឌូចិន ឧត្តមសេនីយ៍ ហ្សង់ ម៉ារី ដឺ ឡាត្រ ដឺតាស៊ីញី (Jean Marie de Lattre de Tassigny) បានកសាងខ្សែក្រវាត់ការពារដ៏រឹងមាំបំផុតមួយ ហៅថាខ្សែក្រវាត់ដឺ ឡាត្រ(De Lattre Line) ដើម្បីទប់ទល់ និងងាយស្រួលក្នុងវាយបកទៅលើពួកវៀតមិញ វិញ។

នៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៥១ ឧត្តមសេនីយ៍ វ៉ូ ង្វៀនយ៉ាប់ បានបញ្ជូនកងពលលេខ៣០៨ និងកងពលលេខ៣១២ មានកម្លាំងសរុបជាង ២ម៉ឺននាក់ ទៅវាយប្រហារក្រុងវិញអៀន( Vĩnh Yên) ដែលមានចម្ងាយប្រមាណ៣២គីឡូម៉ែត្រ ពីភាគពាយ័ព្យនៃទីក្រុងហាណូយ។ តែពេលនោះ កងទ័ពវៀតមិញ បានដើរចូលអន្ទាក់របស់កងទាហានបារាំង ដែលបំពាក់ដោយកាំភ្លើងយន្ត និងកាំភ្លើងធំនៅកណ្តាលវាល។

ការវាយប្រយុទ្ធគ្នាបាន៣ថ្ងៃប៉ុណ្ណោះ គឺត្រឹមថ្ងៃទី១៦ ខែមករា កងកម្លាំងវៀតមិញ



**ឧត្តមសេនីយ៍ផ្កាយ៥**
**ហ្សង់ ម៉ារី ដឺ ឡាត្រ ដឺតាស៊ីញី**

ត្រូវបាត់បង់ជីវិតចំនួន៦,០០០នាក់, រង របួសចំនួន ៨,០០០នាក់ និងប្រមាណ ៥០០នាក់ទៀត ត្រូវពួកបារាំង ចាប់ខ្លួនបាន។

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥១ ដើម្បីជាការសងសឹក ឧត្តមសេនីយ៍ វ៉ង្វៀនយ៉ាប់ បានបញ្ជាឱ្យកងទ័ពវៀតមិញ ប្រមាណ ១១,០០០នាក់ បើកការវាយប្រហារទៅលើក្រុងម៉ៅ ឃេ ( Mạo Khê ) ដែលមានចម្ងាយប្រមាណ៣២គីឡូម៉ែត្រ ពីភាគខាងជើងក្រុងហៃហ្វុង។ តែលទ្ធផល គឺបរាជ័យដូចមុនដដែល ដោយ កងទ័ពវៀតមិញ ត្រូវបានដកថយ។ លើកនេះ កងទ័ពវៀតមិញ បានអះអាងថា កងទ័ពខ្លួនត្រូវ បាត់បង់ជីវិតចំនួនពី៥០០នាក់ តែបើតាមការប៉ាន់ស្មានរបស់ភាគីបារាំងថា កងទ័ពវៀតមិញ ត្រូវបាត់បង់ ជីវិតទៅដល់៣,០០០នាក់។

ទោះបីត្រូវបរាជ័យផ្ទួនៗគ្នាយ៉ាងណា នៅថ្ងៃទី២៩ ខែឧសភា ឧត្តមសេនីយ៍ វ៉ង្វៀនយ៉ាប់ បានបញ្ជាឱ្យកងពលធំលេខ៣០៤ វាយប្រហារទៅលើទាហានបារាំង នៅភូលី ( Phủ Lý )។ បន្ទាប់មក ឱ្យកងពលធំលេខ៣០៨ វាយប្រហារទៅលើទាហានបារាំង នៅនិញប៊ិញ ( Ninh Bình ) ហើយឲ្យកងពលធំលេខ៣២០ ធ្វើការវាយលុកនៅផាត់ យៀម ( Phát Diệm ) ភាគខាងត្បូងនៃក្រុងហាណូយ។

តែការវាយប្រហារទៅលើទីតាំងទាហានបារាំងទាំងបីកន្លែងនេះ ត្រូវបរាជ័យទាំងអស់ ជាពិសេស នៅផាត់យៀម ត្រូវទទួលបរាជ័យធ្ងន់ជាងគេ។ ដោយមានឱកាសល្អ ឧត្តមសេ-

នីយ៍បារាំង ហ្សង់ ម៉ារី ដឺ ឡាត្រ ដឺតាស៊ីញី (Jean Marie de Lattre de Tassigny) បានបន្តវាយរុញច្រានកងកម្លាំងវៀតមិញ ដែលនៅសេសសល់ ឱ្យចូលទៅក្នុងព្រៃជ្រៅ និងចេញពីតំបន់ដីសណ្តទន្លេក្រហម អស់ត្រឹមថ្ងៃទី១៨ ខែមិថុនា។ គិតពីខែកញ្ញា ឆ្នាំ១៩៥០ មកដល់ត្រឹមថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៥១ កងទ័ពវៀតមិញ ត្រូវបាត់បង់ជីវិត សរុបប្រមាណ ១០,០០០ នាក់។



**ឧត្តមសេនីយ៍ផ្កាយ៥ រ៉ាអ៊ូ សាឡង់**

នៅថ្ងៃទី៣១ ខែកក្កដា ឧត្តមសេនីយ៍បារាំងម្នាក់ឈ្មោះ ហ្សាល ឆានសុន (Charles Chanson) ត្រូវបានគេលួចធ្វើឃាតនៅឯក្រុងសាដែក (Sa Đéc)នៅវៀតណាមខាងត្បូង ខណៈគាត់ពេលកំពុងធ្វើការឃោសនា។ បារាំងបានចោទប្រកាន់វៀតមិញ ថានៅពីក្រោយខ្នងរឿងឃាតកម្មនេះ ក៏ប៉ុន្តែ អ្នកខ្លះបានចោទទៅលើអ្នកជាតិនិយម ការវដាយមួយរូប ឈ្មោះជិញ មិញថេ (Trình Minh Thế)ថា អាចជាប់ពាក់ព័ន្ធក្នុងរឿងឃាតកម្មនេះ។

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៥១ កងឆត្រយោងបារាំង បានចុះកាន់កាប់ខេត្តហ័របិញ (Hòa Bình) ដែលមានចម្ងាយ៤០គីឡូម៉ែត្រពីភាគខាងលិចនៃខ្សែក្រវាត់ការពារដឺឡាត្រ(De Lattre)។

នៅក្នុងខែមករា ឆ្នាំ១៩៥២ ឧត្តមសេនីយ៍ ហ្សង់ ម៉ារី ដឺ ឡាត្រ ដឺតាស៊ីញី(Jean Marie de Lattre de Tassigny)ធ្លាក់ខ្លួនឈឺដោយសារជំងឺមហារីក ត្រូវវិលត្រលប់ទៅប្រទេសបារាំង វិញ ដើម្បីព្យាបាល ហើយគាត់ក៏បានស្លាប់នៅប្រទេសបារាំង នោះទៅ។ ឧត្តមសេនីយ៍ រ៉ាអ៊ូល សាឡង់ (Raoul Salan) ត្រូវបានតែងតាំងជាមេបញ្ជាការកងទ័ព

បារាំងនៅឥណ្ឌូចិន ជំនួស។ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៥២ កងទ័ពវៀតមិញ បានបើកការវាយប្រហារដណ្តើមយកខេត្តហ័របិញ វិញ បង្ខំឱ្យកងទ័ពបារាំង រត់ដកថយទៅនៅត្រឹមខ្សែក្រវាត់ការពារដឺឡាត្រ (De Lattre) របស់ខ្លួនវិញ ។ ក្នុងការវាយប្រយុទ្ធគ្នានេះ ភាគីទាំងពីរបានបាត់បង់ជីវិតកងទ័ពជិត ៥,០០០នាក់ តែរៀងៗខ្លួន។

ចាប់ពីពេលនោះមក ការវាយប្រយុទ្ធគ្នាជាទ្រង់ទ្រាយធំ មិនកើតមានទៀតទេ ដោយគ្រាន់តែមានការវាយធ្មក់ខ្លះៗប៉ុណ្ណោះ ព្រោះភាគីទាំងសងខាងកំពុងត្រៀមកម្លាំងដើម្បី បើកប្រតិបត្តិការសឹកជាទ្រង់ទ្រាយធំនៅពេលខាងមុខ ជាថ្មីម្តងទៀត។

នៅថ្ងៃទី២ ខែតុលា ឆ្នាំ១៩៥២ នៅសមរភូមិណាសាន មេបញ្ជាការបារាំង បានចាប់ផ្តើមប្រើយុទ្ធសាស្ត្រ"កាំប្រមា" ធ្វើយ៉ាងណា ឱ្យកងទ័ពវៀតមិញ ដែលប្រើយុទ្ធសាស្ត្រទ័ពព្រៃនោះ ចេញមកវាយប្រយុទ្ធគ្នានៅទីវាលវិញ ។

នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៥២ ឧត្តមសេនីយ៍ វ៉ ង្វៀនយ៉ាប់ បានផ្តើមបើកការវាយប្រហារទៅលើកងទ័ពបារាំង នៅក្រុងងាឡូ (Nghĩa Lộ) នៅភាគពាយ័ព្យនៃទីក្រុងហាណូយ និងជ្រលងដងទន្លេខ្មៅ។ ប៉ុន្តែ គាត់មិនវាយប្រហារទៅលើអាកាសយានដ្ឋានណាសាន (Nà Sản)ជាកន្លែងមានកងទ័ពបារាំងច្រើននោះទេ។

មិនយូរប៉ុន្មាន កងទ័ពវៀតមិញ បានគ្រប់គ្រងទឹកដីភាគច្រើននៃតំបន់តុងកឹង ហើយហួសពីខ្សែក្រវាត់ការពារដឺ ឡាត្រ (De Lattre) របស់បារាំង ទៅទៀត។ ដោយដឹងខ្លួនថាកំពុងតែចាញ់ប្រៀបកងទ័ពវៀតមិញ ឧត្តមសេនីយ៍រ៉ាអ៊ូ សាឡង់ (Raoul Salan) ក៏បានផ្តើមប្រតិបត្តិការសឹកឡូរ៉េន(Lorraine) នៅតាមដងទន្លេឃ្លៀរ (Clear River) ដើម្បីបង្ខំឱ្យកងទ័ពវៀតមិញ បន្ថយការវាយប្រហារមកលើបន្ទាយងាឡូ(Nghĩa Lộ) ។

នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៥២ បារាំង បានប្រតិបត្តិការដ៏ធំមួយ រួមមានទាហានចំនួន ៣០,០០០នាក់ ឆ្លងខ្សែក្រវាត់ការពារដឺ ឡាត្រ(De Lattre)របស់ខ្លួន ទៅវាយប្រហារកន្លែងស្តុកព័ស្តុការរបស់វៀតមិញ នៅខេត្តភូអៀន(Phú Yên)។ នៅថ្ងៃទី៥ ខែវិច្ឆិកា ទាហានបារាំង វាយដណ្តើមបានខេត្តភូ.ថ (Phú Thọ) នៅថ្ងៃទី៩ ខែវិច្ឆិកា កងឆត្រយោងបារាំង

វាយដណ្តើមបានខេត្តភូយាន់(Phu Doan) និងនៅថ្ងៃទី១៣ ខែវិច្ឆិកា វាយដណ្តើមបានខេត្តភូអៀន(Phú Yên) មកវិញ។

ពេលទាហានបារាំង បើកការវាយប្រហារនោះ ដំបូងឧត្តមសេនីយ៍ វ៉ ង្វៀនយ៉ាប់ ប្រើកលល្បិចមិនទប់ទល់ទេ គឺរង់ចាំរហូតទាហានបារាំង ចូលមកដល់ក្នុងតំបន់ដែលគាត់គ្រប់គ្រង ទើបគាត់វាយកាត់ផ្តាច់ទាហានបារាំង ជាកង់ៗតែម្តង។

ភ្លាមៗ ក្រោយពីស្មានដឹងពីកលល្បិចរបស់ វ៉ ង្វៀនយ៉ាប់ នេះមក នៅថ្ងៃទី១៤ ខែវិច្ឆិកា ឧត្តមសេនីយ៍ រ៉ាអ៊ូល សាឡង់ (Raoul Salan) ក៏បានបញ្ជាឱ្យទាហានគាត់ដកថយទៅខ្សែក្រវាត់ការពារដឺ ឡាត្រ(De Lattre)របស់គាត់វិញដែរ។ តែពេលកំពុងដកថយនោះក្នុងថ្ងៃទី១៧ ខែវិច្ឆិកា កងទ័ពវៀតមិញ បានលួចវាយឆ្មក់មកលើកងពលបារាំង នៅចាន់មឿង(Chan Muong) ធ្វើឱ្យទាហានបារាំង ត្រូវបាត់បង់ជីវិតជាច្រើន។

ក្នុងពេលបើកប្រតិបត្តិការឡ័ររ៉ែន (Lorraine) នេះ បារាំង ត្រូវបាត់បង់ជីវិតទាហានប្រមាណ១,២០០នាក់ ក្នុងនោះ ភាគច្រើន ត្រូវបាត់បង់ជីវិតនៅចាន់មឿង (Chan Muong)។

នៅខែឧសភា ឆ្នាំ១៩៥៣ នាយឧត្តមសេនីយ៍ ហង់រី ណាវ៉ា(Henri Navarre) ជាមេបញ្ជាការជាន់ខ្ពស់ថ្មីនៃកងទ័ពបារាំងនៅឥណ្ឌូចិន ដែលមកជំនួសឧត្តមសេនីយ៍ រ៉ាអ៊ូល សាឡង់ (Raoul Salan) បានធ្វើការរាយការណ៍ទៅរដ្ឋាភិបាលបារាំង ថា៖ "...មិនមានលទ្ធភាពអាចឈ្នះសង្គ្រាមនៅឥណ្ឌូចិន បានទេ ហើយអ្វីដែលយើងអាចរំពឹងបាននោះ គឺមានតែការទប់ទល់នៅនឹងកន្លែងប៉ុណ្ណោះ" ។

នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៥៤ កងទ័ពវៀតមិញ គាំទ្រដោយសាធារណរដ្ឋប្រជាមានិតចិន និងសហភាពសូវៀត បានបើកការវាយប្រហារទៅលើបន្ទាយឌៀនបៀនភូ ជាទីតាំងទាហានសហភាពបារាំង ធំជាងគេនៅឥណ្ឌូចិន។

សមរភូមិឌៀនបៀនភូ ជាសមរភូមិសំខាន់ជាងគេ និងជាសមរភូមិចុងក្រោយរវាងទាហានបារាំង និងកងទ័ពវៀតមិញ បានបញ្ចប់នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ ១៩៥៤ ពោលគឺក្នុងរយៈពេលតែ១ខែ ៣សប្តាហ៍ និង៣ថ្ងៃប៉ុណ្ណោះ ទាហានបារាំង ប្រមាណ២,២០០នាក់



**នាយឧត្តមសេនីយ៍ ហង់រី ណាវ៉ា**

បានបាត់បង់ជីវិត ក្នុងចំណោមទាហានសរុប ២០,០០០នាក់, ទាហានចំនួន ១,៧២៩នាក់ត្រូវបានរាយការណ៍ថាបាត់ខ្លួន និងចំនួន ១១,៧២១នាក់ទៀតត្រូវបានចាប់ខ្លួនដោយកងទ័ពវៀតមិញ។

ចំណែកកងទ័ពវៀតមិញ ជាអ្នកទទួលជ័យជម្នះវិញ ក្នុងចំណោមទាហានដែលបានចូលរួមប្រយុទ្ធចំនួន៥០,០០០នាក់ មានប្រមាណ ពី៤,៨០០ ទៅ ៨,-០០០នាក់ បានបាត់បង់ជីវិត ហើយពី៩,០០០ ទៅ១៥,០០០ នាក់ទៀត ត្រូវរងរបួស។

សង្គ្រាមឥណ្ឌូចិនលើកទី១ ដែលចាប់ផ្ដើមផ្ទុះឡើងពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៤៦ ត្រូវបានបញ្ចប់នៅថ្ងៃទី៧ ខែ ឧសភា ឆ្នាំ១៩៥៤ គឺត្រូវបញ្ចប់ត្រឹមថ្ងៃដែលបារាំង ចាញ់សង្គ្រាមនៅសមរភូមិឌៀនបៀនភូ នេះតែម្តង។

ជ័យជម្នះរបស់វៀតមិញនៅឌៀនបៀនភូ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់លទ្ធផលនៃសន្និសញ្ញាទីក្រុងហ្សឺណែវ ដែលបានប្រព្រឹត្តឡើងពីថ្ងៃទី២៦ ខែមេសា ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ ។

នៅសន្និសីទក្រុងហ្សឺណែវនោះ ពួកកុម្មុយនិស្តបានទាមទារឱ្យប្រទេសកម្ពុជា វៀត-ណាម និងឡាវ បែងចែកទឹកដីជាពីរ គឺម្ខាងជាពួកសេរី និងម្ខាងទៀតជាពួកកុម្មុយនិស្ត ។ តែគណៈប្រតិភូកម្ពុជា ដឹកនាំដោយរដ្ឋមន្ត្រីការបរទេស ទេព ផន រួមមាន សម សារី, នង គឹមនី និងសឺន សាន ជាសមាជិក បានតវ៉ាយ៉ាងស្វិតស្វាញមក ប្រទេសកម្ពុជា រួចផុតពីការបែងចែកប្រទេសជាពីរ។ ជាមួយគ្នានោះ កិច្ចព្រមព្រៀងក្រុងហ្សឺណែវ បានសម្រេចឱ្យកងទ័ព



**ឈ្លើយសឹកបារាំង នៅសមរភូមិឌៀនបៀនភូ**

កុម្មុយនិស្តវៀតមិញ ដកចេញពីប្រទេសកម្ពុជា ឡាវ និងវៀតណាមខាងត្បូង ទៅវៀតណាមខាងជើងវិញ ក្នុងនោះក៏មានកងទ័ពខ្មែរកុម្មុយនិស្ត(ខ្មែរវៀតមិញ) ជាង១,០០០នាក់ទៅជាមួយផង។

# ១៦១
# អ្វីទៅដែលហៅថា វៀតកុង ?



**កងទ័ពវៀតកុង**

ក្រោយកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ខែកក្កដា ឆ្នាំ១៩៥៤ ពួកកម្មាភិបាល និងកងទ័ពកុម្មុយនិស្តវៀតមិញ ចំនួនប្រមាណ៩០,០០០នាក់ត្រូវដកចេញពីប្រទេសវៀតណាមខាងត្បូង ឡាវ និងកម្ពុជា ទៅវៀតណាមខាងជើង វិញ។ តែពួកគេចំនួន៥,០០០ ទៅ១០,០០០នាក់ បានបន្តរស់នៅភាគខាងត្បូង ហើយពួកគេភាគច្រើនបានបង្កប់ខ្លួនជាមួយប្រជាជននៅតាមភូមិស្រុក ដើម្បីធ្វើសកម្មភាពបដិវត្តន៍បន្តទៀត។

ពួកគេបានបង្កើតអង្គការស្របច្បាប់ពីរគឺ៖ គណៈកម្មាធិការសន្តិភាពសៃហ្គន-ចឹឡឹង (Saigon-Cholon) និង"គណៈកម្មាធិការប្រតិបត្តិនៃរណសិរ្សមាតុភូមិ" ដែលមានទំនាក់ទំនង

ជាមួយនិកាយ ហ័រហាវ ឬ "សមាគមពុទ្ធសាសនាវៀតណាម-កម្ពុជា" ដើម្បីធ្វើសកម្មភាពតស៊ូសម្ងាត់ ។

កាលពីពេលប្រជុំសន្និសីទក្រុងហ្សឺណែវ ពីថ្ងៃទី២៦ ខែមេសា ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ ពួកកុម្មុយនិស្តវៀតណាម បានស្នើសុំឲ្យបក្សកុម្មុយនិស្តចិន ជួយខ្លួនក្នុងការពង្រឹងសន្តិភាពនៅភាគខាងជើង ការកសាងកងទ័ព ការកែទម្រង់ដីធ្លី ការកែទម្រង់បក្ស ការពង្រីកការងារទូត ការធ្វើអភិបាលកិច្ចទីក្រុង និងស្តារសេដ្ឋកិច្ចឡើងវិញ។ ឆ្លើយតបចំពោះសំណើនេះ ចិនបានបញ្ជូនអនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ហ្វាង យី ឲ្យដឹកនាំក្រុមជំនាញការសេដ្ឋកិច្ចចិនមួយក្រុម ទៅជួយវៀតណាមខាងជើង។

នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៥៥ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន បានសម្រេចចាប់ផ្តើមដកពួកទីប្រឹក្សាយោធារបស់ខ្លួន ពីប្រទេសវៀតណាមខាងជើង ជាបណ្តើរៗ រហូតដល់ពាក់កណ្តាលខែមីនា ឆ្នាំ១៩៥៦ ទើបដកពួកទីប្រឹក្សាចិនអស់ ហើយបានដាក់ក្រុមជំនាញការយោធាមួយក្រុមតូច ដឹកនាំដោយឧត្តមសេនីយ៍ វ៉ាង យ៉ានក្វាន់ (Wang Yan quan) ទៅជួយកងទ័ពវៀតណាមខាងជើង ជំនួសវិញ។

នៅខែកក្កដា ឆ្នាំ១៩៥៥ នាយករដ្ឋមន្ត្រីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម (Ngô Đình Diệm) ដែលមិនព្រមចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ បានប្រកាសថា គាត់មិនចូលរួមក្នុងការបោះឆ្នោតដោយសេរី ដើម្បីបង្រួបបង្រួមវៀតណាមខាងត្បូង និងខាងជើង ក្រោមលក្ខខណ្ឌឱ្យមានការបោះឆ្នោតនៅក្នុងទឹកដីកាន់កាប់ដោយពួកកុម្មុយនិស្តនោះទេ។

នៅក្នុងខែឧសភា ឆ្នាំ១៩៥៥ នៅក្នុងទីក្រុងសៃហ្គន កម្លាំងយោធាឯករាជ្យមួយមានឈ្មោះថា ប៊ិញ ស្វៀន(Bình Xuyên) មានកងទ័ពថ្មើរជើងចំនួន៥ វរសេនាតូច និងកងសន្តិសុខ ចំនួន២កងវរសេនាតូច ដឹកនាំដោយឧត្តមសេនីយ៍ ឡេ វ៉ាន់វៀង (Lê Văn Viễn) ហៅ បាយ វៀង(Bảy Viễn)។

កម្លាំងយោធាឯករាជ្យមួយនេះ ពីមុនធ្លាប់រស់នៅក្រៅច្បាប់ ហើយក៏ធ្លាប់សហការ



ឡេ យន់ និងភរិយា

គ្នាជាមួយពួកវៀតមិញ ដែរនោះ បាន ប៉ុនប៉ងធ្វើរដ្ឋប្រហារដណ្តើមអំណាចពី នាយករដ្ឋមន្ត្រី ង៉ូ ឌិញយៀម ដែរ។ តែ ត្រូវបានឧត្តមសេនីយ៍ យឿង វ៉ាន់មិញ (Dương Văn Minh) ជាមេទ័ពរបស់ ង៉ូ ឌិញយៀម ដឹកនាំកម្លាំងទៅបង្ក្រាបឱ្យ បរាជ័យទៅវិញ ក្នុងរយៈពេលដ៏ខ្លីបំផុត។

ក្រោយទទួលបរាជ័យ ឧត្តមសេ-នីយ៍ ឡេ វ៉ាន់វៀង បាននិរទេសទៅរស់នៅ ទីក្រុងប៉ារីស ប្រទេសបារាំង។ ចំណែក កូនប្រុសរបស់គាត់ម្នាក់ឈ្មោះ ឡេ ប៉ូល (Lê Paul) ជាអ្នកបញ្ជាក្នុងការវាយប្រហារជាមួយ កងទ័ពឧត្តមសេនីយ៍ យឿង វ៉ាន់មិញនោះ ត្រូវចាប់ខ្លួនបាន។ បន្ទាប់មក ឡេ ប៉ូល ត្រូវបាន គេសម្លាប់យ៉ាងឃោរឃៅបំផុត បន្ទាប់ពីឧត្តមសេនីយ៍ យឿង វ៉ាន់មិញ ទាមទារថ្លៃលោះពី ឡេ វ៉ាន់វៀង ជាឪពុកដែលរស់នៅប្រទេសបារាំង នោះ មិនបានដូចបំណង។

នៅដើមឆ្នាំ១៩៥៦ ក្រោយពី ង៉ូ ឌិញយៀម បានបង្ក្រាបចលនាហ័រហាវ ឬ "សមាគម ពុទ្ធសាសនាវៀតណាម-កម្ពុជា" និងនិកាយសាសនាសកម្មប្រយុទ្ធផ្សេងទៀត ដែលជាបណ្តាញ តស៊ូរបស់ពួកកុម្មុយនិស្តវៀតណាមខាងជើង ដោយជោគជ័យបន្តទៀតនោះ គាត់បានបង្វែរ ការយកចិត្តទុកដាក់របស់គាត់ ចំពោះការបង្ក្រាបចលនាកុម្មុយនិស្តនៅវៀតណាម ខាងត្បូង កាន់តែខ្លាំងឡើងៗ។

ដោយសារជោគជ័យ នៃយុទ្ធនាការបង្ក្រាបចលនាតស៊ូរបស់កុម្មុយនិស្តនេះ ក្នុងខែ ឧសភា ឆ្នាំ១៩៥៧ នៅពេលទៅទស្សនកិច្ចនៅសហរដ្ឋអាមេរិក ប្រធានាធិបតីអាមេរិក ដ្វៃត៍ ឌី. អែសិនហាវវើ (Dwight D. Eisenhower) បានចាត់ទុក ង៉ូ ឌិញយៀម ថាជា "វីរជន" ម្នាក់។

នៅខែមីនា ឆ្នាំ១៩៥៦ ឡេ យន់ (Lê Duẩn) មេដឹកនាំកុម្មុយនិស្តវៀតណាមភាគខាងត្បូង បានបង្ហាញផែនការធ្វើសកម្មភាពបះបោរមួយដែលគាត់ឱ្យឈ្មោះថា "ផ្លូវទៅកាន់ភាគខាងត្បូង" ដល់សមាជិកការិយាល័យនយោបាយរបស់គណៈកម្មាធិការមជ្ឈិមបក្សពលករវៀតណាម ផ្សេងទៀត នៅទីក្រុងហាណូយ។ គាត់បានប្រកាសយ៉ាងម៉ឺងម៉ាត់ថា ការធ្វើសង្គ្រាមជាមួយសហរដ្ឋអាមេរិក គឺជាការចាំបាច់ ដើម្បីសម្រេចបាននូវការបង្រួបបង្រួម ទឹកដីវៀតណាម។ ប៉ុន្តែ នៅពេលសាធារណរដ្ឋប្រជាមានិតចិន និងសហភាពសូវៀត មានការបែកបាក់ មិនសូវចុះសម្រុងគ្នា ផែនការរបស់ ឡេ យន់ ត្រូវបានការិយាល័យនយោបាយរបស់គណៈកម្មាធិការមជ្ឈិមបក្សពលករវៀតណាម ច្រានចោល។

នៅពេលជម្លោះបែកបាក់ រវាងសាធារណរដ្ឋប្រជាមានិតចិន និងសហភាពសូវៀត កាន់តែរីកធំឡើង ក្នុងខែធ្នូ ឆ្នាំ ១៩៥៦ បក្សពលករវៀតណាម បានសម្រេចឱ្យចាប់ផ្តើមធ្វើសកម្មភាពបះបោរឡើងវិញនៅវៀតណាមភាគខាងត្បូង ជាបណ្តោះអាសន្នប៉ុណ្ណោះ។ ពេលនោះ ផែនការ"ផ្លូវទៅកាន់ភាគខាងត្បូង" របស់ ឡេ យន់ សម្រាប់ធ្វើសកម្មភាពបដិវត្តន៍នៅវៀតណាមភាគខាងត្បូង ត្រូវបានអនុម័តជាគោលការណ៍។

ក្នុងរយៈពេលធ្វើសកម្មភាពបះបោរឡើងវិញ នៅវៀតណាមភាគខាងត្បូង ជាបណ្តោះអាសន្ននេះ ពួកគេត្រូវស្វែងរកការគាំទ្រពីអន្តរជាតិ និងការធ្វើទំនើបកម្មកងទ័ព ដែលពួកគេរំពឹងថា នឹងត្រូវចំណាយពេលយ៉ាងហោចណាស់រហូតដល់ឆ្នាំ១៩៥៩ ទើបធ្វើសកម្មភាពតស៊ូប្រដាប់អាវុធជាចំហតែម្តង។

ពេលនោះ ប្រធានាធិបតីសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ហូ ជីមិញ (Hồ Chí Minh) យល់ឃើញថា ការតស៊ូប្រដាប់អាវុធនៅតែជាមធ្យោបាយចុងក្រោយ។

ង្វៀន ហ៊ឺវស្វៀន (Nguyễn Hữu Xuyên) ត្រូវបានតែងតាំងជាមេដឹកនាំចលនាកុម្មុយនិស្តនៅវៀតណាមភាគខាងត្បូង ជំនួស ឡេ យន់ ដែលត្រូវបានតែងតាំងជាអគ្គលេខាបក្សពលករវៀតណាមស្តីទី នៅវៀតណាមខាងជើង ហើយឧត្តមសេនីយ៍ វ៉ៃ ង្វៀនយ៉ាប់ (võ nguyên giáp) ជារដ្ឋមន្ត្រីការពារជាតិ។

របត់នយោបាយ

នៅក្នុងខែមេសា ឆ្នាំ១៩៥៧ ចលនាកុម្មុនិស្តនៅវៀតណាមភាគខាងត្បូង បានបើកយុទ្ធនាការបង្កអសន្តិសុខមួយ ហៅថា "យុទ្ធនាការកំចាត់ជនក្បត់ជាតិ" បង្កឱ្យមានការរំជើបរំជួល និងភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ក្នុងខែកក្កដា ឆ្នាំ១៩៥៧ ជនស៊ីវិលចំនួន១៧នាក់ត្រូវបានសម្លាប់ដោយការបាញ់កាំភ្លើងយន្តនៅរង្គសាលមួយកន្លែងនៅចូវដុក (Châu Đốc) ហើយនៅក្នុងខែកញ្ញា ចៅហ្វាយស្រុកម្នាក់ជាមួយគ្រួសាររបស់គាត់ ត្រូវបានគេសម្លាប់ នៅលើផ្លូវធំមួយក្នុងពេលថ្ងៃត្រង់។

នៅខែតុលា ឆ្នាំ១៩៥៧ គ្រាប់បែកបានផ្ទុះជាបន្តបន្ទាប់នៅក្នុងទីក្រុងសៃហ្គន (Saigon) ធ្វើឱ្យជនជាតិអាមេរិក ចំនួន១៣នាក់រងរបួស។

ក្នុងទិវារម្លឹកខួបឆ្នាំទី១២ នៃថ្ងៃបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៥៧ ហូ ជីមិញ បានថ្លែងសុន្ទរកថាមួយ ដោយបានរម្លឹកឡើងវិញពីការតស៊ូដ៏ស្វិតស្វាញរបស់ពួកវៀតមិញ ក្នុងការវាយបណ្តេញពួកជប៉ុន និងពួកអាណានិគមបារាំង មុនពេលមានសន្និសីទក្រុងហ្ស៊ឺណែវ ឆ្នាំ១៩៥៤ និងការតស៊ូបន្តទៀត ដើម្បីប្រឆាំងនឹងរបប ផ្តាច់ការរបស់ ង៉ូ ឌិញយៀម នៅវៀតណាមខាងត្បូង ផងដែរ។

ក្រោយពីការបង្ហោះយានអវកាស ស្ពុតនិក (Sputnik) នៅថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៥៧ មេដឹកនាំសហភាពសូវៀត បានយកចិត្តទុកដាក់ចំពោះសភាពការណ៍នៅឥណ្ឌូចិន ដែលស្ថិតនៅក្រោមឥទ្ធិពលរបស់ចិន ជាយូរមកហើយ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៥៧ ហូ ជីមិញ ប្រធានាធិបតីសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងឡេ យន់ អគ្គលេខាបក្សពលករវៀតណាម បានធ្វើដំណើរទៅបំពេញទស្សនកិច្ចនៅទីក្រុងមូស្គូ។ នៅទីនោះ មេដឹកនាំសហភាពសូវៀត បានប្រកាសគាំទ្រ និងជួយឧបត្ថម្ភដល់ចលនាតស៊ូរបស់ពួកកុម្មុយនិស្តប្រឆាំងនឹងរបបផ្តាច់ការរបស់ ង៉ូ ឌិញយៀម នៅវៀតណាមខាងត្បូង ដែលគាំទ្រដោយសហរដ្ឋអាមេរិក នោះផងដែរ។

នៅដើមឆ្នាំ១៩៥៨ ឡេ យន់ អគ្គលេខាបក្សពលករវៀតណាម បានធ្វើដំណើរទៅតំបន់តស៊ូនៅវៀតណាមខាងត្បូង ដើម្បីឱ្យមេដឹកនាំចលនាតស៊ូនៅទីនោះរៀបចំឃ្លាំងសម្រាប់



**ហូ ជីមិញ និងឡេ យន់ ទៅបំពេញទស្សនកិច្ចកាន់ទីក្រុងមូស្គូ ឆ្នាំ១៩៥៧**

ដាក់គ្រឿងអាវុធយុទ្ធភណ្ឌត្រៀមទុកសម្រាប់ធ្វើសកម្មភាពនៅក្នុងតំបន់ ដីសណ្តទន្លេមេកុង និងក្នុងទីក្រុងផ្សេងៗទៀត។

នៅខែមិថុនា ឆ្នាំ១៩៥៨ ពួកកុម្មុយនិស្តវៀតណាម បានបង្កើតរចនាសម្ព័ន្ធយោធាសម្រាប់តំបន់ភាគខាងកើតដីសណ្តទន្លេមេកុង។

ក្នុងខែកក្កដា ឆ្នាំ១៩៥៨ ប៊ែរណា ប៊ី ហ្វល( Bernard B. Fall ) អ្នកឆ្លើយឆ្លងព័ត៌មានក្នុងសង្គ្រាមដ៏ល្បីល្បាញ និងជាអ្នកជំនាញនយោបាយនៅឥណ្ឌូចិន បានធ្វើការសន្និដ្ឋានថា ក្នុងពេលឆាប់ៗនេះ សង្គ្រាមថ្មីមួយនៅឥណ្ឌូចិន នឹងចាប់ផ្តើមកើតមានជាមិនខាន។

ក្នុងខែមករា ឆ្នាំ១៩៥៩ មេដឹកនាំបក្សពលករវៀតណាម បានប្រជុំអនុម័តសម្រេចធ្វើ "សង្គ្រាមប្រជាជន" នៅភាគខាងត្បូង ។

នៅខែឧសភា ឆ្នាំ១៩៥៩ វៀតណាមខាងជើង បានបង្កើតក្រុមពិសេសមួយ ហៅថាក្រុម៥៥៩ ដើម្បីសិក្សាពីការកសាង និងធ្វើឱ្យប្រសើរឡើងនូវផ្លូវលំហូ ជីមិញ។ ខែមិថុនា ឆ្នាំ១៩៥៩ វៀតណាមខាងជើង ចាប់ផ្តើមបើកការកសាង និងធ្វើឱ្យប្រសើរឡើងវិញនូវផ្លូវលំ



ផ្លូវលំហូ ជីមិញ

ហូជីមិញ ពីវៀតណាមភាគខាងជើង កាត់តាមប្រទេសឡាវ និងប្រទេសកម្ពុជា ចូលទៅវៀតណាមភាគខាងត្បូង។

ផ្លូវលំជាយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ បែកចេញជា៥ខ្សែទៅតាមគោលដៅសំខាន់ៗ មានប្រវែង៤០០គម. និងមានផ្លូវរណប២៩ខ្សែ មានប្រវែងសរុប១៥.០០០គម. ពង្រីកទទឹងពី១០ម៉ែត្រ ទៅ៣០ម៉ែត្រ សម្រាប់កងរថក្រោះ និងកងរថយន្តដឹកសព្វាវុធ។

ផ្លូវនេះ សាងសង់ដោយវិស្វករចិន និងវៀតណាម ព្រមទាំងមានកម្មករចំនួនជាង ៨០.០០០នាក់ ក្នុងនោះមួយចំនួនធំជាជនជាតិម៉ុងតាញ៉ា (ជនជាតិភាគតិចវៀតណាម)។

អតីតកម្មាភិបាល និងយុទ្ធជនវៀតមិញ ចំនួន៥០០នាក់ ដែលត្រូវបញ្ជូនត្រលប់ទៅវៀតណាមភាគខាងជើង តាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ កាលពីឆ្នាំ១៩៥៤នោះ ត្រូវបាន

បក្សពលករវៀតណាម បញ្ជូនឲ្យវិលត្រលប់មកវៀតណាមភាគខាងត្បូង វិញ តាមផ្លូវលំហូ ជីមិញ នេះ ដើម្បីធ្វើសកម្មភាពតស៊ូធ្វើបដិវត្តន៍បន្តទៀត។

ដំបូង បក្សពលករវៀតណាម បានបង្កើតមន្ទីរមួយ ហៅថា មន្ទីរកណ្តាលវៀតណាមខាងត្បូង (Central Office for South Vietnam = COSVN)មានទីតាំងនៅក្នុងព្រៃ នាខេត្តតៃនិញ (Tây Ninh) ជិតព្រំដែនរបស់ប្រទេសកម្ពុជា សម្រាប់ធ្វើការតស៊ូនៅវៀតណាមភាគខាងត្បូង។

នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៥៨ ពួកតស៊ូកុម្មុយនិស្តវៀតណាមនេះ បានសម្លាប់ទីប្រឹក្សាយោធាអាមេរិក ពីរនាក់ នៅខេត្តបៀនហ័រ (Biên Hoa )។

នេះចាត់ទុកថាជាទាហានអាមេរិកទី១ ដែលត្រូវពួកកុម្មុយនិស្តវៀតណាម សម្លាប់នៅក្នុងសង្គ្រាមវៀតណាម ហើយនេះ ក៏អាចចាត់ទុកថាជាការចាប់ផ្តើមនៃការតស៊ូប្រដាប់អាវុធ ប្រឆាំងនឹងរបបសាធារណរដ្ឋវៀតណាម (វៀតណាមខាងត្បូង) ដែលពួកគេចាត់ទុកថាជាអាយ៉ងរបស់ចក្រពត្តិអាមេរិក ផងដែរ។

ក្នុងខែឧសភា ឆ្នាំ១៩៥៩ ប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម បានចេញច្បាប់អាជ្ញាសឹកលេខ១០/៥៩ ឲ្យមានការកាត់ទោសប្រហារជីវិតដល់ជនណាដែលប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម "ប្រឆាំងនឹងសន្តិសុខរបស់រដ្ឋ"។ តែទោះបី ង៉ូ ឌិញយៀម បានចេញច្បាប់អាជ្ញាសឹកនេះ ក៏ដោយ ក៏ការប៉ះទង្គិចគ្នារវាងពួកតស៊ូកុម្មុយនិស្តវៀតណាម និងកងកម្លាំងរដ្ឋាភិបាល ង៉ូ ឌិញយៀម បានកើនឡើងជាបន្តបន្ទាប់ គឺពីខែមករា ដល់ខែកញ្ញា ឆ្នាំ១៩៦០ ការប៉ះទង្គិចគ្នា បានកើនឡើងពី១៨០លើក ទៅ៥៤៥លើក។

នៅចុងឆ្នាំ១៩៥៩ ឆ្លើយតបទៅអ្នកតំណាងរបស់សហរដ្ឋអាមេរិក ដែលបានចោទ-ប្រកាន់ថា មានកងទ័ពវៀតណាមខាងជើង ឆ្លងកាត់ទឹកដីកម្ពុជា ដើម្បីចូលទៅក្នុងទឹកដីវៀតណាមខាងត្បូងនោះ សឺន សាន ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា បានគូសបញ្ជាក់ថា ប្រទេសកម្ពុជាសព្វថ្ងៃ ជាព្រះរាជាណាចក្រប្រកាន់មាគ៌ានយោបាយអព្យាក្រឹត ដូច្នេះយើងមិនអាចលម្អៀងទៅរករបបកុម្មុយនិស្តបានទេ។ យើងបានប្រកាន់

យកនយោបាយអព្យាក្រឹត តាំងពីមាន កិច្ចព្រមព្រៀងសន្តិសីទក្រុងហ្សឺណែវ មក ម្ល៉េះ ហើយមិនមែនបរទេសណាមួយមក បង្ខំឲ្យកម្ពុជា ឱ្យដើរប្រាសចាកពីមាគ៌ានេះ បានដែរ។



ស៊ឺន សាន

ចំពោះការចោទប្រកាន់ពីសំណាក់លោកសេរីថាកម្ពុជាប្រកាន់យកមាគ៌ានយោបាយអព្យាក្រឹត តែលំអៀងទៅរកប្រទេសកុម្មុយនិស្តនោះ ស៊ឺន សាន បានឆ្លើយបំភ្លឺថា តាំងពីឆ្នាំ១៩៥៤មក ប្រទេសកម្ពុជា ប្រៀបបានដូចទូកមួយដែលកំពុងធ្វើដំណើរនៅចំកណ្តាលស្ទឹង ឬកណ្តាលទន្លេ។ ប៉ុន្តែ នៅត្រើយខាងឆ្វេង ទូកយើងមិនដែលមានបញ្ហាទេ តែទូកយើងតែងតែរងគ្រោះដោយសារតែការបាញ់ពីត្រើយខាង ស្តាំទៅវិញ។ ហេតុដូច្នេះ បើពេលណា មានការបាញ់ពីត្រើយខាងស្តាំ ទូកយើងត្រូវតែគេចទៅត្រើយខាងឆ្វេងបន្តិច ហើយប្រឆាំងតបតទៅវិញ។ តែបើគ្មានការបាញ់ពីត្រើយខាងស្តាំ និងពីខាងឆ្វេងទេ យើងនៅតែកាន់យកកណ្តាល គឺអព្យាក្រឹត។ អ៊ីចឹងសុំតែអ្នកត្រើយខាងស្តាំនោះ កុំបាញ់មកលើយើង បានហើយ។

ក្រោយពីមានការបះបោរជាបន្តបន្ទាប់នៅក្នុងខេត្ត បេន ដែ ( Bến Tre ) នៃតំបន់ដីសណ្តទន្លេមេកុងមក ក្នុងខែមករា ឆ្នាំ១៩៦០ ពួកតស៊ូកុម្មុយនិស្តវៀតណាម ក៏បានចាប់ផ្តើមបង្កើត "តំបន់រំដោះ"របស់ពួកគេ។ នៅក្នុងខែឧសភា ឆ្នាំ១៩៦០ ទាំងនៅទីក្រុងហាណូយ និងទីក្រុងប៉េកាំង មេដឹកនាំបក្សពលករវៀតណាម និងមេដឹកនាំបក្សកុម្មុយនិស្តចិន បានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាជាច្រើនលើកច្រើនសា ពីបញ្ហាយុទ្ធសាស្ត្រនានាដែលត្រូវយក

ទៅអនុវត្តនៅវៀតណាមភាគខាងត្បូង។

មេដឹកនាំបក្សកុម្មុយនិស្តចិន ជូ អេនឡាយ និងតេង ស៊ាវពីង បានលើកហេតុផលថា ជាទូទៅការតស៊ូនយោបាយ គួរតែត្របាញ់បញ្ចូលគ្នាជាមួយការតស៊ូដោយអាវុធ ហើយដោយសារថា មានភាពខុសប្លែកពីគ្នារវាងទីក្រុង និងជនបទ នៅវៀតណាមខាងត្បូង យុទ្ធសាស្ត្រទន់ភ្លន់មួយនៃការតស៊ូ ក៏គួរយកមកអនុវត្តដែរ។

មេដឹកនាំបក្សកុម្មុយនិស្តចិន បានផ្តល់យោបល់ដល់មេដឹកនាំបក្សពលករវៀតណាមថា នៅតាមបណ្តាទីក្រុង ជាទូទៅ ការតស៊ូនយោបាយជាភារកិច្ចមួយដែលត្រូវតែធ្វើ។ តែដើម្បីសំពងរបប ង៉ូ ឌិញយៀម ឱ្យដួលរលំ ចាំបាច់ត្រូវតែមានកងកម្លាំងប្រដាប់អាវុធ។

មេដឹកនាំបក្សកុម្មុយនិស្តចិន បានផ្តល់យោបល់បន្ថែមថា នៅពេលមានមូលដ្ឋានមហាជនដ៏ធំទូលាយនិងរឹងមាំនៅតាមជនបទរួចហើយការតស៊ូខាងយោធាគួរតែធ្វើនៅទីនោះ។ តែការតស៊ូយោធានេះ គួរតែត្របាញ់បញ្ចូលគ្នាជាមួយការតស៊ូនយោបាយផងដែរ។

ដើម្បីចៀសវាង កុំឱ្យមានការចោទប្រកាន់ថា សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង) ដឹកនាំដោយ ហូ ជីមិញ រំលោភលើកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ ចូលទៅរំលោភឈ្លានពានទៅលើអធិបតេយ្យភាពរបស់សាធារណរដ្ឋវៀតណាម (វៀតណាមខាងត្បូង) ដឹកនាំដោយ ង៉ូ ឌិញយៀមនោះ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៦០ នៅភូមិតឹនឡឹប (Tân Lập) ក្នុងខេត្តតៃនិញ (Tây Ninh) ពួកកុម្មុយនិស្តវៀតណាមខាងជើងបានបង្កើតរណសិរ្សតស៊ូមួយ ឈ្មោះ រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ហៅកាត់ជាភាសាវៀតណាម ថាវៀតកុង (Việt Cộng) នេះឯង។

វិទ្យុក្រុងហាណូយ បានជួយផ្សព្វផ្សាយសេចក្តីថ្លែងការណ៍១០ចំណុចរបស់រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ដោយបានអំពាវនាវដល់អ្នកស្នេហាជាតិវៀតណាមទាំងអស់ រួមទាំងពួកមិនមែនកុម្មុយនិស្តផងដែរ ឱ្យមកចូលរួមជាមួយរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ដើម្បីធ្វើសង្គ្រាមវាយបណ្តេញពួកចក្រពត្តិនិយមដែលជាពួកអាណានិគមសម័យថ្មី និងផ្តួលរម្លំរបបគ្រប់គ្រងផ្តាច់ការ ង៉ូ ឌិញយៀម ជាអាយ៉ងផងដែរ។



**ថ្ងៃបង្កើតរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង(វៀតកុង)ឆ្នាំ១៩៦០**

នៅក្នុងឆ្នាំ១៩៦០នោះដែរ ទោះបីមានការបែកបាក់ជាមួយសហភាពសូវៀត យ៉ាងណាក៏ដោយ ក៏មេដឹកនាំចិនកុម្មុយនិស្ត ម៉ៅ សេទុង នៅតែគាំទ្រ និងផ្តល់ជំនួយយោធាដ៏ច្រើនសន្ធឹកសន្ធាប់ដល់ការតស៊ូធ្វើសង្គ្រាមរបស់មេដឹកនាំកុម្មុយនិស្តវៀតណាមខាងជើង។

នៅរដូវស្លឹកឈើជ្រុះឆ្នាំ១៩៦១ កងទ័ពវៀតកុង-វៀតណាមខាងជើង បានបង្កើនការវាយប្រហារជាបន្តបន្ទាប់ទៅលើទាហានរដ្ឋការវៀតណាមខាងត្បូង។

នៅក្នុងខែកញ្ញា កងទ័ពវៀតកុង-វៀតណាមខាងជើង បានវាយប្រហារទៅលើទាហានរដ្ឋការវៀតណាមខាងត្បូង ចំនួន៥០លើក ហើយ១ខែក្រោយមក គឺនៅក្នុងខែតុលា ការវាយប្រហារនេះ បានធ្វើឡើងចំនួន១៥០លើក។

ដោយសារកងទ័ពវៀតកុង បង្កើនការវាយប្រហារកាន់តែច្រើនឡើងៗ នៅក្នុងខែវិច្ឆិកាឆ្នាំ១៩៦១ ប្រធានាធិបតីសហរដ្ឋអាមេរិក ចន អែហ្វ. កេណ្ណឌី( John F. Kennedy ) បាន



**នាវាផ្ទុកយន្តហោះ** USS Core **ពេលមកដល់ទីក្រុងសៃហ្គន**

សម្រេចចិត្តបង្កើនជំនួយយោធាយ៉ាងច្រើនដល់របបរដ្ឋការវៀតណាមខាងត្បូង។

នៅក្នុងខែធ្នូ ឆ្នាំ១៩៦១ នាវាផ្ទុកយន្តហោះយូអេសអេស គ័រ (USS Core) របស់អាមេរិក បានដឹកឧទ្ធម្ភាគចក្រចម្បាំងចំនួន៣៥គ្រឿង មកដល់ទីក្រុងសៃហ្គន(Saigon)។ ពីឆ្នាំ១៩៦១ ដល់ឆ្នាំ១៩៦៣ មេដឹកនាំកុម្មុយនិស្តវៀតណាមខាងជើង បានបញ្ជូនកងទ័ពខ្លួនប្រមាណ៤០,០០០នាក់ តាមផ្លូវលំហូ ជីមិញ ទៅកាន់វៀតណាមភាគខាងត្បូង។

នៅចុងឆ្នាំ១៩៦៣ កងទ័ពវៀតកុង ឬកងទ័ពប្រជាជនរំដោះវៀតណាម (PAVN) នៅវៀតណាមភាគខាងត្បូង បានកើនឡើង១៧៤,០០០ នាក់ ហើយនៅក្នុងឆ្នាំ១៩៦៤ បានកើនឡើងដល់ ៣០០,០០០នាក់។

# ១៦២
# ការកាត់ទោសប្រហារជីវិតខ្មែរសេរី ឈ្មោះ ព្រាប អ៊ិន



**ព្រាប អ៊ិន ក្នុងថ្ងៃទី១ នៃសមាជជាតិ ខែវិច្ឆិកា ឆ្នាំ១៩៦៣**

នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៣ សម្តេចសីហនុ តវ៉ាទាមទារឱ្យមេដឹកនាំវៀតណាមខាងត្បូង និងថៃ ធ្វើយ៉ាងណា ត្រូវតែបញ្ឈប់ការផ្សាយវិទ្យុខ្មែរសេរី ពីក្នុងទឹកដីនៃប្រទេសទាំងពីរនេះ។ នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៦៣ នៅក្នុងឱកាសប្រារព្ធខួបលើកទី៩ នៃថ្ងៃបុណ្យឯករាជ្យជាតិ សម្តេចសីហនុ បានប្រកាសលែងទទួលជំនួយទាំងខាងយោធា ទាំងខាងសេដ្ឋកិច្ច ពីសហរដ្ឋអាមេរិក និងប្រកាសធ្វើកំណែទម្រង់ធ្វើជាតូបនីយកម្មធនាគារ និងពាណិជ្ជកម្មក្រៅប្រទេស ដោយព្រះអង្គចាត់ទុកថា នាយទុនអន្តរជាតិ ចិន បារាំង និងអង់គ្លូសាក់សុង ជាសត្រូវរបស់អព្យាក្រឹតភាពរបស់ព្រះអង្គ។

នៅថ្ងៃទី១២ ខែវិច្ឆិកា ព្រះអង្គបានប្រកាស តែងតាំងបុត្រាជាមួយនឹងម្ចាស់ក្សត្រី

ស៊ីសុវត្ថិ មុនីកេសរ ហៅម្ចាស់ដួង គឺព្រះអង្គម្ចាស់ នរោត្តម នរទីបោ ព្រះជន្ម ១៧វស្សា ជាអ្នកស្នងព្រះអង្គក្នុងការដឹកនាំចលនាសង្គមរាស្ត្រនិយម។

នៅថ្ងៃទី១៤ ខែវិច្ឆិកា សម្តេចសីហនុ បានប្រកាសថា ចលនាសង្គមរាស្ត្រនិយមរបស់ព្រះអង្គ ដឹកនាំប្រទេសតាមលទ្ធិថ្មីមួយ គឺលទ្ធិសង្គមនិយមព្រះពុទ្ធសាសនា។ នៅថ្ងៃទី១៧ ខែវិច្ឆិកា មេខ្មែរសេរី២នាក់ គឺ ព្រាប អ៊ិន និងសាំង សន ត្រូវចាប់បាននៅខេត្តតាកែវ បញ្ជូនមកក្រុងភ្នំពេញ។

នៅថ្ងៃទី១៩ ខែវិច្ឆិកា ជាថ្ងៃទី១នៃសមាជជាតិនៅទីលានវាលព្រះមេរុ ក្រោមព្រះរាជធិបតីរបស់សម្តេចសីហនុ ដើម្បីឱ្យអង្គសមាជទាំងមូលធ្វើការពិភាក្សាពីបញ្ហាឈប់ទទួលជំនួយអាមេរិក ដើម្បីងាកទៅទទួលជំនួយពីចិន និងសហភាពសូវៀត វិញ ពិសេសឱ្យប្រជារាស្ត្រដែលចូលរួមក្នុងសមាជនោះ សម្រេចវិនិច្ឆ័យទោសមេខ្មែរសេរី២នាក់ គឺ ព្រាប អ៊ិន និង សាំង សន ចាប់បានមកពីខេត្តតាកែវ ដែលពេលនោះមាន អ៊ិន តាំ ជាអភិបាលខេត្ត។

ក្នុងអង្គសមាជគួរឱ្យចាប់អារម្មណ៍បំផុតនោះ សាំង សន បានឆ្លើយសារភាពថា ចលនាខ្មែរសេរី មានពួក សេ.អ៊ី.អា ជាអ្នកគ្រប់គ្រង និងផ្តល់ប្រាក់កាសសម្ភារៈយោធាគ្រប់បែបយ៉ាងក្នុងគោលបំណងផ្តួលរម្លំសម្តេចសីហនុ ចេញពីអំណាច។ ចំណែក ព្រាប អ៊ិន មិនឆ្លើយសារភាពអ្វីទាំងអស់ ហើយនៅតែរក្សាជំហរមិនតក់ស្លុតអ្វីបន្តិចឡើយ ។

នៅថ្ងៃទី២នៃសមាជជាតិនោះ នៅវេលាម៉ោង១១ព្រឹក ព្រាប អ៊ិន ពាក់អាវស ត្រូវបានគេដាក់ក្នុងទ្រុងមានចម្រឹងដែកនៅព័ទ្ធជុំវិញ និងមានដំបូលរាងមូល នៅលើរថយន្តកាម៉ុងមួយគ្រឿង នៅផ្លូវជាប់របងព្រះបរមរាជវាំង ក្បែរទីលានវាលព្រះមេរុ ដែលសម្តេចសីហនុកំពុងមានបន្ទូលក្នុងសមាជជាតិនោះដែរ។ ប្រជារាស្ត្រក្មេងចាស់ប្រុសស្រីរាប់រយនាក់ដែលមានស្វាមីភក្តិបំផុតជាមួយសម្តេចសីហនុ បានដណ្តើមគ្នាយកដុំថ្មដុំដី ឬស្បែកជើងគប់ទៅលើ ព្រាប អ៊ិន ដែលនៅក្នុងទ្រុងនោះ ដោយស្រែកជ័យឃោសថា ជយោសម្តេចឪ! និងជេរប្រមាថថា បរាជ័យអាព្រាប អ៊ិន ជាជនក្បត់ជាតិ។ ឯខ្លះទៀតស្រែកចំអកថា បរាជ័យអាព្រាបអាំង ទៀតផង។

## របត់នយោបាយ

ពេលនោះ សម្តេចសីហនុ បានឱ្យគេបង្វែរក្បាលមេក្រូទៅរកថយន្តកាម៉្យុងដែលគេដាក់ ព្រាប អ៊ិន នៅក្នុងទ្រុងដែកនៅផ្លូវជាប់របងព្រះបរមរាជវាំង ខាងក្រោយវេទិកាកិត្តិយសនៃអង្គសមាជនោះ ហើយមានបន្ទូល ដើម្បីបញ្ឆេះកំហឹងប្រជារាស្ត្រក្មេងចាស់ប្រុសស្រីរាប់រយនាក់នោះឱ្យកាន់តែពុះកញ្ជ្រោលទៅលើ ព្រាប អ៊ិន កាន់តែសន្ធោសន្ធៅថែមទៀត។

នៅថ្ងៃទី២៥ ខែវិច្ឆិកា តុលាការសឹកបានសម្រេចផ្តន្ទាទោសប្រហារជីវិត ព្រាប អ៊ិន។ ចំណែក សាំង សន ត្រូវរួចទោស ដោយសារគាត់ឆ្លើយសារភាពទទួលកំហុស និងដោយសារឪពុកគាត់ជាអ្នកបើកបររថយន្តនៅក្នុងព្រះបរមរាជវាំង ផងដែរ ។

ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៦៤ មេខ្មែរសេរីឈ្មោះ ព្រាប អ៊ិន ត្រូវបានត្រូវពួកទាហាននៅបន្ទាយស្លឹក ក្បែរមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដឹកតាមរថយន្តទាហានម៉ាកហ្សេអឹមសេ (GMC) គ្របដំបូលជិត ចេញពីក្រុងភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ៤ ឆ្ពោះទៅកាន់ជើងភ្នំត្រពាំងក្រឡឹង នៅក្នុងឃុំគិរីវន្ត ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

ដៃជាប់ខ្នោះ ក្នុងទឹកមុខធម្មតា ព្រាប អ៊ិន ត្រូវពួកទាហានប្រកៀកចុះពីលើរថយន្តបណ្តើរទៅរកបង្គោលសសរមួយ ដែលដាំបញ្ឈរទុករួចជាស្រេច។

ក្រោយពីពិធីឱ្យធម៌តាមបែបព្រះពុទ្ធសាសនារួចមក ព្រាប អ៊ិន ត្រូវពួកទាហានយកទៅចងផ្អោបនឹងបង្គោលសសរបញ្ឈរនោះ និងរុំភ្នែកដោយក្រណាត់ខ្មៅ មិនឱ្យមើលឃើញអ្វីៗទាំងអស់។ នៅពីក្រោយខ្នងគាត់ចម្ងាយប្រហែលជាង១០ម៉ែត្រ មានពួកទាហានពីរជួរ ដោយជួរទី១ មានគ្នា៥នាក់ អង្គុយលុតជង្គង់កាន់កាំភ្លើងវែងគ្រប់ដៃ និងជួរទី២ នៅខាងក្រោយមានគ្នា៥នាក់ដែរ ឈរកាន់កាំភ្លើងវែងគ្រប់ដៃតម្រង់ទៅរកអ្នកទោស ព្រាប អ៊ិន។

ពេលនោះ មេបញ្ជាការម្នាក់ស្រែកថា«បាញ់»ស្នូរកាំភ្លើងក៏លាន់ឡើងព្រមៗគ្នា ព្រាប អ៊ិន ត្រូវគ្រាប់កាំភ្លើងសុសពីក្រោយខ្នង រួចស្រុតដងខ្លួន ដែលកំពុងចងផ្អោបនឹងបង្គោលសសរ។ ភ្លាមនោះដែរ មេបញ្ជាការម្នាក់នោះបានដើរចូលទៅចាប់ក្របួចសក់ក្បាល រួចយកកាំភ្លើងខ្លីបាញ់ត្រង់សៀតផ្កាបន្ថែមមួយគ្រាប់ទៀត ទើបស្រាយចំណង ហើយលើកសាកសពមកដាក់ក្នុងមឈូស។



**កំពង់ផែក្បែរវត្តឧណ្ណាលោម នៅដើមទសវត្សរ៍ឆ្នាំ១៩៦០**

បន្ទាប់មក ពួកទាហានបាននាំគ្នាលើកមឈូសដាក់លើរថយន្តហ្សេអឹមសេ(GMC) ដឹកត្រលប់មកទីក្រុងភ្នំពេញវិញ ដើម្បីយកទៅបូជានៅប៉ាឆាវត្តចង្ក្រានតាព្រហ្មមានជ័យ (វត្តស្ទឹងមានជ័យ)។

ព្រឹត្តិការណ៍ប្រហារជីវិត ព្រាប អ៊ិន នៅភ្នំត្រពាំងក្រឡឹង ត្រូវបានគេថតជាខ្សែភាពយន្តឯកសារខ្នាតខ្លី ទៅចាក់បញ្ចាំងនៅតាមរោងភាពយន្ត និងនៅតាមទីសាធារណៈក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ក្នុងបំណងឱ្យប្រជារាស្ត្រក្មេងចាស់ប្រុសស្រីមានការភ័យខ្លាច និងកុំឱ្យយកតម្រាប់តាម ព្រាប អ៊ិន ផងដែរ។

ជាមួយគ្នានោះ ខ្លឹមសារដើមបទចម្រៀងដ៏មានប្រជាប្រិយមួយបទទៀត គឺបទ ឱ! ស្វាយចន្ទី នារីអូនអើយ បែកមែកសាខា ធ្វើបុណ្យកាលណា បងសូមប្រាថ្នាជួបតែអូនស្រី.... ក៏ត្រូវគេបានកែច្នៃមកជា ៖ ឱស្វាយចន្ទី អាសម សារី អាសឹង ង៉ុកថាញ់ កុំជេរសម្តេចឪអញ ប្រយ័ត្នអញបាញ់ ដូចអាព្រាប អ៊ិន...។

ក្រោយពេលយក ព្រាប អ៊ិន ទៅបាញ់ចោលនៅភ្នំត្រពាំងក្រឡឹង នោះមក ប្រជារាស្ត្រ



**អ៊ិន តាំ**

ខ្មែរក្មេងចាស់ប្រុសស្រីនៅទូទាំងប្រទេស តែងនិយមនាំគ្នាប្រើពាក្យថា អាអ៊ិន ត្រ-ពាំងក្រឡឹង! នៅជាប់នឹងមាត់។ សូម្បីអ្នកខ្លះជំពាក់លុយ គេមិនព្រមសងវិញ ក៏និយាយឌឺថា ចាំយកពីអាអ៊ិន ត្រពាំងក្រឡឹង!ទៅ។

មានប្រភពខ្លះ បានអះអាងថា ព្រាប អ៊ិន ត្រូវជាក្មួយអ៊ិន តាំ ហើយក្រុមគ្រួសារគាត់បានស្ដីបន្ទោស អ៊ិន តាំ ព្រោះគាត់មិនបានជួយធ្វើអន្តរាគមន៍ឱ្យ ព្រាប អ៊ិន បានរួចពីទោសប្រហារជីវិត តែ អ៊ិន តាំ ប្រាប់ពួកគេវិញថា៖ ខ្ញុំមិនអាចជួយវាបានទេ វាសមតែស្លាប់ ពីព្រោះវាមាត់រឹង ព្រហើន មិនព្រមឆ្លើយសារភាពនៅចំពោះព្រះភក្ត្រសម្ដេចឳ។

ទាក់ទងដល់ការកាត់ទោសប្រហារជីវិត ព្រាប អ៊ិន នេះ នៅក្នុងយុទ្ធនាការឃោសនារកសំឡេងឆ្នោតសម្រាប់តំណែងប្រធានាធិតី នៃរបបសាធារណរដ្ឋខ្មែរ ក្នុងឆ្នាំ១៩៧២ ក្រុមឃោសនិករបស់បេក្ខជន លន់ នល់ មកពីគណបក្សសង្គមសាធារណរដ្ឋ បានចោទប្រកាន់បេក្ខជន អ៊ិន តាំ ប្រធានគណបក្សប្រជាធិបតេយ្យថា ជាអ្នកបោកបញ្ឆោត ព្រាប អ៊ិន យកមកឱ្យសម្ដេចសីហនុ កាត់ទោសសម្លាប់ចោល កាលពីចុងឆ្នាំ១៩៦៣នោះ។

ចំពោះការចោទប្រកាន់នេះ អ៊ិន តាំ បានបញ្ជាក់ប្រាប់ក្រុមឃោសនិករបស់គាត់ថា កាលនោះគាត់ជាចៅហ្វាយខេត្តតាកែវ ត្រូវធ្វើដំណើរឡើងមកក្រុងភ្នំពេញ ដើម្បីចូលរួមក្នុងសមាជជាតិ ក៏មានសហការីគាត់ផ្ញើសារទូរលេខមួយពីខេត្តតាកែវ មកប្រាប់គាត់ថា មានមេខ្មែរសេរី២នាក់មករកជួបគាត់នៅផ្ទះគាត់នៅទីរួមខេត្តតាកែវ នោះ។ គាត់ក៏តបវិញ



**ទិដ្ឋភាពបាញ់ប្រហារខ្មែរសេរីនៅត្លុំត្រពាំងក្រឡឹង**

ថា ឱ្យពួកគេសម្រាកនៅផ្ទះគាត់សិនទៅ ពេលគាត់ត្រលប់ទៅវិញ ចាំជួបគ្នា។

តែបន្តិចក្រោយមក ដំណឹងពីរឿងមេខ្មែរសេរី២នាក់មករកជួបគាត់នៅផ្ទះគាត់នៅទីរួមខេត្តតាកែវ នោះ បានបែកធ្លាយមកដល់ក្រុងភ្នំពេញ សម្តេចសីហនុ ក៏បានបញ្ជាឱ្យព្រះអង្គម្ចាស់ នរោត្តម កន្តុល កាលនោះ ជានាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឱ្យកម្លាំងសមត្ថកិច្ចទៅនាំយកពួកគេមកក្រុងភ្នំពេញ ហើយដាក់ក្នុងសមាជជាតិនោះ សួរដេញដោលពួកគេទាំង២នាក់ រួចបញ្ជូនទៅឱ្យតុលាការសឹកកាត់ទោសប្រហារជីវិតតែម្តង។

ទាក់ទងដល់ការប្រហារជីវិត ព្រាប អ៊ិន នេះដែរ បើតាម ឡឹក សំអឿន មេខ្មែរសេរីនៅភ្នំដងរែក បានឲ្យដឹងថា នៅពេលនោះ ចលនាខ្មែរសេរីបានសម្រេចចិត្តរកផ្លូវដោះស្រាយដោយសន្តិវិធីពីបញ្ហាទាស់ទែងគ្នាខាងផ្លូវនយោបាយជាមួយសម្តេចសីហនុ ក៏បានបញ្ជូនស្នងការនយោបាយមួយរូបនៅតំបន់មាត់ជ្រូក ឈ្មោះ ព្រាប អ៊ិន (ព្រាប ឥន្ទ) ឲ្យទៅរកវិធីចូលគាល់សម្តេចសីហនុ ទូលទ្រង់ឲ្យជ្រាបពីផែនការសម្លាប់របស់ពួកយួនកុម្មុយនិស្ត និង

បរិវារ ព្រមទាំងគម្រោងការដែលខ្មែរយើងត្រូវតែរួបរួមគ្នាដោះស្រាយជាបន្ទាន់ ដើម្បីចៀសវាងកុំឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតរបស់ប្រទេសជាតិ។

ឡឹក សំអឿន បានឲ្យដឹងបន្តថា តាមការត្រិះរិះពិចារណារបស់ចលនាខ្មែរសេរី ខ្មែរយើងនៅសល់មធ្យោបាយតែមួយគត់ក្នុងការទប់ទល់នឹងមហន្តរាយនេះ គឺយើងជាខ្មែរទាំងអស់គ្នា និងគ្រប់និន្នាការនយោបាយត្រូវតែបញ្ឈប់ការទាស់ទែងខ្វែងគំនិតគ្នាខាងផ្លូវនយោបាយ ហើយត្រូវរួបរួមគ្នាជាធ្លុងមួយបំពេញកាតព្វកិច្ចរៀងៗខ្លួន ទើបយើងមានផ្លូវដោះស្រាយបញ្ហានេះបាន។

បើពុំនោះទេ យើងច្បាស់ជាគេចមិនផុតពីក្រឡាអុក ដែលមេដឹកនាំយួនកុម្មុយនិស្តបានគូសទុកនោះបានឡើយ។ តែសម្តេចសីហនុ ត្រលប់ទៅជាខឹងច្រឡោតឥតពិចារណារួចក៏ប្រញាប់បើកវេទិកាសមាជទាំងទទឹងទិស ហើយឲ្យចាប់ ព្រាប អ៊ិន យកទៅប្រហារជីវិតយ៉ាងព្រៃផ្សៃ ដោយគ្មានការជំនុំជម្រះអ្វីឡើយ។

ឡឹក សំអឿន បានបញ្ជាក់ថា ពាក់ព័ន្ធរឿងប្រហារជីវិត ព្រាប អ៊ិន នេះ អ៊ិន តាំ ដែលកាលនោះជាចៅហ្វាយខេត្តតាកែវ ក៏ជាអ្នកទទួលខុសត្រូវដែរ ព្រោះគាត់បានកុហកបោកបញ្ឆោត ព្រាប អ៊ិន។

ព្រាប អ៊ិន (ព្រាប ឥន្ទ) កើតនៅក្នុងឆ្នាំ១៩៣៨ ក្នុងគ្រួសារកសិករមួយ នៅស្រុកកំពង់ត្រាច ខេត្តកំពត។ គាត់ធ្លាប់សិក្សាជំនាញផ្នែកវិស្វកម្មនៅទីក្រុងភ្នំពេញ បានរត់ទៅចូលរួមតស៊ូជាមួយចលនាខ្មែរសេរី ដឹកនាំដោយ សឺង ង៉ុកថាញ់ នៅលើទឹកដីវៀតណាមខាងត្បូង ដើម្បីប្រឆាំងលទ្ធិកុម្មុយនិស្ត និងរបបសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ ផងដែរ។ ព្រាប អ៊ិន មានប្អូនប្រុសម្នាក់ឈ្មោះ ព្រាប អ៊ិន ក៏បានរត់ទៅចូលរួមតស៊ូជាមួយចលនាខ្មែរសេរី ជាមួយគាត់ដែរ។

# ១៦៣
# អាមេរិក យួនខាងត្បូង និងថៃ ជួយបង្កើតចលនាខ្មែរសេរី ម្តងទៀត



**ឡឹក សំអឿន**

នៅពាក់កណ្តាលឆ្នាំ១៩៦៣ នាយទាហានជាន់ខ្ពស់របស់សហរដ្ឋអាមេរិក ចាប់ផ្តើមបានទាក់ទង សឺង ង៉ុកថាញ់ ឱ្យប្រមែប្រមូលកងកម្លាំងខ្មែរសេរី ដែលបានប្រកាសរំសាយកន្លងមក និងបងប្អូនខ្មែរកម្ពុជាក្រោម ដើម្បីបង្កើតកងទ័ពពិសេសប្រដាប់ដោយអាវុធទំនើបៗទាន់សម័យ។

នៅដើមខែវិច្ឆិកា ឆ្នាំ១៩៦៣ គឺក្រោយមានព្រឹត្តិការណ៍រដ្ឋប្រហារផ្តួលរម្លំប្រធានាធិបតី ង៉ូ ឌិញយៀម មក ពួកបាតុករជាព្រះសង្ឃ និងពុទ្ធសាសនិកទាំងវៀតណាមទាំងខ្មែរកម្ពុជាក្រោមដែលរដ្ឋាភិបាល ង៉ូ ឌិញយៀម ចាប់យកទៅឃុំឃាំងនោះ ត្រូវបានឧត្តមសេនីយ៍ យឿង វ៉ាន់មិញ ប្រធានក្រុមប្រឹក្សាបដិវត្តន៍ ជាអ្នកដឹកនាំរដ្ឋប្រហារ ដោះលែងវិញទាំងអស់។

មេខ្មែរសេរីឈ្មោះ ឡឹក សំអឿន បានអះអាងថា៖ ចាប់ពីពេលនោះមក ស្ថានការណ៍តានតឹងរវាងរដ្ឋការវៀតណាមខាងត្បូង និងបងប្អូនខ្មែរកម្ពុជាក្រោម មានសភាពធូរស្រាល។ ជាពិសេសនៅក្នុងសម័យរដ្ឋាភិបាលថ្មីដឹកនាំដោយ ង្វៀន វ៉ាន់ធីវ និងង្វៀន កាវគី អនុញ្ញាត

រូបត់នយោបាយ

ឱ្យមានតំណាងខ្មែរកម្ពុជាក្រោមចំនួន៥រូប នៅក្នុងសភាជម្មនុញ្ញវៀតណាម ហើយនៅក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ គេបានអនុញ្ញាតឱ្យមានតំណាងរាស្ត្រខ្មែរចំនួន៥ នាក់នៅក្នុងសភាវៀតណាមខាងត្បូង ផងដែរ។ ទាំងអស់នេះ សុទ្ធតែជាស្នាដៃរបស់ សឺង ង៉ុកថាញ់ និងបងប្អូនខ្មែរកម្ពុជាក្រោមដែលបានរួបរួមសាមគ្គីចងបាច់គ្នាជាធ្លុងមួយ។

ឡឹក សំអឿន បានអះអាងបន្តថា ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៦៣ សឺង ង៉ុកថាញ់ បង្កើតកងកម្លាំងពិសេសរបស់ចលនាខ្មែរសេរីជាលើកដំបូងនៅតំបន់ឡុកនិញ ដោយមាននាយ-ទាហានអាមេរិក និងនាយទាហានយួនខាងត្បូង ជាអ្នកជួយបង្ហាត់បង្រៀន និងធ្វើជាទីប្រឹក្សា។

បន្ទាប់មក កងកម្លាំងពិសេសរបស់ចលនាខ្មែរសេរីនេះ ក៏បានទៅតាំងមូលដ្ឋានប្រតិ-បត្តិការសឹកនៅតាមបណ្តោយព្រំដែនខ្មែរ-វៀតណាមខាងត្បូង និងចូលមកតាមដានពិនិត្យមើលសកម្មភាពគ្រប់បែបយ៉ាងរបស់កងទ័ពពួកកុម្មុយនិស្តយួនខាងជើង ដែលកំពុងបោះទីតាំងនៅក្នុងទឹកដីខ្មែរផង និងកំពុងធ្វើវិទ្ធង្សនាសេដ្ឋកិច្ចខ្មែរផងនោះដែរ។

អ្វីដែលជាការកត់សម្គាល់នោះ គឺនៅចុងខែធ្នូ ឆ្នាំ១៩៦៣នោះហើយ ដែលស្នងការនយោបាយខ្មែរសេរី ឈ្មោះ ព្រាប អ៊ិន ត្រូវសម្តេចសីហនុ ចាប់បានយកទៅកាត់ទោសប្រហារជីវិត។

ដើមឆ្នាំ១៩៦៤ សឺង ង៉ុកថាញ់ នៅឯប្រទេសវៀតណាមខាងត្បូង បានឱ្យដំណឹងទៅ ឡឹក សំអឿន នៅឯក្រុងវៀងចន្ទ ឱ្យត្រៀមខ្លួនធ្វើសហប្រតិបត្តិការនៅរណសិរ្សយោធាភ្នំដងរែក ជាមួយពួកសម្ព័ន្ធមិត្តថៃ ជាថ្មីឡើងវិញ និងឱ្យប្រមែប្រមូលកម្លាំងតស៊ូជាថ្មីទៀត។

តែលើកនេះ ខុសពីលើកមុនៗ ពីព្រោះមានស្ថានទូតខ្មែរតាំងនៅក្រុងវៀងចន្ទ ដូច្នេះបងប្អូនខ្មែរនៅទីនោះ ភាគច្រើនជាកូនកាត់ខ្មែរ-ចិន មានមុខរបរផ្ទាល់ខ្លួន គិតតែពីរឿងរកស៊ីទទួលទាន និងបានវាយអែបទៅខាងមន្ត្រីស្ថានទូតខ្មែរ ពួកគេមិនចាប់អារម្មណ៍ពីរឿងចូលរួមតស៊ូជាមួយចលនាខ្មែរសេរីនោះទេ។

ពេលនោះ ក្រៅពី អ៊ុក ម៉ិល ដែលស្រលាញ់រាប់អានគ្នាជាយូរមកហើយ គាត់បានជួបមិត្តរួមថ្នាក់គាត់ម្នាក់ឈ្មោះ សៅ ង៉ុយ ធ្លាប់រៀនជាមួយគ្នាតាំងពីថ្នាក់ទី៦ រហូតដល់

បញ្ចប់ការសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ កាលពីឆ្នាំ១៩៥២ ក៏បានភៀសខ្លួនទៅរស់នៅទីក្រុងវៀងចន្ទ នោះដែរ។

សៅ ង៉ុយ និងអ៊ុក ម៉ិល ព្រមទាំងខ្មែរមួយចំនួនតូចនៅក្នុងប្រទេសឡាវ ក៏បានស្ម័គ្រចិត្តចូលរួមតស៊ូជាមួយចលនាខ្មែរសេរី ដែរ។ មួយខែក្រោយមក ឧត្តមសេនីយ៍ថៃ ធៈណៈ សមុទ្ទ ផាណិជ បានចាត់ឲ្យតម្រួតថៃម្នាក់ ទៅតាមរក ឡឹក សំអឿន នៅឯក្រុងវៀងចន្ទ ដើម្បីឱ្យមករៀបចំចលនាខ្មែរសេរី នៅព្រំដែនខ្មែរ-ថៃ ជាថ្មីម្តងទៀត។

គាត់ក៏បានលាឈប់ធ្វើការនៅក្រុមហ៊ុនដឹកជញ្ជូននោះ រួចហើយក៏បានធ្វើដំណើរទៅទីក្រុងបាងកក ជួបជាមួយឧត្តមសេនីយ៍ថៃ ធៈណៈ សមុទ្ទ ផាណិជ ដើម្បីរៀបចំរណសិរ្សយោធាភ្នំដងរែក ជាថ្មីឡើងវិញ។

២ថ្ងៃក្រោយមក គាត់បានចូលប្រជុំជាមួយតំណាងរដ្ឋាភិបាលថៃ ជាអ្នកទទួលខុសត្រូវក្នុងសហប្រតិបត្តិការជាមួយចលនាខ្មែរសេរី ដើម្បីឱ្យជួយបង្កើតប៉ុស្តិ៍វិទ្យុផ្សាយសំឡេងមួយ ឱ្យឈ្មោះថា វិទ្យុខ្មែរសេរី ដោយមានរូបគាត់ផ្ទាល់ និងសៅ ង៉ុយ ជាមិត្តភក្តិគាត់ទៅពីប្រទេសឡាវ ជាអ្នកទទួលខុសត្រូវតាក់តែងអត្ថបទសម្រាប់ចាក់ផ្សាយរៀងរាល់ថ្ងៃ ព្រមទាំងឈ្មោះ សួន អតីតអ្នកជំនាញផ្នែកវិទ្យុផ្សាយសំឡេង នៅក្រសួងឃោសនាការថៃ ជាអ្នកបច្ចេកទេស។

កម្មវិធីផ្សាយរបស់វិទ្យុខ្មែរសេរី មួយថ្ងៃមាន២លើក គឺលើកទី១ ចាប់ពីម៉ោង៦ ដល់ម៉ោង៧ព្រឹក និងលើកទី២ ពេលយប់ ចាប់ពីម៉ោង១៩ ដល់ម៉ោង២០ ចាក់ផ្សាយព័ត៌មានស្តីពីទំនាក់ទំនងរវាងរាជរដ្ឋាភិបាលសីហនុ ជាមួយប្លុកសង្គមនិយម ប្លុកកុម្មុយនិស្តនិយម, ផ្សាយអំពីសកម្មភាពយួនកុម្មុយនិស្ត និងខ្មែរកុម្មុយនិស្តនៅក្នុងទឹកដីខ្មែរ, ផ្សាយដំណឹងពីសកម្មភាពរបស់ចលនាខ្មែរសេរីនៅរណសិរ្សទាំងពីរ គឺនៅព្រំដែនវៀតណាម និងថៃ ព្រមទាំងបទវិចារណកថា រៀបរាប់ពីកំហុសនយោបាយដឹកនាំរបស់សម្តេចសីហនុ ទាំងក្នុង និងទាំងក្រៅប្រទេស, អំពីផលអាក្រក់នៃនយោបាយអត្តឃាតរបស់សម្តេចសីហនុ ដែលបាននាំមកនូវសេចក្តីវិនាសអន្តរាយដល់ប្រទេសជាតិ និងដល់ប្រជាពលរដ្ឋខ្មែរ។

## របត់នយោបាយ

ឡឹក សំអឿន បានឱ្យដឹងថា ក្នុងរយៈពេលមួយខែដំបូង ទោះបីវិទ្យុខ្មែរសេរីចាក់ផ្សាយបទវិចារណកថា វាយប្រហាររិះគន់ទិតៀនទៅលើសម្តេចសីហនុ យ៉ាងណា ក៏ព្រះអង្គ និងក្រសួងឃោសនាការនៅទីក្រុងភ្នំពេញ គ្មានប្រតិកម្មអ្វីទាំងអស់។

បន្ទាប់មក គាត់ក៏បានសរសេរអត្ថបទវិចារណកថាមួយ មានចំណងជើងថា សីហនុជានរណា? ចាក់ផ្សាយបន្តទៀត។

គ្រាន់តែផ្សាយបទវិចារណកថានេះបានប៉ុន្មានថ្ងៃប៉ុណ្ណោះ ស្រាប់តែសម្តេចសីហនុបានចេញមុខឆ្លើយតបវិទ្យុខ្មែរសេរីថា៖ ពីមុនខ្ញុំព្រះករុណាខ្ញុំ អត់ទ្រាំខាំមាត់សង្កត់ចិត្ត មិនឆ្លើយតបទេ ព្រោះអ្នកជំនាញការបរទេសជាទីប្រឹក្សារបស់ខ្ញុំព្រះករុណាខ្ញុំ ហាមមិនឱ្យមានប្រតិកម្មអ្វីទាំងអស់ ព្រោះបើមានប្រតិកម្មទៅ បានន័យថា ខាងរាជរដ្ឋាភិបាលជាអ្នកជួយផ្សាយឲ្យខ្មែរសេរីកាន់តែល្បី។ តែពេលនេះ ខ្ញុំព្រះករុណាទ្រាំមិនបានទេ ដែលពួកអាក្បត់ទាំងនេះបានគាស់កកាយពូជពង្សវង្សត្រកូល និងប្រមាថមើលងាយខ្ញុំព្រះករុណាខ្ញុំ។

ចាប់ពីពេលនោះមក វិទ្យុខ្មែរសេរី និងវិទ្យុភ្នំពេញ ក៏ចាប់ផ្តើមផ្ទុះសង្គ្រាមរលកធាតុ-អាកាសឆ្លើយឆ្លងគ្នារហូតមក ដូចអាយ៉ៃឆ្លើយឆ្លង។

ក្រោយពីបានរៀបចំកងទ័ពខ្មែរសេរីរួចមក ឡឹក សំអឿន បានចែករណសិរ្សយោធាភ្នំដងរែក ទៅជា២មូលដ្ឋានប្រតិបត្តិការគឺ៖ ទី១.មូលដ្ឋានប្រតិបត្តិការឧត្តរទិស មានជំរំប្រតិបត្តិការ២ និងទីបញ្ជាការមួយទៀត នៅលើជួរភ្នំដងរែកគឺ ជំរំភ្នំស្រួច ហៅជំរំតាទុំ ស្ថិតនៅជិតភូមិតាទុំ ក្នុងខេត្តសុរិន្ទ ប្រទេសថៃ,ជំរំភ្នំតាងិល ហៅថាជំរំកាប់ជើង ស្ថិតនៅក្នុងភូមិកាប់ជើង និងជំរំបោកប៉ីស្រីស្រណោះ ហៅថាជំរំបុកអម្ពិល នៅជិតភូមិបុកអម្ពិល ក្នុងខេត្តសុរិន្ទ។

ក្រៅពីជំរំនៅលើជួរភ្នំដងរែក គាត់បានរៀបចំឲ្យមានជំរំបណ្តោះអាសន្នមួយចំនួនទៀត ដូចជានៅភូមិគោករមៀត នៅភ្នំស្រីស្នំ ក្នុងខេត្តឧត្តរមានជ័យ, ជំរំនៅភូមិអន្លង់វែង នៅបន្ទាយស្រី នៅភ្នំគូលែន នៅវ៉ារិន ក្នុងខេត្តសៀមរាប, នៅជាំក្សាន្ត និងនៅរវៀង ក្នុងខេត្តព្រះវិហារ។

ចំណែកមូលដ្ឋានប្រតិបត្តិការទី២ គឺមូលដ្ឋានប្រតិបត្តិការបស្ចិមទិស មានជំរំភ្នំធត្រ ហៅថាជំរំតាផ្សារ ស្ថិតនៅជាប់ស្រុកតាផ្សារ, ជំរំអូរជ្រៅ ហៅថាជំរំអារញ្ញ ស្ថិតនៅជាប់ស្រុកអារញ្ញ និងជំរំភ្នំម៉ាឡៃ ស្ថិតនៅលើភ្នំម៉ាឡៃ។ ក្រៅពីនេះមានជំរំបណ្ដោះអាសន្ន៣ទៀតនៅតាមជាយដែនខ្មែរ-សៀម ជាប់នឹងខេត្តចន្ទបុរី គឺជំរំភ្នំព្រឹក, ជំរំចម្រៀក និងជំរំបរតាំងស៊ូ នៅក្នុងខេត្តបាត់ដំបង។

នៅក្នុងខែមេសា ឆ្នាំ១៩៦៤ បន្ទាប់ពីវិទ្យុសំឡេងខ្មែរសេរី ដំណើរការអស់រយៈពេលពីរខែមក សឺង ង៉ុកថាញ់ នៅខាងរណសិរ្សយោធាវាលភក់ នៅវៀតណាមខាងត្បូង ក៏បានបញ្ជូនសហការីឈ្មោះ ទិត អួន, សម ហ៊ាង និងសហការី៣នាក់ទៀត ឱ្យមកជួយការងារគាត់។

ជាមួយគ្នានោះដែរ មិត្តរបស់គាត់ម្នាក់ឈ្មោះ អ៊ឹង ម៉េងគ្រុយ ដែលបានមកចូលរួមតស៊ូជាមួយគាត់តាំងពីឆ្នាំ១៩៥២ តែក្រោយមកបានទៅបន្តការសិក្សានៅសហរដ្ឋអាមេរិកនោះ ក៏បានមកជួយទទួលខុសត្រូវខាងផ្សព្វផ្សាយឃោសនាសង្គ្រាមចិត្តសាស្ត្រ និងសកម្មភាពនៃចលនាខ្មែរសេរី តាមវិទ្យុសំឡេងខ្មែរសេរី នោះដែរ។ ដូច្នេះគាត់ក៏មានឱកាសចេញទៅបើកសាលាហ្វឹកហ្វឺនខាងក្បួនយុទ្ធសាស្ត្រ និងពីគោលនយោបាយខ្មែរសេរី ដល់នាយទាហាន និងនាយទាហានរង ដោយមាន អ៊ឹង ម៉េងគ្រុយ ជាអ្នកជួយអប់រំពួកគេឱ្យមានស្មារតីជាតិ-និយមផងដែរ។

វគ្គហ្វឹកហ្វឺនជំនាន់ទី១ មាននាយទាហាន២០នាក់ និងនាយទាហានរង៣០នាក់នោះ បានបញ្ចប់ការហ្វឹកហ្វឺននៅពាក់កណ្ដាលខែមិថុនា ឆ្នាំ១៩៦៤។ នាយទាហាន និងនាយទាហានរងជំនាន់ទី១ មានចំនួន៥ក្រុម មានគ្នា៣០នាក់ ដឹកនាំដោយអ៊ុក ម៉ុល មកពីក្រុងវៀងចន្ទ ត្រូវចេញដំណើរទៅរៀបចំបោះទីតាំងនៅជំរំតាទុំ។

វគ្គហ្វឹកហ្វឺនជំនាន់ទី២ មានគ្នា២៥នាក់ ហើយរយៈពេលសិក្សាតែ១ខែកន្លះ ដោយចាប់ផ្ដើមពីខែកក្កដា ឆ្នាំ១៩៦៤ ហើយត្រូវបញ្ចប់នៅពាក់កណ្ដាលខែសីហា ឆ្នាំដដែលនោះ។

## របត់នយោបាយ

ពេលទៅដល់ជំរំតាទុំ បានរយៈពេលតែមួយអាទិត្យប៉ុណ្ណោះ ស្រាប់តែ អ៊ុក ម៉ិល និងមេក្រុមម្នាក់ទៀត ឈ្មោះក្លាយ មានស្រុកកំណើតនៅភូមិចុងកាល់ បានរត់ទៅចុះចូលជាមួយទាហានរាជរដ្ឋាភិបាលនៅបន្ទាយសំពេង ក្នុងខេត្តឧត្តរមានជ័យ។

ក្រោយពីបានទទួលដំណឹងនេះភ្លាម ឡឹក សំអឿន ក៏ផ្អាកការហ្វឹកហ្វឺននាយទាហានជំនាន់ទី២ រួចដឹកនាំកម្លាំងទៅកាន់ជំរំតាទុំ ដើម្បីពិនិត្យសភាពការណ៍។ គាត់គិតថា អ្នកទាំងពីរ ដែលរត់ទៅចូលជាមួយទាហាននៅបន្ទាយសំពេង នោះ ពិសេស អ៊ុក ម៉ិល ច្បាស់ជារាយការណ៍ប្រាប់ទាហានរាជរដ្ឋាភិបាលពីគម្រោងការណ៍ទាំងប៉ុន្មានរបស់ខ្មែរសេរី ហើយពួកទាហានប្រាកដជានឹងរៀបផែនការទប់ទល់ជាមុនមិនខាន ដូច្នេះ គាត់ក៏សម្រេចចិត្តធ្វើសង្គ្រាមឈ្លបភ្លាម ព្រោះបើមិនប្រញាប់ធ្វើសង្គ្រាមឈ្លបឱ្យបានមុនទេ ពួកគាត់នឹងមានការលំបាកក្នុងការចាប់ផ្ដើមតស៊ូនៅរណសិរ្សយោធាភ្នំដងរែកនោះ ជាមិនខាន។

ម្យ៉ាងទៀត ដោយសំអាងទៅលើប្រជាពលរដ្ឋនៅក្នុងតំបន់នោះ ធ្លាប់បានដឹងបានស្គាល់ស្នាដៃ និងកេរ្តិ៍ឈ្មោះតស៊ូរបស់តាំងពីសម័យទាមទារឯករាជ្យពីបារាំង គាត់ក៏បានសាកល្បងទាក់ទងកងជីវពលរបស់រាជរដ្ឋាភិបាល នៅភូមិថ្កាមរមាស នៅជាប់នឹងជើងភ្នំដងរែក។

នៅភូមិថ្កាមរមាស កងជីវពលមានគ្នា១២នាក់ និងមាននាយទាហានរងរបស់រាជ-រដ្ឋាភិបាលពីរនាក់ទៀតជាអ្នកទទួលខុសត្រូវ។ ពេលលួចជួបគ្នាដំបូង មេកងជីវពលជាអតីតគណៈកម្មការភូមិ ដែលគាត់ធ្លាប់ស្គាល់គ្នាពីមុនមកនោះ បានសម្ដែងនូវការរំភើបចិត្តជាខ្លាំង ហើយប្រាប់គាត់ថា ក្នុងចំណោមកងជីវពលទាំង១២នាក់នោះ មានសមាជិក៨នាក់ ជាអតីតយុទ្ធជនរបស់គាត់ដែរ។

ឡឹក សំអឿន បានស្នើឲ្យមេកងជីវពលនោះធ្វើសហការជាមួយកម្លាំងរបស់គាត់រៀបចំផែនការចាប់ឈ្មោះ អ៊ុក ម៉ិល និងឈ្មោះក្លាយ ដែលពួកទាហាននៅបន្ទាយសំពេង ចាត់ឱ្យមកប្រចាំការនៅភូមិថ្កាមរមាស នោះ យកមកវិញ។ មេកងជីវពលប្រាប់គាត់វិញថា ចាំទៅស្ទាបស្ទង់ចិត្តកងជីវពលជាកូនក្រុមគាត់សិន។

លុះដល់ពេលជួបគ្នាលើកទី២ ដោយមានកូនក្រុម៣នាក់មកជាមួយផង មេកងជីវពលនោះ ក៏ប្រាប់គាត់ថា ពួកគេមិនត្រឹមតែចូលរួមធ្វើប្រតិបត្តិការចាប់ឈ្មោះ អ៊ុក ម៉ិល និងឈ្មោះ ក្លាយ នោះប៉ុណ្ណោះទេ គឺពួកគេនឹងស្ម័គ្រចិត្តចូលបម្រើចលនាខ្មែរសេរីទៀតផង។

ឮដំណឹងដូច្នេះ ឡឹក សំអឿន ត្រេកអរយ៉ាងខ្លាំង ហើយក៏បានលើកពីផែនការធ្វើប្រតិបត្តិការចាប់ឈ្មោះ អ៊ុក ម៉ិល និងឈ្មោះក្លាយ ឱ្យបានយល់ច្បាស់ទាំងអស់គ្នា។ លុះដល់ថ្ងៃកំណត់អនុវត្តផែនការ នៅពេលយប់ស្ងាត់ ឡឹក សំអឿន បានបញ្ជាឱ្យកងកម្លាំង៤ក្រុម មានគ្នាសរុប២៤នាក់ទៅកាន់កន្លែងណាត់ជួបគ្នាជាមួយកងជីវពលភូមិថ្កាមរមាស ៨នាក់ ហើយនាំគ្នាលបចូលទៅក្នុងភូមិ ភ្ជង់កាំភ្លើងចាប់ឈ្មោះ អ៊ុក ម៉ិល និងឈ្មោះ ក្លាយ កំពុងតែដេកលក់នៅក្នុងរោងប្រចាំការ នាំមកជួប ឡឹក សំអឿន។ តែ ឡឹក សំអឿន មិន បានប្រកាន់ទោសពួកគេទាំងពីរនាក់ទេ គឺគ្រាន់តែនិយាយអប់រំណែនាំរយៈពេលប្រហែលកន្លះម៉ោង ក៏ដោះលែងឲ្យត្រលប់ទៅក្នុងភូមិវិញ។ ចំណែកឯកងជីវពលភូមិថ្កាមរមាស ៨នាក់ ក៏បានធ្វើដំណើរជាមួយគាត់ឡើងទៅជំរំតាទុំ វិញ។

មួយអាទិត្យក្រោយមក ឡឹក សំអឿន បានរៀបចំទុកកងកម្លាំង៣០នាក់ និងក្រុមកងជីវពលជាអ្នកចំណូលថ្មីចំនួន ៨នាក់ទៀត ឱ្យឈរជើងនៅជំរំតាទុំ នោះ ហើយកងកម្លាំងនៅសល់ប៉ុន្មាន គាត់បាននាំទៅរៀបចំជំរំ២ទៀត គឺនៅបុកអម្ពិល និងនៅកាប់ជើង។

នៅជំរំបុកអម្ពិល គាត់បានធ្វើការទាក់ទងជាមួយអតីតគណៈកម្មការភូមិ និងអតីតយុទ្ធជនរបស់គាត់នៅក្នុងភូមិថ្នល់, ភូមិឈើស្លាប់, ភូមិគោកខ្ពស់, ភូមិប្រើយ, ភូមិគូ, ភូមិគោកមន និងភូមិអម្ពិល ដើម្បីបង្កើតបណ្តាញសម្ងាត់ផ្តល់ដំណឹង និងផ្តល់ស្បៀង។ តែពួកគាត់ពុំបានរៃអង្គាសស្បៀងអាហារពីប្រជាពលរដ្ឋដូចសម័យឥស្សរៈទេ គឺគាត់ប្រគល់ប្រាក់ទៅឱ្យអ្នកទទួលខុសត្រូវ ឲ្យទិញស្បៀងអាហារពីប្រជាពលរដ្ឋ។

នៅតំបន់ខាងលើនោះ មានភាពងាយស្រួលណាស់ក្នុងការរៀបចំបណ្តាញសម្ងាត់ ពីព្រោះជាកន្លែងធ្លាប់នៅក្រោមការគ្រប់គ្រងរបស់អតីតមេខ្មែរឥស្សរៈ កៅ តក់ ហើយក្រោយសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ ឡឹក សំអឿន ក៏បានមកទទួលខុសត្រូវក្នុងតំបន់នេះ

ព្រោះជាតំបន់កសិកម្ម និងចិញ្ចឹមសត្វរបស់ចលនាឥស្សរៈរួមខ្មែរបម្រើជាតិ កាលពីសម័យតស៊ូដណ្ដើមឯករាជ្យពីបារាំងដែរ។

ជាមួយគ្នានោះ គាត់ក៏បានដឹកនាំប្រជាពលរដ្ឋ ព្រមទាំងព្រះសង្ឃគង់នៅវត្តអារាមផ្សេងៗនៅតំបន់នោះ កសាងទំនប់ទឹកនៅតាមដងអូរទាំងឡាយ ដើម្បីយកទឹកធ្វើស្រែ និងបង្ហាត់បង្រៀនឲ្យចេះប្រើជីគីមី ដើម្បីទទួលបានទិន្នផលស្រូវខ្ពស់ ហើយថែមទាំងឲ្យប្រជា-ពលរដ្ឋខ្ចីប្រាក់ទិញគោក្របីធ្វើស្រែចម្ការ ដោយឥតយកការប្រាក់ទៀតផង។

បន្ទាប់មក គាត់បានដឹកនាំកងកម្លាំង៤០នាក់ធ្វើដំណើរទៅរៀបចំជំរំកាប់ជើង ជាទីបញ្ជាការរបស់មូលដ្ឋានឧត្តរទិស បន្តទៀត។ នៅទីនោះ គាត់យល់ថា ដើម្បីត្រៀមទប់ទល់នឹងការវាយប្រហាររបស់ទាហានរាជរដ្ឋាភិបាល គាត់បានស្នើទៅ សឺង ង៉ុកថាញ់ ប្រមុខនៃចលនាខ្មែរសេរី សុំបញ្ជូនកងកម្លាំងដែលមានសមត្ថភាពប្រយុទ្ធពីរណសិរ្សយោធាវាលកក់នៅកម្ពុជាក្រោម មកជាជំនួយ។

ជាដំបូង សឺង ង៉ុកថាញ់ បានបញ្ជូនមនុស្សសំខាន់ៗ ចំនួន២០នាក់ ដែលបានរត់ចេញពីទីក្រុងភ្នំពេញ មកចូលរួមចលនាឥស្សរៈរួមខ្មែរបម្រើជាតិ តាំងពីទសវត្សរ៍ឆ្នាំ១៩៥០នោះ ឲ្យមកជាជំនួយថែមទៀត។

# ១៦៤
# កងទ័ពខ្មែរសេរី ស្ទាក់វាយទាហានរាជរដ្ឋាភិបាល



**តំបន់ជួរភ្នំដងរែកទីតាំងចលនាតស៊ូខ្មែរសេរី**

នៅដើមឆ្នាំ១៩៦៥ សឹង ង៉ុកថាញ់ បានបញ្ជូនកងកម្លាំងមានបទពិសោធខ្ពស់ក្នុងការប្រយុទ្ធចំនួនមួយកងវរសេនាតូច (មាន៣កងអនុសេនាធំ) ពីរណោសិរ្សយោធាវាលភក់ នៅកម្ពុជាក្រោម មកឱ្យគាត់បន្ថែមទៀត។

ជាមួយគ្នានោះ សឹង ង៉ុកថាញ់ ក៏បានបញ្ជូន សុង សាក់ ដែលទើបរត់គេចពីការតាមចាប់ខ្លួននៃអាជ្ញាធរខ្មែរ ហើយស្ម័គ្រចិត្តចូលបម្រើចលនាខ្មែរសេរី នៅកម្ពុជាក្រោមនោះ ឱ្យមកធ្វើជាទីប្រឹក្សានៃចលនាខ្មែរសេរីនៅរណសិរ្សភ្នំដងរែក ផងដែរ។

ឡឹក សំអឿន បានអះអាងថា ក្រោយពីកងកម្លាំងជំនួយមកដល់បានមួយអាទិត្យ គាត់ក៏បើកប្រតិបត្តិការពួនស្ទាក់វាយកងកម្លាំងជំនួយរបស់រាជរដ្ឋាភិបាល ដែលត្រូវបញ្ជូនឱ្យមកជួយកងរាជតម្រួតនៅបន្ទាយអូរស្មាច់ អស់រយៈពេល២យប់ ទើបឃើញកងកម្លាំង

## របត់នយោបាយ

រាជរដ្ឋាភិបាល ដឹកនាំដោយ ជា គឹមអេង មេបញ្ជាការផ្នែកសឹករង និងជាអភិបាលខេត្តឧត្តរ-មានជ័យ មកដល់ ។

ភ្លាមនោះ គាត់ក៏បញ្ជាឱ្យបើកការវាយប្រហារនៅផ្លូវឡើងទៅបន្ទាយអូរស្មាច់នោះ បណ្តាលឱ្យកងកម្លាំងរាជរដ្ឋាភិបាលស្លាប់ និងរបួសមួយចំនួន ក្នុងនោះមានឈ្មោះ អ៊ឹម ស៊ីយ៉ា ជានាយទាហានការិយាល័យទី២ នៃអគ្គសេនាធិការនៅភ្នំពេញ ដែលមកបំពេញបេសកកម្ម មកស៊ើបអង្កេតពីសកម្មភាពខ្មែរសេរី ក៏ត្រូវរងរបួសដែរ។ ឯកងកម្លាំងរាជរដ្ឋាភិបាល ដែល បាក់ទ័ពរត់ចុះពីលើភ្នំនោះ កងទ័ពគាត់ពុំដេញតាមវាយទេ គឺទុកឱកាសឱ្យពួកគេដកថយ តាមសម្រួល។

ក្នុងការពួនស្ទាក់វាយកងកម្លាំងរាជរដ្ឋាភិបាលនេះ ពួកគាត់បានរឹបអូសបានកាំភ្លើង ប៉េអឹមចិន ចំនួន១៥ដើម,កាំភ្លើងយន្តចិន ចំនួន២ដើម កាំភ្លើងបេ៤០ចិន ចំនួន២ដើម កាំភ្លើងខ្លីម៉ាកប៉េអាកុល ចំនួន១ដើម ព្រមទាំងគ្រាប់រំសេវ និងគ្រាប់បែកមួយចំនួនទៀត។

ឡឹក សំអឿន បានបន្តថា ប្រហែល១ខែក្រោយមកទៀត រាជរដ្ឋាភិបាលបានបញ្ជូន កម្លាំងជំនួយមកបន្ថែមមួយកងវរសេនាតូច ក្រោមបញ្ជារបស់ កែវ សង្ហាត មកដល់ខេត្ត ឧត្តរមានជ័យ ដើម្បីបង្ក្រាបពួកគាត់នៅរណសិរ្សភ្នំដងរែកនោះ បន្តទៀត។

ទាហានរបស់រាជរដ្ឋាភិបាលដែលចុះមកបង្ក្រាបនេះ បានរៀបចំវិធានការមួយចំនួន គឺ ១.ហាមប្រជាពលរដ្ឋមិនឱ្យទាក់ទងជាមួយខ្មែរសេរី ដោយបានកំណត់ខ្សែបន្ទាត់ការពារ និងធ្វើការយាមល្បាតជារៀងរាល់ថ្ងៃ, ២.សង់បន្ទាយនៅត្រង់ចំណុចសំខាន់ៗ តាមច្រកចុះ ឡើងទៅលើភ្នំដងរែក, ៣.ធ្វើប្រតិបត្តិការសឹកដេញតាមពួកខ្មែរសេរី កុំឱ្យចូលមកឃោសនា អប់រំប្រជាពលរដ្ឋក្នុងភូមិបាន, ៤.រៀបចំកម្លាំងសន្តិសុខនៅតាមភូមិ ដោយឱ្យអ្នកភូមិផ្ទាល់ យាមកាម និងការឃ្លាំមើល ក្រែងមានខ្មែរសេរីចូលមកបណ្តុះស្នូលនៅក្នុងភូមិ, ៥.ហាមអ្នក ភូមិមិនឱ្យចូលព្រៃ ព្រោះខ្លាចទៅលួចទាក់ទងជាមួយពួកខ្មែរសេរី ហើយបើរកឃើញអ្នកភូមិ ណាទាក់ទងជាមួយពួកខ្មែរសេរី នឹងត្រូវផ្តន្ទាទោសជាទម្ងន់។

តែវិធានការទាំងនេះ ធ្វើឲ្យប្រជាពលរដ្ឋរស់នៅតាមតំបន់ជួរភ្នំដងរែក មិនសប្បាយ

ចិត្ត ព្រោះពួកគេធ្លាប់តែប្រកបមុខរបររកស៊ីទទួលទានចូលក្នុងព្រៃបោចវល្លិ កាប់ឬស្សី រកជ័រចុង កាប់ឧស ជាដើម បានដោយសេរីតាំងពីដូនតាមកនោះ ពួកគាត់ក៏នាំគ្នាលួចចូលទៅឃោសនាធ្វើសង្គ្រាមចិត្តសាស្ត្របំផុសឲ្យអ្នកស្រុកស្អប់ពួកទាហានរបស់រាជរដ្ឋាភិបាលនាំគ្នាមកគាំទ្រពួកគាត់វិញ។

ជាមួយគ្នានោះ គាត់ក៏បានបើកការវាយប្រហាររំខានដល់ពួកទាហានរាជរដ្ឋាភិបាលដែលមកសាងសង់បន្ទាយនៅតំបន់នោះផងដែរ។ ឯពួកទាហានរបស់រាជរដ្ឋាភិបាល ក៏បានព្យាយាមតាមរុករកកងកម្លាំងពួកគាត់ ដែលចូលទៅធ្វើសង្គ្រាមចិត្តសាស្ត្រនៅតាមភូមិនោះដែរ។

ពេលនោះដែរ គាត់បានរៀបចំកម្លាំងឧត្តរទិសសាជាថ្មី ដោយដាក់កម្លាំងចំនួន១២ក្រុម ស្មើនឹង៨២នាក់នៅតាមជំរំប្រតិបត្តិការនីមួយៗ និងដាក់កម្លាំង១០២នាក់នៅទីបញ្ជាការ។

លុះរៀបចំកម្លាំងនៅតាមជំរំមូលដ្ឋានប្រតិបត្តិការឧត្តរទិស លើភ្នំដងរែក រួចហើយគាត់បានទៅរៀបចំមូលដ្ឋានប្រតិបត្តិការបស្ចិមទិស រួមមាន ជំរំប្រតិបត្តិការភ្នំចត្រ, ជំរំអូរជ្រៅ និងជំរំទីបញ្ជាការនៅភ្នំម៉ាឡៃ ជាបន្តទៀត។

នៅមូលដ្ឋានបស្ចិមទិសនេះ គាត់បានពឹងផ្អែកទៅលើអ្នករត់ពន្ធធ្វើជាមធ្យោបាយមួយដ៏មានប្រសិទ្ធភាពបំផុតក្នុងការបង្កើតបណ្តាញសម្ងាត់ ដើម្បីផ្តល់ដំណឹង និងផ្តល់ស្បៀងចូលជ្រៅទៅក្នុងប្រទេស ព្រមទាំងជាមធ្យោបាយមួយដ៏សំខាន់ក្នុងសង្គ្រាមចិត្តសាស្ត្រផងដែរ។

គាត់បានរៀបចំឲ្យមានផ្សាររត់ពន្ធជាមួយអ្នកជំនួញតូចធំមកពីក្នុងដីថៃ និងបានរៀបចំឲ្យមានសន្តិសុខគ្រប់គ្រាន់ ព្រមទាំងមិនបាច់ឱ្យអ្នករត់ពន្ធទាំងអស់បង់វិភាគទានដល់ពួកគាត់ទៀតផង។

បន្ទាប់ពីរៀបចំមូលដ្ឋានបស្ចិមទិសរួច គាត់ក៏ត្រលប់ទៅមូលដ្ឋានឧត្តរទិសវិញ ព្រោះទទួលដំណឹងថា កម្លាំងទាហានរាជរដ្ឋាភិបាល ដែលទើបបញ្ជូនមកដល់បន្ថែមទៀតនោះ កំពុងចាប់ផ្តើមសង់បន្ទាយ ចំនួន ៣កន្លែងទៀត គឺនៅក្នុងភូមិផ្អុង សង់ជាបន្ទាយទីបញ្ជាការ

នៃកងវរសេនាតូច។ នៅខាងកើតភូមិផ្អុង គឺភូមិជ្រឹង សង់បន្ទាយមួយ និងនៅភូមិត្រពាំងតៅ សង់បន្ទាយផ្នែកសឹករងនៅឧត្តរមានជ័យ។

ពេលនោះ គាត់បានដឹកនាំកងកម្លាំងនៅជំរំតាទុំ បើកការវាយប្រហារទៅលើបន្ទាយត្រពាំងតៅ ទាំងថ្ងៃត្រង់ គឺចំថ្ងៃអ្នកស្រុកធ្វើពិធីបុណ្យផ្កាមួយ។ នៅក្នុងការវាយប្រហារទៅលើបន្ទាយត្រពាំងតៅនេះ កងកម្លាំងគាត់មានចំនួន៣ក្រុមប៉ុណ្ណោះ តែវិទ្យុនៅភ្នំពេញ បានផ្សាយថា ខ្មែរសេរីមានកងកម្លាំងចំនួន២០០នាក់ ហើយថា មានទាហានអាមេរិកជាអ្នកដឹកនាំទៀតផង។ តែការវាយប្រហារនេះ ពុំបណ្តាលឱ្យទាហានរាជរដ្ឋាភិបាលណាម្នាក់បាត់បង់អាយុជីវិតទេ ព្រោះមាននេសាទក្នុងផ្តល់ព័ត៌មានឱ្យទាហានរាជរដ្ឋាភិបាលដឹងជាមុន។

ចំណែកទាហានរាជរដ្ឋាភិបាលវិញ ពុំអាចបង្ក្រាបសកម្មភាពរបស់កម្លាំងខ្មែរសេរីបានហើយចេះតែមានគ្រោះថ្នាក់ដោយសារការពួនស្ទាក់ និងការវាយប្រហាររំខានពេលកំពុងសាងសង់បន្ទាយនោះ ពួកគេក៏បានវាយគ្រាប់មីនកប់ក្នុងដីតាមច្រកចុះឡើងទៅភ្នំដងរែកបណ្តាលឲ្យអ្នកភូមិដែលចូលទៅរកបោចវល្លិ កាប់ឫស្សី រកជ័រចុង កាប់ឧសនៅក្នុងព្រៃនោះជាន់មីនផ្ទុះស្លាប់ និងរបួសជាបន្តបន្ទាប់។

ឃើញទាហានរាជរដ្ឋាភិបាលធ្វើដូច្នេះ ពួកគាត់ក៏បានវាយគ្រាប់មីនកប់ក្នុងដីនៅតាមផ្លូវថ្នល់ និងតាមផ្លូវរទេះ ដើម្បីឱ្យរថយន្ត និងទាហានរាជរដ្ឋាភិបាល បើកកិន និងដើរជាន់មីននោះផ្ទុះស្លាប់ និងរបួសវិញដែរ។ តែមិនមែនមានតែទាហានរាជរដ្ឋាភិបាលដើរជាន់មីនពួកគាត់ទេ គឺមានអ្នកភូមិមួយចំនួនបានដើរជាន់មីនពួកគាត់ បណ្តាលឱ្យស្លាប់ និងរបួសជាច្រើននាក់ផងដែរ ហើយពួកគាត់បានឃោសនាតាមវិទ្យុផងតាមបណ្តាញសម្ងាត់ផងទម្លាក់កំហុសទៅលើទាហានរាជរដ្ឋាភិបាលថា ជាអ្នកវាយគ្រាប់មីនកប់ក្នុងដីនោះ ធ្វើឲ្យប្រជាពលរដ្ឋកាន់តែមានកំហឹងឈឺចាប់ទៅលើទាហានរាជរដ្ឋាភិបាលកាន់តែច្រើនខ្លាំងៗជាលំដាប់។

ឡឹក សំអឿន បានបន្តទៀតថា ថ្ងៃមួយមានក្បួនរថយន្តទាហានចំនួន៣គ្រឿង ក្នុងនោះមានរថយន្តហ្ស៊ីប១គ្រឿង និងរថយន្តហ្សេអឹមសេ២គ្រឿងធ្វើដំណើរទៅកាន់ភូមិជ្រឹងដែលពួកទាហានកំពុងសាងសង់បន្ទាយនោះ ពួកគាត់ក៏បានដាក់មីន និងវាយកម្លាំងពួនស្ទាក់

នៅត្រង់អូរមួយនៅចម្ងាយប្រហែល២គីឡូម៉ែត្រពីភូមិជ្រឹង។

នៅពេលក្បួនរថយន្តចុះទឹកឆ្លងអូរ ចូលក្នុងការពួនស្ទាក់របស់ពួកគាត់ បណ្តាលឱ្យរថយន្តហ្ស៊ីប និងរថយន្តហ្សេអឹមសេមួយគ្រឿង បើកជាន់មីនពួកគាត់ផ្ទុះលាន់កក្រើកផ្ទួនៗគ្នាបណ្តាលឱ្យសម្ភារៈទាំងឡាយនៅលើរថយន្តប៉ើងធ្លាក់អណ្តែតពេញទាំងជងអូរ។ ចំណែកកម្លាំងទាហានដែលជិះលើរថយន្តហ្សេអឹមសេ១គ្រឿងទៀតនៅខាងក្រោយគេ ក៏បានលោតចុះរត់ត្រលប់ទៅក្រោយវិញ ដោយមិនហ៊ានតស៊ូប្រយុទ្ធជាមួយពួកគាត់បន្តិចឡើយ ហើយមុនពេលត្រលប់ទៅជំរំវិញ ពួកគាត់បានដុតបំផ្លាញរថយន្តទាំងអស់នោះចោល។

ប៉ុន្មានថ្ងៃក្រោយមក វិទ្យុភ្នំពេញបានផ្សាយព័ត៌មានស្តីពីការពួនស្ទាក់នេះ ទើបពួកគាត់ដឹងថា ក្បួនរថយន្តនោះ ជាក្បួនរថយន្តកងពលតូចមួយរបស់ទាហានរាជរដ្ឋាភិបាល ដែលមានមេបញ្ជាការឈ្មោះ កែវ សង្វាត ធ្វើដំណើរទៅត្រួតពិនិត្យការសង់បន្ទាយនៅភូមិជ្រឹងនោះ។

ចាប់តាំងពីមានការដាក់មីនវាយកម្លាំងពួនស្ទាក់នោះមក ទាហានរាជរដ្ឋាភិបាល ក៏បានបញ្ឈប់ការសាងសង់បន្ទាយនៅភូមិជ្រឹង និងភូមិត្រុម នោះដែរ ហើយកម្លាំងតស៊ូរបស់គាត់នៅមូលដ្ឋានប្រតិបត្តិការឧត្តរទិសលើភ្នំដងរែក និងនៅមូលដ្ឋានប្រតិបត្តិការបស្ចិមទិស ក៏មានឱកាសចូលទៅក្នុងភូមិធ្វើសកម្មភាពឃោសនាអប់រំអ្នកភូមិបានដោយស្រួល មិនសូវមានការដេញតាមបង្ក្រាបពីទាហានរដ្ឋាភិបាលប៉ុន្មានទេ។

# ១៦៥
# សម្ដេចសីហនុ ទាត់ចោលជំនួយអាមេរិក ទទួលជំនួយចិន និងសូវៀត




**សម្ដេចសីហនុ និងមេដឹកនាំចិន ម៉ៅ សេទុង**

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៦៣ ជាថ្ងៃបើកសមាជ ដើម្បីឱ្យអង្គសមាជទាំងមូលធ្វើការពិភាក្សាពីបញ្ហាឈប់ទទួលជំនួយអាមេរិក រាជរដ្ឋាភិបាលកម្ពុជា ក៏បានធ្វើកំណត់ការទូតមួយទៅរដ្ឋាភិបាលសហរដ្ឋអាមេរិក ឱ្យបានដឹងពីគោលបំណងនៃការឈប់ទទួលជំនួយយោធា សេដ្ឋកិច្ច បច្ចេកទេស និងវប្បធម៌ ពីសហរដ្ឋអាមេរិក ព្រមទាំងស្នើសុំបើកការចរចាជាមួយអាមេរិក ដើម្បីទូទាត់បញ្ចប់កម្មវិធីគម្រោងនៃជំនួយផ្សេងៗនេះទៀតផង។

នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៦៣ កម្ពុជា និងសហរដ្ឋអាមេរិក ក៏បានបើកការចរចាស្ដីពីបញ្ហាបញ្ឈប់ទទួលជំនួយពីសហរដ្ឋអាមេរិក និងទូទាត់បញ្ចប់កម្មវិធីគម្រោងជំនួយផ្សេងៗទាំងអស់។

ក្រោយបញ្ចប់ការចរចានេះបាន៣-៤ថ្ងៃ ពួកអ្នកការទូតអាមេរិក ក៏បានធ្វើការទស្សន៍ទាយជាសាធារណៈថា មិនយូរប៉ុន្មាន មេដឹកនាំប្រទេសកម្ពុជា ប្រាកដជាតាមអង្វរសហរដ្ឋអាមេរិក ឱ្យផ្តល់ជំនួយនេះឡើងវិញជាមិនខាន។

តែទោះបីយ៉ាងណា ក៏សម្តេចសីហនុ ក្នុងនាមជាព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា បានមានបន្ទូលថា បើទោះបីជាប្រទេសម្ចាស់ជំនួយ (អាមេរិក) បានអះអាងថា ពួកគេនឹងជួយប្រទេសយើងឱ្យមានស្វ័យភាពខាងសេដ្ឋកិច្ចក៏ពិតមែន តែក៏ធ្វើឱ្យប្រទេសយើងស្ថិតនៅ ក្រោមចំណុះរបស់ប្រទេសជាម្ចាស់ជំនួយនោះដែរ ហើយបើប្រទេសយើងចង់ចៀសវាង កុំឱ្យជួបវាសនាជាអ្នកទោសដូចជាប្រទេសថៃ វៀតណាមខាងត្បូង និងលាវ នោះ យើងត្រូវតែវះ កាត់ក្នុងការឈប់ទទួលជំនួយនេះ។ ទោះបីមានការអះអាងដោយផ្ទាល់ពីប្រធានាធិបតី ចន អែហ្វ. កេណ្ណឌី ថា សហរដ្ឋអាមេរិក គាំទ្រអព្យាក្រឹតភាពរបស់ប្រទេសកម្ពុជា ហើយមិនគាំទ្រដល់ចលនាខ្មែរសេរី ក៏ដោយ ក៏សម្តេចសីហនុ នៅតែប្រកាសឈប់ទទួលជំនួយរបស់សហរដ្ឋអាមេរិក ដែលមានតម្លៃប្រហែល១៥ភាគរយ នៃថវិកាជាតិនោះដែរ។

ទាក់ទងដល់បញ្ហាទទួលជំនួយពីសហរដ្ឋអាមេរិក នេះដែរ ក្រោយពីសម្តេចសីហនុបានឡើងសោយរាជសម្បត្តិជាព្រះមហាក្សត្ររបស់ប្រទេសកម្ពុជា ជាថ្មីម្តងទៀតចាប់ពីឆ្នាំ១៩៩៣មក នៅក្នុងឆ្នាំ២០០៤ មានតំណាងនិស្សិតមួយក្រុមបានសរសេរអ៊ីម៉ែល(email) មកព្រះអង្គ ដោយបានចោទប្រកាន់ព្រះអង្គថា ក្រោមការដឹកនាំរបស់សីហនុ កាលពីទសវត្សរ៍ឆ្នាំ១៩៥០ និង១៩៦០ ព្រះអង្គមិនព្រមទទួលជំនួយអាមេរិកាំង។

នៅទីក្រុងប៉េកាំង ថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៤ ព្រះមហាក្សត្រសីហនុ បានសរសេរអត្ថបទមួយឆ្លើយតបថា ថ្មីៗនេះ មាននិស្សិតជាតិយើងខ្លះបាននិយាយប្រាសចាកពីការពិតដោយអយុត្តិធម៌ថា ទូលព្រះបង្គំជាខ្ញុំព្រះករុណាខ្ញុំ ភូតកុហកថា នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ និង១៩៦០ ពេលដែលខ្ញុំព្រះករុណាគង់ជាប្រមុខរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជាទី១ ខ្ញុំព្រះករុណា មិនបានទទួលជំនួយអាមេរិកាំងទេ។

ខ្ញុំព្រះករុណា សូមព្រះសង្ឃគ្រប់ព្រះអង្គជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងជនរួមជាតិ

## របត់នយោបាយ

បងប្អូនកូនចៅ ចៅទួតជាទីស្រលាញ់ដ៏ជ្រាលជ្រៅជាទីបំផុត ព្រះមេត្តា និងមេត្តាផ្ដល់យុត្តិធម៌ដល់ខ្ញុំព្រះករុណាចំពោះការក្រឡៃការពិតខុសស្រឡះពីប្រវត្តិសាស្ត្រ ដែលតំណាងនិស្សិតមួយក្រុមបានចោទប្រកាន់នេះផង។

ខ្ញុំព្រះករុណា បានសរសេរចុះផ្សាយតាមប្រព័ន្ធអ៊ិនធើណិត និងក្នុងព្រឹត្តិបត្របេអឹមដេ (BMD) ជាច្រើនលើកច្រើនគ្រាមកហើយ អំពីការមិនពេញចិត្តចំពោះខ្ញុំព្រះករុណាខ្ញុំពីសំណាក់នាយទាហាន នាយទាហានរងនៃកងយោធពលខេមរភូមិន្ទ នៅពេលដែលខ្ញុំព្រះករុណាសម្រេចឈប់ទទួលយកជំនួយរបស់សហរដ្ឋអាមេរិក នៅ ឆ្នាំ១៩៦៣។

ជាមួយគ្នានេះ ខ្ញុំព្រះករុណាក៏បានសរសេរបញ្ជាក់ហើយបញ្ជាក់ទៀតថា កម្ពុជា បានទទួលជំនួយអាមេរិក តាំងពីទសវត្សរ៍ឆ្នាំ១៩៥០ រហូតដល់ឆ្នាំ១៩៦៣។ ដូច្នេះ សូមព្រះសង្ឃគ្រប់ព្រះអង្គជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងជនរួមជាតិបងប្អូនកូនចៅ ចៅទួតជាទីស្រលាញ់ដ៏ជ្រាលជ្រៅបំផុត ព្រះមេត្តា និងមេត្តាពិចារណាថា តើការសម្រេចឈប់ទទួលជំនួយនេះមានន័យថា ព្រះរាជាណាចក្រកម្ពុជាទី១ បានទទួលជំនួយពីអាមេរិកាំងដែរឬទេ? បើមិនដែលបានទទួលជំនួយពីគេទេនោះ តើហេតុដូចម្ដេចបានជាខ្ញុំព្រះករុណាសម្រេចឈប់ទទួលជំនួយនោះកើត?។

នៅក្នុងខែឧសភា ឆ្នាំ២០០៤ ដដែលនោះ សម្ដេចសីហនុ បានសរសេរលិខិតមួយទៀតថា ខ្ញុំព្រះករុណា មានការឈឺចាប់ហួសប្រមាណ ចំពោះការសរសេរប្រមាថខ្ញុំព្រះករុណាដែលមានជន្មាយុ៨២ឆ្នាំហើយ ពីសំណាក់និស្សិតមួយក្រុមនោះ។ តើការពិតវាយ៉ាងដូចម្ដេច? ខ្ញុំព្រះករុណា សូមបញ្ជាក់ជូនជនរួមជាតិបងប្អូន កូនចៅ ចៅទួតឱ្យបានជ្រាបថា ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦៣ គឺប្រទេសកម្ពុជា ដែលបានទទួលជំនួយនោះ ពោលគឺមិនមែនបុគ្គលខ្ញុំព្រះករុណា នរោត្តម សីហនុ ទេ។ ខ្ញុំព្រះករុណា មិនដែលបានទទួលប្រាក់ ទទួលសំណូកពីនរណាម្នាក់ទេ។ ខ្ញុំព្រះករុណា ស្អប់ណាស់។ ដោយសារខ្ញុំព្រះករុណា ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនោះហើយ ដែលជាហេតុនាំឲ្យគេគុំគួនខ្ញុំព្រះករុណា និងទម្លាក់ខ្ញុំព្រះករុណា ។

ព្រះមហាក្សត្រសីហនុ បានបន្តថា កាលនោះ កម្ពុជា បានទទួលជំនួយពីអាមេរិកាំង

ក្នុងមួយឆ្នាំៗ គិតជាទឹកប្រាក់សរុបទាំងអស់៣០លានដុល្លារអាមេរិក តែមិនមែនផ្តល់ជាសាច់ប្រាក់នោះទេ គឺគេបូកសព្វគ្រប់អំពីតម្លៃបរិក្ខារផ្សេងៗ មានតម្លៃអគារដែលគេជួយសាងសង់ តម្លៃផ្លូវថ្នល់ តម្លៃរថយន្ត តម្លៃគ្រាប់កាំភ្លើងអាវុធយុទ្ធភណ្ឌ និងជួយដល់វិស័យអប់រំ សុខាភិបាល វិស័យផ្សេងៗទៀត ពិសេសជួយខាងយោធាច្រើនជាងគេ។

កាលពីឆ្នាំ១៩៦៣ ខ្ញុំព្រះករុណា បានសរសេរជម្រាបជនរួមជាតិជាភាសាបារាំង ស្តីពីជំនួយរបស់អាមេរិក ដល់កម្ពុជា ថាជាជំនួយដែលមានចំណង និងមានលក្ខខណ្ឌច្រើនយ៉ាង។ ចំណង និងលក្ខខណ្ឌដែលសហរដ្ឋអាមេរិក ដាក់មកលើយើងនោះ ធ្វើឲ្យប៉ះពាល់ដល់ឯករាជ្យ សេចក្តីថ្លៃថ្នូរ និងកិត្តិយសជាតិយើង។ ដោយឈរលើហេតុផលទាំងនេះហើយ ទើបខ្ញុំព្រះករុណា ក្នុងឋានៈជាប្រមុខរដ្ឋ និងជាប្រធានចលនាសង្គមរាស្ត្រនិយម ដែលប្រជារាស្ត្រជាម្ចាស់ឆ្នោតបានបោះឆ្នោតឲ្យកាន់អំណាច សម្រេចឈប់ទទួលយកជំនួយនោះ។ ការឈប់ទទួលយកជំនួយនេះ ធ្វើឲ្យពួកលន់នល់ និងសិរិមតៈ ដោយមានសេអ៊ីអា ជួយផង សម្រេចថា ត្រូវធ្វើរដ្ឋប្រហារទម្លាក់ខ្ញុំព្រះករុណា នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ នៅក្នុងឱកាសដែលខ្ញុំព្រះករុណា កំពុងបំពេញទស្សនកិច្ចជាផ្លូវការនៅសហភាពសូវៀត។

ប៉ុន្តែចាប់ពីឆ្នាំ១៩៥៦ រហូតមកដល់ឆ្នាំ១៩៦៣ ប្រទេសកម្ពុជាបានចុះហត្ថលេខាព្រមព្រៀងទទួលជំនួយពីសាធារណរដ្ឋប្រជាមានិតចិន ចំនួន៣លើក គឺលើកទី១ បានចុះហត្ថលេខានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៥៦ ទទួលជាទឹកប្រាក់ចំនួន៨លានលីវស្ទែរលីង (ប្រាក់អង់គ្លេស), លើកទី២ ចុះហត្ថលេខានៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៦០ ជាទឹកប្រាក់ចំនួនប្រមាណ ៤លានលីវស្ទែរលីង និងលើកទី៣ ទទួលជាទឹកប្រាក់ចំនួន១,៦លានលីវស្ទែរលីង។ សរុបទាំង៣លើក ស្មើនឹងទឹកប្រាក់ចំនួន១៣,៦ លានលីវស្ទែរលីង។

ក្រៅពីជំនួយជាទឹកប្រាក់នេះ ចិន ក៏បានផ្តល់ជំនួយខាងយោធា រួមមាន អាវុធធុនស្រាល ធុនធ្ងន់ រថយន្តកាម្ញុង និងយន្តហោះ ព្រមទាំងរោងចក្រផលិតក្រដាស នៅស្រុកឆ្លូង ខេត្តក្រចេះ, រោងចក្រក្តារបន្ទះ នៅដីឥដ្ឋ ស្រុកកៀនស្វាយ, រោងចក្រតម្បាញ នៅខេត្តកំពង់ចាម, រោងចក្រផលិតស៊ីម៉ងត៍ នៅចក្រីទីង ខេត្តកំពត និងរោងចក្រកែវ នៅចម្ការដូង



**រោងចក្រកែវ ជំនួយរបស់ចិនប្រជាមានិត**

ស្រុកដង្កោ ខេត្តកណ្តាល( សព្វថ្ងៃនៅក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ )...ជាដើម។

ចំណែកសហភាពសូវៀត ក៏បានជួយកសាងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលជាមន្ទីរពេទ្យដ៏ធំជាងគេបំផុតនៅអាស៊ីអាគ្នេយ៍ និងវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់ខ្មែរ-សូវៀត នៅក្នុងទីក្រុងភ្នំពេញ ដែលមានទឹកប្រាក់សរុបចំនួន៥០០លានរៀល។

ជាមួយគ្នានេះ សហភាពសូវៀត ក៏បានផ្តល់ជំនួយកាំភ្លើងបាញ់យន្តហោះដេសេអា (DCA) យន្តហោះចម្បាំងធុនមិច ១៥ (Mig-15) និងមិច១៧ (Mig-17) ផងដែរ។

ក្រៅពីប្រទេសចិន និងសហភាពសូវៀត ដែលមហាអំណាចកុម្មុយនិស្ត ប្រទេសជប៉ុន ក៏បានចុះហត្ថលេខាស្តីពីសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច និងបច្ចេកទេសនៅថ្ងៃទី ០២ ខែមីនា ឆ្នាំ១៩៥៩ ដោយផ្តល់ជំនួយជាទឹកប្រាក់ចំនួន១៥០០លានយ៉េន ស្មើនឹង ១៥០លានរៀល សម្រាប់ស្ថាបនាមជ្ឈមណ្ឌលកសិកម្មមួយកន្លែង, មជ្ឈមណ្ឌលចិញ្ចឹមសត្វមួយកន្លែង និងមជ្ឈមណ្ឌលសុខភាពនៅតំបន់ជនបទមួយកន្លែងទៀត ដើម្បីជាសក្ខីភាពនៃការដឹងគុណដល់ប្រទេសកម្ពុជា ដែលមិនទាមទារសំណងនៃការខូចខាតទាំងឡាយ នៅពេលកងទ័ពជប៉ុន បង្កឡើងក្នុងសម័យសង្គ្រាមលោកលើកទី២។

ដោយឡែក ប្រទេសបារាំង ដែលធ្លាប់ត្រួតត្រាប្រទេសកម្ពុជា អស់រយៈពេល៩០ឆ្នាំ



**មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជំនួយរបស់សហភាពសូវៀត**

នោះ ក្រោយពីប្រគល់ឯករាជ្យដល់ប្រទេសកម្ពុជាវិញ ក៏បានផ្តល់ជំនួយជាទឹកប្រាក់សរុបប្រមាណ៧៤០លានរៀល ស្មើនឹង៧៤លានហ្វ្រង់ ដល់ប្រទេសកម្ពុជាដែរ ក្នុងនោះរួមមានកំពង់ផែក្រុងព្រះសីហនុ (៣៧៥ លានរៀល), អាកាសយានដ្ឋានពោធិ៍ចិនតុង( ៨៧,៥ លានរៀល),មជ្ឈមណ្ឌលសល្យសាស្ត្រនៅមន្ទីរពេទ្យកាល់ម៉ែត(៦៥លានរៀល),មជ្ឈមណ្ឌលទូរស័ព្ទនៅក្រុងភ្នំពេញ (២១លានរៀល) និងកសិដ្ឋានដាំកប្បាស (២១លានរៀល)។

ក្រៅពីនេះ បារាំងបានផ្តល់ជំនួយជាទឹកប្រាក់ចំនួន៥០០លានរៀលទៀត សម្រាប់វិស័យបច្ចេកទេស និងវប្បធម៌ ព្រមទាំងបានបញ្ជូនសាស្ត្រាចារ្យបារាំង ចំនួន២៨០នាក់ ឱ្យមកជួយបង្រៀនសិស្សនិស្សិតខ្មែរជារៀងរាល់ឆ្នាំ ថែមទាំងផ្តល់ថវិកាជួយកសាងវិទ្យាស្ថានក្សេត្រសាស្ត្រ, សាលាគរុកោសល្យជាន់ខ្ពស់ និងជួយអភិរក្សប្រាសាទអង្គរ ផងដែរ។

លើវិស័យយោធា បារាំង បានផ្តល់ជំនួយសរុបជាទឹកប្រាក់ប្រមាណ១០០០លានរៀល សម្រាប់ការបណ្តុះបណ្តាលនាយទាហានកម្ពុជា និងផ្តល់ជាសម្ភារៈបរិក្ខារយោធាជាច្រើនទៀត រួមទាំងរថក្រោះធុនអាអឹមអិក្ស (AMX) មួយកងអនុសេនាតូច, យន្តហោះប្រដេញ និងរថយន្តដឹកជញ្ជូនធំៗជាច្រើនគ្រឿងទៀត។

# ១៦៦
# ប្រធានាធិបតី ចន អែហ្វ. កេណ្ណឺឌី ត្រូវឃាតករបាញ់សម្លាប់



**ប្រធានាធិបតី ចន អែហ្វ. កេណ្ណឺឌី ពេលរងការបាញ់ប្រហារ**

ក្រោយពីបានធ្វើដំណើរទស្សនកិច្ចទៅកាន់ទីក្រុងសាន់ អានតូនីញ៉ូ (San Antonio) ទីក្រុងហ៊ូស្តុន (Houston) និងទីក្រុងហ្វតវើស (Forth Worth) ទទួលជោគជ័យយ៉ាងត្រចះត្រចង់មក នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៣ ប្រធានាធិបតី ចន អែហ្វ. កេណ្ណឺឌី (Jonh F. Kenedy) មានបំណងទៅបំពេញទស្សនកិច្ចនៅក្រុងដាល្លាស់ (Dallas) ជាបន្តទៀត ក្នុងបំណងឃោសនារកការគាំទ្រពេលឈរឈ្មោះជាប្រធានាធិបតីអាណត្តិទី២ របស់គាត់ នៅឆ្នាំ១៩៦៥ ខាងមុខផង និងទៅធ្វើការសម្របសម្រួលបញ្ហាជម្លោះបែកបាក់ផ្ទៃក្នុងរវាង

រ៉ាល់ យ៉ាបូរ៉ូ (Ralph Yarborough) និង ដុន យ៉ាបូរ៉ូ (Don Yarborough) ជាមន្ត្រីរបស់គណបក្សប្រជាធិបតេយ្យរបស់គាត់នៅរដ្ឋតិចសាស់ (Texas)ផងដែរ។

ពេលនោះ ទីប្រឹក្សារបស់គាត់មានការព្រួយបារម្ភ មិនចង់ឱ្យគាត់ទៅធ្វើដំណើរទស្សនកិច្ចនៅក្រុងដាល្លាស់ (Dallas)នោះទេ ព្រោះទីនោះធ្លាប់មានការផ្ទុះកំហឹងទៅលើឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំនៅអង្គការសហប្រជាជាតិ ម្តងរួចមកហើយ។ តែទោះជាយ៉ាងណា ចន អែហ្វ. កេណ្ណឌី មិនមានការព្រួយបារម្ភ ដូចអ្វី ដែលទីប្រឹក្សារបស់គាត់បានគិតនោះឡើយ។ គាត់យល់ថា ការភ័យខ្លាចរបស់ទីប្រឹក្សាទាំងនោះមិនសមហេតុផលទាល់តែសោះ ព្រោះប្រជាពលរដ្ឋអាមេរិក ពេញចិត្តនឹងប្រធានាធិបតីវ័យក្មេង ព្រមទាំងភរិយាដ៏ស្រស់ស្អាតរបស់គាត់ខ្លាំងណាស់។

ព្រឹកថ្ងៃសុក្រ ទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៣ ប្រធានាធិបតី កេណ្ណឌី និងអ្នកហែហម បានមកដល់អាកាសយានដ្ឋាន ក្រុងដាល្លាស់ ដោយមានប្រជាពលរដ្ឋអាមេរិក យ៉ាងច្រើនកុះករ មកឈរចាំទទួលស្វាគមន៍ដោយទឹកចិត្តសប្បាយរីករាយ។

កេណ្ណឌី ព្រមទាំងភរិយា ចាក្លីលីន កេណ្ណឌី អូណាស៊ីស (Jacqueline Kennedy Onassis) បានឡើងជិះលើរថយន្តបើកដំបូលមួយគ្រឿង ជាមួយអភិបាលរដ្ឋតិចសាស់ និងភរិយាដែលអង្គុយនៅកៅអីខាងមុខ ដោយមានក្បួនរថយន្ត និងម៉ូតូ ព្រមទាំងកងអង្គរក្សជាច្រើនអមការពារផង។

ពេលក្បួនកំពុងឆ្លងកាត់ទីក្រុងដាល្លាស់ (Dallas) ភរិយារបស់អភិបាលរដ្ឋតិចសាស់ បានងាកមកក្រោយពោលពាក្យសរសើរទៅកាន់កេណ្ណឌី ថា៖ «ប្រជាពលរដ្ឋនៅតិចសាស មើលទៅដូចជាចូលចិត្តលោកប្រធានាធិបតីខ្លាំងណាស់!»។ ភ្លាមៗនោះ វេលាម៉ោង ១២និង៣០នាទី ស្រាប់តែត្រូវខ្មាន់កាំភ្លើងលបបាញ់គាត់ពីអគារកម្ពស់៦ជាន់ ពីរគ្រាប់ផ្ទួនៗគ្នា គឺចំក្បាលមួយគ្រាប់ និងចំបំពង់កមួយគ្រាប់ បណ្តាលឱ្យដងខ្លួនដួលរលំទៅលើភ្លៅភរិយារបស់គាត់ ហើយខ្មាន់កាំភ្លើងបានបាញ់បន្ថែមមួយគ្រាប់ទៀត តែត្រូវចំខ្លួនអភិបាលរដ្ឋតិចសាស់។

របត់នយោបាយ

ភ្លាមៗនោះ គាត់ត្រូវបានបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យផាកលែន មេម៉ូរៀល (Parkland Memorial Hospital) ភ្លាមៗដែរ តែដោយសារមុខរបួសមានសភាពធ្ងន់ធ្ងរពេក ក៏ត្រូវបាត់បង់ជីវិតនៅវេលាម៉ោង១រសៀល នៅថ្ងៃដដែល ក្នុងវ័យ៤៦ ឆ្នាំ។ សពរបស់ប្រធានាធិបតី ចន អែហ្វ. កេណ្ណឌី ត្រូវបានបញ្ចុះនៅឯឈាបនដ្ឋានជាតិ អាលីងតុន (Arlington National Cemetery) ក្នុងរដ្ឋធានីវ៉ាស៊ីនតោន។

នៅអំឡុងពេលកើតហេតុនោះ មានអ្នកកាសែតម្នាក់បានឃើញចុងកាណុងកាំភ្លើងវែងមួយដើម ដែលឃាតករដាក់បញ្ចេញពីបង្អួចអគារជាន់ទី៦ នៅក្បែរកន្លែងកើតហេតុ។ បុរសនោះ ត្រូវគេចំណាំមុខបាន ហើយត្រូវគេរាយការណ៍ប្រាប់សមត្ថកិច្ចប៉ូលិសតាមវិទ្យុទាក់ទង។

ក្នុងរយៈពេលតែមួយម៉ោងប៉ុណ្ណោះ សមត្ថកិច្ចប៉ូលិសបានរកឃើញឃាតករដែលកំពុងព្យាយាមរត់គេចខ្លួនចូលនៅក្នុងរោងមហោស្រពមួយ ហើយត្រូវចាប់ខ្លួនបានតែម្តង។ ជនសង្ស័យឈ្មោះ លី ហាវេ អូស្វាលដ៍ (Lee Harvey Oswald) ជាអ្នកធ្វើការនៅកន្លែងតម្កល់សៀវភៅ នៅសាលាតិចសាស់ និងជាអ្នកគាំទ្រ ហ្វីដែល កាស្ត្រូ (Fidel Castro) មេដឹកនាំប្រទេសកុម្មុយនិស្តគុយបា ផងដែរ ។ កន្លងមក ជននេះធ្លាប់ជាប់ចោទថា បានបាញ់សម្លាប់ប៉ូលិសមូលដ្ឋានម្នាក់ ម្តងរួចមកហើយ តែគាត់បានបដិសេធ។

ឃាតករ លី ហាវេ អូស្វាលដ៍ (Lee Harvey Oswald) កើតនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៣៩។ កាលពីអាយុ១២ឆ្នាំ គាត់ត្រូវបានគ្រូពេទ្យវិកលចរិតវាយតម្លៃថា មានបញ្ហាផ្លូវអារម្មណ៍ ដោយសារតែជីវភាពគ្រួសារមិនប្រក្រតី។

ក្នុងវ័យកុមារ បានចូលរៀនជាបន្តបន្ទាប់នៅសាលាចំនួន១២ ពោលគឺគាត់បានឈប់រៀនពីសាលាមួយ ហើយទៅរៀននៅសាលាមួយផ្សេងទៀត ជាបន្តបន្ទាប់ រហូតដល់១២ សាលា។

ទីបំផុត នៅពេលមានអាយុ១៧ឆ្នាំ គាត់បានចូលបម្រើការងារជាទាហានជើងទឹក។ នៅពេលបម្រើការងារជាទាហានជើងទឹកនោះ គាត់ត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគារ



**ឃាតករ លី ហាវេ អូស្វាលដ៍ និងប្រពន្ធជនជាតិរុស្ស៊ី ព្រមទាំងកូនស្រីតូចៗទាំង២នាក់**

ពីរដង តែគាត់ត្រូវបានដោះលែងវិញ ដោយសារមានស្នាដៃល្អ ក្នុងពេលបំពេញកាតព្វកិច្ចជាទាហានជើងទឹកនោះ។

បន្ទាប់មក លី ហាវេ អូស្វាលដ៍ (Lee Harvey Oswald) បានចាកចេញទៅអឺរ៉ុប ហើយបានភៀសខ្លួនទៅរស់នៅសហភាពសូវៀត ក្នុងខែតុលា ឆ្នាំ១៩៥៩ ។ គាត់រស់នៅក្នុងទីក្រុងមីនស្ក៍ (Minsk) រដ្ឋបេឡារុស(Belarus) និងបានរៀបការជាមួយស្ត្រីជនជាតិរុស្ស៊ីម្នាក់ ឈ្មោះ ម៉ារីណា(Marina) និងមានកូនស្រីមួយ។

នៅក្នុងខែមិថុនា ឆ្នាំ១៩៦២ គាត់បានត្រលប់ទៅសហរដ្ឋអាមេរិក ជាមួយប្រពន្ធជនជាតិរុស្ស៊ីរបស់គាត់ ហើយបានតាំងទីលំនៅនៅទីក្រុងដាល្លាស់ (Dallas) រដ្ឋតិចសាស់ (Texas) ជាកន្លែងដែលកូនស្រីទីពីររបស់ពួកគាត់បានចាប់កំណើតផងដែរ។

នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៣ លី ហាវេ អូស្វាលដ៍ (Lee Harvey Oswald) បានក្លាយជាឃាតករ បាញ់សម្លាប់ ចន អែហ្វ. កេណ្ណឌី (Jonh F. Kenedy) ជាប្រធានាធិបតីទី៣៥ របស់សហរដ្ឋអាមេរិក។



**ចាក រូប៊ី បាញ់សម្លាប់ឃាតករ អូស្វាលដ៍ ដែលបាញ់សម្លាប់ប្រធានាធិបតី កេណ្ណឌី**

ពីរថ្ងៃក្រោយមក នៅថ្ងៃទី២៤ ខែវិច្ឆិកា ខណៈក្រុមប៉ូលិសកំពុងនាំខ្លួនឃាតករ អូស្វាលដ៍ បញ្ជូនទៅបញ្ជូនទៅតុលាការជំនុំជម្រះនៅចំពីមុខកាមេរ៉ាទូរទស្សន៍ ផ្សាយបន្តផ្ទាល់ មានអ្នកទស្សនារាប់លាននាក់ ស្រាប់តែមានឃាតករម្នាក់ទៀតឈ្មោះ ចាក រូប៊ី (Jack Ruby) បានរត់សំដៅទៅរកក្រុមប៉ូលិស ហើយបាញ់សម្លាប់លើឃាតករ អូស្វាលដ៍ ដើម្បីបំបិទមាត់ ក៏ត្រូវកម្លាំងសមត្ថកិច្ចចាប់ខ្លួនបានដែរ។

ក្រោយពេល តុលាការសាលាដំបូង សម្រេចកាត់ទោសប្រហារជីវិត ចាក រូប៊ី (Jack Ruby) បានសុំប្តឹងឧទ្ធរណ៍ដែរ ប៉ុន្តែដោយសារជននេះមានជំងឺមហារីក ការបើកសវនាការជំនុំជម្រះ ចេះតែពន្យារពេលម្តងហើយម្តងទៀត រហូតដល់ថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៦៧ ជននេះ ក៏ត្រូវបាត់បង់ជីវិតដោយជំងឺមហារីក។

ក្រោយហេតុការណ៍ សមត្ថកិច្ចប៉ូលិសបានរកឃើញកាំភ្លើងដែលឃាតករឈ្មោះ លី ហារវេ អូស្វាលដ៍ យកទៅបាញ់សម្លាប់ប្រធានាធិបតី ចន អែហ្វ. កេណ្ណឌី ជាកាំភ្លើងម៉ាក ម៉ាន់លីឈ័រ-ការកាណូ (Mannlicher–Carcano) ដែលគេបានទិញក្នុងតម្លៃ១២.៧៨ ដុល្លារ បូករួមទាំងកែវយឺតមួយ តម្លៃ ៧.១៧ ដុល្លារទៀត។

នៅឆ្នាំ១៩៦៤ មានមហាសេដ្ឋីប្រេងកាតម្នាក់ ជាអ្នកចូលចិត្តប្រមូលទិញវត្ថុដែលមានប្រវត្តិចម្លែកៗ យកមកទុកជាសម្បត្តិផ្ទាល់ខ្លួន ឈ្មោះ ចន ជេ. ឃីង (John J. King) បានទាក់ទងស្ត្រីឈ្មោះម៉ារីណា ជាប្រពន្ធរបស់ឃាតករ ដើម្បីរកទិញកាំភ្លើងនោះ ដោយហ៊ានឱ្យតម្លៃ ៤០,០០០ដុល្លារអាមេរិក ហើយបានប្រគល់ប្រាក់កក់៥,០០០ដុល្លារ សិនលុះដល់ពេលបានទទួលបានកាំភ្លើងពីស្ត្រីឈ្មោះម៉ារីណា ទើបប្រគល់ប្រាក់៣៥,០០០ ដុល្លារថែមទៀត។

តែរដ្ឋាភិបាលសហរដ្ឋអាមេរិក បានសម្រេចរក្សាទុកកាំភ្លើងនោះជាសម្បត្តិរដ្ឋ ធ្វើឱ្យមហាសេដ្ឋីប្រេងកាតរូបនេះ ត្រូវខាតបង់ប្រាក់កក់អស់៥,០០០ដុល្លារ គាត់ក៏បានប្តឹងទារសំណងជាទឹកប្រាក់ ៥លានដុល្លារ ពីរដ្ឋាភិបាលសហរដ្ឋអាមេរិក វិញ។

ប៉ុន្តែ ទោះជាយ៉ាងណា កាំភ្លើងម៉ាកម៉ាន់លីឈ័រ-ការកាណូ (Mannlicher–Carcano) នេះ នៅតែត្រូវទុកជាសម្បត្តិរដ្ឋដដែល។

# ១៦៧
# សិស្សនិស្សិតមន្ត្រីរាជការ
# ធ្វើបាតុកម្មបណ្តេញទូតអាមេរិក




**មន្ត្រីរាជការធ្វើបាតុកម្មនៅមុខស្ថានទូតអាមេរិក ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៦៤**

នៅក្នុងខែមករា ឆ្នាំ១៩៦៤ សហរដ្ឋអាមេរិក ចាប់ផ្តើមដកបុគ្គលិកស្ថានទូតរបស់ខ្លួនចេញពីក្រុងភ្នំពេញ ជាបណ្តើរៗ។ ចំណែក នង គឹមនី ឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ឱ្យត្រលប់ឲ្យមកមាតុប្រទេសវិញ។ ចំណែកឯអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ហ្វីលីព ឌី.ស្ព្រូស(philip D. Sprouse) ក៏ត្រូវបានរដ្ឋាភិបាលសហរដ្ឋអាមេរិក ដកទៅកាន់សហរដ្ឋអាមេរិក វិញដែរ។ នៅថ្ងៃទី៩ ខែ កក្កដា ឆ្នាំ១៩៦៤ រដ្ឋាភិបាលអាមេរិក បានតែងតាំងឯកអគ្គរដ្ឋទូតថ្មីមួយម្នាក់ទៀតឈ្មោះរ៉ាន់ដុល អេ. ឃីតឌ័រ(Randolph A. Kidder) ឲ្យមកប្រចាំនៅប្រទេសកម្ពុជា។ តែសម្តេចសីហនុ

មិនទទួលសារតាំងឯកអគ្គរដ្ឋទូតថ្មីនេះទេ។

ពីដើមឆ្នាំ១៩៦៤ ក្នុងចំណោមមន្ត្រីស្ថានទូតអាមេរិក នៅទីក្រុងភ្នំពេញ ប្រមាណ ៣០០នាក់ ត្រូវបានដកឱ្យវិលត្រលប់ទៅសហរដ្ឋអាមេរិកវិញ ជាបណ្តើរៗ រហូតដំណាច់ឆ្នាំ ១៩៦៤ នៅសល់តែ១២នាក់ប៉ុណ្ណោះ ។

នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៦៤ យន្តហោះចម្បាំងវៀតណាមខាងត្បូង បានហោះ មកទម្លាក់គ្រាប់បែកមកក្នុងទឹកដីកម្ពុជា ចម្ងាយ២គីឡូម៉ែត្រពីខ្សែបន្ទាត់ព្រំដែន បណ្តាល ឱ្យស្លាប់អ្នកភូមិ៥នាក់ និងរបួស៦នាក់។

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៦៤ ដោយសារសហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តវៀតណាម ខាងត្បូង ធ្វើសកម្មភាពរំលោភឈ្លានពានមកលើបូរណភាពទឹកដីប្រទេសកម្ពុជា សម្តេច សីហនុ ក៏បានស្នើសុំឱ្យមានសន្និសីទចតុភាគីមួយ ដែលរួមមាន កម្ពុជា, ថៃ, លាវ និង វៀតណាមខាងត្បូង ចូលរួមដើម្បីសុំឱ្យប្រទេសជិតខាង (ពិសេសវៀតណាមខាងត្បូង និង ថៃ) គោរពអព្យាក្រឹតភាព និងបូរណភាពទឹកដីកម្ពុជា។

សម្តេចសីហនុ បានមានបន្ទូលព្រមានថា ប្រសិនបើដល់ចុងខែឧសភា ខាងមុខ សន្និសីទនេះមិនអាចកោះប្រជុំបាន ព្រះអង្គនឹងកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយសហរដ្ឋ អាមេរិក និងសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិកទាំង២នេះ ជាមិនខាន។

ប៉ុន្តែ ១៧ថ្ងៃក្រោយមក គឺនៅថ្ងៃទី០៦ ខែមីនា ក្រសួងការបរទេសសហរដ្ឋអាមេរិក បែរជាចេញសេចក្តីថ្លែងការណ៍គាំទ្រការរំលោភឈ្លានពានពីសំណាក់កងទ័ពវៀតណាម ខាងត្បូង និងថៃ មកលើបូរណភាពទឹកដីខ្មែរទៅវិញ។

នៅថ្ងៃទី១១ ខែមីនា សិស្សនិស្សិត និងប្រជារាស្ត្រនៅទីក្រុងភ្នំពេញ ក៏នាំគ្នាធ្វើបាតុកម្មវាយកម្ទេចស្ថានទូតសហរដ្ឋអាមេរិក និងស្ថានទូតអង់គ្លេស ដើម្បីជាការឆ្លើយតបទៅនឹង សហរដ្ឋអាមេរិក ដែលបានចេញសេចក្តីថ្លែងការណ៍គាំទ្រការរំលោភឈ្លានពានពីសំណាក់ កងទ័ពវៀតណាមខាងត្បូង និងថៃនោះ។

បាតុករជាច្រើននាក់ នាំគ្នាកាន់បដាសរសេរពាក្យស្លោកថ្កោលទោសចំពោះកងទ័ព




**ក្បួនបាតុកម្មនៅមុខស្ថានទូតអាមេរិក ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៦៤**

វៀតណាមខាងត្បូង ដែលបានចូលមករំលោភបំពានមកក្នុងទឹកដីកម្ពុជា និងរិះគន់ចំពោះរដ្ឋាភិបាលអាមេរិក និងអង់គ្លេស ដែលមិនគាំទ្រការស្នើសុំរបស់សម្តេចសីហនុ ដែលចង់ឱ្យមានសន្និសីទចតុភាគីនោះ។

បាតុកម្មនេះ ត្រូវបានគេដឹងថា ដោយមានសញ្ញាភ្លើងខៀវពីសម្តេចសីហនុ ផងដែរនោះ មេដឹកនាំចលនាយុវជនរាជសង្គមនិយមខ្មែរ បានបំផុសឱ្យសិស្ស និស្សិត មន្ត្រីរាជការជាច្រើនពាន់នាក់ឲ្យដើរហែក្បួនមកឡោមព័ទ្ធស្ថានទូតសហរដ្ឋអាមេរិក នៅក្នុងទីក្រុងភ្នំពេញ និងចាប់ផ្តើមចូលវាយលុកក្នុងស្ថានទូត និងទាញទង់ជាតិអាមេរិក ចុះមកក្រោម រួចកម្ទេចចោល។

ដោយមានការក្តៅក្រហាយចំពោះហ្វូងបាតុករដែលចូលមកវាយបំផ្លាញរបស់របរនៅក្នុងស្ថានទូតខ្ទេចខ្ទីអស់នោះ ឆ្មាំការពារស្ថានទូតម្នាក់ជាជនជាតិខ្មែរ ក៏បានទាញកាំភ្លើងតម្រង់ទៅរកហ្វូងបាតុករដែរ តែត្រូវមន្ត្រីស្ថានទូតអាមេរិក មានវត្តមាននៅទីនោះ មករារាំង




**បាតុកម្មប្រឆាំងសហរដ្ឋអាមេរិក ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៦៤**

មិនឱ្យតបតជាមួយនឹងពួកបាតុករនោះឡើយ។

ចំណែកនៅស្ថានទូតចក្រភពអង់គ្លេស វិញ បុគ្គលិកនៅទីនោះ ត្រូវគេរំដោះចេញទាន់ពេលវេលា នៅមុនពេលហ្វូងបាតុករចូលទៅវាយបំផ្លាញបណ្ណាល័យ និងការិយាល័យកុងស៊ុលឱ្យខ្ទេចខ្ទីអស់។

ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៦៤នោះដែរ មន្ត្រីស្ថានទូតអាមេរិក នៅរដ្ឋធានីភ្នំពេញ បានរាយការណ៍ទៅរដ្ឋធានីវ៉ាស៊ីនតោន ថា ចាប់ពីម៉ោង៩ព្រឹកនេះ មានបាតុករជាច្រើន បាននាំគ្នាវាយប្រហារដោយគប់ដុំថ្មយ៉ាងខ្លាំងក្លាទៅលើអគារស្ថានទូត ហើយការវាយប្រហារនៅតែបន្តនៅពេលដែលសារទូរលេខនេះត្រូវបានផ្ញើទៅរដ្ឋធានីវ៉ាស៊ីនតោន។ សញ្ញាកត់សំគាល់ដំបូងនៃការធ្វើបាតុកម្មនេះ គឺលេខ០៨២០។ ពេលពួកបាតុករមានវ័យចំណាស់ៗ មកដល់មុខស្ថានទូត ពួកគេបានប្រាប់តាមរយៈបុគ្គលិកស្ថានទូតជាជនជាតិខ្មែរ ទៅមន្ត្រីស្ថានទូតអាមេរិក ថា បាតុកម្មនេះគ្រោងធ្វើនៅម៉ោង១០ព្រឹក។

តាមពិត បាតុកម្មនេះ បានចាប់ផ្ដើមនៅម៉ោង៩ព្រឹក ក្បួនបាតុករនាំមុខដោយក្រុមកាន់បដា ដែលបង្ហាញថា ជាបដាដែលរៀបចំដោយក្រសួងព័ត៌មាន នៃរដ្ឋាភិបាលកម្ពុជា





**បាតុកម្មហិង្សានៅមុខស្ថានទូតអាមេរិក ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៦៤**

បានមកដល់មុខស្ថានទូតអាមេរិក ។

ភ្លាមនោះ បុរសម្នាក់កាន់ជក់ទៅជ្រលក់ធុងទឹកថ្នាំពណ៌ក្រហម យកទៅសរសេរនៅលើជញ្ជាំងអគារស្ថានទូត និងជញ្ជាំងការិយាល័យផ្តល់ព័ត៌មានថា៖ «អាមេរិក ទៅផ្ទះឯងវិញទៅ! (Americ go home ! ) » ។ ពេលនោះកងកម្លាំងប៉ូលិសដែលឈរក្បែរអគារស្ថានទូត ត្រូវបានគេបញ្ជូនមកកាន់តែច្រើនឡើងៗ តែពួកគេមិនបានធ្វើសកម្មភាពអ្វីមួយដើម្បីរារាំងដល់ពួកបាតុករឡើយ។

បន្ទាប់ពីការដង្ហែក្បួនដោយសន្តិវិធីប្រហែល២០នាទីនៅមុខស្ថានទូត អំពើហិង្សាបានចាប់ផ្តើមផ្ទុះឡើងដោយការគប់ដុំថ្ម។ ក្នុងរយៈពេលម្ភៃនាទី អំពើហិង្សាដោយការគប់ដុំថ្មនោះ បានធ្វើឱ្យកញ្ចក់ស្ទើរតែគ្រប់បង្អួចនៅក្នុងស្ថានទូត និងការិយាល័យសេវាព័ត៌មានអាមេរិក (USIS) ត្រូវបែកខ្ទេចខ្ទី ហើយយ៉ាងហោចណាស់រថយន្តស្ថានទូតមួយគ្រឿងត្រូវបានបំផ្លាញទាំងស្រុង។

នៅពេលនេះ មិនទាន់មានបុគ្គលិកស្ថានទូតណាម្នាក់អាចចេញទៅក្រៅបានទេ ហើយការវាយតម្លៃទំហំនៃការខូចខាត ក៏មិនទាន់អាចសរុបនៅឡើយដែរ។ សេចក្តីរាយការណ៍បានបន្តថា គ្មានបុគ្គលិកស្ថានទូតណាម្នាក់រងរបួសទេ ហើយទោះបីជានៅពេលនេះ ការ

ទំនាក់ទំនងតាមទូរស័ព្ទនៅខាងក្រៅស្ថានទូតត្រូវបានកាត់ផ្តាច់ក៏ដោយ ក៏មិនមានព័ត៌មានណាមួយថា បាតុកម្មបែបនេះ បានរាលដាលដល់លំនៅឋានណាមួយរបស់ជនជាតិអាមេរិកដែលរស់នៅក្នុងទីក្រុងភ្នំពេញ នេះដែរ។

យើងយល់ឃើញថា ប្រសិនបើមិនមានកិច្ចសហប្រតិបត្តិការពីរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជាទេនោះ បាតុកម្មនេះនឹងមិនអាចកើតឡើងបានឡើយ។

បន្ទាប់មកទៀត មន្ត្រីស្ថានទូតអាមេរិក បានរាយការណ៍បញ្ជាក់ទៅរដ្ឋធានីវ៉ាស៊ីនតោនថា កាលពីវេលាម៉ោង៨ និង២៥នាទី ដោយសង្ស័យថា នឹងមានបាតុកម្មនៅស្ថានទូត ខ្ញុំបាននិយាយទូរស័ព្ទដើម្បីទាក់ទងទៅសម្បត្តិ (ហួត សម្បត្តិ រដ្ឋលេខាធិការក្រសួងការបរទេសកម្ពុជា) តែ ចាន់ យូរ៉ាន់ នាយកកិច្ចការនយោបាយរបស់ក្រសួងការបរទេសកម្ពុជា បាននិយាយថា សម្បត្តិ មិននៅទេ។ ប៉ុន្តែ គាត់(ចាន់ យូរ៉ាន់) នឹងព្យាយាមបញ្ជូនរឿងនេះទៅឲ្យ សម្បត្តិ (ហួត សម្បត្តិ) ឲ្យបានដឹងអំពីរឿងនេះក្នុងពេលឆាប់ៗខាងមុខ។

មន្ត្រីស្ថានទូតអាមេរិក បានរាយការណ៍បញ្ជាក់បន្តទៀតថា នៅម៉ោង៩ និង២៨នាទី ខ្ញុំនៅតែមិនអាចទំនាក់ទំនងតាមទូរស័ព្ទជាមួយ សម្បត្តិ(ហួត សម្បត្តិ)ម្តងហើយម្តងទៀត ក្នុងបំណងធ្វើការតវ៉ាយ៉ាងខ្លាំងក្លាបំផុតចំពោះកម្លាំងប៉ូលិសកម្ពុជា ដែលមិនបានយកចិត្តទុកដាក់ក្នុងការអនុវត្តកាតព្វកិច្ចជួយការពារស្ថានទូត តាមច្បាប់អន្តរជាតិ ។ តែមិនបានជួប សម្បត្តិ(ហួត សម្បត្តិ)ដដែល គឺបានជួបតែលេខាធិការរបស់ សម្បត្តិ ប៉ុណ្ណោះ។

ទោះយ៉ាងណា ក៏លេខាធិការនោះបានសន្យាថា គាត់នឹងព្យាយាមបញ្ជូនសាររបស់ខ្ញុំទៅ សម្បត្តិ(ហួត សម្បត្តិ រដ្ឋលេខាធិការក្រសួងការបរទេសកម្ពុជា) ។ ជាមួយគ្នានេះដែរ ប្រសិនបើ ចាន់ យូរ៉ាន់ នាយកកិច្ចការនយោបាយ មិនឆ្លើយតបភ្លាមៗទេ ខ្ញុំនឹងព្យាយាមទាក់ទងទៅ សម្បត្តិ បន្តទៀត ដើម្បីធ្វើការតវ៉ាប្រឆាំងនឹងបាតុកម្មនេះ។

នៅម៉ោង៩និង៤៥នាទី ដោយសារអំពើហិង្សារបស់ពួកបាតុករផ្ទុះឡើងដល់កម្រិតកំពូល បុគ្គលិកទាំងអស់នៅក្នុងអគារស្ថានទូតបានប្រមូលផ្តុំគ្នានៅកន្លែងដែលមានសុវត្ថិភាពបំផុត។ ក្រោយពីឃើញសកម្មភាពនៃការធ្វើបាតុកម្មនោះកាន់តែពុះកញ្ជ្រោលឡើងៗ លើស

## របត់នយោបាយ

ពីការគ្រោងទុក ដោយក្រុមបាតុករនិយាយស្ដាប់គ្នាលែងបាននោះ មេដឹកនាំធ្វើបាតុកម្មក៏គេចខ្លួនពីកន្លែងធ្វើបាតុកម្មបាត់អស់ដែរ។

នៅពេលនេះ ម៉ោង១១និង១៤នាទី សកម្មភាពបាតុកម្មត្រូវបានបញ្ចប់ ទើបកម្លាំងប៉ូលិសចាប់ផ្ដើមប្រឹងប្រែងយ៉ាងសកម្មក្នុងការរារាំងពួកបាតុករមិនឱ្យចូលមកជិតស្ថានទូតដូចមុនទៀត។

តាមការវាយតម្លៃបឋម បានបង្ហាញថា ការិយាល័យនៅជាន់ផ្ទាល់ដីរបស់ស្ថានទូតដែលក្រុមបាតុករបានទម្លាយចូលទៅវាយបំបែកទ្វារខាងមុខនោះ មានការខូចខាតយ៉ាងដំណំ។ របាយការណ៍បន្ថែមអំពីការខូចខាតនេះ ខ្ញុំនឹងបញ្ជូនបន្ថែមឱ្យឆាប់បំផុត។ ចំណែកសម្ដេចសីហនុ ដែលកំពុងតាមដានសកម្មភាពធ្វើបាតុកម្មនោះដែរ ក៏មានព្រះទ័យព្រួយបារម្ភខ្លាំងដែរ ព្រោះបាតុកម្មនោះ គ្រួតត្រាលែងបានទៅហើយ។

ក្រោយមក បាតុកម្មនោះត្រូវបានបញ្ចប់ដោយឯងៗ ហើយរាជរដ្ឋាភិបាល ក៏បានប្រកាសសម្ដែងការសោកស្ដាយជាខ្លាំងចំពោះបាតុកម្មដ៏ហិង្សានោះ។

# ១៦៨
# កងទ័ពវៀតណាមខាងត្បូង ចូលមកបាញ់សម្លាប់ប្រជារាស្ត្រខ្មែរ នៅភូមិចន្ទ្រា



**ប្រជាជនខ្មែរនៅភូមិចន្ទ្រា ស្លាប់ដោយសារកងទ័ពវៀតណាមខាងត្បូង ចូលវាយប្រហារ**

២ថ្ងៃក្រោយពីមានហេតុការណ៍វាយកម្ទេចស្ថានទូតអាមេរិក នៅក្នុងទីក្រុងភ្នំពេញនោះ សម្តេចសីហនុ បានប្រកាសថា ព្រះអង្គនឹងបញ្ជូនគណៈប្រតិភូមួយក្រុមទៅកាន់ទីក្រុងហាណូយ ដើម្បីចរចាជាមួយរដ្ឋាភិបាលវៀតណាមខាងជើង ស្តីពីកិច្ចព្រមព្រៀងពីបញ្ហាព្រំដែន ហើយព្រះអង្គបានបញ្ជាក់ បន្ថែមថា ប្រសិនបើការចរចានោះ ទទួលជោគជ័យ ព្រះអង្គនឹងទទួលស្គាល់របបសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម(វៀតណាមខាងជើង) នោះតែម្តង។

តាមការត្រាស់បង្គាប់របស់សម្តេចសីហនុ ជាព្រះប្រមុខរដ្ឋ ថ្ងៃទី១៤មីនា និងដើមខែមេសា ឆ្នាំ១៩៦៤ ឧត្តមសេនីយ៍ទោ លន់ នល់ និងអ្នកអង្គម្ចាស់ នរោត្តម នរទីបោ ជាបុត្រា

របស់ព្រះអង្គ បានដឹកនាំគណៈប្រតិភូយោធាជាន់ខ្ពស់មួយក្រុម ដែលរួមមានមន្ត្រីយោធាជាន់ខ្ពស់ ដូចជា វង់ សារ៉ាន់ឌី, ឯក ព្រឿង, សូ សាតូ, សាក់ ស៊ុតសាខន, អ៊ុំ ម៉ាន្នូរិន, សេង ស៊ុនថៃ, ង៉ោ ហ៊ូ និងសូ ខាំខូយ ជាដើម ទៅបំពេញទស្សនកិច្ចជាផ្លូវការនៅទីក្រុងប៉េកាំង និងបានជួបពិភាក្សាជាមួយមេដឹកនាំកំពូលៗរបស់ចិន ពីបញ្ហាមិត្តភាព និងបញ្ហាជំនួយយោធា ព្រមទាំងពីបញ្ហានយោបាយផងដែរ។

នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៦៤ កងទ័ពវៀតណាមខាងត្បូង ដោយមានទីប្រឹក្សាយោធាអាមេរិក មកជាមួយផង បានលើកកងទ័ពជាច្រើនរយនាក់ មានទាំងកងរថក្រោះ និងយន្តហោះទម្លាក់គ្រាប់បែកផង ធ្វើការវាយលុកយ៉ាងសាហាវបំផុតចូលមកក្នុងភូមិចន្ទ្រា ឃុំចន្ទ្រា ស្រុកចន្ទ្រា ខេត្តស្វាយរៀង បណ្ដាលឱ្យអ្នកភូមិរងរបួសចំនួន១៥នាក់ និងស្លាប់ចំនួន១៧នាក់។

ភូមិចន្ទ្រា ជាភូមិមួយក្នុងចំណោមភូមិទាំង៤នៅក្នុងឃុំចន្ទ្រា ស្រុកជីភូ (បច្ចុប្បន្នស្រុកចន្ទ្រា) ខេត្តស្វាយរៀង។ ភូមិនេះ ស្ថិតនៅជាប់ព្រំប្រទល់កម្ពុជា-វៀតណាមខាងត្បូង មានចម្ងាយប្រហែលជា ៥ ទៅ៦គីឡូម៉ែត្រ ពីខ្សែបន្ទាត់ព្រំដែន និងមានចម្ងាយប្រមាណជាង៥០គីឡូម៉ែត្រ ពីទីរួមខេត្តស្វាយរៀង។

អ្នកភូមិម្នាក់ឈ្មោះ ដើក នេត កាលឆ្នាំ១៩៦៤នោះ នៅវ័យកុមារនៅឡើយ គាត់នៅចាំបានថា៖ ដោយសារមានកងទ័ពវៀតកុង-វៀតណាមខាងជើង ចូលមកជ្រកពួនក្នុងភូមិចន្ទ្រា ស្រាប់តែគាត់ឃើញកងទ័ពវៀតណាមខាងត្បូង និងយន្តហោះអាមេរិក បានឆ្លងខ្សែបន្ទាត់ព្រំដែន ចូលមកវាយប្រហារ និងទម្លាក់គ្រាប់បែកមកលើភូមិចន្ទ្រា យ៉ាងសាហាវ ឃោរឃៅបំផុត។ ពេលនោះ ដោយសារយន្តហោះបាញ់សាំងពីលើមក ធ្វើឱ្យផ្ទះសំបែងអ្នកភូមិជាច្រើនខ្នង ហើយក្នុងចំណោមនោះ មានផ្ទះក្បឿងមួយខ្នងរបស់ឪពុកម្ដាយគាត់ផងដែរ ត្រូវភ្លើងឆាបឆេះសន្ធោសន្ធៅ។

បងស្រីគាត់ម្នាក់ឈ្មោះមិន សួន កាលនោះអាយុប្រហែល១៣ ឆ្នាំ និងបងប្រុសគាត់ម្នាក់ទៀត ឈ្មោះដើក ណាន អាយុប្រហែល១០ឆ្នាំ រត់ចុះពីលើផ្ទះមិនទាន់ ក៏ត្រូវភ្លើងឆេះ



**លន់ នល់ ដឹកនាំគណៈប្រតិភូទៅចូលជួប តេង ស៊ាវពីង ឆ្នាំ១៩៦៤**

រលោកពេញខ្លួន។

ក្រោយពីកងទ័ពវៀតណាមខាងត្បូង និងយន្តហោះអាមេរិក ដកថយទៅវិញអស់ ឪពុកម្តាយគាត់បានយកបងស្រី និងបងប្រុសគាត់ទាំងពីរនាក់ទៅសង្គ្រោះនៅឯមន្ទីរពេទ្យ នាទីក្រុងភ្នំពេញ។

បងស្រី និងបងប្រុសគាត់បានរួចផុតពីគ្រោះថ្នាក់ដល់ជីវិត។ តែបងស្រីគាត់ ត្រូវក្លាយជាមនុស្សពិការមួយជីវិត ដោយសារដៃដែលត្រូវភ្លើងឆេះនោះ ធ្វើឱ្យរួញសរសៃនៅជាប់ក្លៀក មិនអាចធ្វើចលនាបាន។

ក្រោយពីមានហេតុការណ៍នោះមក ក្រុមគ្រួសារគាត់ ក៏ដូចជាគ្រួសារអ្នកភូមិផ្សេងទៀត ដែលត្រូវភ្លើងឆេះផ្ទះអស់ សម្តេចសីហនុ បានជួយសាងសង់ផ្ទះថ្មីឡើងវិញ ក្នុងមួយគ្រួសារ មួយខ្នងៗទំហំ ៦គុណនឹង៨ម៉ែត្រ ធ្វើអំពីឈើប្រក់ស័ង្កសី ដើម្បីឲ្យបានស្នាក់នៅ បន្តទៀត។

លោកតាប្រាក់ សារិន កើតនៅភូមិចន្ទ្រា ឃុំចន្ទ្រា ស្រុកចន្ទ្រា ខេត្តស្វាយរៀង ដែលនៅដើមទសវត្សន៍មានវ័យជិត ៨០ឆ្នាំទៅហើយ បានរម្លឹកថា នៅក្នុងអំឡុងឆ្នាំ១៩៦៣-១៩៦៤ គាត់មានតួនាទីជាកងជីវពលការពារភូមិចន្ទ្រា គាត់កាន់កាំភ្លើងម៉ាកអំស៊ែស្បេល។

## របត់នយោបាយ

មុនដំបូង រថក្រោះទាហានជីវ គី (ទាហានវៀតណាមខាងត្បូង) តម្រង់ក្បាលទៅទិសខាងកើត។ ដោយខ្លាចពួកវាចូលមកក្នុងភូមិចន្ទ្រា ដុតផ្ទះសំបែងរបស់ប្រជាជន ពួកគាត់ជាកងជីវពលការពារភូមិ បានបាញ់តទល់នៅក្បែរភូមិតែងម៉ៅ ដែលនៅខាងលិចភូមិចន្ទ្រានោះ មួយប្រាវ ស្រាប់តែរថក្រោះពួកវា ក៏ងាកក្បាលមករកពួកគាត់វិញ ហើយឈប់នៅក្បែរអន្លង់មួយហៅថា អន្លង់ព្រៃពស់ មានចម្ងាយប្រហែល៣០០ម៉ែត្រពីភូមិចន្ទ្រា មួយសន្ទុះ។ ពេលនោះពួកគាត់ក៏រត់គេចខ្លួន ដោយបានដេញគោក្របីមួយហ្វូងធំ គេចចេញពីពួកវាផងដែរ។ តែត្រូវរថក្រោះ និងទាហានជីវ គី ដេញតាមបាញ់ពីក្រោយ។

មុនដំបូង គាត់មិនទាន់រត់ចោលគោក្របីមួយហ្វូងធំនោះទេ រហូតដល់មានឧទ្ធម្ភាគចក្រហោះមកបាញ់រះពីលើ គាត់បានរត់ទៅពួនលាក់ខ្លួនក្រាបឱបកាំភ្លើងក្នុងប្រឡាយមួយក្បែរភូមិ។ តែប៉ុន្មាននាទីប៉ុណ្ណោះ គោក្របីជាង១០ក្បាលត្រូវគ្រាប់ ងាប់ពេញវាលស្រែ។ តែសំណាងល្អ ពួកទាហានជីវ គី មើលមិនឃើញគាត់កំពុងក្រាបពួនក្នុងប្រឡាយនោះទេ។

ពេលនោះ ពួកទាហានជីវ គី បានបាញ់កាំភ្លើងផ្លោង និងបាញ់រះពីលើយន្តហោះ និងឧទ្ធម្ភាគចក្រទៅលើភូមិចន្ទ្រា បណ្តាលឱ្យអ្នកភូមិប្រហែល២០នាក់ត្រូវបាត់បង់ជីវិត និងឆេះផ្ទះសំបែងជាច្រើនខ្នង ។

លោកតាប្រាក់ សារិន បានរៀបរាប់បន្តថា ពេលចូលមកដល់ក្នុងភូមិ មេទាហានជីវ គី នៅលើរថក្រោះ បានបញ្ជាឲ្យកូនចៅវាដេញចាប់អ្នកភូមិមួយចំនួនយកទៅជាមួយ ក្នុងនោះមានបងជីដូនមួយគាត់ម្នាក់អាយុ៤៥ឆ្នាំ ឈ្មោះសោម  យុត ក៏ត្រូវពួកទាហានជីវ គី ចាប់យកទៅជាមួយដែរ តែក្រោយមក ពួកវាបានដោះលែងវិញ។

ពេលនោះដែរ អ្នកភូមិមួយចំនួនបានរត់គៀសខ្លួន ទៅផ្សារជីភូ រយៈពេល៣-៤ ថ្ងៃ ទើបត្រលប់ចូលមកក្នុងភូមិវិញ។

នៅថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៦៤ នៅក្រុងវ៉ាស៊ីនតោន ក្រសួងការបរទេសសហរដ្ឋអាមេរិក បានឱ្យដឹងថា គិតត្រឹមថ្ងៃត្រង់ថ្ងៃ(ទី២១ ខែមីនា)នេះ យើងកំពុងស្រាវជ្រាវព័ត៌មានអំពីឧបទ្ទវហេតុវាយប្រហារនៅព្រំដែនកម្ពុជា ឱ្យបានទាន់ហេតុការណ៍ ។



**ប្រជាជនខ្មែរនៅភូមិចន្ទ្រា ស្លាប់ដោយសារកងទ័ពវៀតណាមខាងត្បូង ចូលវាយប្រហារ**

កាលពីម្សិលមិញ មន្ត្រីស្ថានទូតរបស់យើងនៅទីក្រុងភ្នំពេញ បានរាយការណ៍ថា អនុព័ន្ធយោធារបស់យើង បានអមដំណើរតំណាងប្រទេសកាណាដា ជាគណៈកម្មការត្រួត-ពិនិត្យអន្តរជាតិនៅកម្ពុជា ទៅកាន់ភូមិចន្ទ្រា(ខេត្តស្វាយរៀង)។ នៅទីនោះ ពួកគេបានឃើញសាកសពអ្នកភូមិចំនួន១៥នាក់ ដែលស្លាប់ដោយសារការបាញ់នឹងកាំភ្លើងដៃ និងត្រូវគ្រាប់កាំភ្លើងផ្លោង និងការទម្លាក់គ្រាប់បែកណាប៉ាល់ (Napalm)។ ពួកគេបានទទួលយកសក្ខីកម្មពីអ្នកភូមិថា បន្ទាប់ពីការវាយប្រហារនោះ មានមន្ត្រីយោធាអាមេរិកបីនាក់ បានចូល ទៅក្នុងភូមិ ហើយបានសាកសួរអ្នកស្រុកមួយចំនួន។ អ្នកភូមិក៏បានផ្តល់សក្ខីកម្មទៀតថា យន្តហោះសង្កេតការណ៍របស់អាមេរិកមួយគ្រឿង ត្រូវបានបាញ់ធ្លាក់នៅត្រង់ព្រំដែន។

របាយការណ៍ពីទីក្រុងសៃហ្គន នៅតែមានការយឺតយ៉ាវ ហើយព័ត៌មាននៅតែមាន

លក្ខណៈស្រពិចស្រពិល។ ឥឡូវយើងគ្រាន់តែដឹងថា ប្រតិបត្តិការមួយត្រូវបានធ្វើនៅថ្ងៃទី ១៩ ខែមីនា នៅជិតព្រំដែនកម្ពុជា។ យន្តហោះសង្កេតការណ៍អិល-១៩( L-19) មួយគ្រឿងដែលចូលរួមក្នុងប្រតិបត្តិការនេះត្រូវបានទាហានកម្ពុជាពីរនាក់បាញ់ទម្លាក់ ហើយអ្នកបើកយន្តហោះសង្កេតការណ៍នោះត្រូវរងរបួស។

តាមរបាយការណ៍ពីទីក្រុងសៃហ្គន បានឱ្យដឹងថា កងទ័ពនៃសាធារណរដ្ឋវៀតណាមចំនួនបីមុខព្រួញបានធ្វើប្រតិបត្តិការបោសសម្អាតកងទ័ពវៀតកុង នៅជិតព្រំដែនកម្ពុជា។ ប៉ុន្តែយើងមិនទាន់បានទទួលការបញ្ជាក់ពីរដ្ឋការទីក្រុងសៃហ្គន ថា អង្គភាពកងទ័ពនៃសាធារណរដ្ឋវៀតណាម ណាមួយ ដែលបានឆ្លងកាត់ព្រំដែនទៅបើកប្រតិបត្តិការវាយប្រហារភូមិខ្មែរនោះទេ។ ដំបូង មានរបាយការណ៍មកថា មានតែកងទ័ពអាមេរិក ម្នាក់ប៉ុណ្ណោះដែលបានចូលរួមក្នុងប្រតិបត្តិការនោះ។

តែប៉ុន្មានម៉ោងក្រោយមក មានរបាយការណ៍មួយបានឱ្យដឹងថា យ៉ាងហោចណាស់ក៏មានកងទ័ពអាមេរិក បីនាក់ដែរ បានចូលរួមក្នុងប្រតិបត្តិការនោះ។ មកទល់ពេលនេះ នៅមិនទាន់មានការបញ្ជាក់ពីទីក្រុងសៃហ្គន ថាភូមិខ្មែរណាមួយ ត្រូវរងការវាយប្រហារនោះនៅឡើយ។

ទន្ទឹមនឹងនោះ យើងបានសម្តែងការសោកស្តាយចំពោះឧបទ្ទវហេតុនេះបានកើតឡើងនោះ ហើយបានប្រាប់រដ្ឋមន្ត្រីការបរទេសកម្ពុជាថា យើងកំពុងស៊ើបអង្កេតឱ្យបានហ្មត់ចត់ដើម្បីដឹងថា តើការវាយប្រហារនោះមានការចូលរួមពីកងទ័ពអាមេរិក ឬយ៉ាងណា ?។ រដ្ឋាភិបាលកម្ពុជា បានប្តឹងតវ៉ាទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នឹងប្រជុំពិភាក្សាគ្នាពីបញ្ហានេះ នៅថ្ងៃចន្ទខាងមុខ។

ពេលនេះ យើងកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីឲ្យរដ្ឋការទីក្រុងសៃហ្គន ផ្តល់ព័ត៌មានពីឧបទ្ទវហេតុនេះបន្ថែមទៀត។ យើងមិនមានគម្រោងធ្វើការអត្ថាធិប្បាយជាសាធារណៈ ឬសកម្មភាពការទូតបន្ថែមទៀតទេ រហូតទាល់តែយើងមានរបាយការណ៍គ្រប់គ្រាន់នៅក្នុងដៃសិន។ យើងនឹងធ្វើរបាយការណ៍ពីឧបទ្ទវហេតុនេះបន្ថែមទៀត នៅពេលក្រោយ។



ទីប្រឹក្សាយោធាអាមេរិក បង្រៀនកងទ័ពវៀតណាមខាងត្បូង ឱ្យចេះប្រើកាំភ្លើង M-79

ប៉ុន្មានថ្ងៃក្រោយមក មន្ត្រីជាន់ខ្ពស់សេនាធិការសន្តិសុខជាតិ នៅសេតវិមាន បានរាយការណ៍ប្រាប់ប្រធានាធិបតីអាមេរិក លីនដុន ប៊ី. ចនសុន ថា ហេតុការណ៍នេះ បានកើតឡើងដោយសារកងទ័ពវៀតណាមខាងត្បូង ដេញតាមវាយកម្ទេចកងទ័ពវៀតកុង-វៀតណាមខាងជើង តែដោយសារពុំមានព័ត៌មានគ្រប់គ្រាន់ក្នុងការកំណត់ភូមិសាស្ត្រឱ្យបានច្បាស់លាស់ ទើបបណ្តាលឱ្យជ្រុលចូលទៅក្នុងទឹកដីកម្ពុជា។

ជាមួយគ្នា រដ្ឋាភិបាលវៀតណាមខាងត្បូង ក៏បានចេញសេចក្តីថ្លែងការណ៍សុំទោសចំពោះហេតុការណ៍នេះផងដែរ ចំណែកឯប្រធានាធិបតីថ្មីរបស់សហរដ្ឋអាមេរិក វិញ ដំបូងហាក់ដូចជាមានបំណងចង់ប្រកាសសុំទោសចំពោះការវាយប្រហារទៅលើភូមិចន្ទ្រានោះដែរ តែគិតថា បើប្រកាសសុំទោសទៅ គឺ មិនខុសពីអ្វីដែលសម្តេចសីហនុ ធ្លាប់តែលើកឡើងថា អាមេរិក កំពុងតែត្រួតត្រាប្រទេសវៀតណាមខាងត្បូង នោះឡើយ។

ទីបំផុត សហរដ្ឋអាមេរិក គ្រាន់តែប្រកាសសម្តែងការសោកស្តាយជាផ្លូវការចំពោះហេតុការណ៍វាយប្រហារទៅលើភូមិចន្ទ្រា និងបានទទួលស្គាល់ថា មានទីប្រឹក្សាយោធាអា-

មេរិក បានចូលរួមក្នុងការវាយប្រហារនោះដែរ ព្រមទាំងបញ្ជាក់ថា ហេតុការណ៍នោះ កើតឡើងដោយសារតែមើលផែនទីច្រឡំតែប៉ុណ្ណោះ ដោយមិនបានប្រកាសសុំទោស ឬទទួលស្គាល់កំហុសរបស់ខ្លួនជាផ្លូវការណាមួយទេ។

មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលអាមេរិក មួយចំនួនក៏បានទាមទារឱ្យចាត់វិធានការណាមួយដើម្បីកុំឱ្យមានហេតុការណ៍វាយប្រហារណាមួយមកលើភូមិខ្មែរ ជាថ្មីម្តងទៀត។ តែមន្ត្រីជាន់ខ្ពស់យោធានៅមន្ទីរប៉ង់តាហ្គោន (Pentagon) ដែលជាទីបញ្ជាការធំរបស់សហរដ្ឋអាមេរិក មិនមានចំណាត់ការអ្វីមួយទៅលើមេបញ្ជាការកងទ័ពអាមេរិក ប្រចាំនៅវៀតណាមខាងត្បូងនោះបន្តិចឡើយ។

ក្រោយពីការរំលោភឈ្លានពានដ៏សាហាវឃោរឃៅនោះប៉ុន្មានថ្ងៃ សម្តេចសីហនុ បានសម្រេចផ្តាច់ទំនាក់ទំនងការទូតជាមួយសាធារណរដ្ឋវៀតណាមខាងត្បូង ដោយគ្មានរារែកព្រះទ័យបន្តិចឡើយ។ ប៉ុន្តែ មេដឹកនាំវៀតណាមខាងត្បូង ដែលជាសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក នៅតែបន្តការរំលោភឈ្លានពានកម្ពុជាបន្តទៀត។

នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៦៤ កងទ័ពវៀតណាមខាងត្បូង បានវាយប្រហារមកលើភូមិសំដី ឃុំធ្លក ស្រុកស្វាយជ្រំ ក្នុងខេត្តស្វាយរៀង ជាថ្មីម្តងទៀត ។

មួយថ្ងៃក្រោយមក កងទ័ពវៀតណាមខាងត្បូង ក៏បានវាយប្រហារទៅលើភូមិធ្លកដែលនៅក្នុងឃុំធ្លក ជាមួយគ្នាដែរ មួយទៀត ហើយត្រូវទាហានកម្ពុជា វាយប្រយុទ្ធតបតវិញ ដោយបានបាញ់រថក្រោះមួយគ្រឿងឱ្យខូច និងស្លាប់កងទ័ពវៀតណាមខាងត្បូងនៅទីលានប្រយុទ្ធផងដែរ។

នៅក្នុងខែឧសភា នោះដែរ សម្តេចសីហនុ បានចោទប្រកាន់សហរដ្ឋអាមេរិកថាបានធ្វើវិទ្ធង្សនាបំផ្លាញគ្រឿងចក្រដែលកម្ពុជា ទិញមកជួសជុលផ្លូវមិត្តភាពកម្ពុជា-អាមេរិក (ផ្លូវជាតិលេខ៤)ហើយថា ការស្រាវជ្រាវរុករកសត្វគោព្រៃ ដែលអាមេរិក ស្នើសុំនោះ បានបំផ្លាញសត្វព្រៃ និងព្រៃឈើរបស់កម្ពុជា អស់ជាច្រើន ។ ប៉ុន្តែ ទាំងការរំលោភឈ្លានពានទៅលើភូមិចន្ទ្រា(ក្នុងឃុំ-ស្រុកចន្ទ្រា) និងក្រោយមកទៀតទៅលើភូមិសំដី និងភូមិធ្លក(ឃុំ

ធ្លក ស្រុកស្វាយជ្រំ )នោះ សហរដ្ឋអាមេរិក បានទម្លាក់កំហុសទៅលើពួកវៀតកុង-វៀតណាម ខាងជើងថា បានប្រើប្រាស់ភូមិទាំងអស់នោះ ធ្វើជាជម្រកលាក់ខ្លួន ទើបកងទ័ពវៀតណាម ខាងត្បូង និងអាមេរិក ធ្វើការវាយប្រហារទៅលើភូមិទាំងនោះ។

ដូចកាលមុនៗដែរ ពេលនោះសម្តេចសីហនុ បានបដិសេធថា កងទ័ពវៀតកុង-វៀតណាម ខាងជើង មិនមានធ្វើសកម្មភាពលាក់ខ្លួននៅតាមភូមិដែលប្រជារាស្ត្រខ្មែររស់នៅនោះទេ ហើយព្រះអង្គបានចាត់ទុកថា ហេតុការណ៍នៅភូមិចន្ទ្រា ក៏ដូចជានៅភូមិសំដី និងភូមិធ្លក នោះដែរ ជាសកម្មភាពរំលោភឈ្លានពានមកលើបូរណភាពទឹកដីកម្ពុជា ហើយព្រះអង្គបាន ដាក់ពាក្យបណ្តឹងជាផ្លូវការទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ពីការរំលោភឈ្លាន ពានរបស់វៀតណាមខាងត្បូង និងសហរដ្ឋអាមេរិក មកលើទឹកដីកម្ពុជា ផងដែរ។

នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៦៤ ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ បានសម្រេចបញ្ជូនក្រុមបេសកកម្មឱ្យមកបោះទីតាំងនៅតាមបណ្តោយព្រំដែនប្រទេសទាំង ពីរ ដើម្បីស៊ើបអង្កេតសកម្មភាពរំលោភឈ្លានពានរបស់វៀតណាមខាងត្បូង និងសហរដ្ឋអាមេ-រិក មកលើបូរណភាពទឹកដីកម្ពុជា ។ តែក្រុមបេសកកម្មនោះ មិនបានទទួលស្គាល់ថា មាន ទីប្រឹក្សាយោធាអាមេរិក ជាអ្នកដឹកនាំកងទ័ពវៀតណាមខាងត្បូង ឱ្យចូលមកលុកលុយភូមិ កម្ពុជា ដូចការចោទប្រកាន់របស់ភាគីកម្ពុជាទេ។ ចំណែករបបរដ្ឋការវៀតណាមខាងត្បូង ក៏បដិសេធថា ខ្លួនមិនបានចូលមកឈ្លានពានមកលើទឹកដីកម្ពុជា ដែរ។

តែទោះបីយ៉ាងណា ក៏ថ្ងៃទី០៦ ខែមិថុនា ក្រុមប្រឹក្សាសន្តិសុខអង្គសហប្រជាជាតិ បានសម្រេចឱ្យវៀតណាមខាងត្បូង និងសហរដ្ឋអាមេរិក សងសំណងដល់ការបាត់បង់ ជីវិតមនុស្ស អ្នករងរបួស និងទ្រព្យសម្បត្តិផ្សេងៗ ដែលកងទ័ពវៀតណាមខាងត្បូង និង សហរដ្ឋអាមេរិក ចូលមករំលោភឈ្លានពាន បំផ្លិចបំផ្លាញនោះដែរ ។

ជាមួយគ្នានេះដែរ អង្គការកំពូលនេះ ក៏បានអំពាវនាវឱ្យប្រទេស និងរដ្ឋទាំងអស់ ទទួលស្គាល់អព្យាក្រឹតភាព និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ផងដែរ។

# ១៦៩
# ទំនាក់ទំនងការទូតកម្ពុជា-អាមេរិក កាន់តែធ្លាក់ដុនដាប




**សម្តេចសីហនុ, អ្នកម្នាងម៉ូនិក និងប្រធានាធិបតី ហ្សាល ដឺហ្គោល ឆ្នាំ១៩៦៤**

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៦៤ សម្តេចសីហនុ បានស្នើឱ្យរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង(វៀតកុង) ដែលកំពុងធ្វើសង្គ្រាមនៅវៀតណាមខាងត្បូង និងកងទ័ពអាមេរិក ទទួលស្គាល់ព្រំដែន និងអធិបតេយ្យភាពរបស់កោះនានា ដែលវៀតណាមខាងត្បូងកំពុងរំលោភឈ្លានពានដណ្តើមយកទាំងកម្រោលនោះ។

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៦៤ សម្តេចសីហនុ និងអ្នកម្នាងម៉ូនិក យាងទៅប្រទេសបារាំង ដោយមានមន្ត្រីជាន់ខ្ពស់ជាច្រើនហែហមព្រះរាជដំណើរផងដែរ។

នៅទីក្រុងប៉ារីស ប្រធានាធិបតី ហ្សាល ដឺហ្គោល (Charles De Gaulle) បានទទួលជួបព្រះអង្គយ៉ាងរាក់ទាក់កក់ក្តៅបំផុត ហើយប្រធានាធិបតីរូបនេះបានសម្តែងការគាំទ្រយ៉ាងពេញទំហឹង នូវគោលនយោបាយអព្យាក្រឹតរបស់សម្តេចសីហនុ និងអំពាវនាវឱ្យបណ្តាប្រទេស

នានា ទទួលស្គាល់ និងគោរពបូរណភាពទឹកដីកម្ពុជា ទៀតផង។

នៅក្នុងឱកាសនោះដែរ ព្រះអង្គក៏បានតែងតាំងគណៈកម្មការមួយក្រុមដោយមាន ញឹក ជូឡុង ជាប្រធាន និង សឺន សាន ជាអនុប្រធាន ដើម្បីជួបពិភាក្សាគ្នាជាមួយភាគីបារាំង ស្តីពីការផ្តល់ជំនួយសេដ្ឋកិច្ចរបស់បារាំង មកឱ្យកម្ពុជា ផងដែរ។

នៅពាក់កណ្តាលខែកក្កដា សម្តេចសីហនុ បានចោទប្រកាន់សហរដ្ឋអាមេរិកថា បានបាចជាតិគីមីពុលមកលើតំបន់ព្រៃឈើមួយចំនួនក្នុងខេត្តរតនគិរី និងខេត្តស្វាយរៀង បណ្តាលឱ្យអន្តរាយដល់ព្រៃឈើ និងប្រជារាស្ត្រខ្មែររស់នៅតំបន់នោះ ត្រូវស្លាប់ជាច្រើនរយនាក់។

នៅពេលនោះដែរ ព្រះអង្គបានប្រកាសថា ព្រះអង្គនឹងបង្កើតទំនាក់ទំនងការទូតជាមួយសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង) ទៀតផង។

ជាមួយនឹងការបាចជាតិគីមីពុលមកលើទឹកដីខ្មែរនេះ កងទ័ពវៀតណាមខាងត្បូងក៏បានធ្វើការវាយប្រហារ និងទម្លាក់គ្រាប់បែកមកលើភូមិខ្មែរជាបន្តបន្ទាប់ថែមទៀតនោះ ធ្វើឱ្យសម្តេចសីហនុ កាន់តែពិរោធខ្លាំងថែមទៀត រហូតដល់មានបន្ទូលថា ព្រះអង្គមិនទទួលសារតាំងឯកអគ្គរដ្ឋទូតថ្មី រ៉ាន់ដុលហ្វ៍ អេ ឃីដដ័រ (Randolph A. Kidder) ដែលរដ្ឋាភិបាលអាមេរិក ទើបនឹងតែងតាំងឱ្យមកធ្វើឯកអគ្គរដ្ឋទូតប្រចាំនៅកម្ពុជា នៅថ្ងៃទី៩ ខែ កក្កដា ឆ្នាំ១៩៦៤នោះជាដាច់ខាត។

លុះដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៦៤ រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក ក៏បានបញ្ជាឱ្យឯកអគ្គរដ្ឋទូតថ្មី រ៉ាន់ដុលហ្វ៍ អេ. ឃីដដ័រ (Randolph A. Kidder) ចាកចេញពីទីក្រុងភ្នំពេញ ត្រលប់ទៅសហរដ្ឋអាមេរិក វិញដែរ។

នៅខែតុលា ឆ្នាំ១៩៦៤ សម្តេចព្រះនរោត្តម សីហនុ បានព្រមានទៅកាន់អាមេរិក ថា៖ «ករណីមានការរំលោភលើដែនអធិបតេយ្យកម្ពុជា សាជាថ្មីដោយកងទ័ពអាមេរិក កម្ពុជានឹងកាត់ផ្តាច់ចំណងការទូតជាមួយសហរដ្ឋអាមេរិក ភ្លាមៗជាមិនខាន»។

ដោយសារទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ កាន់តែធ្លាក់ចុះដុនដាបទៅៗ សហរដ្ឋអាមេរិក ក៏បានព្យាយាមស្នើសុំឱ្យមានជំនួបចរចាជាមួយភាគីកម្ពុជា នៅទីក្រុងញូវដែលី

ប្រទេសឥណ្ឌា ដើម្បីស្តារទំនាក់ទំនងការទូតនេះឡើងវិញ។ ពេលនោះសម្តេចសីហនុ ក៏បានយល់ព្រមឱ្យមានជំនួបចរចាគ្នានោះ ដោយគ្មានរារែកបន្តិចឡើយ។

ជំនួបចរចារវាងគណៈប្រតិភូកម្ពុជា ដឹកនាំដោយសឺន សាន និងគណៈប្រតិភូអាមេរិក ដឹកនាំដោយមន្ត្រីការទូតអាមេរិក ឈ្មោះហ្វីលីព បោនសាល ( Philip Bonsal ) នៅប្រទេសឥណ្ឌា បានចាប់ផ្តើមពីថ្ងៃទី០៨ រហូតដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៦៤។

នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៦៤ ជំនួបចរចានេះ បានធ្វើឡើងនៅឯវិមានហ៊ីដឺរ៉ាបេដ ( hyderabad ) ក្នុងទីក្រុងញូវ ដែលី ( New Delhi )។ ក្រោយពីកិច្ចពិភាក្សាគ្នាអស់រយៈពេល ៩ម៉ោងមក ភាគីទាំងពីរបានផ្អាកការចរចា ដោយមិនមានការព្រមព្រៀងគ្នាអ្វីមួយឡើយ។ ចំណុចសំខាន់នៃការចរចាមិនត្រូវគ្នានោះ គឺអាមេរិកមិនទទួលខុសត្រូវចំពោះឧបទ្ទវហេតុនៅព្រំដែនកម្ពុជា-វៀតណាមខាងត្បូង។ បន្ទាប់ពីជំនួបចរចាគ្នាមិនបានលទ្ធផលអ្វីមក ហ្វីលីព បោនសាល ( Philip Bonsal )ប្រធានគណៈប្រតិភូអាមេរិក បានថ្លែងថា គាត់ត្រូវការសិក្សាបញ្ហានេះឱ្យបានយ៉ាងល្អិតល្អន់សិន ហើយពេលវិលត្រលប់ទៅទីក្រុងវ៉ាស៊ីនតោនវិញ គាត់នឹងរាយការណ៍អំពីបញ្ហានេះទៅរដ្ឋាភិបាលរបស់គាត់។

ប្រធានគណៈប្រតិភូអាមេរិក បានថ្លែងការណ៍ជាផ្លូវការថា សហរដ្ឋអាមេរិក បានស្នើឱ្យមានកិច្ចប្រជុំជាចម្បងមួយនៃការធ្វើឱ្យប្រាកដថា រាជរដ្ឋាភិបាលកម្ពុជា យល់ច្បាស់អំពីតួនាទីរបស់សហរដ្ឋអាមេរិក ព្រោះវាក៏ជាក្តីសង្ឃឹមរបស់យើងក្នុងការស្វែងរកមធ្យោបាយដើម្បីនាំមកនូវភាពប្រសើរឡើងវិញក្នុងទំនាក់ទំនងរវាងប្រទេសទាំងពីរ។

ដោយឡែក គណៈប្រតិភូកម្ពុជា បានចេញសេចក្តីថ្លែងការណ៍ថា យើងចង់ឱ្យមានដំណោះស្រាយ២ចំណុចគឺ ទី១. ភូមិខ្មែរនៅជិតព្រំដែន មិនត្រូវទទួលរងការឈ្លានពានណាមួយពីកងកម្លាំងសហរដ្ឋអាមេរិក និងវៀតណាមខាងត្បូង និងទី២. សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្ត មិនត្រូវចោទប្រកាន់កម្ពុជា ដោយអយុត្តិធម៌ថា ជាជម្រកសម្រាប់កងទ័ពវៀតកុង ឬជាមធ្យោបាយដឹកជញ្ជូនអាវុធសម្រាប់វៀតកុងនោះទេ។ សេចក្តីថ្លែងការណ៍នោះ ក៏បានកត់សម្គាល់ថា សហរដ្ឋអាមេរិក ជាអ្នកផ្តួចផ្តើមគំនិតធ្វើឱ្យមានជំនួបចរចានេះ។



**ស៊ីនសាន ជួបចរចាជាមួយមន្ត្រីការទូតអាមេរិក ឈ្មោះហ្វីលីព បោនសាល** (រូបថតalamy)

ប៉ុន្តែ រយៈពេល១០ថ្ងៃនៃជំនួបចរចានោះ ភាគីទាំងពីរនៅតែមិនទទួលបានលទ្ធផលជាវិជ្ជមានណាមួយឡើយ។

ចំណែកភាគីសហរដ្ឋអាមេរិក បានធ្វើការស្តីបន្ទោសពីភាពរឹងរូសរបស់សម្តេចសីហនុ។ ឯសម្តេចសីហនុ ក៏បានស្តីបន្ទោសទៅសហរដ្ឋអាមេរិក វិញថា ការដែលអាមេរិក បង្កើតឱ្យមានការចរចានេះ គឺគ្រាន់តែដើម្បីកែលម្អកំហុសឆ្គងរបស់ខ្លួនតែប៉ុណ្ណោះ ហើយព្រះអង្គបញ្ជាក់ថា គ្មានមូលហេតុអ្វី ដែលត្រូវព្រះអង្គចំណាយពេលវេលា និងថវិកាឥតប្រយោជន៍ក្នុងការបន្តលេងល្បែងចរចាកំប្លុកកំប្លែងជាមួយអាមេរិក ទៀតទេ។

ដោយសារបរាជ័យក្នុងជំនួបចរចាគ្នានេះ អាមេរិក ក៏មានការព្រួយបារម្ភខ្លាចកើតមានបាតុកម្មហិង្សាណាមួយ មកលើស្ថានទូតរបស់ខ្លួននៅទីក្រុងភ្នំពេញ ជាថ្មីម្តងទៀតដែរ។

ពេលនោះ នៅទីក្រុងភ្នំពេញ បើទោះបីមិនមានបាតុកម្មហិង្សាណាមួយទៅលើស្ថានទូតអាមេរិក ដូចការព្រួយបារម្ភនោះ ក៏ពិតមែន តែក៏មានការខឹងសម្បារើសអើងចំពោះជនជាតិអាមេរិក ដែរ។

ថ្ងៃមួយ សមាជិកគណៈកម្មការត្រួតពិនិត្យអន្តរជាតិម្នាក់ ជាជនជាតិប៉ូឡូញ បានរង

របួសធ្ងន់ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍មួយ នៅក្បែរអាកាសយានដ្ឋានពោធិ៍ចិនតុង ជាយទីក្រុងភ្នំពេញ ប្រជារាស្ត្រខ្មែរជាច្រើនដែលបានឃើញហេតុការណ៍នោះ មិនបានឈឺឆ្អាលជួយយកអាសាទេ ព្រោះពួកគេនឹកស្មានថា ជនរងគ្រោះជាជនជាតិប៉ូឡូញ នោះ ជាជនជាតិអាមេរិក។

ពីមុនមក មានជនជាតិអាមេរិក ប្រមាណ៣០០នាក់ រស់នៅក្នុងទីក្រុងភ្នំពេញ។ ប៉ុន្តែក្រោយពីមានហេតុការណ៍វាយកម្ទេចស្ថានទូតអាមេរិក កាលពីថ្ងៃទី១១ ខែមីនា មក រហូតដល់ចុងឆ្នាំ១៩៦៤ ជនជាតិអាមេរិក ដែលរស់នៅក្នុងប្រទេសកម្ពុជា មានចំនួនតែ១២នាក់ប៉ុណ្ណោះ។

ពេលនោះទីប្រឹក្សាសន្តិសុខជាតិរបស់ប្រធានាធិបតីអាមេរិក ក៏បានទទូចឱ្យប្រធានាធិបតី លីនដុន ប៊ី. ចនសុន(Lyndon B. Johnson) ដែលឡើងជំនួស ចន អែហ្វ. កេណ្ណឌីនោះ ធ្វើការណែនាំទៅលើមេដឹកនាំវៀតណាមខាងត្បូង ឱ្យបន្ធូរបន្ថយភាពតានតឹងនៅតាមបណ្តោយព្រំដែនកម្ពុជា។ បើមិនដូច្នេះទេ គាត់គិតថា សម្តេចសីហនុ នឹងកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយ សហរដ្ឋអាមេរិក បានជាមិនខាន។

ទោះបីយ៉ាងនេះ ក៏ដោយ ក៏ប្រធានាធិបតីសហរដ្ឋអាមេរិក មិនបានរកវិធីណាមួយដើម្បីធ្វើឱ្យទំនាក់ទំនងការទូតជាមួយប្រទេសកម្ពុជា ល្អប្រសើរវិញដែរ។

ចំណែកសម្តេចសីហនុ វិញ ក៏កាន់តែមានការខឹងសម្បាជាមួយសហរដ្ឋអាមេរិក ខ្លាំងឡើងៗ ដោយព្រះអង្គតែងតែលើកឡើងជារឿយៗថា ជំនួយរបស់សហរដ្ឋអាមេរិក សុទ្ធតែជាជំនួយមានចំណង, អាមេរិក ក្តៅក្រហាយពីរឿងព្រះអង្គមិនព្រមចូលជាសមាជិកអង្គការសេអាតូ (SEATO) ដែលខ្លួនជាអ្នកផ្តួចផ្តើមបង្កើតឡើងនោះ និងបានឱ្យពួកអ្នកកាសែតរបស់ខ្លួនសរសេរបន្ទុះបង្អាប់ព្រះអង្គ និងប្រទេសកម្ពុជា...ជាដើម។

ជាមួយគ្នានោះ អាមេរិក បានឱ្យយន្តហោះទៅទម្លាក់គ្រាប់បែកលើវៀតណាមខាងជើង ដែលធ្វើឱ្យមតិពិភពលោកស្អប់ខ្ពើមអាមេរិក ជាងបារាំង កាលពីសម័យអាណានិគមទៅទៀត ពិសេស អាមេរិក បានគប់គិតជាមួយវៀតណាមខាងត្បូង លើកទ័ពចូលមករំលោភឈ្លានពាន




**ប្រធានាធិបតី លីនដុន បី. ចនសុន ទៅសួរសុខទាហានអាមេរិក**
**នៅមូលដ្ឋានកាំរ៉ាញ់ វៀតណាមខាងត្បូង**

ទឹកដីកម្ពុជា គ្មានឈប់ឈរ។

នៅក្នុងខែសីហា ឆ្នាំ១៩៦៤ សម្តេចសីហនុ បង្ហើបឱ្យដឹងពីព្រះទ័យចង់ផ្តាច់ទំនាក់ទំនងការទូតជាមួយសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម(វៀតណាមខាងជើង)។

# ១៧០
# ចិន ជួយវៀតណាមខាងជើង អាមេរិក ជួយវៀតណាមខាងត្បូង



**ហូ ជីមិញ និងម៉ៅ សេទុង ជួបគ្នានៅក្រុងប៉េកាំង ក្នុងខែសីហា ឆ្នាំ១៩៥៧**

តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៤០មក ប្រទេសចិន មានតួនាទីសំខាន់ក្នុងការជួយឧបត្ថម្ភគាំទ្រពួកវៀតមិញ ដើម្បីធ្វើសង្គ្រាមប្រឆាំងនឹងពួកអាណានិគមនិយមបារាំង។ ក្រោយពីមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ឆ្នាំ១៩៥៤មក ហូ ជីមិញ មេដឹកនាំកុម្មុយនិស្ត(វៀតណាមខាងជើង) បានស្នើសុំឱ្យមេដឹកនាំចិន ជួយពង្រឹងសន្តិភាព និងអភិវឌ្ឍន៍ប្រទេសរបស់ខ្លួនបន្តទៀត។

នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៥៥ វ៉ូ ង្វៀនយ៉ាប់ រដ្ឋមន្ត្រីការពារជាតិ បានដឹកនាំគណៈប្រតិភូយោធាមួយក្រុម ដោយមានប្រធានក្រុមទីប្រឹក្សាចិន ប្រចាំនៅសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម អមដំណើរផង ទៅបំពេញទស្សនកិច្ចសម្ងាត់មួយនៅទីក្រុងប៉េកាំង។

វ៉ ង្វៀនយ៉ាប់ បានជួបសន្ទនាជាមួយរដ្ឋមន្ត្រីការពារជាតិចិន សេនាប្រមុខ ប៉េង តឺហួយ (Peng Dehuai) និងឧត្តមសេនីយ៍ ប៉េត្រូ ស្វេវស្គី(Petro Shevski) ជាទីប្រឹក្សាយោធាជាន់ខ្ពស់របស់សហភាពសូវៀត ប្រចាំប្រទេសចិន ពីបញ្ហាកសាងកងទ័ព និងផែនការតស៊ូធ្វើសង្គ្រាមនៅពេលអនាគត និងបង្រួបបង្រួមវៀតណាម ទាំង២ផងដែរ។ ពេលនោះរដ្ឋមន្ត្រីការពារជាតិចិន និងទីប្រឹក្សាសហភាពសូវៀត មានការខ្វែងគំនិតគ្នាពីយុទ្ធសាស្ត្រដើម្បីបង្រួបបង្រួមវៀតណាមទាំង២។

ទីប្រឹក្សាសហភាពសូវៀត ចង់ឱ្យវៀតណាមខាងជើង រកមធ្យោបាយបង្រួបបង្រួមវៀតណាមដោយសន្តិវិធី និងឈរលើមូលដ្ឋានឯករាជ្យ និងប្រជាធិបតេយ្យ(ប្រជាធិបតេយ្យបែបកុម្មុយនិស្ត) ប៉ុន្តែពួកទីប្រឹក្សាចិន បានជំទាស់ថា ដោយសារការធ្វើវិទ្ធង្សនារបស់ពួកចក្រពត្តិនិយម គេមិនអាចបង្រួបបង្រួមវៀតណាម តាមរយៈការបោះឆ្នោតស្របទៅនឹងកិច្ចព្រមព្រៀងក្រុងហ្សឺណែវ បានឡើយ។ ដូច្នេះ វៀតណាមខាងជើង គួរតែត្រៀមខ្លួនធ្វើការតស៊ូយូរអង្វែង។

ដោយសារការខ្វែងគំនិតគ្នានេះ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៥៥ មេដឹកនាំចិន ក៏បានចាប់ផ្តើមដកពួកទីប្រឹក្សា និងជំនាញការសំខាន់ៗរបស់ខ្លួន ចេញពីវៀតណាមខាងជើង។ បន្ទាប់មក ក៏បានដាក់ពួកទីប្រឹក្សា និងជំនាញការដែលមិនសូវសំខាន់ជំនួសវិញ ដើម្បីជួយកសាងប្រទេសវៀតណាម បន្តទៀត។

នៅក្នុងខែមេសា ឆ្នាំ១៩៥៦ ចេន យុន (Chen Yun) ឧបនាយករដ្ឋមន្ត្រី និងជាអ្នកជំនាញខាងសេដ្ឋកិច្ចរបស់បក្សកុម្មុយនិស្តចិន បានធ្វើដំណើរទៅបំពេញទស្សនកិច្ចយ៉ាងសម្ងាត់មួយនៅទីក្រុងហាណូយ។

តបតាមសំណើរបស់ ហូ ជីមិញ ប្រធានាធិបតីសាធារណរដ្ឋប្រជាធិតេយ្យវៀតណាមដែលចង់អភិវឌ្ឍសេដ្ឋកិច្ចរបស់វៀតណាម ឱ្យបានរីកចម្រើនឆាប់រហ័សនោះ ឧបនាយករដ្ឋមន្ត្រីចិន រូបនេះ បានផ្តល់យោបល់ថា ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច វៀតណាម ត្រូវធ្វើឱ្យវិស័យកសិកម្មដើរមុនវិស័យឧស្សាហកម្ម ហើយវិស័យឧស្សាហកម្មធុនស្រាល ត្រូវដើរមុនវិស័យឧស្សាហ



**ហូ ជីមិញ និងនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ**

កម្មធុនធ្ងន់។ ហូ ជីមិញ និងថ្នាក់ដឹកនាំសាធារណរដ្ឋប្រជាធិតេយ្យវៀតណាម ផ្សេងទៀត បានទទួលយកយោបល់របស់ ចេន យុន(Chen Yun) ទៅអនុវត្ត។

នៅពាក់កណ្តាលឆ្នាំ១៩៥៦ មេដឹកនាំសាធារណរដ្ឋប្រជាធិតេយ្យវៀតណាម បានបើកអង្គប្រជុំពិភាក្សាសួរដេញដោលគ្នាថា តើនរណាជាអ្នកទទួលខុសត្រូវ ពីបញ្ហាបរាជ័យក្នុងការធ្វើកំណែទម្រង់ដីធ្លីកាលពីឆ្នាំ១៩៥៣ ដែលបានអនុវត្តតាមគំរូកំណែទម្រង់ដីធ្លីរបស់ប្រទេសចិននោះ?។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៥៦ ទ្រឿង ជិញ អគ្គលេខាគណៈកម្មាធិការមជ្ឈិមពលកវៀតណាម ដែលជាអ្នកទទួលខុសត្រូវពីបញ្ហាកែទម្រង់ដីធ្លីកាលពីឆ្នាំ១៩៥៣នោះ ត្រូវមហាសន្និបាតគណៈកម្មាធិការមជ្ឈិមពលករវៀតណាម ដកចេញពីមុខតំណែង ហើយមហាសន្និបាតបានជ្រើសតាំង ឡេ យន់ ជាអគ្គលេខាបក្សពលករវៀតណាម ជំនួសវិញ។

ឡេ យន់ បានបន្ទោស ទ្រឿង ជិញ ថា បរាជ័យនៃការយកបទពិសោធស្តីពីការធ្វើកំណែទម្រង់ដីធ្លីរបស់ចិន មកអនុវត្តកាលពីឆ្នាំ១៩៥៣នោះ មកពី ទ្រឿង ជិញ មិនបាន

គិតគូរដល់ស្ថានភាពជាក់ស្តែងនៅប្រទេសវៀតណាម។

ក្នុងពេលបំពេញទស្សនកិច្ចនៅទីក្រុងហាណូយ ពីថ្ងៃទី១៨ ដល់ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៥៦ ជូ អេនឡាយ នាយករដ្ឋមន្ត្រីចិន បានដាស់តឿន ហូ ជីមិញ ឱ្យប្រយ័ត្នប្រយែង ក្នុងការរៀបចំផែនការអភិវឌ្ឍសេដ្ឋកិច្ច ដូចអ្វីដែលឧបនាយករដ្ឋមន្ត្រី ចេន យុន (Chen Yun) បានផ្តល់យោបល់កាលពីខែមេសា នោះដែរ តែ ជូ អេនឡាយ បានផ្តាំផ្ញើថា កុំប្រញាប់ប្រញាល់ក្នុងការធ្វើសមូហភាវូបនីយកម្មកសិកម្ម ខ្លាំងពេក ។ ការផ្លាស់ប្តូររបៀបនេះត្រូវតែធ្វើជាជំហានៗ...។

ចាប់ពីឆ្នាំ១៩៥៧មក មេដឹកនាំវៀតណាមខាងជើង ចាប់ផ្តើមទាក់ទងមេដឹកនាំសហភាពសូវៀត ដើម្បីទទួលបានជំនួយសេដ្ឋកិច្ចយកមកអភិវឌ្ឍប្រទេសរបស់ខ្លួនផងដែរ។ ប៉ុន្តែបញ្ហានយោបាយធំៗ និងបញ្ហាតស៊ូបដិវត្តន៍នៅវៀតណាមខាងត្បូង មេដឹកនាំក្រុងហាណូយនៅតែបន្តជួបពិភាក្សាជាមួយមេដឹកនាំក្រុងប៉េកាំង យ៉ាងជិតស្និទ្ធដូចមុនដដែល។

នៅរដូវក្តៅឆ្នាំ១៩៥៨ បក្សពលករវៀតណាម បានផ្ញើឯកសារស្តីពីគម្រោងយុទ្ធសាស្ត្រ ដើម្បីឲ្យមេដឹកនាំចិនជួយផ្តល់អនុសាសន៍។ ឯកសារគម្រោងយុទ្ធសាស្ត្រទី១ មានចំណងជើងថា "ទស្សនៈរបស់យើងលើភារកិច្ចជាមូលដ្ឋាន សម្រាប់វៀតណាម ក្នុងដំណាក់កាលថ្មីៗ" និងទី២ មានចំណងជើងថា យោបល់មួយចំនួនពាក់ព័ន្ធនឹងមាគ៌ាបង្រួបបង្រួម និងមាគ៌ាធ្វើបដិវត្តន៍នៅភាគខាងត្បូង។

ក្រោយពីបានធ្វើការពិនិត្យពិចារណាយ៉ាងល្អិតល្អន់មក មេដឹកនាំចិន ក៏បានឆ្លើយតបជាលាយលក្ខណ៍អក្សរ ដោយបានផ្តល់អនុសាសន៍ថា ភារកិច្ចដ៏សំខាន់ និងបន្ទាន់បំផុតសម្រាប់បដិវត្តន៍វៀតណាម គឺការធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅភាគខាងជើង។ ឯនៅវៀតណាមភាគខាងត្បូង គួរតែជំរុញឱ្យធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យសិន បានហើយ។ ប៉ុន្តែ បើមិនអាចធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យជាចំហនៅវៀតណាមភាគខាងត្បូង បានទេ បក្សពលករវៀតណាម គួរតែប្រមូលផ្តុំកម្លាំងមហាជនបង្កើតបណ្តាញតស៊ូសម្ងាត់ ដើម្បីរង់ចាំកាលានុវត្តភាព( ឱកាសល្អ )មកដល់...។

របត់នយោបាយ

ក្នុងខែឧសភា ឆ្នាំ១៩៥៩ គណៈកម្មាធិការមជ្ឈិមបក្សពលកររៀតណាម បានសម្រេចចិត្ត ធ្វើការតស៊ូនយោបាយ រួមជាមួយនឹងការតស៊ូដោយអាវុធ។ ពេលនោះហើយ ដែលផ្លូវលំហូ ជីមិញ ចាប់ផ្តើមស្តារ និងកសាងឱ្យទៅជាផ្លូវយុទ្ធសាស្ត្រដែលមានសារៈសំខាន់ជាអាយុជីវិតរបស់ពួកកុម្មុយនិស្តវៀតណាម ក្នុងការដឹកជញ្ជូនអាវុធយុទ្ធភណ្ឌ ស្បៀង និងកងទ័ពពីវៀតណាមខាងជើង មកធ្វើសង្គ្រាមបដិវត្តន៍នៅវៀតណាមខាងត្បូង។

មហាសន្និបាតបក្សពលករវៀតណាម ក្នុងខែកញ្ញា ឆ្នាំ១៩៦០ មិនមានយុទ្ធសាស្ត្រអ្វីប្លែកប៉ុន្មានពីយុទ្ធសាស្ត្រដែលមានពីមុនមកនោះទេ តែបក្សពលករវៀតណាម បានធ្វើការកត់សម្គាល់ពីបញ្ហាបែកបាក់ប្រេះឆា នៅក្នុងជួរមេដឹកនាំវៀតណាមខាងត្បូង ហើយដើម្បីដណ្តើមយកប្រៀបខ្លាំងពីការបែកបាក់ប្រេះឆានោះ ពួកគេត្រូវតែធ្វើការតស៊ូនយោបាយរួមផ្សំជាមួយការតស៊ូអាវុធនៅភាគខាងត្បូងឱ្យបានខ្លាំងក្លាថែមទៀត។

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៦០ ពួកកុម្មុយនិស្តវៀតណាមខាងជើង បានបង្កើតរណសិរ្សតស៊ូមួយ ឈ្មោះ រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ហៅកាត់ជាភាសាវៀតណាមថា វៀតកុង ( Việt Cộng ) ។

នៅក្នុងឆ្នាំ១៩៦១ ប្រធានាធិបតីអាមេរិក ចន អែហ្វ. កេណ្ណឌី បានបញ្ជូនក្រុមជំនួយការ និងទីប្រឹក្សាយោធា ហៅកាត់ថា MAAG (Military Assistance and Advisory Group) ចំនួន១០០នាក់ ទៅជួយរបបវៀតណាមខាងត្បូង និងបានបញ្ជូនកងទ័ពពិសេសចំនួន៤០០ នាក់ ឱ្យទៅជួយបង្ហាត់បង្រៀនកងទ័ពវៀតណាមខាងត្បូង ពីក្បួនយុទ្ធសាស្ត្រប្រឆាំងនឹងការបះបោរ។

បញ្ហាអាមេរិក បញ្ជូនក្រុមជំនួយការ និងទីប្រឹក្សាយោធា ទៅជួយរបបវៀតណាមខាងត្បូងនេះ ធ្វើឱ្យមេដឹកនាំចិន មានការព្រួយបារម្ភខ្លះៗដែរ។

ក្នុងពេលនាយករដ្ឋមន្ត្រីវៀតណាមខាងជើង ផាម វ៉ាន់ដុង ទៅបំពេញទស្សនកិច្ចនៅក្រុងប៉េកាំង ក្នុងខែមិថុនា ឆ្នាំ១៩៦១ ប្រធានម៉ៅ (ម៉ៅ សេទុង) បានសម្តែងការគាំទ្រយ៉ាងពេញទំហឹងដល់ការតស៊ូប្រដាប់អាវុធរបស់ប្រជាជននៅវៀតណាមខាងជើង។





**ទីប្រឹក្សាយោធាអាមេរិក ជួយហ្វឹកហ្វឺនទាហានវៀតណាមខាងត្បូង**

តែទោះបីជាយ៉ាងនេះក៏ដោយ ក៏នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ នៅតែណែនាំឱ្យ ផាម វ៉ាន់ដុង មានភាពទន់ភ្លន់ក្នុងយុទ្ធវិធីនានា ដោយបានបញ្ជាក់ប្រាប់ ផាម វ៉ាន់ដុង ថា ការបូកបញ្ចូលគ្នារវាងការតស៊ូដោយស្របច្បាប់ ជាមួយការតស៊ូមិនស្របច្បាប់ និងយុទ្ធសាស្ត្រនៃការតស៊ូអាវុធ រួមផ្សំជាមួយនឹងការតស៊ូនយោបាយ វាមានសារៈសំខាន់ណាស់។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦២ សហរដ្ឋអាមេរិក បានបង្កើតបញ្ជាការដ្ឋានជំនួយយោធា (Military Assistance Cammand/Vietnam) របស់ខ្លួនមួយនៅក្នុងទីក្រុងព្រៃនគរ ដើម្បីបំពេញការងារជំនួសក្រុមជំនួយការ និងទីប្រឹក្សាយោធា(ហៅកាត់ថា MAAG = Military Assistance and Advisory Group)។

ចាប់ពីដើមឆ្នាំ ១៩៦២ មក ប្រធានាធិបតី ចន អែហ្វ. កេណ្ណឌី បានបញ្ជូនទីប្រឹក្សាអាមេរិក និងផ្តល់ជំនួយយោធាកាន់តែច្រើនថែមទៀត ទៅជួយរបបរដ្ឋការវៀតណាមខាងត្បូង។

ក្នុងឆ្នាំ១៩៦២ នេះដែរ ហូ ជីមិញ និងង្វៀន ជីថាញ់ បានធ្វើដំណើរទៅទីក្រុងប៉េកាំង ដើម្បីពិភាក្សាគ្នាជាមួយមេដឹកនាំចិន ពីបញ្ហាសហរដ្ឋអាមេរិក លូកដៃចូលមកធ្វើអន្តរាគមន៍នៅវៀតណាមខាងត្បូង កាន់តែជ្រៅទៅៗ និងភ័យខ្លាចសហរដ្ឋអាមេរិក បើកការវាយប្រហារទៅលើវៀតណាមខាងជើង ផងដែរ។

ពេលនោះ ហូ ជីមិញ បានស្នើសុំឱ្យចិន ជួយឧបត្ថម្ភដល់ចលនាតស៊ូរបស់ពួកវៀតកុងដែលកំពុងធ្វើសង្គ្រាមរំដោះវៀតណាមខាងត្បូង ផងដែរ។

ចិន បានផ្តល់កាំភ្លើងដៃ និងកាំភ្លើងយន្តចំនួន៩ម៉ឺនដើម ដោយមិនគិតថ្លៃ ឱ្យមេដឹកនាំ



**កងកុម្ម៉ង់ដូពិសេសអាមេរិក ចេញប្រតិបត្តិការវាយឆ្មក់**

វៀតណាមខាងជើង ដែលអាចយកទៅបំពាក់ឱ្យកងទ័ពថ្មើរជើងរបស់ពួកវៀតកុង បានរាប់រយកងវរសេនាតូច។

នៅពេលប្រធានអគ្គសេនាធិការកងទ័ពរំដោះប្រជាជនចិន ទៅបំពេញទស្សនកិច្ចនៅទីក្រុងហាណូយ ក្នុងខែមីនា ឆ្នាំ១៩៦៣ មេដឹកនាំវៀតណាមខាងជើង បានសួរទៅមេទ័ពកំពូលរបស់ចិន រូបនោះថា "ប្រសិនបើសហរដ្ឋអាមេរិក បើកការវាយប្រហារមកលើវៀតណាមខាងជើង តើចិន អាចជួយយើងយ៉ាងដូចម្ដេចខ្លះ?"។

ពេលប្រធានាធិបតីចិន លីវ ចាវជី ទៅបំពេញទស្សនកិច្ចនៅទីក្រុងហាណូយ នៅក្នុងខែឧសភា ឆ្នាំ១៩៦៣ នោះដែរ គាត់បានប្រាប់ ហូ ជីមិញ មេដឹកនាំកំពូលវៀតណាមខាងជើងថា ប្រសិនបើសង្គ្រាមផ្ទុះឡើងនៅវៀតណាមខាងជើង មែននោះ សមមិត្តអាចចាត់ទុកប្រទេសចិន ជាសមរភូមិក្រោយរបស់សមមិត្តបាន។

ពីឆ្នាំ១៩៥៦ ដល់ឆ្នាំ១៩៦៣ សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម បានទទួលជំនួយយោធាពីសាធារណរដ្ឋប្រជាមានិតចិន រួមមានកាំភ្លើងយន្តចំនួន២៧0.000ដើម, កាំភ្លើងផ្លោងប្រមាណ១០.០០០ដើម, គ្រាប់កាំភ្លើងដៃជាង ២០០.០០០.០០០គ្រាប់, គ្រាប់កាំភ្លើងផ្លោង ចំនួន២.០២០.០០០គ្រាប់, វិទ្យុត្រង់ស៊ីតទ័រ ប្រើខ្សែចំនួន១៥.០០០គ្រឿង, វិទ្យុត្រង់

ស៊ីតទ័រ ចំនួន៥.០០០គ្រឿង, រថយន្តដឹកជញ្ជូន ចំនួន១.០០០គ្រឿង, យន្តហោះចំនួន ១៥ គ្រឿង, នាវាចម្បាំង២៨គ្រឿង និងខោអាវឯកសណ្ឋានកងទ័ពចំនួន១.១៨០.០០០ កំផ្លេ សរុបជាទឹកប្រាក់ ប្រមាណ៣២០លានយ៉ន។

ក្នុងឆមាសទី១ ឆ្នាំ១៩៦៤ សហរដ្ឋអាមេរិក ចាប់ផ្តើមបញ្ជូនយន្តហោះស៊ើបការណ៍ និងបាចខិត្តប័ណ្ណឃោសនាប្រឆាំងនឹងពួកកុម្មុយនិស្តនៅវៀតណាមខាងជើង ពិសេសបានទាំងបញ្ជូនកងកុម្ម៉ង់ដូពិសេស ទៅធ្វើការវាយឆ្មក់នៅតាមឆ្នេរសមុទ្ររបស់វៀតណាមខាងជើងទៀតផង។

ជាមួយគ្នានេះដែរ សហរដ្ឋអាមេរិក បានគំរាមថា ខ្លួននឹងធ្វើសកម្មភាពយោធាទៅលើសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម កាន់តែខ្លាំងថែមទៀត ប្រសិនមេដឹកនាំក្រុងហាណូយ មិនព្រមបញ្ឈប់ការគាំទ្រ និងលើកទឹកចិត្តចំពោះពួកវៀតកុង ដែលកំពុងធ្វើសង្គ្រាមនៅវៀតណាមខាងត្បូង នោះទេ។ តែមេដឹកនាំក្រុងហាណូយ បានប្រកាសតបវិញថា ពួកគេមិនចុះញ៉មចំពោះការគំរាមកំហែងរបស់អាមេរិកជាដាច់ខាត ហើយពួកគេនៅតែបន្តគាំទ្រចំពោះការតស៊ូរបស់ប្រជាជនវៀតណាមខាងត្បូង តទៅទៀត។

# ១៧១
# ចិន ប្រកាសផ្ដល់ជំនួយយោធា និងជួយការពារកម្ពុជា




**ជំនួបសម្ដេចសីហនុ និងម៉ៅ សេទុង ថ្ងៃ២៨តុលា ឆ្នាំ១៩៦៤**

នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៦៤ សម្ដេចសីហនុ បានយាងទៅចូលរួមក្នុងពិធីបុណ្យរម្លឹកខួបលើកទី១៥ ថ្ងៃបង្កើតសាធារណរដ្ឋប្រជាមានិតចិន (ថ្ងៃទី១ ខែតុលា ១៩៤៩ - ថ្ងៃទី១ ខែតុលា ១៩៦៤) នៅទីក្រុងប៉េកាំង។

នៅថ្ងៃទី២៨ ខែកញ្ញា ព្រះអង្គបានចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយប្រធានម៉ៅ។

ជាដំបូង ម៉ៅ សេទុង បានទូលសម្ដេចសីហនុ ថា កាលពីថ្ងៃទី៥ ខែសីហា កន្លងទៅសហរដ្ឋអាមេរិក បានទម្លាក់គ្រាប់បែកលើមូលដ្ឋានយោធាជាច្រើនរបស់សាធារណរដ្ឋប្រជា

មានិតប្រជាធិបតេយ្យវៀតណាម។ តែការគាំទ្ររបស់សម្ដេច ចំពោះសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម មានច្រើនលើស លុបជាងបណ្ដាប្រទេសសង្គមនិយមមួយចំនួនទៅទៀត។ ប្រទេសសង្គមនិយមខ្លះ មិនល្អដូចសម្ដេចទេ គឺពួកគេធ្វើជាមិត្តជាមួយអាមេរិក។ តែសម្ដេចកំពុងតស៊ូប្រឆាំងនឹងអាមេរិក។ មានតែការតស៊ូទេ ដែលធ្វើឲ្យប្រទេសសម្ដេច អាចរស់រានមានជីវិតបាន។

ម៉ៅ សេទុង ផ្ដល់យោបល់ទូលសម្ដេចសីហនុ ថា ដើម្បីតស៊ូប្រឆាំងនឹងអាមេរិក ព្រះអង្គត្រូវតែពឹងផ្អែកលើកម្លាំងមហាជន ហើយថា អ្នកដែលនិយាយពីសន្តិភាពជាមួយពួកអាមេរិក និងខ្លាចអាមេរិក នៅពេលនេះ នឹងទទួលរងនូវការឈឺចាប់នៅពេលអនាគតជាមិនខាន។

ម៉ៅ សេទុង បានបន្តថា យើងបានបង្កើតទំនាក់ទំនងការទូតមួយផ្នែកជាមួយចក្រភពអង់គ្លេស។ ដំបូង អង់គ្លេស ស្នើឱ្យដំឡើងទំនាក់ទំនងពីកម្រិតភារៈធារី ទៅដល់កម្រិតឯកអគ្គរដ្ឋទូត។ តែយើងមិនយល់ព្រមទេ ព្រោះមានមូលហេតុពីរយ៉ាង គឺ៖ ទី១ អង់គ្លេសនិយាយថា បញ្ហាចិនតៃវ៉ាន់ មិនទាន់ត្រូវបានកំណត់ឋានៈច្បាស់លាស់។ ទី២ ពួកគេធ្វើនយោបាយចិនពីរ នៅឯអង្គការសហប្រជាជាតិ។ អាមេរិក ធ្វើរឿងភ្លីភ្លើគ្រប់បែបយ៉ាង។

បញ្ហាបណ្ដេញតំណាងរបស់ចិនតៃវ៉ាន់ ជៀង កៃជៀក ចេញពីអសនៈអង្គការសហប្រជាជាតិ មើលទៅប្រហែលជាត្រូវស៊ីពេលពី៩ ទៅ១០ឆ្នាំ ទម្រាំអាមេរិក ត្រូវគេបង្ខំឲ្យបណ្ដេញតំណាងរបស់ចិនតៃវ៉ាន់ ចេញពីអង្គការសហប្រជាជាតិ។ ពេលនេះ មើលទៅ រឿងនេះប្រហែលជាមិនអាចទៅរួចទេ។

តែសម្ដេចមានបន្ទូលថា៖ ពួកតំណាងតៃវ៉ាន់ គួរតែត្រូវបានបណ្ដេញចេញភ្លាមៗ។

ម៉ៅ សេទុង បានតបវិញថា តាមពិតយើងត្រូវប្រើរយៈពេលទាមទារបញ្ហានេះច្រើនឆ្នាំទៅមុខទៀត។ យើងធ្លាប់ជាប់ជំពាក់ក្នុងសង្គ្រាមអស់រយៈពេល២៥ឆ្នាំរួចមកហើយ។ អំឡុងពេលធ្វើសង្គ្រាមនោះ យើងប្រយុទ្ធជាមួយពួកជាតិនិយម ជៀង កៃជៀក អស់រយៈពេល១៤ឆ្នាំ យើងប្រយុទ្ធជាមួយពួកជប៉ុន អស់រយៈពេល៨ឆ្នាំ និងប្រយុទ្ធជាមួយអាមេរិក នៅកូរ៉េខាងជើង អស់រយៈពេល៣ឆ្នាំ។



**សេនាប្រមុខ ប៉េង តឺហួយ និងម៉ៅ សេទុង**

ការប្រយុទ្ធជាមួយអាមេរិក នៅកូរ៉េខាងជើង អស់រយៈពេល៣ឆ្នាំនោះ មុនដំបូង ក្នុងចំណោមកងទ័ព និងកម្មាភិបាលរបស់យើង មានតែ២០ភាគរយប៉ុណ្ណោះ ដែលមានជំនឿជឿជាក់ថា យើងនឹងអាចយកឈ្នះលើពួកអាមេរិក។ តែកងទ័ព និងកម្មាភិបាលរបស់យើង ២០ភាគរយទៀត មិនព្រមឆ្លងទន្លេយ៉ាលូ ទៅធ្វើសង្គ្រាមជាមួយអាមេរិក នៅកូរ៉េខាងជើងទេ។ ពួកគេនិយាយថា មិនគួរទៅវាយប្រហារទៅលើទាហានអាមេរិកទេ។ ចំណែកកងទ័ព និងកម្មាភិបាលរបស់យើង៦០ភាគរយទៀតសុទ្ធតែជាអ្នកមានជំហរស្ទាក់ស្ទើរក្នុងចិត្ត មិនខ្វល់ពីរឿងប្រយុទ្ធ ឬមិនប្រយុទ្ធជាមួយពួកអាមេរិក នោះឡើយ។ តែទីបំផុត កងទ័ព និងកម្មាភិបាលរបស់យើងទាំងអស់គ្នាសម្រេចចិត្តថា ត្រូវតែទៅធ្វើសង្គ្រាមជាមួយអាមេរិក នៅកូរ៉េខាងជើង...។

សម្តេចសីហនុ មានបន្ទូលកាត់ ម៉ៅ សេទុង ថា ពេលនោះ កងទ័ពរបស់លោកប្រធានធ្វើការប្រយុទ្ធបានល្អ១០០ភាគរយ។

ម៉ៅ សេទុង បានបញ្ជាក់ថា មិនជាអន់ប៉ុន្មានដែរ។ តែយើងក៏នៅមានកំហុសមួយចំនួនដែរ ដោយសារតែមេបញ្ជាការយើងនៅសមរភូមិកូរ៉េខាងជើងនោះ មានការអន់ថយខាងផ្នែកនយោបាយខ្លាំងពេក។ មេបញ្ជាការនោះ គឺសមមិត្ត ប៉េង តឺហួយ ( Peng Dehuai ) ។

តែហេតុអ្វី បានជាយើងបញ្ជូនគាត់ឱ្យទៅបញ្ជាកងទ័ពនៅសមរភូមិកូរ៉េខាងជើងនោះ? ម៉េចក៏មិនបញ្ជូនមេបញ្ជាការផ្សេងទៀត? នេះមកពីគាត់មានសុខភាពល្អ ហើយពេលនោះគាត់មានឋានន្តរស័ក្តិជាសេនាប្រមុខទៀតផង។ ចំណែក សេនាប្រមុខម្នាក់ទៀតមានជំងឺមិនអាចទៅបាន។ និយាយរួម កងទ័ពយើងប្រយុទ្ធបានល្អគួរសមដែរ។ តែប្រសិនបើសមមិត្តប៉េង តឺហួយ(Peng Dehuai) មេបញ្ជាការយើងនៅសមរភូមិកូរ៉េខាងជើងនោះ មានការឈ្លាសវៃបន្តិច ការប្រយុទ្ធរបស់យើងកាន់តែល្អជាងនេះទៅទៀត។

ម៉ៅ សេទុង បានទូលសម្តេចសីហនុ ថា ដើម្បីធ្វើសង្គ្រាម ការត្រៀមលក្ខណៈសម្បត្តិមានសារៈសំខាន់ណាស់។ នៅពេលណា ដែលសម្តេចត្រៀមលក្ខណៈសម្បត្តិជាមុនហើយនោះ សត្រូវមិនសូវហ៊ានជាមួយយើងទេ ហើយបើទោះជាសត្រូវហ៊ានចូលមកវាយយើង ក៏យើងមិនពិបាកក្នុងការទប់ទល់ជាមួយពួកវាដែរ។

ម៉ៅ សេទុង បានទូលរម្លឹកសម្តេចសីហនុ ថា ទូលបង្គំចាប់ផ្តើមសិក្សាលទ្ធិម៉ាក្សស៊ីសនៅពេលដែលទូលបង្គំមានអាយុ២៨ឆ្នាំ ហើយពីមុនមក ទូលបង្គំមិនដែលបានរៀនអ្វី ក្រៅតែពីលទ្ធិសក្តិភូមិ និងមូលធនទេ។ មានម្តងនោះ ទូលបង្គំជឿលើទស្សនវិជ្ជារបស់លោក កង់(Kant)។ ទូលបង្គំមិនបានចាប់ផ្តើមសិក្សាលទ្ធិម៉ាក្សស៊ីស និងទ្រឹស្តីសម្ភារៈនិយមបដិច្ចសមុប្បាទទេ។ តែបដិវត្តន៍រុស្ស៊ី ឆ្នាំ១៩១៧ បានបង្រៀនឲ្យទូលបង្គំស្គាល់លទ្ធិម៉ាក្សស៊ីស និងទ្រឹស្តីសម្ភារៈនិយមបដិច្ចសមុប្បាទនេះ។

មុនបដិវត្តន៍រុស្ស៊ី ឆ្នាំ១៩១៧ ខ្ញុំមិនដែលទាំងដឹងថា តើកាល់ម៉ាក្ស(Karl Marx) និងអង់ហ្គែល(Engels) ជានរណាផង?។ ទូលបង្គំគ្រាន់តែធ្លាប់ស្គាល់ឈ្មោះរបស់ណាប៉ូឡេអុង (Napoleon), ហ្សក វ៉ាស៊ីនតោន (George Washington), ហ្សង់ សាក់រូស្សូ (Jean-Jacques Rousseau) និងចន ស៊ុអាត មីល (John Suart Mill) ជាដើម បូកផ្សំជាមួយទ្រឹស្តីលទ្ធិសក្តិភូមិរបស់ចិន ដូចជា ខុងជឺ(Confucius) ម៉េងជឺ(Mencius) ព្រមទាំងទ្រឹស្តីខ្លះៗ ក្នុងលទ្ធិមូលធននិយមផងដែរ។

ម៉ៅ សេទុង បានទូលរម្លឹកសម្តេចសីហនុ បន្តថា ការជួបគ្នាចុងក្រោយកន្លងទៅនេះ

# របត់នយោបាយ

ទូលបង្គំបានស្នើឲ្យព្រះអង្គអានសៀវភៅ ដែលជាផ្នែកមួយនៃស្នាដៃនិពន្ធ របស់ អង់ហ្គែល(Engels) មានចំណងជើង ថា លទ្ធិសង្គមនិយម ៖ ពីសង្គមល្អឥត ខ្ចោះទៅកាន់សង្គមបែបវិទ្យាសាស្ត្រ។

សីហនុ មានបន្ទូលតបវិញថា៖ ខ្ញុំបានអានសៀវភៅនោះរួចហើយ។ ម៉ៅ សេទុង ទូលបន្តទៀតថា ប្រសិនបើ សម្ដេចសព្វព្រះទ័យ សូមសម្ដេចអាន សៀវភៅមួយទៀត មានចំណងជើង ថា៖ សេចក្ដីថ្លែងការណ៍របស់លទ្ធិកុម្មុយ និស្ត ជាសៀវភៅទី១ របស់លទ្ធិម៉ាក្ស ស៊ីស...។




**សៀវភៅទ្រឹស្តីកុម្មុយនិស្តរបស់ កាល់ម៉ាក្ស** (Karl Marx) **និងអង់ហ្គែល** (Engels)

សម្ដេចសីហនុ បញ្ជាក់តបវិញ ថា៖ ខ្ញុំស្គាល់សៀវភៅនោះដែរ។

ម៉ៅ សេទុង បន្តថា សម្ដេចស្គាល់សៀវភៅនោះដែរ? ដូច្នេះសម្ដេច ត្រូវប្រកាន់ចិត្ត ឈរនៅខាងភាគច្រើន។ តែដំបូង ការប្រកាន់ចិត្តបែបនេះ អាចនឹងមានការលំបាកខ្លះៗ។ ដំបូង ទូលបង្គំខ្លួនឯង ក៏ធ្លាប់ជួបប្រទះការលំបាកដែរ។ តែទូលបង្គំបានប្ដូរជំហរ ងាកទៅ រកការរៀនសូត្រ ពីរបៀបធ្វើសង្គ្រាមវិញ។ ទូលបង្គំធ្លាប់ធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សា តែទូលបង្គំមិនដែល ឬក៏បង្រៀនអំពីអ្វីដែលហៅថា របៀបធ្វើសង្គ្រាមនោះទេ?។ គ្រូរបស់ ទូលបង្គំ គឺ ជៀង កៃជៀក ពីព្រោះគាត់បានសម្លាប់មនុស្សជាច្រើន។ នៅពេល គាត់សម្លាប់ មនុស្ស ទូលបង្គំចាប់ផ្ដើមរៀនពីគាត់ ហើយទូលបង្គំរៀនសូត្រអស់រយៈពេល១០ ឆ្នាំ គឺរៀន សឹងតែគ្រប់មុខទាំងអស់។



**ជៀង កៃជៀក និងម៉ៅ សេទុង**

បន្ទាប់មក ពួកជប៉ុន បានចូលឈ្លានពានប្រទេសចិន ទូលបង្គំជាពួកកុម្មុយនិស្ត បានសហការជាមួយ ជៀង កៃជៀក និងគណបក្សគួមីងតាំង កាលនោះឆ្នាំ១៩៣៧...។

ម៉ៅ សេទុង ងាកទៅសួរ វ៉ាង ក្វាងមុី (Wang Guangmei) ជាប្រពន្ធរបស់ប្រធានាធិបតី លីវ ចៅជី (Liu Shaoqi) ដែលមានវត្តមាននៅក្នុងកិច្ចពិភាក្សាគ្នានោះដែរថា តើពេលនោះ សមមិត្តនារីកើតហើយឬនៅ? វ៉ាង ក្វាងមុី ឆ្លើយថា៖ ចាស! ពេលនោះ ខ្ញុំកើតហើយ(វ៉ាង ក្វាងមុី កើតថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩២១ នៅក្រុងប៉េកាំង)។

ម៉ៅ សេទុង បន្តថា យើងវាយពួកជប៉ុន អស់រយៈពេល៨ឆ្នាំ។ ក្រោយពីពួកជប៉ុនចាកចេញទៅ ពួកជៀង កៃជៀក វាយយើងវិញម្តង។ ក្រោយពីពួកជៀង កៃជៀក ត្រូវទទួលបរាជ័យ អាមេរិក បានដើរតួជាសត្រូវរបស់យើងតែម្តង។ នៅពេលទាហានរបស់អាមេរិកចូលមកជិតដល់ទន្លេយ៉ាលូ នៅត្រង់ព្រំប្រទល់របស់យើងជាមួយកូរ៉េខាងជើង យើងបានបញ្ជូនទ័ពរបស់យើងទៅប្រយុទ្ធជាមួយពួកគេអស់រយៈពេល៣ឆ្នាំ ទម្រាំតែមានបទឈប់បាញ់គ្នាមួយ។

ឥឡូវនេះ សហរដ្ឋអាមេរិក ជាសត្រូវរបស់យើង។ តែយើងកំពុងធ្វើការចរចា។ យើង

បានធ្វើការចរចានៅក្រុងវ៉ាសូវី អស់រយៈពេល៩ឆ្នាំហើយ។ កាលពីមុន យើងជួបគ្នាជាមួយ អាមេរិក មួយសប្តាហ៍ម្តង ពីរសប្តាហ៍ម្តង ឬក៏មួយខែម្តង។ តែឥឡូវ យើងជួបចរចាគ្នាពីរឬបី ខែម្តង។ តែយើងគ្មានជជែកគ្នាអ្វី ក្រៅតែពីសេចក្តីថ្លែងការណ៍ទ្បើងវិញដដែលៗដូចពីមុន នោះទេ។ សេចក្តីថ្លែងការណ៍ទី១របស់យើង គឺទាមទារឱ្យអាមេរិក ដកនាវាទី៧ និងទាហាន របស់គេចេញពីកោះតៃវ៉ាន់ ព្រោះជម្លោះរបស់យើងជាមួយ ជៀង កៃជៀក ជារឿងផ្ទៃក្នុងរបស់ ចិន មិនគួរសហរដ្ឋអាមេរិក ចូលមកជ្រៀតជ្រែកទេ។ តែអាមេរិក មិនធ្វើតាមការទាមទាររបស់ យើងឡើយ។

អាមេរិក ទាមទារឲ្យយើងដោះលែងអ្នកទោសរបស់គេជាច្រើន ដែលយើងបានចាប់ ឃុំនៅក្នុងពន្ធនាគាររបស់យើង ហើយអាមេរិក ចង់បញ្ជូនអ្នកកាសែតឱ្យមកយកព័ត៌មាន ជាប្រចាំនៅប្រទេសចិន ទៀតផង។ តែយើងជំទាស់ សូម្បីអ្នកកាសែតអាមេរិកតែម្នាក់ ក៏ យើងមិនអនុញ្ញាតឲ្យចូលមកក្នុងប្រទេសយើងដែរ។

ជំហានដំបូង អាមេរិក គួរតែដកកងទ័ពរបស់ខ្លួនចេញពីកោះតៃវ៉ាន់។ ឥឡូវនេះ យើងប្រកាសថា ដែនសមុទ្ររបស់យើងគ្របដណ្តប់ចម្ងាយ១២ម៉ៃ ពីដែនគោក។ តែ អាមេរិក បដិសេធ មិនទទួលស្គាល់ ហើយថែមទាំងធ្វើការលុកលុយដោយចេតនាមកលើយើងទៀត ផង។ យើងបានដាក់ចេញសេចក្តីថ្លែងការណ៍ព្រមានជាច្រើនមកហើយ តែមិនអាចបញ្ឈប់ ពួកគេបានឡើយ។យើងបានចេញសេចក្តីថ្លែងការណ៍ព្រមានរហូតទៅដល់ជាង៣០០លើក ហើយយើងត្រៀមធ្វើ ការព្រមានចំនួន៣០០០លើកទៀត។

អ្វីដែលជាលទ្ធផលសំខាន់បំផុត ក្នុងការយាងទៅចូលរួមក្នុងពិធីរម្លឹកខួបលើកទី១៥ ថ្ងៃបង្កើតសាធារណរដ្ឋប្រជាមានិតចិន (ថ្ងៃទី១ ខែតុលា ១៩៤៩ - ថ្ងៃទី១ ខែតុលា ១៩៦៤) នៅទីក្រុងប៉េកាំង នោះ សម្តេចសីហនុ និងមេដឹកនាំចិន បានចេញសេចក្តីថ្លែងការណ៍រួមមួយ ដោយភាគីចិន ប្រកាសផ្តល់ជំនួយយោធាឱ្យកម្ពុជាបន្ថែមទៀត និងប្រកាសជួយការពារកម្ពុជា នៅពេលណាមានការឈ្លានពានពីពួកបរទេស ផងដែរ។

# ១៧២
# សម្តេចសីហនុ ចរចាបញ្ហាព្រំដែន ជាមួយវៀតណាមខាងជើង




**ផាម វ៉ាន់ដុង និងសម្តេចសីហនុ**

មួយថ្ងៃ ក្រោយពីជួបពិភាក្សាការងារជាមួយ ម៉ៅ សេទុង នោះមក នៅថ្ងៃទី២៩ ខែកញ្ញា នៅទីក្រុងប៉េកាំង នោះដែរ សម្តេចសីហនុ ក៏បានជួបពិភាក្សាគ្នាជាមួយនាយករដ្ឋមន្ត្រីវៀតណាមខាងជើង ផាម វ៉ាន់ដុង ដែលបានទៅចូលរួមក្នុងពិធីរម្លឹកខួបលើកទី១៥ ថ្ងៃបង្កើតសាធារណរដ្ឋប្រជាមានិតចិន (១ តុលា ១៩៤៩ - ១ តុលា ១៩៦៤) នៅទីក្រុងប៉េកាំង នោះដែរ។ ពេលនោះ សម្តេចសីហនុ មានបំណងចង់ជួបពិភាក្សាជាមួយ ផាម វ៉ាន់ដុង ដើម្បីឱ្យមានកិច្ចព្រមព្រៀងមួយស្តីពីបញ្ហាព្រំដែនគោក និងព្រំដែនសមុទ្រកម្ពុជា និងវៀតណាម។

ផាម វ៉ាន់ដុង បានសម្តែងទឹកចិត្តសប្បាយរីករាយដ៏ជ្រាលជ្រៅបំផុតពីចំណងមិត្តភាព

របស់ប្រទេសគាត់ ជាមួយប្រទេសកម្ពុជា និងបានសន្យាជាមួយសម្តេចសីហនុ ថា សូមព្រះអង្គទុកព្រះទ័យលើទូលបង្គំចុះ យើងខ្ញុំនឹងមិនធ្វើដូចបុព្វបុរសរបស់យើងខ្ញុំទៀតឡើយ ហើយប្រជាជនវៀតណាមបច្ចុប្បន្ន មិនដូចប្រជាជនវៀតណាម ពីអតីតកាលទេ។

ចំណែកបញ្ហាដែលសម្តេចសីហនុ មានបំណងចង់ធ្វើការចរចា ដើម្បីឱ្យមានកិច្ចព្រមព្រៀងជាមួយសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ស្តីពីបញ្ហាព្រំដែនគោក និងព្រំដែនសមុទ្រនោះ ផាម វ៉ាន់ដុង បានឆ្លើយតបទៅព្រះអង្គវិញថា ការចរចានេះ មិនត្រូវធ្វើជាមួយគាត់ជានាយករដ្ឋមន្ត្រីវៀតណាមខាងជើងទេ គឺត្រូវធ្វើជាមួយរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ( ពួកវៀតកុង ) វិញ ព្រោះប្រទេសកម្ពុជា មិនមានព្រំប្រទល់ជាប់ជាមួយសាធារណ-រដ្ឋប្រជាធិបតេយ្យវៀតណាមខាងជើងឡើយ ហើយគាត់នឹងត្រៀមខ្លួនជួយជំរុញឱ្យមានកិច្ចព្រមព្រៀងនេះ។

មូលហេតុដែល ផាម វ៉ាន់ដុង ទូលសម្តេចសីហនុ ឱ្យទៅចរចាពីបញ្ហាព្រំដែនគោក និងព្រំដែនសមុទ្រ ជាមួយរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង( ពួកវៀតកុង )នោះ បើមើលតែរូបភាពភូមិសាស្ត្រខាងក្រៅ ប្រទេសកម្ពុជា មិនមានព្រំប្រទល់ជាប់ជាមួយសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមខាងជើងនោះ ជាការត្រឹមត្រូវម្យ៉ាងដែរ ។ ប៉ុន្តែ សម្តេចសីហនុ ក៏ឈ្វេងយល់ច្បាស់ដែរថា រណសិរ្សរំដោះជាតិវៀតណាមខាងត្បូង( ពួកវៀតកុង )នោះ គឺមេដឹកនាំ វៀតណាមខាងជើងជាអ្នកបង្កើតឡើង និងជាអ្នកដឹកនាំនៅពីក្រោយខ្នង ហើយមេដឹកនាំវៀតណាមខាងជើង បង្កើតរណសិរ្សនេះឡើង គឺគ្រាន់តែដើម្បីបំភាន់សាធារណមតិអន្តរជាតិ ឱ្យមើលឃើញថា ប្រជាជនវៀតណាមខាងត្បូង ជាអ្នកក្រោកឡើងធ្វើបដិវត្តន៍ដោយខ្លួនឯង ដើម្បីផ្តួលរម្លំរបបសាធារណរដ្ឋវៀតណាម ដែលជាសម្ព័ន្ធមិត្តរបស់អាមេរិកតែប៉ុណ្ណោះ។

បន្ទាប់មក នៅទីក្រុងប៉េកាំងនោះដែរ ភាគីរបស់កម្ពុជា ដែលមាន ទ្រឿង កាង ឯកអគ្គ-រាជទូតកម្ពុជាប្រចាំប្រទេសចិន និងសារិន ឆាក ទីប្រឹក្សាអមស្ថានទូតកម្ពុជា នៅប្រទេសបារាំង ក៏បានចាប់ផ្តើមជួបចរចាគ្នាស្តីពីបញ្ហាព្រំដែនគោក និងព្រំដែនសមុទ្រនោះ ជាមួយ

ភាគីរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង(ពួកវៀតកុង) ដែលមាន ង្វៀន វ៉ាន់ហ៊ីវ ជាតំណាងរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ប្រចាំប្រទេសឆេកូស្លូវ៉ាគី និងត្រាញ់ វ៉ាន់ថាញ់ តំណាងរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ប្រចាំប្រទេសចិន។

ង្វៀន វ៉ាន់ហ៊ីវ និងត្រាញ់ វ៉ាន់ថាញ់ ជាតំណាងភាគីវៀតណាមទាំង២នាក់នេះ សុទ្ធតែមានតំណែងជាសមាជិករបស់គណៈកម្មាធិការមជ្ឈិមបក្សពលកវៀតណាម។

ភាគីទាំង២ បានជួបពិភាក្សាគ្នាចំនួន៣លើក ដើម្បីសិក្សាពីខ្លឹមសារលម្អិតនៃកិច្ចព្រមព្រៀងនោះ។ ប៉ុន្តែដោយមានការខ្វែងគំនិតគ្នាលើចំណុចជាច្រើននោះ ភាគីទាំងពីរក៏សម្រេចលើកការចរចានោះទៅថ្ងៃក្រោយវិញ។

សារិន ឆាក ទីប្រឹក្សាអមស្ថានទូតកម្ពុជា នៅប្រទេសបារាំង បានបញ្ជាក់ថា ការទទួលស្គាល់ខ្សែបន្ទាត់ព្រំដែន នៅលើផែនទីណាផ្សេងដែលខុសពីខ្សែបន្ទាត់ព្រំដែន ដែលបារាំងបានកំណត់នោះ នឹងធ្វើឱ្យប្រទេសជាតិយើងត្រូវខាតបង់។

ឯកអគ្គរាជទូត ទ្រឿង កាង វិញ ក៏បានលើកឡើងថា យើងបានស្នើឱ្យចុះហត្ថលេខាលើឯកសាររួមមួយ ដើម្បីឱ្យរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (ពួកវៀតកុង) ទទួលស្គាល់សិទ្ធិផ្សេងៗរបស់សហគមន៍ខ្មែរកម្ពុជាក្រោម ដែលកំពុងរស់នៅវៀតណាមខាងត្បូង។

ចំណែកភាគីវៀតណាម ង្វៀន វ៉ាន់ហ៊ីវ មិនព្រមទទួលស្គាល់ខ្សែបន្ទាត់ព្រំដែនដែលបានកំណត់នោះទេ។ ប៉ុន្តែភាគីកម្ពុជា នៅតែទាមទារថា ការចរចាបញ្ហាព្រំដែននេះ ត្រូវតែផ្អែកតាមឯកសារដែលបារាំងទទួលស្គាល់តាំងពីដើមមកនោះ ធ្វើជាមូលដ្ឋាននៃការចរចា។

នៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៦៤ យន្តហោះចម្បាំងរបស់អាមេរិក បានហោះមកទម្លាក់គ្រាប់បែកលើភូមិអន្លង់ជ្រៃ ក្នុងឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ បណ្តាលឱ្យអ្នកភូមិខ្មែរនៅទីនោះចំនួន៨នាក់ ត្រូវបាត់បង់ជីវិត និងរងរបួសមួយចំនួនទៀត។

៤ថ្ងៃក្រោយមកទៀត ឧទ្ធម្ភាគចក្ររបស់អាមេរិក ជាច្រើនគ្រឿងទៀតក៏បានហោះមកបាញ់រះមកលើប៉ុស្តិ៍ដាក់ដាំ ខេត្តមណ្ឌលគិរី ដែលជាទីតាំងឈរជើងរបស់កងទ័ពកម្ពុជា ដោយពួកគេយកលេសថា ដេញតាមវាយកម្ទាត់កងទ័ពវៀតកុង។



**ពហុកីឡដ្ឋានជាតិអូឡាំពិក ពេលកំពុងសាងសង់**

ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៦៤ សាកលវិទ្យាល័យ ចំនួន៤ ត្រូវបានបង្កើតឡើង គឺសាកលវិទ្យាល័យភូមិន្ទបច្ចេកទេស, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, សាកលវិទ្យាល័យភូមិន្ទកំពង់ចាម និងសាកលវិទ្យាល័យភូមិន្ទតាកែវ-កំពត (ស្ថិតនៅផ្លូវជាតិលេខ៣ ត្រង់ព្រំប្រទល់ខេត្តតាកែវ-កំពត ម្តុំភ្នំនរាយណ៍)។

ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៦៤ សម្តេចសីហនុ បានយាងជាអធិបតីក្នុងពិធីសម្ពោធពហុកីឡដ្ឋានជាតិអូឡាំពិក ដំណាលគ្នានឹងបុរីកីឡាដែរ។ ការកសាងពហុកីឡដ្ឋានជាតិអូឡាំពិក និងបុរីកីឡានេះ ត្រូវចំណាយថវិកាប្រមាណ៧០លានរៀល ក្នុងនោះក៏មានជំនួយពីប្រទេសចិន មួយចំនួនដែរ។

ពហុកីឡដ្ឋានជាតិអូឡាំពិក គឺជាពហុកីឡដ្ឋានរដ្ឋ គូរប្លង់ដោយវណ្ណ មូលីវណ្ណ ជាស្ថាបត្យករខ្មែរដ៏ល្បីមួយរូប និងមានទីតាំងនៅចំកណ្តាលទីក្រុងភ្នំពេញ។

ក្រោយបញ្ចប់ការប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games) លើកទី២ ដែលប្រព្រឹត្តទៅនៅទីក្រុងរ៉ង់ហ្គូន ប្រទេសភូមា កាលពីអំឡុងខែធ្នូ ឆ្នាំ១៩៦១ ពហុកីឡដ្ឋានជាតិអូឡាំពិកបានចាប់ផ្ដើមសាងសង់ភ្លាមៗនៅឆ្នាំក្នុង១៩៦២ ព្រោះព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើជាម្ចាស់ផ្ទះនៅក្នុងការប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games) លើកទី៣ ក្នុងឆ្នាំ១៩៦៣ ។

ប៉ុន្តែ ដោយសារកម្ពុជា មិនអាចសាងសង់ពហុកីឡដ្ឋានជាតិអូឡាំពិកនេះ ឱ្យបានរួចរាល់ជាស្ថាពរទាន់ពេលវេលាកំណត់ ការប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games) លើកទី៣ ត្រូវលើកទៅធ្វើនៅឆ្នាំ១៩៦៥ នៅក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី វិញ។

ក្រោយពីពិធីសម្ពោធ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៦៤ មក ពហុកីឡដ្ឋាននេះបានរៀបចំប្រារព្ធពិធីប្រកួតកីឡាហ្គានេហ្វូ(Ganefo) អាស៊ីលើកទី១ ចាប់ពីថ្ងៃទី២៥ វិច្ឆិកា ដល់ថ្ងៃទី៦ធ្នូ ឆ្នាំ១៩៦៦ ដោយមានកីឡាករ កីឡាការិនី មកពី១៧ប្រទេសចូលរួម និងធ្លាប់ជាទឹកដីកណ្ដាលនៃការប្រកួតបាល់ទាត់ពិភពលោក (World Cup) ឆ្នាំ១៩៦៦ រវាងប្រទេសកូរ៉េខាងជើង និងអូស្ត្រាលី ទៀតផង។

យោងតាមឯកសារ ទស្សនាវដ្ដីកាំបូហ្សា(Cambodja ) គម្រោងសាងសង់ពហុកីឡដ្ឋានជាតិអូឡាំពិក នៅពេលនោះ គឺត្រូវចំណាយថវិការដ្ឋ ជាទឹកប្រាក់ចំនួន៣៥០លានរៀល។ ប៉ុន្តែពេលចាប់ផ្ដើមធ្វើការសាងសង់ អស់រយៈពេល១ឆ្នាំមក ក៏ខ្វះថវិកាជាច្រើនទៀត។

ដូច្នេះ នាពេលនោះសម្ដេចសីហនុ ជាព្រះប្រមុខរដ្ឋ បានផ្ដើមគំនិតបង្កើតមូលនិធិមួយដើម្បីជួយក្នុងការសាងសង់បន្តទៀត ដោយស្នើឱ្យមន្ត្រីរាជការ ឬប្រជាពលរដ្ឋខ្មែរដែលស្ម័គ្រចិត្តជួយជាថវិកាចំនួន ២៨០រៀលឡើងទៅ ព្រះអង្គនឹងប្រទានមេដាយមួយហៅថា មេដាយទ្រទ្រង់ការកសាងពហុកីឡដ្ឋានជាតិ។ ទម្រាំសាងសង់ពហុកីឡដ្ឋានជាតិរួចរាល់ ត្រូវចំណាយថវិកាអស់ចំនួន៧៧៨លានរៀល ស្មើនឹង៤០លានហ្វ្រង់(ប្រាក់បារាំង) ។

ពហុកីឡដ្ឋានជាតិនេះ មានរចនាសម្ព័ន្ធដូចជា សាលវិមានកីឡា មានកន្លែងសម្រាប់ទស្សនាកីឡាបាល់ទះ, កីឡាបាល់បោះ, កីឡាប្រដាល់ និងប្រភេទកីឡាមួយចំនួនទៀត មានកន្លែងអង្គុយទស្សនាសម្រាប់ទស្សនិកជនចំនួន៨០០០នាក់។ ទីលានបាល់ទាត់ជាខ្នាត



**ពហុកីឡដ្ឋានជាតិអូឡាំពិក ពេលសាងសង់រួច ឆ្នាំ១៩៦៤**

អន្តរជាតិ មានផ្លូវសម្រាប់រត់អត្តពលកម្ម និងប្រភេទកីឡាផ្សេងៗជាច្រើនទៀត អាចដាក់ទស្សនិកជនចំនួន ៦០០០០នាក់។ ចំណែកផ្នែកខាងកើតមានអាងហែលទឹក និងលោតទឹក ព្រមទាំងទីធ្លាវាយកូនបាល់ ជាដើម។

នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៦៤ រាជរដ្ឋាភិបាលដែលមានព្រះអង្គម្ចាស់ នរោត្តម កន្តុល ជានាយករដ្ឋមន្ត្រី ក៏បានធ្វើការផ្លាស់ប្តូរសមាសភាពមួយចំនួន និងរក្សាទុកសមាសភាពដដែលមួយចំនួនទៀត ក្នុងនោះ លន់ នល់ ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ, គូ រុន ជាទេសរដ្ឋមន្ត្រីទទួលបន្ទុកសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស, ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ជាទេសរដ្ឋមន្ត្រី ទទួលបន្ទុកអប់រំជាតិ, ម៉ៅ សាយ ជារដ្ឋមន្ត្រីផែនការ, អ៊ឹង ក្រពុំផ្កា ជារដ្ឋមន្ត្រីឧស្សាហកម្ម និងទូរគមនាគមន៍ , ប៉ុន វង្សវដ្តី ជារដ្ឋមន្ត្រីយុត្តិធម៌, គួន វិច ជារដ្ឋមន្ត្រីការបរទេស, អ៊ិន តាំ ជារដ្ឋមន្ត្រីមហាផ្ទៃ, អ៊ឹង គៀត ជារដ្ឋលេខាធិការក្រសួងសាធារណការ, សូ ណៃម ជារដ្ឋលេខាធិការពាណិជ្ជកម្ម , ចៅ សៅ ជារដ្ឋលេខាធិការហិរញ្ញវត្ថុ, ជា សាន ជារដ្ឋលេខាធិការព័ត៌មាន, ជួន សៅឌី ជារដ្ឋលេខាធិការកសិកម្ម, ទិប ម៉ម (ស្រី) ជារដ្ឋលេខាធិការការងារ និងសង្គមកិច្ច , ម៉ែន ឈុំ ជាអនុរដ្ឋលេខាធិការធម្មការ, អាំង គឹម ឃន ជាអនុរដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកទេសចរណ៍ និងសំរិទ្ធ សុទ្ធ ជាអនុរដ្ឋលេខាធិការអប់រំជាតិ។



**ទ្រង់នរោត្តម កន្ថុល យាងទៅប្រទេសសិង្ហបុរី ដើមខែតុលា ឆ្នាំ១៩៦៤**

ចំណែកចៅ សេង ដែលពីមុនជារដ្ឋលេខាធិការកសិកម្ម , ហ៊ូ យន់ ជារដ្ឋលេខាធិការផែនការ និងខៀវ សំផន ជារដ្ឋលេខាធិការពាណិជ្ជកម្ម និងជាពួកឆ្វេងនិយម មិនមានឈ្មោះនៅក្នុងសមាសភាពរាជរដ្ឋាភិបាលថ្មីនេះទេ។

ដោយមានការព្រមព្រៀង រវាងភាគីកម្ពុជា និងចិន គណៈកម្មការមួយ រួមមាន ហ៊ិន ឌី ជាប្រធាន, មាស សាអែម , ភី ធៀនឡាយ, អ៊ាប គឹមជន និងហ៊ូ យន់ ជាដើម ជាសមាជិក ត្រូវបានបង្កើតឡើង ដើម្បីរៀបចំសមាសភាពដឹកនាំសមាគមមិត្តភាពកម្ពុជា-ចិន។

គណៈកម្មការនេះ បានសម្រេចជ្រើសរើស ឡុង ង៉េត អតីតនាយករដ្ឋមន្ត្រីតាំងពីឆ្នាំ១៩៥៥ ជាប្រធានសមាគម, ហ៊ិន ឌី ជាអនុប្រធានទី១, សូ ណៃម អនុប្រធានទី២, ហ៊ូ នឹម ជាអគ្គលេខាធិការ, វ៉ាន់ ទិព្វសុវណ្ណ ជាហិរញ្ញឹក, ភី ធៀនឡាយ, ស្វាយ បុរី, អ៊ាប គឹមជន និងហ៊ូ យន់ ជាទីប្រឹក្សា។

# ១៧៣
# សម្ដេចសីហនុ ធ្វើជាគូបនីយកម្ម ដើម្បីកែទម្រង់សេដ្ឋកិច្ច



**សម្ដេចសីហនុ ជាមួយគិលានុបដ្ឋាយិកា**

ពីឆ្នាំ១៩៥៧ ដល់ឆ្នាំ១៩៥៩ សម្ដេចសីហនុ ក្នុងព្រះនាមជាប្រធានចលនាសង្គមរាស្ត្រនិយម ព្រះអង្គបានដាក់ចេញនូវផែនការ២ឆ្នាំនៃចលនាសង្គមរាស្ត្រនិយម ជាលើកដំបូង ដើម្បីស្ថាបនា និងជួសជុលផ្លូវថ្នល់ស្ពានទាំងឡាយ ដែលត្រូវខូចខាតក្នុងពេលប្រទេសជាតិមានអសន្តិសុខពីសម័យអាណានិគមនោះ ឡើងវិញ។

ដោយសារការអនុវត្តផែនការ២ឆ្នាំនេះ ទទួលបានជោគជ័យគួរជាទីពេញចិត្ត ព្រះអង្គបានដាក់ចេញផែនការមួយទៀត ហៅថា ផែនការ៥ឆ្នាំនៃចលនាសង្គមរាស្ត្រនិយម មានគោលដៅពង្រីកផលិតកម្មខាងកសិកម្ម និងខាងឧស្សាហកម្ម ដោយត្រូវចាប់ផ្ដើមអនុវត្តផែនការពីឆ្នាំ១៩៦០ ដល់១៩៦៥។

ដើម្បីអនុវត្តឲ្យបានជោគជ័យនូវផែនការ៥ឆ្នាំនេះឱ្យបានជោគជ័យ សម្ដេចសីហនុ

ជាព្រះប្រមុខរដ្ឋបានបញ្ចូលនយោបាយទឹក(ជារាសាស្ត្រ) និងការហត្ថកម្មទៅក្នុងផែនការនេះផងដែរ។ ជាមួយគ្នានេះ ព្រះអង្គបានបង្កើត «មន្ទីររាជសហករណ៍» ដើម្បីជួយដល់រាស្ត្រក្រីក្រតូចតាច ឲ្យគេចផុតពីកេងប្រវ័ញ្ចពីពួកឈ្មួញកណ្តាល និងជួយផ្តល់ឥណទានដល់សមាជិកនៃសហករណ៍ ដើម្បីយកឥណទាននោះទៅប្រើប្រាស់ពង្រីកផលិតផលកសិកម្មរបស់ខ្លួនផងដែរ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៣ សម្តេចសីហនុ បានប្រគល់ភារកិច្ចឱ្យ សឺន សាន ជាឧបនាយករដ្ឋមន្ត្រីសម្របសម្រួលកិច្ចការសេដ្ឋកិច្ច-ហិរញ្ញវត្ថុ និងផែនការ ធ្វើការកែទម្រង់សេដ្ឋកិច្ចដ៏ធំមួយ គឺ៖

១.ធ្វើជាតូបនីយកម្មនៃមុខរបរនាំចេញ-នាំចូល, ធ្វើជាតូបនីយកម្មនៃមុខរបរខាងធនាគារ, ធ្វើជាតូបនីយកម្មនៃមុខរបរខាងធានារ៉ាប់រង, ការបង្កើតនូវផ្នែកសេដ្ឋកិច្ចមួយ ដែលរដ្ឋទទួលកាន់កាប់ទាំងស្រុង ជាដើម។

ពេលធ្វើជាតូបនីយកម្មនៃមុខរបរខាងធនាគារនោះ ឈ្មោះ សុង សាក់ ជាម្ចាស់ធនាគារឯកជនមួយ ធ្លាប់តែរកស៊ីកេងបន្លំរូបិយប័ណ្ណជាតិ ក៏បានប្រមូលប្រាក់ក្នុងធនាគារទាំងអស់រត់គេចតាមយន្តហោះទៅសុំសិទ្ធិជ្រកកោននៅប្រទេសវៀតណាមខាងត្បូង និងបានចូលរួមជាមួយ សឺង ង៉ុកថាញ់ ដឹកនាំចលនាតស៊ូខ្មែរសេរី ដើម្បីប្រឆាំងនឹងរបបសង្គមរាស្ត្រនិយមវិញ។

ក្រោយពីសម្តេចសីហនុ ប្រកាសទាត់ចោលជំនួយគ្រប់បែបយ៉ាងរបស់សហរដ្ឋអាមេរិក ការធ្វើកំណែទម្រង់នេះ មានសារប្រយោជន៍ជាអាយុជីវិតរបស់ប្រទេសជាតិ ពិសេសការកែទម្រង់សេដ្ឋកិច្ច ព្រះអង្គមានគោលដៅឆ្ពោះទៅរកឯករាជ្យខាងសេដ្ឋកិច្ច ដែលជាមូលដ្ឋានសំខាន់ចំពោះនយោបាយឯករាជ្យ និងអព្យាក្រឹតរបស់ព្រះអង្គ ។

ព្រះអង្គឈ្វេងយល់ថា តាំងពីបានឯករាជ្យមក វិស័យសង្គមកិច្ច និងវប្បធម៌មានការរីកចម្រើនច្រើន។ ក្រសួងសុខាភិបាលសាធារណៈ ត្រូវបានរៀបចំជាថ្មី។ មន្ទីរពេទ្យ គិលានដ្ឋាន មន្ទីរចែកឱសថ មណ្ឌលសុខភាពជាច្រើន បានត្រូវស្ថាបនានៅតាមទីក្រុង និងតាមជនបទ ។



**រោងចក្រផលិតកង់រថយន្តរបស់រដ្ឋ**

ចំនួនគ្រែសម្រាប់អ្នកជំងឺមានការកើនឡើងច្រើន ឯចំនួនវេជ្ជបណ្ឌិត គ្រូពេទ្យ គិលានុបដ្ឋាក គិលានុបដ្ឋាយិកា ឆ្មប ក៏បានកើនឡើងយ៉ាងឆាប់រហ័សដែរ។ លំនៅឋាននៅតាមទីក្រុងក្តី នៅតាមជនបទក្តី ក៏មានសភាពស្អាតបាតសមរម្យ។ ឯរាជធានី និងទីរួមខេត្ត ទីប្រជុំជននានា ក៏បានផ្លាស់ប្តូរប្រែប្រួលយ៉ាងច្រើន ។

រាជរដ្ឋាភិបាលរបស់ព្រះអង្គបានបញ្ញត្តច្បាប់ការងារ ដើម្បីការពារផលប្រយោជន៍កម្មករ ដូចជាតម្រូវឲ្យម្ចាស់សហគ្រាសផ្តល់ដល់និយោជិតរបស់ខ្លួននូវអត្ថប្រយោជន៍ផ្សេងៗ ខាងសង្គម ដូចនៅក្នុងប្រទេសដែលមានឧស្សាហកម្មលូតលាស់ដែរ ដូចជាពេលឈប់សម្រាក កម្មករត្រូវមានបៀវត្ស, ប្រាក់ធានារ៉ាប់រងចំពោះគ្រោះថ្នាក់ក្នុងពេលបំពេញការងារ និងប្រាក់កម្រៃសម្រាប់គ្រួសារ ជាដើម។

ក្នុងវិស័យវប្បធម៌ ការរីកចម្រើនមានល្បឿនឆាប់រហ័សក្រៃលែង ពិសេស គឺវិស័យសិក្សាធិការជាតិគ្រប់ភូមិសិក្សាទាំងអស់ ( បឋមភូមិ - មធ្យមភូមិ - ឧត្តមភូមិ )។

# ១៧៤
# សម្តេចសីហនុ អញ្ជើញតំណាងវៀតកុង មកចូលរួមសន្និសីទប្រជាជនឥណ្ឌូចិន នៅភ្នំពេញ



វិញ តាន់ផាត អនុប្រធានរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង(វៀតកុង)

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៤ នៅពេលជម្លោះរវាងមេដឹកនាំអាមេរិក និងសម្តេចសីហនុ កាន់តែពុះកញ្ជ្រោល ព្រះអង្គបានស្នើសុំឱ្យមានសន្និសីទប្រជាជនឥណ្ឌូចិនមួយ នៅទីក្រុងភ្នំពេញ ដោយបើកចំហរឱ្យអង្គការ និងចលនាប្រឆាំងនឹងសហរដ្ឋអាមេរិក ទាំងអស់នៅឥណ្ឌូចិន ចូលរួម។

លិខិតអញ្ជើញឱ្យចូលរួមក្នុងសន្និសីទប្រជាជនឥណ្ឌូចិន នេះ ត្រូវបានផ្ញើទៅឱ្យរណសិរ្សមាតុភូមិវៀតណាម, រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង(វៀតកុង) និងអង្គការណែវឡាវ ហាក់សាត នៅប្រទេសលាវ។

នៅថ្ងៃបើកសន្និសីទប្រជាជនឥណ្ឌូចិន នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៦៥ គណៈប្រតិភូចូលរួមសរុបទាំងអស់ មានចំនួន៣៨ ដូចជា គណៈប្រតិភូចលនាអព្យាក្រឹតនិយមរបស់

វៀតណាម ចំនួន២គណៈប្រតិភូ, គណបក្សប្រជាធិបតេយ្យវៀតណាម, គណបក្សសង្គមនិយម វៀតណាម, តំណាងសមាគមព្រះពុទ្ធសាសនាជាច្រើនគណៈប្រតិភូ, គណៈប្រតិភូសហភាពសាសនាកៅដាយនិយម, រណសិរ្សរួបរួម ដើម្បីរំដោះជនជាតិភាគតិចដែលរងការជិះជាន់ ហៅកាត់ថា ចលនាហ្វ៊ុលរ៉ូ( FULRO = Front Unifié de Lutte de la Race Opprimées ) ឬហៅម្យ៉ាងទៀតថា ពួកម៉ុងតាញ៉ា, អង្គការកុម្មុយនិស្តខ្មែរ, អង្គការកុម្មុយនិស្តចាម, អង្គការអូទ្រីយាង ( Austriens ) និងរណសិរ្សតស៊ូដើម្បីកម្ពុជាក្រោម រួមទាំងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនទៀត បង្កើតឡើងដោយសម្តេចសីហនុ ជាព្រះប្រមុខរដ្ឋ។

រណសិរ្សតស៊ូដើម្បីកម្ពុជាក្រោម ត្រូវបានគេបង្ហើបឱ្យដឹងថា ស្ថិតនៅក្រោមការគាំទ្រ និងឧបត្ថម្ភប្រាក់កាស និងសម្ភារៈ ដោយលួចលាក់ពីឧត្តមសេនីយ៍ លន់ នល់ និងឥស្សរជនខ្មែរនៅទីក្រុងភ្នំពេញ ដែលមានដើមកំណើតនៅកម្ពុជាក្រោម មួយចំនួនទៀត ដូចជា វេជ្ជបណ្ឌិត គឹម វៀន, ថាច់ ចាន់ ជាតំណាងរាស្ត្រ និងចៅ សេង ជាដើម។

នៅថ្ងៃបើកសន្និសីទប្រជាជនឥណ្ឌូចិន ក្រោមប្រធានបទ សន្តិភាព ឯករាជ្យ និងសាមគ្គីភាពនោះ គណៈប្រតិភូសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម, គណៈប្រតិភូរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (វៀតកុង) និងគណៈប្រតិភូលាវ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះពួកគេឃើញមានប្រតិភូគណៈកម្មាធិការដើម្បីសន្តិភាព និងអភិវឌ្ឍវៀតណាមខាងត្បូង ជាចលនាមួយមានគោលជំហរអព្យាក្រឹតនិយម ដែលបង្កើតឡើងដោយពួកអន្តោប្រវេសន៍វៀតណាម នៅប្រទេសបារាំង ដឹកនាំដោយអតីតប្រធានាធិបតីវៀតណាមខាងត្បូង ចឺន វ៉ាន់ហៀវ និងគណៈប្រតិភូរណសិរ្សតស៊ូដើម្បីកម្ពុជាក្រោម ដែលកំពុងតស៊ូទាមទារសិទ្ធិសេរីភាព និងប្រឆាំងការជិះជាន់របស់ពួកមេដឹកនាំនៅទីក្រុងព្រៃនគរ បានមកចូលរួមដែរ។

គណៈប្រតិភូរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង( វៀតកុង ) ដឹកនាំដោយ ហ្វីញ តឹនផាត ( Huỳnh Tấn Phát ) ជាអនុប្រធានរណសិរ្ស។ ក្នុងពេលគណៈប្រតិភូរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (វៀតកុង) ស្នាក់នៅសណ្ឋាគារមនោរម្យ ក្នុងទីក្រុងភ្នំពេញ ចឹន ប៊ីវគៀម ជាប្រធានគណៈកម្មការទំនាក់ទំនងបរទេស និងជាសមាជិកគណៈប្រតិភូរបស់

រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង បានទទួលជួបអ្នកសារព័ត៌មានពីរបីនាក់ នៅក្នុងបន្ទប់ទទួលភ្ញៀវបានកត់សម្គាល់ថា ហ្វីញ តឹនផាត ប្រធានគណៈប្រតិភូរបស់គាត់ត្រូវបានកម្លាំងសមត្ថកិច្ចរបស់កម្ពុជា ចាត់ចែងការពារសន្តិសុខយ៉ាងហ្មត់ចត់បំផុត។



**សម្តេចសីហនុ និងចឹន ប៊ីវគៀម កាលពីឆ្នាំ១៩៦៣**

ក្នុងខែកក្កដា ឆ្នាំ១៩៦៣ ចឹន ប៊ីវគៀម បានមកស្នាក់នៅទីក្រុងភ្នំពេញ និងបានចូលជួបពិភាក្សាជាមួយសម្តេចសីហនុ ផងដែរ។ ពេលទៅលំហែកាយនៅមាត់សមុទ្រនាទីក្រុងកែប នៅភូមិគ្រឹះមួយ ចឹន ប៊ីវគៀម បានផ្តល់បទសម្ភាសឱ្យអ្នកឆ្លើយឆ្លងសារព័ត៌មានឡឺម៉ុង របស់បារាំងឈ្មោះ ហ្សក ហ្សាហ៊្វា។

លុះដល់ថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៦៣ សារព័ត៌មានឡឺម៉ុង បានចុះផ្សាយខ្លឹមសារនៃបទសម្ភាសរបស់គាត់ ដោយពេលនោះ គាត់ជឿជាក់ និងសង្ឃឹមថា រណសិរ្សជាតិរំដោះរបស់គាត់ នឹងទទួលជ័យជម្នះនៅវៀតណាមខាងត្បូង យ៉ាងពិតប្រាកដ។

ចឹន ប៊ីវគៀម កើតនៅខេត្តកឺនថឺ វៀតណាមខាងត្បូង ក្នុងឆ្នាំ១៩២០។ កាលនៅយុវវ័យ គាត់ជាប្រធានសហភាពនិស្សិតរំដោះជាតិ និងជាសមាជិកគណៈកម្មការកណ្តាល របស់គណបក្សប្រជាធិបតេយ្យ។ ក្នុងសម័យសង្គ្រាមឥណ្ឌូចិនលើកទី១ គាត់បានប្រមែប្រមូលយុវជនឱ្យចូលជាកងទ័ពវៀតមិញ ជាមួយគាត់ ដើម្បីធ្វើសង្គ្រាមដណ្តើមឯករាជ្យពីអាណានិគមបារាំង។

ក្រោយពីមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ គាត់បានសម្រេចចិត្តចាកចេញ



**ចលនាតស៊ូហ្វ៊ុលរ៉ូ** (FULRO)

ពីវៀតណាមភាគខាងត្បូង ជាមួយកងទ័ពវៀតមិញដែលមកវៀតណាមភាគខាងជើង វិលត្រលប់ទៅវៀតណាមភាគខាងជើងវិញដោយស្ម័គ្រចិត្ត។ ប៉ុន្តែ នៅក្នុងឆ្នាំ១៩៦០ គាត់បានត្រលប់មកនៅវៀតណាមខាងត្បូង វិញជាសម្ងាត់ ហើយបានក្លាយជាមេដឹកនាំក្នុងជួរណេសិរ្សជាតិរំដោះវៀតណាមខាងត្បូង ចាប់ពីពេលនោះមក។

នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៦៦ ង្វៀន វ៉ាន់ហៀវ ជាឯកអគ្គរដ្ឋទូតគោចររបស់រណេសិរ្សជាតិរំដោះវៀតណាមខាងត្បូង(វៀតកុង)ត្រូវបានបញ្ជូនមកជាតំណាងអចិន្ត្រៃយ៍រណេសិរ្សនៅទីក្រុងភ្នំពេញ។ ទោះបីមានការរិះគន់ថា ការទទួលស្គាល់តំណាងអចិន្ត្រៃយ៍រណេសិរ្សជាតិរំដោះវៀតណាមខាងត្បូង (វៀតកុង) ជាផ្លូវការបែបនេះ គឺជាការខុសពីក្បួនពិធីការ និងលក្ខន្តិកៈការទូតក៏ដោយ ក៏សម្តេចសីហនុ ទទួលស្គាល់ថា តំណាងរណេសិរ្សវៀតកុងនេះ មានអភ័យឯកសិទ្ធិ គ្មាននរណាអាចប៉ះពាល់បាន ដូចមន្ត្រីទូតរបស់បរទេសផ្សេងៗទៀតដែរ។

គួរបញ្ជាក់ថា រណេសិរ្សរួបរួមដើម្បីរំដោះជនជាតិភាគតិច ដែលរងការជិះជាន់ ឬចលនាហ្វ៊ុលរ៉ូ (FULRO)នេះ បានបង្កើតឡើងនៅក្នុងឆ្នាំ១៩៦៤ ដឹកនាំដោយ ឡេស កូសេម



**ឡេស កូសេម មេដឹកនាំចលនាហ្វូលរ៉ូ ចូលជួបសេនាប្រមុខលន់ នល់ ឆ្នាំ១៩៧៣**

មានមូលដ្ឋានស្ថិតនៅក្បែរព្រំដែនកម្ពុជា ក្នុងតំបន់ខ្ពង់រាបខេត្តដាក់ឡាក់ ( Dăk Lăk ) ជាប់នឹងព្រំដែនខេត្តមណ្ឌលគិរី របស់ប្រទេសកម្ពុជា ដើម្បីប្រឆាំងនឹងនយោបាយបំបាត់ពូជសាសន៍ជនជាតិភាគតិចរដែ ជាច្រើនពាន់នាក់ ត្រូវពួកទាហានរដ្ឋការវៀតណាមខាងត្បូង បាញ់សម្លាប់ ដោយសារពួកគេនាំគ្នាងើបបះបោរការពារពូជសាសន៍របស់ពួកគេ ហើយការងើបបះ-បោរនេះ បានរាលដាលទៅដល់ជនជាតិចារ៉ាយ ដែលនៅក្នុងខេត្តផ្លេគូ ( Pleiku ) បន្តទៀត។

ឧត្តមសេនីយ៍ លន់ នល់ បានសម្រេចគាំទ្រដល់ចលនាហ្វ៊ុលរ៉ូ នេះ ដោយគាត់ចាត់ទុកថា ជនជាតិភាគតិចរដែនោះ ជាអម្បូរមនខ្មែរ ហើយគាត់ក៏បានលួចបញ្ជូនកងទ័ពខ្មែរជាច្រើនឱ្យទៅជួយចលនាហ្វ៊ុលរ៉ូ ក្នុងអំឡុងពេលមានការបះបោរបំបែកទឹកដីចេញ ពីវៀតណាមនៅតំបន់បួនម៉ាធួត ( BuÔn Ma ThuÔt ) ផងដែរ។

ប៉ុន្តែ នៅទីបំផុត ពួកសេ.អ៊ី.អា អាមេរិក បានទិញទឹកចិត្ត និងបញ្ចុះបញ្ចូលពួកមេដឹកនាំសំខាន់ៗ របស់ចលនាហ្វ៊ុលរ៉ូ នេះ ឱ្យទៅសហការគ្នាមេដឹកនាំរដ្ឋការក្រុងព្រៃនគរ ដើម្បីប្រឆាំងនឹងពួកកុម្មុយនិស្តទៅវិញ។

# ១៧៥
# សម្តេចសីហនុ សុំឱ្យសន្និសីទអន្តរជាតិមួយ ដើម្បីរកដំណោះស្រាយបញ្ហាកម្ពុជា




**សម្តេចសីហនុ និងមហេសី ព្រមទាំងបុត្រា សីហមុនី យាងទៅប្រទេសបារាំង ឆ្នាំ ១៩៦៤**

ក្រោយសន្និសីទប្រជាជនឥណ្ឌូចិន ខែកុម្ភៈ ឆ្នាំ១៩៦៥ នោះមក ទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ហាក់ដូចជាមានការសោះអង្គើយដាក់គ្នាទៅវិញទៅមក។

ពេលនោះ ខាងភាគីវៀតណាមខាងជើង ក៏លែងនិយាយពីគម្រោងយាងសម្តេចសីហនុឱ្យទៅបំពេញទស្សនកិច្ចនៅទីក្រុងហាណូយ ហើយខាងភាគីកម្ពុជា ក៏លែងនិយាយពីគម្រោងមកបំពេញទស្សនកិច្ចរបស់ ផាម វ៉ាន់ដុង នាយករដ្ឋមន្ត្រីវៀតណាមខាងជើង និងពីគម្រោង

មកបំពេញទស្សនកិច្ចមកបំពេញទស្សនកិច្ចរបស់ង្វៀន ហ៊ីវ.ថ (Nguyễn Hữu Thọ)ប្រធានរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង (វៀតកុង) នៅទីក្រុងភ្នំពេញ ដែរ។ ពិសេស គឺឈប់និយាយពីកិច្ចសហការផ្នែកនយោបាយ ដើម្បីប្រឆាំងនឹងនយោបាយរបស់ចក្រពត្តិអាមេរិក ផងដែរ។

ឆ្នាំ១៩៦៥ ហ៊ូ នឹម ត្រូវបានតែងតាំងជាប្រធានគណៈប្រតិភូសមាគមមិត្តភាពកម្ពុជា-ចិន ដោយមាន វ៉ាន់ ទិព្វសុវណ្ណ, សំ ថាំង, អុល ចាន់, ស្វាយ បុរី, ភី ធៀនឡាយ, អ៊ាប គឹមជន ជាសមាជិក ដែលសុទ្ធតែជាពួកស្តាំនិយម ទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋប្រជាមានិតចិន ហើយបានចូលជួបសម្តែងការគួរសមជាមួយប្រធានាធិបតី លីវ ចាវជី និងនាយករដ្ឋមន្ត្រី ជូ អេនឡាយ ផងដែរ។

ក្រោយពីមានការរំលោភបំពានចូលមកទម្លាក់គ្រាប់បែកនៅលើទឹកដីខ្មែរ ពីសំណាក់កងទ័ពអាមេរិក ដែលមានទីតាំងនៅប្រទេសវៀតណាមខាងត្បូង ជាបន្តបន្ទាប់មកទៀត សម្តេចសីហនុ ក៏បានថ្លែងថា ព្រះអង្គនឹងប្រកាសសង្គ្រាមប្រឆាំងនឹងសហរដ្ឋអាមេរិក ក៏ដូចជាអាយ៉ងរបស់គេនៅទីក្រុងព្រៃនគរដែរ ប្រសិនបើការទម្លាក់គ្រាប់បែក នៅតែកើតមានបន្តទៀត ហើយជាមួយគ្នានេះ ព្រះអង្គនឹងអំពាវនាវសុំការគាំទ្រពីប្រទេសចិន ផងដែរ។

នៅទីក្រុងភ្នំពេញ មន្ត្រីស្ថានទូតអាមេរិក ប៉ែរ ជេសិន បានលើកហេតុផលថា ការវាយប្រហាររបស់កងទ័ពរដ្ឋការវៀតណាមខាងត្បូង និងអាមេរិក នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ក៏ដូចជាសកម្មភាពរបស់ពួកខ្មែរសេរី សឺង ង៉ុកថាញ់ ដែរ នឹងមិនបានទទួលលទ្ធផលជាវិជ្ជមានឡើយ ហើយបើទោះបីគាត់មើលឃើញថា សម្តេចសីហនុ មានគោលជំហរឆាប់ប្តូរផ្លាស់ និងមានការក្រេវក្រោធប្រឆាំងនឹងអាមេរិក ក៏ពិតមែន ក៏មន្ត្រីស្ថានទូតអាមេរិករូបនេះ ជឿថា សម្តេចសីហនុ គឺជាមេដឹកនាំដ៏មានប្រជាប្រិយបំផុត ហើយប្រទេសកម្ពុជានឹងសម្បូររុងរឿង ដោយសារការដឹកនាំរបស់ព្រះអង្គ។ ហេតុនេះ អាមេរិក គួរតែកុំព្យាយាមជំរុញឱ្យពួកខ្មែរសេរី ដែលនៅក្នុងប្រទេសវៀតណាមខាងត្បូង និងថៃ ប៉ុនប៉ងផ្តួលរម្លំព្រះអង្គធ្វើអ្វី?។

## របត់នយោបាយ

ដោយសារសន្និសីទប្រជាជនឥណ្ឌូចិន នាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៦៥ នៅទីក្រុងភ្នំពេញ ដែលផ្តួចផ្តើមឡើងដោយសម្តេចសីហនុ មិនទទួលបានលទ្ធផលអ្វីនោះ ព្រះអង្គក៏បានអំពាវនាវឱ្យសហប្រធានសន្និសីទនៅក្រុងហ្សឺណែវ កោះប្រជុំសន្និសីទនេះជាថ្មីម្តងទៀត ដើម្បីធានាដល់បូរណភាព និងអព្យាក្រឹតភាពរបស់ប្រទេសកម្ពុជា ។

នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៦៥ សហប្រធានសន្និសីទក្រុងហ្សឺណែវទាំងពីរ គឺ អង់គ្លេស និងសហភាពសូវៀត បានយល់ព្រមតាមការអំពាវនាវរបស់សម្តេចសីហនុ ដែលសុំឱ្យកោះប្រជុំសន្និសីទនេះ ដែរ។ ប៉ុន្តែស្ថានទូតអាមេរិក ប្រចាំនៅទីក្រុងព្រៃនគរ និងទីក្រុងបាងកក បានព្រមានធ្ងន់ៗទៅលើរដ្ឋាភិបាលរបស់ខ្លួនថា ប្រសិនបើអាមេរិក យល់ព្រមឱ្យមានសន្និសីទនោះមែន ប្រាកដជាធ្វើឱ្យរដ្ឋាភិបាលក្រុងព្រៃនគរ ដែលជាសម្ព័ន្ធមិត្តរបស់ខ្លួន ចុះខ្សោយជាមិនខាន។ ប៉ុន្តែ ប៉ែរ ដេសិន ជាមន្ត្រីស្ថានទូតអាមេរិក នៅទីក្រុងភ្នំពេញវិញ យល់ថា ប្រសិនបើអាមេរិក យល់ព្រមឱ្យមានសន្និសីទនោះ នឹងធ្វើឱ្យទំនាក់ទំនងការទូតរវាងអាមេរិក និងកម្ពុជា អាចវិលត្រលប់មករកភាពល្អប្រសើរវិញបាន។ ពេលនោះ ប្រទេសកាណាដា និងប្រទេសបារាំង ក៏បានយល់ព្រមឱ្យមានសន្និសីទនោះដែរ។

ថ្វីបើសម្តេចសីហនុ មានព្រះទ័យប្រឆាំងនឹងអាមេរិក ខ្លាំងក្លាយ៉ាងណា ក៏ដោយ ក៏ព្រះអង្គមានការព្រួយបារម្ភពីឥទ្ធិពលរបស់វៀតណាមខាងជើង ក្រោយពីពួកគេទទួលបានជ័យជម្នះទាំងស្រុងទៅលើវៀតណាមខាងត្បូង ដែរ។ ព្រះអង្គ បានថ្លែងទៅកាន់អ្នកកាសែតជាតិ និងអន្តរជាតិថា ចំពោះប្រទេសកម្ពុជា ពួកកុម្មុយនិស្តវៀតណាមខាងជើង អាក្រក់បំផុត គឺអាក្រក់ជាងចិន និងសហភាពសូវៀត ទៅទៀត។

នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៦៥ នៅសាកលវិទ្យាល័យចន ហបគីន ដោយមានការចាក់ផ្សាយបន្តតាមកញ្ចក់ទូរទស្សន៍ផងដែរ ប្រធានាធិបតីសហរដ្ឋអាមេរិក ចនសុន (John son) បានលើកឡើងថា យើងសុខចិត្តចូលរួមក្នុងសន្និសីទនោះ ដើម្បីពិភាក្សាពីបញ្ហាវៀតណាម តែយើងអាចមិនពិភាក្សាពីបញ្ហាកម្ពុជា ដែលគ្មានបញ្ហាប្រទូសរ៉ាយអ្វីធ្ងន់ធ្ងរ ដូចនៅវៀតណាមនោះទេ។ ប៉ុន្តែ សាធារណមតិអាមេរិក បានលើកឡើងថា គម្រោងបើកសន្និសីទ

ដើម្បីជានាដល់បូរណភាព និងអព្យាក្រឹតភាពរបស់ប្រទេសកម្ពុជា នោះ គឺគ្មានអ្វីក្រៅពីផ្តល់មធ្យោបាយឱ្យពួកកុម្មុយនិស្តវៀតណាម ការពារមុខមាត់របស់ពួកគេនៅលើឆាកអន្តរជាតិនោះឡើយ ជាពិសេស គឺរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (វៀតកុង) ដែលកាលពីសន្និសីទក្រុងហ្សឺណែវ កាលពីឆ្នាំ១៩៥៤ មិនទាន់បង្កើតឡើងផងនោះ មានឱកាសចូលរួមក្នុងសន្និសីទនេះដែរ តែប៉ុណ្ណោះ។

ថ្វីដ្បិតតែឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំទីក្រុងព្រៃនគរ និងទីក្រុងបាងកក មិនចង់ឱ្យមានសន្និសីទនោះក៏ពិតមែន ប៉ុន្តែឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅក្រុងញូវ ដែលីប្រទេសឥណ្ឌា និងឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅទីក្រុងរ៉ង់ហ្គូន ប្រទេសភូមា ពិសេសសូម្បីតែនាយករដ្ឋមន្ត្រីថៃ ថៈណម គិតទិខៈ ចន ក៏ចង់ឱ្យមានសន្និសីទ នោះដែរ។

ថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៦៥ រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក ឌៀន រ៉ាស់ (Dean Rusk) បានប្រកាសថា សហរដ្ឋអាមេរិក នឹងចូលរួមដោយរីករាយក្នុងសន្និសីទស្តីពីបញ្ហាជានាដល់បូរណភាព និងអព្យាក្រឹតភាពរបស់ប្រទេសកម្ពុជា ប្រសិនបើមានលិខិតអញ្ជើញ ហើយគាត់នឹងតែងតាំងអ្នកការទូតម្នាក់ ឈ្មោះ អេវើល លី ហារវមែន ឱ្យទៅចូលរួមក្នុងសន្និសីទនោះ ជាតំណាងសហរដ្ឋអាមេរិក ទៀតផង។

ប៉ុន្តែ ថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៦៥ នៅក្នុងពិធីសម្ពោធមហាវិថីសហភាពសូវៀត (សហព័ន្ធរុស្ស៊ី) សម្តេចសីហនុ បានថ្លែងថា សហរដ្ឋអាមេរិក កំពុងធ្វើការពិចារណា ចំពោះបញ្ហាចូលរួមប្រជុំសន្និសីទ ដែលព្រះអង្គបានស្នើសុំបង្កើតនោះដែរ។ តែព្រះអង្គឈ្វេងយល់ថា លុះត្រាតែវៀតណាមខាងត្បូង បានទទួលផលចំណេញពីសន្និសីទនេះ ទើបអាមេរិកចូលប្រជុំដែរ។

ព្រះអង្គបានបញ្ជាក់ទៅសហរដ្ឋអាមេរិក វិញថា សន្និសីទដែលគ្រោងធ្វើឡើងនៅពេលខាងមុខនេះ គឺពិភាក្សាតែបញ្ហារបស់កម្ពុជា ប៉ុណ្ណោះ ។

ប៉ុន្មានថ្ងៃក្រោយមកទៀត នៅក្នុងពិធីសម្ពោធបើកឱ្យដំណើរការភោជនីយដ្ឋានមួយក្នុងក្រុងភ្នំពេញដែរ ព្រះអង្គបានប្រកាសថា ឥឡូវនេះ ព្រះអង្គមិនចង់ឱ្យប្រទេសថៃ, វៀតណាម



**រដ្ឋមន្ត្រីការបរទេស ឌៀន រ៉ាស់, ប្រធានាធិបតី ចនសុន**
**និងរដ្ឋមន្ត្រីការពារជាតិ ណាម៉ារ៉ា ទើបមកពីវៀតណាមខាងត្បូង**

ខាងត្បូង និងសហរដ្ឋអាមេរិក ចូលរួមសន្និសីទស្តីពីបញ្ហាកម្ពុជានោះទេ ព្រោះព្រះអង្គធុញទ្រាន់ចំពោះជំហររបស់ប្រទេសទាំង៣នេះ ដែលនៅតែទាមទារយកបញ្ហាវៀតណាម មកពិភាក្សា។

មកដល់ចុងខែឧសភា ឆ្នាំ១៩៦៥ នោះ សម្តេចសីហនុ បានប្រកាសថា ព្រះអង្គមិនចង់ឱ្យមានសន្និសីទដើម្បីធានាដល់បូរណភាព និងអព្យាក្រឹតភាពរបស់ប្រទេសកម្ពុជា នោះទៀតទេ។

មូលហេតុដែលធ្វើឱ្យសម្តេចសីហនុ ផ្លាស់ប្តូរព្រះទ័យលែងឱ្យមានសន្និសីទនោះ ត្រូវបានគេសន្និដ្ឋានថា ដោយសារអាមេរិក ពន្យារពេលយូរពេកក្នុងការសម្រេចចិត្តថា ត្រូវចូលរួម ឬមិនចូលរួមក្នុងសន្និសីទនោះ តែនេះគ្រាន់ជាលេសមួយរបស់សម្តេចសីហនុ តែប៉ុណ្ណោះ។

ទន្ទឹមនោះ គេដឹងថា នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ធ្លាប់បានទទូចទៅសម្តេចសីហនុថា កុំឱ្យមានការកោះប្រជុំសន្និសីទ ដែលព្រះអង្គចង់ឱ្យមានពីមុនមកនោះធ្វើអ្វី ព្រោះ

វាអាចធ្វើឱ្យខូចដល់ផលប្រយោជន៍របស់វៀតណាមខាងជើង ដែលជាសម្ព័ន្ធមិត្តរបស់ប្រទេស ចិន ហើយសម្តេចសីហនុ ក៏គ្មានជម្រើសណាផ្សេង ក្រៅពីធ្វើតាមការទទូចចង់បានរបស់ ជូ អេនឡាយ ដែរ។

គេដឹងហើយថា មុននេះ ចិន ក៏គាំទ្រឱ្យមានសន្និសីទនេះដែរ តែហេតុអ្វីបានជាចិន ទទូចឱ្យសម្តេចសីហនុ លុបចោលគម្រោងប្រជុំសន្និសីទនោះទៅវិញ? បញ្ហានេះ ត្រូវបាន ពួក សេ.អ៊ី.អា រាយការណ៍ថា អ្វីដែលជាការគាំទ្រដំបូង របស់ចិនក្នុងការឱ្យមានសន្និសីទ នោះ គឺគ្រាន់តែជាការបន្លំភ្នែកសាធារណមតិអន្តរជាតិប៉ុណ្ណោះ ព្រោះចិន ភ័យខ្លាចសហភាព សូវៀត កាន់តែមានឥទ្ធិពលទៅលើវៀតណាមខាងជើង ខ្លាំងថែមទៀត។

ការរឹតចំណងមិត្តភាពរវាងសម្តេចសីហនុ និងមេដឹកនាំចិន ពិសេសជាមួយ ម៉ៅ សេទុង និងជូ អេនឡាយ ធ្វើឱ្យសហភាពសូវៀត មិនសប្បាយចិត្ត រហូតសម្រេចលុបចោលគម្រោង យាងទៅទស្សនកិច្ចជាផ្លូវការរបស់សម្តេចសីហនុ នៅទីក្រុងមូស្គូ ដែលខ្លួនបានរៀបចំឡើង នោះទៀតផង។

# ១៧៦
# បាតុកម្មវាយស្ថានទូតអាមេរិក លើកទី២



**បាតុកម្មវាយស្ថានទូតអាមេរិក ថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៦៥**

ចាប់ពីដើមឆ្នាំ១៩៦៥មក ចលនាតស៊ូរបស់បក្សពលករកម្ពុជា បានរីករាលដាលពីទីក្រុងភ្នំពេញ ទៅដល់ទីរួមខេត្តនានា ជាបន្តបន្ទាប់។ យុវជនមួយចំនួនលែងសូវយកចិត្តទុកដាក់ក្នុងការរៀនសូត្រដូចមុនៗទៀតហើយ ពួកគេបានយកពេលវេលាចូលរួមធ្វើសកម្មភាពនយោបាយ ដោយដើរបាចខិត្តប័ណ្ណប្រឆាំងនឹងរាជរដ្ឋាភិបាល ពិសេស ពួកគេបានរិះគន់ប្រមាថទៅលើឧត្តមសេនីយ៍ លន់ នល់ យ៉ាងធ្ងន់ធ្ងរ ហើយកម្លាំងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ក៏បានចាប់ខ្លួនពួកគេជាហូរហែផងដែរ។

តែក្នុងចំណោមពួកគេដែលត្រូវប៉ូលិសចាប់ខ្លួន និងជំរិតសួរចម្លើយ ដោយសារធ្វើសកម្មភាពបាចខិតប័ណ្ណនោះ ភាគច្រើនតែងតែឆ្លើយដោយគ្មានតក់ស្លុតដូចៗគ្នាថា គ្មានប្រយោជន៍អ្វីនៅក្នុងការជំរិតសួរចម្លើយពួកគេទេ។ ទោះបីប៉ូលិសចង់ធ្វើអ្វីពួកគេ ក៏ធ្វើចុះពីព្រោះរបបសព្វថ្ងៃនេះ(របបសង្គមរាស្ត្រនិយម) អ្នកតូចតាច អ្នកទន់ខ្សោយតែងតែរងនូវ

អំពើអយុត្តិធម៌ ជិះជាន់ធ្វើបាបសង្កត់សង្កិន ពីពួកអ្នកធំ ពួកអ្នកមានអំណាច និងពួកអ្នកមាន ទ្រព្យសម្បត្តិយ៉ាងដូច្នេះឯង។



ទូតអាមេរិក នៅទីក្រុងភ្នំពេញ ឆ្នាំ១៩៦៥

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៦៥ សិស្ស និស្សិត និងអ្នករស់នៅទីក្រុងភ្នំពេញ ២ម៉ឺននាក់ទៀត បាននាំគ្នាធ្វើបាតុកម្មនៅមុខស្ថានទូតអាមេរិក ជាថ្មីម្តងទៀត ដើម្បីសម្តែងការខឹងសម្បា និងប្រឆាំងតវ៉ាចំពោះយន្តហោះសហរដ្ឋអាមេរិក ដែលបានឆ្លងដែនអាកាស ចូលមកវាយប្រហារភូមិកម្ពុជា បណ្តាលឱ្យស្លាប់ប្រជាពលរដ្ឋកម្ពុជា ច្រើននាក់ និងដោយសារ ថ្ងៃទី៥ ខែមេសា ទស្សនាវដ្តី ញូស្វីក (Newsweek) របស់សហរដ្ឋអាមេរិក ចេញផ្សាយអត្ថបទមួយបង្កាច់បង្ខូចព្រះកិត្តិនាមសម្តេចសីហនុ និងអ្នកម្នាងម៉ូនិក ជាព្រះជាយារបស់ព្រះអង្គ។ ក្រុមបាតុករបានគប់ដុំថ្មទៅលើអគារទូតអាមេរិក ហើយបានហែកទង់ជាតិអាមេរិក ចោល។

ក្នុងពេលធ្វើបាតុកម្មវាយស្ថានទូតអាមេរិក ថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៦៥នោះ កម្លាំងបង្កប់របស់ពួកខ្មែរកុម្មុយនិស្តជាសិស្សនិស្សិត និងជាមន្រ្តីរាជការជាច្រើនបានចូលរួមយ៉ាងសកម្មបំផុត។ មន្ត្រីទូតសហរដ្ឋអាមេរិក ចាត់ទុកថា សម្តេចសីហនុ ជាអ្នកបើកភ្លើងខៀវឱ្យបាតុកម្មនេះ ។

២ថ្ងៃក្រោយការធ្វើបាតុកម្មវាយស្ថានទូតអាមេរិក ជាថ្មីម្តងទៀតនោះ មានរបាយការណ៍មួយបានឱ្យដឹងថា យន្តហោះចម្បាំងរបស់វៀតណាមខាងត្បូង ចំនួន៤គ្រឿង បានហោះមកទម្លាក់គ្រាប់បែកមកលើភូមិចំនួនពីរ របស់ខ្មែរស្ថិតនៅក្នុងខេត្តកំពង់ចាម (សព្វថ្ងៃជាខេត្តត្បូងឃ្មុំ) ដែលមានចម្ងាយពីខ្សែបន្ទាត់ព្រំដែនប្រមាណ៤គីឡូម៉ែត្រ បណ្តាលឱ្យអ្នកភូមិ

ស្លាប់ និងរបួសជាច្រើន។

ពេលនោះ អនុព័ន្ធយោធាប្រចាំស្ថានទូតអាមេរិក នៅទីក្រុងភ្នំពេញ ក៏បានធ្វើដំណើរទៅពិនិត្យហេតុការណ៍ដល់កន្លែងទម្លាក់គ្រាប់បែកនោះដែរ តែការពិតយន្តហោះទម្លាក់គ្រាប់បែកនោះ ពុំមែនជារបស់កងទ័ពជើងអាកាសវៀតណាមខាងត្បូង ដូចក្នុងរបាយការណ៍នោះទេ គឺជាយន្តហោះទម្លាក់គ្រាប់បែករបស់អាមេរិក តែម្តង។

ក្នុងហេតុការណ៍នោះ សម្តេចសីហនុ បានទាមទារឱ្យអាមេរិក ធ្វើការសុំទោសជាផ្លូវការ និងសងសំណងចំពោះជនរងគ្រោះកម្ពុជា ដែលរងគ្រោះដោយសារការទម្លាក់គ្រាប់បែកមកលើភូមិ ទាំង២ នោះ។

ប៉ែរ ដេសិន មន្ត្រីស្ថានទូតអាមេរិក នៅភ្នំពេញ បានរៀបចំកំណត់ទូតមួយស្តីពីហេតុ-ការណ៍ទម្លាក់គ្រាប់បែកនេះ ផ្ញើទៅសេតវិមាន និងស្នើសុំឱ្យរដ្ឋាភិបាលអាមេរិក ធ្វើការសុំទោសជាសាធារណៈ និងផ្តល់សំណងចំពោះការខូចខាតទ្រព្យសម្បត្តិ និងជីវិតមនុស្សផងដែរ។

នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៦៥ សម្តេចសីហនុ ប្រកាសជាផ្លូវការផ្តាច់ទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក ទាំងស្រុងតែម្តង។

៤ថ្ងៃក្រោយមក គឺនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៦៥ រាជរដ្ឋាភិបាលដែលមានព្រះអង្គម្ចាស់ នរោត្តម កន្តុល ជានាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីមហាផ្ទៃ និងធម្មការ បានធ្វើការផ្លាស់ប្តូររុះរើសមាសភាពគណៈរដ្ឋមន្ត្រីថ្មីមួយចំនួន ក្នុងនោះ លន់ នល់ នៅជាឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីការពារជាតិ និងកីឡា ដដែល, សឺន សាន ជាឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីសម្របសម្រួលកិច្ចការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងផែនការ, គូ រុន ជារដ្ឋមន្ត្រីទទួលបន្ទុកសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស, ទ្រង់ស៊ីសុវត្ថិ សិរិមតៈ ជាទេសរដ្ឋមន្ត្រីទទួលបន្ទុកអប់រំជាតិ, ចៅ សៅ ជារដ្ឋមន្ត្រីផែនការ, ផ្លែក ឆាត ជារដ្ឋមន្ត្រីឧស្សាហកម្ម, ប៉ុន វង្សវដ្ថី ជារដ្ឋមន្ត្រីយុត្តិធម៌, គួន វិច ជារដ្ឋមន្ត្រីការបរទេស, អ៊ឹង គៀត ជារដ្ឋលេខាធិការសាធារណការ និងទូរគមនាគមន៍, សូ ណៃម ជារដ្ឋលេខាធិការពាណិជ្ជកម្ម, ចៅ សេង ជារដ្ឋលេខាធិការផែនការ, ជា សាន ជារដ្ឋ





**ទូតអាមេរិក នៅទីក្រុងភ្នំពេញ សម័យសង្គមរាស្ត្រនិយម**

លេខាធិការព័ត៌មាន, ជួន សៅឌី ជារដ្ឋលេខាធិការកសិកម្ម, ទិត ម៉ម (ស្រី)ជារដ្ឋលេខាធិការការងារ និងសង្គមកិច្ច, ឆាយ ហាន់ចេង ជារដ្ឋលេខាធិការសុខាភិបាលសាធារណៈ, យ៉ែម សារ៉ុង ជារដ្ឋលេខាធិការហិរញ្ញវត្ថុ, ទ្រិញ វ៉ាញ ជាអនុរដ្ឋលេខាធិការធម្មការ, អាំង គឹមឃន ជាអនុរដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី បន្ទុកមន្ទីរទេសចរណ៍, សំរិទ្ធ សុទ្ធ ជាអនុរដ្ឋលេខាធិការអប់រំជាតិ និងហែម កេតសាណា ជាអនុរដ្ឋលេខាធិការមហាផ្ទៃ។

ទោះបីសម្តេចសីហនុ ប្រកាសជាផ្លូវការផ្តាច់ទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៦៥ហើយក៏ដោយ ក៏មកដល់ថ្ងៃទី១១ ខែឧសភា មន្ត្រីទូតអាមេរិក ប៉ែរ ជេសិន នៅតែមានសង្ឃឹមថា អាចស្តារទំនាក់ទំនងការទូតនេះឱ្យមានភាពប្រក្រតីឡើងវិញបាន។ ចំណែករាជរដ្ឋាភិបាលកម្ពុជា ក៏បានប្រាប់ទៅរដ្ឋាភិបាលអង់គ្លេសដែរថា កម្ពុជាក៏នៅចាប់អារម្មណ៍ពីការបន្តទំនាក់ទំនងការទូតជាមួយអាមេរិក ដែរ។

សម្តេចសីហនុ បានថ្លែងប្រាប់មន្ត្រីបារាំងថា ការផ្តាច់ទំនាក់ទំនងការទូតជាមួយអាមេរិកនេះ គឺគ្មានមូលហេតុអ្វី ក្រៅពីការវាយប្រហាររបស់កងទ័ពអាមេរិក ចូលមកក្នុងទឹកដីខ្មែរនោះទេ។ តែព្រះអង្គ ក៏បានព្រលយពាក្យដែរថា ព្រះអង្គរីករាយនឹងការផ្សារទំនាក់ទំនងគ្នាឡើងវិញ ប្រសិនបើអាមេរិក បញ្ឈប់សកម្មភាពរំលោភឈ្លានពានកម្ពុជា តទៅទៀត។

ក្រោយពីប្រទេសកម្ពុជា ប្រកាសផ្តាច់ទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក មិន

## របត់នយោបាយ

បានប៉ុន្មានថ្ងៃផង នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ដែលរង់ចាំឱកាសនេះជាយូរមកហើយ ក៏បានផ្ញើសារទូរលេខ មួយមកថ្វាយសម្តេចសីហនុ ដើម្បីសម្តែងការស្វាគមន៍អបអរសាទរ ចំពោះការសម្រេចព្រះទ័យបែបនេះហើយ ជូ អេនឡាយ ក៏បានសន្យាដែរថា ប្រសិនបើអាមេរិក ពង្រីកភ្លើងសង្គ្រាមឱ្យឆេះរាលដាលមកដល់ប្រទេសកម្ពុជា នោះ ប្រទេសចិន នឹងមិនឈរឱប ដៃនៅស្ងៀមឡើយ ហើយប្រជាជនចិន ទាំង៧០០លាននាក់ នឹងគាំទ្រដល់ប្រជាជនខ្មែរ ជាបងប្អូនជានិច្ច។

ពេលនោះ នង សួន ហៅជ័យ សួន ជាមេដឹកនាំគណបក្សប្រជាជន ដែលកំពុងជាប់នៅក្នុងពន្ធនាគារ ដោយត្រូវតុលាការផ្តន្ទាទោសប្រហារជីវិតកាលពីឆ្នាំ១៩៦២ តែក្រោយមកសម្តេចសីហនុ បានបន្ធូរបន្ថយទោសឱ្យមកនៅត្រឹមជាប់គុកអស់មួយជីវិតវិញនោះ គាត់ក៏បានឆ្លៀតឱកាសផ្ញើលិខិតមួយច្បាប់ចេញពីពន្ធនាគារទៅថ្វាយសម្តេចសីហនុ សម្តែងការកោតសរសើរចំពោះព្រះអង្គ ដែលបានសម្រេចព្រះទ័យផ្តាច់ទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក នោះដែរ។

# ១៧៧
# សាឡុត ស និងអៀង សារី រត់ចូលព្រៃតស៊ូ



សាឡុត ស និងអៀង សារី

ឆ្នាំ១៩៦២ នៅពេល នង សួន ត្រូវតុលាការសើកកាត់ទោសប្រហារជីវិត។ តែត្រូវសម្តេចសីហនុ បន្ធូរបន្ថយទោសមកនៅត្រឹមជាប់ពន្ធនាគារអស់មួយជីវិតវិញ។ ចំណែក កែវ មាស ជាប្រធានគណបក្សប្រជាជន ត្រូវបង្ខំចិត្តរត់ចូលព្រៃ។

នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៦៣ ក្រោយធ្វើការស៊ើបអង្កេតជាច្រើនថ្ងៃមក លន់ នល់ ពេលនោះជាទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងការពារប្រទេស និងកីឡា បានដាក់ថ្វាយសម្តេចសីហនុ នូវបញ្ជីឈ្មោះជនសង្ស័យជាប់ពាក់ព័ន្ធនឹងការធ្វើវិទ្ធង្សនា និងបំផុសញុះញង់ឱ្យមានបាតុកម្មប្រឆាំងនឹងរបបសង្គមរាស្ត្រនិយម ចំនួន៣៤រូប ក្នុងនោះភាគច្រើនគឺពួកមេដឹកនាំបក្សពលករកម្ពុជា និងពួកឆ្វេងនិយម មានជាអាទិ៍ៈ សាឡុត ស, អៀង សារី, សុន សេន, គាត ឈន់, កេង វ៉ាន់សាក់, ហ៊ូ នឹម, ទេព ឈីវខេង, ជួន ប្រាសិទ្ធ, ឱក សុគន្ធ, ខៀវ សំផន (ពេលនោះជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម), ហ៊ូ យន់ (ពេលនោះជារដ្ឋលេខាធិការក្រសួងផែនការ), ថៅ សេង (ពេលនោះជារដ្ឋលេខាធិការក្រសួងកសិកម្ម) ជាដើម។ ដោយសារ

ភ័យខ្លាចសម្តេចសីហនុ ឱ្យគេចាប់យកទៅសម្លាប់ចោល ពួកមេដឹកនាំបក្សពលករកម្ពុជា ដែលមាននៅក្នុងបញ្ជីឈ្មោះនោះមួយចំនួន ក៏នាំគ្នារត់ចូលព្រៃ ។

ប៉ុន្តែ បើតាមខៀវ សំផន ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះនោះដែរ បានឱ្យដឹងថា ក្រោយពីសម្តេចសីហនុ បានទតបញ្ជីឈ្មោះនោះមក ដូចជាមិនមានហេតុការណ៍អាក្រក់ណាមួយទៅលើនរណាម្នាក់ក្នុងចំណោមអ្នកទាំង៣៤នាក់នោះទេ ពោលគឺព្រះអង្គមិនបានឱ្យ លន់ នល់ ចាត់ការអ្វីចំពោះនរណាម្នាក់ដែលមានឈ្មោះនៅក្នុងបញ្ជីនោះឡើយ។

ខៀវ សំផន យល់ថា នេះ គ្រាន់តែជាឧបាយកលនិន្នាឈ្នានីសមួយរបស់ លន់ នល់ ដើម្បីទម្លាក់គាត់ (ជាពួកឆ្វេងនិយម) ចេញពីតំណែងរដ្ឋមន្ត្រីប៉ុណ្ណោះ។ ឧបាយកលនិន្នាឈ្នានីសមួយទៀត គឺ លន់ នល់ បានចោទប្រកាន់គាត់ជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មថា អសមត្ថភាព ទើបបណ្តាលឱ្យសាច់គោឡើងថ្លៃ។ តែតាមពិត ពេលនោះ សាច់គោឡើងថ្លៃពិតមែន តែទំនិញផ្សេងៗទៀតមិនឡើងថ្លៃទេ។

ក្នុងខែឧសភា ឆ្នាំ១៩៦៣ ដោយមានបណ្តាញនិរសារ របស់រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ជួយចាត់ចែងផងដែរ សាឡុត ស, អៀង សារី និងមេដឹកនាំបក្សពលករខ្មែរ ផ្សេងទៀត ដូចជា ស៊ាត ឆែ ហៅសមមិត្តទុំ (ជាអតីតសិស្សជំនិតរបស់ សាឡុត ស និងខៀវ ប៉ុណ្ណារី) ជាដើម បាននាំគ្នាចាកចេញជាបន្តបន្ទាប់ពីទីក្រុងភ្នំពេញ ដោយសម្ងាត់ឆ្ពោះទៅកាន់មូលដ្ឋានមជ្ឈិមរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង(វៀតកុង) ដែលស្ថិតក្នុងទឹកដីខេត្តតៃនិញ វៀតណាមខាងត្បូង ចម្ងាយប្រមាណ១០គីឡូម៉ែត្រពីព្រំប្រទល់កម្ពុជា។

កាលពីខែសីហា ឆ្នាំ១៩៥៣ សម័យសង្គ្រាមឥណ្ឌូចិនលើកទី១ សាឡុត ស និងមិត្តភក្តិ ២នាក់ទៀត មកពីប្រទេសបារាំង ជាមួយគ្នា គឺ រ័ត្ន សាមឿន និងយុន សឿន ធ្លាប់បានចាកចេញពីក្រុងភ្នំពេញ ទៅចូលរួមតស៊ូជាមួយពួកវៀតមិញ នៅក្បែរមូលដ្ឋាននេះ ម្តងរួចមកហើយ។

នៅក្បែរមន្ទីរមជ្ឈិមរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង(វៀតកុង) សាឡុត ស ដែលជាលេខាបក្សពលករកម្ពុជា បានសាងសង់មន្ទីររបស់គាត់ នៅក្រោមដើមចំបក់ធំមួយ

ឱ្យឈ្មោះថាមន្ទីរ១០០ ជាលេខសម្ងាត់របស់គណៈកម្មាធិការមជ្ឈិមបក្សពលករកម្ពុជា។ ពេលនោះ សោ ភឹម (ឈ្មោះដើម ប្រាក់ ចាម ឬសោ យ៉ាន់) សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្ស និងជាលេខាបក្សភូមិភាគបូព៌ា ភាគច្រើនគាត់ស្ថិតនៅក្នុងទឹកដីកម្ពុជា នៅជាប់ព្រំដែននោះ តែងតែធ្វើដំណើរទៅតាមភូមិនានាដែលមានបណ្ដាញសម្ងាត់របស់គាត់ដើម្បីធ្វើសកម្មភាពបដិវត្តន៍។

តែបើមានការប្រជុំគណៈកម្មាធិការមជ្ឈិមបក្ស ឬត្រូវជួបពិភាក្សាការងារជាមួយសាឡុត ស គាត់ត្រូវធ្វើដំណើរទៅមន្ទីរ១០០ ដែលស្ថិតក្នុងខេត្តតៃនិញ នោះ។

ចំណែក នួន ជា អនុលេខាបក្ស រស់នៅទីក្រុងភ្នំពេញ បន្តទៀត ដោយប្រើរូបភាពជាអ្នករកស៊ីបើកដេប៉ូលក់ឈើ និងបន្ទះឫស្សីនៅក្បែរវត្តស្ទឹងមានជ័យ ដូចមុនដដែលនោះ គាត់នៅតែដឹកនាំសកម្មភាពធ្វើបដិវត្តន៍នៅទីក្រុងភ្នំពេញ និងចុះទៅភូមិភាគដទៃទៀត ញឹកញាប់ដែរ។

អំឡុងពេលនោះដែរ នួន ជា ក៏បានធ្វើដំណើរទៅមន្ទីរ១០០ ដើម្បីពិភាក្សាការងារជាមួយ សាឡុត ស ពីការរៀបចំគណៈកម្មាធិការបក្សទីក្រុងភ្នំពេញ ថ្មី ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ វន វ៉េត (ឈ្មោះដើម ពេញ ធួក ឬ សុខ ធួក) ផងដែរ។

នៅមន្ទីរ១០០ សាឡុត ស និងមេដឹកនាំបក្សពលករកម្ពុជាផ្សេងទៀត មានការស្រងាកចិត្តយ៉ាងខ្លាំង ព្រោះពួកគេរស់នៅតែក្នុងមន្ទីរ ប្រៀបដូចពួកវៀតកុង យកមកឃុំឱ្យនៅតែមួយកន្លែង ហើយអ្វីៗត្រូវធ្វើតាមតែពួកវៀតកុងទាំងអស់។ ការដឹកនាំរបស់ពួកគេតាំងពីថ្នាក់កំពូល ដល់ថ្នាក់ក្រោម និងការផ្គត់ផ្គង់សព្វសារពើ ត្រូវពឹងផ្អែកទាំងស្រុងទៅលើពួកវៀតកុង ហើយជាទូទៅ គឺពួកវៀតកុង មិនអនុញ្ញាតឲ្យដើរចេញពីបរិវេណជំរំឡើយ។

ចំណែកឯកសារទ្រឹស្ដីនយោបាយជាភាសាវៀតណាម ត្រូវបានគេយកមកបកប្រែជាភាសាខ្មែរឲ្យពួកគាត់រៀនសូត្រ។

នៅចុងឆ្នាំ១៩៦៣ ដោយមានការស្មុគស្មាញក្នុងចិត្តខ្លាំងពេក អៀង សារី បានសម្រេចចិត្តចាកចេញពីមន្ទីរ១០០ ត្រលប់មកពីក្រុងភ្នំពេញ វិញ។ ប៉ុន្តែ នៅក្នុងឆ្នាំ១៩៦៤ តាមរយៈ

គណៈទាក់ទងមជ្ឈិមបក្ស គាត់ត្រូវបាន សាឡុត ស ណែនាំឲ្យត្រលប់មកមន្ទីរ១០០ វិញ។

ឆ្នាំនោះដែរ សិស្សវិទ្យាល័យព្រះយុគន្ធរម្នាក់ ឈ្មោះ ឈឹម សំអោក (ឈ្មោះបដិវត្តន៍ សមមិត្តប៉ង់) ជាសម្ព័ន្ធយុវកក ក៏បានរត់ចេញពីទីក្រុងភ្នំពេញ ធ្វើដំណើរទៅដល់មន្ទីរ១០០ នោះដែរ។ ពេលទៅ ដល់ដំបូង ឈឹម សំអោក មិនបានស្គាល់ថា នរណាជាអ្នកដឹកនាំបក្ស ពលករកម្ពុជា នោះទេ។ ប៉ុន្តែ មិនយូរប៉ុន្មាន សមមិត្តដែលរស់នៅក្នុងមន្ទីរ១០០នោះ ក៏ណែនាំគាត់ឱ្យបានស្គាល់សមាសភាពមេដឹកនាំកំពូលៗនៅទីនោះ ទើបគាត់ដឹងថា សាឡុត ស ជាបងធំទី១ ។

នៅមន្ទីរ១០០នោះ សាឡុត ស និងអៀង សារី មិនបានដឹកនាំការងារអ្វីសំខាន់ ក្រៅពីសរសេរឯកសារបដិវត្តន៍បន្តិចបន្តួច ដោយមាន ឈឹម សំអោក ជាអ្នកជួយរៀបចំក្រដាសស្តង់-ស៊ីល (Stencil) ដើម្បីអូសចម្លងឯកសារទាំងនោះ ។

ជាមួយនឹងការខិតខំព្យាយាមរៀនសូត្រឯកសារបដិវត្តន៍ និងធ្វើកិច្ចការអូសចម្លងឯក-សារនេះ ដោយយកចិត្តទុកដាក់បំផុត ឈឹម សំអោក ក៏បានហាត់ពត់លត់ដំកសាងខ្លួនឱ្យទៅជាជនបដិវត្តន៍តាមគំរូបងៗជាមេដឹកនាំនៅទីនោះ ដោយស្មារតីលះបង់ខ្ពស់បំផុត។

នៅមន្ទីរ១០០នោះ ឈ្មោះ ស៊ាត ឆែ ហៅសមមិត្តទុំ ក៏បានបំពេញតួនាទីរបស់ខ្លួនជាជំនួយការរបស់ សាឡុត ស ។ ស៊ាត ឆែ បានធ្វើការកោតសរសើរមេដឹកនាំរបស់គាត់នៅទីនោះថា ទោះបីបងៗ មានជំងឺគ្រុនចាញ់ក៏ដោយ ក៏ពួកបងៗខិតខំធ្វើការទាំងឈឺដែរ ហើយគាត់ជាអ្នកដើររកឫសឈើ និងវល្លិផ្សេងៗមកធ្វើថ្នាំដាំទឹកដើម្បីជួយព្យាបាលជំងឺគ្រុនចាញ់ពួកបងៗ ទៀតផង។

ក្នុងខែសីហា ឆ្នាំ១៩៦៤ នៃ សារ៉ាន់ ហៅសមមិត្តយ៉ា ត្រូវបក្សចាត់តាំង ឱ្យចាកចេញពីទីក្រុងភ្នំពេញ ទៅតស៊ូជំរំក្នុងព្រៃដែរ។ តែបក្សមិនទាន់ឱ្យ សួស នៅ ហៅសមមិត្ត ឈូក ចាកចេញពីទីក្រុងភ្នំពេញ ទេ។

នៅចុងឆ្នាំ១៩៦៤ សាឡុត ស បានកោះអញ្ជើញកម្មាភិបាល នៅទូទាំងប្រទេស ឱ្យមករួមប្រជុំធំមួយនៅក្នុងទឹកដីភូមិភាគបូព៌ា ដែលនៅមិនឆ្ងាយប៉ុន្មានពីមន្ទីរ១០០ ក្នុងទឹកដី

វៀតណាមនោះ។

ដោយចង់យកគំរូតាមបក្សពលកររៀតណាម ដែលបានផ្លាស់ប្តូរការតស៊ូនយោបាយ ទៅជាការតស៊ូដោយអាវុធ ដើម្បីរំដោះវៀតណាមភាគខាងត្បូង ចាប់ពីឆ្នាំ១៩៥៩ មកនោះ សាឡុត ស បានអប់រំបំពាក់បំប៉នដល់កម្មាភិបាលរបស់គាត់នៅទូទាំងប្រទេសឱ្យមានគោលជំហរតស៊ូដោយហិង្សានយោបាយ និងប្រដាប់អាវុធ ឈរលើស្មារតីឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន។

បន្ទាប់ពីកិច្ចប្រជុំនោះមក សោ ភឹម បានអះអាងថា នៅភូមិភាគបូព៌ា គាត់អាចមានលទ្ធភាពអាចដឹកនាំធ្វើការតស៊ូដោយហិង្សានយោបាយ និងប្រដាប់អាវុធនេះបាន។

បើទោះបីជាបញ្ហាតស៊ូដោយហិង្សានយោបាយ និងប្រដាប់អាវុធ មិនទាន់ចេញជាមាគ៌ានយោបាយជាផ្លូវការក៏ដោយ ក៏នៅដើមឆ្នាំ១៩៦៥ នៅក្នុងកិច្ចប្រជុំមួយនៅមន្ទីរ១០០ គណៈកម្មាធិការអចិន្ត្រៃយ៍បក្សពលករខ្មែរ បានអនុម័តសេចក្តីសម្រេចមួយបង្ហាញថា ពេលវេលាត្រូវប្តូរទិសពីការតស៊ូនយោបាយ មកជាការតស៊ូប្រដាប់អាវុធ កាន់តែខិតជិតមកដល់ហើយ ព្រោះពួកចក្រពត្តិអាមេរិក បានរៀបចំពង្រីកឱ្យមានសង្គ្រាមនៅទូទាំងឥណ្ឌូចិន ហើយ។ សេចក្តីសម្រេចនេះ បានបញ្ជាក់ជាគោលការណ៍ថា ដើម្បីធ្វើការតស៊ូប្រឆាំងចក្រពត្តិនិយមដាច់ខាតត្រូវតែប្រើកម្លាំងប្រដាប់អាវុធ ទើបមានជ័យជម្នះ។

បន្ទាប់មក មានការប្រជុំមួយទៀតនៅមន្ទីរ១០០ ដោយមានកម្មាភិបាលជាន់ខ្ពស់មកពីទីក្រុងភ្នំពេញ និងមកពីភូមិភាគឦសាន, ភូមិភាគនិរតី និងភូមិភាគឧត្តរ។ អង្គប្រជុំនេះធ្វើឡើងក្រោមការឃាមកាមរបស់កងទ័ពវៀតកុង។

សាឡុត ស ក្នុងនាមគណៈកម្មាធិការអចិន្ត្រៃយ៍បក្សពលករខ្មែរ បានណែនាំកម្មា-ភិបាលជាន់ខ្ពស់មកពីទីក្រុងភ្នំពេញ ឱ្យបង្កើនសកម្មភាពបំផុសឱ្យប្រជាជន ពិសេសក្នុងចំណោមយុវជន និងកម្មករ ប្រឆាំងនឹងពួកចក្រពត្តិអាមេរិក ឲ្យកាន់តែខ្លាំងក្លាថែមទៀត។

ចំណែកកម្មាភិបាលមកពីភូមិភាគឦសាន, ភូមិភាគនិរតី និងភូមិភាគឧត្តរ ត្រូវត្រៀមធ្វើសកម្មភាពហិង្សានយោបាយ។ ប៉ុន្តែការណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍

នេះ គ្រាន់តែជាទ្រឹស្តីប៉ុណ្ណោះ ព្រោះរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង(វៀតកុង)ជាម្ចាស់ផ្ទះ បានជំទាស់ ដោយលើកហេតុផលថា ស្ថានភាពនៅកម្ពុជា គឺការកសាងកម្លាំងបដិវត្តន៍ជាការត្រឹមត្រូវហើយ តែការធ្វើសកម្មភាពហិង្សានយោបាយនៅមិនទាន់ដល់ពេលនៅឡើយទេ។

អ្វីដែលថ្នាក់ដឹកនាំបក្សពលករខ្មែរ មានការខឹងសម្បាបំផុតនោះ គឺនៅពេលពួកគេស្នើសុំកាំភ្លើងមួយចំនួនសម្រាប់បំពាក់ដល់កងឈ្លប និងមួយចំនួនទៀតសម្រាប់បំពាក់ឲ្យក្រុមឃោសនិក ពេលចេញទៅធ្វើសកម្មភាពចាត់តាំងនៅតំបន់ជនបទនោះ ត្រូវបានមេដឹកនាំរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង បដិសេធ។

នៅក្នុងឆ្នាំ ១៩៦៤ ដូ ដេត ចាងហ្វាងកាសែតប្រជាជន និងកាសែតបញ្ជាសីលា ជាកម្លាំងបង្កប់របស់បក្សពលករកម្ពុជា នៅក្នុងទីក្រុងភ្នំពេញ ព្រមទាំងប្រពន្ធឈ្មោះអ៊ឹម ណៃន ហៅលី បានចាកចេញពីក្រុងភ្នំពេញ ទៅធ្វើបដិវត្តន៍នៅមន្ទីរ១០០នោះដែរ។ សមមិត្តនារី អ៊ឹម ណៃន ហៅលី ជាអ្នកដាំស្ល និងបម្រើបាយទឹកសម្រាប់សាឡុត ស និងអៀង សារី។ ដោយសារបានបំពេញតួនាទីជាចុងភៅសម្រាប់មេដឹកនាំកំពូលបានល្អ នឹងស្មោះត្រង់បំផុតនោះ សមមិត្តនារី អ៊ឹម ណៃន ហៅលី ត្រូវសាឡុត ស និងអៀង សារី ឱ្យចូលជាបក្ខជននៅក្នុងឆ្នាំ១៩៦៦។

ប៉ុន្តែ ក្រោយពីពួកខ្មែរក្រហមទទួលបានជ័យជម្នះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូ ដេត ហៅ សមមិត្តស៊ី ជាលេខាគណៈកម្មាធិការបក្សភូមិភាគបស្ចិម ត្រូវប៉ុល ពត (សាឡុត ស) ឱ្យគេចាប់មកដាក់មន្ទីរ ស.២១(គុកទួលស្លែង) ជាមួយនឹងប្រពន្ធឈ្មោះ អ៊ឹម ណៃន ហៅលី នោះ នៅចុងខែមីនា ឆ្នាំ១៩៧៨។

ក្រោយពីទទួលរងនូវការធ្វើទារុណកម្មយ៉ាងសាហាវឃោរឃៅ នៅមន្ទីរ ស.២១ នោះមក នៅទីបំផុត អ៊ឹម ណៃន ហៅលី បានសារភាពថា គាត់បានព្យាយាមប៉ុនប៉ងដាក់ថ្នាំពុលដើម្បីសម្លាប់ប៉ុល ពត (សាឡុត ស) តាំងពីពេលគាត់ធ្វើចុងភៅនៅមន្ទីរ១០០នោះមកម្ល៉េះ តែពុំបានសម្រេច។

# ១៧៨
# សាឡុត ស ធ្វើដំណើរទៅក្រុងហាណូយ



**សាឡុត ស ជួបជាមួយ ហូ ជីមិញ ឆ្នាំ១៩៦៥**

នៅក្នុងខែមីនា ឆ្នាំ១៩៦៥ សហរដ្ឋអាមេរិក បានបញ្ជូនកងទ័ពថ្មើរជើងជាទ្រង់ទ្រាយធំទៅកាន់វៀតណាមភាគខាងត្បូង និងបន្តទម្លាក់គ្រាប់បែកទៅលើវៀតណាមខាងជើងយ៉ាងខ្លាំងក្លាបំផុត។

នេះគឺជាការឆ្លើយតបចុងក្រោយរបស់សហរដ្ឋអាមេរិក ទៅលើជោគជ័យរបស់ពួកកុម្មុយនិស្តវៀតណាម បន្ទាប់ពីមានព្រឹត្តិការណ៍រដ្ឋប្រហារសម្លាប់ប្រធានាធិបតី ង៉ូ ឌិញយៀម កាលពីខែវិច្ឆិកា ឆ្នាំ១៩៦៣មក។

ពេលនោះមេដឹកនាំវៀតណាមខាងជើង បានចេញសេចក្តីថ្លែងការណ៍មួយថា សហរដ្ឋអាមេរិក បានព្យាយាមបំផ្លាញនយោបាយអព្យាក្រឹតរបស់សម្តេចសីហនុ និងប្រែក្លាយប្រទេសនេះ ឲ្យទៅជាមូលដ្ឋានសឹកមួយសម្រាប់ឡោមព័ទ្ធ និងបង្ក្រាបចលនាតស៊ូបដិវត្តន៍នៅវៀតណាម ភាគខាងត្បូង។

## របត់នយោបាយ

ក្នុងខែមេសា ឆ្នាំ១៩៦៥ សាឡុត ស អមដំណើរដោយ កែវ មាស និងអ៊ុំ ណេង ហៅ សមមិត្តវី ឬសមមិត្តវ៉ង់ ដោយមានកងទ័ពវៀតណាមខាងជើងជាច្រើននាក់ ជាអ្នកនាំផ្លូវផងដែរ បានធ្វើដំណើរចាកចេញពីមន្ទីរ១០០ តាមផ្លូវលំ ហូ ជីមិញ កាត់តំបន់ព្រៃភ្នំ ទៅទីក្រុងហាណូយ ប្រទេសវៀតណាមខាងជើង។

នៅទីក្រុងហាណូយ សាឡុត ស និងកែវ មាស បានជួបអតីតមេដឹកនាំបក្សប្រជាជនបដិវត្តន៍ខ្មែរ តាំងពីសម័យតស៊ូប្រឆាំងនឹងបារាំង គឺ សឺង ង៉ុកមិញ (ហៅអាចារ្យមៀន)និង កែវ មុនី (ហៅសមមិត្តម៉ៅ) ដែលបានដឹកនាំកងទ័ពខ្មែរឥស្សរៈ ប្រមាណជាង១០០០នាក់ ចាកចេញពីប្រទេស ទៅរស់នៅវៀតណាមខាងជើង ក្រោយពីមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ នោះដែរ។

សាឡុត ស សង្ឃឹមថា មេដឹកនាំវៀតណាមខាងជើង ពិសេស ឡេ យន់ លេខាបក្សពលករវៀតណាម គាំទ្រការតស៊ូដោយអាវុធរបស់គាត់នៅកម្ពុជា ព្រមទាំងផ្តល់អាវុធយុទ្ធភណ្ឌសមតាមបំណងរបស់គាត់ជាមិនខាន ព្រោះមុនពេលគាត់ធ្វើដំណើរមកទីក្រុងហាណូយនេះ មេដឹកនាំវៀតណាមខាងជើង បានចេញសេចក្តីថ្លែងការណ៍មួយចំនួនពីសភាពការណ៍ និងក្រឹត្យក្រមនៃការធ្វើបដិវត្តន៍នៅកម្ពុជា និងនៅឥណ្ឌូចិនទាំងមូល ដោយបានឆ្លុះបញ្ចាំងពីការដំឡើងថ្នាក់សង្គ្រាមរបស់អាមេរិក ដើម្បីកម្ទេចការបះបោរពួកកុម្មុយនិស្តវៀតណាមនៅភាគខាងត្បូង និងការដាក់ទណ្ឌកម្មដល់វៀតណាមភាគខាងជើង ដែលបានគាំទ្ររណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (វៀតកុង)។

ពេល សាឡុត ស ទៅដល់ទីក្រុងហាណូយ ដំបូង មេដឹកនាំវៀតណាមខាងជើង បានប្រាប់គាត់ថា អាមេរិក មានផែនការអាក្រក់ធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ដូច្នេះបក្សពលករខ្មែរ ត្រូវរៀបចំខ្លួន ដើម្បីឈានទៅប្រើហិង្សាបដិវត្តន៍ ដោយយកគំរូតាមការតស៊ូរបស់រណសិរ្សរំដោះជាតិវៀតណាមខាងត្បូង (វៀតកុង)។

មេដឹកនាំវៀតណាមខាងជើង មានការព្រួយបារម្ភខ្លាំងចំពោះការគំរាមកំហែងរបស់សហរដ្ឋអាមេរិក ដែលមានបំណងដណ្តើមកាន់កាប់តំបន់តាយង្វៀន របស់វៀតណាម មុន

នឹងឈានទៅកាន់កាប់តំបន់ខ្ពង់រាបព្រៃសានកម្ពុជា ហើយចាត់តាំងជនជាតិភាគតិចនៅសងខាងព្រំដែនប្រទេសទាំងពីរ ជាកម្លាំងជំនួយ ដើម្បីវាយប្រហាររណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (វៀតកុង) ពីក្រោយខ្នង។


វ៉ ង្វៀនយ៉ាប់ រដ្ឋមន្ត្រីការពារប្រទេស

រដ្ឋមន្ត្រីការពារប្រទេសវៀតណាមខាងជើង វ៉ ង្វៀនយ៉ាប់ បានប្រកាសថា សហរដ្ឋអាមេរិក ជាគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរបំផុតសម្រាប់សន្តិសុខប្រជាជននៅក្នុងប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះ វៀតណាមខាងជើង សង្ឃឹមថា ការចូលរួមរបស់ប្រជាជននៅគ្រប់ទិសទីក្នុងចលនាប្រឆាំងការគំរាមកំហែងរបស់ចក្រពត្តិអាមេរិក នឹងធ្វើឱ្យបដិវត្តន៍វៀតណាមខាងត្បូង ទទួលជោគជ័យជាមិនខាន។

វ៉ ង្វៀនយ៉ាប់ បានសម្តែងមោទកភាពថា ការពុះកញ្ជ្រោលក្នុងចលនាតស៊ូដោយអាវុធរបស់ពួកគាត់នៅវៀតណាមភាគខាងត្បូង មិនពឹងផ្អែកលើប្រទេសដទៃទេ គឺពឹងផ្អែកលើកម្លាំងរបស់វៀតណាមផ្ទាល់ ឈរលើស្មារតីខ្លួនទីពឹងខ្លួន តាំងពីមានតែកាំភ្លើងហួសសម័យ និងមានតែចម្រូងឫស្សី ក្លាយទៅជាកងទ័ពប្រជាជន ដោយវាយដណ្តើមអាវុធពីខ្មាំង ដើម្បីយកមកបំពាក់ឲ្យខ្លួនឯង ធ្វើសង្គ្រាមឈ្លប និងបន្ទាប់មក កសាងកម្លាំងទ័ពមួយ ដ៏ខ្លាំងពូកែបំផុត។

ចំណែក ទ្រឿង ជិញ សមាជិកគណៈអចិន្ត្រៃយ៍មជ្ឈិមបក្សពលករវៀតណាម និងជាប្រធានរដ្ឋសភាវៀតណាមខាងជើង បានពិភាក្សាជាមួយ សាឡុត ស ថា ជនបដិវត្តន៍នៃអតីតប្រទេសអាណានិគមទាំងឡាយ ត្រូវរៀបចំខ្លួនឲ្យបានឆាប់រហ័ស ដើម្បីធ្វើការតស៊ូដោយអាវុធ និងធ្វើសង្គ្រាមបដិវត្តន៍។

## របត់នយោបាយ

ទ្រឿង ជិញ បានបញ្ជាក់បន្ថែមថា សង្គ្រាមប្រជាជន គឺជាផ្លូវឆ្ពោះទៅមុខសម្រាប់ជនបដិវត្តន៍នៅក្នុងប្រទេសទាំងឡាយណា ដែលមានប្រជាជនតិច ទឹកដីតូច និងសេដ្ឋកិច្ចអន់ថយ។ ជាមួយសង្គ្រាមប្រជាជន យើងអាចវាយប្រយុទ្ធ ធ្វើឲ្យខ្មាំងដែលខ្លាំងក្លាលើសលុបជាងយើង ឱ្យបរាជ័យបាន។

ជាការពិតណាស់ ជាឯកជនមេដឹកនាំបក្សពលកររៀតណាម និយាយជាមួយ សាឡុត ស ជំរុញឱ្យតស៊ូដោយអាវុធ។ ប៉ុន្តែនៅក្នុងអង្គប្រជុំមួយនាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៦៥ បន្ទាប់ពី សាឡុត ស បានលើកឡើងកម្មវិធីនយោបាយរបស់បក្សពលករកម្ពុជា និងស្នើសុំអាវុធ ដើម្បីធ្វើការតស៊ូដោយអាវុធមក ឡេ យន់ លេខាបក្សពលកររៀតណាម បានសម្តែងការចាប់អារម្មណ៍ជាខ្លាំងទៅលើកម្មវិធីនយោបាយរបស់បក្សពលករកម្ពុជា តែចំពោះបញ្ហាស្នើសុំអាវុធ ដើម្បីធ្វើការតស៊ូដោយអាវុធ ឡេ យន់ បានផ្តល់អនុសាសន៍ថា បក្សពលករកម្ពុជា ត្រូវបង្កើតមូលដ្ឋានបដិវត្តន៍នៅជនបទតាមរយៈចលនាមហាជន ដោយមិនចាំបាច់មានអាវុធទេ។

ជាមួយគ្នានោះ ត្រូវបញ្ជ្រាបខ្លួនទៅក្នុងរដ្ឋសភា និងក្នុងរាជរដ្ឋាភិបាល ដើម្បីត្រៀមខ្លួនដណ្តើមអំណាច តាមរយៈការតស៊ូដោយអាវុធ ក្រោយពេលរណសិរ្សជាតិរំដោះរៀតណាមខាងត្បូង (រៀតកុង)ឈ្នះសង្គ្រាម នៅរៀតណាមខាងត្បូង។

ឡេ យន់ បានបញ្ជាក់ប្រាប់ សាឡុត ស ថា ការបង្កើតមូលដ្ឋានបដិវត្តន៍នៅជនបទតាមរយៈចលនាមហាជននេះ ក្នុងទិសដៅធ្វើឱ្យកម្ពុជា ត្រៀមខ្លួនជាស្រេច ដើម្បីចាប់កាន់អាវុធងើបឡើងជាមួយរៀតណាម ក្នុងការតស៊ូដោយអាវុធនៅកម្ពុជា។

ឡេ យន់ លើកហេតុផលថា ប្រសិនបើ សម្តេចសីហនុ ត្រូវបានគេទម្លាក់ចេញពីអំណាចដោយពួក លន់ នល់ នោះ សហរដ្ឋអាមេរិក នឹងប្រើប្រាស់ទឹកដីប្រទេសកម្ពុជា ធ្វើជាមូលដ្ឋានសឹករបស់គេ ដើម្បីប្រឆាំងនឹងបដិវត្តន៍រៀតណាម។ ដូច្នេះ គន្លឹះសំខាន់ គឺចក់ឱកាស និងជំរុញឱ្យសម្តេចសីហនុ និងមហាជនប្រឆាំងចក្រពត្តិអាមេរិក បន្តទៀត ដើម្បីពង្រីកចលនាកុម្មុយនិស្តនៅជនបទ និងនៅក្នុងជួររាជរដ្ឋាភិបាល។ បន្ទាប់មក នៅពេលរៀតណាម ទទួលបានជ័យជម្នះនៅភាគខាងត្បូង ឬសម្តេចសីហនុ ត្រូវគេទម្លាក់ចេញពី

អំណាចពេលនោះ ដោយមានជំនួយយោធាពីវៀតណាម (វៀតណាមកុម្មុយនិស្ត) បក្សពលករកម្ពុជា ប្រាកដជាមានលទ្ធភាពធ្វើការតស៊ូដោយអាវុធ ដើម្បីដណ្តើមអំណាចបានជោគជ័យជាមិនខាន។

ឡេ យន់ សង្កត់ធ្ងន់ថា ហេតុផលនេះ បានឈរលើមូលដ្ឋាននៃការវិភាគមួយបញ្ជាក់ថា តុល្យភាពនៃកម្លាំងនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃនេះ មិនអំណោយផលដល់ការផ្តួលរម្លំរបបសក្តិភូមិទេ ហើយការផ្តួលរម្លំសម្តេចសីហនុ នឹងធ្វើឲ្យខូចប្រយោជន៍ដល់បដិវត្តន៍ឥណ្ឌូចិន ទាំងមូលតែម្តង។



**ឡេ យន់ លេខាបក្សពលករវៀតណាម**

ឡេ យន់ លេខាបក្សពលករវៀតណាម បានឯកភាពចំពោះការលើកឡើងរបស់ សាឡុត ស លេខាបក្សពលករកម្ពុជា ដែលថា ប្រទេសកម្ពុជា កំពុងរងគ្រោះដោយការឈ្លានពានរបស់សហរដ្ឋអាមេរិក ជាពួកអាណានិគមនិយមបែបថ្មី តែ ឡេ យន់ បានបញ្ជាក់ប្រាប់ សាឡុត ស ថា ទោះបីជាសម្តេចសីហនុ មាននយោបាយការទូតប្រឆាំងចក្រពត្តិអាមេរិក ក៏ពិតមែន ប៉ុន្តែ ពេលថ្មីៗកន្លងទៅនេះមានរឿងរ៉ាវមួយចំនួន បង្ហាញថា នៅក្នុងព្រះទ័យសម្តេចសីហនុ នៅតែចង់រក្សាទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក នៅឡើយ។ តែយ៉ាងណា ក៏បក្សពលករកម្ពុជា ដែលចង់ធ្វើយ៉ាងណាជំរុញឲ្យសម្តេចសីហនុ ប្រឆាំងនឹងចក្រពត្តិអាមេរិក និងអាយ៉ងរបស់វានៅក្នុងប្រទេសកម្ពុជានោះ គឺជារឿងត្រឹមត្រូវហើយ។

ឡេ យន់ បានផ្តល់យោបល់ទៅ សាឡុត ស ថា យកល្អ បក្សពលករកម្ពុជា ត្រូវយក

ព្រះកិត្តិនាមសម្ដេចសីហនុ ដើម្បីបំផុសអំពាវនាវដល់មហាជនខ្មែរទូទាំងប្រទេស ឱ្យក្រោកឡើងប្រឆាំងចក្រពត្តិអាមេរិក និងពួកខ្ញុំកញ្ជះវា។

ឡេ យន់ បានស្នើសុំ សាឡុត ស លេខាបក្សពលករកម្ពុជា កុំទាន់ធ្វើការតស៊ូដោយអាវុធធ្វើអ្វី គឺត្រូវរង់ចាំការតស៊ូបដិវត្តន៍វៀតណាម ទទួលបានជ័យជម្នះលើរបបរដ្ឋការវៀតណាមខាងត្បូង សិន ហើយថា នៅពេលបដិវត្តន៍វៀតណាម បានជ័យជម្នះនោះ បដិវត្តន៍កម្ពុជា ក៏នឹងទទួលបានជ័យជម្នះជាស្វ័យប្រវត្តិដែរ។

ឡេ យន់ បានលើកហេតុផលថា៖ បដិវត្តន៍វៀតណាម ត្រូវរង់ចាំរហូតដល់បដិវត្តន៍ចិន ទទួលបានជ័យជម្នះ(ឆ្នាំ១៩៤៩) ទើបបដិវត្តន៍វៀតណាម ទទួលបានជ័យជម្នះលើបារាំង(ឆ្នាំ១៩៥៤)ដែរ ដូច្នេះកម្ពុជា ក៏ត្រូវរង់ចាំជ័យជម្នះរបស់បដិវត្តន៍វៀតណាម នៅភាគខាងត្បូង សិនដែរ ទើបបដិវត្តន៍របស់កម្ពុជា ទទួលបានជ័យជម្នះជាស្វ័យប្រវត្តិ។

ឡេ យន់ បានបញ្ជាក់ប្រាប់ សាឡុត ស ថា៖ ទំនាស់សំខាន់ជាងគេនៅក្នុងសកលលោក គឺទំនាស់រវាងសង្គមនិយម ជាមួយពួកចក្រពត្តិនិយម មិនមែនទំនាស់រវាងប្រជាជនដែលត្រូវគេជិះជាន់ជាមួយពួកចក្រពត្តិនិយម ដូចកម្ពុជា បានលើកឡើងនោះទេ។

ឡេ យន់ បានបញ្ជាក់ប្រាប់ សាឡុត ស ម្ដងទៀតថា នៅក្នុងសភាពការណ៍បច្ចុប្បន្ននេះ អ្វីដែលសំខាន់ គឺសាមគ្គីអន្តរជាតិ ហើយយ៉ាងហោចណាស់ យើងកុំធ្វើឱ្យប៉ះពាល់ដល់សម្ដេចសីហនុ ឱ្យសោះ។

យោងតាមប្រភពពីបក្សពលករវៀតណាម បានឲ្យដឹងថា ពេលនោះ សាឡុត ស មិនបានតវ៉ានឹងមតិណែនាំរបស់ ឡេ យន់ នោះទេ។

ប៉ុន្តែ ក្រោយមក បើតាមការរៀបរាប់របស់ សាឡុត ស បានឱ្យដឹងថា ពេលនោះ ទោះបីរូបគាត់បានអត់ធ្មត់រក្សាការស្ងៀមស្ងាត់ចំពោះមុខ ឡេ យន់ ក៏ដោយ ក៏គាត់គិតនៅក្នុងចិត្តថា គាត់ដាច់ខាតនៅតែឈរលើគោលជំហរឯករាជ្យភាព និងអធិបតេយ្យភាពក្នុងការទាក់ទងជាមួយបក្សពលករវៀតណាម ព្រមទាំងកំណត់មាគ៌ានយោបាយមួយដោយខ្លួនឯង មានន័យថា គាត់មិនមែនចេះតែធ្វើតាមមតិណែនាំរបស់បក្សពលករវៀតណាម គ្រប់

បញ្ហានោះទេ ពិសេសបើមានលទ្ធភាព គាត់នឹងដឹកនាំធ្វើសកម្មភាពតស៊ូដោយអាវុធ ឱ្យពេញទំហឹងតែម្តង។

មេដឹកនាំវៀតណាមកុម្មុយនិស្ត មិនចង់ឱ្យ សាឡុត ស ធ្វើការតស៊ូបដិវត្តន៍ដោយយោធាទេ ព្រោះខ្លាចពួកគេមានបញ្ហាជាមួយសម្តេចសីហនុ ដែលបានអនុញ្ញាតឱ្យកងទ័ពរបស់ពួកគេបោះទីតាំងនៅក្នុងទឹកដីខ្មែរ ដើម្បីធ្វើសង្គ្រាមផ្តួលរម្លំរបបរដ្ឋការវៀតណាមខាងត្បូង។ តែ សាឡុត ស មិនសប្បាយចិត្តចំពោះមេដឹកនាំវៀតណាមកុម្មុយនិស្ត ដែលមិនព្រមឱ្យគាត់ធ្វើការតស៊ូដោយអាវុធនៅកម្ពុជា នោះឡើយ។

ដើម្បីបញ្ជាក់ឲ្យឃើញថា តើវៀតណាម បានធ្វើពលិកម្មអ្វីខ្លះក្នុងការជួយជ្រោមជ្រែងដល់ការតស៊ូរបស់បដិវត្តន៍ខ្មែរនោះ ឡេ យន់ បានអញ្ជើញ សាឡុត ស ទៅមើលឯកសារជាច្រើននៅក្នុងសារមន្ទីរមួយ ដែលវៀតណាម បានរក្សាទុកតាំងកាលពីសម័យតស៊ូប្រឆាំងពួកអាណានិគមបារាំង មកម្ល៉េះ។ សាឡុត ស បានចំណាយពេលជាច្រើនថ្ងៃ ដើម្បីអានឯកសារទាំងនោះយ៉ាងល្អិតល្អន់បំផុត។

ទាក់ទងដល់ការអានឯកសារខាងលើនេះ មកដល់សម័យតស៊ូធ្វើសង្គ្រាមផ្តួលរម្លំរបបសាធារណរដ្ឋខ្មែរ ក្រោយរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ឆ្នាំ១៩៧០ សាឡុត ស បានពន្យល់និងអប់រំដល់ពួកកម្មាភិបាលរបស់គាត់ថា ក្រោយពីបានអានឯកសារទាំងនោះយ៉ាងល្អិតល្អន់មក គាត់បានធ្វើការវាយតម្លៃថា តាំងពីឆ្នាំ១៩៣០ មក ប្រទេសកម្ពុជា និងឡាវ ប្រៀបដូចជាមែកធាងរបស់បក្សវៀតណាម ហើយបក្សទាំង២នេះ គ្រាន់តែជាអ្នកអនុវត្តគោលមាគ៌ានយោបាយ និងយុទ្ធសាស្ត្ររបស់បក្សវៀតណាម តែប៉ុណ្ណោះ។

សាឡុត ស បញ្ជាក់ថា៖ មុនពេលខ្ញុំបានឃើញឯកសារទាំងអស់នោះដោយផ្ទាល់ ខ្ញុំជឿទុកចិត្តលើវៀតណាម។ ប៉ុន្តែ ក្រោយពីបានអានឯកសារទាំងអស់នោះមក ខ្ញុំឈប់ជឿគេទៀតហើយ ខ្ញុំគិតថា គេបានចាត់តាំងអង្គការបក្សនៅក្នុងស្រុកយើង ដើម្បីសម្រេចទិសដៅយុទ្ធសាស្ត្រតែមួយ គឺសហព័ន្ធឥណ្ឌូចិន។ គេបានបង្កើតបក្សតែមួយ ដើម្បីតំណាងឲ្យទឹកដីដែលបញ្ចូលគ្នាតែមួយ។

# ១៧៩
# សាឡុត ស ទៅបំពេញទស្សនកិច្ច
# នៅសាធារណរដ្ឋប្រជាមានិតចិន



**មេដឹកនាំចិន ជូ អេនឡាយ, ម៉ៅ សេទុង និងលីន ពៀវ**

ក្រោយពេលស្នាក់នៅក្នុងប្រទេសវៀតណាមខាងជើង អស់រយៈពេល៩ខែមក សាឡុត ស ត្រូវបានអនុញ្ញាតឲ្យទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន បន្តទៀត។ នៅទីក្រុងប៉េកាំង គាត់មានការចាប់អារម្មណ៍ជាខ្លាំងចំពោះកូនសៀវភៅក្រហម របស់ម៉ៅ សេទុង ដែលទើបត្រូវបានបោះពុម្ព សាជាថ្មីឡើងវិញ ហើយអ្វីដែលធ្វើឱ្យគាត់ចាប់អារម្មណ៍ជាងនេះទៅទៀត គឺសៀវភៅឯកសារមួយមានចំណងជើងថា យុទ្ធសាស្ត្រនៃការធ្វើសង្គ្រាមប្រជាជន។

សៀវភៅឯកសារដែល សាឡុត ស យល់ថាមានសារៈសំខាន់ និងអត្ថន័យធំធេង សម្រាប់គាត់ដើម្បីយកទៅអនុវត្តក្នុងការដឹកនាំតស៊ូដោយអាវុធនៅក្នុងប្រទេសកម្ពុជា នោះជាស្នាដៃនិពន្ធរបស់ លីន ពៀវ ជារដ្ឋមន្ត្រីក្រសួងការពារជាតិចិន បូកបញ្ចូលគ្នាជាមួយទ្រឹស្តីរបស់ ម៉ៅ សេទុង បោះពុម្ពផ្សាយក្នុងខែកញ្ញា ឆ្នាំ១៩៦៥ ។

ក្នុងសៀវភៅឯកសារនោះ លីន ពៀវ បានសរសេរថា ដើម្បីធ្វើសង្គ្រាមប្រជាជន ទទួលបានជោគជ័យ ចលនាកុម្មុយនិស្តទាំងឡាយត្រូវប្រើយុទ្ធសាស្ត្រ៤ជាសំខាន់ គឺ៖

ទី១.ត្រូវបង្កើតរណសិរ្សរួបរួមជាតិមួយ ដោយប្រមូលកម្លាំងប្រជាជន និងអ្នកនយោបាយទាំងអស់ ដែលគាំទ្រដល់ការតស៊ូប្រឆាំងចក្រពត្តិនិយម ឱ្យមកចូលរួម។

ទី២.ត្រូវពឹងផ្អែកលើកម្លាំងកសិករ ដើម្បីកសាងមូលដ្ឋានបដិវត្តន៍នៅតំបន់ជនបទ និងយកតំបន់ជនបទដើម្បីឡោមព័ទ្ធទីក្រុង ហើយនៅទីបញ្ចប់ដណ្តើមកាន់កាប់ទីក្រុងទាំងអស់។

ទី៣.ត្រូវបង្កើតកងទ័ពប្រជាជន ដែលជាកម្លាំងប្រយុទ្ធ ព្រមគ្នានឹងការបង្កើតកម្លាំងនយោបាយ ដើម្បីឃោសនាផ្សព្វផ្សាយមាគ៌ាបដិវត្តន៍ក្នុងចំណោមមហាជន ដើម្បីឱ្យពួកគេចូលបម្រើក្នុងជួរកងទ័ពប្រជាជន ហើយចាត់តាំង និងបំពាក់អាវុធដល់ពួកគេ ព្រមទាំងជួយពួកគេឲ្យបង្កើតរដ្ឋអំណាចបដិវត្តន៍ និងអង្គភាពផលិតកម្មផងដែរ។

ទី៤.កិច្ចការទាំងអស់នេះ ត្រូវឈរជាសំខាន់លើកម្លាំងផ្ទាល់ខ្លួន ជាមួយការខិតខំដើម្បីអូសទាញការគាំទ្រពីសំណាក់បរទេស ឲ្យបានច្រើនបំផុត តាមដែលអាចធ្វើទៅបាន។

សៀវភៅរបស់សេនាប្រមុខ លីន ពៀវ បានពណ៌នាថា ទ្រឹស្តីរបស់ ម៉ៅ សេទុង មានសារៈសំខាន់ជាទីបំផុត សម្រាប់ប្រទេសជាតិ ដែលកំពុងរងនូវការជិះជាន់ ក្នុងការទប់ទល់ជាមួយការឈ្លានពានរបស់ពួកចក្រពត្តិនិយម និងជាទ្រឹស្តីមួយ ដែលអាចយកទៅអនុវត្តបាន សម្រាប់ប្រទេសពាក់កណ្តាលអាណានិគមនិយម និងពាក់កណ្តាលសក្តិភូមិនិយម ដែលជាប្រទេសទន់ខ្សោយ ដើម្បីយកជ័យជន្នះលើប្រទេសចក្រពត្តិនិយម ដែលជាប្រទេសខ្លាំងបាន។

យុទ្ធសាស្ត្រសង្គ្រាមប្រជាជននេះ មិនត្រឹមតែធ្វើបាននៅប្រទេសចិន ប៉ុណ្ណោះទេ តែវាក៏ជាការរួមចំណែកមួយដ៏ធំធេងដល់ការតស៊ូចំពោះប្រជាជាតិ និងប្រជាជនដែលទទួលរងនូវការជិះជាន់នៅទូទាំងពិភពលោកផងដែរ។ យុទ្ធសាស្ត្រនេះក៏ជាអាវុធមួយ ដែលបានក្លាយទៅជាតម្រូវការជាបន្ទាន់ សម្រាប់ប្រទេសជាតិ ដែលត្រូវគេជិះជាន់ និងការបង្ក្រាបដោយអាវុធ ដើម្បីម្ចាស់ការ និងយកទៅអនុវត្ត ក្នុងការប្រឆាំងចក្រពត្តិនិយមអាមេរិក និង



សេនាប្រមុខ លីន ពៀវ

ពួកអាយ៉ងរបស់វា។

ក៏ប៉ុន្តែ ក្នុងអំឡុងពេលរង់ចាំបង្កើតមូលដ្ឋានបដិវត្តន៍នៅតំបន់ជនបទ វាក៏មានសារៈ សំខាន់ក្នុងការយកទៅអនុវត្តសម្រាប់ការតស៊ូបដិវត្តន៍របស់ប្រជាជាតិ និងប្រជា-ជន ដែលទទួលរងនូវការជិះជាន់ទាំងអស់នៅអាស៊ី អាហ្វ្រិក និងនៅអាមេរិកឡាទីន ក្នុងពេលបច្ចុប្បន្ន នេះដែរ។

សៀវភៅរបស់សេនាប្រមុខ លីន ពៀវ បានពណ៌នាបន្តថា ជាឧទាហរណ៍ជាក់ស្តែង នាពេលបច្ចុប្បន្ននេះ នៅប្រទេសវៀតណាម បក្សពលករវៀតណាម បានយកទ្រឹស្តីនេះទៅអនុវត្តយុទ្ធសាស្ត្រសង្គ្រាមប្រជាជនយ៉ាងត្រឹមត្រូវ និងធ្វើឲ្យចក្រពត្តិអាមេរិកទទួលបរាជ័យជាមិនខាន។

អត្ថបទឯកសារនៅក្នុងសៀវភៅនោះ បានលើកឡើងដែរថា នៅឥណ្ឌូចិន ពួកចក្រពត្តិអាមេរិក បានពង្រីកសង្គ្រាមកាន់តែធំឡើងៗ ដើម្បីស្រោចស្រង់បរាជ័យរបស់ពួកគេ។ តែការពង្រីកសង្គ្រាមនេះ នឹងនាំឲ្យប្រជាជាតិដទៃទៀត យល់ឃើញថា ដោយបានរៀនសូត្រពីការធ្វើសង្គ្រាមប្រជាជននេះ អ្វីៗ ក៏ពួកគេអាចធ្វើបានដូចប្រជាជនវៀតណាម បានធ្វើមកហើយនោះដែរ។

កាលណាពេលវេលាមកដល់ហើយ ពួកគេនឹងងើបឡើង ដើម្បីធ្វើសង្គ្រាមនេះ។ បើចាំបាច់ ពួកគេនឹងចាប់ផ្តើមពីបាតដៃទទេ ដោយប្រើតែដាវកញ្ចាស់ៗ ចម្រូង ស្នា កាំភ្លើងហួសសម័យប៉ុណ្ណោះ។ ពួកគេត្រូវរៀនសូត្រពីមេរៀនយុទ្ធសាស្ត្រសង្គ្រាមប្រជាជន ដែលបក្សពលករវៀតណាម កំពុងអនុវត្ត ដើម្បីតស៊ូប្រឆាំងការឈ្លានពានរបស់ចក្រពត្តិអាមេរិក និង

រំដោះប្រជាជនវៀតណាមភាគខាងត្បូង ផងដែរ។

ដោយសារបានអានអត្ថបទឯកសារនៅក្នុងសៀវភៅយុទ្ធសាស្ត្រសង្គ្រាមប្រជាជន របស់សេនាប្រមុខ លីន ពៀវ នោះ ធ្វើឲ្យ សាឡុត ស កាន់តែមានទឹកចិត្តពុះកញ្ជ្រោលខ្លាំងឡើងៗក្នុងការតស៊ូដោយអាវុធ។ តែមេដឹកនាំចិន ម៉ៅ សេទុង និងជូ អេនឡាយ ក៏មិនខុសពីមេដឹកនាំវៀតណាម ដែរ គឺពួកគេមិនយល់ស្របតាមគំនិត សាឡុត ស ដែលមានបំណងតស៊ូបដិវត្តន៍ដោយអាវុធ នៅកម្ពុជា នោះទេ។

នៅក្រុងប៉េកាំង សាឡុត ស បានចូលជួបពិភាក្សាគ្នាជាមួយ ម៉ៅ សេទុង, លីវ ចាវជី និងតេង ស៊ាវពីង ជាសម្ងាត់ ដើម្បីសុំការគាំទ្រដល់ការតស៊ូដោយអាវុធរបស់គាត់នៅកម្ពុជា។ តែមេដឹកនាំចិន មានការថ្លឹងថ្លែងចំពោះការគាំទ្រ សាឡុត ស មេដឹកនាំបក្សពលករកម្ពុជា និងទំនាក់ទំនងការទូតជាមួយសម្តេចសីហនុ ជាប្រមុខរដ្ឋនៃប្រទេសកម្ពុជា ផងដែរ។ សូម្បីតែ យ៉ាវ វិនយាន ជាសមាជិកម្នាក់ដែលដាច់ខាតជាងគេបំផុត ក្នុងចំណោមបនទាំងបួននៃចលនាបដិវត្តន៍វប្បធម៌ ក៏មិនគាំទ្រឱ្យ សាឡុត ស ធ្វើការតស៊ូដោយអាវុធ ដើម្បីប្រឆាំងនឹងសម្តេចសីហនុ ដែរ។

ទីបំផុត ដូចមេដឹកនាំវៀតណាមដែរ មេដឹកនាំចិន នៅតែគាំទ្របក្សពលករកម្ពុជា តែមិនអាចផ្តល់អាវុធដល់កងទ័ពតស៊ូខ្មែរកុម្មុយនិស្ត តាមការស្នើសុំរបស់ សាឡុត ស លេខាបក្សពលករកម្ពុជា បានទេ ពិសេស គឺ ចិន បានប្រកាន់គោលជំហរថា នៅកម្ពុជា ក្រៅសម្តេចសីហនុ ខ្លួនមិនអាចផ្តល់អាវុធឱ្យភាគីណាមួយទៀតបានឡើយ។ ដូច្នេះ ការជួបពិភាក្សាគ្នាជាសម្ងាត់ ដែល សាឡុត ស ស្នើសុំឱ្យមេដឹកនាំចិន គាំទ្រដល់ការតស៊ូដោយអាវុធរបស់គាត់នៅកម្ពុជានោះ មិនទទួលបានលទ្ធផលអ្វីឡើយ។

មេដឹកនាំចិន យល់ថា ពេលនោះ សាឡុត ស ជាមេដឹកនាំចលនាកុម្មុយនិស្តខ្មែរ ក៏ពិតមែន តែគាត់បានរួមវិភាគទានបន្តិចបន្តួចប៉ុណ្ណោះនៅក្នុងការប្រឆាំងនឹងសហរដ្ឋអាមេរិកនៅអាស៊ី គឺមិនសំខាន់ ដូចសម្តេចសីហនុ និងវៀតណាមខាងជើង ជាសម្ព័ន្ធមិត្តរបស់ខ្លួនទេ ។

## របត់នយោបាយ

ក្រោយពេល ម៉ៅ សេទុង ចាប់ផ្តើមធ្វើ បដិវត្តន៍វប្បធម៌ បានរយៈពេលប្រមាណ៤ខែ សាឡុត ស ក៏បានវិលត្រលប់មកប្រទេសកម្ពុជា ដោយឆ្លងកាត់ប្រទេសវៀតណាម និងផ្លូវលំហូ ជីមិញ ដដែល។

មុនពេលចាកចេញពីទីក្រុងប៉េកាំង ត្រលប់មកប្រទេសកម្ពុជាវិញ មេដឹកនាំចិនបានរៀបចំពិធីជប់លៀងមួយ ជូនចំពោះគណៈប្រតិភូខ្មែរកុម្មុយនិស្ត ដែលដឹកនាំដោយ សាឡុត ស ដោយបានអញ្ជើញមន្ត្រីទូតវៀតណាមខាងជើង ចូលរួមដែរ។

ក្នុងពិធីជប់លៀងនោះ ម៉ៅ សេទុង ក៏បានកោតសរសើរដល់ចលនាតស៊ូខ្មែរកុម្មុយនិស្តនោះ ផងដែរ។

# ១៨០
# សម្តេចសីហនុ សរសើរចិន រិះគន់សហភាពសូវៀត



**សម្តេចសីហនុ និងមេដឹកនាំចិន នៅក្រុងប៉េកាំង ខែកញ្ញា ឆ្នាំ១៩៦៥**

នៅចុងខែឧសភា ឆ្នាំ១៩៦៥ សម្តេចសីហនុ បានប្រកាសឱ្យប្រជារាស្ត្ររបស់ព្រះអង្គ បានដឹងពីការរឹបអូសឯកសាររបស់ពួកកុម្មុយនិស្តមួយចំនួន នៅខេត្តកោះកុង ក្នុងនោះ ក៏មានឯកសារខ្លះមានសរសេរជាភាសាថៃ ផងដែរ។ ឯកសារទាំងនោះ បានសរសេរញុះញង់ អុជអាលប្រជារាស្ត្រ និងយុវជនឱ្យប្រឆាំងនឹងចលនាសង្គមរាស្ត្រនិយម និងព្រះអង្គផ្ទាល់ផងដែរ។

ព្រះអង្គបានបន្តថា ពួកចៅហ្វាយនាយរបស់ខ្មែរកុម្មុយនិស្ត មិនសប្បាយចិត្តនឹងវិធានការទាំងឡាយដែលព្រះអង្គធ្វើឡើង ដើម្បីផលប្រយោជន៍របស់ជាតិ ដូចជាការធ្វើជាតូបនីយកម្មធនាគារ, ការកែទម្រង់សេដ្ឋកិច្ច និងការទទួលយកជំនួយរបស់សហរដ្ឋអាមេរិកជាដើមនោះទេ ពីព្រោះវិធានការទាំងនេះ នឹងបង្កឱ្យមានការលំបាកដល់ពួកខ្មែរកុម្មុយនិស្ត

ដែលមានមហិច្ឆតាផ្តួលរម្លំព្រះអង្គ ដើម្បីដណ្តើមអំណាច ស្របតាមទ្រឹស្តីរបស់ពួកគេមួយឃ្លា ដែលបានលើកឡើងថា ត្រូវជម្រុះស្មៅនៅក្រោមជើងរបស់សីហនុ តែម្តង។

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៦៥ សម្តេចសីហនុ បានត្រាស់បង្គាប់ឱ្យ ភោគ ឆាយ ជាប្រធានសមាគមនិស្សិតខ្មែរ ដឹកនាំសមាជិកមួយក្រុម មានគ្នា១០ នាក់ទៅបំពេញទស្សនកិច្ចនៅប្រទេសចិន។

នៅថ្ងៃទី០៩ ខែសីហា ពេលកំពុងដឹកនាំគណៈប្រតិភូធ្វើទស្សនកិច្ចនៅក្រុងប៉េកាំងនោះ ភោគ ឆាយ បានផ្ញើសារទូរលេខមកថ្វាយសម្តេចសីហនុ ដោយអួតសរសើរពីបដិវត្តន៍នៅប្រទេសចិន ថា ប្រព័ន្ធអប់រំសិក្សាធិការនៅទីនោះ បានរៀបចំឡើងក្នុងគោលបំណង បង្កើតប្រភេទមនុស្សថ្មី និងការឱ្យតម្លៃពលកម្ម ដែលធ្វើដោយកម្លាំងកាយ ខ្លាំងជាងពលកម្ម ដែលធ្វើដោយប្រាជ្ញា។

១០ថ្ងៃក្រោយមក ព្រះអង្គបានប្រកាសបង្កើតកសិដ្ឋានមួយ ដែលឱ្យឈ្មោះថា កសិដ្ឋានយុវជនរាជសង្គមនិយមខ្មែរ នៅខេត្តបាត់ដំបង និងបានបញ្ជូនយុវជនមួយចំនួនឱ្យទៅដាំដុះដំណាំផ្សេងៗ និងចិញ្ចឹមសត្វនៅទីនោះ ផងដែរ។

ក្រោយមក សម្តេចសីហនុ បានថ្លែងជាសាធារណៈថា កន្លងមកយើងបានអនុវត្តប្រព័ន្ធអប់រំសិក្សាធិការ តាមបែបបស្ចិមប្រទេសទាំងដុល ធ្វើឱ្យយើងជួបប្រទះបញ្ហាសង្គមមួយចំនួន គឺពួកបញ្ញវន្តអត់ការងារធ្វើ និងធ្វើឱ្យបញ្ញវន្តយើងមានចំណេះដឹង និងសមត្ថភាពតិចជាងមនុស្សប្រភេទថ្មី ដែលនៅក្នុងប្រព័ន្ធអប់រំសិក្សាធិការនៅប្រទេសចិនផងដែរ។ ដូច្នេះយើងត្រូវតែធ្វើតាមគំរូរបស់ចិន ដោយចាំបាច់ត្រូវតែធ្វើកំណែទម្រង់ទាំងស្រុង ហើយព្រះអង្គបានស្នើសុំឱ្យថ្នាក់ដឹកនាំក្រសួងអប់រំ សិក្សាធិការជាតិ ហ៊ានវះកាត់បញ្ហាសំខាន់ៗជាបន្ទាន់ ព្រោះផលប្រយោជន៍របស់ប្រទេសជាតិ និងយុវជនខ្មែរ ត្រូវពឹងផ្អែកលើកំណែទម្រង់នេះ។

គួររម្លឹកថា នៅក្នុងអំឡុងពេលសម្តេចសីហនុ ស្វះស្វែងឱ្យមានសន្និសីទអន្តរជាតិមួយនៅក្រុងហ្សឺណែវ ដើម្បីធានាដល់បូរណភាព និងអព្យាក្រឹតភាពរបស់ប្រទេសកម្ពុជា កាលពីឆ្នាំ១៩៦៤ នោះ ក្នុងកិច្ចសម្ភាសជាមួយអ្នកឆ្លើយឆ្លងសារព័ត៌មាន ឡា ប្រាវដា ជាសារព័ត៌មាន

ផ្លូវការរបស់បក្សកុម្មុយនិស្តសូវៀត នៅថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៦៤ នោះ សម្តេចសីហនុ បានមានបន្ទូលថា៖ យើងធ្វើសេចក្តីសង្ឃឹមដ៏ធំធេងជាមួយសហភាពសូវៀត ហើយទីបំផុត យើងជឿជាក់ថា នឹងមានការកោះប្រជុំសន្និសីទនៅក្រុងហ្សឺណែវ ជាមិនខាន។ យើងសូមសម្តែងនូវកតញ្ញូតាធម៌ចំពោះសហភាពសូវៀត ដែលជាអ្នកការពារប្រជាជាតិតូចតាច។

លុះដល់សរទរដូវឆ្នាំ១៩៦៥ សម្តេចសីហនុ មានកម្មវិធីដឹកនាំគណៈប្រតិភូមួយក្រុម ទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន, សាធារណរដ្ឋប្រជាធិតេយ្យកូរ៉េ និងសាធារណរដ្ឋសង្គមនិយមសហភាពសូវៀត និងបណ្តាប្រទេសអឺរ៉ុប មួយចំនួនទៀត។

នៅចុងខែកញ្ញា និងដើមខែតុលា ដែលពេលនោះ សាឡុត ស (ប៉ុល ពត) កំពុងស្ថិតនៅទីក្រុងប៉េកាំងនៅឡើយ សម្តេចសីហនុ បានដឹកនាំគណៈប្រតិភូមួយក្រុមទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន និងចូលរួមក្នុងពិធីរម្លឹកខួបថ្ងៃជ័យជម្នះបដិវត្តន៍ចិន លើកទី១៦ (ថ្ងៃទី០១ តុលា ១៩៤៩ -០១ តុលា ១៩៦៥) ផងដែរ។

នៅក្នុងពិធីជប់លៀងជាកិត្តិយសមួយនាទីក្រុងប៉េកាំង នៅចំពោះវត្តមានមេដឹកនាំចិន និងបណ្តាអគ្គទូតប្រទេសនានា សម្តេចសីហនុ បានថ្លែងសង្កថា អបួតសរសើរពីចំណងមិត្តភាពខ្មែរ-ចិន ជាថ្មីទៀត និងបានថ្លែង( ទំនងជាចង់ដៀមដាមដល់សហភាពសូវៀត) ថា៖ មានមហាអំណាចមួយ ដែលនិយាយថា ខ្លួនជាមិត្តរបស់វៀតណាមខាងជើង និងជាអ្នក-ប្រឆាំងនឹងចក្រពត្តិអាមេរិកនោះ បែរជាទៅណែនាំវៀតណាមខាងជើង ឲ្យធ្វើការចរចាដោយគ្មានលក្ខខណ្ឌជាមួយចក្រពត្តិអាមេរិក ជាអ្នកឈ្លានពានទៅវិញ។

សម្តេចសីហនុ បានថ្លែងបញ្ជាក់ថា៖ គេមិនអាចចាត់ទុកអ្នកឈ្លានពាន និងអ្នករងគ្រោះក្នុងឋានៈស្មើគ្នាបានទេ។

ថ្ងៃទី៧ ខែតុលា ព្រះអង្គបានយាងបន្តទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋប្រជាធិតេយ្យកូរ៉េ (កូរ៉េខាងជើង)ទៀត។

ដោយសារសម្តេចសីហនុ បានថ្លែងសង្កថាអបួតសរសើរពីចំណងមិត្តភាពខ្មែរ-ចិន និងដៀមដាមដល់សហភាពសូវៀត នៅក្នុងពិធីជប់លៀងនៅទីក្រុងប៉េកាំង នោះហើយ ទើប



**លេខាបក្សសូវៀត នីគីតា គ្រូស្ចេវ ជួបសម្តេចសីហនុ នៅក្រុងញូវ យ៉ក ថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៦០**

បានជានៅថ្ងៃទី៨ ខែតុលា អ្នកការទូតសហភាពសូវៀត ប្រចាំទីក្រុងព្យុងយ៉ាង បានថ្វាយព័ត៌មានមកសម្តេចសីហនុ ថា មេដឹកនាំសហភាពសូវៀត ជាប់រវល់ខ្លាំងណាស់ ពុំអាចមានលទ្ធភាពធ្វើពិធីទទួលស្វាគមន៍ព្រះអង្គតាមកម្មវិធីដែលបានគ្រោងទុកនោះបានទេ ហើយកម្មវិធីនៃព្រះរាជទស្សនកិច្ចនេះ ត្រូវលើកទៅពេលក្រោយទៀត។ តែអ្នកការទូតសហភាពសូវៀត បានបញ្ជាក់ថា ប្រសិនបើសម្តេចសីហនុ ប្រាថ្នាចង់យាងទៅបំពេញព្រះរាជទស្សនកិច្ចនៅអឺរ៉ុបខាងកើត ព្រះអង្គអាចយាងឆ្លងកាត់តាមសហភាពសូវៀត បាន។

ការផ្តល់ព័ត៌មានរបស់អ្នកការទូតសហភាពសូវៀត ប្រចាំទីក្រុងព្យុងយ៉ាង ដូចខាងលើនេះ ធ្វើឱ្យសម្តេចសីហនុ អាក់អន់ព្រះទ័យយ៉ាងខ្លាំង។ ព្រះអង្គបានសម្រេចព្រះទ័យយាងត្រលប់មកសាធារណរដ្ឋប្រជាមានិតចិន វិញ ហើយកម្មវិធីយាងទៅបំពេញព្រះរាជទស្សនកិច្ច

នៅអឺរ៉ុបខាងកើត ត្រូវបានពន្យារពេល។ ក្រោយមក កម្មវិធីយាងទៅបំពេញព្រះរាជ ទស្សនកិច្ចនៅសហភាពសូវៀត ត្រូវចាត់ទុកជាមោឃៈ។

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៦៥ នៅពេលយាងត្រលប់មកដល់ខេត្តហេឡុងជៀង នៃសាធារណរដ្ឋប្រជាមានិតចិន វិញ ប្រធានាធិបតីចិន លីវ ចាវជី និងសេនាប្រមុខ ចេន យី បានធ្វើដំណើរពីក្រុងប៉េកាំង ទៅទទួលស្វាគមន៍ព្រះអង្គដោយរីករាយរាក់ទាក់បំផុត។

ក្នុងឱកាស លី ហ្វានវូ ប្រធានខេត្តហេឡុងជៀង រៀបចំពិធីជប់លៀងថ្វាយជាកិត្តិយសចំពោះព្រះអង្គ សម្តេចសីហនុ បានថ្លែងសង្កថាមួយ( ទំនងជាចង់ជៀមជាមដល់មេដឹកនាំសហភាពសូវៀត ជាថ្មីម្តងទៀត) ថា៖ បើមហាអំណាចណាអួតអាងថា ខ្លួនស្រលាញ់សន្តិភាព ហ៊ានប្រកាសប្រឆាំងចក្រពត្តិអាមេរិក ហើយហ៊ានគាំទ្រយ៉ាងម៉ឺងម៉ាត់ចំពោះការតស៊ូរបស់ប្រទេសវៀតណាម និងកម្ពុជា ក៏ដូចជាការតស៊ូរបស់ប្រទេសតតិយលោកទាំងឡាយនៅក្នុងពិភពលោក ដូចសាធារណរដ្ឋប្រជាមានិតចិន នោះ ប្រហែលជាពួកល្មោភសង្គ្រាមអាមេរិក នឹងដកខ្លួនចេញពីប្រទេសទាំងឡាយ ដែលពួកគេបានសាបព្រោះអសន្តិសុខ និងសង្គ្រាម តាំងពីយូរយារណាស់មកហើយ ជាមិនខាន។

សម្តេចសីហនុ បានថ្លែងបន្តថា មហាអំណាចខ្លះអួតអាងថា ខ្លួនជាអ្នកប្រឆាំងពួកចក្រពត្តិនិយម មិនបានដឹកនាំការតស៊ូដោយគ្មានការសម្រុះសម្រួលជាមួយពួកចក្រពត្តិនិយម ដូចសាធារណរដ្ឋប្រជាមានិតចិនឡើយ ហើយក៏មិនអាចជួយប្រទេសតតិយលោកទាំងឡាយឲ្យទទួលបានសន្តិភាព ឬរក្សាឯករាជ្យភាពនៅក្នុងបូរណភាពដែនដី ឲ្យឈ្នះលើពួកជិះជាន់ ឱ្យឈ្នះចក្រពត្តិនិយមអាមេរិក ជាឈ្មួញសង្គ្រាមនោះបានទេ។

សម្តេចសីហនុ បានបន្ថែមទៀតថា មហាអំណាចនោះ មិនបានគិតគូរដោះស្រាយដល់វត្ថុជាទីប្រាថ្នានៃប្រជាជន ដែលរងគ្រោះដូចជាប្រជាជនវៀតណាម ទេ។ ប៉ុន្តែ បែរជាបន្តជួយសម្រួលដល់អំពើឈ្លានពានរបស់ចក្រពត្តិអាមេរិក ប្រឆាំងនឹងប្រជាជនវៀតណាម ទៅវិញ។

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៦៥ ទិនានុប្បវត្តិប្រចាំសប្តាហ៍របស់បក្សកុម្មុយនិស្ត

ចិន បានយកខ្លឹមសារនៃសង្កថារបស់សម្តេចសីហនុ ដែលព្រះអង្គថ្លែងនៅក្នុងពិធីជប់លៀងជាកិត្តិយសនៅក្រុងប៉េកាំង នោះ ទៅចុះផ្សាយ ជាថ្មីម្តងទៀត។

ការចុះផ្សាយបែបនេះ អាចជាចេតនារបស់មេដឹកនាំសាធារណរដ្ឋប្រជាមានិតចិន ចង់បង្ហាញឱ្យសាធារណមតិអន្តរជាតិ ពិសេសបណ្តាប្រទេសកុម្មុយនិស្ត មើលឃើញថា សម្តេចសីហនុ គាំទ្រខ្លួនយ៉ាងពេញទំហឹងក្នុងការប្រឆាំងពួកចក្រពត្តិនិយម មិនដូចមេដឹកនាំសហភាពសូវៀត ដែលចង់ធ្វើការសម្រុះសម្រួលជាមួយពួកចក្រពត្តិនិយម នោះឡើយ។

ក្រោយពេលមកដល់ទីក្រុងភ្នំពេញ វិញ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៦៥ សម្តេចសីហនុ បានធ្វើសេចក្តីថ្លែងការណ៍មួយយ៉ាងវែងតាមវិទ្យុជាតិ ទៅកាន់ប្រជាជាតិរបស់ព្រះ-អង្គ។ ក្នុងសេចក្តីថ្លែងការណ៍នោះ ព្រះអង្គបញ្ជាក់ថា ពាក់ព័ន្ធជាមួយសហភាពសូវៀត មានចំណុចសំខាន់៣ គឺ៖

ទី១. មុនពេលខ្ញុំព្រះករុណាថ្លែងសង្កថានៅទីក្រុងប៉េកាំង និងព្យុងយ៉ាង នោះ សហភាពសូវៀត ជឿជាក់ និងសង្ឃឹមថា អាចបញ្ចុះបញ្ចូលបន្ទន់ជំហររបស់យើងបានពីបញ្ហាវៀតណាម និងការតស៊ូប្រឆាំងពួកចក្រពត្តិនិយម តាមរយៈការគំរាមផ្តាច់ជំនួយជាដើម។ តែបន្ទាប់ពីខ្ញុំព្រះករុណាថ្លែងសង្កថានៅទីក្រុងប៉េកាំង និងព្យុងយ៉ាង នោះមក សហភាពសូវៀត យល់ថាក្តីសង្ឃឹមរបស់គេត្រូវបរាជ័យ។ ដូច្នេះ គេបង្ខំចិត្តលែងទាក់ទងជាមួយយើងទៀត។

ទី២. សហភាពសូវៀត មានការអាក់អន់ស្រពន់ចិត្តជាមួយយើង ដោយសារយើងមានទំនាក់ទំនងជាមួយសាធារណរដ្ឋប្រជាមានិតចិន ដែលជាមិត្តទី១របស់យើង។ សហភាពសូវៀតថា យើងជាអ្នកកាន់ជើងចិន ហើយចាត់ទុកយើងថា ជាអ្នកប្រឆាំងនឹងសហភាពសូវៀត។

ទី៣. ទាំងនេះ គ្រាន់តែជាការសម្តែងឱ្យឃើញនូវគំនិតប្រកាន់ពូជសាសន៍របស់សហ-ភាពសូវៀត ប៉ុណ្ណោះ។ សហភាពសូវៀត ខិតទៅជិតអាមេរិក ពីព្រោះពួកអាមេរិក ជាសាសន៍ស្បែកស ដូចពួកគេដែរ។ ចំពោះពួកសហភាពសូវៀត ចាត់ទុកចិន ជាជនជាតិស្បែកលឿង គឺជាគ្រោះថ្នាក់ និងជាសត្រូវទី១របស់គេ ហើយអ្នកទាំងឡាយណាដែលជាមិត្តជិតស្និទ្ធរបស់ចិន សហភាពសូវៀត ក៏ចាត់ទុកជាសត្រូវរបស់គេដែរ។

ប្រហែលពីរបីថ្ងៃក្រោយមក ក្នុងអង្គប្រជុំមួយនៅព្រះបរមរាជវាំង ជាមួយមន្ត្រីយោធាសំខាន់ៗ សម្តេចសីហនុ បានថ្លែងថា យើងមិនមែនជាប្រជាជាតិអកតញ្ញូនោះទេ តែហេតុ-ការណ៍ក្រុងព្យុងយ៉ាង (អ្នកការទូតសូវៀត បានផ្តល់ព័ត៌មានមកថា មេដឹកនាំសហភាពសូវៀត ជាប់រវល់ខ្លាំងណាស់ ពុំអាចមានលទ្ធភាពដើម្បីទទួលស្វាគមន៍ព្រះអង្គនោះ) គឺជាកត្តាគ្រប់គ្រាន់ ដើម្បីធ្វើឲ្យប្រជាជាតិយើងអាចភ្លេចអស់រាល់អំពើល្អទាំងឡាយ ដែលយើងបានទទួលពីសហភាពសូវៀត តែយើងនៅតែរក្សាកតញ្ញូតាធម៌ចំពោះប្រជាជនសហភាពសូវៀតដ៏អង់អាច និងឧត្តុងឧត្តម។ ប៉ុន្តែប្រសិនបើទំនាក់ទំនងរបស់យើងត្រូវចុះឱនថយ រហូតដល់បាត់បង់ឯករាជ្យភាព សេចក្តីថ្លៃថ្នូរ និងកិត្តិនាមរបស់ខ្លួន ខ្ញុំព្រះករុណានឹងសួរទៅមេដឹកនាំក្រុងមូស្គូ និងក្រុងប៉េកាំង ថាអ្វីដែលជាដំណោះស្រាយប្រសើរបំផុតសម្រាប់ពួកគេ តើឲ្យកម្ពុជា ក្លាយទៅជាប្រទេសកុម្មុយនិស្ត ឬជួយទប់កម្ពុជា ឲ្យនៅជាប្រទេសអព្យាក្រឹត? ។

សម្តេចសីហនុ មានជំនឿថា មេដឹកនាំចិន មិនគាំទ្រ ឬផ្តល់ជំនួយអ្វីដល់ពួកខ្មែរកុម្មុយនិស្ត នៅក្នុងប្រទេសកម្ពុជានោះទេ ពីព្រោះចិន មានទំនាក់ទំនងល្អបំផុតជាមួយព្រះអង្គ ហើយប្រទេសចិន ក៏ស្ថិតនៅឆ្ងាយពីប្រទេសកម្ពុជាដែរ។ ព្រះអង្គឈ្វេងយល់ថា គឺវៀតណាមខាងជើង ឯនោះទេ ដែលធ្វើជាខ្នងបង្អែកសំខាន់ឱ្យពួកខ្មែរកុម្មុយនិស្តនោះ។

ការពិតមេដឹកនាំចិន និងវៀតណាមខាងជើង បានប្រើយុទ្ធសាស្ត្រមុខពីរ គឺគាំទ្រដល់ចលនាតស៊ូរបស់ខ្មែរកុម្មុយនិស្តផង និងភ្ជាប់ទំនាក់ទំនងស្និតល្អតជាមួយសម្តេចសីហនុផង។

ជាមួយគ្នានោះ មេដឹកនាំចិន ក៏បានប្រើយុទ្ធសាស្ត្របន្សាបឥទ្ធិពលរបស់វៀតណាមខាងជើង ដែលមានទៅលើខ្មែរកុម្មុយនិស្ត ផងដែរ។ ប៉ុន្តែទាំងមេដឹកនាំចិន និងមេដឹកនាំវៀតណាម បានសំណូមពរ កុំឱ្យ សាឡុត ស ធ្វើការតស៊ូដោយអាវុធប្រឆាំងនឹងសម្តេចសីហនុ ព្រោះខ្លាចប៉ះពាល់ដល់ទំនាក់ទំនងរបស់ពួកគេជាមួយព្រះអង្គផងដែរ។

# ១៨១
# ចិនថា បើអាមេរិក ចូលឈ្លានពាន កងទ័ពលន់ នល់ មិនអាចទប់ទល់បានទេ



កងទ័ពអាមេរិក នៅវៀតណាមខាងត្បូង និងសាកសពពួកវៀតកុង

បើតាម នួន ជា បានឲ្យដឹងថា ពេល សាឡុត ស ទៅទស្សនកិច្ចនៅវៀតណាមភាគខាងជើង នោះ ពួកវៀតណាម ក៏មានការអាក់អន់ចិត្តចំពោះ សាឡុត ស ដែលមិនបានផ្តល់ការគោរពឲ្យបានត្រឹមត្រូវចំពោះ ហូ ជីមិញ ជាប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ពីព្រោះក្នុងពេលជួបពិភាក្សាគ្នា សាឡុត ស បានហៅ ហូ ជីមិញ ថា សមមិត្តៗ ដោយមិនបានហៅថា អ៊ំហូៗ ដូចពួកគេនោះឡើយ។

ជាមួយគ្នានោះ មេដឹកនាំសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ក៏មិនសប្បាយចិត្តផងដែរ ដោយសារក្នុងអំឡុងពេលទៅទស្សនកិច្ចនៅប្រទេសចិននោះ សាឡុត ស អន្ទះសាក្នុងការជំរុញចលនាតស៊ូនយោបាយរបស់គាត់ ទៅជាការតស៊ូដោយអាវុធ ដូចអ្វីដែលវៀត-ណាម បានធ្វើនៅភាគខាងត្បូង ចាប់ពីឆ្នាំ១៩៥៩ មកដែរ។

ក្រោយមក សាឡុត ស បានឱ្យដឹងថា បក្សកុម្មុយនិស្តចិន បានគាំទ្រមាគ៌ានយោ-

បាយរបស់បក្សពលករកម្ពុជា យ៉ាងអស់ពីចិត្តពីថ្លើម ក្នុងនោះរួមទាំងការវិភាគវណ្ណៈរបស់បក្ស ព្រមទាំងការបែងចែករវាងមិត្ត និងសត្រូវរបស់បក្សពលករកម្ពុជា ទៀតផង។ ក៏ ប៉ុន្តែ ដូចវៀតណាមដែរ ចិន មិនគាំទ្រឲ្យមានការប្តូរទិសដៅពីការតស៊ូនយោបាយ ទៅជាការតស៊ូដោយអាវុធទេ។

ជាមួយគ្នានោះដែរ ចិន ក៏បានថ្លែងសរសើរដល់កម្មវិធីនយោបាយរបស់បក្សពលករកម្ពុជា ត្រង់ឃ្លា ដែលសរសេរថា លើកលែងតែជម្រើសចុងក្រោយប៉ុណ្ណោះ ដែលបក្សពលករកម្ពុជា ត្រូវធ្វើសកម្មភាពតស៊ូដោយអាវុធ ។

មេដឹកនាំចិន បានណែនាំ សាឡុត ស ថា បច្ចុប្បន្ននេះ បក្សនីមួយៗចង់ប្រឆាំងចក្រពត្តិអាមេរិក ខ្លាំងណាស់ ដូច្នេះបក្សទាំងអស់ ត្រូវតែតាមដានសភាពការណ៍ដោយយកចិត្តទុកដាក់បំផុត ដើម្បីមានលទ្ធភាពក្នុងការផ្តួចផ្តើមគំនិតក្នុងការរៀបចំខ្លួនប្រឆាំងចក្រពត្តិមួយនេះ។

អាស្រ័យហេតុនេះ បក្សពលករកម្ពុជា ក៏ដូចជាបក្សរបស់ប្រទេសដទៃទៀតដែរ ពេលណាចក្រពត្តិអាមេរិក ពង្រីកសង្គ្រាម( នៅឥណ្ឌូចិន ) ត្រូវតែដោះស្រាយភ្លាមៗ ។ បក្សនីមួយៗ រួមទាំងបក្សកម្ពុជា ផង មានភារកិច្ចប្រយុទ្ធជាមួយចក្រពត្តិអាមេរិក ដើម្បីរក្សាសន្តិភាព និងអព្យាក្រឹតភាពរបស់ខ្លួន ហើយបើបក្សណាមានបំណងប្រឆាំងនឹងការរួមគំនិតក្បត់របស់ចក្រ-ពត្តិអាមេរិក ក្នុងនោះរួមទាំងគំនិតក្បត់ក្នុងការដំឡើងថ្នាក់សង្គ្រាមរបស់ពួកវាផង គឺត្រូវតែពឹងផ្អែកលើកម្លាំងកសិករ។

នៅពីក្រោយការណែនាំនេះ មេដឹកនាំចិន បានរៀបចំសេណារីយោមួយ អំពីលទ្ធភាពនៃការធ្វើបដិវត្តន៍នៅកម្ពុជា ដូចគ្នានឹងអ្វីដែល ឡេ យន់ លេខាបក្សពលករវៀតណាម បានលើកឡើងដែរ ទោះបីវាមានការពាក់ព័ន្ធខ្លះៗជាមួយសម្តេចសីហនុ និងឧត្តមសេនីយ៍ លន់ នល់ ក៏ដោយ។

សេណារីយោ ដែលមេដឹកនាំចិន បានគិតទុកជាមុននោះ គឺថា បើសហរដ្ឋអាមេរិក ពង្រីកសង្គ្រាមនៅឥណ្ឌូចិន ដោយចូលឈ្លានពានកម្ពុជា ពេលនោះ កងទ័ពកម្ពុជា ដែល



**ឧត្តមសេនីយ៍លន់ នល់ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយប្រធានអគ្គសេនាធិការ កងទ័ពប្រជាជនចិន ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៦៥**

ដឹកនាំដោយ លន់ នល់ មុខជាចាប់ផ្តើមវាយទប់ទល់ជាមួយចក្រពត្តិអាមេរិក វិញ ដោយប្រើអាវុធ និងគ្រាប់រំសេវដែលបានមកពីចិន ផ្តល់ឲ្យដោយផ្ទាល់ តាំងពីដើមឆ្នាំ១៩៦៤ និងគ្រឿងសព្វាវុធជាជំនួយរបស់ចិន ដែល លន់ នល់ ដកហូតយក នៅពេលដឹកជញ្ជូនតាមនាវាចូលចតនៅកំពង់ផែកំពង់សោម មុនពេលដឹកជញ្ជូនបន្ត ទៅឲ្យកងទ័ពរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង នៅភាគខាងកើតប្រទេសកម្ពុជា នោះជាមិនខាន។

ចិន សង្ឃឹមថា លន់ នល់ នឹងអនុវត្តតាមកិច្ចសន្យាជាមួយចិន ដែលគាត់បានចុះហត្ថលេខាក្នុងដំណើរទស្សនកិច្ចរបស់គាត់នៅទីក្រុងប៉េកាំង ក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៥ ដែលក្នុងកិច្ចសន្យានោះបានបញ្ជាក់ច្បាស់ថា កងទ័ពរបស់គាត់ បានប្តេជ្ញាចិត្តវាយប្រយុទ្ធប្រឆាំងចំពោះការឈ្លានពានណាមួយ ពីសំណាក់ចក្រពត្តិអាមេរិក មកលើប្រទេសកម្ពុជា ។

ជាគោលការណ៍ ចិន គាំទ្រសម្តេចសីហនុ និងចាត់ទុកព្រះអង្គជាមេដឹកនាំជួរមុខនៃសង្គ្រាមតស៊ូប្រឆាំងនឹងចក្រពត្តិអាមេរិក។ ប៉ុន្តែ អាចធ្វើដូច្នេះបាន ព្រះអង្គត្រូវទទួលយកអនុសាសន៍របស់ប្រធានម៉ៅ ដែលថា ការធ្វើសង្គ្រាមតស៊ូប្រឆាំងនឹងចក្រពត្តិអាមេរិក ត្រូវពឹងផ្អែកលើកម្លាំងមហាជនដ៏ធំទូលាយ ដែលម៉ៅ សេទុង ចង់និយាយដោយពុំចាំបាច់សង្ស័យនោះ គឺគ្មានអ្វីក្រៅពីកម្លាំងកសិករដែលបានរៀបចំដោយបក្សពលករកម្ពុជា ហើយកម្លាំងនេះ

នឹងស្ថិតនៅជួរមុខនៅក្នុងពេលតស៊ូប្រឆាំងនឹងចក្រពត្តិអាមេរិកនោះ ជាមិនខាន។

មេដឹកនាំចិន ជឿជាក់លើទស្សនៈវិស័យនេះ ដោយសារសម្តេចសីហនុ បានសន្យាជាមួយពួកគេថា ក្នុងករណីមានការវាយប្រហារពីសំណាក់សហរដ្ឋអាមេរិក មកលើប្រទេសកម្ពុជា ព្រះអង្គនឹងចាកចេញទៅកាន់ទីជនបទ ដើម្បីដឹកនាំការតស៊ូ។ តែមេដឹកនាំចិន ក៏គិតដែរថា កងទ័ពរបស់ លន់ នល់ មិនមានសមត្ថភាពធ្វើសង្គ្រាមនៅតំបន់ជនបទព្រៃភ្នំ នោះទេ ដូច្នេះកងទ័ពរបស់ លន់ នល់ ត្រូវតែបង្ខំចិត្តពឹងពាក់សហការជាមួយពួកកុម្មុយនិស្តខ្មែរជាមិនខាន។ ដូច្នេះ មុនពេល កងទ័ពសហរដ្ឋអាមេរិក វាយប្រហារមកលើប្រទេសកម្ពុជា ចិនត្រូវតែប្រើឱ្យអស់លទ្ធភាព ដើម្បីដឹកជញ្ជូនគ្រឿងសព្វាវុធ ឆ្លងកាត់តាមកំពង់ផែសមុទ្ររបស់ប្រទេសកម្ពុជា ទៅឲ្យពួកកុម្មុយនិស្តនៅវៀតណាមភាគខាងត្បូង ហើយក្នុងពេលជាមួយគ្នានោះដែរ ចិនក៏ផ្តល់គ្រឿងសព្វាវុធ ឲ្យកងទ័ព លន់ នល់ ផងដែរ។

ទាំងប្រភពកម្ពុជា និងវៀតណាម បានឲ្យដឹងថា ក្នុងអំឡុងពេល សាឡុត ស ទៅទស្សនកិច្ចនៅសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងសាធារណរដ្ឋប្រជាមានិតចិននោះ នៅមន្ទីរ១០០ មេដឹកនាំរណសិរ្សជាតិរំដោះវៀតណាមខាងត្បូងក៏បានបញ្ចុះបញ្ចូល អៀង សារី, សុន សេន និងសោ ភឹម ឱ្យអត់ធ្មត់កុំប្រើប្រាស់អាវុធប្រឆាំងនឹងសម្តេចសីហនុ ផងដែរ ។

តែទោះបីដូច្នោះ ក៏ដោយ ក៏បក្សពលករកម្ពុជា បានជំរុញឱ្យមានសកម្មភាពតស៊ូនយោបាយបង្កឱ្យមានការរំជើបរំជួលជាច្រើននៅក្នុងទីក្រុងភ្នំពេញ តែសកម្មភាពនេះក៏ត្រូវប្រឈមនឹងការបង្ក្រាបរបស់របស់សម្តេចសីហនុ កាន់តែធ្ងន់ធ្ងរឡើងៗ រហូតដល់ចុងឆ្នាំ១៩៦៥ សកម្មជន និងបក្ខជនជាកម្លាំងបង្កប់នៅក្នុងទីក្រុងភ្នំពេញ ជាច្រើននាក់ នាំគ្នារត់គេចខ្លួនទៅកាន់តំបន់ជនបទ ធ្វើឱ្យសកម្មភាពតស៊ូនយោបាយរបស់កម្មករសិស្សនិស្សិតដែលបក្សពលករកម្ពុជា ជាអ្នករៀបចំឡើង ធ្លាប់ទទួលបានជោគជ័យនាពេលកន្លងមក ត្រូវបានផ្អាកសកម្មភាពមួយរយៈទៅវិញ ហើយកម្លាំងបង្កប់នៅក្នុងទីក្រុងភ្នំពេញ ក៏លែងហ៊ានធ្វើសកម្មភាពអ្វីលេចធ្លោដូចមុនដែរ។

# ១៨២
# សាឡុត ស ប្តូរឈ្មោះបក្សពលករកម្ពុជា ទៅជាបក្សកុម្មុយនិស្តកម្ពុជា



**សាឡុត ស (រូបកណ្តាលគេ) និងមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាផ្សេងទៀត**

នៅដើមឆ្នាំ១៩៦៦ ពេលសាឡុត ស កំពុងស្ថិតនៅក្នុងប្រទេសចិន នៅឡើយ សម្តេចសីហនុ បានបញ្ជាឲ្យចាប់ខ្លួនចាងហ្វាង ឬនិពន្ធនាយកអ្នកកាសែត ដែលជាជនកុម្មុយនិស្តជាច្រើននាក់ ពាក់ព័ន្ធក្នុងការតស៊ូនយោបាយ នៅក្នុងទីក្រុងភ្នំពេញ នោះដែរ។ ចំណែក អ្នកខ្លះទៀតត្រូវទទួលការព្រមានថា បើមិនឈប់ធ្វើសកម្មភាពទេ ពួកគេនឹងត្រូវសម្លាប់ចោល។

តែនៅក្នុងភូមិភាគបូព៌ា ដែលមាន សោ ភឹម ជាលេខាបក្ស បានបង្គាប់ឱ្យកម្លាំងបង្កប់របស់គាត់ លួចដើរបាចខិត្តប័ណ្ណនៅតាមភូមិមួយចំនួន ប្រកាសអំពាវនាវឲ្យប្រជាជនក្រោកឡើងតស៊ូ ដើម្បីផ្តួលរម្លំសម្តេចសីហនុ ដែលពួកគាត់ចាត់ទុកថា ជាមេក្លោងសក្តិភូមិ។

នៅតាមតំបន់ជនបទ បក្សពលករកម្ពុជា បានលួចដើរឃោសនាប្រាប់ប្រជាកសិករ

ថា ក្រោមការដឹកនាំរបស់សម្ដេចសីហនុ គម្លាតរវាងអ្នកមាននៅទីក្រុង និងអ្នកក្រនៅជនបទ កាន់តែឃ្លាតឆ្ងាយពីគ្នាខ្លាំងឡើងៗ។ កសិករជាអ្នកក្រនៅជនបទ មានជីវភាពលំបាកវេទនាខ្លាំងទៅៗ ចំណែកពួកអ្នកមាននៅទីក្រុង ពិសេស ពួកសក្តិភូមិ នាយទុន ម្ចាស់ដី មានជីវភាពរុងរឿងហ៊ឺហាសម្បូរណ៍សប្បាយ ខុសឆ្ងាយពីកសិករជាអ្នកក្រ ដូចមេឃ និងដី។

ក្នុងខែកញ្ញា ឆ្នាំ១៩៦៦ ក្រោយពីវិលត្រលប់មកពីសាធារណរដ្ឋប្រជាធិបតេយ្យវៀត-ណាម មកដល់ខេត្តតៃនិញ (វៀតណាមភាគខាងត្បូង) វិញ ទើប សាឡុត ស ដឹងថា បន្ទាប់ពីកងទ័ពសហរដ្ឋអាមេរិក និងកងទ័ពរដ្ឋការវៀតណាមខាងត្បូង បើកការវាយប្រហារមកលើមន្ទីរ១០០ ហើយមេដឹកនាំបក្សពលករកម្ពុជាម្នាក់ ប៉ិះតែនឹងត្រូវកងទ័ពនេះចាប់ខ្លួនបាន រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង បានជម្លៀសមេដឹកនាំបក្សពលករកម្ពុជា នៅមន្ទីរ ១០០ ឲ្យទៅនៅក្នុងជំរំថ្មីមួយទៀត ដែលចូលកាន់តែជ្រៅពីព្រំដែនកម្ពុជា ទៅក្នុងខេត្តតៃនិញថែមទៀត ដោយទុកតែខ្មែរមួយចំនួនប៉ុណ្ណោះឱ្យនៅមន្ទីរ១០០នេះ បន្តទៀត។

ក្រោយពីស្នាក់នៅក្នុងជំរំថ្មីនោះ បានប៉ុន្មានថ្ងៃប៉ុណ្ណោះ នៅក្នុងខែកញ្ញាដដែលនោះដែរ សាឡុត ស បានកោះប្រជុំគណៈកម្មាធិការមជ្ឈិមបក្សពលករខ្មែរ និងកម្មាភិបាលជាន់ខ្ពស់សរុបប្រមាណ៦០នាក់ ដើម្បីពិភាក្សាគ្នាពីបញ្ហាកំណត់គោលនយោបាយកម្ពុជា ដែលត្រូវប្រកាន់យក នៅពេលអនាគត។

ក្នុងពេលប្រជុំគណៈកម្មាធិការមជ្ឈិមបក្សនោះ សាឡុត ស បានសម្រេចប្តូរឈ្មោះបក្សពលករកម្ពុជា ទៅជាបក្សកុម្មុយនិស្តកម្ពុជា វិញ ហើយចាត់ទុកសហភាពសូវៀត ជាពួកសេរីនិយម ដូចដែលមេដឹកនាំបក្សកុម្មុយនិស្តចិន ចោទប្រកាន់សហភាពសូវៀត ដែរ។

ទាក់ទងដល់ការប្តូរឈ្មោះបក្សនេះ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងអំឡុងឆ្នាំ២០១៥ ជនជាប់ចោទ នួន ជា អតីតអនុលេខាបក្សកុម្មុយនិស្តកម្ពុជា និងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យ បានលើកឡើងថា ការសម្រេចប្តូរឈ្មោះពីបក្សពលករកម្ពុជា ទៅជាបក្សកុម្មុយនិស្តកម្ពុជា នេះ គឺដោយសារមិនចង់ឱ្យឈ្មោះបក្សពលករនេះដូចឈ្មោះបក្សពលករវៀតណាម។

## របត់នយោបាយ

ពេលនោះដែរ សាឡុត ស បានប្រកាន់ខ្ជាប់នូវគោលជំហរដើមរបស់គាត់ គឺការតស៊ូដោយអាវុធ ដោយគាត់មិនយល់ស្របតាមការណែនាំរបស់មេដឹកនាំរណសិរ្សជាតិរំដោះវៀត-ណាមខាងត្បូង ដែលបានណែនាំឱ្យ អៀង សារី, សុន សេន និងសោ ភឹម អត់ធ្មត់ កុំប្រើប្រាស់អាវុធប្រឆាំងនឹងសម្ដេចសីហនុ នៅពេលគាត់អវត្តមានពីមន្ទីរ១០០ ត្រូវចេញទៅបំពេញទស្សនកិច្ចនៅប្រទេសវៀតណាមខាងជើង និងប្រទេសចិន នោះទេ។

សាឡុត ស បានដាក់ផែនការឱ្យកម្មាភិបាលជាន់ខ្ពស់ទាំងអស់ ដែលមានវត្តមានក្នុងអង្គប្រជុំនោះ រៀបចំលក្ខណៈសម្បត្តិ ដើម្បីដឹកនាំធ្វើសង្គ្រាមប្រជាជន ក្នុងនោះ រួមទាំងការរៀនសូត្រពីបច្ចេកទេសធ្វើសង្គ្រាមឈ្លប តាមគំរូរបស់វៀតកុង ផងដែរ។

ជាមួយគ្នានោះ គាត់ឱ្យកម្មាភិបាលជាន់ខ្ពស់ទាំងអស់ ខិតខំបង្កើនការធ្វើសកម្មភាពតស៊ូនយោបាយបន្ថែមទៀត នៅក្នុងទីក្រុង និងធ្វើការឃោសនាក្នុងពេលបោះឆ្នោត ហើយត្រូវត្រៀមខ្លួនជាស្រេច សម្រាប់ធ្វើការតស៊ូដោយអាវុធជាយថាហេតុ ដើម្បីទប់ទល់ការបង្ក្រាបរបស់កងកម្លាំងរាជរដ្ឋាភិបាលនៅតំបន់ជនបទ និងឆ្លៀតឱកាសយកប្រៀបលើហេតុការណ៍នៃសកម្មភាពងើបឡើងបះបោរតវ៉ាបង្កចលាចលរបស់កសិករ ដែលកំពុងកើតមានកាន់តែច្រើនឡើងៗនៅតំបន់ជនបទ ជាពិសេសនៅភូមិភាគពាយ័ព្យ ដែលប្រជាជនមានការមិនសប្បាយចិត្តជាមួយរាជរដ្ឋាភិបាលកាន់តែខ្លាំងឡើងៗ ពីបញ្ហាប្រមូលទិញស្រូវក្នុងតម្លៃថោកជាងទីផ្សារ។

តាមការស្នើសុំរបស់ អៀង សារី នៅដើមខែវិច្ឆិកា ឆ្នាំ១៩៦៦ សាឡុត ស បានសម្រេចយល់ព្រមផ្លាស់ប្ដូរទីតាំងមន្ទីរ១០០ ពីខេត្តតៃនិញ ទៅតាំងនៅភូមិភាគឦសាន ក្នុងទឹកដីកម្ពុជា វិញ ខណៈកងទ័ពសហរដ្ឋអាមេរិក បើកការវាយប្រហារដ៏ធំមួយ ទៅលើកងទ័ពរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង នៅតាមបណ្ដោយព្រំដែនខេត្តតៃនិញ និងកម្ពុជា។

ទីតាំងថ្មីនេះ អៀង សារី បានទៅពិនិត្យមើល និងកំណត់យកធ្វើជាមន្ទីររបស់មជ្ឈិមបក្ស តាំងពីអំឡុងចុងឆ្នាំ១៩៦៥មកម្លេះ តែគាត់ត្រូវរង់ចាំការយល់ព្រមពី សាឡុត ស ជាលេខាបក្ស ពេលត្រលប់មកពីវៀតណាមខាងជើង វិញសិន។

ទីតាំងមន្ទីររបស់មជ្ឈិមបក្សថ្មីនេះ ស្ថិតនៅក្នុងតំបន់ខ្ពង់រាបមួយ ក្នុងខេត្តរតនគិរី ជាប់តំបន់ខ្ពង់រាប តាយង្វៀន នៅក្នុងទឹកដីវៀតណាម ជាតំបន់ខ្ពង់រាប ដែលមានសារៈសំខាន់ជាអាយុជីវិតសម្រាប់បដិវត្តន៍ឥណ្ឌូចិនទាំងមូល ពីព្រោះកាលសម័យសង្គ្រាមឥណ្ឌូចិនលើកទី១ បារាំង ធ្លាប់តាំងមូលដ្ឋានទ័ពនៅតំបន់ខ្ពង់រាប តាយង្វៀន នេះដែរ។ លុះដល់ឆ្នាំ១៩៥៩ រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ចាប់ផ្ដើមតស៊ូដោយអាវុធដំបូង ក៏បានតាំងមូលដ្ឋានទ័ពនៅតំបន់ខ្ពង់រាប តាយង្វៀន នេះដែរ ហើយពេលនេះ សហរដ្ឋអាមេរិក ក៏ចង់វាយយកតំបន់ខ្ពង់រាបនេះ ធ្វើជាមូលដ្ឋានយោធាធំមួយរបស់ខ្លួន ដើម្បីវាយបង្ក្រាបចលនាតស៊ូកុម្មុយ-និស្ត នៅឥណ្ឌូចិន ដែរ។

អៀង សារី បានធ្វើដំណើរតាមផ្លូវលំហូ ជីមិញ ទៅកាន់ខេត្តរតនគិរី ភូមិភាគឦសាន នោះមុនគេ ដើម្បីរៀបចំមន្ទីរមជ្ឈិមបក្សថ្មី ហើយគាត់បានទាក់ទងរណសិរ្សជាតិរំដោះវៀត-ណាមខាងត្បូង ដែលនៅក្បែរនោះ ដើម្បីឱ្យជួយសម្រួលដល់ការធ្វើដំណើររបស់ សាឡុត ស ដែលត្រូវធ្វើដំណើរមកតាមក្រោយគាត់ បន្តទៀតផងដែរ។

អៀង សារី បានបើកវគ្គរៀនសូត្រមួយដល់កម្មាភិបាលតស៊ូទាំងអស់ ឱ្យបានដឹងថា បក្សបានពិនិត្យឃើញលក្ខណៈសម្បត្តិនៅទីនេះ ក្នុងការបង្កើតមន្ទីរមជ្ឈិមបក្ស ដើម្បីម្ចាស់ការដឹកនាំធ្វើសង្គ្រាមបដិវត្តន៍ដោយឯករាជ្យម្ចាស់ការ។ តែយ៉ាងណា អៀងសារី និងកម្មាភិបាលទាំងនោះ នៅតែបន្តពឹងពាក់លើជំនួយផ្សេងៗ ពីរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ដូចជាការព្យាបាលជំងឺ ដល់ពួកគេជាដើម។

ពេលនោះ សាឡុត ស និងថ្នាក់ដឹកបក្សផ្សេងទៀត កំពុងស្នាក់នៅក្នុងជំរំដែលនៅកាន់តែជ្រៅឆ្ងាយពីព្រំដែនកម្ពុជា បានត្រលប់ទៅមន្ទីរ១០០ចាស់ នៅក្បែរព្រំដែនកម្ពុជា វិញ ដើម្បីរៀបចំកម្មាភិបាលមួយចំនួន ឱ្យធ្វើដំណើរទៅភូមិភាគឦសាន ជាមួយគាត់ ហើយកម្មា-ភិបាលមួយចំនួនទៀត ត្រូវចាត់តាំងទៅដឹកនាំធ្វើសកម្មភាពបដិវត្តន៍នៅភូមិភាគបូព៌ា និងនិរតី។

តែ សាឡុត ស មិនមានឱកាសធ្វើដំណើរទៅភូមិភាគឦសាន ភ្លាមៗទេ ព្រោះពេលនោះ

របត់នយោបាយ

កងទ័ពសហរដ្ឋអាមេរិក បានបើកប្រតិបត្តិការសឹកធំមួយទៀត ដើម្បីបោសសម្អាតកងទ័ពរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ដែលនៅក្បែរមន្ទីរ១០០ចាស់ នៅក្នុងខេត្តតៃនិញនោះ ។

សាឡុត ស ត្រូវស្នាក់នៅជាមួយកងទ័ពរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង នៅខេត្តតៃនិញ តាំងពីដើមខែឧសភា ឆ្នាំ១៩៦៧ រហូតដល់ខែសីហា ឆ្នាំ១៩៦៧ ទើបគាត់មានឱកាសធ្វើដំណើរតាមផ្លូវលំហូ ជីមិញ ទៅដល់ភូមិភាគឦសាន ដោយមាននិរសារវៀតណាមជាអ្នកនាំផ្លូវ។

សាឡុត ស ខំប្រឹងធ្វើដំណើរទាំងមានជំងឺគ្រុនចាញ់ អស់រយៈពេលជាង១០ ថ្ងៃ ទើបមកដល់ជំរំតស៊ូរបស់ភូមិភាគឦសាន មានលេខសម្គាល់ថា មន្ទីរ១០២។

នៅទីនោះ សាឡុត ស ជួបជាមួយអៀង សារី, សុន សេន, នៃ សារ៉ាន់ ឬម៉ែន សាន ហៅអាចារ្យសៀង និងសុក ខ្នុល...ដែលបានបែកគ្នា តាំងពីនៅមន្ទីរ១០០ ជាងមួយឆ្នាំមកហើយ។

ឈឹម សំអោក ហៅសមមិត្តប៉ង់ ដែលរត់ចេញពីភ្នំពេញ ទៅតស៊ូជាមួយមេដឹកនាំខ្មែរក្រហម កាលឆ្នាំ១៩៦៤ នោះ ក៏បានជួយដើររកឫសឈើ មើមឈើ ធ្វើជាឱសថបុរាណ ដើម្បីព្យាបាលជំងឺគ្រុនចាញ់ឱ្យ សាឡុត ស រហូតបានជាសះស្បើយ ទើប សាឡុត ស ទៅស្នាក់នៅមន្ទីរមជ្ឈិមបក្សថ្មី មានលេខសម្គាល់ថា មន្ទីរ១០៤។ ក្រោយមានព្រឹត្តិការណ៍រដ្ឋប្រហារឆ្នាំ១៩៧០ មក មន្ទីរ១០២នោះ ត្រូវបានបក្សប្រគល់ឱ្យធ្វើជាមន្ទីររបស់តំបន់១០២ និងមន្ទីរ១០៤ ត្រូវបានបក្សប្រគល់ឱ្យធ្វើជាមន្ទីររបស់តំបន់១០៤ វិញ ។

នៅភូមិភាគឦសាន សាឡុត ស បានចាត់តាំង អៀង សារី ជាលេខាបក្សភូមិភាគ, សុន សេន ជាអនុលេខា, នៃ សារ៉ាន់ ហៅយ៉ា និងកែវ មាស ជាសមាជិក។

នៅចុងឆ្នាំ១៩៦៧ នៅមន្ទីរ១០៤ សាឡុត ស បានប្រជុំគណៈកម្មាធិការ មជ្ឈិមបក្សទាំងអស់ ដែលមានវត្តមាននៅទីនោះ ដើម្បីជំរុញការតស៊ូដោយអាវុធ រួមផ្សំនឹងការតស៊ូដោយនយោបាយ ឱ្យបានខ្លាំងក្លាថែមទៀត និងបានផ្តល់សិទ្ធិអំណាចឱ្យលេខាគណៈកម្មា-

ធិការបក្សភូមិភាគនីមួយៗ ប្រើគំនិតច្នៃប្រតិដ្ឋ តាមសភាពការណ៍ជាក់ស្តែងនៅតាមភូមិភាគនីមួយៗ ពិសេសគឺត្រូវស្វែងរកអាវុធខ្លួនឯង ដោយម្ចាស់ការវាយដណ្តើមយកអាវុធ ពីពួកទាហាន-ប៉ូលិសរបស់រាជរដ្ឋាភិបាលសម្តេចសីហនុ។

សម័យតស៊ូនោះ ដោយសារតែពួកគេគ្មានវិទ្យុទាក់ទង ពួកខ្មែរក្រហមបង្កើតឱ្យមានពួកនិរសារ ដើម្បីធ្វើជាមធ្យោបាយទាក់ទងគ្នាពីកន្លែងមួយ ទៅកន្លែងមួយ ។

ក្នុងខែតុលា ឆ្នាំ១៩៦៧ សាឡុត ស បានផ្ញើលិខិតសម្ងាត់មួយ ទៅមេដឹកនាំក្រុងប៉េកាំង តែត្រូវពួកមេដឹកនាំក្រុងហាណូយ ចាប់បាន។ នៅក្នុងលិខិតនោះ សាឡុត ស បានប្រាប់មេដឹកនាំក្រុងប៉េកាំង បានដឹងថា ចាំបាច់ គាត់ត្រូវតែចាប់ផ្តើមធ្វើសង្គ្រាមរំដោះប្រជាជន ដោយគ្មានត្រលប់ថយក្រោយវិញឡើយ ហើយគាត់បានថ្លែងសរសើរថា មានតែតាមអនុវត្តតាមគំរូសង្គ្រាមរំដោះប្រជាជនចិន របស់ប្រធានម៉ៅ ដែលឈរលើគោលការណ៍អធិបតេយ្យភាព ឯករាជ្យម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួន ទើបទទួលបានជោគជ័យ។

ឃ្លាប្រយោគ ដែលសាឡុត ស ប្រើប៉ុន្មានឃ្លានេះ ធ្វើឱ្យមេដឹកនាំក្រុងហាណូយ កាន់តែមិនសប្បាយចិត្តថែមទៀត ព្រោះពួកគេមិនចង់ឱ្យពួកខ្មែរក្រហមធ្វើការតស៊ូដោយអាវុធ មុនពេលពួកគេទទួលបានជ័យជម្នះនៅលើសមរភូមិវៀតណាមខាងត្បូង ទេ ហើយពួកគេក៏ចង់ឱ្យពួកខ្មែរក្រហមស្ថិតនៅក្រោមឥទ្ធិពលរបស់ពួកគេ បន្តទៀតផងដែរ។

# ១៨៣
# បដិវត្តន៍វប្បធម៌ នៅប្រទេសចិនកុម្មុយនិស្ត




**ពួកឆ្មាំក្រហម ចាប់កម្មាភិបាលចាស់យកទៅធ្វើទារុណកម្ម**

ពេល សាឡុត ស កំពុងបំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន គឺចំពេល ម៉ៅ សេទុង ចាប់ផ្តើមធ្វើបដិវត្តន៍វប្បធម៌។ ដោយយកគំរូតាម ចូសេហ្វ ស្តាលីន (Joseph Stalin) មេដឹកនាំសហភាពសូវៀត ក្រោយពីបានឡើងកាន់ អំណាចដឹកនាំប្រទេស នៅក្នុងឆ្នាំ១៩៤៩ ម៉ៅ សេទុង បានដាក់ចេញគោលនយោបាយមហាលោតផ្លោះ រយៈពេល ១០ឆ្នាំ ដើម្បីអភិវឌ្ឍកសិកម្ម និងឧស្សាហកម្ម។

ក្នុងឆ្នាំដំបូងនៃការអនុវត្តគោលនយោបាយមហាលោតផ្លោះនោះ វិស័យកសិកម្មទទួលបានផលយ៉ាងច្រើន។ ប៉ុន្តែ ដោយសារកម្លាំងពលកម្មមួយភាគធំ ត្រូវផ្ទេរទៅរោងចក្រផលិតដែក ដើម្បីអភិវឌ្ឍវិស័យឧហ្សាកម្ម បណ្តាលឱ្យខ្វះខាតកម្លាំងប្រមូលផលកសិកម្ម ធ្វើឱ្យផលិត-

ផលកសិកម្មជាច្រើន ត្រូវទុំស្អុយចោលនៅពេញវាលស្រែ និងចម្ការ។

មិនតែប៉ុណ្ណោះ ដើម្បីផ្គាប់ចិត្តថ្នាក់ដឹកនាំខាងលើៗ ពួកកម្មាភិបាលមូលដ្ឋាន បានរាយការណ៍ពន្លើសតួលេខ បង្កឱ្យប្រជាជនចិន ជាច្រើនលាននាក់ ខ្វះអាហារសម្រាប់បរិភោគ។

ដោយសារយល់ឃើញថា តាំងពីឆ្នាំ១៩៥៦មក មេដឹកនាំសហភាពសូវៀត នីគីតា គ្រូស្ឆេវ (Nikita Khrushchev) ជាអ្នកសេរីនិយម បានផ្លាស់ប្តូរលទ្ធិម៉ាក្សឡេនីននិយម ដើម្បីឱ្យពួកមូលធននិយមអាចឡើងមកគ្រប់គ្រងប្រទេសឡើងវិញ បាននោះ ក្នុងពេលប្រជុំគណៈកម្មាធិការមជ្ឈិមបក្ស នៅក្រុងណានជីង (Nanjing) នាខែមករា ឆ្នាំ ១៩៥៨ ម៉ៅ សេទុង បានប្រកាស ធ្វើកំណែទម្រង់ថ្មីមួយទៀត គឺផែនការអភិវឌ្ឍសេដ្ឋកិច្ចរយៈពេល ៥ឆ្នាំ ដែលហៅថា "ផែនការមហាលោតផ្លោះ" គឺធ្វើទំនើបកម្មវិស័យកសិកម្មរបស់ប្រទេសតាមបែបកុម្មុយនិស្ត ដើម្បីក្លាយទៅជាប្រទេសឧស្សាហកម្មទំនើបមួយ ដោយសង្ឃឹមថា រយៈពេល១៥ឆ្នាំទៀត ចិននឹងដើរទាន់ ឬហួសសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស ទៅទៀត។

ពេលនោះ នៅទូទាំងប្រទេស ទាំងនៅទីក្រុង និងនៅតាមទីជនបទត្រូវអនុវត្តរបបសមូហភាពទាំងស្រុង កម្មសិទ្ធិឯកជនទាំងអស់ត្រូវលុបបំបាត់ចោល។ ទ្រព្យសម្បត្តិឯកជនទាំងអស់ តាំងពីដីធ្លី សត្វពាហនៈ និងផលដំណាំដែលដាំបាន សុទ្ធតែជារបស់សមូហភាព និងជារបស់រដ្ឋ។ ប្រជាជន ក្មេង ចាស់ ប្រុស ស្រី ត្រូវបានកែនឲ្យទៅជីកប្រឡាយ លើកទំនប់ ធ្វើស្រែចម្ការរួម និងហូបបាយរួមនៅតាមសហករណ៍។

ប្រជាជនចិន ជាច្រើនលាននាក់ ត្រូវបញ្ជូនចេញពីទីក្រុង ឱ្យទៅតំបន់ជនបទ ហើយភាគច្រើនបញ្ជូនទៅធ្វើការនៅតាមសហករណ៍កសិកម្ម និងប្រជាជនជាច្រើនលាននាក់ ផ្សេងទៀត ឱ្យទៅធ្វើការនៅក្នុងរោងចក្រតូចៗ។

ក៏ប៉ុន្តែ គ្រាន់តែចាប់ផ្តើមអនុវត្ត"ផែនការមហាលោតផ្លោះ"នេះ ក្នុងរយៈពីរបីឆ្នាំ ប្រទេសចិន មិនត្រឹមតែមិនបានប្រែក្លាយទៅជាប្រទេសជឿនលឿនអ្វីសូម្បីបន្តិចនោះទេ ផ្ទុយទៅវិញ ប្រជាជនចិនច្រើនលាននាក់ត្រូវស្លាប់ដោយការអត់បាយ ។

នៅខែមេសា ឆ្នាំ១៩៦០ ម៉ៅ សេទុង សុខចិត្តលាឈប់ពីតំណែងជាប្រធានាធិបតី

ហើយបានប្រគល់តំណែងប្រធានាធិបតីនេះ ទៅឱ្យ លីវ ចាវជី (Liu Shaoqi) និងឲ្យតេង ស៊ាវពីង ធ្វើកំណែទម្រង់ ដើម្បីស្តារសេដ្ឋកិច្ចជាតិ ឡើងវិញ។ តែ ម៉ៅ សេទុង នៅតែរក្សាតំណែងជាលេខាបក្សកុម្មុយនិស្តចិនដដែល ដោយគាត់មិនចេញមុខដឹកនាំបក្សជាចំហដូចមុនៗទៀតទេ។

ក្រោយពីបានឡើងកាន់អំណាចដឹកនាំប្រទេសមក លីវ ចាវជី និងតេង ស៊ាវពីង ក៏ចាប់ផ្តើមធ្វើកំណែទម្រង់បន្ធូរបន្ថយផែនការមហាលោតផ្លោះរបស់ ម៉ៅ សេទុង ដោយលុបចោលការហូបរួម ធ្វើការរួម មកធ្វើកសិកម្មជាលក្ខណៈឯកជន និងឱ្យប្រជាជនមានកម្មសិទ្ធិឯកជន ឡើងវិញ។

ដោយសារការធ្វើកំណែទម្រង់របស់ លីវ ចាវជី និងតេង ស៊ាវពីង ជីវភាពប្រជាជនចិន ក៏បានធូរស្រាល មានការហូបចុកគ្រាន់បើឡើងវិញ សេដ្ឋកិច្ចរបស់ប្រទេសជាតិ ក៏ចាប់ផ្តើមងើបឡើងវិញជាបណ្តើរៗ ចាប់ពីពេលនោះមក ហើយឥទ្ធិពលដឹកនាំរបស់ ម៉ៅ សេទុង កាន់តែស្រុតចុះទៅៗ ទាំងនៅក្នុងជួរកងទ័ព ទាំងនៅក្នុងជួរបក្ស និងក្នុងចំណោមប្រជាជនមហាជន។

ចាប់ពីពេលនោះមក ម៉ៅ សេទុង និងតេង ស៊ាវពីង មានការខ្វែងគំនិតគ្នាលើយុទ្ធសាស្ត្រនៃការអភិវឌ្ឍសេដ្ឋកិច្ច និងគោលនយោបាយផ្សេងៗទៀត។ ទ្រឹស្តីដ៏ល្បីល្បាញរបស់តេង ស៊ាវពីង គឺនៅពេលដែលគាត់ថ្លែងសុន្ទរកថាម្តងៗ គាត់តែងតែលើកឡើងថា៖ "វាមិនសំខាន់ថា ជាឆ្មាខ្មៅ ឬឆ្មាសទេ សំខាន់ឱ្យតែវាអាចចាប់កណ្តុរបាន ។

ដោយមើលឃើញថា ម៉ៅ សេទុង កាន់តែបាត់បង់ឥទ្ធិពលដឹកនាំបន្តិចម្តងៗនោះ សេនាប្រមុខ លីន ពៀវ បានជួយពង្រឹងឥទ្ធិពលរបស់ ម៉ៅ សេទុង នៅក្នុងជួរកងទ័ពឡើងវិញ។

ចំណែក ជៀង ឈិង (ប្រពន្ធទី៤របស់ ម៉ៅ សេទុង) ជួយឃោសនាលើកកម្ពស់ឥទ្ធិពល ម៉ៅ សេទុង ក្នុងចំណោមប្រជាជនមហាជន ព្រមទាំងធ្វើការវាយប្រហារទៅលើ លីវ ចាវជី និងតេង ស៊ាវពីង ដើម្បីស្តារឥទ្ធិពល និងប្រជាប្រិយភាពរបស់ ម៉ៅ សេទុង ឡើងវិញ។

នៅក្នុងឆ្នាំ១៩៦៤ លីន ពៀវ បានប្រមូលទ្រឹស្តីសំខាន់ៗរបស់ ម៉ៅ សេទុង ពាក់ព័ន្ធនឹងមនោគមវិជ្ជាកុម្មុយនិស្ត ចំនួន២៦៧ឃ្លា យកទៅចងក្រង និងបោះពុម្ពជាសៀវភៅតូចៗជាច្រើនលានក្បាល។ សៀវភៅតូចៗនោះ ត្រូវបានគេឱ្យឈ្មោះថា កូនសៀវភៅក្រហម "The little Red Book" ដើម្បីត្រៀមទុកសម្រាប់ធ្វើបដិវត្តន៍វប្បធម៌។

នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៦៦ នៅទីក្រុងប៉េកាំង ម៉ៅ សេទុង អគ្គលេខាបក្សកុម្មុយនិស្តចិន បានប្រកាសថា ពេលនេះ ពួកប្រឆាំងបដិវត្តន៍ បានជ្រៀតចូលមកនៅក្នុងជួរបក្សយើង ហើយកំពុងរៀបចំផែនការបង្កើតរបបផ្តាច់ការនៃវណ្ណៈគហបតីនៅក្នុងប្រទេសយើងឡើងវិញ...។

នៅក្នុងខែ សីហាឆ្នាំ១៩៦៦ នៅក្នុងកិច្ចប្រជុំពេញអង្គគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន ម៉ៅ សេទុង ក៏បានប្រកាសធ្វើបដិវត្តន៍ថ្មីមួយទៀត គឺបដិវត្តន៍វប្បធម៌ ដើម្បីលុបបំបាត់ពួកសេរីនិយម, លុបបំបាត់ឥទ្ធិពលមូលធននិយម និងប្រពៃណីចិនពីបុរាណ ហើយដាក់បញ្ចូលលទ្ធិម៉ៅនិយម (Maoism) ដើម្បីបំពេញចំណុចចន្លោះប្រហោងរបស់សៀវ-ភៅស្តីពី "គោលគំនិតកុម្មុយនិស្ត" ឬ "គោលគំនិតនៃបក្សកុម្មុយនិស្ត" ជាស្នាដៃនិពន្ធរបស់កាល់ម៉ាក្ស និងអង់ហ្គែល ដែលបានចេញផ្សាយនៅក្នុងទីក្រុងឡុងដ៍ នៅឆ្នាំ១៨៤៨ ហើយក្រោយមក បានក្លាយទៅជាសៀវភៅមនោគមន៍វិជ្ជាកុម្មុយនិស្ត ដ៏មានឥទ្ធិពលបំផុតមួយនៅលើសាកលលោក ។

ដើម្បីដឹកនាំចលនាបដិវត្តន៍វប្បធម៌នោះ ឱ្យមានប្រសិទ្ធភាព ម៉ៅ សេទុង បានបង្កើតក្រុមកម្មាភិបាលជាន់ខ្ពស់មួយក្រុម មានគ្នា៤នាក់ ហៅថាបនទាំង៤ (Gang of Four) រួមមាន៖ ១.ជៀង ឈិង (Jiang Qing) ជាភរិយាទី៤របស់គាត់, ២.ចាង ឈុនឈៀវ (Zhang Chunqiao) ៣.យ៉ាវ វិនយាន (Yao Wenyuan) និង៤.វ៉ាង ហុងវិន (Wang Hong-wen)។

មុនដំបូង ម៉ៅ សេទុង បានបញ្ជាឱ្យបិទសាលារៀនទាំងអស់នៅទូទាំងប្រទេស តាំងពីថ្នាក់បឋមសិក្សា រហូតដល់មហាវិទ្យាល័យ និងសាកលវិទ្យាល័យ ហើយប្រមូលផ្តុំសិស្ស




**យុវជន-យុវនារីចិន ជប់ជល់ជាមួយទ្រឹស្តីនៅក្នុងកូនសៀវភៅក្រហម**

និស្សិតតាំងពីវ័យជំទង់ និងយុវវ័យនៅតាមមូលដ្ឋាននីមួយៗ សរុបទាំងអស់ច្រើនលាននាក់ បង្កើតជាកងកម្លាំងបដិវត្តន៍វប្បធម៌ ដោយឱ្យឈ្មោះថា ពួកឆ្មាំក្រហម (Red Guards) មកអប់រំសតិអារម្មណ៍បំពាក់បំប៉នគោលជំហរបដិវត្តន៍វប្បធម៌ និងរៀនសូត្រទ្រឹស្តីម៉ៅនិយម ផងដែរ ក្នុងទិសដៅបោសសម្អាតពួកប្រឆាំងបដិវត្តន៍ និងពួកមានគំនិតសេរីនិយម ដែលកំពុងសំងំលាក់ខ្លួននៅក្នុងជួរថ្នាក់ដឹកនាំបក្សគ្រប់លំដាប់ថ្នាក់ ដោយចម្រាញ់ទុកតែកម្មាភិបាលទាំងឡាយណា ដែលមានគោលជំហរធ្វើបដិវត្តន៍កុម្មុយនិស្តបរិសុទ្ធ និងទុកតែកម្មាភិបាលដែលមានការស្មោះត្រង់ជាមួយគាត់តែប៉ុណ្ណោះ។

កូនសៀវភៅក្រហម ប្រមាណ២០០លានក្បាល ត្រូវបានយកទៅចែកឱ្យប្រជាជនទូទាំងប្រទេស ដើម្បីផ្សព្វផ្សាយពីទ្រឹស្តីធ្វើបដិវត្តន៍វប្បធម៌របស់ ម៉ៅ សេទុង។ ពេលនោះដែរ ម៉ៅ សេទុង បានត្រលប់មកកាន់តំណែងជាប្រធានាធិបតី វិញ ។

ចំណែក លីវ ចាវជី ត្រូវបានដកចេញពីតំណែងប្រធានាធិបតី ហើយយកទៅឃុំឃាំង និងធ្វើទារុណកម្ម រហូតត្រូវស្លាប់នៅក្នុងគុក នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៦៩ ។



**សាកសព លីវ ចាវជី និងពេលពួកឆ្មាំក្រហមចាប់ខ្លួនគាត់**

ចំណែក វ៉ាង ក្វាងម៉ី (Wang Guangmei) ជាប្រពន្ធរបស់ លីវ ចាវជី បន្ទាប់ពីគេឃុំខ្លួនក្នុងផ្ទះមួយរយៈ ត្រូវយកទៅដាក់ពន្ធនាគារវិញ ហើយកូនៗរបស់ពួកគាត់ទាំង៤នាក់ក៏ត្រូវបានគេដាក់ទោសដែរ តែទោសស្រាលជាងពួកគាត់។ ពេលជាប់ពន្ធនាគារនោះ គាត់មិនបានដឹងពីជោគវាសនារបស់ប្ដី និងកូនៗ ថានឹងទៅជាយ៉ាងណានោះទេ?។

៤ឆ្នាំក្រោយមក កូនៗទាំង៤នាក់ របស់ពួកគាត់មានចិត្តក្លាហាន បាននាំគ្នាទៅសុំអនុញ្ញាតពី ម៉ៅ សេទុង ដើម្បីចូលជួបឪពុកម្ដាយនៅក្នុងពន្ធនាគារ។

ម៉ៅ សេទុង ក៏បានយល់ព្រមដែរ តែឪពុករបស់ពួកគេបានស្លាប់បាត់ទៅហើយ ពួកគេបានជួបតែម្ដាយនៅក្នុងពន្ធនាគារប៉ុណ្ណោះ។ ពេលនោះ ទើប វ៉ាង ក្វាងម៉ី (Wang Guang mei) ជាប្រពន្ធបានដឹងថា លីវ ចាវជី ជាប្ដីស្លាប់បាត់ទៅហើយ។

ម៉ៅ សេទុង បានជំរុញឱ្យពួកឆ្មាំក្រហម វាយធ្វើបាបកាប់សម្លាប់ប្រជាជនវ័យចំណាស់ កម្មាភិបាល និងបញ្ញវន្តទាំងឡាយណានៅតែ ប្រកាន់យកវប្បធម៌ចាស់ ដែលពួកគេយល់ថា បានបង្កការរាំងស្ទះដល់ការលុបបំបាត់វណ្ណៈសក្តិភូមិផ្តាច់ការ វណ្ណៈគហបតី ដែលបានជិះជាន់កេងប្រវ័ញ្ចមកលើប្រជាជនកសិករចិន រាប់ពាន់ឆ្នាំមកហើយ។ ព្រះវិហារជាទីសក្ការៈ បណ្ណាល័យ និងផ្ទះឯកជនត្រូវបានរឹបអូស ឬត្រូវបំផ្លាញចោល ។

ត្រឹមតែរយៈពេល១ខែនៃការចាប់ផ្តើមធ្វើបដិវត្តន៍វប្បធម៌នេះ នៅក្នុងទីក្រុងប៉េកាំង មានមនុស្សប្រហែល១៨០០នាក់ បានបាត់បង់ជីវិត។

នៅពេល ម៉ៅ សេទុង បញ្ជាឱ្យកងទ័ពនៅឱ្យស្ងៀម កុំជ្រៀតជ្រែកដល់សកម្មភាព




វ៉ាង ក្វាងម៉ី ប្រពន្ធ លីវ ចាវជី ពេលចាប់ខ្លួន

របស់ពួកឆ្មាំក្រហម ធ្វើឱ្យពួកនេះកាន់តែបញ្ចេញសកម្មភាពឡើងចាង ដើររកចាប់ពួកម្នាក់បាល និងបញ្ញវន្តជាច្រើនយកមកវាយដំ ឬចងបណ្ដើរឱ្យស្រែកអាក្រោសជាសាធារណៈ ហើយខ្លះត្រូវបានសម្លាប់ចោល ឬបង្ខំឱ្យធ្វើអត្តឃាតនោះ កាន់តែកើតមានច្រើនឡើងៗ។

នៅទូទាំងប្រទេស ពួកឆ្មាំក្រហម ត្រូវបាន ម៉ៅ សេទុង ផ្ដល់សិទ្ធិអំណាចឲ្យធ្វើការឆែកឆេរផ្ទះសម្បែងប្រជាជន ដើម្បីស្វែងរក និងចាប់ចងប្រជាជន និងកម្មាភិបាលគ្រប់លំដាប់ថ្នាក់ដែលពួកគេរកឃើញថានៅជាប់កម្អែលវណ្ណៈសក្តិភូមិ វណ្ណៈនាយទុន និយមបរទេស ឬមានគំនិតសេរីនិយម និងមានគំនិតប្រឆាំងនឹង ម៉ៅ សេទុង ជាដើម។ សាសនាទាំងអស់ត្រូវលុបបំបាត់ចោល។

ពួកបញ្ញវន្តជាច្រើនត្រូវគេយកទៅសម្លាប់ចោល។ ខ្សែភាពយន្ត សៀវភៅ និងអ្វីៗទាំងអស់ជារបស់បរទេស ក៏ត្រូវលុបបំបាត់ចោល និងដាក់ជំនួសមកវិញដោយ«សៀវភៅក្រហម» របស់ប្រធានម៉ៅ ដ៏មហិមា។

ក៏ប៉ុន្តែ មិនយូរប៉ុន្មាន ពួកឆ្មាំក្រហមមានសិទ្ធិអំណាចហួសហេតុនេះ ក៏មានទំនាស់បាក់បែក ប្រដែងអំណាចគ្នាទៅវិញទៅមក និងបង្កឱ្យមានភាពអនាធិបតេយ្យពេញផ្ទៃប្រទេស។

នៅពេលពួកឆ្មាំក្រហម បង្កចលាចលប្រដែងអំណាចគ្នាទៅវិញទៅមក កាន់តែធ្ងន់ធ្ងរទៅៗ រហូតដល់ចង់ក្លាយទៅជាសង្គ្រាមស៊ីវិលទៅហើយនោះ ក្នុងឆ្នាំ១៩៦៨ ម៉ៅ សេទុង ក៏បានចេញបញ្ជាឲ្យ លីន ពៀវ បញ្ជូនកងទ័ពទៅបង្ក្រាប និងរៀបចំពួកឆ្មាំក្រហមឱ្យមានសណ្ដាប់ធ្នាប់ឡើងវិញ។ ពួកឆ្មាំក្រហមដ៏ច្រើនសន្ធឹកសន្ធាប់ ត្រូវកងទ័ពចាប់បញ្ជូនឲ្យទៅនៅតាមទី



**ម៉ៅ សេទុង និងលីន ពៀវ**

ជនបទ ដើម្បីលត់ដំ កសាងខ្លួនវិញម្តង។

នៅក្នុងឆ្នាំ ១៩៦៩ លីន ពៀវ ត្រូវបានតែងតាំងជាអ្នកស្នងតំណែង ម៉ៅ សេទុង ជាផ្លូវការ។ ប៉ុន្តែ ក្រោយពីមានការប៉ះទង្គិចគ្នារវាងកងទ័ពចិន ជាមួយកងទ័ពសូវៀត នៅព្រំដែនមក លីន ពៀវ ក៏បានយកច្បាប់អាជ្ញាសឹកមកអនុវត្តនៅទូទាំងប្រទេស ធ្វើឲ្យ ម៉ៅ សេទុង មានការសង្ស័យខ្លាច លីន ពៀវ ដណ្តើមអំណាចពីគាត់មុនកាលកំណត់ ។

មិនយូរប៉ុន្មាន នាយករដ្ឋមន្ត្រី ជូ អេនឡាយ ក៏បានទទួលព័ត៌មានសម្ងាត់ថា លីន ពៀវ បានរៀបចំគម្រោងធ្វើរដ្ឋប្រហារ និងធ្វើឃាត ម៉ៅ សេទុង ផងដែរ។

ក្រោយពេលទទួលទទួលព័ត៌មានសម្ងាត់នេះ ម៉ៅ សេទុង ក៏បានរៀបចំគម្រោងមួយដើម្បីកម្ចាត់ លីន ពៀវ ដោយបានអញ្ជើញ លីន ពៀវ និងភរិយា ឈ្មោះ យេ ឈុន (Ye Qun) ឱ្យទៅចូលរួមក្នុងពិធីជប់លៀងមួយនៅវិមានរបស់គាត់ នៅ អ៊ីថាសាន នាយប់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧១។

លុះព្រឹកឡើង ថ្ងៃទី១៣ ខែកញ្ញា ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋចិន បានផ្សាយព័ត៌មានថា លីន ពៀវ មានគំនិតក្បត់បក្ស រៀបចំគម្រោងធ្វើរដ្ឋប្រហារ និងធ្វើឃាតប្រធាន



**បំណែកយន្តហោះដែលព័ត៌មានរដ្ឋចិន ផ្សាយថា ជាយន្តហោះរបស់ លីន ពៀវ តែដូចជាមិនឃើញមានរូបបំណែកសាកសពមនុស្សទេ**

ម៉ៅ។ នៅពេលបែកការណ៍ ក៏នាំគ្រួសារលួចជិះយន្តហោះ រត់ចេញពីប្រទេសចិន ក្នុងបំណងទៅសុំសិទ្ធិជ្រកកោននយោបាយនៅសហភាពសូវៀត តែជាអកុសល យន្តហោះ ដែលពួកគេជិះនោះ បានធ្លាក់នៅក្នុងប្រទេសម៉ុងហ្គោលី ស្លាប់ទាំងអស់គ្នា។

ប៉ុន្តែ តាមសៀវភៅ «មហារាជិនីក្រហម» ឬ«សមមិត្តនារី ជៀង ឈិង» បោះពុម្ពឆ្នាំ ១៩៧៧ និពន្ធដោយលោកស្រី រ៉ុកសាន វីតឃើរ (Roxane Witke) បានអះអាងថា នៅយប់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧១នោះ លីន ពៀវ និងភរិយា ក៏បានទៅចូលរួមក្នុងពិធីជប់លៀងតាមការអញ្ជើញរបស់ ម៉ៅ សេទុង ដោយមានផឹកស្រាពិសេសអាយុ៤៨២ឆ្នាំ ផលិត




**សេនាប្រមុខ ប៉េង តឺហួយ ពេលពួកឆ្មាំក្រហមចាប់ខ្លួន**

តាំងពីសម័យរាជវង្សម៉េង ក្លែមជាមួយសាច់ខ្លាផងដែរ។

រហូតដល់យប់ជ្រៅ នៅវេលាម៉ោង២៣ ពេលរថយន្តរបស់ លីន ពៀវ និងភរិយា បើកចេញផុតពីវិមានរបស់ប្រធានម៉ៅ បន្តិច ក៏ត្រូវគេបាញ់ឆេះខ្ទេច មើលលែងស្គាល់ទាំងមនុស្សទាំងរថយន្ត។

ចំណែក សេនាប្រមុខ ប៉េង តឺហួយ (Peng Dehuai) ដែល ម៉ៅ សេទុង ចាត់តាំងឱ្យដឹកនាំកងទ័ពប្រជាជនចិន ទៅធ្វើសង្គ្រាមនៅឧបទ្វីបកូរ៉េ កាលពីឆ្នាំ១៩៥០នោះ ក៏ត្រូវសេនាប្រមុខ លីន ពៀវ និងជៀង ឈិង (Jiang Qing) ជាភរិយាទី៤របស់ ម៉ៅ សេទុង បញ្ជាឱ្យពួកឆ្មាំក្រហមចាប់ខ្លួននៅចុងឆ្នាំ១៩៦៦។

គាត់ត្រូវពួកឆ្មាំក្រហមយកទៅឃុំឃាំង ធ្វើទារុណកម្មសួរចម្លើយ និងធ្វើឱ្យមានការអាម៉ាស់ជាសាធារណៈ ដើម្បីបង្ខំឱ្យគាត់សារភាពពីបទឧក្រិដ្ឋកម្មរបស់គាត់ក្នុងការប្រឆាំងនឹង ម៉ៅ សេទុង និងបក្សកុម្មុយនិស្តចិន។

សេនាប្រមុខ ប៉េង តឺហួយ ត្រូវពួកឆ្មាំក្រហមយកទៅឃុំឃាំងធ្វើទារុណកម្មសួរចម្លើយពីឆ្នាំ១៩៦៦ រហូតដល់ឆ្នាំ១៩៧០ ទើបគេកាត់ទោសជាផ្លូវការ ឱ្យជាប់គុកអស់មួយជីវិត ហើយគាត់បានបាត់បង់ជីវិតនៅក្នុងគុក នាឆ្នាំ១៩៧៤។

## របត់នយោបាយ

រយៈពេលធ្វើបដិវត្តន៍វប្បធម៌ តែ៤ឆ្នាំប៉ុណ្ណោះ ម៉ៅ សេទុង បានកម្ចាត់គូប្រជែងរបស់ខ្លួននៅក្នុងជួរថ្នាក់ដឹកនាំគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន ស្ទើរតែទាំងអស់។

នៅក្នុងឆ្នាំ១៩៦៩ ម៉ៅ សេទុង បានបញ្ជូន តេង ស៊ាវពីង ឲ្យទៅរស់នៅធ្វើស្រែ ដើម្បីឲ្យលត់ដំកែប្រែខ្លួន កុំឱ្យមានគំនិតមូលធននិយមទៀត នៅតំបន់ជនបទមួយ ក្នុងខេត្តជាំងស៊ី។

នៅទីនោះ តេង ស៊ាវពីង ខិតខំធ្វើការគ្រប់បែបយ៉ាង និងបានលត់ដំកែប្រែគោលជំហររបស់ខ្លួនឱ្យទៅជាវណ្ណៈកម្មករ កសិករ ដើម្បីក្លាយខ្លួនជាជនបដិវត្តន៍បរិសុទ្ធ ស្របតាមទ្រឹស្តីរបស់ម៉ៅ ហើយសង្ឃឹមថា ថ្ងៃណាមួយ គាត់ នឹងត្រូវបានបក្សបន្ធូរបន្ថយ ឬលើកលែងទោសវិញ។

នៅចុងឆ្នាំ១៩៧១ ក្រោយពេលឮដំណឹងថា  សេនាប្រមុខ លីន ពៀវ ប៉ុនប៉ងធ្វើរដ្ឋប្រហារទម្លាក់ ម៉ៅ សេទុង ហើយធ្លាក់យន្តហោះស្លាប់ទាំងគ្រួសារ នៅក្នុងប្រទេសម៉ុងហ្គោលីនោះមក  តេង ស៊ាវពីង ក៏បានសរសេរលិខិតមួយច្បាប់ទៅ ម៉ៅ សេទុង ដោយបានសម្តែងការកោតសរសើរពីភាពឈ្លាសវៃរបស់  ម៉ៅ  សេទុង  ក្នុងការទប់ស្កាត់រដ្ឋប្រហារមិនឲ្យបានសម្រេច និងបានថ្កោលទោស លីន ពៀវ ផងដែរ។

បន្ទាប់មកទៀត តេង ស៊ាវពីង បានសរសេរលិខិតមួយច្បាប់ទៀត ទៅ ម៉ៅ សេទុង ដើម្បីសុំអនុញ្ញាតឲ្យត្រលប់មកធ្វើការនៅក្រុងប៉េកាំងវិញ  និងបានសន្យាថា  ធ្វើខ្លួនជាជនបដិវត្តន៍បរិសុទ្ធ ស្របតាមទ្រឹស្តីរបស់ម៉ៅ  ដោយឥតងាករេ។

ក្រោយពីកម្ចាត់គូប្រជែង និងពង្រឹងអំណាចបានរឹងមាំក្នុងដៃមក ម៉ៅ សេទុង ក៏ចាប់ផ្តើមងាកមកគិតគូរស្តារសេដ្ឋកិច្ច វិញម្តង។ តែពេលនោះ ម៉ៅ សេទុង ត្រូវប្រឈមមុខនឹងបញ្ហាដ៏ធំមួយ គឺការខ្វះខាតធនធានមនុស្ស ដោយសារតែបដិវត្តន៍វប្បធម៌បានធ្វើឲ្យកម្មាភិ-បាលមានសមត្ថភាពមួយផ្នែកធំត្រូវបានគេសម្លាប់  ហើយខ្លះទៀតត្រូវបានដកតំណែង  ឬបញ្ជូនឲ្យទៅធ្វើការនៅតាមតំបន់ជនបទ។

ដើម្បីស្តារសេដ្ឋកិច្ចជាតិឡើងវិញ ម៉ៅ សេទុង សង្ឃឹមលើមនុស្សជំនិតចុងក្រោយ គឺ



**តេង ស៊ាវពីង និង ជូ អេនឡាយ**

នាយករដ្ឋមន្ត្រី ជូ អេនឡាយ ។

នៅក្នុងខែមីនា ឆ្នាំ១៩៧២ ជូ អេនឡាយ បានបញ្ជូនបញ្ជីឈ្មោះកម្មាភិបាលជាន់ខ្ពស់មានសមត្ថភាព ជាង៤០០នាក់ ក្នុងនោះ ក៏មាន តេង ស៊ាវពីង ម្នាក់ដែរ ទៅសុំការឯកភាពពី ម៉ៅ សេទុង ដើម្បីឲ្យពួកគេវិលត្រលប់មកពីជំរំលត់ដំនៅឯជនបទ ចូលមកបម្រើការងារនៅក្នុងទីក្រុងវិញ។ ពេលនោះ ម៉ៅ សេទុង នៅមិនទាន់ ទុកចិត្ត តេង ស៊ាវពីង នៅឡើយទេ។

រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧៣ ទើប ម៉ៅ សេទុង យល់ព្រមឲ្យ តេង ស៊ាវពីង បញ្ចប់ការលត់ដំខ្លួននៅជនបទស្រុកស្រែ ហើយវិលត្រលប់មកក្រុងប៉េកាំង វិញ។ ប៉ុន្តែ តេង ស៊ាវពីង ក៏នៅមិនទាន់ត្រូវបានតែងតាំងឲ្យកាន់មុខតំណែងណាមួយដែរ ព្រោះ ជៀង ឈិង (Jiang Qing) ជាភរិយាទី៤របស់ម៉ៅ សេទុង និងគូកន៣នាក់ទៀត ដែលសុទ្ធតែមានតំណែងជាសមាជិកដ៏មានឥទ្ធិពលនៅក្នុងជួរគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន ជាអ្នកប្រឆាំងជំទាស់នឹងការវិលត្រលប់មកកាន់តំណែងវិញរបស់ តេង ស៊ាវពីង។

តែដោយសារតែ ជូ អេនឡាយ បានធ្វើអន្តរាគមន៍ម្តងហើយម្តងទៀត នៅថ្ងៃទី២៨

## របត់នយោបាយ

ខែមីនា ឆ្នាំ១៩៧៣ ម៉ៅ សេទុង ក៏បានអនុញ្ញាតឲ្យ តេង ស៊ាវពីង ចូលជួបជាលើកដំបូង ចាប់តាំង ពីពេលបញ្ជូនគាត់ ឲ្យទៅរស់នៅធ្វើស្រែ ដើម្បីឲ្យលត់ដំកែប្រែខ្លួន តាំងពីឆ្នាំ១៩៦៩ នោះមក។

នៅល្ងាចថ្ងៃដដែលនោះ ជូ អេនឡាយ បានកោះប្រជុំគណៈអចិន្ត្រៃយ៍គណៈកម្មាធិការមជ្ឈិមបក្ស ហើយបានប្រកាសជាផ្លូវការ តែងតាំង តេង ស៊ាវភីង ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស។

ក្រោយពីបាត់មុខអស់រយៈពេល ៤ឆ្នាំ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៣ តេង ស៊ាវពីង បានចេញមុខជាសាធារណៈឡើងវិញជាលើកទីមួយ នៅក្នុងឱកាសជប់លៀងមួយ ថ្វាយជាព្រះកិត្តិយសចំពោះសម្តេចសីហនុ ក្នុងឋានៈជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ដឹកនាំចលនាតស៊ូ ដើម្បីប្រយុទ្ធប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ របស់សេនាប្រមុខ លន់ នល់ ។

នៅក្នុងឆ្នាំ១៩៧៤ ជូ អេនឡាយ ត្រូវធ្លាក់ខ្លួនឈឺធ្ងន់ដោយសារជំងឺមហារីក មិនអាចធ្វើការបាន តេង ស៊ាវពីង ត្រូវបាន ម៉ៅ សេទុង ប្រគល់ភារកិច្ចជានាយករដ្ឋមន្ត្រីស្តីទី។ ប៉ុន្តែ ការដំឡើងតំណែង តេង ស៊ាវពីង ជានាយករដ្ឋមន្ត្រីស្តីទីនេះ ធ្វើឱ្យ ជៀង ឈិង (Jiang Qing) ជាភរិយាទី៤របស់ម៉ៅ សេទុង និងគូកន៣នាក់ទៀត ដែលសុទ្ធតែជាសមាជិកដ៏មានឥទ្ធិពលនៅក្នុងគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន កាន់តែប្រណែននិន្ទា និងបន្តរករឿងមកវាយប្រហារ តេង ស៊ាវពីង ជាងពេលមុនៗទៅទៀត។

ក្រោយពី ជូ អេនឡាយ ទទួលមរណភាព នៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៦ មក ជៀង ឈិង ជាភរិយាទី៤ និងគូកន៣នាក់ទៀត បាននាំគ្នាចាក់រុក ម៉ៅ សេទុង ឱ្យដកតំណែង តេង ស៊ាវពីង ជាថ្មីម្តងទៀត។

នៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៦ អ្នកគាំទ្រ ជូ អេនឡាយ មួយក្រុម បានជួបជុំគ្នានៅទីលានធានអានមេន ក្នុងពិធីរម្លឹកវិញ្ញាណក្ខន្ធ ជូ អេនឡាយ បានរិះគន់ថា អ្នករៀបចំពិធីរម្លឹកវិញ្ញាណក្ខន្ធនោះ មិនបានរៀបចំឲ្យអធិកអធម ជូ អេនឡាយ ឲ្យស័ក្តិសម ជារដ្ឋបុរសដ៏ឆ្នើម ដែលពួកគេគោរពស្រលាញ់នោះទេ។



ស.ម.នារី ជៀង ឈិង ជាភរិយាទី៤ របស់ម៉ៅ សេទុង

ជាមួយគ្នានោះ ពួកគេក៏បាននាំគ្នាស្រែកគាំទ្រការដឹកនាំរបស់ តេង ស៊ាវពីង ផងដែរ។

ហេតុការណ៍ខាងលើនេះ ត្រូវបានបនទាំង៤ គឺ ជៀង ឈិង ជាភរិយាទី៤ របស់ម៉ៅ សេទុង និងគូកន៣នាក់ទៀត ចាត់ទុកថា ជាចលនាប្រឆាំងបដិវត្តន៍ ប្រឆាំងនឹងលោកប្រធាន ម៉ៅ ហើយបានចោទប្រកាន់ថា តេង ស៊ាវពីង ជាអ្នកញុះញង់ឲ្យមានចលនាប្រឆាំងនេះផងដែរ។

នៅថ្ងៃទី៧ ខែមេសា គឺ២ថ្ងៃក្រោយមានហេតុការណ៍នៅទីលានធានអានមេននោះ តាមបញ្ជារបស់ ម៉ៅ សេទុង គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន បាន បើកកិច្ចប្រជុំបន្ទាន់មួយ សម្រេចដកតំណែងជានាយករដ្ឋមន្ត្រីស្តីទី ពី តេង ស៊ាវពីង វិញ ហើយចាត់តាំង ហួ គួហ្វឹង ឱ្យឡើងជានាយករដ្ឋមន្ត្រី បន្តពី ជូ អេនឡាយ។

ជាមួយគ្នានោះដែរ ម៉ៅ សេទុង បានចាត់តាំង ហួ គួហ្វឹង ឲ្យកាន់តំណែងជាអនុលេខាទី១ នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន ផងដែរ ក្នុងបំណងបិទផ្លូវ មិនឲ្យ តេង ស៊ាវពីង អាចវិលត្រលប់មកកាន់អំណាចវិញបាន។

ក៏ប៉ុន្តែ ក្រោយមរណភាពរបស់ ម៉ៅ សេទុង នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ ហួ គួហ្វឹង ត្រូវឡើងជាលេខាគណៈកម្មាធិការមជ្ឈិមបក្សកម្មុយនិស្តចិន បានចេញបញ្ជាឲ្យចាប់ខ្លួនបនទាំង៤ ដែលរួមមាន៖ ១.ជៀង ឈិង ជាភរិយាទី៤របស់ ម៉ៅ សេទុង, យ៉ាវ វិនយាន, ចាង ឈុនឆៀវ និង វ៉ាង ហុងវិន យកទៅកាត់ទោស និងបោសសម្អាតក្រុមអ្នកមានគំនិតម៉ៅនិយមជ្រុល ចេញពីជួរថ្នាក់ដឹកនាំបក្សទៀតផង ។



**ចាង ឈុនឈៀវ, វ៉ាង ហុងវិន, យ៉ាវ វិនយាន និងជៀង ឈីង ពេលត្រូវកាត់ទោស**

នៅពាក់កណ្ដាលឆ្នាំ១៩៧៧ តេង ស៊ាវពីង ក៏ត្រូវបានតែងតាំងឲ្យកាន់តំណែងសំខាន់ៗឡើងវិញ រួមមាន តំណែងជាអនុលេខាគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន, អនុប្រធានគណៈកម្មាធិការកងទ័ពរំដោះប្រជាជនចិន និងជានាយសេនាធិការកងទ័ពរំដោះ ប្រជាជនចិន។

ទោះបីក្នុងឋានានុក្រម ហួ គួហ្វឹង មានតំណែងជាលេខាគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន និងជានាយករដ្ឋមន្ត្រី ក៏ពិតមែន តែជាក់ស្ដែង គឺ តេង ស៊ាវពីង ជាអនុលេខាគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន ជាអ្នកចាត់ចែងកិច្ចការសំខាន់ៗទាំងនៅក្នុងកិច្ចការបក្ស និងកិច្ចការរដ្ឋ។

ក្រោយពីបានឡើងកាន់អំណាច តេង ស៊ាវពីង បានប្រកាសបិទបញ្ចប់បដិវត្តន៍វប្បធម៌របស់ម៉ៅ សេទុង ហើយគ្រប់អ្នកដែលត្រូវរងគ្រោះដោយសារបដិវត្តន៍វប្បធម៌ទាំងអស់ ទោះបីជាអ្នកនោះបានស្លាប់ទៅហើយក្ដី កំពុងជាប់ទោសក្ដី ត្រូវបាន តេង ស៊ាវពីង ស្ដារនីតិសម្បទា លុបលាងទោសកំហុសវិញទាំងអស់ ក្នុងនោះសេនាប្រមុខ ប៉េង តឺហួយ (Peng Dehuai) ទោះបី គាត់ស្លាប់ទៅហើយ ក៏ពិតមែន គាត់គឺជាកម្មាភិបាលជាន់ខ្ពស់ដំបូងគេ ដែលត្រូវបានស្ដារនីតិសម្បទា និងបានចាត់ទុកថា ជាឧត្ដមសេនីយ៍ដ៏ជោគជ័យ និងជាទីគោរពបំផុត

ក្នុងប្រវត្តិសាស្ត្របក្សកុម្មុយនិស្តចិន។

ចំណែក វ៉ាង ក្វាងម៉ី ប្រពន្ធរបស់អតីតប្រធានាធិបតី លីវ ចាវជី ត្រូវជាប់នៅក្នុងពន្ធនាគារ អស់រយៈពេល១២ឆ្នាំ មកហើយនោះ ក៏ត្រូវបានដោះលែងវិញដែរ។

ទាក់ទងដល់ការធ្វើបដិវត្តន៍វប្បធម៌នៅប្រទេសចិន នោះដែរ យស់ ប៉ោ ជាអតីតខ្មែរឥស្សរៈ ដែលបានទៅរស់នៅទីក្រុងហាណូយ ក្រោយសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ ហើយត្រូវបានតែងតាំងជាអគ្គលេខាធិការរណសិរ្សសាមគ្គីសង្គ្រោះជាតិ ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្រោយថ្ងៃជ័យជម្នះថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ បានឱ្យដឹងថា នៅឆ្នាំ១៩៦៣ ពួកគាត់ជាអតីតខ្មែរឥស្សរៈ នៅទីក្រុងហាណូយ ត្រូវមេដឹកនាំវៀតណាមខាងជើង ជ្រើសរើសជាង៣០នាក់ បញ្ជូនឱ្យទៅរៀនសូត្រអប់រំបំពាក់បំប៉ននយោបាយកុម្មុយនិស្ត រយៈពេល៤ឆ្នាំ នៅប្រទេសចិន។

ពួកគាត់ ព្រមទាំងយុវជនបរទេសមួយចំនួនទៀត មកពីអាមេរិកឡាទីន ស្នាក់នៅធុងគី ក្នុងខេត្តស៊ីឈួន គ្មានរៀនសូត្រអ្វីផ្សេង ក្រៅពីរៀនសូត្រលទ្ធិម៉ៅនិយមនោះឡើយ។

ក្នុងពេលបដិវត្តន៍វប្បធម៌ចាប់ផ្តើមកក្រើកឡើងនោះ គាត់ឃើញយុវកម្មករ, យុវនិស្សិត និងយុវកសិករចិន វាយធ្វើបាប កាប់សម្លាប់គ្នាទៅវិញទៅមក។ ខ្លះបើកឡានបុកគ្នា ដើម្បីការពារទ្រឹស្តីរបស់ម៉ៅ សេទុង។

ការប្រយុទ្ធគ្នានៅតាមផ្លូវក៏មាន រថយន្តបើកបុកពួកនាយទុន ឬត្រូវគេសម្លាប់ចោល ហើយមួយចំនួនទៀតត្រូវគេបង្ខំឱ្យធ្វើអត្តឃាត។ អ្នកគាំទ្រ ម៉ៅ សេទុង ស្ទើរតែទាំងអស់គឺជាក្មេងៗសិស្សសាលា ពួកគេដើរវាយដំធ្វើបាបមនុស្សចាស់ៗ។ ពេលធ្វើបដិវត្តន៍វប្បធម៌នោះ ពួកចិន មិនអនុញ្ញាតឱ្យពួកគាត់ដើរទៅណាផ្តេសផ្តាសឡើយ។

យស់ ប៉ោ យល់ឃើញថា បដិវត្តន៍វប្បធម៌នោះ គ្មានអ្វីល្អប្រសើរទេ។ នៅក្នុងឆ្នាំ១៩៦៧ ពេលញប់ការសិក្សារយៈពេល៤ឆ្នាំ ពួកគាត់ក៏ត្រូវត្រលប់មកប្រទេសវៀតណាមខាងជើងវិញ។

# ១៨៤
# ប្រពន្ធកូនសម សារី ត្រូវបង្ខំឲ្យចាកចេញពីមាតុប្រទេស



ប្រពន្ធ និងកូនៗទាំង៥ របស់សម សារី កាលពីដើមទសវត្សរ៍ឆ្នាំ១៩៥០

នៅឆ្នាំ១៩៦៤ ទោះបីស្ថិតក្នុងសភាពភ័យខ្លាចលំបាកវេទនាយ៉ាងណាក៏ដោយ ក៏ម្តាយរបស់សម រង្ស៊ី ប្រឹងតស៊ូលះបង់គ្រប់បែបយ៉ាង ដើម្បីបញ្ជូនបងប្រុសបង្អស់របស់គាត់ ឈ្មោះ សម អេម៉្មារ៉ា ឱ្យបានទៅប្រទេសបារាំង ជិតមួយឆ្នាំមកហើយ។ តែពេលនោះ ពួកនិស្សិតខ្មែរនៅប្រទេសបារាំង ពិសេសនៅទីក្រុងប៉ារីស និងទីក្រុងម៉ុងប៉ឺលីយេរ បានធ្វើសកម្មភាពប្រឆាំងនឹងសម្តេចសីហនុ យ៉ាងខ្លាំងក្លា ។

សម រង្ស៊ី យល់ឃើញថា បងប្រុសគាត់ជានិស្សិតម្នាក់ដែរ តែមិនចូលចិត្តរឿងនយោបាយឡើយ។ តើសម្តេចសីហនុ ជឿថា បងប្រុសគាត់ជាអ្នកធ្វើសកម្មភាពប្រឆាំងព្រះអង្គជាមួយពួកនិស្សិតខ្មែរនៅប្រទេសបារាំងនោះ ដែរឬទេ? រឿងនេះប្រហែលជាមិនពិតទេ។ ថ្វីបើដូច្នោះក៏ដោយ ក៏គេចោទបងប្រុសគាត់ថា ជាអ្នកចូលរួមធ្វើសកម្មភាពប្រឆាំងនឹងសម្តេច

សីហនុ នៅប្រទេសបារាំង នោះដែរ។ តែតាមមើលទៅ នេះគ្រាន់តែជាល្បិចមួយ ដើម្បីនិរទេសម្ដាយគាត់ និងពួកគាត់ជាកូនៗ ឲ្យចេញពីប្រទេស តែប៉ុណ្ណោះ។

ចំណែកបងស្រីគាត់ ឈ្មោះ សម អេម៉្មារ៉ាន ក្រោយពីប្រលងជាប់បាក់ឌុបខាងទស្សនវិជ្ជា នៅវិទ្យាល័យដេកាដ នៅក្នុងឆ្នាំ១៩៦១មក បានប្រលងចូលរៀននៅសាលាភូមិន្ទរដ្ឋបាលបន្តទៀត។ ប៉ុន្តែ ដើម្បីបងស្រីចូលរៀនក្នុងសាលានេះបាន ក្រុមអតីតសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ជ័យវរ្ម័នទី៧ នៃសាលាភូមិន្ទរដ្ឋបាលនេះ ដែលបានចេញទៅបម្រើការងារក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ហើយនោះ ត្រូវស្នើសុំរាជាអនុញ្ញាតពីសម្ដេចសីហនុ ជាមុនសិន ពីព្រោះបងស្រីគាត់គឺជាកូនរបស់ សម សារី ដែលព្រះអង្គចាត់ទុកថា ជាជនក្បត់ជាតិ។ តែយ៉ាងណា សម្ដេចសីហនុ ក៏យល់ព្រមឱ្យបងស្រីចូលរៀនក្នុងសាលានេះ តាមការស្នើសុំនោះដែរ។ នៅសាលាភូមិន្ទរដ្ឋបាលនោះ មានសាស្ត្រាចារ្យជាជនជាតិបារាំង មួយចំនួនជាអ្នកបង្រៀនផងដែរ។

នៅក្នុងខែមករា ឆ្នាំ១៩៦៥ ពេលបងស្រីគាត់កំពុងរៀនថ្នាក់ឆ្នាំបញ្ចប់ ហើយជានិស្សិតស្រីតែម្នាក់គត់ដែលត្រូវទទួលសញ្ញាប័ត្រពីសាលាភូមិន្ទរដ្ឋបាល ក្នុងរយៈពេលដ៏ខ្លីខាងមុខ ស្រាប់តែមានមិត្តភក្តិម្នាក់បាននិយាយប្រាប់បងស្រីគាត់ថា កាលពីវេលាម៉ោង១២ថ្ងៃត្រង់មុននេះបន្តិច គេឮសម្ដេចសីហនុ ថ្លែងសុន្ទរកថាមួយផ្សាយផ្ទាល់តាមរលកធាតុអាកាសវិទ្យុជាតិ ដោយប្រើសំនួនវោហាថា សម សារី ជាជនក្បត់ជាតិ និងជាឆ្កែបម្រើពួកខ្មាំងសត្រូវបរទេសដូចពីពេលមុនៗដែរ។ ប៉ុន្តែ រឿងដែលគួរឱ្យភ្ញាក់ផ្អើលលើសសព្វមួយជងនោះ គឺព្រះអង្គមានបន្ទូលសង្កត់ធ្ងន់ថា ប្រពន្ធ និងកូនៗ របស់សម សារី ត្រូវតែចាកចេញពីប្រទេសខ្មែរ ចាប់តាំងពីពេលឥឡូវ នេះទៅ។

ក្រោយពីឮមិត្តភក្តិនិយាយ ប្រាប់ដូច្នេះ បងស្រីគាត់មិនអស់ចិត្ត ក៏បានទៅជួបសាស្ត្រាចារ្យបារាំង ដែលគាត់ស្រលាញ់ និងជឿទុកចិត្ត ដើម្បីសួរបញ្ជាក់ថា តើរឿងនេះប្រាកដ ដូចដែលមិត្តភក្តិគាត់បាននិយាយប្រាប់ នោះដែរឬទេ? ពេលនោះ សាស្ត្រាចារ្យបារាំងម្នាក់ឈ្មោះ ហ្សង់ ហ្ស៊ីកដង់ (Jean Giordan) ពីមុនជាមន្ត្រីជាន់ខ្ពស់បម្រើការងារនៅក្រសួងមហាផ្ទៃបារាំង បានបញ្ជាក់ប្រាប់ថា សម្ដេចសីហនុ ប្រាកដជាបានប្រកាសដូច្នេះមែន។

## របត់នយោបាយ



ស្ថានទូតបារាំង

សាស្ត្រាចារ្យបារាំង ហ្សង់ហ្ស៊ែកដង់ ដែលធ្លាប់តែស្រលាញ់រាប់អានក្រុមគ្រួសារគាត់តាំងពីដើមមកនោះ មានការព្រួយបារម្ភពីរឿងនេះខ្លាំងណាស់ ហើយបានណែនាំបងស្រីគាត់ថា ៖ ដំណោះស្រាយមានតែមួយគត់គឺ ៖ គ្រួសារអ្នកឯងត្រូវតែរត់ទៅស្ថានទូតបារាំង ដើម្បីសុំសិទ្ធិជ្រកកោននយោបាយ ខ្ញុំនឹងជួយ...។ ភ្លាមៗនោះ បងស្រីគាត់ក៏បានប្រញាប់ប្រញាល់ចាកចេញពីសាលា វិលមកផ្ទះវិញ ទាំងអារម្មណ៍តក់ស្លុតបំផុត។

នៅវេលាម៉ោង១៤រសៀល ពោលគឺរយៈពេលប្រហែល២ម៉ោងប៉ុណ្ណោះ ក្រោយពីការប្រកាសរបស់សម្តេចសីហនុ ក្រុមប៉ូលិស និងទាហានជាច្រើនបាននាំគ្នាចូលមកដល់ផ្ទះ និងបានស្រែកប្រាប់ម្តាយគាត់ថា ត្រូវរៀបចំខ្លួនចេញពីផ្ទះនេះជាបន្ទាន់ ហើយយកតែរបស់របរបន្តិចបន្តួចទៅជាមួយបានហើយ។ ចំណែកអត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែនត្រូវទុកនៅទីនេះ។ ឮដូច្នេះម្តាយគាត់គិតថា នេះជាពេលចុងក្រោយនៃជីវិតរបស់ពួកគាត់ហើយ។

បងស្រីគាត់ អេម្ម៉ាប៉ាន យំខ្សឹកខ្សួលបន្ទោសខ្លួនឯងថា នេះមកពីគាត់មិនព្រមធ្វើតាមការណែនាំរបស់សាស្ត្រាចារ្យ ហ្សង់ហ្ស៊ែកដង់ ដែលបានណែនាំគាត់ឱ្យរត់ទៅស្ថានទូតបារាំង ដើម្បីសុំសិទ្ធិជ្រកកោននយោបាយ។

តែម្តាយគាត់ គិតថា ពេលនោះទំនាក់ទំនងរវាងសម្តេចសីហនុ និងបារាំង មានភាពជិតស្និទ្ធគ្នាខ្លាំងណាស់ បើសិនជាពួកគាត់រត់ទៅសុំសិទ្ធិជ្រកកោននៅស្ថានទូតបារាំង ក៏គេមិនឱ្យជ្រកកោនដែរ។

ម្តាយគាត់ បានផ្តាំផ្ញើប្អូនស្រីជីដូនមួយពួកគាត់ម្នាក់ឈ្មោះគង់ ទើបមានអាយុ១០ឆ្នាំកំព្រាម្តាយ មកស្នាក់នៅជាមួយពួកគាត់ថា ប្រាប់ឪពុកឯងឲ្យមកយកតុទូកៅអីនៅក្នុងផ្ទះនេះ

យកទៅលក់ខ្លះ យកដាក់វត្តខ្លះ និងទុកប្រើប្រាស់ខ្លះ ហើយកុំភ្លេចមើលផ្ទៃឆ្នាផង។

ពេលកំពុងរៀបចំអីវ៉ាន់យ៉ាងញាប់ដៃនោះ ពួកគាត់សួរទៅពួកមន្ត្រីប៉ូលិស ដែលមកបង្ខំឱ្យពួកគាត់ចេញពីផ្ទះនោះថា តើពួកយើងមានទោសអ្វី? តើអស់លោកឱ្យពួកយើងទៅណា? តែគ្មាននរណាម្នាក់ឆ្លើយនឹងសំណួរនេះសោះ។

បងប្រុសគាត់ ឈ្មោះអេម៉្មាឫទ្ធិ កាន់តែមួម៉ៅខ្លាំងឡើងៗ លែងខ្លាចញញើតអ្វីទៀតនោះ បានទទូចសួររកហេតុផលដដែលៗថា តើពួកយើងមានទោសអ្វី? តើពួកយើងមានទោសអ្វី?... រហូតភ្នាក់ងារប៉ូលិសម្នាក់ ឆ្លើយថា៖ សុំទោស ពួកខ្ញុំមកនេះ គ្រាន់តែអនុវត្តតាមបញ្ជាពីថ្នាក់លើប៉ុណ្ណោះ កុំខឹងនឹងពួកខ្ញុំអី...។

លុះដល់ម៉ោងប្រហែល៧យប់ មានរថយន្តដឹកអ្នកទោសមួយគ្រឿងបានមកឈប់នៅមុខផ្ទះ ខណៈផ្លូវជុំវិញផ្ទះត្រូវគេបិទឃាំងដោយរនាំងដែកជាច្រើន ដែលមើលទៅហាក់ដូចជាពួកគេកំពុងឡោមព័ទ្ធចាប់ក្រុមជនឧក្រិដ្ឋដ៏កាចសាហាវបំផុត។

ទីបំផុត ពួកគាត់នាំគ្នាលើកជញ្ជូនកញ្ចប់ស្បោងដាក់អីវ៉ាន់ និងវ៉ាលិសដោយខ្លួនឯងដាក់ទៅក្នុងរថយន្តដឹកអ្នកទោសនោះ។ ពេលឃើញប្អូនស្រីជីដូនមួយគាត់ ឈ្មោះគង់ រត់មកឱបពួកគាត់ មានភ្នាក់ងារប៉ូលិសម្នាក់បានមករុញច្រានចេញ រួចបញ្ជាឱ្យពួកគាត់ចូលទៅក្នុងរថយន្ត ហើយទ្វាររថយន្តត្រូវបិទពីក្រោយខ្នងពួកគាត់ លាន់សូរ ក្ដាំង។

សម រង្ស៊ី បានរម្លឹកថា ពេលនោះ ភ្នាក់ងារប៉ូលិសចំនួន៥នាក់ ដែលនៅក្នុងរថយន្តជាមួយពួកគាត់នោះ ម្នាក់ៗ មានកាំភ្លើងខ្លីមួយដើមសៀតនៅជាប់នឹងចង្កេះ និងមានកាំភ្លើងវែងមួយដើម ដាក់សណ្ដូកនៅក្បែរជើងខាងក្រោមកៅអីអង្គុយ បានបញ្ជាឱ្យរថយន្តចេញដំណើរ។

ពេលរថយន្តបានដឹកពួកគាត់ចេញពីក្រុងភ្នំពេញ ទៅតាមបណ្ដោយផ្លូវជាតិលេខ១ បានចម្ងាយប្រហែលជា៣០គីឡូម៉ែត្រ ក៏ឈប់នៅកន្លែងស្ងាត់មួយ ដែលមើលតាមភ្លើងហ្វាររថយន្ត ឃើញមានព្រៃស្បាតទាបៗនៅសងខាងផ្លូវ។ ភ្នាក់ងារប៉ូលិសនាំគ្នាចុះពីលើរថយន្តដើរទៅក្នុងព្រៃងងឹតនៅខាងស្ដាំថ្នល់ បាត់ស្រមោល។

## របត់នយោបាយ

ម្ដាយគាត់ធ្លាប់ឮអ្នករស់នៅក្នុងក្រុងភ្នំពេញ ជាមួយគ្នា និយាយពីមាត់មួយទៅមាត់មួយថា ជារឿយៗ ពួកភ្នាក់ងារប៉ូលិសតែងដឹកពួកអ្នកនយោបាយមាននិន្នាការប្រឆាំង យកមកបាញ់សម្លាប់ចោលនៅទីស្ងាត់បែបនេះ ដោយយកលេសថា អ្នកប្រឆាំងទាំងនោះរត់គេចខ្លួន ហៅមិនឈប់ ហើយបាញ់សម្លាប់ពីក្រោយ តែម្ដង។

ម្ដាយគាត់គិតថា ពួកគេប្រាកដជាបាញ់សម្លាប់ពួកគាត់ចោលនៅទីនេះមិនខាន។ ម្ដាយគាត់តាំងស្មារតីឱ្យរឹងមាំ រួចខ្សឹបប្រាប់ពួកគាត់ថា៖ កូនៗទាំងអស់នាំគ្នាសូត្រធម៌ឡើង ព្រោះនៅពេលបន្តិចទៀត ពួកគេនឹងឱ្យពួកយើងចុះពីរថយន្ត ហើយបាញ់សម្លាប់ពួកយើងជាមិនខាន។ តែកូនទាំងអស់ត្រូវតាំងចិត្តឲ្យក្លាហាន និងនឹកទៅដល់ប៉ារបស់កូន និងសេចក្ដីក្លាហានរបស់ប៉ាកូន។ ម៉ាក់ស្រលាញ់កូនទាំងអស់ខ្លាំងណាស់...។

ប៉ុន្តែ បន្តិចក្រោយមក ពួកភ្នាក់ងារប៉ូលិស ដែលចុះពីលើរថយន្តនោះ ក៏ត្រលប់មកបើកទ្វារចូលក្នុងរថយន្តវិញ ហើយប្រាប់អ្នកបើកបរឲ្យបន្តដំណើរទៅមុខទៀត។

រថយន្តដឹកអ្នកទោស ដឹកពួកគាត់បន្តដំណើររហូតដល់ពេលទៀបភ្លឺ ពន្លឺព្រះអាទិត្យចាំងពណ៌ក្រហមព្រឿងៗ ទើបទៅដល់មុខប៉ុស្តិ៍ច្រកទ្វារបាវិត ជាចំណុចព្រំដែនខ្មែរ និងវៀត-ណាមខាងត្បូង ដោយមានលាន់សូរកាំភ្លើងតូចធំលាន់កក្រើកនៅក្នុងទឹកដីប្រទេសវៀតណាមខាងត្បូង ទទួលស្វាគមន៍គួរឱ្យរន្ធត់ផងដែរ។

រថយន្តបានឈប់នៅមុខប៉ុស្តិ៍ត្រួតពិនិត្យរបស់ប៉ូលិសច្រកទ្វារ ពួកគាត់ត្រូវរង់ចាំនៅក្នុងរថយន្ត។ ចំណែកពួកប៉ូលិស ដែលជូនដំណើរពួកគាត់មក បាននាំគ្នាចុះទៅនិយាយទាក់ទងគ្នាយ៉ាងយូរជាមួយពួកមន្ត្រីប៉ូលិស ដែលប្រចាំការនៅក្នុងប៉ុស្តិ៍ត្រួតពិនិត្យនោះ។

មួយសន្ទុះធំ ទើបមន្ត្រីប៉ូលិសម្នាក់ដើរមកប្រាប់ពួកគាត់ឲ្យនាំគ្នារើអីវ៉ាន់ចុះពីលើរថយន្ត ហើយណែនាំពួកគាត់ថា៖ ពេលណា ឮស្នូរខ្ញុំបាញ់កាំភ្លើងឡើងលើ ពួកអ្នកឯងត្រូវតែរត់ឆ្លងព្រំដែនតម្រង់ចូលទៅក្នុងទឹកដីវៀតណាម ភ្លាមៗតែម្ដង។

ពេលនោះដែរ មេប៉ូលិសនៅប៉ុស្តិ៍ច្រកទ្វារព្រំដែន បានបើករនាំងបន្លាលួស រង់ចាំឱ្យការវាយប្រយុទ្ធគ្នាស៊ីសាច់ហុតឈាមរវាងកងទ័ពវៀតណាមខាងត្បូង និងសម្ព័ន្ធមិត្តអាមេរិក

ជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង ស្ងប់គ្រាប់កាំភ្លើងបន្តិចសិន។

ពួកគាត់បារម្មណ៍ថា ពេលពួកគាត់រត់ឆ្លងព្រំដែន ចូលទៅក្នុងទឹកដីវៀតណាមនោះ តើពួកប៉ូលិសនៅព្រំដែននោះ នឹងឆ្លៀតឱកាសបាញ់សម្លាប់ពួកគាត់ពីក្រោយខ្នង ឬមួយពួកគាត់ត្រូវស្លាប់ដោយសារគ្រាប់កាំភ្លើងរបស់គូសត្រូវ ដែលកំពុងវាយប្រយុទ្ធគ្នា យ៉ាងស៊ីសាច់ហុតឈាមនោះ?។

បន្តិចក្រោយមក ក៏លាន់ឮស្នូរកាំភ្លើងប៉ូលិសខ្មែរ បាញ់ឡើងលើ ម្តាយគាត់ក៏ស្រែកប្រាប់កូនៗទាំង៤នាក់ថា៖ រត់តាមម៉ាក់មក ហើយកុំចោលអីវ៉ាន់ឱ្យសោះ!។

សម រង្ស៊ី បានរម្លឹកពីព្រឹត្តិការណ៍រត់ឆ្លងព្រំដែននោះថា ដោយសារមានការភិតភ័យខ្លាំងពេក គាត់មិនបានចាំថា ពេលនោះតើពួកគាត់នាំគ្នារត់ពីប៉ុស្តិ៍ព្រំដែនខ្មែរ ចូលទៅក្នុងទឹកដីវៀតណាម អស់រយៈពេលប៉ុន្មានម៉ោងទេ?។ គាត់គ្រាន់តែនៅចាំថា ពេលខ្លះពួកគាត់ត្រូវរត់ ពេលខ្លះត្រូវដើរលឿនៗ ពេលខ្លះត្រូវឈប់សម្រាក ដើម្បីដកដង្ហើមឱ្យបានស្រួលឡើងវិញ។

ការបាញ់ប្រយុទ្ធគ្នាកាន់តែមានសភាពខ្លាំងឡើងៗ ពួកគាត់បានរត់គេចពីផ្លូវលំ ចូលទៅផ្លូវថ្មើរជើងមួយមានដើមឈើធំៗ ដែលអាចឲ្យពួកគាត់មានសុវត្ថិភាព ក្នុងការការពារខ្លួនពីគ្រាប់កាំភ្លើងបាន។ បាតជើងគាត់ហើម ហើយឈឺខ្លាំង ពីព្រោះគាត់រត់ជាន់បន្លា ជាន់គ្រាប់គ្រួសស្រួចៗនៅលើផ្លូវ ដែលមានស្នាមរណ្តៅគ្រាប់ផ្លោងធ្លាក់ក្រហេងក្រហូង។

រហូតដល់ពេលព្រលប់ព្រាលៗ ដោយមិនដឹងថា ត្រូវរត់ទៅទីណា ពេលពួកគាត់បានឃើញមនុស្សប្រុសស្រីក្មេងចាស់មួយក្រុមនាំគ្នារត់នៅខាងមុខ ពួកគាត់ក៏ព្យាយាមរត់ឱ្យទាន់ពួកគេដែរ ប៉ុន្តែ ពួកគាត់មិនអាចរត់ទាន់ ដោយសារពួកគាត់មានអីវ៉ាន់សំពីងសំពោងច្រើនពេក ហើយម្យ៉ាងយប់ងងឹតក៏បានមកដល់ មើលពួកគេ ក៏លែងឃើញដែរ។

ពួកគាត់បានសម្រាកនៅជិតបន្ទាយរបស់ទាហានវៀតណាមខាងត្បូង ដែលពេលថ្ងៃរះភ្លឺឡើង ទើបដឹងថា បន្ទាយនោះស្ថិតនៅជិតទីរួមខេត្តតៃនិញ មានចម្ងាយប្រមាណ៣០គីឡូម៉ែត្រ ពីប៉ុស្តិ៍ព្រំដែនបាវិត។

## របត់នយោបាយ

ម្តាយគាត់ចេះភាសាវៀតណាមច្រើនគួរសមដែរ ព្រោះធ្លាប់បានរៀនសូត្រ រហូតដល់ប្រលងជាប់បាក់ឌុបនៅវិទ្យាល័យហ្សាស្សឺលូ ឡូបា (Chasseloup-laubat) ក្នុងទីក្រុងព្រៃនគរ តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៤០មកម្ល៉េះ។

ពេលនាយទាហានវៀតណាមនាំទៅសាកសួរ ម្តាយគាត់បានរៀបរាប់ពីដំណើររឿងតាំងពីដើមទី រហូតដល់ពេលត្រូវគេនិរទេស បង្ខំឱ្យពួកគាត់រត់ចូលមកក្នុងទឹកដីវៀតណាមខាងត្បូងនេះ ព្រមទាំងបានប្រាប់ថា ប្តីគាត់ ឈ្មោះ សម សារី ជាមេខ្មែរសេរី កំពុងឋិតនៅក្នុងប្រទេសវៀតណាមខាងត្បូង នេះដែរ។ តែនាយទាហានវៀតណាមនោះ មិនដឹងថា ឈ្មោះ សម សារី ជានរណាទេ គេមិនស្គាល់ឡើយ? ហើយនាយទាហានវៀតណាមនោះ កាន់តែមិនទុកចិត្តថែមទៀត ព្រោះពួកគាត់គ្មានអត្តសញ្ញាណប័ណ្ណ គ្មានលិខិតឆ្លងដែន បង្ហាញជាភស្តុតាង។ ពួកគេសង្ស័យថា ពួកគាត់ជាគិញសម្ងាត់របស់ខ្មែរ?។

ម្តាយគាត់ព្យាយាមនិយាយពន្យល់ម្តងហើយ ម្តងទៀត ពីមូលហេតុដែលនាំឲ្យពួកគាត់ត្រូវអាជ្ញាធរសម្តេចសីហនុ និរទេសឱ្យចាកចេញពីប្រទេសខ្មែរ ចូលមកក្នុងប្រទេសវៀតណាម និងមូលហេតុ ដែលពួកគាត់គ្មានអត្តសញ្ញាណប័ណ្ណ គ្មានលិខិតឆ្លងដែននៅជាប់នឹងខ្លួនឱ្យពួកគេបានយល់។

នៅទីបំផុត នាយទាហានវៀតណាម ក៏បានបញ្ជូនព័ត៌មាននេះតាមវិទ្យុទាក់ទងទៅទីក្រុងសៃហ្គន (ព្រៃនគរ)។ ប្រហែល២ម៉ោងក្រោយមក នាយទាហានវៀតណាម នៅបន្ទាយនោះ បានមកប្រាប់ម្តាយគាត់ថា ពួកគេទើបតែទទួលបានចម្លើយពីក្រុងសៃហ្គនមកថា ថ្នាក់លើនឹងធ្វើការស្រាវជ្រាវពីករណីពួកគាត់នេះ តែចាំបាច់ត្រូវប្រើពេលយូរបន្តិច ហើយពួកគាត់អាចសម្រាកនៅក្នុងបន្ទាយនេះបាន។

នៅក្នុងបន្ទាយនោះ មានជនភៀសសឹករាប់រយនាក់ ដោយអ្នកខ្លះសម្រាកនៅក្នុងរោងឈើវែងនោះ និងខ្លះទៀតសម្រាកនៅក្នុងរោងប្រក់ស័ង្កសីមួយស្ថិតនៅទីវាលស្រឡះក្បែរនោះដែរ។ ពួកគាត់ត្រូវគេឲ្យទៅសម្រាកនៅក្នុងរោងឈើវែងមួយ ដែលមើលទៅដូចជាឃ្លាំងទុកអីវ៉ាន់ មានដំបូលពាក់កណ្តាលផ្ទះឆ្លាយ។




**មូលដ្ឋានកងទ័ពអាមេរិក និងវៀតណាមខាងត្បូង នៅខេត្តតៃនិញ**

ទាហានវៀតណាមម្នាក់ បានប្រាប់ពួកគាត់ថា នៅក្នុងបន្ទាយនេះមានអ្នកភៀសសឹកខ្មែរ និងវៀតណាមច្រើនរយនាក់ ក្នុងនោះអ្នកខ្លះជាអ្នកសុំទាន អ្នកខ្លះជាស្រីពេស្យា អ្នកខ្លះជាចោរ អ្នកខ្លះជាអ្នករត់ពន្ធ និងអ្នកខ្លះទៀតជាឃាតករ។ ដូច្នេះ គេណែនាំពួកគាត់ឲ្យមានការប្រុងប្រយ័ត្នទាំងយប់ទាំងថ្ងៃ ព្រោះខ្លាចពួកជនខិលខូចលួចអីវ៉ាន់របស់ពួកគាត់។

ក្នុងរយៈសម្រាកជាបណ្ដោះអាសន្ននៅក្នុងបន្ទាយនោះ ចំនួន៤ថ្ងៃ ពួកគាត់បានយករបស់របរបន្តិចបន្តួចយកពីភ្នំពេញ ទៅដោះដូរចំណីបន្តិចបន្តួចពីជនជាតិវៀតណាមដែលស្នាក់នៅជាមួយគ្នាក្នុងបន្ទាយនោះ ហើយស្ទើរតែជារៀងរាល់ថ្ងៃ ពេលមានគ្រាប់កាំភ្លើងធំធ្លាក់មកក្នុងបន្ទាយម្ដងៗ ទាំងអស់គ្នាត្រូវរត់ចូលក្នុងលេណដ្ឋាន ឬក្រាបនៅនឹងដីដើម្បីគេចពីគ្រោះថ្នាក់។

# ១៨៥
# កូនៗ និងប្រពន្ធ សម សារី សង្ឃឹមបានជួបឪពុក និងប្ដី ហេតុអ្វី ជួបតែ សឹង ង៉ុកថាញ់ ?



សម សារី ព្រមទាំងប្រពន្ធ និងកូនៗទាំង៥នាក់ កាលពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៥០

៤ថ្ងៃក្រោយមកទៀត នាយទាហានវៀតណាមម្នាក់ បានមកប្រាប់ពួកគាត់ថា គេទើបនឹងបានទទួលបញ្ជាពីចៅហ្វាយនាយរបស់គេពីក្រុងសៃហ្គន(ព្រៃនគរ) ឱ្យពួកគាត់រៀបចំខ្លួនចេញពីបន្ទាយនោះ ដោយមានរថយន្តកងទ័ពមួយគ្រឿងចូលមក ទទួលពួកគាត់ផងដែរ។

អ្នកបើកបរជួយលើកអីវ៉ាន់ដាក់ក្នុងរថយន្ត រួចចេញដំណើរឆ្ពោះទៅនិវេសនដ្ឋានចៅហ្វាយខេត្តតៃនិញ។ និវេសនដ្ឋាននោះ ជាភូមិគ្រឹះសម័យអាណានិគមបារាំង មានកម្ពស់ពីរជាន់ គេឱ្យពួកគាត់សម្រាកក្នុងបន្ទប់មួយ មានគ្រែស្អាតៗ និងមានម្ហូបអាហារឆ្ងាញ់ៗ។ សហការីរបស់ចៅហ្វាយខេត្តតៃនិញ ក៏បានមកសម្ដែងការគួរសមចំពោះម្ដាយគាត់យ៉ាងរាក់ទាក់បំផុត។

បីថ្ងៃក្រោយមក ឧទ្ធម្ភាគចក្រចម្បាំងមួយគ្រឿងបានមកដឹកពួកគាត់នាំយកទៅក្រុង

សៃហ្គន ធ្វើឱ្យពួកគាត់សប្បាយរីករាយជាទីបំផុត ព្រោះសង្ឃឹមថា បានទៅជួបមុខប្ដី និងឪពុករបស់ពួកគាត់ជាមិនខាន។

ពេលឧទ្ធម្ភាគចក្របន្ទាបខ្លួនចុះចតនៅអាកាសយានដ្ឋាន មានរថយន្តប្រណីតពណ៌ខ្មៅមួយគ្រឿងបានបើកចូលមក ម្ដាយគាត់ឱនខ្សឹបប្រាប់កូនៗថា៖ នុះ!ឪពុកកូនមកទទួលពួកយើងហើយ។ តែគួរឱ្យសោកស្ដាយ នៅក្នុងរថយន្តដ៏ប្រណីតនោះមានតែអ្នកបើកបរតែម្នាក់ប៉ុណ្ណោះ គេមានកាតព្វកិច្ចជូនពួកគាត់ទៅដាក់នៅភូមិគ្រឹះប្រណីតមួយ ដែលរដ្ឋាភិបាលវៀតណាមខាងត្បូង រៀបចំទុកជាស្រេច ដើម្បីឲ្យពួកគាត់ស្នាក់នៅ។

សម រង្ស៊ី នៅចាំបានថា ពេលពួកគាត់ស្នាក់នៅភូមិគ្រឹះប្រណីតនោះ វរសេនីយ៍ឯកភ្នាក់ងារសម្ងាត់វៀតណាមម្នាក់ ឈ្មោះឡុង រាងទាបក្រអាញ ត្រូវបានរដ្ឋាភិបាលវៀតណាមខាងត្បូង ចាត់ឱ្យមកធ្វើជាអ្នកទទួលខុសត្រូវ និងជួយសម្របសម្រួលរាល់សេចក្ដីត្រូវការរបស់ពួកគាត់។ វរសេនីយ៍ឯកជាភ្នាក់ងារសម្ងាត់រូបនេះ ក៏បានសាកសួរពីព័ត៌មានផ្សេងៗដែលទាក់ទងនឹងស្ថានភាពនយោបាយនៅទីក្រុងភ្នំពេញ ពីម្ដាយគាត់វិញដែរ។

ជាមួយគ្នានោះ វរសេនីយ៍ឯកឡុង ក៏ចង់ដឹងពីជម្លោះក្នុងរាជវង្សខ្មែរថា តើហេតុអ្វីបានជាមានការប្រណាំងប្រជែងគ្នារវាងសៃស្រឡាយ នរោត្តម និងសៃស្រឡាយ ស៊ីសុវត្ថិ? តើហេតុដូចម្ដេចបានជាសៃ នរោត្តម មានប្រៀបជាងសៃស៊ីសុវត្ថិ? តើសម្ដេចសីហនុ ប្រើវិធីអ្វី ដើម្បីយកឈ្នះរាជវង្សខ្មែរដទៃទៀត? តើមូលហេតុអ្វី បានជាព្រះអង្គម្ចាស់ស៊ីសុវត្ថិយុត្តិវង្ស ដែលមានបញ្ញាឈ្លាសវៃក្នុងការដឹកនាំប្រទេស ទទួលមរណភាព? តើមរណភាពនេះ ធ្វើឲ្យប្រជាពលរដ្ឋខ្មែរមានការចាប់អារម្មណ៍យ៉ាងណាដែរ? ពិសេស វរសេនីយ៍ឯកឡុងសួរថា តើមានអ្នកណាខ្លះ មានបំណងបង្កើតកងកម្លាំង ដើម្បីផ្ដួលរម្លំសម្ដេចសីហនុ? តើឪពុកមារបស់សម្ដេចសីហនុ គឺព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ឬមួយព្រះអង្គម្ចាស់ស៊ីសុវត្ថិសិរិមតៈ ជាអ្នករៀបចំផែនការប្រឆាំងសម្ដេចសីហនុ? តើពួកគេទាំងនោះអាចទៅពឹងពាក់នរណាឲ្យជួយ?...។

ពេលនោះ ម្ដាយគាត់មិនបានដឹងរឿងអ្វី ដែលពាក់ព័ន្ធនឹងសំណួរខាងលើនេះទេ ម្ដាយ




**ទីក្រុងសៃហ្គន ក្នុងទសវត្សរ៍ឆ្នាំ១៩៦០**

គាត់គ្រាន់តែដឹងរឿងរ៉ាវមិនចុះសម្រុងគ្នារវាងឪពុកគាត់ ជាមួយសម្តេចសីហនុ ដូចដែល ឪពុកគាត់ធ្លាប់បាននិយាយប្រាប់ម្តាយតែប៉ុណ្ណោះ។

អ្វីដែលពួកគាត់អន្ទះសាចង់ដឹងបំផុតនោះ គឺសម សារី ឪពុករបស់ពួកគាត់ ដែលបានរត់គេចខ្លួនពីទីក្រុងភ្នំពេញ មកនៅប្រទេសវៀតណាមខាងត្បូង អស់រយៈពេល៦ ឆ្នាំមកហើយ ពួកគាត់មិនដែលបានទទួលដំណឹងអ្វីបន្តិចទាល់តែសោះ។

ពួកគាត់ជឿជាក់ថា វរសេនីយ៍ឯក ឡុង ប្រាកដជាដឹងព័ត៌មានខ្លះៗពីប្តី និងឪពុកពួកគាត់ជាមិនខាន។ តែគេមិនដែលបង្ហើបប្រាប់ពីរឿងប្តី និងឪពុកពួកគាត់ សូម្បីបន្តិចឡើយ។

ក្រោយពីប្រពន្ធ និងកូនៗរបស់ សម សារី ស្នាក់នៅភូមិគ្រឹះប្រណីតមួយតាមបណ្តោយផ្លូវទៅអាកាសយានដ្ឋាននោះ បានរយៈពេលបីខែ ហើយនៅតែគ្មានដំណឹងពីប្តី និងឪពុកដដែលនោះ ពួកគាត់ក៏សង្កេតឃើញវរសេនីយ៍ឯកភ្នាក់ងារសម្ងាត់វៀតណាម ឈ្មោះឡុង លែងសូវរវីរវល់ជាមួយពួកគាត់ ដូចពេលមុនៗទៀតដែរ។

សម រង្ស៊ី បានរម្លឹកបន្តថា ម្ដាយគាត់បានប្រាប់ពួកគាត់ថា មានថ្ងៃមួយ វរសេនីយ៍ឯក ឡុង បានផ្ដោយមាត់និយាយជាមួយគាត់ថា៖ ពីមុន សម សារី ជាមនុស្សគួរឱ្យគោរពខ្លាំងណាស់...។

មិនយូរប៉ុន្មាន ពួកគេបានផ្លាស់ប្ដូរពួកគាត់ចេញពីភូមិគ្រឹះប្រណីត ដែលគេឱ្យពួកគាត់ស្នាក់នៅតាំងពីមកដល់ទីក្រុងសៃហ្គន ដំបូងនោះ ឱ្យទៅស្នាក់នៅផ្ទះធម្មតាមួយវិញ។

ចាប់ពីពេលនោះមក វរសេនីយ៍ឯក ឡុង មិនត្រឹមតែមិនសូវមានការគួរសមចំពោះពួកគាត់ ដូចមុនៗទេ គឺមានពេលមួយ គេបានបញ្ជាឱ្យកូនចៅគេ មកឆែកឆេរផ្ទះ ដែលពួកគាត់មកស្នាក់នៅថ្មីនោះទៀតផង។

លើសពីនេះទៅទៀត វរសេនីយ៍ឯក ឡុង បានគំរាមម្ដាយគាត់ថា៖ សូមលោកស្រីជ្រាបណា! មិនត្រឹមតែអនាគតរបស់លោកស្រី និងកូនៗទេ សូម្បីតែជីវិតរបស់លោកស្រី និងកូនៗ ក៏ស្ថិតនៅក្នុងកណ្ដាប់ដៃរបស់ពួកយើងដែរ។

ក្រោយពីមកស្នាក់នៅកន្លែងថ្មីមួយរយៈខ្លីមក មានបុរសម្នាក់រាងទាប សម្បុរខ្មៅស្រអែម ពាក់វ៉ែនតា ពាក់អាវកុតស្ដើង មានអង្គរក្សហែហមជាច្រើនផង បានមកជួបពួកគាត់។

បុរសម្នាក់នោះ ឈ្មោះ សឺង ង៉ុកថាញ់ មេចលនាខ្មែរសេរី មានឈ្មោះល្បីជាសត្រូវស្ឋរពូជរបស់សម្ដេចសីហនុ។ ពេលនោះ ពួកគាត់សង្ឃឹមថា នឹងបានទទួលដំណឹងពីឪពុកជាមិនខាន ព្រោះនរណាក៏ដឹងថា ឪពុកគាត់បានរត់គេចខ្លួនពីក្រុងភ្នំពេញ មករួបរួមជាមួយ សឺង ង៉ុកថាញ់ ដឹកនាំចលនាតស៊ូខ្មែរសេរី តាំងពីឆ្នាំ១៩៥៩មកម្ល៉េះ។

សម រង្ស៊ី បានរម្លឹកថា សឺង ង៉ុកថាញ់ បានលើកដៃសំពះម្ដាយពួកគាត់តាមប្រពៃណីខ្មែរ ដែលនេះជាការបង្ហាញនូវការគោរពដ៏ជ្រាលជ្រៅបំផុត ព្រោះក្នុងឋានៈសឺង ង៉ុកថាញ់ ជាអតីតនាយករដ្ឋមន្ត្រីម្នាក់ដែរនោះ មិនចាំបាច់គោរពគួរសមម្ដាយគាត់ដល់ថ្នាក់នេះទេ។ ប៉ុន្តែគួរឱ្យសោកស្ដាយ សឺង ង៉ុកថាញ់ មិនបាននិយាយអ្វីពីឪពុកគាត់បន្តិចឡើយ ហើយអ្វីធ្វើឲ្យពួកគាត់មានការខកចិត្ត និងមានការភ្ញាក់ផ្អើលបំផុតនោះ គឺសឺង ង៉ុកថាញ់ បាននិយាយច្បាស់នៅចំពោះមុខពួកគាត់ថា សម សារី ដែលរត់គេចខ្លួនមកប្រទេសវៀតណាម នេះ ព្រោះ



សឺង ង៉ុកថាញ់

តែមានរឿងផ្ទាល់ ខ្លួនប៉ុណ្ណោះ។ ពេលនោះ ម្ដាយគាត់ក៏ពុំដឹងថាត្រូវតបតទៅសឺង ង៉ុកថាញ់ វិញយ៉ាងដូចម្ដេចដែរ។

តែយ៉ាងណា នៅទីបញ្ចប់ សឺង ង៉ុកថាញ់ បានសួរម្ដាយគាត់ថា តើលោក-ស្រីចង់បានអ្វី? មួយសន្ទុះធំ ទើបម្ដាយគាត់ប្រាប់ថា៖ ពួកយើងត្រូវការប្រាក់...។ សឺង ង៉ុកថាញ់ ប្រាប់ម្ដាយគាត់យ៉ាងខ្លីថា៖ លោកស្រីនឹងទទួលបានប្រាក់មួយចំនួន។ រួចសឺង ង៉ុកថាញ់ ក៏លាចេញទៅវិញ ដោយមិនបានសម្ដែងការគួរសមអ្វីបន្តិចដូចកាលពីដំបូងទីឡើយ។

សម រង្ស៊ី បានបង្ហើបឱ្យដឹងថា ក្រោយមក ទើបពួកគាត់យល់ន័យនៃពាក្យ ដែលសឺង ង៉ុកថាញ់ បាននិយាយថា ឪពុកគាត់រត់មកប្រទេសវៀតណាមនេះ ព្រោះតែមានរឿងផ្ទាល់ខ្លួននោះ។

សម រង្ស៊ី យល់ឃើញថា នេះជាការនិយាយបន្ទាបបន្ថោកឪពុកគាត់ជាអ្នកដឹកនាំប្រឆាំងម្នាក់ គ្មានទម្ងន់នយោបាយអ្វីឡើយ ហើយវាជាការបញ្ជាក់ឱ្យឃើញច្បាស់ពីការបែកបាក់ខ្វែងគំនិតគ្នាយ៉ាងជ្រាលជ្រៅ រវាងថ្នាក់ដឹកនាំក្នុងចលនាខ្មែរសេរី ផងដែរ។

សម រង្ស៊ី យល់ឃើញបន្តទៀតថា មូលហេតុដែលនាំឱ្យមានការបែកបាក់ខ្វែងគំនិតគ្នារវាងឪពុកគាត់ជាមួយ សឺង ង៉ុកថាញ់នេះ គឺទី១ ឪពុកគាត់ជាអ្នកទាមទារឯករាជ្យជាតិពីបារាំងម្នាក់ ក្នុងចំណោមអ្នកទាមទារឯករាជ្យដទៃទៀតជាច្រើនទៀត កាលសម័យពីសម័យអាណានិគម បារាំង ក៏ពិតមែន។ ប៉ុន្តែ ឪពុកគាត់នៅតែមានសមានចិត្តចំពោះប្រទេសបារាំង។

ម្យ៉ាងទៀតឪពុកគាត់ជាអ្នកនយោបាយម្នាក់ មានបំណងចង់ឱ្យមានការកែទម្រង់នយោ-

បាយសន្សឹមៗ ដោយមានបំណងចង់ឱ្យមានរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញដែលផ្ទុយពីបំណងរបស់ សឺង ង៉ុកថាញ់ ដែលចង់ឱ្យមានរបបសាធារណរដ្ឋនិយម។ ដូច្នេះគួរឱ្យឆ្ងល់ដែរថា តើហេតុដូចម្តេច បានជាឪពុកគាត់បែរជាទៅចូលរួមក្នុងការតស៊ូជាមួយចលនាខ្មែរសេរី ប្រឆាំងនឹងសម្តេចសីហនុ ទៅវិញ?។

សម រង្ស៊ី មានការស្រពិចស្រពិលថា មែនហើយ សម្តេចសីហនុ បានធ្វើឲ្យឪពុកគាត់ខកចិត្តយ៉ាងខ្លាំង ក៏ប៉ុន្តែឪពុកគាត់នៅតែមានការគោរពយ៉ាងជ្រាលជ្រៅចំពោះសម្តេចសីហនុ។ ឪពុកគាត់ដឹងច្បាស់ថា នៅកម្ពុជា មានតែសម្តេចសីហនុ តែមួយអង្គគត់ ដែលអាចប្រមែប្រមូលបង្រួបបង្រួមការបែកបាក់ខ្មែរបាន។

តែគាត់ក៏ពិបាកយល់ដែរថា បើដូច្នេះមែន តើហេតុអ្វី បានជាឪពុកគាត់សុខចិត្តរត់ទៅចូលរួមជាមួយចលនាខ្មែរសេរីរបស់ សឺង ង៉ុកថាញ់ ដែលគាំទ្រដោយវៀតណាមខាងត្បូង ថៃ និងសហរដ្ឋអាមេរិក ដែលប្រឆាំងនឹងនយោបាយរបស់សម្តេចសីហនុ ទៅវិញ? ។

សម រង្ស៊ី គិតថា ក្រោយពីមានការចោទប្រកាន់ថា ក្បត់ជាតិ និងត្រូវចាប់ខ្លួន ឪពុកគាត់គ្មានជម្រើសអ្វី ក្រៅតែពីរត់ទៅចូលរួមជាមួយ សឺង ង៉ុកថាញ់ ជាមេចលនាខ្មែរសេរីនោះទេ។

ប៉ុន្មានថ្ងៃ បន្ទាប់ពីជួបជាមួយ សឺង ង៉ុកថាញ់ ដែលបានប្រាប់ម្តាយគាត់ថា នឹងទទួលបានប្រាក់កាសមួយចំនួននោះមក វរសេនីយ៍ឯក ឡុង បានឱ្យពួកគាត់ឡើងយន្តហោះកងទ័ពអាកាសមួយគ្រឿងម៉ាកដាកូតា ហោះឆ្លងកាត់ឈូងសាមុទ្រថៃ ឆ្ពោះទៅទីក្រុងបាងកក ប្រទេសថៃ។

នៅលើយន្តហោះកងទ័ពនោះ មានមេខ្មែរសេរីម្នាក់ អមដោយពួកអង្គរក្ស៤-៥ នាក់ផងដែរ។ បងប្រុសគាត់ ឈ្មោះអេម្ម៉ាឫទ្ធ ស្គាល់មេខ្មែរសេរីម្នាក់នោះច្បាស់ គឺ ចៅ បូរី ជាសហការីដ៏ជិតស្និទ្ធបំផុត និងប្រៀបដូចជាប្អូនរបស់ឪពុកគាត់ដែរ បានរត់គេចខ្លួនជាមួយឪពុកគាត់ចេញពីក្រុងភ្នំពេញ កាលពីឆ្នាំ១៩៥៩ មកចូលរួមជាមួយចលនាខ្មែរសេរី របស់ សឺង ង៉ុកថាញ់ នោះដែរ។



**ទីក្រុងបាងកក ក្នុងទសវត្សរ៍ឆ្នាំ១៩៦០**

ពេលនោះ បងប្រុសគាត់សាកល្បងក្រោកពីកៅអី ក្នុងបំណងដើរទៅអង្គុយជិត ថៅ បូរី ដើម្បីសួរដំណឹងពីឪពុករបស់ពួកគាត់។ តែត្រូវពួកអង្គរក្សមកឈរពាំង មិនអាចឱ្យបងប្រុសគាត់ដើរទៅនិយាយជាមួយបាន បងប្រុសគាត់ក៏បានត្រូវបង្ខំចិត្តថយមកអង្គុយកន្លែងដើមរបស់គាត់វិញ។

ពេលចុះពីយន្តហោះនៅក្រុងបាងកក គេបាននាំពួកគាត់ និងក្រុម ថៅ បូរី ទៅឱ្យសម្រាកនៅក្នុងភូមិគ្រឹះមួយ ហើយគេប្រាប់ពួកគាត់ថា កុំទាន់ចូលដេកអី ព្រោះមហាសេដ្ឋី សុង សាក់ ជាហេរញ្ញិករបស់ចលនាខ្មែរសេរី នឹងមកជួបក្នុងរយៈពេលមួយ ឬពីរម៉ោងទៀត។

ក្នុងពេលរង់ចាំនោះ បងប្រុសគាត់ អេម្ម៉ាឫទ្ធ សាកល្បងចូលទៅនិយាយជាមួយ ថៅ បូរី ជាថ្មីម្តងទៀតដែរ តែត្រូវពួកអង្គរក្សរារាំងដដែល។

សម រង្ស៊ី ចងចាំមិនភ្លេចថា លុះយប់ជ្រៅបន្តិច សុង សាក់ ចងក្រវាត់កសូត្រ ពាក់វ៉ែនតាខ្មៅមិនដោះសោះ ទោះបីពេលយប់ងងឹតយ៉ាងណាក៏ដោយ បានចូលមកជួបពួកគាត់ ហើយបានបញ្ជាក់ប្រាប់ម្តាយគាត់ថា គេនឹងជួយឱ្យប្រាក់ច្រើនគួរសមដល់ម្តាយគាត់ ដើម្បីសម្រួលដល់ជីវភាពរស់នៅ និងឱ្យកូនៗបានរៀនសូត្របន្តទៀត។

ក្នុងពេលជួបគ្នានោះ សុង សាក់ បានប្រាប់ថា គេបានស្គាល់គ្នាជាមួយឪពុកគាត់

ពេលកាន់តំណែងជាឧបនាយករដ្ឋមន្ត្រី។ តែ សុង សាក់ បញ្ជាក់ថា តាំងពីគេរត់ចេញពីប្រទេសខ្មែរមក គេមិនដែលបានជួបឪពុកគាត់ម្តងណាទេ។ ឮដូច្នេះពួកគាត់គិតថា នេះមិនមែនជាសញ្ញាល្អចំពោះពួកគាត់ឡើយ។

ក្រោយពីបានទទួលប្រាក់កាសពីមហាសេដ្ឋី សុង សាក់ ពួកគាត់ត្រូវបានគេដឹកតាមយន្តហោះកងទ័ពម៉ាកដាកូតាដដែលនោះ ត្រលប់មកក្រុងព្រៃនគរ វិញ ដោយសុវត្ថិភាព។

# ១៨៦
# មហាសេដ្ឋី សុង សាក់ ជានរណា?



**ធនាគារជាតិកម្ពុជា ក្នុងទសវត្សរ៍ឆ្នាំ១៩៦០**

សុង សាក់ មានឈ្មោះជាភាសាថៃ សុងសាក់ កិច្ចផាណិជ ជាពាណិជ្ជករថៃ មានដើមកំណើតជាកូនថៃកាត់ខ្មែរផង និងកាត់ចិនផង។ ពេលខេត្តបាត់ដំបង កំពុងស្ថិតនៅក្រោមការត្រួតត្រារបស់ថៃ ឪពុកម្ដាយគាត់រស់នៅក្នុងទីរួមខេត្តមួយនេះ។ តែក្រោយពេលថៃ ត្រូវប្រគល់ខេត្តបាត់ដំបង មកឲ្យខ្មែរវិញឪពុកម្ដាយគាត់ក៏បានទៅរស់នៅទីក្រុងបាងកក។

នៅក្នុងឆ្នាំ១៩៥៣ សុង សាក់ បានរត់គេចខ្លួនពីប្រទេសថៃ ចូលមកក្នុងប្រទេសខ្មែរ ដោយសារគាត់ត្រូវអាជ្ញាធរថៃតាមរកចាប់ខ្លួនពីបទរកស៊ីជួញដូរទំនិញគេចពន្ធខុសច្បាប់។

ពេលបានមករស់នៅទីក្រុងភ្នំពេញ ដោយសារសម្បូរប្រាក់កាសផង និងការឈ្លាសវៃផង សុង សាក់ បានទាក់ទងអែបអបជាមួយពួកមន្ត្រីធំៗ និងរាជវង្សខ្មែរនៅក្នុងព្រះបរមរាជវាំង រហូតដល់ព្រះមហាក្សត្រនរោត្តម សុរាម្រិត ស្រលាញ់រាប់អានគាត់ធ្វើជាប្អូនធម៌ទៀត

ផង។ ដូច្នេះមុខជំនួញធំៗនៅក្នុងប្រទេសខ្មែរ គឺស្ថិតនៅក្នុងកណ្ដាប់ដៃសុង សាក់ ទាំងអស់។

ជាមួយគ្នានោះ គាត់បានបើកធនាគារឯកជនមួយនៅទីក្រុងភ្នំពេញ មានពួកមន្ត្រី និងអ្នកជំនួញធំៗជាច្រើន បានយកប្រាក់របស់ពួកគេទៅដាក់ផ្ញើក្នុងធនាគាររបស់គាត់យ៉ាងច្រើនសន្ធឹកសន្ធាប់។

លុះដល់ឆ្នាំ១៩៦៤ ក្រោយពេលសម្ដេចសីហនុ ទាត់ចោលជំនួយអាមេរិក និងធ្វើជាតូបនីយកម្មខាងធនាគារ សុង សាក់ ក៏បានលួចផ្ទេរប្រាក់ដែលពួកមន្ត្រី និងអ្នកជំនួញធំៗយកទៅផ្ញើនៅក្នុងធនាគាររបស់គាត់នោះ ចេញទៅក្រៅប្រទេសជាបណ្ដើរៗ។

មិនយូរប៉ុន្មាន រឿងលួចផ្ទេរប្រាក់ចេញទៅក្រៅប្រទេសនេះ ក៏បានបែកធ្លាយដល់អាជ្ញាធរខ្មែរ សុង សាក់ ក៏រត់គេចខ្លួនចេញពីទីក្រុងភ្នំពេញ ទៅទីក្រុងព្រៃនគរ ហើយបានចូលជាមួយចលនាតស៊ូខ្មែរសេរី របស់ សឺង ង៉ុកថាញ់ និងសម សារី តែម្ដងទៅ ។

បើតាម ឡឹក សំអឿន មេដឹកនាំចលនាតស៊ូខ្មែរសេរីនៅព្រំដែនថៃ បានឱ្យដឹងថា ក្រោយពេល សុង សាក់ រត់គេចខ្លួនចេញពីទីក្រុងភ្នំពេញ ទៅទីក្រុងព្រៃនគរនោះ វរសេនីយ៍ឯកតម្រួតថៃម្នាក់ ឈ្មោះធៈណៈសមុទ្ទ ផាណិជ និងវរសេនីយ៍ឯកយោធាថៃម្នាក់ទៀត ជាអ្នកទទួលខុសត្រូវក្នុងកិច្ចសហប្រតិបត្តិការជាមួយខ្មែរសេរី បាននិយាយពីរឿងនេះប្រាប់គាត់ឱ្យដឹងផងដែរ។

គាត់ក៏បានសួរបញ្ជាក់ទៅវរសេនីយ៍ឯកតម្រួត និងយោធាថៃទាំង២នាក់ នោះថា ប្រសិនបើ សុង សាក់ ត្រលប់ចូលមកក្នុងប្រទេសថៃ វិញ តើអាជ្ញាធរថៃ ចាប់ខ្លួន សុង សាក់ ឬទេ? វរសេនីយ៍ឯកថៃ ទាំងពីរនាក់ បានប្រាប់គាត់ច្បាស់ថា៖ ឲ្យតែ សុង សាក់ ហ៊ានឈានជើងចូលមកក្នុងទឹកដីថៃ វិញ ច្បាស់ជាត្រូវអាជ្ញាធរចាប់ខ្លួនហើយ។

ប៉ុន្តែមួយខែក្រោយមក សុង សាក់ បានធ្វើដំណើរពីក្រុងព្រៃនគរ ទៅដល់ទីក្រុងបាងកក តែមិនឃើញមានអាជ្ញាធរថៃណា ទៅចាប់ខ្លួន ដូចដែលវរសេនីយ៍ឯកថៃ ទាំងពីរនាក់នោះ ប្រាប់គាត់ឡើយ ព្រោះ សុង សាក់ មានលិខិតមួយ ដែលសឺង ង៉ុកថាញ់ តែងតាំងគាត់ជាទីប្រឹក្សារបស់ចលនាខ្មែរសេរី មកជាមួយ។ បន្ទាប់មក សុង សាក់ បានបើកហាង

លក់គ្រឿងសំអាង និងសំលៀកបំពាក់មួយនៅចំកណ្តាលទីក្រុងបាងកកទៀតផង។

ឡឹក សំអឿន បានឱ្យដឹងបន្តថា ក្រោយពេល សុង សាក់ មករស់នៅប្រទេសថៃវិញបាន៣ខែ គាត់ក៏បានធ្វើដំណើរពីមូលដ្ឋានប្រតិបត្តិការភ្នំដងរែក ទៅទីក្រុងបាងកក ដើម្បីជួប សុង សាក់។

ពេលជួបគ្នាដំបូង សុង សាក់ ប្រើពាក្យសម្តីទន់ភ្លន់ និងនិយាយបញ្ជោរលើកជើងគាត់ ដោយហៅគាត់ថា លោកមេទ័ពៗ ជាប់នឹងមាត់ ហើយប្រាប់គាត់ថា បើគាត់ត្រូវការចង់បានអ្វី សូមឱ្យប្រាប់គេមក គេនឹងចាត់ចែងបំពេញឱ្យបានដូចបំណង។

គាត់ក៏បានថ្លែងអំណរគុណ និងឆ្លៀតឱកាសសួរសុង សាក់ ថា តើហេតុអ្វី បានជាលោករត់ចេញពីទីក្រុងភ្នំពេញ? សុង សាក់ ឆ្លើយថា មកពីរាជរដ្ឋាភិបាលសម្តេចសីហនុ សង្ស័យថា រូបគេជាភ្នាក់ងារស៊ើបការណ៍អាមេរិក ហើយបានផ្ទេរទុនចល័តទាំងអស់ ចេញពី ធនាគាររបស់គេ ទៅក្រៅប្រទេស។

គាត់សួរបន្តថា តើលោកមានមធ្យោបាយអ្វី ដែលអាចគេចផុតពីការចាប់ខ្លួនរបស់អាជ្ញាធរខ្មែរ ហើយអាចកៀសខ្លួនចេញពីទីក្រុងភ្នំពេញ ទៅដល់ក្រុងព្រៃនគរ?

សុង សាក់ ឆ្លើយរៀបរាប់ប្រាប់គាត់យ៉ាងវែងអន្លាយ គឺតាំងពីពេលគេបានចូលទៅរស់នៅក្នុងទឹកដីខ្មែរ ដំបូង រហូតដល់ថ្ងៃ ដែលគេរត់ចេញពីក្រុងភ្នំពេញ ហើយបញ្ជាក់ថា នៅស្រុកខ្មែរឲ្យតែមានប្រាក់យើងចង់ធ្វើអ្វីក៏អាចធ្វើបានទាំងអស់។ ដូចគេជាឧទាហរណ៍ជាក់ស្តែងស្រាប់ មិនត្រឹមតែមន្ត្រីជាន់ខ្ពស់ខ្មែរប៉ុណ្ណោះទេ ដែលគេអាចប្រើបាន សូម្បីតែស្តេចខ្មែរ ក៏គេអាចប្រើបានដែរ។ ដូច្នេះមធ្យោបាយរត់គេចខ្លួនចេញពីក្រុងភ្នំពេញនោះ គឺស្រួលលើគោក។

សុង សាក់ បន្តទៀតថា នៅវេលាយប់ ដែលគេរត់ចេញពីទីក្រុងភ្នំពេញនោះ គេបានរៀបចំពិធីជប់លៀងមួយយ៉ាងធំនៅគេហដ្ឋាន ដោយបានអញ្ជើញភ្ញៀវជាមន្ត្រីធំៗ និងសំខាន់ៗ មកចូលរួម។

នៅពេលភ្ញៀវកំពុងផឹកស៊ីរាំលេងសប្បាយនោះ រូបគេ ក៏បានលួចគេចចេញពីគេហដ្ឋាន

ឡើងរថយន្ត ដែលបានរៀបចំទុកជាស្រេចទាំងយប់ ធ្វើដំណើរសំដៅទៅចម្ការកៅស៊ូនៅជប់ នៅក្នុងខេត្តកំពង់ចាម (សព្វថ្ងៃនៅក្នុងខេត្តត្បូងឃ្មុំ) ដែលនៅទីនោះ មានយន្តហោះបារាំង មួយគ្រឿង រង់ចាំដឹករូបគេយកទៅទីក្រុងព្រៃនគរ បន្តទៀត។

សុង សាក់ ប្រាប់ឡឹក សំអឿន បន្តទៀតថា ក្រោយពេលទៅដល់ទីក្រុងព្រៃនគរ គេបានទៅជួប សឺង ង៉ុកថាញ់ ដើម្បីសុំចូលរួមបម្រើចលនាខ្មែរសេរីដែរ ហើយបន្ទាប់មក គេក៏ត្រូវ សឺង ង៉ុកថាញ់ បញ្ជូនទៅប្រទេសសថៃ ឱ្យធ្វើជាទីប្រឹក្សាចលនាខ្មែរសេរី នៅរណសិរ្សឃោជាភ្នំដងរែក ដែលមានរូបគាត់( ឡឹក សំអឿន )ជាមេដឹកនាំ។

បន្ទាប់មក សុង សាក់ បានសួរគាត់ ចង់ដឹងពីសកម្មភាពរបស់ខ្មែរសេរី នៅរណសិរ្សឃោជាភ្នំដងរែកនោះ ជាពិសេស បញ្ហាកិច្ចសហប្រតិបត្តិការរវាងមន្ត្រីថៃ និងចលនាខ្មែរសេរី តើមានការលំបាក និងងាយស្រួលយ៉ាងណា? គាត់ប្រាប់ថា សហប្រតិបត្តិការនេះបានប្រព្រឹត្តទៅជាធម្មតា មិនមានបញ្ហាអ្វីទេ។

សុង សាក់ ប្រាប់គាត់វិញថា បើមានបញ្ហាអ្វីលំបាក សូមលោកមេទ័ពកុំព្រួយអី ចាំខ្ញុំទាក់ទងជាមួយមន្ត្រីថៃ ឱ្យជួយដោះស្រាយ។

មុនពេលបែកគ្នា សុង សាក់ បានបបួលគាត់ទៅពិសាអាហារនៅភោជនីយដ្ឋានបារាំងមួយ ដែលស្ថិតក្បែរហាងលក់សំលៀកបំពាក់របស់គេនោះដែរ។

ឡឹក សំអឿន បញ្ជាក់ពីគុណវិបត្តិរបស់ សុង សាក់ ថា ទោះបី សុង សាក់ មានតួនាទីជាទីប្រឹក្សាចលនាខ្មែរសេរី នៅរណសិរ្សឃោជាភ្នំដងរែក ក៏ពិតមែន តែគេពុំដែលបានចុះទៅអើត មើលកងកម្លាំងតស៊ូរបស់គាត់នៅភ្នំដងរែកនោះ ម្តងណាឡើយ គឺ សុង សាក់ នៅតែក្នុងទីក្រុងបាងកក ចាត់ចែងមុខជំនួញជួញដូររបស់គេតែប៉ុណ្ណោះ។

ចំណែករឿងទាក់ទងជាមួយមន្ត្រីថៃ ដែល សុង សាក់ បានអះអាងប្រាប់គាត់ថា កុំព្រួយ ចាំគេជួយដោះស្រាយនោះ គឺ សុង សាក់ គ្មានបានជួយអ្វី ក្រៅតែពីជួយបំបែកបំបាក់ផ្ទៃក្នុងរបស់ចលនាតស៊ូខ្មែរសេរី និងជួយសហការជាមួយពួកមន្ត្រីថៃ ធ្វើជំនួញឆ្លងដែន ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួននោះឡើយ។



**មូលដ្ឋានតស៊ូរបស់ខ្មែរសេរី នៅភ្នំដងរែក**

ឡឹក សំអឿន បញ្ជាក់បន្ថែមថា លើសពីនេះ សុង សាក់ បានគប់គិតគ្នាជាមួយនាយទាហានថៃមួយក្រុម ដែលមេដឹកនាំថៃ ចាត់ឱ្យមកធ្វើសហប្រតិបត្តិការជាមួយខ្មែរសេរី រារាំងគាត់មិនឲ្យចុះទៅត្រួតពិនិត្យកងកម្លាំងខ្មែរសេរីរបស់គាត់ ដែលបោះទីតាំងក្នុងទឹកដីខ្មែរ ដូចជានៅភ្នំម៉ាឡៃ ជាដើម ដើម្បីពួកគេមានឱកាសបញ្ជាឱ្យពួកយុទ្ធជនរបស់គាត់នៅទីតាំងនោះ កាប់ឈើដឹកជញ្ជូនចូលទៅលក់នៅក្នុងប្រទេសថៃ ដោយនិយាយបោកប្រាស់ថា កាប់ឈើនោះ យកទៅលក់ យកប្រាក់កម្រៃ ដើម្បីជួយពង្រឹកកម្លាំងចលនាខ្មែរសេរី។

តែតាមពិត ប្រាក់កម្រៃបានមកពីកាប់ឈើលក់ទាំងអស់ សុង សាក់ បានយកទៅចែកគ្នាជាមួយពួកទាហានថៃមួយក្រុមនោះ តែប៉ុណ្ណោះ។

# ១៨៧
# សម រង្ស៊ី ដូរត្រកូល សម ទៅជាត្រកូល ង្វៀន



**ថ្ងៃរៀបការកូនក្រមុំឈ្មោះ អ៊ិន អែម និងកូនកម្លោះឈ្មោះ សម សារី ឆ្នាំ១៩៣៩**

សម រង្ស៊ី បានឲ្យដឹងថា កាលរៀនផ្នែកវិទ្យាសាស្ត្រនយោបាយនៅទីក្រុងប៉ារីស ឪពុកគាត់មានទំនាក់ទំនងល្អជាមួយគ្រួសារបារាំងមួយ ឈ្មោះឡេអុង ស្ហេសីម៉ារ៍តាំង (Leon Chaisemartin)។

ពេលនោះ សង្គ្រាមលោកលើកទី២ ទើបតែត្រូវបានបញ្ចប់ ប្រជាពលរដ្ឋបារាំង មានជីវភាពលំបាកខ្លាំងណាស់។ តែទោះបីជាយ៉ាងនេះ ក៏ដោយ ក៏គ្រួសារឡេអុង ស្ហេសីម៉ារ៍ តាំង (Leon Chaisemartin) ស្រលាញ់រាប់អានឪពុកគាត់ខ្លាំងណាស់ ហើយឪពុកគាត់តែងហៅប្ដីប្រពន្ធ ឡេអុង ស្ហេសីម៉ារ៍តាំង នោះថា ឪពុកម្ដាយជាទីស្នេហារបស់គាត់ផងដែរ។

ជារឿយៗ ពិសេស ពេលថ្ងៃអាទិត្យពួកគេតែងហៅឪពុកគាត់ ឲ្យទៅទទួលទានបាយល្ងាចជាមួយគ្នា ធ្វើឱ្យឪពុកគាត់បំបាត់ការនឹករឭកដល់ក្រុមគ្រួសារ ដែលនៅឯប្រទេសកម្ពុជាបានខ្លះៗដែរ។



**អ៊ិន អេម និងសម សារី**

ពេលស្នាក់នៅទីក្រុងព្រៃនគរនោះ ថ្ងៃមួយ មានគេមកប្រាប់គ្រួសារគាត់ថា មានជនជាតិបារាំងម្នាក់ចង់ជួប។ ពេលនោះ ធ្វើឱ្យពួកគាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ បងស្រីគាត់ អេម្ម៉ារ៉ាន ចេញទៅភ្លាម ស្រាប់តែឃើញសាស្ត្រាចារ្យ ហ្សង់ ហ្សិកដង់ (Jean Giordan) និងភរិយារបស់លោក មកជាមួយដែរ។

សាស្ត្រាចារ្យ ហ្សង់ ហ្សិកដង់ (Jean Giordan) នេះហើយ ជាសាស្ត្រចារ្យបង្រៀនបងស្រីគាត់នៅសាលាភូមិន្ទរដ្ឋបាលទីក្រុងភ្នំពេញ មុនពេលពួកគាត់ត្រូវគេនិរទេសឱ្យទៅនៅប្រទេសវៀតណាមខាងត្បូង ហើយបងស្រីគាត់ស្រលាញ់ និងជឿទុកចិត្តសាស្ត្រាចារ្យបារាំងនេះខ្លាំងណាស់ មានបញ្ហាអ្វី បងស្រីគាត់តែងតែសុំយោបល់ពីលោក។

ការពិត សាស្ត្រាចារ្យបារាំង រូបនេះ ធ្លាប់បានសរសេរសំបុត្រមកឱ្យក្រុមគ្រួសារគាត់ពីរបីដងរួចមកហើយដែរ។ ប៉ុន្តែលើកនេះ លោកបានស្ពាត់មកជួបក្រុមគ្រួសារគាត់ដោយផ្ទាល់តែម្តង។

សាស្ត្រាចារ្យ ហ្សង់ ហ្សិកដង់ បានរៀបរាប់ប្រាប់ពួកគាត់ថា លោកព្យាយាមស្វះស្វែងរកមន្ត្រីធំៗ ដែលលោកធ្លាប់ស្គាល់ទាំងប៉ុន្មាន ដើម្បីជួយធ្វើយ៉ាងណា ដើម្បីឱ្យក្រុមគ្រួសារ

គាត់បានទៅរស់នៅប្រទេសបារាំង ក្នុងនាមជាជនភៀសខ្លួន ដោយសារបញ្ហានយោបាយ។

ចំណែកគ្រួសារ ឡេអុង ស្ឆេសឺម៉ារតាំង (Leon Chaisemartin) នៅប្រទេសបារាំងឯណោះ តាំងពីឆ្នាំ១៩៥៩មក ក៏បានសាកល្បងព្យាយាមជាច្រើនលើកច្រើនសា ដើម្បីឱ្យ សម សារី សុំសិទ្ធិជ្រកកោននយោបាយនៅប្រទេសបារាំង ឬក៏ប្រទេសគុយបា និងប្រទេសយូហ្គោស្លាវី ដែរ តែមិនបានលទ្ធផលអ្វីសោះ។

សាស្ត្រាចារ្យ ហ្សង់ ហ្ស៊ែកដង់ បានប្រាប់ពួកគាត់ថា លោកបានមកជួបស័ក្តិ៥ វៀតណាមខាងត្បូង ឈ្មោះឡុង ហើយប្រើឥទ្ធិពលរបស់លោកក្នុងនាមជាមន្ត្រីជាន់ខ្ពស់បារាំង ព្រមានដោយពាក្យសំដីម៉ឺងម៉ាត់ថា បើមានហេតុការណ៍អាក្រក់មួយមកលើក្រុមគ្រួសារ សម សារី គឺស័ក្តិ៥ ឡុង ឯងជាទទួលខុសត្រូវ។

ក្រោយពី សុង សាក់ ជួយផ្តល់ប្រាក់កាស និងមានការជួយអន្តរាគមន៍របស់សាស្ត្រាចារ្យ ហ្សង់ ហ្ស៊ែកដង់ អស់រយៈពេល២ខែមក ថ្ងៃមួយ ពួកគាត់បានទទួលសំបុត្រមួយ ឱ្យសុំត្រៀមខ្លួន ដើម្បីចេញដំណើរទៅប្រទេសទី៣ បន្តទៀត។

ពេលនោះ ពួកគាត់ពុំដឹង ថា តើត្រូវចាកចេញពីប្រទេសវៀតណាមខាងត្បូង តាមវិធីណាទេ បើគ្មានលិខិតស្នាមអ្វីបន្តិចផង ព្រោះអត្តសញ្ញាណប័ណ្ណ ត្រូវអាជ្ញាធរខ្មែរដកហូតយកអស់ តាំងពីពេលពួកគាត់ត្រូវគេបង្ខំឱ្យចាកចេញពីក្រុងភ្នំពេញ មកម្ល៉េះ ?

តែប៉ុន្មាន ម៉ោងក្រោយមក ស័ក្តិ៥ ឈ្មោះឡុង បានយកលិខិតឆ្លងដែនវៀតណាមចំនួន៥ក្បាលមកប្រគល់ឱ្យពួកគាត់ម្នាក់មួយៗ។ ក្នុងលិខិតឆ្លងដែនវៀតណាមទាំងនោះ ឈ្មោះពួកគាត់ត្រូវគេដាក់សញ្ជាតិជាវៀតណាម និងដូរឈ្មោះជាវៀតណាម ដោយប្រើត្រកូល ង្វៀន នៅខាងមុខ។ ចំណែករូបថតនៅលើលិខិតឆ្លងដែននោះ ត្រូវបានគេកែច្នៃ ដើម្បីកុំឲ្យមើលស្គាល់ទម្រង់មុខជាជនជាតិខ្មែរ។

គួរបញ្ជាក់ដែរថា ក្រោយពី សម សារី រត់ភៀសខ្លួនទៅចូលរួមជាមួយចលនាតស៊ូខ្មែររបស់សឺង ង៉ុកថាញ់ នៅប្រទេសវៀតណាមខាងត្បូង ក្នុងឆ្នាំ១៩៥៩ សម សារី ក៏កាន់លិខិតឆ្លងដែនវៀតណាម និងបានដូរឈ្មោះមកជា ង្វៀន យ៉ាំងសាម ដើម្បីធ្វើដំណើរទៅប្រទេស

ថៃ និងប្រទេសឡាវ ដែរ។

ក្រោយពីប្រគល់លិខិតឆ្លងដែនរួច ស័ក្តិ៥ ឡុង ប្រាប់ពួកគាត់ថា អ្នកឯងទាំងអស់គ្នាត្រូវទៅឡើងយន្តហោះ ដើម្បីធ្វើដំណើរទៅទីក្រុងហុងកុង។ នៅទីនោះមានសហការីរបស់ សុង សាក់ នឹងមកទទួលពួកអ្នកឯងហើយ។

ពេលទៅដល់អាកាសយានដ្ឋាន នៅទីក្រុងហុងកុង ដូចស័ក្តិ៥ ឡុង បានប្រាប់មុនពេលពួកគាត់ចេញដំណើរពីប្រទេសវៀតណាមខាងត្បូង មែន។ ពេលនោះ សហការីរបស់ សុង សាក់ ឈ្មោះមីស្ហែល (Michel) បានមកចាំទទួលពួកគាត់ ហើយនាំគ្នាឡើងជិះរថយន្តម៉ែរសីដេសមួយគ្រឿង ចេញដំណើរទៅសម្រាកនៅសណ្ឋាគារដ៏ប្រណីតមួយឈ្មោះ អាំប៉េរ៉ាទ្រីស(Imperatrice)។

ក្រោយពីស្នាក់នៅបណ្តោះអាសន្នក្នុងសណ្ឋាគារដ៏ប្រណីតនោះ រយៈពេលមួយអាទិត្យ ឈ្មោះមីស្ហែល (Michel) ក៏បានទិញសំបុត្រយន្តហោះរបស់ក្រុមហ៊ុនអាកាសចរណ៍ជប៉ុន (Japan Airlines) ដើម្បីឱ្យពួកគាត់ធ្វើដំណើរទៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី បន្តទៀត។ តែមុនពេលឡើងយន្តហោះ ឈ្មោះមីសែល(Michel) បានប្រគល់ប្រាក់ដុល្លារមួយបាច់ធំ ឱ្យម្តាយពួកគាត់ផងដែរ។

ពេលចុះពីយន្តហោះនៅអាកាសយានដ្ឋានហ្វុយមីស៊ីន(Fumicin)នៃទីក្រុងរ៉ូម គេបានស្រែកប្រកាសតាមឧគ្ឃោសនសព្ទ រកគ្រួសារត្រកូលង្វៀន របស់ពួកគាត់ ឱ្យចូលទៅកន្លែងផ្តល់ព័ត៌មាន ហើយបុគ្គលិកនៅទីនោះ បានប្រគល់សំបុត្រមួយ ដែលសាស្ត្រាចារ្យ ហ្សង់ ហ្សែកដង់ ផ្ញើទុកឱ្យពួកគាត់ ដោយបញ្ជាក់ប្រាប់ពួកគាត់ថា ពេលព្រឹកស្អែក ពួកគាត់ត្រូវធ្វើដំណើរឲ្យទៅស្ថានទូតបារាំង នៅវិមានហ្វាណែស(Farnese)។

នៅទីក្រុងរ៉ូម គេបានកក់សណ្ឋាគារតូចមួយឲ្យពួកគាត់ស្នាក់នៅមួយយប់។ លុះព្រឹកឡើង ពួកគាត់ក៏ធ្វើដំណើរទៅស្ថានទូតបារាំង តាមបណ្តាំរបស់សាស្ត្រាចារ្យ ហ្សង់ ហ្សែកដង់។

បន្ទាប់ពីនៅរង់ចាំរាប់ម៉ោង មន្ត្រីស្ថានទូតបារាំង ក៏អនុញ្ញាតឲ្យពួកគាត់ចូលជួបនៅ




**ទីក្រុងប៉ារីស ឆ្នាំ១៩៦៥**

ខាងមុខចន្លោះបង្អួចបន្ទប់ការិយាល័យសម្រាប់សុំទិដ្ឋាការ។ ក្រោយពីបានសួរនាំម្ដាយពួកគាត់យ៉ាងយូរ និងមានការងឿងឆ្ងល់ពីបញ្ហាមិនប្រក្រតីរបស់ពួកគាត់មួយចំនួនមក មន្ត្រីស្ថានទូតបារាំង នោះ ក៏ប្រាប់ពួកគាត់ថា គ្មានទិដ្ឋាការសម្រាប់គ្រួសារត្រកូលង្វៀន របស់ពួកគាត់ទេ ធ្វើឱ្យពួកគាត់មានការងឿងឆ្ងល់ និងអស់សង្ឃឹមទៅវិញ។

ពេលត្រលប់មកសណ្ឋាគារវិញ ម្ដាយពួកគាត់បានព្យាយាមទូរស័ព្ទទាក់ទងទៅសាស្ត្រាចារ្យ ហ្សង់ ហ្ស៊ែកដង់ (Jean Giordan) សួរថា ហេតុអ្វីបានជាមន្ត្រីស្ថានទូតបារាំង មិនផ្ដល់ទិដ្ឋាការឱ្យពួកគាត់? សាស្ត្រាចារ្យ ហ្សង់ ហ្ស៊ែកដង់ ឆ្លើយថា ចាំលោកទូរស័ព្ទទៅសួរគេសិន! រួចលោកបានបញ្ជាក់ប្រាប់ថា ទោះជាយ៉ាងណា លោកនៅមានដំណោះស្រាយមួយផ្សេងទៀត ដើម្បីឱ្យពួកគាត់ចូលទៅក្នុងប្រទេសបារាំង ព្រោះលោកមាននាវាតូចមួយចតនៅជិតទីក្រុងកាន (Cannes) បើពិបាកខ្លាំងពេក គាត់នឹងមកយកនាវាតូចនោះមកដឹក

ពួកគាត់តាមផ្លូវទឹក លួចចូលទៅក្នុងទឹកដីរបស់ប្រទេសបារាំង ឱ្យទាល់តែបាន។

តែសំណាងល្អ ពីរបីថ្ងៃក្រោយមក សាស្ត្រាចារ្យ ហ្សង់ ហ្ស៊ែកដង់ បានទូរស័ព្ទមកប្រាប់ពួកគាត់ថា លោកទើបនឹងបានយល់ពីរឿងមន្ត្រីស្ថានទូតបារាំង មិនព្រមផ្តល់ទិដ្ឋាការឱ្យពួកគាត់នោះ ដោយសារមកពីពួកគាត់ចូលទៅការិយាល័យផ្តល់ទិដ្ឋាការសម្រាប់សាធារណៈជនធម្មតា ទើបបានជាគ្មានឈ្មោះក្លែងក្លាយរបស់ពួកគាត់។ តាមពិត ពួកគាត់មានគេនៅរង់ចាំនៅការិយាល័យផ្តល់ទិដ្ឋាការសម្រាប់កិច្ចការពិសេស មួយផ្សេងទៀត ពេលពួកគាត់ទៅដល់ មន្ត្រីស្ថានទូតបារាំង នៅទីនោះ នឹងផ្តល់ទិដ្ឋាការឱ្យពួកគាត់ជាមិនខាន។

បញ្ហាទាំងប៉ុន្មានត្រូវបានបញ្ចប់ ពួកគាត់ក៏ប្រញាប់ធ្វើដំណើរទៅស្ថានទូតបារាំង ជាថ្មីម្តងទៀត ដើម្បីយកទិដ្ឋាការ ដោយក្តីរីករាយបំផុត រួចបន្តដំណើរទៅទិញសំបុត្ររថភ្លើងនៅស្ថានីយទីក្រុងរ៉ូម។

ព្រឹកស្អែកឡើង ក្រោយពីបានធ្វើដំណើរពេញមួយយប់ឆ្លងកាត់ជួរភ្នំសាំផ្លុង (Simplon) ជួរភ្នំអាល់(Alpes) និងជួបភ្នំហ្សុយរ៉ា(Jura) មក ពួកគាត់ក៏បានទៅដល់ទីក្រុងប៉ារីស ដើម្បីចាប់ផ្តើមកសាងជីវិតថ្មីបន្តទៀត។

# ១៨៨
# សម្ដេចសីហនុ ថា៖ (ហ៊ូ យន់) ឈ្មោះ យន់ ស្រដៀងយួន




**សម្ដេចសីហនុ**

នៅក្នុងឆ្នាំ១៩៦៥ គូ រុន ជារដ្ឋមន្ត្រីការពារលើផ្ទៃប្រទេស និងសន្តិសុខជាតិ បានទៅទាក់ទង សួស នៅ ហៅឈូក ដែលជាបុគ្គលិករដ្ឋបាល នៅវិទ្យាល័យឯកជនកម្ពុជបុត្រ ដើម្បីឱ្យគាត់ជួយយកការណ៍ពីសកម្មភាពរបស់ ហ៊ូ យន់ និងហ៊ូ នឹម ជាអតីតសមាជិករាជរដ្ឋាភិបាលរបស់សង្គមរាស្ត្រនិយម និងជាសាស្ត្រាចារ្យបង្រៀននៅមហាវិទ្យាល័យច្បាប់ផងដែរ។

សួស នៅ ហៅឈូក ដែលពេលនោះជាបក្ខជនរបស់បក្សពលករកម្ពុជាម្នាក់ដែរ មិនព្រមធ្វើជាអ្នកយកការណ៍ឱ្យ គូ រុន ទេ តែគាត់ខ្លាច គូ រុន ដឹងថា គាត់ជាអ្នកតស៊ូសម្ងាត់ និងជាបក្ខជនរបស់បក្សពលករកម្ពុជា គូ រុន នឹងចាប់ខ្លួនគាត់ជាមិនខាន។ ដូច្នេះ គាត់ក៏បានប្រាប់រឿងនេះឱ្យអង្គការថ្នាក់លើរបស់គាត់ដឹង អង្គការថ្នាក់លើ ក៏បានឱ្យគាត់ចាកចេញពីក្រុងភ្នំពេញ ទៅលាក់ខ្លួនធ្វើសកម្មភាពបដិវត្តន៍សម្ងាត់នៅស្រុកព្រះស្ដេច ក្នុងខេត្តព្រៃវែង



**លោក ហ៊ូ យន់**

វិញ។

ក្រោយពី សួស នៅ ហៅ ឈូក គេចខ្លួនចេញពីក្រុងភ្នំពេញ ប្រពន្ធគាត់ ក៏បានវិលត្រលប់ទៅរស់នៅស្រុកកំណើត នៅខេត្តស្វាយរៀង វិញ ហើយពួកប៉ូលិស បានទៅតាមស៊ើបសួរប្រពន្ធគាត់ពីកន្លែងដែលគាត់ទៅស្នាក់នៅផងដែរ។

ចំណែកនៅភូមិភាគពាយ័ព្យវិញ លេខាបក្សភូមិភាគ ឈ្មោះ មូល សម្បត្តិ ហៅរស់ ញឹម ក៏បង្ខំចិត្តរត់ចូលព្រៃដែរ ព្រោះចៅហ្វាយខេត្តបាត់ដំបង បានបញ្ជាឱ្យពួកទាហានទៅ តាមរកចាប់គាត់៤ដងមកហើយ។

ក្រោយពីប៉ូលិសរបស់សម្តេចសីហនុ ចាប់ខ្លួនយុវជនមួយចំនួនដែលជាប់ពាក់ព័ន្ធនឹងចលនាតស៊ូរបស់បក្សពលករកម្ពុជា និងបិទកាសែតចតុមុខ លែងឱ្យចេញផ្សាយមក បក្ខជនម្នាក់ឈ្មោះ កី ត្រូវមេដឹកនាំបក្សពលករកម្ពុជា បញ្ជូនឱ្យទៅនៅជាមួយ មូល សម្បត្តិ ហៅ រស់ ញឹម ដើម្បីជួយប្រមូលកម្លាំងតស៊ូ។ ក្រោយមក បក្ខជនឈ្មោះ កី នេះ ក៏ត្រូវចាត់-តាំងជាប្រធានយោធាភូមិភាគពាយ័ព្យ។

ពេលដែលបក្សពលករកម្ពុជា ធ្វើសកម្មភាពប្រមូលកម្លាំងជនជាតិភាគតិច នៅភូមិភាគឦសាន ឱ្យចូលរួមក្នុងចលនាតស៊ូរបស់ខ្លួនកាន់តែច្រើនឡើងៗនោះ នៅក្នុងខែមករា ឆ្នាំ១៩៦៥ សម្តេចសីហនុ បានយាងទៅធ្វើព្រះរាជទស្សនកិច្ចនៅខេត្តមណ្ឌលគិរី ជាលើកទី២។

ពេលនោះ ព្រះអង្គបានអំពាវនាវឱ្យជនជាតិភាគតិចទាំងនោះ មករស់នៅប្រមូលផ្តុំ

គ្នា បង្កើតជាភូមិតូចៗ កុំឱ្យរស់នៅរប៉ាត់រប៉ាយឆ្ងាយៗពីគ្នាដូចមុនទៀត ហើយពន្យល់ថា ការរស់នៅប្រមូលផ្តុំគ្នានេះ អាចមានលទ្ធភាពក្នុងការការពារពីការលួចឆក់ប្លន់ពីសំណាក់ពួកចោរព្រៃ(ពួកឧទ្ទាម)ផង និងទទួលបាននូវរង្វាន់ ឬអំណោយពីរាជរដ្ឋាភិបាលកាន់តែច្រើនថែមទៀតផងដែរ។

ព្រះអង្គបានផ្តាំផ្ញើកូនចៅជាជនជាតិភាគតិចរបស់ព្រះអង្គ ឱ្យស្តាប់តាមការណែនាំរបស់ពួកអាជ្ញាធរ ពួកមន្ត្រីរាជការរបស់ព្រះអង្គ ក្នុងការជ្រើសរើសទីតាំងបង្កើតជាភូមិ និងដីសម្រាប់ធ្វើស្រែចម្ការ។

ជាមួយគ្នានោះ ព្រះអង្គ ក៏បានប្រទាននូវសម្លៀកបំពាក់ វត្ថុប្រើប្រាស់ សម្ភារៈផ្សេងៗទៀត ពិសេស ដូចជាខ្សែក កងដៃ ក្រវិលសិប្បនិម្មិតជាគ្រឿងអលង្ការ ដែលជាទីស្រលាញ់ពេញចិត្តបំផុតរបស់ជនជាតិភាគតិចទាំងនោះផងដែរ ។

ប៉ុន្តែព្រះអង្គមិនបានដោះស្រាយពីបញ្ហាទំនាស់ដីធ្លី ដែលពួកអ្នកមានអំណាចបុណ្យស័ក្តិមួយចំនួនតូច ដណ្តើមយកពីបងប្អូនជនជាតិភាគតិចនៅទីនោះទេ ឬមួយព្រះអង្គមិនបានដឹងពីបញ្ហានេះ ?។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦៥ សម្តេចសីហនុ បានប្រកាសថា សហជីវិន ហ៊ូ យន់ (អតីតរដ្ឋមន្ត្រីក្រសួងផែនការ) ជាអ្នកការពារមនុស្សអាក្រក់មួយចំនួន ដែលជាអ្នកប្រឆាំងនឹងសេចក្តីសម្រេចចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការចែកដីធ្លីទៅឱ្យប្រជារាស្ត្រឱ្យបានស្មើៗគ្នា នៅក្នុងខេត្តកំពង់ចាម ហើយពួកមនុស្សអាក្រក់មួយចំនួន ដែលចង់បានដីច្រើនលើសគេឯងនោះបាននាំគ្នាបង្កការលំបាកដល់រាជរដ្ឋាភិបាល ដូច្នេះ ពួកនេះត្រូវតែចាប់យកទៅឱ្យតុលាការផ្តន្ទាទោសតាមច្បាប់។

ប៉ុន្តែ បើតាមប្រភពអ្នករស់នៅកន្លែងកើតហេតុ បានឱ្យដឹងថា ជម្លោះដីធ្លីនោះកើតឡើងដោយសារពួកអ្នកមានអំណាច និងពួកអ្នកមានៗ ដែលមិនមែនជាអ្នករស់នៅទីនោះបានមករំលោភបំពានយកដីធ្លីរបស់អ្នកស្រុកនៅមណ្ឌលសួរគង នៃស្រុកកងមាស (ខេត្តកំពង់ចាម) ដែល ហ៊ូ យន់ ឈរឈ្មោះជាតំណាងរាស្ត្រនៅទីនោះ ហើយអ្នកស្រុកបានចាត់

តំណាង១០នាក់ ឡើងទៅក្រុងភ្នំពេញ ដើម្បីជួប ហ៊ូ យន់ ឱ្យជួយដោះស្រាយ និងឱ្យមានការដោះលែងអ្នកស្រុកទាំងអស់ ដែលកម្លាំងសមត្ថកិច្ចបានចាប់ខ្លួនក្នុងការតវ៉ាពីបញ្ហារំលោភយកដីធ្លីរបស់ពួកគេផងដែរ។

ហ៊ូ យន់ បានថ្លែងថា ពេលនេះ ប្រជាធិបតេយ្យត្រូវធ្លាក់ចុះ ហើយការចាប់ខ្លួនអ្នកស្រុកទាំងនោះ បង្ហាញឱ្យឃើញថា សេរីភាពនៃការនិយាយស្តី មិនមានទៀតឡើយ បើនរណាហ៊ាននិយាយស្តី ឬតវ៉ាទៀតនោះ ប្រាកដជាត្រូវគេចាប់យកទៅដាក់គុកច្រវាក់ និងធ្វើទារុណកម្មជាមិនខាន។

ប៉ុន្តែសម្តេចសីហនុ បានមានបន្ទូលថា សហជីវិន គូ រុន(រដ្ឋមន្ត្រីសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស) បានទូលព្រះអង្គថា ប៉ូលិសរបស់គាត់មិនដែលធ្វើទារុណកម្មដល់ប្រជារាស្ត្រស្លូតត្រង់ណាម្នាក់ទេ តែអាចមានខ្លះៗ ដើម្បីជាការព្រមានចំពោះជនណា ដែលបានប្រព្រឹត្តខុសច្បាប់។

តែទោះបីយ៉ាងណា ក៏អ្នកស្រុកមួយចំនួន ដែលត្រូវសមត្ថកិច្ចចាប់ខ្លួន ដោយសារជម្លោះដីធ្លីនោះ ត្រូវបានតុលាការសម្រេចឱ្យឈ្នះក្តី និងដោះលែងឱ្យមានសេរីភាពវិញ។

ពេលនោះដែរ ភោគ ឆាយ ជាប្រធានសមាគមនិស្សិតខ្មែរ នៅក្រុងភ្នំពេញ និងជាកូនសិស្សជំនិតរបស់ ហ៊ូ យន់ និងខៀវ សំផន ក៏បានឆ្លៀតឱកាសជួយការពារអ្នកស្រុកដែលត្រូវគេរំលោភយកដីធ្លី តាមរយៈការសរសេរអត្ថបទចុះផ្សាយនៅលើទំព័រកាសែតឡាដេប៉ែស្ហ (La Dépêche)ថា អ្នកស្រុកជាប្រជាកសិករជាច្រើនត្រូវបាត់បង់ដីស្រែចម្ការ ដោយសារការរំលោភដណ្តើមយកពីសំណាក់ពួកអ្នកមានអំណាច ពួកម្ចាស់ដីធំៗ ហើយបង្ខំឱ្យអ្នកស្រុកចាកចេញទៅរកកន្លែងរស់នៅផ្សេងទៀត។

សម្តេចសីហនុ ទទួលស្គាល់ថា ពិតជាមានការរំលោភបំពានយកដីស្រែចម្ការអ្នកស្រុកខ្លះប្រាកដមែន តែព្រះអង្គបានបដិសេធទៅតាមអ្វី ដែលសមត្ថកិច្ចប៉ូលិសបានរាយការណ៍ថា ពុំមានម្ចាស់ដីធំៗណា ហ៊ានបណ្តេញអ្នកស្រុកឱ្យចាកចេញពីភូមិឋានរបស់ពួកគេនោះទេ តែអ្នកស្រុកមួយចំនួន បានចាកចេញទៅរកកន្លែងរស់នៅផ្សេងទៀត ដោយសារតែដី

ស្រែចម្ការនៅកន្លែងពួកគាត់រស់នៅនោះ ត្រូវខ្សោះជីជាតិអស់ទៅហើយ។

នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៦៥ គ្រូបង្រៀនម្នាក់នៅខេត្តពោធិ៍សាត់ឈ្មោះ លី សែ ត្រូវជាក្មួយរបស់ នៃ សារ៉ាន់ ហៅយ៉ា ដែលជាថ្នាក់ដឹកនាំនៅក្នុងជួរបក្សពលករកម្ពុជា ត្រូវសមត្ថកិច្ចចាប់ខ្លួន រួមជាមួយនឹងសហការីគាត់៣នាក់ទៀត យកទៅឃុំទុកនៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ដោយសារពួកគាត់នាំគ្នាបាចខិត្តប័ណ្ណប្រឆាំងនឹងរាជរដ្ឋាភិបាល។

ជាមួយគ្នានេះដែរ នៅទីក្រុងភ្នំពេញ សមត្ថកិច្ចប៉ូលិសក៏បានចាប់ខ្លួនសិស្សមួយចំនួនដែលនាំគ្នាដើរបិតខិត្តប័ណ្ណ និងបដានៅតាមដើមឈើ និងតាមជញ្ជាំងវិទ្យាល័យនានា ដោយបដានោះបានសរសេរចោទប្រកាន់ថា ឧត្តមសេនីយ៍ លន់ នល់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងអប់រំជាតិ ជាជនក្បត់ លក់ប្រទេសជាតិឱ្យទៅអាមេរិក។

ក្រោយពីពួកប៉ូលិសសួរចម្លើយពួកសិស្ស ដែលចាប់ខ្លួនបានទាំងប៉ុន្មាននោះមក ពួកគេបានឆ្លើយសារភាពថា ការដែលបិតខិត្តប័ណ្ណ និងចងបដាថា៖ "លន់ នល់ និងទ្រង់ សិរិមតៈ ជាអ្នកលក់ជាតិឱ្យអាមេរិកនោះ គឺធ្វើឡើងតាមការណែនាំរបស់ពួកសាស្ត្រាចារ្យរបស់ពួកគេដែលមាននិន្នាការទៅខាងលទ្ធិកុម្មុយនិស្ត។

សម្តេចសីហនុ ក៏បានបញ្ជាប៉ូលិសឱ្យដោះលែងពួកសិស្សទាំងអស់នោះ វិញ។ ប៉ុន្តែព្រះអង្គ បានព្រមានថា ព្រះអង្គនឹងឱ្យសមត្ថកិច្ចប៉ូលិសតាមចាប់ខ្លួនសាស្ត្រាចារ្យណា ដែលមានបំណងធ្វើសកម្មភាពគំរាមកំហែងដល់សន្តិសុខជាតិផងដែរ ទោះបីនៅក្នុងខិត្តប័ណ្ណ និងបដានោះ មិនមានសរសេរអ្វីប៉ះពាល់ដល់ព្រះអង្គអ្វីបន្តិច ក៏ដោយ ។

ជាមួយគ្នានោះ ព្រះអង្គបានប្រកាសដោយចំឈ្មោះថា ហ៊ូ យន់ ជាមេដឹកនាំចលនាប្រឆាំង ចង់បានតែម្យ៉ាង គឺ ផ្តួលរម្លំរាជបល្ល័ង្ក។ គាត់មានឈាមជ័រជាអ្នកប្រឆាំងនឹងរាជ-បល្ល័ង្ក។ គាត់តែងតែសម្លឹងឃើញចលនារាជានិយមអាក្រក់ជានិច្ច ហើយថា មានតែរបបកុម្មុយនិស្តទេ ដែលត្រឹមត្រូវ និងយុត្តិធម៌បំផុត។

ព្រះអង្គសង្កត់ធ្ងន់ថា ហ៊ូ យន់ ជាមនុស្សអាក្រក់បំផុត សូម្បីតែឈ្មោះរបស់គាត់

"យន់" នោះ ក៏មានសូរសៀងស្រដៀងនឹងពាក្យថា"យួន" ដែរ។ តែទោះបីយ៉ាងនេះក្ដី ក៏ព្រះអង្គមិនបានបញ្ជាឱ្យគេចាប់ខ្លួន ហ៊ូ យន់ ឬក៏ប្ដឹងផ្ដល់អ្វីទៅតុលាការតាមការទាមទាររបស់ពួកអ្នកជាតិនិយម (ទាំងទាហាន ទាំងស៊ីវិល) នៅក្នុងចលនាសង្គមរាស្ត្រនិយមរបស់ព្រះអង្គដែរ។

ប៉ុន្មានថ្ងៃក្រោយមក ព្រះអង្គបានប្រកាសបញ្ជាក់ថា៖ ហ៊ូ យន់នេះ ជំពាក់គុណខ្ញុំព្រះករុណា ដោយសារតែខ្ញុំព្រះករុណា មិនបានដាក់ទោសឱ្យសមតាមកំហុស ដែលមិនអាចអត់ឱនឱ្យបានរបស់គាត់ ហើយគាត់ជាមនុស្សពោរពេញដោយភាពក្រអឺតក្រទម និងតែងតែរិះគន់ចំពោះមន្ត្រីទាំងឡាយណា ដែលមិនមែនជាពួកកុម្មុយនិស្ដ ដូចខ្លួន។

ព្រះអង្គបានប្រកាសបន្តថា ដោយសារខ្ញុំព្រះករុណាមិនចង់ឱ្យ ហ៊ូ យន់ ក្លាយទៅជាវីរជនពលីជីវិតនោះ ខ្ញុំព្រះករុណាតែងបដិសេធក្នុងការដាក់ទោសបែបណាមួយចំពោះគាត់ជានិច្ច។ ប៉ុន្តែ ប្រសិនបើប្រជារាស្ត្រភាគច្រើនមានការខឹងសម្បាចំពោះគាត់ហើយនោះ គាត់មិនអាចធ្វើវិច្ឆេទកម្មក្នុងប្រទេសបាន ដោយគ្មានការកាត់ទោសពីប្រជារាស្ត្រភាគច្រើននោះបានទៀតទេ ហើយពេលនោះ ខ្ញុំព្រះករុណាក៏មិនទទួលខុសត្រូវចំពោះជោគវាសនារបស់ ហ៊ូ យន់ ទៀតដែរ។

នៅចុងខែមីនា ឆ្នាំ១៩៦៥ នៅខេត្តកំពង់ចាម យុវជនម្នាក់ត្រូវប៉ូលិសចាប់ខ្លួន ដោយសារបានបាចខិត្តប័ណ្ណប្រឆាំងនឹងរាជរដ្ឋាភិបាល ហើយយុវជននោះត្រូវស្លាប់ដោយមានខ្សែចង.កនៅបន្ទប់ទឹកក្នុងប៉ុស្ដិ៍ប៉ូលិស។

ករណីនេះ សម្ដេចសីហនុ បានប្រកាសថា ព្រះអង្គមិនបានបញ្ជាឱ្យប៉ូលិសចាប់ខ្លួនយុវជននោះទេ។

# ១៨៩
# ឧត្ដមសេនីយ៍ លន់ នល់ ចុះហត្ថលេខាជាមួយចិន ជួយដឹកជញ្ជូនអាវុធឱ្យពួកវៀតកុង



ឧត្តមសេនីយ៍ លន់ នល់ ដឹកនាំគណៈប្រតិភូចូលជួប ម៉ៅ សេទុង

នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៦៥ កងទ័ពសហរដ្ឋអាមេរិក បានធ្វើការវាយប្រហារទៅលើភូមិបាធូ ក្នុងឃុំទួលស្ដី ស្រុកចន្ទ្រា ខេត្តស្វាយរៀង បណ្ដាលឱ្យអ្នកភូមិ៧នាក់ ត្រូវបាត់បង់ជីវិត។

បន្ទាប់មកទៀត នៅថ្ងៃទី២០ ខែតុលា យន្តហោះអាមេរិកបានទម្លាក់គ្រាប់បែកមកលើ ភូមិអន្លង់ជ្រៃ ក្នុងស្រុកពញាក្រែក ខេត្តកំពង់ចាម (សព្វថ្ងៃជាខេត្តត្បូងឃ្មុំ) បណ្ដាលឱ្យអ្នកភូមិស្លាប់ និងរងរបួសជាច្រើន។

នៅថ្ងៃទី២៤ ខែតុលា ឧទ្ធម្ភាគចក្ររបស់កងទ័ពសហរដ្ឋអាមេរិក ក៏បានបាញ់រះមកលើ ប៉ុស្ដិ៍ដាក់ដាំ ក្នុងខេត្តរតនគិរី បន្តទៀត។

## របត់នយោបាយ

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៥ ឧត្តមសេនីយ៍ លន់ នល់ រដ្ឋមន្ត្រីការពារជាតិ និងជានាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់មួយក្រុមទៅបំពេញទស្សនកិច្ចនៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន ម្តងទៀត។

នៅថ្ងៃទី២៥ ខែវិច្ឆិកា តាមព្រះរាជបញ្ជារបស់សម្តេចសីហនុ ឧត្តមសេនីយ៍ លន់ នល់ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសម្ងាត់មួយជាមួយឧត្តមសេនីយ៍ ឡូ ជុយជីង ( Lo Jui Ching ) នាយអគ្គសេនាធិការកងទ័ពប្រជាជនចិន អនុញ្ញាតឱ្យនាវាចិន ដឹកជំនួយជាគ្រឿងអាវុធយុទ្ធភណ្ឌ និងសម្ភារសឹកផ្សេងៗទៀតមកចូលចតនៅកំពង់ផែ ក្រុងព្រះសីហនុ ហើយកងទ័ពកម្ពុជា នឹងជួយដឹកបន្តទៅប្រគល់ឱ្យកងទ័ពវៀតកុង-វៀតណាម ខាងជើង ដែលនៅប៉ែកខាងកើតប្រទេសកម្ពុជា ផងដែរ។ ក្នុងករណីចាំបាច់កម្ពុជា នឹងអនុញ្ញាតឱ្យកងទ័ពបរទេសនេះ បោះទីតាំងនៅលើទឹកដីកម្ពុជា ទៀតផង។

ក្នុងកិច្ចព្រមព្រៀងសម្ងាត់នោះ បានបញ្ជាក់ថា គ្រឿងអាវុធយុទ្ធភណ្ឌ និងសម្ភារសឹកផ្សេងៗទៀតរបស់ចិន ដែលមកចូលចតនៅកំពង់ផែក្រុងព្រះសីហនុនោះ ត្រូវអនុញ្ញាតឱ្យកងទ័ពកម្ពុជា ដកហូតមួយចំនួនទុកជារបស់ខ្លួនផងដែរ មុនពេលជួយដឹកបន្តទៅប្រគល់ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង។

ក្រោយពីមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះមក សហរដ្ឋអាមេរិក បានចោទប្រកាន់ជាចំហថា សម្តេចសីហនុ បានផ្តល់ទឹកដីកម្ពុជា ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង បោះទីតាំងកងទ័ព ដើម្បីធ្វើការវាយប្រហារទៅលើកងទ័ពអាមេរិក និងកងទ័ពវៀតណាមខាងត្បូង ហើយអាមេរិក ក៏បានធ្វើសកម្មភាពប្រឆាំងនឹងកម្ពុជា កាន់តែខ្លាំងក្លាថែមទៀត។

ដោយសារសហរដ្ឋអាមេរិក បានក្លាយទៅជាសត្រូវចេញមុខទៅហើយនោះ សម្តេចសីហនុ ឈ្វេងយល់ថា មានតែប្រទេសចិន តែមួយគត់ ដែលព្រះអង្គសង្ឃឹមថា អាចយកធ្វើជាខ្នងបង្អែកបាន។

មូលហេតុ ដែលធ្វើឱ្យសម្តេចសីហនុ យល់ព្រមឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង បោះទីតាំងលើទឹកដីកម្ពុជានោះ ក៏ដោយសារព្រះអង្គជឿជាក់ថា ពួកវៀតកុង-វៀតណាម


ឧត្តមសេនីយ៍ លន់ នល់ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយឧត្តមសេនីយ៍ ឡូ ជុយជីង

ខាងជើង នឹងបានទទួលជ័យជម្នះលើពួកវៀតណាមខាងត្បូង និងសហរដ្ឋអាមេរិក ជាក់ជាមិនខាន ហើយក្រោយទទួលបានជ័យជម្នះ ព្រះអង្គសង្ឃឹមថា ពួកវៀតកុង-វៀតណាមខាងជើង នឹងតបស្នងមកព្រះអង្គវិញ យ៉ាងហោចណាស់ ក៏ពួកគេមិនធ្វើការរំលោភឈ្លានពានមកលើបូរណភាពទឹកដីខ្មែរ ដូចពួកវៀតណាមខាងត្បូង ទៀតដែរ។

តាមពិតទៅ កងទ័ពវៀតកុង-វៀតណាមខាងជើង បានចូលមកយកទឹកដីខ្មែរជាជម្រក តាំងពីមុនឧត្តមសេនីយ៍ លន់ នល់ ទៅចុះកិច្ចព្រមព្រៀងជាមួយនាយអគ្គសេនាធិការកងទ័ពប្រជាជនចិន ថ្ងៃទី២៥ ខែវិច្ឆិកានោះ ទៅទៀត ហើយបើតាមប្រភពស៊ើបការណ៍សម្ងាត់របស់សហរដ្ឋអាមេរិក បានឱ្យដឹងថា នៅដើមខែវិច្ឆិកា មុនមានកិច្ចព្រមព្រៀងនោះ មេដឹកនាំវៀតកុង-វៀតណាមខាងជើង បានមកជួបជាសម្ងាត់ជាមួយ សឺន សាន ដែលជាឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីសម្របសម្រួលកិច្ចការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងផែនការ ដើម្បីជំរុញការសុំទិញអង្ករពីកសិករខ្មែរយកទៅផ្គត់ផ្គង់ឱ្យកងទ័ពរបស់ខ្លួន រួចទៅហើយ។

ចាប់ពីពេលពួកវៀតកុង-វៀតណាមខាងជើង ប្រមូលទិញអង្កររបស់កសិករខ្មែរយក

ទៅផ្គត់ផ្គង់ឱ្យកងទ័ពរបស់ខ្លួននោះមក សេដ្ឋកិច្ចកម្ពុជា ត្រូវជួបវិបត្តិយ៉ាងធ្ងន់ធ្ងរ។ អង្ករប្រមាណ១០ម៉ឺនតោន ដែលស្មើនឹងពាក់កណ្តាលនៃបរិមាណអង្ករប្រចាំឆ្នាំ ដែលរដ្ឋជាអ្នកនាំចេញទៅក្រៅប្រទេស បានក្លាយជាទំនិញគេចពន្ធ ដោយពួកឈ្មួញ និងប្រជាកសិករខ្លួនឯងនាំយកទៅលក់ឱ្យពួកកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលកំពុងបោះទីតាំងក្នុងទឹកដីខ្មែរតាមបណ្តោយព្រំដែនខាងកើត ក្នុងតម្លៃខ្ពស់ជាងតម្លៃរដ្ឋ ទ្វេ១ជា៣។

បញ្ហានេះបានធ្វើឱ្យការនាំចេញអង្កររបស់រដ្ឋត្រូវធ្លាក់ចុះ ហើយកាន់តែធ្វើឱ្យសេដ្ឋកិច្ចជាតិដុនដាបថែមទៀត ពិសេសសូម្បីតែមេទាហានធំៗមួយចំនួន ក៏មានទំនាក់ទំនងជាមួយពួកឈ្មួញធំៗ ក្នុងការរត់ពន្ធអង្ករយកទៅលក់ឱ្យពួកវៀតកុង-វៀតណាមខាងជើង នោះដែរ។

ដើម្បីបង្កើនប្រភពចំណូលថវិការដ្ឋ ពីការនាំចេញអង្ករទៅក្រៅប្រទេសឡើងវិញនោះ រាជរដ្ឋាភិបាលគ្មានមធ្យោបាយអ្វីក្រៅពីបង្ខំឱ្យប្រជាកសិករលក់ស្រូវអង្ករឱ្យរដ្ឋក្នុងតម្លៃទាបជាងតម្លៃនៅទីផ្សារសេរីនោះឡើយ។

សម្តេចសីហនុ ក៏បានត្អូញត្អែរថា ការរត់ពន្ធអង្ករទៅឱ្យពួកវៀតកុង-វៀតណាមខាងជើងនោះ ធ្វើឱ្យរាជរដ្ឋាភិបាលត្រូវខាតបង់ប្រាក់ចំណូលចូលរដ្ឋច្រើនណាស់។

ពួកឈ្មួញងងឹត មិនត្រឹមតែដឹកអង្ករទៅលក់ឱ្យពួកវៀតកុង-វៀតណាមខាងជើង ប៉ុណ្ណោះទេ គឺពួកគេបង្កើតជាខ្សែរយៈទាក់ទងទៅលក់ឱ្យប្រទេសវៀតណាមខាងត្បូង ទៀតដែរ។

ចំណែកកងទ័ពវៀតកុង-វៀតណាមខាងជើង វិញ នៅពេលរងការវាយប្រហារពីកងទ័ពវៀតណាមខាងត្បូង និងសហរដ្ឋអាមេរិក កាន់តែខ្លាំងឡើងៗ ពួកគេក៏ចេះតែរំកិលទីតាំងឈរជើងរបស់ពួកគេចូលមកកាន់តែជ្រៅទៅៗ ក្នុងទឹកដីកម្ពុជា។

ជាមួយគ្នានេះ បើតាមរបាយការណ៍របស់ភ្នាក់ងារសម្ងាត់អាមេរិក បានឱ្យដឹងថា កងទ័ពវៀតកុង-វៀតណាមខាងជើង ក៏បានប៉ះទង្គិចគ្នាបន្តិចបន្តួចជាមួយទាហានការពារព្រំដែនកម្ពុជា ចំនួន៨លើកផងដែរ។

គេជឿថា ឧត្តមសេនីយ៍ លន់ នល់ ប្រាកដជាដឹងរឿងនេះដែរ ព្រោះពួកទាហានការពារព្រំដែន ដែលនៅក្រោមបញ្ជារបស់គាត់ ប្រាកដជារាយការណ៍ពីការប៉ះទង្គិចគ្នានោះ



កងទ័ពរំដោះជាតិរំដោះវៀតណាមខាងត្បូង (វៀតកុង) ដើមទសវត្សរ៍ឆ្នាំ១៩៦០

ឱ្យគាត់ដឹងជាមិនខាន។

នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៦៦ ឧត្តមសេនីយ៍ ស្តេឡេយ៍ ឡារសុន មេបញ្ជាការកងទ័ពអាមេរិក ប្រចាំភូមិភាគកណ្តាលវៀតណាមខាងត្បូង ក៏បានរាយការណ៍ទៅទីបញ្ជាការប៉ង់តាហ្គោន ថា មានកងទ័ពវៀតកុងប្រមាណ១ម៉ឺននាក់ កំពុងប្រមូលផ្តុំគ្នានៅក្នុងទឹកដីខ្មែរក្បែរព្រំប្រទល់វៀតណាម។

បើទោះបីសម្តេចសីហនុ បានអនុញ្ញាតឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង បោះទីតាំងជាច្រើនកន្លែង នៅលើទឹកដីរបស់ប្រទេសកម្ពុជា ក៏ដោយ ក៏ក្នុងខែមករា ឆ្នាំ១៩៦៦ មេដឹកនាំវៀតកុង-វៀតណាមខាងជើង បានបង្កើតអង្គភាពសម្ងាត់មួយឈ្មោះ ប៉េ៣៦ (P36)។

អង្គភាពប៉េ៣៦(P36)នេះ ស្ថិតនៅក្រោមការដឹកនាំ និងគ្រប់គ្រងផ្ទាល់របស់ ឡេ ឌឹកថ ជាសមាជិកការិយាល័យនយោបាយរបស់គណៈកម្មាធិការមជ្ឈិមបក្សពលករវៀតណាម។ កាលពីឆ្នាំ១៩៤៨ គាត់ជាអនុលេខាបក្សកុម្មុយនិស្តឥណ្ឌូចិន នៅកូសាំងស៊ីន និងធ្លាប់ប្រចាំការនៅក្នុងប្រទេសកម្ពុជា កាលពីសម័យនោះផងដែរ។

## របត់នយោបាយ

នៅក្នុងឆ្នាំ១៩៦៦ ចៅ សេង (អតីតរដ្ឋមន្ត្រីក្រសួងឃោសនាការ) ជានិពន្ធនាយកកាសែតប្រចាំសប្តាហ៍ ឡា ដេប៉ែស្ហ(La Dépêche)មាននិន្នាការឆ្វេងនិយម បានបោះពុម្ពផ្សាយកាសែតរបស់គាត់ ក្នុងមួយលេខៗ ចំនួន៤000 ច្បាប់។

ចំណែកកាសែតមាតុភូមិ របស់ សឺង កឿកថ ដែលចេញផ្សាយតាំងពីឆ្នាំ១៩៥២ មកនោះ បានបោះពុម្ពផ្សាយក្នុងមួយលេខៗ ចំនួន៧000ច្បាប់។ កាសែតមាតុភូមិនេះ ជាញឹកញាប់តែងតែដកស្រង់យកអត្ថបទរបស់កាសែតរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (វៀតកុង)ឈ្មោះថាកាសែត ជុង ឡាប់ (អព្យាក្រឹត) មក បកប្រែជាភាសាខ្មែរ ទៅចុះផ្សាយនៅក្នុងកាសែតមាតុភូមិ បន្តទៀតផង។

ពេលនោះដែរ ក៏មានកាសែតព្រះវិហារ, កាសែតដំណឹងថ្មី, កាសែតភ្នំពេញប្រេស្ស និងកាសែតផ្សេងៗមួយចំនួនទៀត។

ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៦៦ ក្រុមហ៊ុនរកស៊ីឯកជនរបស់អាមេរិក ទាំងប៉ុន្មាន នៅក្នុងទីក្រុងភ្នំពេញ ដែលសង្ស័យថា មានជាប់ពាក់ព័ន្ធជាមួយពួក សេ.អ៊ី.អា ត្រូវរាជរដ្ឋាភិបាលកម្ពុជា ចេញបញ្ជាឲ្យបិទទ្វារទាំងអស់។

អំឡុងពេលនោះ ភោគ ឆាយ ត្រូវបានសម្តេចសីហនុ តែងតាំងជាអគ្គនាយកក្រុមហ៊ុនជាតិនាំចូល ដែលមានឈ្មោះកាត់ជាភាសាបារាំងថា សូណាព្រីម (SOMAPRIM)។

នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៦៦ សហភាពសូវៀត បានផ្តល់ជំនួយយោធាជាលើកដំបូង ដល់ប្រទេសកម្ពុជា។

នៅក្នុងខែឧសភា ឆ្នាំ១៩៦៦ នៅទីក្រុងភ្នំពេញ មានកិច្ចប្រជុំសំខាន់មួយស្តីពីបញ្ហាសេដ្ឋកិច្ចរបស់ប្រទេសជាតិ ហើយពួកឆ្វេងនិយម ដូចជា សូ ណែម, ចៅ សេង និងហ៊ូ នឹម ក៏បានឡើងជាវាគ្មិន ដើម្បីផ្តល់អនុសាសន៍ ក្នុងបំណងរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចជាតិមានការរីកចម្រើនដែរ។

# ១៩០
# កងទ័ពថៃ បានចូលមកឈ្លានពាន ប្រាសាទព្រះវិហារ ជាថ្មីម្តងទៀត



ប្រាសាទព្រះវិហារ

នៅដើមខែមេសា ឆ្នាំ១៩៦៦ កងទ័ពថៃ បានចូលរុករានទន្ទ្រានកាន់កាប់ប្រាសាទព្រះវិហារខ្មែរ ជាថ្មីម្តងទៀត។

ទាក់ទងដល់បញ្ហាឈ្លានពានរបស់ថៃ មកលើប្រាសាទព្រះវិហារនេះ យើងសូមរម្លឹកឡើងវិញថា នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៥៧ សេនាប្រមុខ សារិត ថាណារ៉ាត បានធ្វើរដ្ឋប្រហារទម្លាក់សេនាប្រមុខ ភិបុល សង្គ្រាម ចេញពីតំណែងនាយករដ្ឋមន្ត្រី ហើយសេនាប្រមុខ ភិបុល សង្គ្រាម នេះ ក៏បានភៀសខ្លួនចូលមកសុំសម្តេចសីហនុ ជ្រកកោននយោបាយនៅក្នុងប្រទេសកម្ពុជា។

សម្តេចសីហនុ ក៏បានទទួលស្វាគមន៍ចំពោះសេនាប្រមុខ ភិបុល សង្គ្រាម ដោយឱ្យ

ស្នាក់នៅក្នុងដំណាក់មួយរបស់ព្រះអង្គ និងឱ្យក្រុមព្រះរាជវង្សានុវង្សជួយទំនុកបម្រុងគាត់គ្រប់បែបយ៉ាង។

ក្រោយពីស្នាក់នៅបណ្ដោះអាសន្នក្នុងទីក្រុងភ្នំពេញ អស់រយៈពេលជិត៣ខែមក អតីតនាយករដ្ឋមន្ត្រីថៃ រូបនេះ ក៏បានសុំលាសម្ដេចសីហនុ ចាកចេញទៅរស់នៅទីក្រុងតូក្យូ ប្រទេសជប៉ុន នៅថ្ងៃទី០៣ ខែធ្នូ ក្នុងឆ្នាំដដែលនោះ បាត់ទៅ។

ដោយសារតែសម្ដេចសីហនុ ជួយយកអាសាសេនាប្រមុខ ភិបុល សង្គ្រាម នេះហើយ ទើបធ្វើឱ្យរាជរដ្ឋាភិបាលយោធារបស់សេនាប្រមុខ សារិត ថាណារ៉ាត ដែលកើតចេញពីរដ្ឋប្រហារនោះ ចេះតែបង្កជម្លោះជាមួយប្រទេសកម្ពុជា ពិសេសគឺបានរំលោភបំពានមកលើប្រាសាទព្រះវិហារទាំងកម្រោល។

ប៉ុន្តែ ទោះបីយ៉ាងនេះក្ដី ក៏នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៥៨ សម្ដេចសីហនុ ក៏បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់មួយក្រុមទៅទីក្រុងបាងកក ក្នុងរយៈពេលខ្លី ដើម្បីជួបសន្ទនាជាមួយព្រះមហាក្សត្រថៃ ភូមិវិបុល អាប់ឌុលយ៉ាដេត និងមេដឹកនាំកំពូលថៃផ្សេងៗទៀត។

ក្រោយមក ព្រះអង្គចាត់ឱ្យមានគណៈប្រតិភូមួយ ដោយមាន សឺន សាន ជាប្រធាន ទ្រឿង កាង និងសារិន ឆាក ជាអនុប្រធាន ព្រមទាំងថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធជាច្រើនទៀត (ស្ថាប័នភូមិសាស្ត្រ, ប៉ូលិស, គយ, រាជអយស្ម័យយាន)ជាសមាជិក ទៅចរចាជាមួយភាគីថៃ ដែលដឹកនាំដោយព្រះអង្គម្ចាស់ វណ្ណ វៃថៈយ៉ាកន និងហ្លួង វិជិត្រ វ៉ាថៈកាន ព្រមទាំងនាយទាហានជាន់ខ្ពស់ថៃ ជាច្រើនរូបទៀត ដើម្បីធ្វើការសម្របសម្រួលគ្នាពីបញ្ហាជម្លោះប្រាសាទព្រះវិហារ នេះបន្តទៀតដែរ។ ប៉ុន្តែ មិនអាចធ្វើការសម្របសម្រួលគ្នាបានទេ ព្រោះភាគីថៃ មិនទទួលស្គាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងផែនទីឧបសម្ព័ន្ធក្នុងកិច្ចព្រមព្រៀងបារាំង-សៀម ឆ្នាំ១៩០៧។

ទោះបីកិច្ចចរចានោះ មិនទទួលបានលទ្ធផលអ្វីបន្តិច ក៏ដោយ ក៏នៅពេលបែកគ្នា ភាគីទាំងពីរនៅតែញញឹមរាក់ទាក់ ដាក់គ្នាទៅវិញទៅមក ដូចធម្មតា។

ប៉ុន្តែ មួយថ្ងៃក្រោយមក មេដឹកនាំថៃ បានរៀបចំឱ្យមានបាតុកម្មធំមួយ ប្រឆាំងនឹង

ស្ថានទូតរបស់កម្ពុជា នៅក្នុងក្រុងបាងកក រួចហើយបន្តទៅមុខស្ថានទូតអាមេរិក ទៀត។

លុះមកដល់ខែកញ្ញាឆ្នាំ១៩៥៨ ភាគីកម្ពុជា និងថៃ ក៏ចាប់ផ្ដើមជេរប្រមាថគ្នាទៅវិញទៅមកតាមរយៈទំព័រសារព័ត៌មាន និងរលកធាតុអាកាសវិទ្យុរៀងៗខ្លួន បង្កជាសង្គ្រាមពាក្យសម្ដី មួយឆាបឆេះយ៉ាងសន្ធោសន្ធៅ។

ពួកអ្នកការទូតបស្ចិមប្រទេស ក៏បានកត់ត្រាទុករាល់ពាក្យសម្ដី និងឃ្លាឃ្លោងដែលភាគីទាំង២ ជេរប្រមាថគ្នានោះ ចងក្រងជាឯកសារក្នុងសៀវភៅ.ស ផងដែរ។

បន្ទាប់មក ភាគីថៃ បានដាក់ពង្រាយកងទ័ពជាច្រើននៅតាមបណ្ដោយព្រំដែន ដើម្បីគំរាមមកលើប្រទេសកម្ពុជា។

ជាការឆ្លើយតបនឹងការគំរាមកំហែងនេះ ភាគីកម្ពុជា ក៏បានដាក់ពាក្យបណ្ដឹងទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងបានប្រកាសផ្ដាច់ទំនាក់ទំនងការទូតជាមួយប្រទេសថៃ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៥៨។

ពេលនោះ ដាក ហាំម៉ាស្គហ្សូល (Dag Hammarskjöld) អគ្គលេខាធិការអង្គការសហប្រជាជាតិ ក៏បានចាត់ឱ្យតំណាងម្នាក់ ឈ្មោះ បេក ហ្វ្រីអ៊ីស ទៅធ្វើការស្រាវជ្រាវពីបញ្ហាជម្លោះនៅប្រាសាទព្រះវិហារ នោះផ្ទាល់តែម្ដង និងបានជួយធ្វើការសម្របសម្រួលផ្សះផ្សាឱ្យមានការជានាគ្នាវិញ ហើយភាគីកម្ពុជា និងថៃ បានយល់ព្រមផ្សារទំនាក់ទំនងការទូតជាមួយគ្នាឡើងវិញ នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៥៩។

នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៥៩ ថៈណាត់ ខម៉ាន់ ជារដ្ឋមន្ត្រីការបរទេសថៃ បានធ្វើដំណើរមកទីក្រុងភ្នំពេញ ដើម្បីចុះហត្ថលេខាជាមួយ សឺន សាន រដ្ឋមន្ត្រីការបរទេសកម្ពុជា លើសេចក្ដីប្រកាសរួមមួយ ស្ដីពីការគោរពបូរណភាពទឹកដី និងមិនជ្រៀតជ្រែកដល់កិច្ចការផ្ទៃក្នុងរបស់គ្នា ទៅវិញទៅមក។

តែដោយសារភាគីថៃ គ្មានឆន្ទៈពិតប្រាកដក្នុងការដកកងទ័ពចេញពីប្រាសាទព្រះវិហារនោះ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៥៩ រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ពាក្យបណ្ដឹងទៅតុលាការយុត្តិធម៌អន្តរជាតិ នៅទីក្រុងឡាអេឱ្យជួយដោះស្រាយ ហើយពីរថ្ងៃក្រោយមក ភាគី

ទាំងពីរ ក៏ចាប់ផ្ដើមជេរប្រមាថគ្នាជាថ្មីម្ដងទៀត។

នៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៦០ សេនាប្រមុខ សារិត ថាណារ៉ាត នាយករដ្ឋមន្ត្រីថៃ បានថ្លែងសុន្ទរកថាមួយ ដោយបានប្រើពាក្យជេរប្រមាថធ្ងន់ៗមកលើសម្ដេចសីហនុ ធ្វើឱ្យភាគីកម្ពុជា បង្ខំចិត្តកាត់ផ្ដាច់ចំណងការទូតជាមួយប្រទេសថៃ ជាថ្មីម្ដងទៀត។

នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ តុលាការយុត្តិធម៌អន្តរជាតិ នៅក្រុងឡាអេ បានសម្រេចថា ប្រាសាទព្រះវិហារជារបស់កម្ពុជា និងឱ្យកងទ័ព ប៉ូលិស និងឆ្មាំថៃទាំងអស់ ត្រូវដកចេញពីបរិវេណប្រាសាទនេះ។

ដោយសារតែការទាមទារប្រាសាទព្រះវិហារ ឱ្យមកជាសម្បត្តិវប្បធម៌ជាតិវិញ ដោយជោគជ័យដូចការបន់ស្រន់នោះ សម្ដេចសីហនុ បានកោរព្រះកេសាថ្វាយដល់ព្រះពុទ្ធជាម្ចាស់ ដោយក្ដីជឿជាក់បំផុត ហើយប្រជារាស្ត្រខ្មែរទាំងមូលក៏មានចិត្តសប្បាយរីករាយរកអ្វីប្រៀបផ្ទឹមពុំបានដែរ។ ប៉ុន្តែ សម្រាប់មេដឹកនាំថៃ ដែលចាញ់ក្ដីយ៉ាងអាម៉ាស់បំផុតនោះ បានរៀបចំឱ្យមានបាតុកម្មដ៏ធំមួយ ប្រឆាំងនឹងសាលក្រមតុលាការក្រុងឡាអេ និងបានបញ្ជាឱ្យកងទ័ពខ្លួនធ្វើសកម្ម ភាពអុកឡុកបង្ករឿងនៅតំបន់ប្រាសាទព្រះវិហារ និងតាមតំបន់ឆ្នេរសមុទ្រក្នុងខេត្តកោះកុង ផងដែរ។ ប៉ុន្តែ ដោយសារខ្លាចញញើតមានការតបតពីភាគីកម្ពុជា វិញនោះ ថៃបានស្នើសុំទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ឱ្យមានការស៊ើបអង្កេតមួយ ស្ដីពីបញ្ហាព្រំដែនប្រទេសទាំងពីរ។

ក្នុងខែតុលា ឆ្នាំ១៩៦២ អគ្គលេខាធិការអង្គការសហប្រជាជាតិ បានប្រគល់ភារកិច្ចជូនអ្នកការទូតជាជនជាតិស៊ុយអែដម្នាក់ឈ្មោះ នីល ហ្គូស៊ីង (Nils Gussing) ឱ្យមកពិនិត្យស្ថានការណ៍ជម្លោះជាក់ស្ដែង ទាំងនៅខាងថៃ និងនៅខាងកម្ពុជា។

អ្នកការទូតអន្តរជាតិរូបនេះ បានធ្វើការវាយតម្លៃពីជម្លោះនោះថា ភាគីទាំងពីរ ពុំមានចេតនាពង្រីកការប៉ះទង្គិចគ្នាបន្តិចបន្តួចនោះ ឱ្យទៅជាសង្គ្រាមបង្ហូរឈាមគ្នាអ្វីធំដុំទេ ហើយគាត់បានសំណូមពរឱ្យភាគីទាំងពីរ កុំធ្វើសកម្មភាពអ្វីឱ្យលើសពីនេះទៀត។

នៅថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៦៣ សម្ដេចសីហនុ បានយាងទៅធ្វើព្រះរាជបូជនីយេសក៍

ដ៏ធំមួយនៅប្រាសាទព្រះវិហារ ដែលជាសម្បត្តិវប្បធម៌ខ្មែរដ៏មានតម្លៃ មិនអាចកាត់ថ្លៃបាននោះ។

នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ១៩៦៣ សេនាប្រមុខ សារិត ថាណារ៉ាត នាយករដ្ឋមន្ត្រីថៃ ទទួលមរណភាព ដោយសារជំងឺខ្សោយតម្រងនោម (តម្រងទឹកមូត្រ) និងជំងឺផ្សេងៗមួយចំនួនទៀត ក្នុងវ័យ៥៥ ឆ្នាំ។



**សម្តេចសីហនុ យាងទៅធ្វើព្រះរាជបូជនីយសក្ការៈ នៅប្រាសាទព្រះវិហារ ឆ្នាំ១៩៦៣**

នាយករដ្ឋមន្ត្រីថៃ ជាអ្នកប្រឆាំងនឹងនយោបាយរបស់សម្តេចសីហនុ រូបនេះ បានទទួលមរណភាពក្រោយរយៈពេលតែ៦ថ្ងៃប៉ុណ្ណោះ បន្ទាប់ពីប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម និងប្អូនប្រុសគាត់ ង៉ូ ឌិញញូ ជាអ្នកប្រឆាំងនឹងនយោបាយរបស់សម្តេចសីហនុ ដ៏មោះមុតដែរនោះ ត្រូវឧត្តមសេនីយ៍ យឿង វ៉ាន់មិញ ធ្វើរដ្ឋប្រហារចាប់ខ្លួនបាន និងបញ្ជាឱ្យទាហានកូនចៅជំនិតរបស់គាត់ យកកាំបិតខ្លីមកចាក់សម្លាប់ចោលកាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ ១៩៦៣។

លុះដល់ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៣ ប្រធានាធិបតី កេណ្ណឌី ជាអ្នកប្រឆាំងនឹងនយោបាយរបស់សម្តេចសីហនុ ដែរនោះ ត្រូវខ្មាន់កាំភ្លើងលបបាញ់គាត់ពីអគារកម្ពស់៦ជាន់ ពីរគ្រាប់ផ្ទួនៗគ្នា គឺចំក្បាលមួយគ្រាប់ និងចំបំពង់កមួយគ្រាប់ បណ្តាលឱ្យដងខ្លួនដួលរលំ

ទៅលើភ្លៅកវិយារបស់គាត់ ហើយខ្មាន់កាំភ្លើងបានបាញ់បន្ថែមមួយគ្រាប់ទៀត តែត្រូវចំខ្លួនអភិបាលរដ្ឋតិចសាស់។ តែដោយសារមុខរបួសមានសភាពធ្ងន់ធ្ងរពេក ក៏ត្រូវបាត់បង់ជីវិតនៅវេលាម៉ោង១រសៀល នៅថ្ងៃដដែល ក្នុងវ័យ៤៦ ឆ្នាំ ក្រោយពេលបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ។

ដំណឹងស្តីពីការធ្វើរដ្ឋប្រហារសម្លាប់ប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម និងមរណភាពសេនាប្រមុខ សារិត ថាណារ៉ាត នាយករដ្ឋមន្ត្រីថៃ ព្រមទាំងការបាញ់ប្រហារប្រធានាធិបតី កេណ្ណឺឌី គួរឱ្យក្រៀមក្រំ និងភ្ញាក់ផ្អើលនោះ នៅប្រទេសកម្ពុជា ជាដំណឹងដ៏រីករាយ និងការចំអកផ្តន្ទាទៅវិញ ចំពោះប្រជារាស្ត្រខ្មែរ ដែលគាំទ្រយ៉ាងស្ម័គ្រស្មោះជាមួយគោលមាគ៌ានយោបាយរបស់សម្តេចសីហនុ។

ជាមួយគ្នានេះ ប្រជារាស្ត្រខ្មែរបានសម្តែងកំហឹងឈឺចាប់ទៅលើឧត្តមសេនីយ៍ ប្រ៉ះផាត ចារុសៈធៀន ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងថៈណាត់ ខម៉ាន់ ជារដ្ឋមន្ត្រីការបរទេសថៃ ដោយសារតែការរំលោភបំពានមកលើអធិបតេយ្យភាពកម្ពុជា នោះទៀតដែរ។

ក្រោយពី សារិត ថាណារ៉ាត ស្លាប់ទៅ ថៈណម គិតទិខៈចន បានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីថៃ បន្តទៀត។

តាំងពី ខែមករា ឆ្នាំ១៩៦៤ មកម្ល៉េះ សម្តេចសីហនុ បានស្នើសុំឱ្យមេដឹកនាំថៃ ចុះហត្ថលេខាលើកតិកាសញ្ញាស្តីពីការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងគ្នាទៅវិញទៅមក និងទទួលស្គាល់ខ្សែបន្ទាត់ព្រំដែនរបស់ប្រទេសទាំងពីរ តាមផែនទីដែលជាឧបសម្ព័ន្ធនៃកិច្ចព្រម ព្រៀងបារាំង-សៀម កាលពី ឆ្នាំ១៩០៤ និងឆ្នាំ១៩០៧។ ប៉ុន្តែមេដឹកនាំថៃ មិនដែលឆ្លើយតបម្តងណាទេ គឺមានតែការរំលោភបំពានតាមបណ្តោយព្រំដែន ថែមទៀតប៉ុណ្ណោះ។

នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៦៦ អគ្គសេនាធិការដ្ឋានកងទ័ពកម្ពុជា បានប្រកាសថា កងទ័ពថៃជាច្រើន បានចូលមករំលោភបំពានដណ្តើមកាន់កាប់ប្រាសាទព្រះវិហារ ជាថ្មីម្តងទៀត ហើយបានសម្លាប់ឆ្មាំការពារប្រាសាទរបស់កម្ពុជា ចំនួន៥នាក់។

ប៉ុន្តែ ៣ថ្ងៃក្រោយមក អគ្គសេនាធិការដ្ឋានកងទ័ពកម្ពុជា ក៏បានប្រកាសថា កងទ័ព

កម្ពុជា បានវាយដណ្ដើមប្រាសាទព្រះវិហារ មកវិញហើយ។ ប៉ុន្តែភាគីថៃ បដិសេធថា ការវាយប្រហារគ្នានៅតំបន់ប្រាសាទព្រះវិហារនោះ គឺជារឿងជម្លោះ ដែលកើតឡើងពីការដោះដូរទំនិញខុសច្បាប់ទៅវិញ ហើយភាគីថៃ ក៏បានស្នើទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ឱ្យបញ្ជូនអ្នកសង្កេតការណ៍ មកធ្វើការពិនិត្យស្រាវជ្រាវបញ្ហានេះ។ ឯភាគីកម្ពុជា ក៏យល់ព្រមតាមការស្នើសុំរបស់ភាគីថៃ នេះដែរ។

នៅក្នុងខែសីហា ឆ្នាំ១៩៦៦ អគ្គលេខាធិការអង្គការសហប្រជាជាតិ អ៊ូ ថាន់ បានតែងតាំងអ្នកការទូតជាជនជាតិស៊ុយអែដម្នាក់ទៀត ឈ្មោះហឺបឺត ដឺ រីបប៊ិញ( Herbert De Ribbing )ជាតំណាង ឱ្យមកជួយធ្វើការសម្របសម្រួលពីបញ្ហាជម្លោះព្រំដែនរបស់ប្រទេសទាំងពីរ។

តែដោយសារមេដឹកនាំប្រទេសទាំងពីរ ប្រកែកយកត្រូវតែរៀងៗខ្លួន ធ្វើឱ្យពួកមន្ត្រីអង្គការអន្តរជាតិទាំងអស់ ដែលបានចូលរួមដោះស្រាយ និងតាមដានហេតុការណ៍ជម្លោះនេះ នាំគ្នាគ្រវីក្បាលហួសចិត្តគ្រប់ៗគ្នា។

សម្ដេចសីហនុ បានប្រកាសប្រាប់សាធារណមតិអន្តរជាតិថា ការចាប់ផ្ដើមផ្សារទំនាក់ទំនងការទូតរបស់ប្រទេសកម្ពុជា ជាមួយប្រទេសថៃ ឡើងវិញ គឺត្រូវតែធ្វើតាមរយៈការចុះហត្ថលេខាលើសេចក្ដីថ្លែងការណ៍រួមមួយ ឈរលើគោលការណ៍គោរពព្រំដែនរួមគ្នា។ ប៉ុន្តែរដ្ឋមន្ត្រីការបរទេសថៃ ថៈណាត់ ខម៉ាន់ មិនចង់ឱ្យមានសេចក្ដីថ្លែងការណ៍រួម តាមការចង់បានរបស់សម្ដេចសីហនុ ហើយគាត់ក៏មិនធ្វើការសម្របសម្រួលណាមួយពីបញ្ហាខ្សែបន្ទាត់ព្រំដែននោះដែរ។

ដោយសារតែខឹងសម្បាពីបញ្ហានេះ សម្ដេចសីហនុ បានចំអកដោយហៅរដ្ឋមន្ត្រីការបរទេសថៃ ដែលមានឈ្មោះថៈណាត់ ខម៉ាន់ នោះថាជា ថៈណាត់ ខមាន់ និងហៅនាយករដ្ឋមន្ត្រីថៃ ថៈណម គិតទិខៈចន នោះ ថាជា ថៈណម កាទិច កាទី ទៅវិញ។

ពេលកំពុងមានជម្លោះជាមួយមេដឹក- នាំថៃនោះដែរ ពួកខ្មែរកុម្មុយនិស្ត នៅក្នុងប្រទេសក៏បានធ្វើសកម្មភាពប្រឆាំងនឹងសម្ដេចសីហនុ កាន់តែខ្លាំងឡើងៗផងដែរ។ ពួកគេបានបាច


នាយករដ្ឋមន្ត្រីថៃ ថៈណោម គិតតិខៈចន

ខិត្តប័ណ្ណ ដែលមានខ្លឹមសារថា ពួកសក្តិភូមិកំពុងសង្ឃឹមថា អាចរក្សាការពារបាននូវរបបគ្រប់គ្រងមួយ ដែលបណ្តោយឱ្យពួកគេជិះជាន់សង្កត់សង្កិនវណ្ណៈ កម្មករ កសិករ បានស្រេចតែចិត្តដោយគ្មាន ការរើបម្រះ។

ជាមួយគ្នានោះដែរ នៅខេត្តកំពង់ចាម កម្មករចម្ការកៅស៊ូបាននាំគ្នាងើបឡើងប្រឆាំងនឹងពួកបារាំង ដែលជាអ្នកគ្រប់គ្រងចម្ការកៅស៊ូនោះថា បានជិះជាន់សង្កត់សង្កិនពួកគេ ហើយបានចោទប្រកាន់សម្តេចសីហនុ និងមន្ត្រី នៃរបបសង្គមរាស្ត្រនិយមថា ជាបរិវាររបស់ពួកអាណានិគមបែបថ្មីទៀតផង។

នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៦៦ កងឧទ្ទាមកុម្មុយនិស្តនៅភូមិភាគពាយ័ព្យ ដែលស្ថិតនៅក្រោមការដឹកនាំរបស់ រស់ ញឹម ហៅមូល សម្បត្តិ បានធ្វើសកម្មភាពពួនស្ទាក់វាយប្រហារទៅលើរថភ្លើងមួយខ្សែនៅក្នុងខេត្តបាត់ដំបង។

ទោះបីយ៉ាងនេះក៏ដោយ ក៏នៅក្នុងឆ្នាំ១៩៦៦ សម្តេចសីហនុ បានចេញព្រះរាជក្រឹត្យមួយឱ្យដោះលែង ឈ្មោះ លី សែ (ក្មួយរបស់ នៃ សារ៉ាន់) ចេញពីពន្ធនាគារព្រៃស វិញ។

ប៉ុន្តែ នៅភូមិភាគបូព៌ាឯណោះវិញ យុវជនម្នាក់ឈ្មោះ ស៊ិន សុង ជាកូនកសិករនៅខេត្តព្រៃវែង ដែលបានចូលរួមក្នុងចលនាយុវកក(យុវជនកុម្មុយនិស្តកម្ពុជា)កាលពីឆ្នាំ១៩៦៥ ក៏ត្រូវប៉ូលិសចាប់យកទៅដាក់ពន្ធនាគារនៅទីរួមខេត្តព្រៃវែង រយៈពេល៣ខែដែរ ពីបទបះបោរប្រឆាំងនឹងចៅហ្វាយស្រុកពាមជរ ដែលប្រជាជនចោទប្រកាន់ថា បានបន្លំប្រាក់កាសចូលរួមក្នុងការបង្កើតរាជសហករណ៍របស់ពួកគេ។

ក្រោយការចាប់ខ្លួនរបស់យុវជន ស៊ិន សុង និងអ្នកភូមិមួយចំនួនទៀត ប្រជាជនក៏នាំ


រដ្ឋមន្ត្រីការបរទេសថៃ ថៈណាត់ ខម៉ាន់

គ្នាធ្វើបាតុកម្មនៅមុខសាលាស្រុកពាមជរ ខេត្តព្រៃវែង ទាមទារឱ្យដោះលែងពួកគេវិញ។

មិនយូរប៉ុន្មាន សម្តេចសីហនុក៏បានបញ្ជាឱ្យដោះលែង ស៊ិន សុង និងអ្នកតវ៉ា៦នាក់ទៀត។

ក្នុងរបបរដ្ឋ កម្ពុជា ស៊ិន សុង បានឡើងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជារដ្ឋមន្ត្រីក្រសួង សន្តិសុខជាតិ ពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩៣។

នៅស្រុកកំចាយមារ ក្នុងខេត្តព្រៃវែង ពួកទាហានលន់ នល់ បានសម្លាប់អតីតខ្មែរឥស្សរៈ និងជាខ្សែរយៈរបស់ពួកឧទ្ទាមកុម្មុយនិស្តម្នាក់ ហើយព្រះសង្ឃមួយរូបទៀត ត្រូវចាប់ផ្សឹកយកទៅដាក់ពន្ធនាគារ ពីបទចូលរួមសកម្មភាពជាមួយពួកឧទ្ទាមកុម្មុយនិស្ត។

នៅក្នុងខេត្តកំពង់ស្ពឺ ក្រុមអ្នកលេងភ្លេងការមួយក្រុម មានគ្នា៦នាក់នៅក្នុងស្រុកឧដុង្គ ត្រូវរងការចោទប្រកាន់ថា ជាខ្សែរយៈបង្កប់របស់ពួកឧទ្ទាមកុម្មុយនិស្តដែរនោះ ត្រូវពួកទាហានលន់ នល់ ចាប់យកទៅសម្លាប់ចោលដោយវះពោះ រួចយកថ្លើមទៅដាក់តាំងនៅក្បែរបេងបន្ទាយរបស់ពួកគេ។

នៅខេត្តកោះកុង មេឧទ្ទាមកុម្មុយនិស្តម្នាក់ ឈ្មោះ ប្រាសិទ្ធ បាននាំយុទ្ធជនរបស់គាត់រត់គេចខ្លួនទៅរស់នៅបណ្តោះអាសន្នក្នុងទឹកដីថៃ នៅពេលពួកទាហានលន់ នល់ បើក ប្រតិបត្តិការបោសសម្អាតពួកឧទ្ទាមនៅក្នុងខេត្តនោះ។

ប្រឈមនឹងការធ្វើសកម្មភាពយ៉ាងផុសផុលគ្រប់ទីកន្លែងរបស់ពួកកុម្មុយនិស្តនោះ សម្តេចសីហនុ បានសរសេរអត្ថបទមួយចុះផ្សាយតាមរយៈទំព័រទស្សនាវដ្តីប្រចាំខែ របស់ព្រះអង្គឈ្មោះសង្គម ដោយដាក់ចំណងជើងថា តើហេតុអ្វី បានជាពួកកុម្មុយនិស្តអំពាវនាវ

ឱ្យប្រជារាស្ត្រ បញ្ញវន្ត និងយុវជន ប្រឆាំងនឹងព្រះអង្គ?។

អំឡុងពាក់កណ្តាលឆ្នាំ១៩៦៦ ពួកឧទ្ទាមកុម្មុយនិស្ត បានបាចខិតប័ណ្ណជាច្រើនកន្លែង ដែលខិត្តប័ណ្ណទាំងនោះ មានសរសេរខ្លឹមសារថា របបសព្វថ្ងៃនេះ ជារបបពុករលួយដែលគ្រប់គ្រង ដោយបុគ្គលនិយម។ យើងរស់នៅក្នុងភាពអាប់អួរមួយ តាំងពីប្រទេសមានឯករាជ្យមក ដូច្នេះ យើងត្រូវតែលុបបំបាត់ របបនេះឱ្យបានជាដាច់ខាត។

ខ្លឹមសារនៃខិត្តប័ណ្ណបានបន្តថា កូនចៅរបស់មាតុភូមិដ៏អង់អាចក្លាហាន និងដ៏សុចរិតទៀងត្រង់របស់យើងទាំងអស់ ត្រូវតែចូលរួមជាមួយបក្សបដិវត្តន៍ ដើម្បីដឹកនាំប្រទេសទៅកាន់លទ្ធិសង្គមនិយម លទ្ធិកុម្មុយនិស្តនិយម ដែលស្អាតស្អំ និងស្មើភាពគ្នា។ ពួកសក្តិភូមិនាយទុន ដែលរស់នៅសប្បាយហ៊ឺហាលើគំនរញើសឈាមរបស់វណ្ណៈកសិករ កម្មករ និងមហាជននោះ មិនញញើតក្នុងការប្រើវិធីផ្សេងៗដើម្បីឱ្យបានវត្ថុសម្ភារៈប្រើប្រាស់ប្រណីតៗ និងដើម្បីបំពេញតណ្ហារបស់ពួកគេឡើយ។ ពួកគេនេះហើយ ដែលបង្កឱ្យប្រជាជនយើងរស់នៅក្នុងភាពទុគ្គត អត់ឃ្លាន លំបាកវេទនា។

នៅចុងបញ្ចប់ ខិត្តប័ណ្ណនោះបានសង្កត់ធ្ងន់ថា គោលដៅរបស់បដិវត្តន៍ គឺរំដោះ-ប្រជាជនពីការជិះជាន់របស់វណ្ណៈនាយទុន និងពួកសក្តិភូមិ ហើយដើម្បីឱ្យបដិវត្តន៍នេះទទួលជោគជ័យ ចាំបាច់ត្រូវតែប្រើកម្លាំងប្រយុទ្ធតស៊ូ។

# ១៩១
# នរណាជាអ្នកឲ្យឈ្មោះខ្មែរកុម្មុយនិស្តថា ខ្មែរក្រហម ?



**កងទ័ពខ្មែរក្រហម**

នៅថ្ងៃទី៣១ ខែកក្កដា ដល់ថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៦៦ ឧទ្ធម្ភាគចក្ររបស់អាមេរិក បានធ្វើការបាញ់រះជាប់ៗគ្នា រយៈពេល៤ថ្ងៃមកលើភូមិថ្លុកត្រាច ដែលស្ថិតនៅក្នុងឃុំកក់ ស្រុកពញាក្រែក ខេត្តកំពង់ចាម (សព្វថ្ងៃជាខេត្តត្បូងឃ្មុំ) ជាកន្លែងគណៈកម្មការត្រួតពិនិត្យអន្តរជាតិមួយក្រុម កំពុងឈរជើងនៅទីនោះផងដែរ បណ្តាលឱ្យស្លាប់ និងរបួសអ្នកភូមិមួយចំនួន។

លុះដល់ថ្ងៃទី១០ខែសីហា សហរដ្ឋអាមេរិកក៏បានប្រកាសសុំទោសចំពោះហេតុការណ៍វាយប្រហារនោះ ដោយលើកហេតុផលថា ដោយសារមើលតាមផែនទីដែលធ្វើឡើងដោយសហរដ្ឋអាមេរិក ពួកគេឃើញភូមិថ្លុកត្រាចនេះ មិនស្ថិតនៅខាងក្នុងខ្សែបន្ទាត់ព្រំដែនខាងកម្ពុជា ទេ។

ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៦៦ ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង ឧត្តមសេនីយ៍ ហ្សារាល ជឺ ហ្គោល (Charles de Gaulle) បានអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជា។ សម្តេចសីហនុ បានរៀបចំពិធីទទួលស្វាគមន៍យ៉ាងកក់ក្តៅអធិកអធមបំផុត។



**ហ្សាល ដឺ ហ្គោល**

ថ្លែងនៅក្នុងពិធីទទួលស្វាគមន៍ក្នុងចំណោមរាស្ត្រខ្មែរជាច្រើនម៉ឺននាក់ នៅពហុកីឡដ្ឋានជាតិអូឡាំពិក នៅថ្ងៃទី០២ ខែកញ្ញា ប្រធានាធិបតីបារាំងរូបនេះ បានប្រកាសជាឱឡារិកថា គាត់គាំទ្រយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិស្វ័យសម្រេចរបស់ប្រជាជាតិមួយ ដែលមានឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដី គឺក្នុងន័យផ្ញើសារទៅឱ្យសហរដ្ឋអាមេរិក ឱ្យគោរពនូវសិទ្ធិស្វ័យសម្រេចរបស់ប្រទេសកម្ពុជា។

ក្នុងដំណើរទស្សនកិច្ចជាប្រវត្តិសាស្ត្រនោះ ហ្សាល ដឺ ហ្គោល និងភរិយា ក៏បានចូលរួមទស្សនាព្រះរាជពិធីបុណ្យអុំទូក អកអំបុក លយប្រទីប និងសំពះព្រះខែ ដែលជាបុណ្យប្រពៃណីជាតិខ្មែរ ដ៏សំខាន់មួយ។

នៅក្នុងខែកញ្ញានោះដែរ ក្រោយពីសម្ដេចសីហនុ ចុះផ្សាយអត្ថបទមួយ ដែលព្រះអង្គជាអ្នកនិពន្ធផ្ទាល់មានចំណងជើងថា៖ "អាកប្បកិរិយាពួកកុម្មុយនិស្តខ្មែរ ចំពោះសង្គមរាស្ត្រនិយម" នៅក្នុងទស្សនាវដ្ដីសង្គម របស់ព្រះអង្គនោះមក សាឡុត ស ដែលទើបវិលត្រលប់មកពីប្រទេសចិន និងវៀតណាមខាងជើង មកដល់មន្ទីរ១០០នៅក្នុងព្រៃនៃខេត្តតៃនិញ វិញ បានបើកអង្គប្រជុំពិសេសមួយ សម្រេចការប្ដូរឈ្មោះពីបក្សពលករកម្ពុជា មកជាបក្សកុម្មុយនិស្តកម្ពុជា វិញ។

ដោយសារមានសម្ពាធពីតំណាងពួកឈ្មួញធំៗ និងពួកវណ្ណៈម្ចាស់ដីផង និងដោយ

លែងចង់ការពារពួកឆ្វេងនិយមនៅក្នុងប្រព័ន្ធនយោបាយទៀតនោះ  នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសម្រាប់អាណត្តិថ្មី នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៦៦ សម្តេចសីហនុ បានសម្រេចព្រះទ័យឈប់ជ្រើសរើសបេក្ខជនរបស់ចលនាសង្គមរាស្ត្រនិយម ដោយ ព្រះអង្គផ្ទាល់ដូចអាណត្តិមុនៗទៀត  គឺទុកឱកាសឱ្យឥស្សរជន  ឬប្រជាជនទូទៅអាចឈរឈ្មោះជាបេក្ខជនបានដោយសេរី។

ការបើកចំហឱ្យឈរឈ្មោះដោយសេរីបែបនេះ ជាការបង្ហាញឱ្យឃើញថា ការបោះឆ្នោតនោះ មានលទ្ធិប្រជាធិបតេយ្យសេរី និងយុត្តិធម៌ក៏ពិតមែន ប៉ុន្តែ វាជាឱកាសល្អរបស់បេក្ខជនជាអ្នកមានលុយកាក់ទ្រព្យសម្បត្តិមួយចំនួន  ងាយស្រួលក្នុងការទិញទឹកចិត្តប្រជារាស្ត្រជាម្ចាស់ឆ្នោតផងដែរ។

ក្នុងចំណោមអតីតតំណាងរាស្ត្រពីអាណត្តិមុន  ចំនួន៧៧នាក់  មាន៤២នាក់  បានឈរឈ្មោះជាបេក្ខជនសម្រាប់អាណត្តិថ្មី  ហើយអាណត្តិមុន  អាសនៈនៅក្នុងរដ្ឋសភាមាន៧៧អាសនៈនោះ  ត្រូវបន្ថែម៥អាសនៈទៀត  ឱ្យទៅជា៨២អាសនៈនៅក្នុងអាណត្តិថ្មី  និងមានបេក្ខជនឈរឈ្មោះ សរុប៤២៥នាក់ សម្រាប់មណ្ឌលបោះឆ្នោតចំនួន៨២ ដោយមណ្ឌលនីមួយៗត្រូវជ្រើសរើសតំណាងរាស្ត្រម្នាក់។

ពេលនោះ សឺង គឿកថ ជាចាងហ្វាងកាសែតមាតុភូមិ ដែលមានបញ្ហាថ្នាំងថ្នាក់ជាមួយសម្តេចសីហនុ ព្រមទាំង ចៅ សេង អតីតរដ្ឋមន្ត្រីក្រសួងឃោសនាការ និងសូ ណែម ជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ដែលជាពួកឆ្វេងនិយម មិនបានឈរឈ្មោះជាបេក្ខជនជាថ្មីទៀតទេ។

ខៀវ សំផន, ហ៊ូ នឹម និងហ៊ូ យន់ បានសម្រេចចិត្តឈរឈ្មោះជាបេក្ខជនជាថ្មីម្តងទៀត តែពួកគាត់ក៏ជួបការលំបាកខ្លះៗដែរ ព្រោះសម្តេចសីហនុ បានមានព្រះរាជឱង្ការវាយប្រហារពួកគាត់ចំៗតែម្តង។

ទោះបីយ៉ាងនេះក៏ដោយ ក៏ ខៀវ សំផន ដែលឈរឈ្មោះនៅមណ្ឌលស្អាង ក្នុងខេត្តកណ្តាលបានជាប់ឆ្នោតជាថ្មីម្តងទៀត  ហើយ  ហ៊ូ  យន់  បានទទួលសំឡេងគាំទ្រហូតដល់

ទៅ៧៨ភាគរយ នៅក្នុងមណ្ឌលកងមាស ក្នុងខេត្តកំពង់ចាម។

ចំណែក ហ៊ូ នឹម ដែលឈរឈ្មោះមណ្ឌលជ្រៃវៀន ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម បានប្រជែងគ្នាជាមួយបេក្ខជន៣នាក់ទៀត គឺ ១- ឈ្មោះ ជុំ សារុំ ជាមនុស្សរបស់ លន់ នល់, ២- ឈ្មោះ សុស សាអ៊ុន ជាមនុស្សរបស់ អ៊ី ទុយ ចៅហ្វាយខេត្តកំពង់ចាម និង៣-វ៉ា កឹមតុន ជាមនុស្សរបស់ គួ រុន ដែលសុទ្ធតែជាមនុស្សមានអំណាចលើមេឃុំទាំងអស់ក្នុងស្រុកព្រៃឈរ រួមទាំង ជ័យ ឥន្ទ ជាចៅហ្វាយស្រុកព្រៃឈរ ដែលមានឥទ្ធិពលលើទាហាន ប៉ូលិសនៅទីនោះទៀតផង។

តែការពិត ហ៊ូ នឹម បានឈ្នះឆ្នោតមណ្ឌលជ្រៃវៀននោះ គឺដោយសារតែមានការជួយជ្រោមជ្រែងពីមេដឹកនាំខ្មែរកុម្មុយនិស្ត ឈ្មោះ កុយ ធួន ហៅឃួន (អតីតសាស្ត្រាចារ្យនៅវិទ្យាល័យកំពង់ចាម) ជាលេខាបក្សភូមិភាគឧត្តរ និងស្រេង (ឈ្មោះដើម ឈូក ឆាង ឬជ ឆាន) ជាអនុលេខាភូមិភាគឧត្តរ បានចាត់តាំងឱ្យសកម្មជន និងយុវជនរបស់ចលនាតស៊ូកុម្មុយនិស្តដើរចែកខិត្តប័ណ្ណ និងជួយឃោសនាបំផុសប្រជារាស្ត្រនៅមណ្ឌលជ្រៃវៀននោះឱ្យបោះឆ្នោតគាំទ្របេក្ខភាពរបស់ ហ៊ូ នឹម។

តែទោះបីយ៉ាងណា ក៏ការបោះឆ្នោតលើកនេះ ពួកស្តាំនិយមបានជាប់ជាតំណាងរាស្ត្រដ៏ច្រើនលើសលុបនៅក្នុងសភាដែរ។

នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៦៦ ភាគីកម្ពុជា បានបើកការចរចាជាមួយភាគីវៀតកុងដើម្បីបង្កើតកិច្ចព្រមព្រៀងស្តីពីបញ្ហាព្រំដែនមួយ តែការចរចានេះ មិនទទួលបានលទ្ធផលអ្វីឡើយ។

ក្រោយប្រកាសលទ្ធផលនៃការបោះឆ្នោត ថ្ងៃទី១១ ខែកញ្ញា នោះមក នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៦៦ រាជរដ្ឋាភិបាលថ្មីមួយបានបង្កើតឡើង ដោយមាន លន់ នល់ ជានាយករដ្ឋមន្ត្រី, ស៊ឹម វ៉ា ជាឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងធម្មការ និងជារដ្ឋមន្ត្រីទំនាក់ទំនងសង្គមកិច្ច-វប្បធម៌-បោសសម្អាត និងយុវជន, ម៉ៅ សាយ ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទំនាក់ទំនងសេដ្ឋកិច្ចហិរញ្ញវត្ថុ -ផែនការការងារ និងផលិតកម្ម, ព្រះអង្គម្ចាស់ នរោត្តម វិរីយ៉ា ជា

ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការបរទេស និងជារដ្ឋមន្ត្រីទំនាក់ទំនងផ្នែកនយោបាយ-ឃោសនាការ-ទេសចរណ៍ និងកិច្ចការពារជាតិ, យ៉ែម សំបូរ ជាទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីយុត្តិធម៌, ឡុង បូរ៉េត ជារដ្ឋមន្ត្រីឧស្សាហកម្ម, ហ៊ីង កន្ធែល ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ, ឧប គឹមអាង ជារដ្ឋមន្ត្រីការពារប្រទេស, អ៊ឹង ម៉ឹង ជារដ្ឋមន្ត្រីឃោសនាការ និងទេសចរណ៍, ផ្លែក ភីន ជារដ្ឋមន្ត្រីសាធារណការ និងទូរគមនាគមន៍, មាស យ៉ង់ ជារដ្ឋមន្ត្រីកសិកម្ម, ពុង ប៉េងចេង ជារដ្ឋមន្ត្រីសាធារណសុខាភិបាល សង្គមកិច្ច និងការងារ, ឌុក រ៉ាស៊ី ជារដ្ឋលេខាធិការផែនការ, ដៀប ឌីណា (ស្រី) ជារដ្ឋលេខាធិការអប់រំ, អ៊ុន ត្រមុច ជារដ្ឋលេខាធិការក្រសួង មហាផ្ទៃ-សន្តិសុខ និងការពារលើផ្ទៃប្រទេស, ញឹក ផុន ជារដ្ឋលេខាធិការពាណិជ្ជកម្ម, ឌី បែលឡុង ជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ-សន្តិសុខ និងការពារ លើផ្ទៃប្រទេស, គុយ ពៅ ជាអនុរដ្ឋលេខាធិការធម្មការ, នូ នៅ (ស្រី) ជាអនុរដ្ឋលេខាធិការទេសចរណ៍ និងព្រំ សេង ជាអនុរដ្ឋលេខាធិការសង្គមកិច្ច និងការងារ។

សមាសភាពគណៈរដ្ឋមន្ត្រីថ្មីនេះ មិនមានឈ្មោះពួកឆ្វេងនិយមទៀតទេ។ ប៉ុន្តែ សម្តេចសីហនុ បានបង្កើតស្ថាប័នថ្មីមួយ ឱ្យឈ្មោះថា បរះរាជរដ្ឋាភិបាល ដើម្បីឱ្យស្ថាប័នថ្មីមួយនេះតាមដាន និងទិទៀនសកម្មភាពរបស់រាជរដ្ឋាភិបាល ដោយក្នុងនោះ ព្រះអង្គបានតែងតាំង ហ៊ូ យន់ ជាសមាជិកបរះរាជរដ្ឋាភិបាល មានតួនាទីជាអ្នកតាមដានត្រួតពិនិត្យក្រសួងមហាផ្ទៃ, ហ៊ូ នឹម ជាសមាជិកបរះរាជរដ្ឋាភិបាល មានតួនាទីជាអ្នកតាមដានត្រួតពិនិត្យក្រសួងពាណិជ្ជ-កម្ម និងខៀវ សំផន, សូ ណៃម, ភោគ ឆាយ ព្រមទាំងពួកឆ្វេងនិយមមួយចំនួនទៀត ជាសមាជិកបរះរាជរដ្ឋាភិបាល មានតួនាទីជាអ្នកតាមដានត្រួតពិនិត្យក្រសួងផ្សេងៗទៀត។

ប៉ុន្តែក្រោយពីខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ធ្វើការរិះគន់វាយប្រហារទៅលើរាជរដ្ឋាភិបាលខ្លាំងពេក ពួកស្តាំនិយមក៏បានដាក់សម្ពាធសម្តេចសីហនុ ឱ្យដក ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់, ភោគ ឆាយ និងសូ ណៃម ជាពួកឆ្វេងនិយមចេញពីស្ថាប័នបរះរាជរដ្ឋាភិបាលនោះវិញ។

ជាមួយគ្នានោះ សម្តេចសីហនុ ក៏បានដក ចៅ សេង ជាពួកឆ្វេងនិយមដែរនោះ

ចេញពីតំណែងនាយកខុទ្ទកាល័យព្រះប្រមុខរដ្ឋរបស់ព្រះអង្គផងដែរ។

ក្រោយពីត្រូវដកចេញពីតំណែងនាយខុទ្ទកាល័យព្រះប្រមុខរដ្ឋ ថៅ សេង បានត្រលប់មកគ្រប់គ្រងកាសែតឡា ដេប៉េស្ហ(La Dépêche)វិញ ហើយបានបន្ថែមឈ្មោះកាសែតឡា ដេប៉េស្ហ(La Dépêche)នេះ ឱ្យទៅជា ឡាដេប៉េស្ហ ឌុយ កាំបូត ( La Dépêche du Cambodge) វិញ។

ក្រោយមក ថៅ សេង បានសរសេរបទវិចារណកថាមួយទៅក្នុងកាសែតនោះ ដោយស្នើសុំឱ្យសម្តេចសីហនុ ធ្វើជានាយករដ្ឋមន្ត្រី ដោយផ្ទាល់តែម្តង។

តែសម្តេចសីហនុ មិនព្រមធ្វើនាយករដ្ឋមន្ត្រីទៀតទេ ដោយព្រះអង្គបានថ្លែងតបវិញថា ការពិតទៅ បើព្រះអង្គឡើងធ្វើនាយករដ្ឋមន្ត្រី តាមការចង់បានរបស់ពួកឆ្វេងនិយមនោះ គឺគ្រាន់តែឱ្យពួកឆ្វេងនិយមមានឱកាសអាចធ្វើសកម្មភាពវិទ្ធង្សនាមកលើសង្គមជាតិបានងាយស្រួលជាងទុកឱ្យ លន់ នល់ ធ្វើជានាយករដ្ឋមន្ត្រីតែប៉ុណ្ណោះ។

ជាមួយគ្នានោះ សម្តេចក៏បានប្រកាសផ្តាំផ្ញើទៅពួកឆ្វេងនិយមដែរថា កុំឱ្យព្រួយបារម្ភអី! ក្នុងរយះពេល១២ឆ្នាំទៀត ពួកអ្នកឯងនឹងបានឡើងកាន់អំណាចហើយ។

ក្រោយពេលសិស្ស៤នាក់ត្រូវអាជ្ញាធរមានសមត្ថកិច្ចចាប់ខ្លួនឃុំទុកនៅប៉ុស្តិ៍ប៉ូលិសពីបទដើរបាចខិត្តប័ណ្ណអំពាវនាវឱ្យ លន់ នល់ ចុះចេញពីតំណែងនាយករដ្ឋមន្ត្រី និងទាមទារឱ្យមានការបោះឆ្នោតជាថ្មីឡើងវិញមក សិស្សនៅតាមវិទ្យាល័យនានានៅទីក្រុងភ្នំពេញ ក៏បាននាំគ្នាធ្វើបាតុកម្មឡោមព័ទ្ធប៉ុស្តិ៍ប៉ូលិស ស្រែកទាមទារឱ្យដោះលែងគ្នាគេទាំង៤នាក់នោះវិញ ប៉ុន្តែដោយសារអាជ្ញាធរមានសមត្ថកិច្ចមិនព្រមធ្វើតាមការទាមទារនេះ ពួកសិស្សជាបាតុករបាននាំគ្នាសម្រុកចូលទៅវាយកម្ទេចកៅអី តុ ទូដាក់ឯកសារ និងសម្ភារៈផ្សេងៗទៀតក្នុងប៉ុស្តិ៍ប៉ូលិស ឱ្យខូចហិនហោចអស់។

ក្រោយពីកាសែតព្រះវិហារ និងកាសែតដំណឹងថ្មី បានចុះផ្សាយអត្ថបទបរិយាយថាប្រទេសកម្ពុជា មិនមែនទទួលបានឯករាជ្យ នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣នោះទេ គឺកងកម្លាំងតស៊ូរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរទៅវិញទេ ដែលជាអ្នកទាមទារឯករាជ្យ មកជូន

ជាតិនៅក្នុងឆ្នាំ១៩៥៤ តាមរយៈសន្និសីទក្រុងហ្សឺណែវមក សម្ដេចសីហនុ ខ្វាល់នឹងការចុះផ្សាយនោះយ៉ាងខ្លាំង ហើយគំរាមប្ដឹងកាសែតទាំង២នេះទៅតុលាការទៀតផង ព្រោះនរណាក៏ដឹងថា ព្រះអង្គជាអ្នកទាមទារឯករាជ្យ មកជូនជាតិមាតុភូមិ នៅថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ នោះដែរ គឺឯករាជ្យនោះពុំមែនបានមកដោយសារសន្និសីទក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ ទេ ហើយក្នុងសន្និសីទនោះ ក៏គេមិនអនុញ្ញាតឱ្យពួកខ្មែរវៀតមិញ ចូលប្រជុំ តាមការទាមទាររបស់ពួកមេដឹកនាំវៀតណាមខាងជើង ទៀតផង។

តែក្រោយមក ព្រះអង្គមិនបានប្ដឹងផ្ដល់អ្វីទេ ដោយព្រះអង្គគ្រាន់តែហៅចាងហ្វាងកាសែតទាំង២នោះ មកតទល់គ្នាជាមួយព្រះអង្គនៅក្នុងសមាជជាតិ ជំនួសការប្ដឹងផ្ដល់នោះទៅវិញ។

ចាងហ្វាងកាសែតទាំង២ បានរងការអាម៉ាស់យ៉ាងខ្លាំងនៅក្នុងអង្គសមាជនោះ ហើយគ្មានអ្វីក្រៅពីនាំគ្នាសុំឱ្យព្រះអង្គព្រះរាជទានទោសដល់ពួកគេឡើយ ហើយព្រះអង្គក៏បានថ្លែងចំអកដល់ពួកគេថា ពួកនេះគ្មានសេចក្ដីក្លាហាន ប្រឈមនឹងការពិតនោះទេ។

មួយថ្ងៃក្រោយមក ចាងហ្វាងកាសែត ទាំង២នេះ ត្រូវជនមិនស្គាល់មុខលបវាយធ្វើបាបនៅតាមផ្លូវ។ បន្ទាប់មកកាសែតព្រះវិហារ និងកាសែតដំណឹងថ្មី ត្រូវរាជរដ្ឋាភិបាល លែងឱ្យបោះពុម្ពផ្សាយបន្តទៀត ហើយអ្នកទទួលខុសត្រូវកាសែតទាំង២នេះ ក៏មិនដឹងបាត់ទៅទីណាដែរ។

នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៦៦ សម្ដេចសីហនុ បានដាក់ឈ្មោះឱ្យពួកឧទ្ទាមកុម្មុយនិស្តខ្មែរ ទៅលាក់ខ្លួននៅក្នុងព្រៃ និងពួកឆ្វេងនិយមនៅក្នុងក្រុងភ្នំពេញថា ជាពួកខ្មែរក្រហម ហើយពាក្យថា ខ្មែរក្រហមនេះ ក៏ត្រូវបានគេចាប់ផ្ដើមហៅរត់មាត់តៗគ្នា ចាប់ពីពេលនោះមក ។

# ១៩២
# ការប្រហារជីវិតខ្មែរសេរីឈ្មោះ សៅ ង៉ុយ



សៅ ង៉ុយ បឺតបារីបណ្ដើរ ស្រែកបណ្ដើរ



សៅ ង៉ុយ ក្រោយត្រូវគ្រាប់កាំភ្លើង

នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៦៦ ខ្មែរសេរីម្នាក់ ឈ្មោះ មធុរ៉ា ត្រូវអាជ្ញាធរចាប់ខ្លួនបាន។ បន្ទាប់មកទៀត នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៦៦ ខ្មែរសេរីម្នាក់ទៀត ឈ្មោះ ចៅ បូរី ដែលជាមនុស្សជិតស្និទ្ធជាមួយ សម សារី និងបានរួមគំនិតគ្នាបង្កើតគណបក្សប្រឆាំងមួយកាលពីឆ្នាំ១៩៥៩។ នៅពេលសម្ដេចសីហនុ រកចាប់ខ្លួន គាត់ក៏នាំគ្នារត់គេចខ្លួនជាមួយ សម សារី ទៅចូលរួមជាមួយចលនាខ្មែរសេរីរបស់ សឺង ង៉ុកថាញ់នោះ ក៏ត្រូវចាប់ខ្លួនបានដែរ។

ប៉ុន្មានថ្ងៃក្រោយមក ខ្មែរសេរីឈ្មោះ មធុរ៉ា និងឈ្មោះ ចៅ បូរី ត្រូវបានដឹកយកទៅបាញ់សម្លាប់ចោលនៅភ្នំត្រពាំងក្រឡឹង ខេត្តកំពង់ស្ពឺ ដូចខ្មែរសេរី ឈ្មោះ ព្រាប អ៊ិន ដែលគេយកទៅចងបាញ់សម្លាប់កាលពីដំបូងគេ នៅដើមឆ្នាំ១៩៦៤ នោះដែរ។

នៅដើមខែឧសភា ឆ្នាំ១៩៦៧ ខ្មែរសេរីម្នាក់ទៀត ឈ្មោះ សៅ ង៉ុយ ដែលជាមិត្តរួម

ថ្នាក់ជាមួយ ឡឹក សំអឿន ហៅផ្កាយព្រឹក កាលសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ កាលពីដើមទសវត្សរ៍ឆ្នាំ១៩៥០ ត្រូវកម្លាំងសមត្ថកិច្ចរបស់សម្តេចសីហនុ ចាប់ខ្លួនបាន។ លុះដល់ថ្ងៃទី ២២ ខែឧសភា ឆ្នាំ១៩៦៧ សៅ ង៉ុយ ត្រូវគេដឹកយកទៅបាញ់ចោលនៅភ្នំត្រពាំងក្រឡឹង ក្នុងខេត្តកំពង់ស្ពឺ ។

បើតាមប្រកពពីនាយទាហានជាន់ខ្ពស់ម្នាក់ឈ្មោះ គឹម ទ្រឿង ធ្វើការនៅការិយាល័យទី២ នៃកងយោធពលខេមរភូមិន្ទ បានឱ្យដឹងថា ក្រោយពេលចាប់ខ្លួនបាន នៅពេលតុលាការសួរថា តើអ្នកឯងជាអ្នកស៊ីឈ្នួលបម្រើអាមេរិកាំង ពិតមែនឬ? សៅ ង៉ុយ ឆ្លើយថា ខ្ញុំរស់ដោយសារអាមេរិកាំង ពិតមែន ប៉ុន្តែខ្ញុំគ្មានបានធ្វើអ្វី បម្រើអាមេរិកាំង ទេ។

នៅទីបំផុត សៅ ង៉ុយ ត្រូវតុលាការសឹកសម្រេចកាត់ទោសប្រហារជីវិត។ នៅយប់មុនថ្ងៃដឹកយកទៅបាញ់សម្លាប់នៅភ្នំត្រពាំងក្រឡឹង ភ្នាក់ងារសមត្ថកិច្ចចូលទៅក្នុងកន្លែងឃុំឃាំង ហើយសួរថា មុននឹងស្លាប់ តើអ្នកឯងចង់បានអ្វី? គាត់ប្រាប់ថា ចង់បានស្រា និងបារី ព្រមទាំងស្រីម្នាក់។ យប់នោះភ្នាក់ងារសមត្ថកិច្ចក៏បានយកស្រា និងបារីមកប្រគល់ឱ្យគាត់ ប៉ុន្តែបានបដិសេធ មិនយកស្រីមកឱ្យតាមសំណូមពររបស់គាត់ទេ។

ព្រឹកឡើង នៅពេលរថយន្តហ្សេអឹមសេ(GMC)គ្របដំបូលជិត មកពីបន្ទាយស្លឹកដឹកគាត់ទៅដល់ទីលានប្រហារជីវិតនៅភ្នំត្រពាំងក្រឡឹង ក្នុងសម្លៀសបំពាក់អាវសឺមីពណ៌សដៃខ្លី ខោជើងវែងព៌ណខ្មៅ ដៃជាប់ខ្នោះ សៅ ង៉ុយ ត្រូវពួកទាហានក្រៀកចុះពីលើរថយន្ត។ គាត់បានដើរយ៉ាងសង្ហាទៅរកបង្គោលសសរដែលគេដាំទុកសម្រាប់ចងផ្អោបគាត់ ដោយមិនចាំបាច់ ឱ្យពួកទាហានបង្ខំ ឬរុញច្រានគាត់បន្តិចឡើយ។

ក្រោយពីមន្ត្រីតុលាការសឹកអានសាលក្រមកាត់ទោសប្រហារជីវិត និងតាអាចារ្យឱ្យធម៌រួចមក ទោះបីពួកទាហានបាននាំគ្នាចងគាត់ផ្អោបនឹងបង្គោល រួចយកក្រណាត់ខ្មៅមករុំគ្រង់ភ្នែកគាត់ ដើម្បីកុំឱ្យមើលឃើញអ្វីៗទាំងអស់ក៏ដោយ ក៏គាត់នៅតែញញឹម ដោយគ្មានតក់ស្លុតបន្តិចឡើយ។

ចុងក្រោយ គាត់សុំបារីមួយដើម ទាហានម្នាក់ក៏បានយកបារីមួយដើមទៅដាក់ឱ្យគាត់

បៀមកន្ទុយបារីនោះ រួចកេះដៃកកេះបញ្ជោះចុងបារីឱ្យគាត់បឺត។ គាត់ប្រឹងយកដៃស្តាំដែលគេចងជាប់នឹងបង្គោលសសរ មកត្បៀតបារីចេញពីបបូរមាត់ ហើយស្រែកថា ជយោ! សម្តេចព្រះនរោត្តម សីហនុ! រួចគាត់បឺតបារីបន្តទៀត រហូតដល់ទាហានពីរជួរនៅពីក្រោយខ្នងគាត់បាញ់កាំភ្លើងស្រោចមកលើខ្នង ទើបសាកសពគាត់ស្រុតចុះមកក្រោម ទាំងជាប់ចំណង។

សៅ ង៉ុយ ជាអតីតសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ។ នៅក្នុងឆ្នាំ១៩៥២ សៅ ង៉ុយ ដែលកំពុងស្នាក់នៅមជ្ឈមណ្ឌលអន្តេវាសិកក្នុងវិទ្យាល័យ ត្រូវមេប៉ូលិសឈ្មោះ ប្រាក់ ប្រព្រឿង ទៅចាប់យកទៅវាយធ្វើទារុណកម្ម ដើម្បីបង្ខំឲ្យឆ្លើយថា សឺន សាន ប្រធានរដ្ឋសភា មកពីគណបក្សប្រជាធិបតេយ្យ ជាអ្នករៀបចំឲ្យសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ ធ្វើបាតុកម្មទាមទារឯករាជ្យនៅមុខមន្ទីររដ្ឋសភា។

ក្នុងអំឡុងពេល សៅ ង៉ុយ ត្រូវកាត់ទោសប្រហារជីវិតនៅក្នុងខែឧសភា ឆ្នាំ១៩៦៧ នោះ សុទ្ធ ប៉ូលីន ចាងហ្វាងការផ្សាយកាសែតនគរធំ និងជាអ្នកនិពន្ធរឿងប្រលោមលោកដ៏ល្បីល្បាញនោះ កំពុងនិពន្ធរឿងប្រលោមលោកមួយមានចំណងជើងថា៖ ចំតិតឥតអាសូរ ។ ដោយសារការដាក់ចំណងជើងអាក្រក់ស្តាប់នេះ នុត ឈឿម ចាងហ្វាងការផ្សាយកាសែតសុជីវធម៌ បានសរសេររិះគន់ថា សុទ្ធ ប៉ូលីន ជាអ្នកនិពន្ធខ្វះការអប់រំ គ្មានក្រមសីលធម៌ និងមានខួរក្បាលជាពួកបរទេស។

ជាមួយគ្នានោះ រដ្ឋមន្ត្រីក្រសួងឃោសនាការ ជាស្ត្រីភេទ ឈ្មោះ ជិន រ៉ែន បានប្រកាសតាមវិទ្យុជាតិក្នុងមួយថ្ងៃបីដង ក្នុងរយៈពេល២ថ្ងៃជាប់ៗគ្នាថា បុគ្គលទាំងឡាយណា ដែលភ្ជាក់ងារមានសមត្ថកិច្ចទៅទាន់ពេលកំពុងអានសៀវភៅរឿងចំតិត ឥតអាសូរនេះ នឹងត្រូវកោះហៅទៅសាលាដំបូង។

សៅ ង៉ុយ ជាមនុស្សមានចរិតសុភាពរាបសា រូបរាងសង្ហាមាំមួន និងក្លាហាន មិនចេះតក់ស្លុតនឹងហេតុការណ៍គ្រោះថ្នាក់ផ្សេងៗ។ គាត់តែម្នាក់ឯងអាចប្រយុទ្ធទប់ទល់នឹងគូជម្លោះ ៥នាក់។ កាលនៅរៀនវិទ្យាល័យព្រះស៊ីសុវត្ថិ ដោយដៃទទេ គាត់បានប្រយុទ្ធទប់ទល់ជាមួយពួកបង្ករឿងមកពីសាលាន័រម៉ាល់( Normal ) ដែលមានគ្នាច្រើនមាឌធំៗប្រដាប់ដោយ



**ការប្រហារជីវិតខ្មែរសេរីឈ្មោះ មធុរ៉ា និងចៅ ម៉ូរី**

កាំបិតពូថៅ ឱ្យរត់ទៅវិញបាត់អស់។

បើនៅក្នុងភូមិណាល្បីថា មានចោរលួចចោរប្លន់ សៅ ង៉ុយ ចូលចិត្តជិះកង់តែម្នាក់ ដោយគ្មានខ្លាចញញើតអ្វីបន្តិចឡើយ។ ប៉ុន្តែ ក្រោយមក នៅជ្រោយអំពិល គាត់ជ្រុលដៃវាយមនុស្សស្លាប់ម្នាក់ ដោយគ្មាននរណាម្នាក់ដឹងឡើយ ហើយគាត់បានលាក់រឿងអាថ៌កំបាំងនេះ មិនឱ្យនរណាដឹងឡើយ។

ក្រោយបញ្ចប់ការសិក្សា សៅ ង៉ុយ បានប្រលងជាប់ជាឧត្តមមន្ត្រី។ បន្ទាប់មក គាត់បានស្ដីដណ្ដឹងកូនក្រមុំចៅហ្វាយស្រុកម្នាក់ ឈ្មោះ ដាលីន មានរូបសម្រស់ស្រស់ប្រិមប្រិយ រៀបការជាប្រពន្ធ។

ដោយសារស្រលាញ់ និងទុកចិត្តប្រពន្ធខ្លាំងពេក មិនដឹងជាបាបកម្មអ្វី នៅសុខៗ បណ្ដាលឱ្យគាត់យកអាថ៌កំបាំងរឿងជ្រុលដៃ វាយមនុស្សម្នាក់ស្លាប់ នៅជ្រោយអំពិលនោះ ប្រាប់ប្រពន្ធឱ្យបានដឹងដែរ។

ក្រោយពេលបានគ្នាជាប្ដីប្រពន្ធ មិនបានប៉ុន្មានឆ្នាំផង ដោយសារ សៅ ង៉ុយ ជាមន្ត្រីស្អាតស្អំមិនសូវចេះរកស៊ីក្រៅ សង្ឃឹមតែលើប្រាក់ខែ បណ្ដាលឲ្យមានការរកាំរកូសជាមួយគ្រួសារខាងប្រពន្ធ រហូតឪពុកម្ដាយក្មេកខឹងសម្បាខ្លាំង ក៏បានយករឿងអាថ៌កំបាំង ដែល



**ការប្រហារជីវិតខ្មែរសេរីឈ្មោះ ចៅ ស៊ី និង ង៉ែត ងិន**

គាត់ជ្រុលដៃវាយមនុស្សម្នាក់នៅជ្រោយអំពិលនោះ ទៅរាយការណ៍ប្រាប់ភ្នាក់ងារសមត្ថកិច្ច ដើម្បីឱ្យចាត់ការតាមច្បាប់។

ពេលនោះ គាត់ដឹងខ្លួនទាន់ ក៏រត់ទៅសំងំលាក់ខ្លួននៅប្រទេសឡាវ ។ ចំណែក នាង ដាលីន ក្រោយមកបានក្លាយទៅជាភរិយារបស់ សុខ ធុង ជាមន្ត្រីជាន់ខ្ពស់ម្នាក់។

ក្នុងឆ្នាំ១៩៦៤ ទីក្រុងវៀងចន្ទ គាត់បានជួបមិត្តរួមថ្នាក់ម្នាក់ធ្លាប់រៀនជាមួយគ្នាតាំងពីថ្នាក់ទី៦ រហូតដល់បញ្ចប់ការសិក្សានៅវិទ្យាល័យស៊ីសុវត្ថិ ក្រុងភ្នំពេញ កាលពីឆ្នាំ១៩៥១ ឈ្មោះ ឡឹក សំអឿន ជាមេខ្មែរសេរី កំពុងដើរប្រមូលបងប្អូនខ្មែរនៅក្នុងប្រទេសឡាវ ឱ្យចូលរួមក្នុងចលនាតស៊ូខ្មែរសេរី ជាថ្មីម្តងទៀត។ គាត់ក៏បានស្ម័គ្រចិត្តចូលរួមតស៊ូជាមួយចលនាខ្មែរសេរីនោះដែរ ដោយដំបូង គាត់មានតួនាទី ជាអ្នកទទួលខុសត្រូវតាក់តែងអត្ថបទសម្រាប់ចាក់ផ្សាយកម្មវិធីរបស់វិទ្យុខ្មែរសេរី នៅក្នុងប្រទេសថៃ ហើយត្រូវសមត្ថកិច្ចចាប់ខ្លួនបាន ពេលគាត់ឆ្លងដែនចូលក្នុងទឹកដីខ្មែរ នៅដើមខែឧសភា ឆ្នាំ១៩៦៧។

ក្រោយមក ពួកខ្មែរសេរីមួយចំនួនទៀត ដូចជា ចៅស៊ី, ង៉ែត ងិន, ឈឹម អែម ,ថាច់ ញឹង... ក៏ត្រូវតុលាការសឹករបស់សម្តេចសីហនុ កាត់ទោសយកទៅប្រហារជីវិត នៅភ្នំត្រពាំងក្រឡឹងនោះ ជាបន្តបន្ទាប់។

# ១៩៣
# កសិករនៅស្រុកសំឡូត នាំគ្នាបះបោរ
# ប្រឆាំងនឹងនាយករដ្ឋមន្ត្រី លន់ នល់



**លន់ នល់ នាយករដ្ឋមន្ត្រី ពីខែតុលា**
**ឆ្នាំ១៩៦៦ ដល់ខែមេសា ឆ្នាំ១៩៦៧**

នៅថ្ងៃទី២៦ ខែវិច្ឆិកា ដល់ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៦៦ ប្រទេសកម្ពុជា បានធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាហ្កាណេហ្វូ(Ganefo) អាស៊ី លើកទី១ នៅពហុកីឡដ្ឋានជាតិអូឡាំ-ពិក ដោយមានកីឡាករ-កីឡាការិនី ប្រមាណ២០០០នាក់ មកពីប្រទេសចំនួន១៧ បានចូលរួម ជាអាទិ៍គឺប្រទេសកម្ពុជា ជាម្ចាស់ផ្ទះ ស្រីលង្កា ចិនប្រជាមានិត ឥណ្ឌូនេស៊ី អ៊ីរ៉ាក់ ជប៉ុន កូរ៉េខាងជើង លាវ លីបង់ ម៉ុងហ្គោលី សិង្ហបុរី ស៊ីរី វៀតណាមខាងជើង យេម៉ែន

ជាដើម។

ក្រោយពីបញ្ចប់ ការប្រកួតកីឡាហ្គាណេហ្វូ (Ganefo) អាស៊ី លើកទី១ នោះភ្លាម សម្តេចសីហនុ បានយាងទៅប្រទេសបារាំង ដើម្បីព្យាបាលព្រះរោគអស់រយៈពេល២ខែ។ ពេលនោះដែរ បញ្ហារត់ពន្ធអង្ករយកទៅលក់ឱ្យកងទ័ពវៀតកុង កាន់តែធ្វើឱ្យសេដ្ឋកិច្ចធ្លាក់ចុះដុនដាបទៅៗ។ ថវិកាជាតិត្រូវបាត់បង់មួយផ្នែកធំ ហើយអង្ករចេះតែឡើងថ្លៃទៅៗ។

ការរត់ពន្ធអង្ករទៅលក់ឱ្យពួកវៀតកុងនេះ មិនមែនមានតែពួកពាណិជ្ជកររទេ សូម្បីតែពួកមេទាហានធំៗមួយចំនួន ក៏ឆ្លៀតឱកាសរកស៊ីរត់ពន្ធអង្ករនេះដែរ។

ដើម្បីស្តារសេដ្ឋកិច្ចជាតិឡើងវិញ នាយករដ្ឋមន្ត្រីលន់ នល់ បានបង្កើតលេខាធិការដ្ឋានមួយរបស់គាត់នៅខេត្តបាត់ដំបង ជាខេត្តដែលគាត់ធ្លាប់ធ្វើជាចៅហ្វាយខេត្តនេះកាលពីឆ្នាំ ១៩៤៦ ដល់ឆ្នាំ១៩៥៣។

គាត់បានប្រើកម្លាំងកងទ័ពដ៏ច្រើនសន្ធឹកសន្ធាប់ ដើម្បីបើកយុទ្ធនាការបង្ខំឱ្យប្រជាកសិករ លក់ស្រូវឱ្យរដ្ឋ ក្នុងតម្លៃថោកជាងតម្លៃនៅទីផ្សារងងឹត ដល់ទៅ១ភាគ៣ឯណោះ។

ជាមួយគ្នានោះ គាត់ក៏បានដក ជុំ ម៉ែម ពីតំណែងនាយកទីចាត់ការគយ និងរដ្ឋាករ ដែលជាមនុស្សរបស់ព្រះរាជដំណាក់ចំការមន ហើយដាក់ឧត្តមសេនីយ៍ សូ ខាំខូយ ដែលល្បីថាជាមន្ត្រីស្អាតស្អំ ឱ្យមកកាន់ដំណែងជានាយកទីចាត់ការគយ និងរដ្ឋាករ ជំនួសវិញ។

ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៧ កងទ័ពអាមេរិក និងវៀតណាមខាងត្បូង បានចូលមកបណ្តេញប្រជាកសិករខ្មែរ នៅច្រកក្រាញ់ ក្នុងខេត្តកំពង់ចាម ឱ្យចេញពីភូមិ និងផ្ទះសម្បែង រួចហើយពួកគេបានបោះទីតាំងឈរជើងនៅទីនោះ រហូតដល់ថ្ងៃទី០៤ ខែមីនា ទើបដកថយចូលទៅក្នុងទឹកដីវៀតណាមខាងត្បូង វិញ។

ថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៦៧ សម្តេចសីហនុ យាងត្រលប់មកពីប្រទេសបារាំងវិញ ព្រះអង្គមានបន្ទូលថា យុទ្ធនាការប្រមូលទិញស្រូវរបស់នាយករដ្ឋមន្ត្រី លន់ នល់ នោះ គឺធ្វើឡើងតាមការណែនាំរបស់ព្រះអង្គ ក្នុងទិសដៅដើម្បីបំបាត់ពួកឈ្មួញកណ្តាល។ សំខាន់ជាងនេះទៅទៀត គឺដើម្បីគាបសង្កត់ពួកឆ្វេងនិយម កុំឱ្យធ្វើវិទ្ធង្សនា និងវិច្ឆេទកម្មមកលើ

សង្គមជាតិផងដែរ និងឱ្យ លន់ នល់ បង្កើតគណៈកម្មការប្រមូលទិញស្រូវនៅតាមភូមិឃុំ និងស្រុកនានាផងដែរ។

លុះបង្កើតគណៈកម្មការប្រមូលទិញស្រូវនៅតាមភូមិឃុំ និងស្រុកនេះ បានហើយ គណៈកម្មការទាំងអស់នោះ ក៏មានតួនាទីជាតំណាងឱ្យចលនាសង្គមរាស្ត្រនិយមនៅតាមភូមិ ឃុំ និងស្រុកទាំងអស់នោះ ដើម្បីដឹកនាំធ្វើការទប់ស្កាត់ មិនឱ្យពួកឆ្វេងនិយមធ្វើសកម្មភាពវិទ្ធង្សនា និងធ្វើវិច្ឆេទកម្មមកលើសង្គមជាតិ ដោយគ្មានទោសពៃរ៍ ដូចពេលមុនៗទៀតនោះឡើយ។

ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៦៧ ពួកខ្មែរក្រហមបានបំផុសឱ្យមានបាតុកម្មមួយនៅក្រុងភ្នំពេញ ដោយមានសិស្សនិស្សិត និងព្រះសង្ឃជាច្រើនចូលរួមផង ទាមទារឱ្យរាជរដ្ឋាភិបាលដកកងទ័ពចេញពីតំបន់សំឡូត ដោយចោទប្រកាន់កងទ័ពដែលបោះទីតាំងនៅទីនោះថា បានធ្វើបាប និងសម្លាប់អ្នកភូមិគ្មានត្រាប្រណី និងតវ៉ាទាមទារឱ្យ លន់ នល់ ចុះចេញពីតំណែងនាយករដ្ឋមន្ត្រី និងសូ ខាំខូយ ចុះចេញពីតំណែងនាយកទីចាត់ការគយ និងរដ្ឋាករ។

មិនតែប៉ុណ្ណោះ ពួកបាតុករក៏បាននាំគ្នាទាមទារឱ្យមានការបោះឆ្នោតឡើងវិញ ហើយការបោះឆ្នោតវិញនោះ ពួកគេស្នើសុំឱ្យសម្តេចសីហនុ ជាអ្នកជ្រើសរើសបេក្ខជនមកឈរឈ្មោះនៅតាមមណ្ឌលបោះឆ្នោតនីមួយៗ ដូចកាលបោះឆ្នោតឆ្នាំ១៩៥៨ និងឆ្នាំ១៩៦២។

ក្នុងការធ្វើបាតុកម្មនោះ ខ្មែរក្រហមបានបំផុសឱ្យពួកបាតុករស្រែកបរិហារថា លន់ នល់ ជាអាយ៉ងរបស់ពួកចក្រពត្តិអាមេរិក ហើយពួកគេបានស្នើសុំសម្តេចសីហនុ បំពាក់អាវុធឱ្យជនជាតិខ្មែរ ដែលរស់នៅតាមបណ្តោយព្រំដែនខាងកើត ដើម្បីប្រឆាំងនឹងការឈ្លានពានរបស់ចក្រពត្តិអាមេរិក និងបរិវារក្រុងព្រៃនគរ ផងដែរ។

ប៉ុន្តែ ទោះបីយ៉ាងណា សម្តេចសីហនុ មិនព្រមដកកងទ័ពចេញពីតំបន់សំឡូត តាមការទាមទាររបស់ពួកបាតុករនោះទេ។

ក្រោយបាតុកម្មនោះ សម្តេចសីហនុ មានបន្ទូលជាសាធារណៈនៅក្នុងការជួបជុំប្រជា-រាស្ត្រដ៏ធំមួយ ជាសារផ្ញើទៅកាន់ពួកខ្មែរក្រហមថា៖ "សូមអស់លោកក្រហម (ពួកខ្មែរក្រហម)

កុំភ្លេចថា ពីអតីតកាល ពួកអស់លោកជំពាក់គុណ សីហនុ ច្រើនណាស់ ហើយនៅពេលបច្ចុប្បន្ន ក៏ដោយសារ សីហនុនេះដែរ ដែលពួកអស់លោកអាចធ្វើសកម្មភាពប្រឆាំង ដោយពុំភ័យខ្លាចការបាត់បង់អាយុជីវិត"។

សម្តេចសីហនុ មានបន្ទូលបញ្ជាក់ថា៖ "នេះគ្រាន់តែជាការរម្លឹកប៉ុណ្ណោះ គឺមិនមែនជាការគំរាមកំហែងអ្វីទេ តែចាំបាច់ខ្ញុំសូមប្រាប់អស់លោកថា នៅប្រទេសឥណ្ឌូនេស៊ី ការបោសសម្អាតពួកកុម្មុយនិស្ត ៧០០.០០០ នាក់នោះ គ្មានអ្វីលំបាកឡើយ ហើយខ្ញុំសូមបញ្ជាក់ថាចំពោះខ្ញុំ គឺខ្ញុំមិនចាំបាច់ចេញបញ្ជាទេ គឺគ្រាន់តែនៅស្ងៀមប៉ុណ្ណោះ ក៏ក្នុងរយៈពេលតែមួយព្រឹបប៉ុណ្ណោះ ពួកអស់លោក ដែលមានគ្នាតែប៉ុន្មានរយនាក់នោះ នឹងវិនាសសូន្យជាមិនខាន"។ ចប់បន្ទូលខាងលើនេះភ្លាម ស្នូរទះដៃរបស់ប្រជារាស្ត្រ ក៏លាន់ឮយ៉ាងខ្លាំងដើម្បីសម្តែងការគាំទ្រ។

ព្រះអង្គបានបន្ថែមថា "យើងមិនខ្វះទេ ស៊ូហារតូ និងណាស៊ូសឹន។ ពីរនាក់នេះ ជាមេដឹកនាំសេរីនិយមរបស់ប្រទេសឥណ្ឌូនេស៊ី ដែលស្អប់ខ្ពើមលទ្ធិកុម្មុយនិស្តជាទីបំផុត និងបានសម្លាប់ពួកកុម្មុយនិស្តនៅប្រទេសឥណ្ឌូនេស៊ី អស់៧០០.០០០នាក់ កាលពីអំឡុងឆ្នាំ១៩៥៦ ដល់១៩៦៦)"។

ចុងបញ្ចប់ ព្រះអង្គបានព្រលយបន្ទូលថា៖ "ខ្ញុំសូមជម្រាបអស់លោកទៀតថា ខ្ញុំក៏មានវិធានការក្តៅដែរ ដើម្បីបំបាត់ការស្រមើស្រមៃរបស់ពួកអស់លោក ដោយនៅពេលណាមួយ ខ្ញុំនឹងចាកចេញពីប្រទេសជាបណ្តោះអាសន្នមួយរយៈ ដើម្បីទុកឱ្យពួកអស់លោកប្រឈមមុខនឹង ស៊ូ ហារតូ និងណាស៊ូសឹន របស់កម្ពុជាយើង...។

នៅក្នុងខែមីនា ឆ្នាំ១៩៦៧ ខិត្តប័ណ្ណរបស់ខ្មែរក្រហមជាច្រើន ត្រូវបានគេបាចនៅក្នុងខេត្តបាត់ដំបង។ ខ្លឹមសារក្នុងខិត្តប័ណ្ណនោះ បានចោទប្រកាន់សម្តេចសីហនុ, ឧត្តមសេនីយ៍ លន់ នល់ និងឧត្តមសេនីយ៍ ញឹក ជូឡុង ថា សុទ្ធតែជាជនក្បត់។

ក្រោយមានការបាចខិត្តប័ណ្ណនៅក្នុងខេត្តបាត់ដំបងនោះ សម្តេចសីហនុ ក៏បានថ្លែងជាសាធារណៈថា ពួកខ្មែរក្រហមបានយកព្រះនាមព្រះអង្គទៅសម្តែងឆាកល្ខោនជាតួក្បត់




**ស៊ូហារតូ បញ្ជាឲ្យចាប់ពួកកុម្មុយនិស្តឥណ្ឌូនេស៊ី យកទៅសម្លាប់**

និងបានតែងបទចម្រៀងទៅតាមអ្វី ដែលពួកគេចោទប្រកាន់ថា ជាជនក្បត់នោះទៀតផង។

នៅខេត្តកំពង់ស្ពឺ ពួកឧទ្ទាមខ្មែរក្រហមបានដើរឃោសនាប្រាប់ប្រជារាស្ត្រថា ត្រូវតែទម្លាក់សីហនុ ចេញពីអំណាច ព្រោះពេលប្រទេសជាតិមានវិបត្តិសេដ្ឋកិច្ច សីហនុ មិនគិតដោះស្រាយ បែរជាទៅដើរកម្សាន្តសប្បាយនៅប្រទេសបារាំង ទៅវិញ។

កាលពីឆ្នាំ១៩៦៥ កូនសៀវភៅតូចៗរបស់ពួកខ្មែរក្រហម ដែលមានឈ្មោះថា រស្មីក្រហម និងទង់បដិវត្តន៍ បានផ្សព្វផ្សាយលទ្ធិកុម្មុយនិស្ត និងរិះគន់សម្តេចសីហនុ ខ្លះៗដែរ តែមិនសូវខ្លាំងក្លាប៉ុន្មានទេ។

កូនសៀវភៅ រស្មីក្រហម និងទង់បដិវត្តន៍ ព្រមទាំងខិត្តប័ណ្ណទាំងអស់នោះ ត្រូវបានគេរាយការណ៍មកថា ពួកមន្ត្រីស្ថានទូតចិន នៅក្រុងភ្នំពេញ ជាអ្នកជួយលួចបោះពុម្ពឱ្យ។

លុះមកដល់ ខែមេសា ឆ្នាំ១៩៦៧ នៅខេត្តកំពង់ស្ពឺ ខេត្តបាត់ដំបង រហូតដល់ខេត្តកំពង់ចាម និងខេត្តកំពង់ធំ គេឃើញមានការបាចខិត្តប័ណ្ណ និងការប្រជុំសម្ងាត់ផ្សេងៗរបស់ពួកមេខ្មែរក្រហម ជាបន្តបន្ទាប់។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦៧ នៅភូមិបុស ស្រុកពញាក្រែក ខេត្តកំពង់ចាម មេខ្មែរក្រហមនៅភូមិភាគបូព៌ា បានប្រជុំកម្មាភិបាលយោធា និងកម្មាភិបាលឃោសនារបស់ពួកគេ ដោយបានលើកឡើងថា ពីមុនយើងធ្វើការតស៊ូខាងនយោបាយប៉ុណ្ណោះ គឺពុំប្រើប្រាស់អាវុធ

ទេ។ ឥឡូវនេះ យើងត្រូវកាន់កាំភ្លើង ដើម្បីធ្វើការតស៊ូដោយអាវុធ រួមផ្សំជាមួយនឹងការតស៊ូនយោបាយ តែយើងវាយប្រហារទៅលើទីតាំងរបស់ពួកខ្មាំងណា ដែលមានគ្នាតិច ឬប៉ុស្តិ៍តូចៗ និងពួនស្ទាក់ធ្វើការវាយប្រហារនៅតាមផ្លូវស្ងាត់ៗប៉ុណ្ណោះ។

ក្រោយពីមានអង្គប្រជុំនេះមក កងទ័ពរបស់រាជរដ្ឋាភិបាល ក៏បានបើកយុទ្ធនាការឡោមព័ទ្ធភូមិបុស នោះ ហើយបានសម្លាប់ពួកខ្មែរក្រហម អស់ចំនួន២៦នាក់ ក្នុងនោះមានខ្លះត្រូវកាត់ក និងវះទ្រូងរូងយកថ្លើម។

នៅស្រុកត្បូងឃ្មុំ ពួកមេខ្មែរក្រហមខ្លះ ត្រូវកងទ័ពរបស់រាជរដ្ឋាភិបាលបាញ់សម្លាប់ និងខ្លះទៀតត្រូវចាប់ដាក់គុក ហើយអ្នកភូមិរាប់រយនាក់ទៀតដែលជាប់ពាក់ព័ន្ធជាមួយខ្មែរក្រហម បាននាំគ្នារត់ចោលផ្ទះសម្បែង ទៅរស់នៅលាក់ខ្លួននៅក្នុងព្រៃចម្ការកៅស៊ូ។

នៅភូមិញ្ញៅ ក្រោយពីកងទ័ពរាជរដ្ឋាភិបាលបាញ់សម្លាប់ពួកខ្មែរក្រហម ៦នាក់មក អ្នកភូមិប្រមាណ២០០នាក់ បានរត់ទៅពួនសម្ងំនៅក្នុងព្រៃចម្ការកៅស៊ូ ដោយមានមេខ្មែរក្រហមម្នាក់ នៅស្រុកមេមត់ ជាអតីតអ្នកតស៊ូតាំងពីសម័យអាណានិគមបារាំង ហើយបានរត់ចូលព្រៃតស៊ូជាថ្មីម្តងទៀត កាលពីឆ្នាំ១៩៦៤ ជាអ្នកដឹកនាំ។

នៅក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ ពួកខ្មែរក្រហម២១នាក់ ត្រូវកងទ័ពរាជរដ្ឋាភិបាលចាប់ខ្លួននៅក្នុងថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៦៧ ពីបទជាប់ពាក់ព័ន្ធការបាចខិត្តប័ណ្ណដែលសរសេរថា សីហនុ និងលន់ នល់ ជាមនុស្ស ដែលមានលក្ខណៈដូចភ្លើងចំបើង បានលក់ប្រទេសជាតិទៅឱ្យពួកចក្រពត្តិអាមេរិក ហើយថា ការបង្កើតឱ្យមានអង្គការរាជសហករណ៍ (OROC)របស់សម្តេចសីហនុ នោះ គឺគ្រាន់តែជាការបោកប្រាស់ប្រជាជនតែប៉ុណ្ណោះ។

ពួកមេខ្មែរក្រហមស្រុកបារាយណ៍ បានអំពាវនាវឱ្យអ្នកភូមិ ចូលរួមតស៊ូជាមួយពួកគេ ដោយសន្យាថា ក្រោយពីទទួលបានជ័យជម្នះ ពួកគេនឹងផ្តល់តួនាទីមុខតំណែងឱ្យស័ក្តិសមនឹងវីរភាពនៃការតស៊ូនោះ។ ជាមួយគ្នានោះ ពួកគេសន្យាថា នឹងលុបបំបាត់ចោលការទារពន្ធពីប្រជាជនទៀតផង។

ក្រោយការចាប់ខ្លួនមេខ្មែរក្រហម២នាក់ ឈ្មោះ ម៉ក់ សឿន និងនេត ប៉ុន ព្រមទាំង

សកម្មជន១៩នាក់នៅស្រុកបារាយណ៍ មិនដឹងថា ត្រូវគេបញ្ជូនទៅដាក់ពន្ធនាគារនៅទីណា ហើយក៏មិនដឹងថា ស្លាប់ ឬរស់ដែរ គឺបាត់ដំណឹងសូន្យឈឹង។

ដោយឡែក នៅភូមិក្រវ៉ាំ ក្នុងស្រុកបារាយណ៍នោះដែរ កងទ័ពរាជរដ្ឋាភិបាលបានចាប់អ្នកភូមិប្រមាណ៣០នាក់ ពីបទលួចទាក់ទងជាមួយពួកខ្មែរក្រហម។

នៅចុងខែមីនា ឆ្នាំ១៩៦៧ ដោយមានការខឹងសម្បានឹងកាសែតខ្មែរឯករាជ្យ របស់ ស៊ឹម វ៉ា ដែលបានសរសេររិះគន់ប្រមាថដល់បដិវត្តន៍វប្បធម៌ នៅប្រទេសចិន ពួកខ្មែរក្រហមបានបំផុសយុវកកមួយក្រុម ដែលសុទ្ធតែជាអ្នកជឿជាក់លើទ្រឹស្តីកុម្មុយនិស្តម៉ៅនិយម ឱ្យធ្វើបាតុកម្មវាយបំផ្លាញទីចាត់ការកាសែតខ្មែរឯករាជ្យ ព្រមទាំងបំផ្លាញពុទ្ធបដិមាមួយអង្គនៅក្នុងស្នាក់ការកាសែតនោះ។ តាមការប៉ាន់ស្មាននៃការខូចខាតរបស់កាសែតខ្មែរឯករាជ្យ នាពេលនោះ គឺមានតម្លៃជាទឹកប្រាក់ប្រហែល១លានរៀល។

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៦៧ ម៉ៅ សាយ ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទំនាក់-ទំនងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ផែនការ ការងារ និងផលិតកម្ម និងឌុក រ៉ាស៊ី រដ្ឋលេខាធិការផែនការ ត្រូវរដ្ឋសភាកោះហៅទៅសួរដេញដោល និងបោះឆ្នោតទម្លាក់ចេញពីតំណែង។

ក្រោយពីការវាយបំផ្លាញទីស្នាក់ការកាសែតខ្មែរឯករាជ្យនោះមក សិស្សនៅតាមសាលាឯកជនរបស់ជនជាតិចិន ផ្សេងៗទៀត ក៏នាំគ្នាបះបោរដែរ។

ពេលនោះ កូនសៀវភៅក្រហមដែលសរសេរពីទ្រឹស្តីកុម្មុយនិស្តរបស់ម៉ៅ សេទុង ត្រូវបានកម្លាំងបង្កប់ខ្មែរក្រហមដើរចែកផ្សព្វផ្សាយនៅគ្រប់ទិសទី ហើយសមាគមមិត្តភាពកម្ពុជា-ចិន ដែលដឹកនាំដោយ ហ៊ូ នឹម, សូ ណែម និងភោគ ឆាយ ក៏បានបំផុសឱ្យមានចលនាបះបោរនៅកន្លែងផ្សេងៗទៀត យ៉ាងសកម្មបំផុត។

តែទោះបីយ៉ាងណា ក៏ពួកមេដឹកនាំខ្មែរក្រហម មើលឃើញពីតម្លៃរបស់សម្តេចសីហនុ ដែលព្រះអង្គបានដំឡើងទំនាក់ទំនងការទូតដល់ថ្នាក់ឯកអគ្គរាជទូត និងឯកអគ្គរដ្ឋទូតជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង) ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៦៧ ខ្លះៗដែរ។

## របត់នយោបាយ

នៅក្នុងឆ្នាំ១៩៦៦ អាជ្ញាធរខេត្តបាត់ដំបង មានគម្រោងកសាងរោងចក្រផលិតស្ករ.ស មួយ នៅកំពង់គល់ នៅឃុំចែងមានជ័យ ស្រុកបាណន់។ តែដើម្បីកសាងរោងចក្រនោះ អាជ្ញាធរខេត្តបានដកហូតយកដីពីប្រជារាស្ត្រនៅក្នុងតំបន់នោះ ដោយមិនផ្ដល់សំណងឱ្យបានសមរម្យទេឡើយ។

ឆ្លៀតឱកាសនោះដែរ ពួកខ្មែរក្រហមដែលមានអាវុធប្រមាណ២០០ដើម លាក់ទុកនៅក្នុងព្រៃនៅភ្នំវាយចាប ក៏បានបំផុសឱ្យអ្នកស្រុកនៅទីនោះ ងើបឡើងបះបោរប្រឆាំងនឹងអាជ្ញាធរវិញ។

ដើម្បីទប់ទល់នឹងការបះបោរនោះ នាយករដ្ឋមន្ត្រី លន់ នល់ ក៏បានបញ្ជាឱ្យវរសេនីយ៍-ទោ ឆាយ ឡាយ ដឹកនាំកងទ័ព និងអ៊ុំ ម៉ាន្នូរិន ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស ដឹកនាំកម្លាំងប៉ូលិស ជាច្រើនរយនាក់ទៅបង្ក្រាបការបះបោរនោះ។

ពួកទាហាន និងប៉ូលិស បានទៅដុតផ្ទះសម្បែង និងបាញ់សម្លាប់អ្នកភូមិអស់ជាច្រើន ធ្វើឱ្យអ្នកភូមិមានការឈឺចាប់ នាំគ្នារត់ចូលព្រៃទៅចូលរួមជាមួយពួកខ្មែរក្រហម ដែលនៅភ្នំវាយចាបនោះ ជាច្រើននាក់។

ប៉ុន្មានខែក្រោយមក រាជរដ្ឋាភិបាល លន់ នល់ បើកយុទ្ធនាការប្រមូលទិញស្រូវ ដោយឱ្យតម្លៃទាបពេក ប្រជាកសិករមិនព្រមលក់ឱ្យ ក៏កើតមានការបះបោរប្រឆាំងតបតវិញជាថ្មីម្ដងទៀត។

នៅថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៦៧ ប្រជារាស្ត្រនៅក្នុងស្រុកសំឡូត ប្រមាណ២០០នាក់ បាននាំគ្នាធ្វើបាតុកម្ម ដោយមានអ្នកខ្លះកាន់បដាសរសេរពាក្យស្លោកផ្សេងៗ ក្នុងន័យប្រឆាំងនឹងរាជរដ្ឋាភិបាល។

សកម្មភាពបាតុកម្មនេះ បានរាលដាលទៅជាសកម្មភាពកុបកម្ម ដោយបានសម្លាប់ទាហានរាជរដ្ឋាភិបាល ២នាក់នៅនឹងកន្លែង និងដណ្ដើមយកកាំភ្លើងបាន២ដើម។

នៅថ្ងៃបន្ទាប់មកទៀត ការងើបបះបោរក៏បានរីករាលដាលពីភូមិមួយ ទៅភូមិមួយទៀត

ធ្វើឱ្យស្ថានការណ៍កាន់តែរីកវរធ្ងន់ធ្ងរឡើងៗ។

ភ្លាមៗនោះ រាជរដ្ឋាភិបាលបានបញ្ជូនកម្លាំងទាហាន និងប៉ូលិសជាច្រើនពាន់នាក់ ទៅបង្ក្រាបការបះបោរនោះ ហើយអ្នកបះបោរប្រមាណ១០០នាក់ ដែលសង្ស័យថា ជាពួកខ្មែរក្រហមលួចជ្រៀតចូលមកធ្វើសកម្មភាពបះបោរនោះ ត្រូវចាប់ខ្លួនយកមកធ្វើទារុណកម្ម និងសួរចម្លើយ។

ចំណែកអ្នកស្រុកប្រមាណ១០០នាក់ ផ្សេងទៀត បាននាំគ្នារត់គេចខ្លួនចូលព្រៃក្រោយ អ្នកស្រុក១៩នាក់ ត្រូវពួកទាហាននិងប៉ូលិសបាញ់សម្លាប់។

# ១៩៤
# មេដឹកនាំចិន និងវៀតណាម
# ពិភាក្សាគ្នាពីបញ្ហាប្រទេសកម្ពុជា




**នាយករដ្ឋមន្ត្រី ជូ អេនឡាយ និងនាយករដ្ឋមន្ត្រីវៀតណាមខាងជើង ផាម វ៉ាន់ដុង**

នៅព្រឹកថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៦៧ នៅទីក្រុងប៉េកាំង នាយករដ្ឋមន្ត្រី ជូ អេនឡាយ និងរដ្ឋមន្ត្រីការបរទេស ចេន យី បានជួបពិភាក្សាជាមួយនាយករដ្ឋមន្ត្រីវៀតណាមខាងជើង ផាម វ៉ាន់ដុង និងរដ្ឋមន្ត្រីការពារជាតិ វ៉ ង្វៀនយ៉ាប់។

ក្រៅពីពិភាក្សាគ្នាពីបញ្ហាប្រទេសចិន និងវៀតណាម ព្រមទាំងស្ថានការណ៍នយោបាយនៅលើពិភពលោកកាលពីអតីតកាលមក មេដឹកនាំប្រទេសទាំង២នេះ ក៏បានពិភាក្សាគ្នាពីស្ថានការណ៍នយោបាយនៅកម្ពុជា ផងដែរ។

នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ បាននិយាយទៅកាន់មេដឹកនាំវៀតណាមខាងជើង

ថា ទាក់ទិននឹងការព្រមព្រៀងរបស់ប្រទេសទាំង២ពីមុនមកនោះ ការដឹកជញ្ជូនអាវុធយុទ្ធភណ្ឌទៅជួយវៀតកុង-វៀតណាមខាងជើង មានបរិមាណ១០ពាន់តោន ក្នុងមួយខែ។ ឥឡូវនេះ យើងចង់បង្កើនវាឱ្យទៅដល់៣០ពាន់តោន ក្នុងមួយខែ។

ចំពោះអាវុធយុទ្ធភណ្ឌជាជំនួយរបស់សូវៀត វៀតណាមត្រូវគិតគូរថា តើការប្រើប្រាស់អាវុធយុទ្ធភណ្ឌទាំងនោះ មានភាពសមស្រប ហើយមានប្រសិទ្ធភាពដែរឬទេ? វៀតណាមត្រូវរាយការណ៍ឱ្យយើងដឹងអំពីបរិមាណនៃអាវុធយុទ្ធភណ្ឌទាំងនោះផង ដើម្បីឱ្យយើងធ្វើការផ្ទៀងផ្ទាត់មើល។ បើមានការខ្វះខាត យើងនឹងផ្តល់ជូនបន្ថែមទៀត។

ដូ អេនឡាយ បន្តថា បច្ចុប្បន្ននេះ កំពង់ផែហៃហ្វុង មិនទាន់ត្រូវបានគេរាំងខ្ទប់ទេ។ ដូច្នេះមិនទាន់ចាំបាច់គិតគូរពីការប្រើប្រាស់កំពង់ផែចិន ឡើយ។ សហភាពសូវៀត ធ្លាប់និយាយម្តងមកហើយថា សហរដ្ឋអាមេរិក នឹងមិនវាយប្រហារមកលើនាវាសូវៀត ទេ។

ប្រាកដណាស់ ក្នុងករណីកំពង់ផែហៃហ្វុង ត្រូវបានគេរាំងខ្ទប់ គឺគ្មានកំពង់ផែណាផ្សេងទៀតទេ។ ដូច្នេះការដឹកជញ្ជូនអាវុធយុទ្ធភណ្ឌពីសូវៀតទៅវៀតណាម ត្រូវតែឆ្លងកាត់តាមកំពង់ផែចិន។ យើងបានព្រមព្រៀងគ្នាពីបញ្ហានេះហើយ។ ប៉ុន្តែទាក់ទិននឹងការប្រើប្រាស់កំពង់ផែចិន សម្រាប់ដឹកជញ្ជូនជំនួយយោធារបស់សូវៀត យកទៅវៀតណាម យើងនឹងធ្វើការគិតគូរតាមស្ថានការណ៍ជាក់ស្តែង និងពេលវេលាសមស្រប និងមានកិច្ចព្រមព្រៀងមួយផ្សេងទៀត។ ពួកសូវៀត មិនចង់ដឹកអាវុធយុទ្ធភណ្ឌទៅឱ្យវៀតណាម តាមកំពង់ផែចិន គឺគេមានចេតនាលាក់កំបាំងរឿងផ្សេងទៀត។

ដូ អេនឡាយ បន្តទៀតថា នៅមានសមរភូមិមួយទៀត និយាយឱ្យចំ គឺកម្ពុជា។ ប្រទេសកម្ពុជា ជាប់ជំពាក់ទៅនឹងប្រទេសបារាំង ដូចគ្នានឹងប្រទេសឡាវ និងប្រទេសវៀតណាមខាងត្បូង ដែលជាប់ពាក់ព័ន្ធនឹងសហរដ្ឋអាមេរិក ដែរ។ បារាំង បានតាំងចិត្តថា នឹងមិនបោះបង់កម្ពុជា ចោលទេ។ ពេលខ្លះ សម្តេចសីហនុ ផ្ទុះកហឹង ដេរប្រទេចយើង តែយើងអាចយល់បានពីកំហឹងរបស់ព្រះអង្គ ។ ដូច្នេះយើងត្រូវតែដណ្តើមយកសមានចិត្តរបស់ព្រះអង្គឱ្យបាន ហើយយើងក៏ត្រូវយល់អំពីចរិតធម្មជាតិរបស់ព្រះអង្គដែរ។



**មិត្តភាពរវាង ជូ អេនឡាយ និងសម្តេចសីហនុ**

ថ្មីៗនេះ នាយករដ្ឋមន្ត្រីអូស្ត្រាលី ហារ៉ុលដ៍ ហូលត៍ (Harold Holt) បានទៅធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ហើយគាត់សួរសម្តេចសីហនុ ថា ព្រះអង្គពិតជាបានជួយរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (វៀតកុង) មែនទេ? ព្រះអង្គមិនបានបដិសេធរឿងនេះទាំងស្រុងទេ ដោយមានបន្ទូលថា ព្រះអង្គជួយបន្តិចបន្តួចក្នុងរឿងដឹកជញ្ជូន។

ជូ អេនឡាយ រម្លឹកប្រាប់ ផាម វ៉ាន់ដុង និង វ៉ ង្វៀនយ៉ាប់ ថា ខ្ញុំបានស្គាល់សម្តេចសីហនុជាង១០ឆ្នាំមកហើយ ខ្ញុំមើលឃើញថា ព្រះអង្គមានការឈ្លាសវៃជាងស៊ូការណូ(មេដឹកនាំឥណ្ឌូនេស៊ី ពីឆ្នាំ១៩៤៥-៦៧)។ ស៊ូការណូ ប្រហែលជាខ្លាចចលនាប្រជាជន តែសម្តេចសីហនុ មិនខ្លាចទេ។

ពេលនេះការដណ្តើមយកសមានចិត្តរបស់សម្តេចសីហនុរបស់យើង ទទួលលទ្ធផលល្អគួរសមដែរ តែយើងក៏ត្រូវតែគិតគូរអំពីលទ្ធភាពនៃការរាំងខ្ទប់ដែរ។ យើងគិតថា ការដឹកជញ្ជូនក្នុងរដូវវស្សាអាវុធយុទ្ធភណ្ឌ និងសម្ភារៈយោធាឆ្លងកាត់ប្រទេសកម្ពុជា មិនសម្រាប់តែក្នុងរដូវវស្សាឆ្នាំនេះទេ គឺយើងត្រូវការដឹកជញ្ជូននៅឆ្នាំក្រោយទៀតដែរ។ ដូច្នេះយើងគួរតែកេងយកឱកាសជានិច្ច នៅពេលដែលវាហុចឱ្យ។

វ៉ ង្វៀនយ៉ាប់ ប្រាប់ទៅ ជូ អេនឡាយ វិញថា បច្ចុប្បន្ននេះ សហរដ្ឋអាមេរិក ចង់ប្រើ-ប្រាស់ក្រុមអ្នកគាំទ្រអាមេរិកនៅកម្ពុជា (ពួកស្តាំនិយម) ឱ្យធ្វើវិទ្ធង្សនា និងធ្វើរដ្ឋប្រហាររម្លំសម្តេចសីហនុ។ តើសមមិត្តមានយោបល់អ្វីទេ ពីបញ្ហានេះ?

ជូ អេនឡាយ ឆ្លើយថា យើងមិនគួរប្រានចេញនូវលទ្ធភាព ដែលថានឹងមានរដ្ឋប្រហារនៅកម្ពុជា នោះទេ។ សម្តេចសីហនុ ដូចជាស៊ូការណូ ដែរ កំពុងប្រើវិធីដឹកនាំប្រទេសផ្សេងៗពីគ្នា ដើម្បីរក្សាអំណាច។ តែទោះជាយ៉ាងណា សម្តេចសីហនុ ក៏មិនដូច ណេវិន (មេដឹកនាំភូមា ពីឆ្នាំ១៩៦២-១៩៨១) ដែលជាអ្នកគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធទាំងមូលដែរ។ បច្ចុប្បន្ននេះ ណេវិន ត្រូវបានពិភពលោកទិតៀនកាន់តែខ្លាំងឡើងៗ ចំពោះការប្រើកម្លាំងអាវុធ ដើម្បីបង្ក្រាបអ្នកប្រឆាំងនឹងគាត់ ហើយជាលទ្ធផល ធ្វើឱ្យគាត់មិនសូវមានប្រជាប្រិយភាព។ ខ្ញុំបាននិយាយជាមួយគាត់ច្រើនលើកមកហើយ អំពីយុទ្ធសាស្ត្រក្នុងការ-គ្រប់គ្រងដឹកនាំប្រទេស និងបានទូន្មានគាត់ កុំឱ្យបង្ក្រាបអ្នកប្រឆាំងនឹងគាត់មានលក្ខណៈឃោរឃៅខ្លាំងពេក។ តែអ្វី ដែលខ្ញុំបានដឹងតាមរយៈ អ៊ូ ថាន់ (អគ្គលេខាធិការអង្គការសហប្រជាជាតិ ពីឆ្នាំ១៩៦២-៧១) ណេវិន ស្តាប់យោបល់អាមេរិក, អង់គ្លេស និងបារាំង ដែរតែគាត់ស្តាប់តិចតួច ហើយគាត់ក៏នៅតែរក្សានូវចំណងទាក់ទងជាមួយចិន និងសហភាពសូវៀត ផងដែរ។ លក្ខខណ្ឌ និងស្ថានការណ៍នៅភូមា មានភាពប្រសើរដែរ តែខ្ញុំមិនដឹងថាហេតុអ្វី បានជាបដិវត្តន៍នៅភូមា មិនវិវឌ្ឍទៅមុខ?។

បន្ទាប់មក ផាម វ៉ាន់ដុង បានសួរ ជូ អេនឡាយ ថា តើសមមិត្តគិតយ៉ាងម៉េចដែរ អំពី លន់ នល់? ជូ អេនឡាយ ឆ្លើយថា លន់ នល់ ជាមនុស្សមិនគួរឱ្យជឿទុកចិត្តបានទេ។

ផាម វ៉ាន់ដុង តបថា តែក្នុងការជជែកជាមួយយើងខ្ញុំ ពេលនិយាយពីប្រទេសចិន លន់ នល់ ប្រើពាក្យពេចន៍ល្អៗណាស់។

ជូ អេនឡាយ និយាយកាត់ថា លន់ នល់ ក៏ប្រើពាក្យពេចន៍ល្អៗជាមួយយើងខ្ញុំដែរ ហើយគាត់ថែមទាំងបាននិយាយថា គាត់មានឈាមជ័រជាចិន ទៀតផង។ ចំណែក ភូមី នូសាវ៉ាន់ (ឧត្តមសេនីយ៍ឡាវ មាននិន្នាការស្តាំនិយម) ក៏គេនិយាយថា គាត់មានឈាមជ័រជា




**លន់ នល់ ពេលទៅជួប ជូ អេនឡាយ ឆ្នាំ១៩៦៥**

ចិន ដែរ។ ប៉ុន្តែឈាមពួកនេះ សុទ្ធតែជាឈាមសក្តិភូមិ និងចក្រពត្តិនិយម...។

ចេន យី រដ្ឋមន្ត្រីការបរទេស ដែលមានវត្តមានជំនួបពិភាក្សានោះ បានលើកឡើងថា លន់ នល់ ជាមនុស្សអែបអបជាមួយអាមេរិក ហើយសម្តេចសីហនុ ក៏បានដឹងពីរឿងនេះដែរ។

ជូ អេនឡាយ បន្តថា លន់ នល់ មកទស្សនកិច្ចនៅចិន ហើយគាត់បាន ធ្វើឱ្យយើងមានការចាប់អារម្មណ៍ខ្លះៗដែរ ហើយប្រសិនបើយើងចាយលុយខ្លះទៅលើគាត់ យើងនឹងអាចជញ្ជក់យកផលប្រយោជន៍ពីគាត់បានខ្លះ។ មាតារបស់សម្តេចសីហនុ ក៏ធ្វើនយោបាយដូចអគ្គមហេសីចិន ធ្លាប់ធ្វើពីមុនមកដែរ។ ម្តាយ និងកូនមានការទាស់ទែងខ្វែងគំនិតគ្នា។ តែពួកគេក៏ជញ្ជក់យកផលប្រយោជន៍ពីគ្នាទៅវិញទៅមក។ ចំណុចខ្សោយរបស់សម្តេច សីហនុ គឺគាត់មិនគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធដូច ណេវិន នៅភូមា ទេ។

បើតាមការវាយតម្លៃរបស់យើងលើលទ្ធភាពសង្គ្រាម យើងត្រូវតែគិតអំពីលទ្ធភាព២ គឺលទ្ធភាពទី១ សង្គ្រាមអាចបន្ត ហើយអាចរីករាលដាល។ ក្រឹត្យក្រមនៃសង្គ្រាមមិនមែនកំណត់ដោយឆន្ទៈរបស់មនុស្សលោក ហើយក៏មិនមែនកំណត់ដោយឆន្ទៈរបស់សត្រូវ និងឆន្ទៈរបស់យើងដែរ។ តែសង្គ្រាមមានក្រិត្យក្រមរបស់វា។

បើទោះជាសត្រូវចង់បញ្ចប់ ក៏ពួកគេពិបាកនឹងបញ្ចប់ដែរ។ ដោយហេតុនេះហើយ នៅពេលដែលយើងធ្វើការវាយតម្លៃលើលទ្ធភាពសង្គ្រាម យើងត្រូវត្រៀមលក្ខណៈសម្រាប់ការរីករាលដាលរបស់វា។

លទ្ធភាពទី២ សត្រូវអាចរាំងខ្ទប់សមុទ្រ។ បើសត្រូវចាប់ផ្ដើមការរាំងខ្ទប់ទាំងអស់ មានន័យថា ពួកគេកំពុងរៀបចំពង្រីកសង្គ្រាមឲ្យកាន់តែរីកធំ។

បើសត្រូវធ្វើការរាំងខ្ទប់ ដើម្បីបង្ខំសមមិត្តឱ្យធ្វើការសម្របសម្រួល តែសមមិត្តប្រកែក មិនព្រមធ្វើតាមនោះ ពួកគេត្រូវតែធ្វើអ្វីផ្សេងទៀតដែលជាផែនការបម្រុងរបស់ពួកគេ។ វា មិនមែនជារឿងងាយស្រួលសម្រាប់សត្រូវធ្វើការរាំងខ្ទប់ទាំងស្រុង តាមសមុទ្រនោះទេ ព្រោះ វាត្រូវមានការដាក់ពង្រាយនាវាច្រើនណាស់។

នេះជាសកម្មភាពមួយមានទំហំធំធេង ហើយវាអាចបណ្ដាលឱ្យមានភាពតានតឹង កាន់តែខ្លាំងឡើងក្នុងទំនាក់ទំនងរបស់ពួកគេជាមួយប្រទេសដទៃទៀត។

ជូ អេនឡាយ បន្តទៀតថា ដូចសមមិត្តទាំងពីរទើបតែមានប្រសាសន៍រួចហើយ ពី លទ្ធភាពទីបី គឺរដូវប្រាំងឆ្នាំក្រោយ ជាពេលវេលាមួយសំខាន់បំផុត គឺថា យើងមានលទ្ធភាព ផ្ដួលសត្រូវបាន ដោយបង្ខំឱ្យពួកគេ (អាមេរិក) ទទួលស្គាល់បរាជ័យ ហើយដកទ័ពចេញពី វៀតណាម។

តើវាអាចទៅរួចទេ ការដែលថា សង្គ្រាមនឹងមិនចប់ ឬមិនរីករាល ដោយគ្រាន់តែបន្ត ទៅទៀត ដូចក្នុងសភាពសព្វថ្ងៃ។ វាមិនអាចទៅរួចទេ។ វាគ្រាន់តែជារឿង ពេលវេលាតែ ប៉ុណ្ណោះ។ គេមិនអាចថា សង្គ្រាមនឹងនៅរ៉ាំរ៉ៃ ងាប់ក៏មិនងាប់ រស់ក៏មិនរស់ រហូតនោះបានទេ។ ទាក់ទិនទៅនឹងសំណួរអំពីការតស៊ូនយោបាយ មិនបាច់ឆ្ងល់ទេ ការតស៊ូនយោបាយ ត្រូវតែ បន្ត ទោះជាស្ថិតក្រោមលក្ខខណ្ឌណាក៏ដោយ។ សង្គ្រាមជាការបន្តនៃនយោបាយនៅក្នុង ទ្រង់ទ្រាយខ្ពស់បំផុតរបស់វា ដូច្នេះការធ្វើសង្គ្រាមដោយគ្មានការតស៊ូនយោបាយមិនអាច ទៅរួចទេ។

ដើម្បីពង្រឹងការឃោសនាអន្តរជាតិ ក្នុងការដណ្ដើមយកសមានចិត្ត ដើម្បីធ្វើឱ្យសត្រូវ ចុះខ្សោយ និងបាក់បែក ព្រមទាំងដើម្បីទាញយកប្រយោជន៍ពីការខ្វែងគំនិតគ្នារបស់សត្រូវ សុទ្ធតែជាការតស៊ូនយោបាយក្នុងទម្រង់ផ្សេងៗគ្នា។ សមមិត្តធ្លាប់ធ្វើដូច្នេះ កាលពីអតីតកាល រួចមកហើយ។ ដូច្នេះសមមិត្តគួរតែបន្តធ្វើបែបនេះទៀត ទៅថ្ងៃអនាគត។



សូ ណែម



ឌុក រ៉ាសុី



ចៅ សេង

មួយថ្ងៃក្រោយមកទៀត គឺនៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៦៧ ពួកមេដឹកនាំចិន និង វៀតណាមខាងជើង បានប្រជុំពិភាក្សាគ្នាពីបញ្ហា ដែលទាក់ទងជាមួយប្រទេសកម្ពុជា បន្តទៀត។

ពេលនោះ នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ បានសួរទៅមេដឹកនាំវៀតណាមខាងជើងថា តើមានការមន្ទិលសង្ស័យណាមួយទេថា អាវុធយុទ្ធភណ្ឌដែលយើងបញ្ជូនទៅឱ្យសមមិត្តតាមរយៈប្រទេសកម្ពុជា ត្រូវបានបែងចែកឱ្យទៅបក្សកុម្មុយនិស្តកម្ពុជាឬទេ ?

ផាម វ៉ាន់ដុង ឆ្លើយថា ប្រហែលជាអាវុធទាំងអស់នោះវាចាស់ៗហើយ ប៉ុន្តែមិនប្រាកដទេ។ ក្រោយពេលត្រលប់ទៅហាណូយ វិញ យើងខ្ញុំនឹងសួរអំពីរឿងនេះ ហើយនឹងជូនព័ត៌មានមកឱ្យសមមិត្តជ្រាប។

ជូ អេនឡាយ បន្តទៀតថា កាលពីថ្ងៃទី៣០ ខែកញ្ញា (ឆ្នាំ១៩៦៦) សម្តេចសីហនុមានបន្ទូលថា ព្រះអង្គប្រហែលជាតែងតាំង លន់ នល់ (ជាមនុស្សស្តាំនិយម)ឱ្យធ្វើជានាយករដ្ឋមន្ត្រី និងរៀបចំគណៈរដ្ឋមន្ត្រីថ្មីមួយ ហើយព្រះអង្គបានផ្តល់ព្រះតម្រិះឱ្យ លន់ នល់ ថា គួរអញ្ជើញពួកក្រហមខ្លះឱ្យមកធ្វើការក្នុងគណៈរដ្ឋមន្ត្រីរបស់គាត់ ផងដែរ។ តែ លន់ នល់ មិនធ្វើតាមព្រះតម្រិះនោះទេ សូម្បីតែ សូ ណែម ដែលគ្រាន់តែសង្ស័យជាជនឆ្វេងនិយម ក៏ លន់ នល់ បដិសេធបេក្ខភាពរបស់គាត់ ហើយដាក់ ឌុក រ៉ាសុី(ជាមនុស្សស្តាំនិយម) ឱ្យធ្វើ

ជារដ្ឋមន្ត្រីក្រសួងផែនការ វិញដែរ។ ចំណែក ចៅ សេង ស្ថិតក្នុងក្រុមសម្តេចសីហនុ ក៏ លន់ នល់ ចាត់ទុកថាជាជនឆ្វេងនិយមដែរ។

ចៅ សេង ក៏បាននិយាយដែរថា សម្តេចសីហនុ បានស្នើឡើងនូវបញ្ជីឈ្មោះបេក្ខជន គណៈរដ្ឋមន្ត្រីមួយចំនួន ប៉ុន្តែ លន់ នល់ មិនយល់ព្រម។ បើសិនជាគណៈរដ្ឋមន្ត្រីរបស់ លន់ នល់ ត្រូវដួលរលំ សម្តេចសីហនុ នឹងអញ្ជើញ ប៉ែន នុត ដែលជាមនុស្សអព្យាក្រឹត ឱ្យមក បង្កើតរាជរដ្ឋាភិបាលថ្មីមួយទៀត។

នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៦៧ មានបាតុកម្មមួយនៅមុខព្រះបរមរាជវាំង ហើយ មេដឹកនាំបាតុករត្រូវបានអញ្ជើញឱ្យចូលក្នុងវាំង ដើម្បីចូលថ្វាយបង្គំព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ ។ ពេលនោះ សភាជាតិ ក៏មានការកោះប្រជុំបន្ទាន់មួយ ហើយក្រោយពី មានការជជែកដេញដោលគ្នាដ៏ក្តៅគគុក សភាជាតិបានសម្រេចថ្វាយអំណាចពិសេសមួយ ចំពោះសម្តេចសីហនុ។

សម្តេចសីហនុ មានព្រះបន្ទូលថា ព្រះអង្គសម្រេចព្រះទ័យថា នឹងរក្សានូវជំហរអព្យាក្រឹត តែមន្ត្រីស្ថានទូតរបស់យើងនៅទីនោះ ធ្វើការសន្និដ្ឋានថា សំខាន់គឺព្រះអង្គប្រឆាំងនឹងពួក ឆ្វេងនិយម។ ប៉ុន្តែហេតុអ្វី បានជាព្រះអង្គចង់តែងតាំង ប៉ែន នុត ឱ្យបង្កើតរាជរដ្ឋាភិបាលថ្មី? គឺមានប្រការផ្ទុយគ្នាមួយចំនួន។

ជូ អេនឡាយ បន្តថា នៅខេត្តកណ្តាល មានគេបាចខិត្តប័ណ្ណប្រឆាំងនឹង ខៀវ សំផន ដែលគេសង្ស័យថា គាត់ជាជនឆ្វេងនិយម។ នៅឯខេត្តកំពង់ចាម និងស្ទឹងត្រែង មានបាតុកម្ម ជាច្រើន គាំទ្រនយោបាយរបស់សម្តេចសីហនុ ប្រឆាំងនឹងពួកឆ្វេងនិយម។

និយាយឱ្យខ្លីទៅ ស្ថានការណ៍នៅតែផ្លាស់ប្តូរនៅឡើយ ក្រោយពីមានហេតុការណ៍ នៅខេត្តបាត់ដំបង។ នៅកម្ពុជា មានរាជរដ្ឋាភិបាលពីរ គឺមួយ រាជរដ្ឋាភិបាលផ្លូវការ និង មួយទៀត ជារាជរដ្ឋាភិបាលលាក់លៀម(បរៈរាជរដ្ឋាភិបាល)។

រាជរដ្ឋាភិបាលលាក់លៀម(បរៈរាជរដ្ឋាភិបាល) បានសរសេរថា ប្រទេសយើងស្ថិត ក្រោមការគំរាមកំហែង។ ពួកខ្មែរក្រហម កំពុងតែបើកសមរភូមិនៅខេត្តបាត់ដំបង។ យើង

ត្រូវតែលៃលកដោះស្រាយជាមួយសត្រូវនៅលើសមរភូមិពីរ គឺទី១.សមរភូមិមួយប្រឆាំងនឹងពួកខ្មែរសេរី និងមួយទៀត គឺប្រឆាំងនឹងពួកខ្មែរក្រហម។ កាលពីមុន រាជរដ្ឋាភិបាលកម្ពុជាប្រយុទ្ធតែជាមួយនឹងពួកចក្រពត្តិនិយមអាមេរិក តែប៉ុណ្ណោះ តែបច្ចុប្បន្ន រាជរដ្ឋាភិបាលនេះត្រូវប្រយុទ្ធប្រឆាំងនឹងពួកចក្រពត្តិនិយមអាមេរិកផង និងប្រយុទ្ធប្រឆាំងនឹងពួកកុម្មុយនិស្តនិយមផង។

ឥរិយាបថរបស់យើងទៅកាន់ពួកកុម្មុយនិស្ត គឺត្រឹមត្រូវជានិច្ច តែហេតុអ្វីបានជាពួកគេវាយប្រហារយើងទៅវិញ ? ហេតុអ្វី បានជាប្រទេសកម្ពុជា ប្រកាន់យកឥរិយាបថបែបនេះចំពោះរណសិរ្សជាតិរំដោះរបស់វៀតណាម ?

ជូ អេនឡាយ ធ្វើការបកស្រាយថា ៖ ហេតុផលដែលខ្ញុំមើលឃើញមានច្រើន គឺរណសិរ្សជាតិរំដោះវៀតណាម ព្យាយាមអូសទាញទាហានអាមេរិក ឲ្យទៅកាន់ព្រំប្រទល់កម្ពុជា ដើម្បីធ្វើឱ្យប្រទេសកម្ពុជា ចូលប្រឡូកក្នុងសង្គ្រាមដែរ។

រណសិរ្សជាតិរំដោះវៀតណាម បានបញ្ជាដោយចេតនាឱ្យប្រជាជនវៀតណាម ចំនួនជាង២០០០ នាក់ ចូលទៅប្រទេសកម្ពុជា ក្នុងឋានៈជាជនភៀសខ្លួន។ ក្នុងចំណោមមនុស្សទាំងនោះ មានវេជ្ជបណ្ឌិត៧រូប ជាអ្នកថែទាំសុខភាព និងធ្វើឱ្យមានឥទ្ធិពលលើប្រជាជនកម្ពុជា។

លន់ នល់ ទទួលការទិតៀនពីសំណាក់ពួកឆ្វេងនិយម ហើយគាត់ក៏មិនសប្បាយចិត្តដែរ។ គាត់និយាយថា ដោយសារតែស្ថានភាពមានការយ៉ាប់យ៉ឺន គាត់សម្រេចព្យួរការជួយឧបត្ថម្ភដល់រណសិរ្សជាតិរំដោះវៀតណាម។ តែគាត់មិនបាននិយាយពីបញ្ហាអាវុធយុទ្ធភណ្ឌរបស់យើង ដែលបានដឹកទៅដល់ប្រទេសកម្ពុជា រួចហើយនោះទេ។ ជាមួយគ្នានោះ គាត់ក៏បានផ្អាកការដឹកជញ្ជូនអង្ករ ផងដែរ។ លើសពីនេះទៀត លន់ នល់ ដើម្បីបញ្ជាឱ្យមានការត្រួតពិនិត្យតឹងរ៉ឹងលើការរត់ពន្ធអង្ករតាមព្រំដែន ដើម្បីគំរាមដល់រណសិរ្សជាតិរំដោះវៀត-ណាម។ ប៉ុន្តែ នេះគ្រាន់តែជាការសម្តែងមួយប៉ុណ្ណោះ។

វ៉ ង្វៀនយ៉ាប់ បាននិយាយប្រាប់ ជូ អេនឡាយ ថា មានករណីខ្លះកើតឡើងថ្មីៗ ក្នុង

តំបន់ព្រំដែនកម្ពុជា និងវៀតណាមខាងត្បូង។ កងវរសេនាតូចអាមេរិក បានបើកការវាយប្រហារឆ្លងចូលព្រំដែនកម្ពុជា ហើយកងទ័ពរណសិរ្សជាតិរំដោះវៀតណាម (វៀតកុង) បានជួយទាហានកម្ពុជា ក្នុងការវាយបកវិញ។

ក្នុងអំឡុងកងទ័ពអាមេរិក បើកប្រតិបត្តិការសឹកឈ្មោះចុនសុន ស៊ីធី យែមភែន (Junction City Campaign) ជនស៊ីវិលវៀតណាម និងកងទ័ពរណសិរ្សជាតិរំដោះវៀតណាម បាននាំគ្នាជម្លៀសខ្លួនចូលទៅក្នុងទឹកដីប្រទេសកម្ពុជា។

ផាម វ៉ាន់ដុង បន្ថែមថា វេជ្ជបណ្ឌិតវៀតណាមមួយចំនួនត្រូវបញ្ជូនទៅទីនោះ ដើម្បីជួយព្យាបាលប្រជាជនកម្ពុជា។ ទោះជាយ៉ាងណាក្តី ក៏យើងនៅតែមានការប្រុងប្រយ័ត្នដែរជាមួយកិច្ចការនេះ។

ជូ អេនឡាយ ប្រាប់វិញថា ត្រូវហើយ ព្រោះថារឿងតូចតាចខ្លះ អាចបណ្តាលឱ្យមានការយល់ច្រឡំ។ យោងតាមប្រភពរបស់យើង តំណាងរបស់រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (វៀតកុង) បានជួបជាមួយតំណាងរបស់ក្រុមខ្មែរក្រហម ហើយបានផ្លាស់ប្តូរយោបល់គ្នាស្តីពីស្ថានការណ៍នៅកម្ពុជា។ តែមានការខ្វែងគំនិតច្រើន ពីគោលនយោបាយដែលត្រូវយកទៅដោះស្រាយជាមួយ លន់ នល់។

យើងចង់ដណ្តើមយកសមានចិត្តពី លន់ នល់ ដែរ ប៉ុន្តែពួកគេ(ខ្មែរក្រហម)ជំទាស់នឹងគាត់។ ពេលនេះជោគជ័យរបស់រណសិរ្សរំដោះជាតិ(វៀតកុង)ជាអាទិភាពទីមួយ។ បើសិនជាតំបន់ព្រំដែនវៀតណាម-កម្ពុជា ត្រូវបានបិទនោះ កងទ័ពរណសិរ្សជាតិរំដោះវៀតណាម (វៀតកុង) ប្រាកដជាជួបការលំបាកច្រើន ហើយកម្លាំងបដិវត្តន៍របស់កម្ពុជា ក៏នឹងមិនដំណើរការទៅមុខដែរ។ ការតស៊ូរបស់វៀតណាម ស្ថិតក្នុងផលប្រយោជន៍រួមរបស់ប្រជាជនឥណ្ឌូចិន និងអាស៊ីអាគ្នេយ៍ ហើយជោគជ័យនៃការតស៊ូនេះមានចរិតផ្តាច់ព្រ័ត្រ។

នៅក្នុងស្ថានការណ៍បែបនេះ បើទោះការតស៊ូនៅកម្ពុជា មានចរិតជាប្រដាប់អាវុធក្តី ក៏គោលដៅរបស់វាមានព្រំដែនដែរ។ បើទោះជាក្នុងករណីត្រូវទទួលបានជ័យជម្នះក៏ដោយ ក៏វានៅមានកម្រិត ហើយក៏មិនទទួលបានជ័យជម្នះផ្តាច់ព្រ័ត្រដែរ។ នេះ មិនទាន់និយាយ



**ប្រតិបត្តិការសឹកឈ្មោះចុនសុន ស៊ីធី ឃែមភែន** (Junction City Campaign)

ដល់ការបាត់បង់ជ័យជម្នះទាំងនោះទៅវិញ ដោយងាយៗផង។

ទាក់ទងនឹងរឿងនេះ យើងត្រូវដឹងថា តើយើងត្រូវតម្កល់ប្រយោជន៍រួមលើប្រយោជន៍មានកម្រិត របៀបម៉េច? តែវាជារឿងមួយផ្សេងទៅវិញ បើការតស៊ូនោះត្រូវបានផ្តួចផ្តើមដោយឆន្ទៈប្រជាជនខ្លួនឯង។ ក្នុងករណីនេះ ការតស៊ូដោយអាវុធជាប្រការមិនអាចរារាំងបាន ពីព្រោះឆន្ទៈជាធម្មជាតិរបស់ប្រជាជន គឺតែងតែរើបម្រះតទល់នឹងការគាបសង្កត់ ហើយប្រជាជនក៏ត្រូវឆ្លងកាត់ការបង្ក្រាបផងដែរ ប៉ុន្តែពួកគេនឹងដកស្រង់បានមេរៀនជាច្រើនតាមរយៈការតស៊ូ។

ភារកិច្ចរបស់បក្សបដិវត្តន៍ គឺដឹកនាំការតស៊ូ។ និយាយឱ្យខ្លី បើសិនជាការតស៊ូរបស់ប្រជាជនវៀតណាមខាងត្បូង បានសម្រេច វាក៏នឹងនាំមកនូវក្តីសង្ឃឹមដល់ការតស៊ូនៅប្រទេសកម្ពុជា ដែរ។ ភាពឡូហ្សិកនេះ គួរតែត្រូវបានពន្យល់ឱ្យបានច្បាស់លាស់ដល់ភាគីប្រជាជននៅកម្ពុជា ផងដែរ។

ផាម វ៉ាន់ដុង ឆ្លើយតបទៅ ជូ អេនឡាយ វិញថា ជាញឹកញាប់យើងតែងតែព្យាយាម បញ្ចុះបញ្ចូលពួកគេ (មេដឹកនាំខ្មែរក្រហម) ហើយយើងត្រូវតែធ្វើដូច្នេះតទៅទៀត។

ជូ អេនឡាយ តបថា ត្រូវហើយ ព្រោះថាបក្សនីមួយៗមានឯករាជ្យរបស់ខ្លួន។ សមមិត្ត ង្វៀន ធឿង (Nguyen Thuong) និយាយថា វាជាការចាំបាច់ក្នុងការអភិវឌ្ឍឱ្យបាននូវទំនាក់ទំនងល្អជាមួយកម្ពុជា។ ខ្ញុំមើលឃើញនូវលទ្ធភាពពីរ៖

ទី១ គឺសម្តេចសីហនុ ប្រើប្រាស់ស្ថានភាពនេះ ដើម្បីធ្វើការគាបសង្កត់លើកម្លាំងបដិវត្តន៍កម្ពុជា ក្នុងទស្សនៈថា ធ្វើឱ្យមានតុល្យភាពកម្លាំងរវាងពួកឆ្វេងនិយម និងពួកស្តាំនិយម។

ទី២ គឺដើម្បីបង្ហាញនូវនយោបាយអព្យាក្រឹត កម្លាំងទាំងអស់ត្រូវតែគ្រប់គ្រងដោយព្រះអង្គ មិនថាកម្លាំងទាំងនោះមានទំនោរទៅរកចិន, វៀតណាម ឬសហរដ្ឋអាមេរិក ឡើយ។

ជាទូទៅ ដូចដែលខ្ញុំបានប្រាប់សមមិត្តពីមុនមកហើយថា យើងត្រូវតែដណ្តើមយកសមានចិត្តរបស់គាត់ (សម្តេចសីហនុ)។ ជាមួយគ្នានោះដែរ ត្រូវត្រៀមខ្លួនសម្រាប់ទទួលអាវុធយុទ្ធភណ្ឌឆ្លងកាត់ប្រទេសកម្ពុជា នៅពេលណា ដែលស្ថានភាពហុចឱកាសឱ្យ។ ដូច្នេះ សមមិត្តត្រូវរក្សាទំនាក់ទំនងជាមួយអគ្គសេនាធិការ, ក្រសួងគមនាគមន៍ និងទូរគមនាគមន៍ចិនជាប្រចាំ និងឱ្យបានខ្ជាប់ខ្ជួន។

---

## សូមរង់ចាំអានភាគ៥ បន្តទៀត
## សូមអរគុណ

# ឯកសារយោង ៖


1. Le Cambodge de Sihanouk Espoir, Désillusions et Amertume. par Richard Sola .
2. Le mal Cambodge Histoire D´une société traditionnelle Face à ses Leaders Politiques 1946 – 1987. par Marie Alexandrine Martin .
3. Pol Pot Frère Numéro Un. par Davidp – Chandler.
4. Le Cambodge dans la tourmente: Le troisième conflit indochinois, 1978-1991. par Nicolus Regaud .
5. Cambodge : Rêves et Réalités. par Vandy Kaonn.
6. Histoire du Cambodge 1863 – 1992. par Vandy Kaonn .
7. Cambodia: Year Zero by Francois Ponchaud
8. Hun Sen strongman of Cambodia. by Harrish C. Metha Julie B. metha.
9. When the War Was Over by Elizabeth Becker
10. How Pol Pot to come Power. By Ben Kiernan .
11. Wikipedia The free encyclopedia .
12. Wikipedia Org. wiki.
13. DP. Pedia org. page.
14. Wikiwand.
15. U.S. Embassy in Cambodia document.
16. Cold war international history Project.
17. The New York Times newspaper.
18. Times Magazine.
19. The Far Eastern Economic Review Magazine.
20. Le Figaro newspaper.

21. Le Monde newspaper.

22. Les Echos newspaper.

23. Le Parisien newspaper.

24. L´ humanite newspaper.

25. Liberation newspaper.

26. Washington Post newspaper.

27. Pol Pot by Philip Short.

28. The Gate by Francois Bizot.

29. Haing Ngor: A Cambodian Odyssey by Haing S. Ngor with Roger Warner.

30. My War With the CIA by Norodom Sihanouk .

31. War and Hope: The Case for Cambodia by Norodom Sihanouk .

32. Flying Tigers Over Cambodia by Larry Partridge.

33. The United States and Cambodia, 1870-1969 By Kenton Clymer.

34 .L´histoire terrible mais inachevée de Norodom Sihanouk, roi du Cambodge
(THEATRE) (French Edition).

35. Souvenir doux et amers  par Norodom Sihanouk.

36. គុកនយោបាយ  ដោយ ប៊ុណ្ណ ចន្ទម៉ុល.

37. ឧត្តមគតិ លោកអៀវ កើស ដោយ ង៉ែត ហៀង.

38. លោកព្រឹទ្ធាចារ្យ បណ្ឌិតជួន មុម្ម ដោយបណ្ឌិតពុទ្ធី ទត់.

39. ជីវប្រវត្តិសង្ខេប ប៉ែន សុវណ្ណ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា
ដោយប៉ែន សុវណ្ណ និងនាង សារុន.

40. Des racines dans la pierre par Sam raingsy

41. ខ្មែរអ្នកជាតិនិយម ដោយឡឹក សំអឿន ហៅផ្កាយព្រឹក

# ជីវប្រវត្តិសង្ខេបរបស់អ្នកសិក្សាស្រាវជ្រាវ



**រូបថត ឆ្នាំ១៩៨៥**



**រូបថត បច្ចុប្បន្ន**

ឈ្មោះ **ឈឹម សេរីវុទ្ធន** កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៥៤ កើតនៅភូមិស្រម៉ជ្រំ សង្កាត់សង្ស័រ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។ ឪពុកឈ្មោះ **ឈឹម ប៉ាច** មានស្រុកកំណើតនៅខេត្តព្រៃវែង មុខរបរជាអ្នកថែសួននៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត។ ម្ដាយឈ្មោះ **ទេព ឌុន** មានស្រុកកំណើតនៅខេត្តស្វាយរៀង មុខរបរជាមេផ្ទះ។ មានបង៣នាក់ ( ស្រី១ប្រុស២ ) និងប្អូន៣នាក់( ស្រី២ប្រុស១ )។

ឆ្នាំ១៩៦២ - ៦៣ ចូលរៀនថ្នាក់ទី១២ សាលាបឋមសិក្សាឯកជនសង្គមមានជ័យ នៅម្តុំខាងក្រោយសាលាបច្ចេកទេសថៃទាំវេជ្ជសាស្ត្រសព្វថ្ងៃ ។

ឆ្នាំ១៩៦៣ - ៦៩ រៀននៅសាលាបឋមសិក្សាចង្ក្រានតាព្រហ្មមានជ័យ (វត្តចង្ក្រានតាព្រហ្មស្ទឹងមានជ័យ )

ឆ្នាំ១៩៦៩ - ៧៤ រៀននៅវិទ្យាល័យឥន្ទ្រទេវី (វិទ្យាល័យទួលគោក )

ឆ្នាំ១៩៧៤ - ៧៥ រៀនថ្នាក់ទីបញ្ចប់ផ្នែកទស្សនវិជ្ជា នៅវិទ្យាល័យកែវ សង់គីម

(វិទ្យាល័យ១៨មីនា ១៩៧០ ឬវិទ្យាល័យព្រះយុគន្ធរ)។

**ប្រវត្តិការងារ ៖**

-ពីឆ្នាំ១៩៧៩ -១៩៨៤ ជានាយកអប់រំឃុំព្រៃរំដេង ស្រុកមេសាង ខេត្តព្រៃវែង

-ពីឆ្នាំ១៩៨៤ -១៩៨៥ ជាអនុប្រធានការិយាល័យអប់រំស្រុកមេសាង ខេត្តព្រៃវែង

-ពីឆ្នាំ១៩៨៥ -១៩៨៦ ជាប្រធានការិយាល័យឃោសនាការ វប្បធម៌ និងព័ត៌មាន ស្រុកមេសាង

-ពីឆ្នាំ១៩៨៦ -១៩៨៧ ជាលេខាបក្សឃុំត្រពាំងស្រែ ស្រុកមេសាង ខេត្តព្រៃវែង

-ពីឆ្នាំ១៩៨៧ -១៩៩៣ ជាប្រធានមន្ទីរគណៈកម្មាធិការបក្សស្រុកមេសាង និងជាសមាជិកគណៈកម្មាធិការបក្សស្រុក មេសាង ខេត្តព្រៃវែង

-ដើមឆ្នាំ១៩៩៣ ជាជំនួយការមន្ត្រីរៀបចំការបោះឆ្នោតអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ(UNTAC) ប្រចាំស្រុកមេសាង ខេត្តព្រៃវែង

-ឆ្នាំ១៩៩៤ ជាមន្ត្រីនគរបាលនៅនាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ

- ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០២២៖ ជាអ្នកនិពន្ធអត្ថបទវិភាគនយោបាយ វិចារណកថា បទបរិយាយ ឱ្យកាសែតចក្រវាឡ, កាសែតអរិយធម៌, កាសែតសំឡេងនិស្សិត, ទស្សនាវដ្តីកងរាជអាវុធហត្ថរាជធានីភ្នំពេញ។ ជានិពន្ធនាយកទស្សនាវដ្តីអង្គរធំ, ជានិពន្ធនាយកទស្សនាវដ្តីខេមរា, ជានិពន្ធនាយកទស្សនាវដ្តីសោភ័ណ, ជានិពន្ធនាយករងទស្សនាវដ្តីរថយន្ត, ជាទីប្រឹក្សាកាសែតនគរធំ, ជានិពន្ធនាយកគេហទំព័រTVFB, ជានិពន្ធនាយកគេហទំព័រKBN និងជាប្រធានផ្នែកព័ត៌មានជាតិ គេហទំព័រSBM News និងជាអ្នកសិក្សាស្រាវជ្រាវឯកសារប្រវត្តិសាស្ត្របក់នយោបាយ

-ឆ្នាំ២០២២ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ

-ឆ្នាំ២០២៣ ជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ

**UNITED NATIONS**
**UNITED NATIONS TRANSITIONAL AUTHORITY IN CAMBODIA (UNTAC)**

**NATIONS UNIES**
**AUTORITE PROVISOIRE DES NATIONS UNIES AU CAMBODGE (APRONUC)**

# CERTIFICATE OF OUTSTANDING SERVICE

This certifies that Mr. Chhim Sery Phuon worked with UNTAC Electoral Component at the District of Mesang for more than eight months at different capacities. Initially, he was recruited as a Registration Team Leader (RTL) for four months. As he extraordinarily completed his contract as RTL, his contract was extended for two more months as Senior Election Assistant (SEA). Finally, after the completion of his contract as SEA, he was re-employed as a Presiding Officer for UNTAC Election in May 1993 in Combodia.

As a RTL, Mr. Chhim worked out Training Manual in Khemer, Trained the Local Staff about Registration Process and was a Team Leader of Eight other Registration Teams. I was really impressed with Mr. Chhim's training capabilities. Because of his fine training skill, we had no complains from the higher authorities regarding registration, despite complex and long procedures. His profound ability to teach others was also reflected during civic education campaign. He trained all the assistants for civic education regarding Paris Peace Agreement, UNTAC Electoral Law, Human Rights etc. so well that 99.3 % people turned over to express their opinion during the Election. He was the best PO in respect of due completion of all the technicalities during the election.

I am very much impressed of his originality, managerial skill and sincerity at work. In brief, he is a multidimensional personality with whom every one would love to work. I give him my highest regards and wish every success in his future assignments.

Sincerely,

H. Prasad

Hari Prasad, DES
Mesang, Prey Veng
COMBODIA

June 7, '93



# លិខិតថ្លែងអំណរគុណ

ក្រោមការជួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លាពីសំណាក់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្រ្តី-រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ** ឯកសារប្រវត្តិសាស្រ្តមានចំណងជើងថា **របត់នយោបាយ** (**សីហនុ** - **លន់ នល់** - **ប៉ុល ពត** - **ជា ស៊ីម** - **ហេង សំរិន** - **ហ៊ុន សែន**) **ភាគ៤** នេះ ក៏ដូចជា **ភាគ១ ភាគ២** និង**ភាគ៣** ដែរត្រូវបានបោះពុម្ពជាសៀវភៅឡើង ស្រប តាមគតិបណ្ឌិត និងមនសិការប្រវត្តិសាស្រ្តជាតិដ៏ខ្ពង់ខ្ពស់របស់**សម្តេច** ដែលបានចារបញ្ជាក់ថា៖ **សំខាន់ចង់បានសៀវភៅប្រវត្តិសាស្រ្តមួយនេះ ទុកឲ្យកូនចៅរៀនសូត្រ** ។

ខ្ញុំបាទសូមលំអោនកាយគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅនិងសូមប្រសិទ្ធិពរជ័យជូន**សម្តេច ជាទីគោរព** សូមប្រកបដោយពលានុភាពខ្លាំងក្លា បញ្ញាញាណភ្លឺថ្លា សុខភាពល្អបរិបូរណ៍ អាយុយឺនយូរ និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

សូមសម្តេចមេត្តាទទួលនូវគោរពដ៏ខ្ពង់ខ្ពស់បំផុត

ពីខ្ញុំបាទ **ឈឹម សេរីត្នួន**

9 789924 969808 >